# ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា

## ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា

ឯកសារពិភាក្សាលេខ ៣០

**Caroline Hughes** និង គីម សេតារា

ដោយមានជំនួយការពី អាន សុវត្ថា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឯកសារស្រាវជ្រាវនេះ បានទទួលជំនួយហិរញ្ញវត្ថុពី AusAID

ខែមិថុនា ឆ្នាំ២០០៤

**The Evolution of Democratic Process and Conflict Management in Cambodia: A Comparative Study of Three Cambodian Elections — Working Paper 30**

*June 2004*
*Caroline Hughes and Kim Sedara with the assistance of Ann Sovatha*


© រក្សាសិទ្ធិឆ្នាំ២០០៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។



ISSN 1560 9812


**ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា ~ ឯកសារពិភាក្សាលេខ ៣០**

ខែមិថុនា ឆ្នាំ២០០៤

Caroline Hughes និង គឹម សេដារា *ដោយមានជំនួយការពី អាន សុវត្ថា*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*


វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
**អ៊ីមែល:** cdri@camnet.com.kh **website:** http://www.cdri.org.kh

បកប្រែដោយ: យូ សិទ្ធីរិទ្ធ
កែសម្រួល: អ៊ុំ ចាន់ថា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព ជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


បុព្វកថា........................................................................................................ ១

បញ្ជីអក្សរកាត់.................................................................................................៣

សេចក្ដីថ្លែងអំណរគុណ................................................................................... ៥

សេចក្ដីសង្ខេប.................................................................................................៧

**ជំពូកទី ១. គំរូនៃការស្រាវជ្រាវ និងវិធីសាស្ត្រ**...............................................................**១១**

១.១ គោលដៅនៃការសិក្សា...................................................................................... ១៣

១.២ វិធីសាស្ត្រស្រាវជ្រាវ.......................................................................................... ១៤

**ជំពូកទី ២. ឆ្នាំ១៩៩៨ និង ២០០៣ ប្រៀបធៀបគ្នា**................................................................**១៩**

២.១ កំណែទំរង់ច្បាប់ ............................................................................................. ១៩

២.២ កំណែទំរង់ស្ថាប័នៈ កំណែទំរង់ គជប ........................................................................ ២១

២.៣ ការតស៊ូមតិរបស់សង្គមស៊ីវិល ................................................................................ ៣០

២.៤ ការវិវត្តន៍ខាងនយោបាយ....................................................................................... ៣២

២.៥ វិស័យមានការរីកចំរើនតិចៈ ប្រព័ន្ធផ្សព្វផ្សាយ .................................................................. ៣៨

**ជំពូកទី ៣. ការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន ~ ករណីសិក្សាប្រៀបធៀបគ្នា**.............**៣៩**

៣.១ ការជ្រើសរើសករណីសិក្សា........................................................................................៣៩

៣.២ ការបង្ហាញលទ្ធផលរកឃើញក្នុងមួយករណីៗ.......................................................................៤២

៣.៣ ការប្រៀបធៀបឃុំករណីសិក្សា.......................................................................................៧០

៣.៤ សេចក្ដីសន្និដ្ឋាន ................................................................................................... ៧៣

**ជំពូកទី ៤. ការគ្រប់គ្រងទំនាស់នៅកំរិតជាតិ ~ ករណីសិក្សា**.............................................**៧៧**

៤.១ ទំនាស់ស្ដីពីការចុះបញ្ជី.......................................................................................... ៧៧

៤.២ ទំនាស់អំពីប្រធានភូមិ ........................................................................................... ៨៩

៤.៣ ទំនាស់ស្ដីពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ................................ ៩៧

៤.៤ ទំនាស់ស្ដីពីការដោះស្រាយបណ្ដឹងតវ៉ា........................................................................ ១១១

**ជំពូកទី ៥. ការកសាងយន្តការគ្រប់គ្រងទំនាស់ក្នុងយន្តការបោះឆ្នោតនៅកម្ពុជាពីឆ្នាំ១៩៩៨ ដល់ ២០០៣**............**១១៩**

៥.១ ផលប៉ះពាល់នៃដំណើរការផ្លាស់ប្តូរ............១១៩

៥.២ សេចក្តីសន្និដ្ឋាន............១៣០

**ឧបសម្ព័ន្ធ ខេត្តករណីសិក្សា**............**១៣៧**

**បញ្ជីឯកសារពិភាក្សារបស់ ទបសអ**............**១៤១**

# បុព្វកថា

ឯកសារពិភាក្សារបស់ វិបសអ ស្តីពី "ការវិវត្តន៍ដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជាៈ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា" ត្រូវបានបោះពុម្ពផ្សាយក្នុងកាលៈទេសៈមួយដ៏ផុយស្រួយសំរាប់ប្រទេសកម្ពុជា និងស្ថាប័ននយោបាយផ្សេងៗរបស់កម្ពុជា ។ មកដល់ចុងខែមេសា ២០០៤ នេះ ប្រទេសកម្ពុជានៅតែជួបការទាល់ច្រកក្នុងការបង្កើតរដ្ឋាភិបាលថ្មីនៅក្រោយការបោះឆ្នោតក៏រិតជាតិនាខែកក្កដា ២០០៣ ដែលជាការបោះឆ្នោតលើកទីបីនៅក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។

ឯកសារពិភាក្សានេះ បានវិភាគពីការវិវត្តន៍សំខាន់ៗក្នុងសមត្ថភាពបច្ចេកទេស និងលក្ខណៈពេញច្បាប់ខាងនយោបាយរបស់ស្ថាប័ននានាដែលទទួលបន្ទុកគ្រប់គ្រងទំនាស់, ប្រភេទនៃទំនាស់ដែលយន្តការមានស្រាប់នានាអាចគ្រប់គ្រងបានយ៉ាងសក្តិសិទ្ធិ, និងបញ្ហាផ្សេងៗដែលនាំឱ្យមានការរីករាលដាលទំនាស់ និងដែលប្រហែលទាមទារឱ្យមានគោលនយោបាយថ្មី និងការឆ្លើយតបខាងរដ្ឋបាល ។

ឯកសារនេះបានបញ្ចូនសារសំខាន់ៗមួយចំនួន នៅក្នុងបរិស្ថានដ៏ផុយស្រួយនេះ ។ ការសិក្សាបានសន្និដ្ឋានស្របគ្នានឹងមតិរបស់អ្នកតាមដានការបោះឆ្នោតឯករាជ្យនានាដែរថា ការបោះឆ្នោតក៏រិតជាតិឆ្នាំ២០០៣ គឺជាលទ្ធផលពេញលក្ខណៈច្បាប់នៃដំណើរការប្រជាធិបតេយ្យនៅក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ឯកសារបានសន្និដ្ឋានទៀតថា ថ្វីបើមានការទិតៀនដ៏សមរម្យជាច្រើនពីលទ្ធផលការងារ និងពីគោលនយោបាយ និងរបៀបរបបអនុវត្តន៍ដែលអាចកែលំអថែមទៀតបានក្តី ប៉ុន្តែបន្ទាប់ពីការបោះឆ្នោតក៏រិតជាតិឆ្នាំ១៩៩៨ មក ស្ថាប័នកម្ពុជានានាបានរីកចំរើនពេញវ័យ និងបានកែលំអសមត្ថភាពសំរាប់គ្រប់គ្រងទំនាស់នៅក្នុងដំណើរការធ្វើនយោបាយតាមបែបប្រជាធិបតេយ្យ ។

វិបសអ បានបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សានេះ ជាភស្តុតាងនៃការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចសន្ទនាខាងនយោបាយជាសាធារណៈដែលមានពត៌មានគ្រប់គ្រាន់ និងមានការទទួលខុសត្រូវខ្ពស់ និងដែលជាកត្តាគន្លឹះសំរាប់ការរីកចំរើនខាងនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចនៃប្រទេសកម្ពុជាទៅអនាគត ។

*ឡារី ស្ត្រេន្ទ*

*នាយក*

*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

*ភ្នំពេញ, ខែមេសា ២០០៤*

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ADHOC | សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា<br>Cambodia Human Rights and Development Association |
| BLDP | គណបក្សប្រជាធិបតេយ្យ សេរីនិយមព្រះពុទ្ធសាសនា<br>Buddhist Liberal Democracy Party |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា<br>Cambodia Center for Human Rights |
| វបសអ (CDRI) | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>Cambodia Development Resource Institute |
| គឃប (CEC) | គណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត<br>Commune Election Committee |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍<br>Community Legal Education Center |
| COFFEL | សម្ព័ន្ធគាំទ្រការបោះឆ្នោតសេរី និងយុត្តិធម៌<br>Coalition for Free and Fair Elections |
| COHCHR | ការិយាល័យប្រចាំកម្ពុជានៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស<br>Cambodia Office of the High Commissioner for Human Rights |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតសេរី និងយុត្តិធម៌នៅកម្ពុជា<br>The Committee for Free and Fair Elections in Cambodia |
| COPCEL | ក្រុមការងារបង្ការទំនាស់ក្នុងយន្តការបោះឆ្នោតនៅកម្ពុជា<br>Conflict Prevention in the Cambodian Election |
| CPD | មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍<br>Center for Peace and Development |
| CPP | គណបក្សប្រជាជនកម្ពុជា<br>Cambodian People Party |
| CSD | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម<br>Center for Social Development |
| EMO | អង្គការឃ្លាំមើលការបោះឆ្នោត<br>Election Monitoring Organisation |
| EU | សហភាពអឺរ៉ុប<br>European Union |
| FUNCINPEC | រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាអព្យាក្រឹត្យ សន្តិ និងសហប្រតិបត្តិការ<br>Front Uni Nation pour un Cambodge  Neutre, Pacifique et Cooperative |

| | |
|---|---|
| KID | វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ<br>Khmer Institute for Democracy |
| MOI | ក្រសួងមហាផ្ទៃ<br>Ministry of Interior |
| NADK | កងទ័ពជាតិនៃកម្ពុជាប្រជាធិបតេយ្យ<br>National Army of Democratic Kampuchea |
| NDI | វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ<br>National Democratic Institute |
| NGO | អង្គការមិនមែនរដ្ឋាភិបាល<br>Non-Government Organization |
| គជប (NEC) | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត<br>National Election Committee |
| NICFEC | គណៈកម្មាធិការអព្យាក្រិត្យនិងយុត្តិធមិ ដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធមិនៅកម្ពុជា<br>Neutral and Impartial Committee for Free and Fair Elections in Cambodia |
| គខប (PEC) | គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត<br>Provincial Election Committee |
| PRK | សាធារណរដ្ឋប្រជាមានិតុកម្ពុជា<br>People’s Republic of Cambodia |
| PSO | មន្ត្រីការិយាល័យបោះឆ្នោត<br>Polling Station Officer |
| RCAF | កងយោធពលខេមរភូមិន្ទ<br>Royal Cambodian Armed Forces |
| RFA | វិទ្យុអាស៊ីសេរី<br>Radio Free Asia |
| SRP | គណបក្សសម រង្ស៊ី<br>Sam Rainsy Party |
| TVK | ទូរទស្សន៍ជាតិកម្ពុជា<br>National Television of Kampuchea |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ<br>United Nation Development Programme |
| UNTAC | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា<br>United Nation Transitional Authority in Cambodia |
| VOA | វិទ្យុសំលេងសហរដ្ឋអាមេរិក<br>Voice of America |
| WFP | អង្គការចំរើនស្ត្រី<br>Women For Prosperity |

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះមិនអាចធ្វើទៅបានទេ បើសិនគ្មានការឧបត្ថម្ភគាំទ្រយ៉ាងសប្បុរសពីសំណាក់បុគ្គល និងក្រុមជាច្រើន ។ ក្នុងនេះ ទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (Australian Agency for International Development: AusAID) បានផ្តល់យ៉ាងសប្បុរសនូវជំនួយទ្រទ្រង់ជាមូលនិធិដ៏សំខាន់ ។ យើងខ្ញុំ សូមអរគុណជាពិសេសដល់លោកស្រី Sandy Hudd ចំពោះកិច្ចប្រឹងប្រែងជួយសំរបសំរួលការផ្តល់មូលនិធិនេះ ។ ជំនួយទ្រទ្រង់ខាងផ្គត់ផ្គង់មួយទៀត បានផ្តល់ឱ្យដោយវិទ្យាស្ថានមេលប៊ីនសំរាប់ភាសានិងសង្គមអាស៊ី នៃសាកលវិទ្យាល័យមេលប៊ីន (Melbourne Institute of Asian Languages and Societies, University of Melbourne) ដែលបានទទួលលោកស្រី Caroline Hughes ក្នុងដំណើរទស្សនកិច្ចស្រាវជ្រាវនៅទីនោះ ក្នុងដំណាក់កាលសរសេររបាយការណ៍នៃការសិក្សា ។ យើងខ្ញុំសូមអរគុណដល់បុគ្គលិកខាងរដ្ឋបាល និងខាងស្រាវជ្រាវរបស់វិទ្យាស្ថាន ចំពោះការទទួលស្វាគមន៍យ៉ាងរាក់ទាក់កក់ក្តៅ ។

សំខាន់ដូចគ្នាដែរចំពោះជោគជ័យនៃគំរោងនេះ គឺអំណោយដ៏សប្បុរសជាពេលវេលា និងជាយោបល់របស់អ្នកឆ្លើយសំភាសន៍ជាច្រើន និងអង្គការផ្សេងៗដែលបានបើកទ្វារទទួលពួកយើងនៅក្នុងដំណាក់កាលស្រាវជ្រាវ ។ ក្នុងនេះយើងខ្ញុំសូមថ្លែងអំណរគុណដល់: គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងអង្កេតរបស់យើងខ្ញុំ, ការិយាល័យថ្នាក់ជាតិរបស់ COMFREL និង NICFEC, អ្នកចូលរួម និងលេខាធិការដ្ឋាន COPCEL, អ្នកសំរបសំរួលពតិមានបោះឆ្នោតរបស់ UNDP, មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ដែលបានចែករំលែកលទ្ធផលស្រាវជ្រាវដ៏ប្រសើររបស់ខ្លួនស្តីពីដំណើរការប្តឹងតវ៉ា, និងតំណាងជាច្រើនទៀតរបស់អង្គការជាតិ និងអន្តរជាតិ ចំពោះការផ្តល់ពតិមានត្រឡប់នៅក្នុងសិក្ខាសាលាដែលយើងបានយក សេចក្តីព្រាងដំបូងនៃរបាយការណ៍នេះទៅបង្ហាញ ។

ចំពោះខេត្តបានចុះស្រាវជ្រាវទាំងបួនគឺ បាត់ដំបង កំពត កំពង់ចាម និង តាកែវ យើងខ្ញុំសូមអរគុណដល់គណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត, ការិយាល័យគណបក្សខេត្តរបស់ CPP, SRP, និង FUNCINPEC, ការិយាល័យខេត្តរបស់ COMFREL និង NICFEC, ដែលបានចែករំលែកមតិយោបល់អំពីស្ថានភាពក្នុងទូទាំងខេត្ត ។

ចំពោះឃុំករណីសិក្សារបស់យើងគឺ ពាមឯក វត្តតាមឹម តាខែន វាលវង់ និង ត្នោត, យើងខ្ញុំសូមអរគុណដល់គណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលរួមក្នុងការប្រជុំរបស់ខ្លួន, មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ដែលបានឆ្លើយសំភាសន៍ជាច្រើនលើក និងជួយសំរួលទស្សនកិច្ចរបស់យើង, សកម្មជនគណបក្សនយោបាយឃុំដែលបាននិយាយត្រង់ទៅត្រង់មកពីបញ្ហាផ្សេងៗក្នុងការឃោសនា, និងបុគ្គលជាច្រើនទៀត មកពីស្ថាប័នរដ្ឋ គណបក្ស និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់ពេលវេលានិងមតិយោបល់ ព្រមទាំងបានចែករំលែកពីការបារម្ភ និងការខកចិត្តផ្សេងៗរបស់ខ្លួន ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកជួយពិនិត្យរបាយការណ៍នេះឡើងវិញ ចំពោះការយកចិត្តទុកដាក់ផ្ទៀងផ្ទាត់មើលរបាយការណ៍ចុងក្រោយ និងដល់សហសេវិកទាំងអស់នៅ វបសអ ចំពោះមតិយោបល់ ការទិតៀន ពតិមានត្រឡប់ និងការសំរបសំរួលផ្សេងៗទៀតសំរាប់ការស្រាវជ្រាវនេះ ។ យើងខ្ញុំសូមអរគុណជាពិសេសដល់ការប្រឹងប្រែងរបស់បុគ្គលបីនាក់ដែលមានសារៈសំខាន់បំផុតចំពោះគំរោងនេះ ។ យើងខ្ញុំសូមបញ្ជាក់ពីវិភាគទានដ៏សំខាន់របស់លោក អាន សុវត្ថា ដល់ការស្រាវជ្រាវនេះ និងសូមអរគុណចំពោះការចូលរួមដ៏សកម្មរបស់ជំនួយការស្រាវជ្រាវរូបនេះ ក្នុងការធ្វើអង្កេតដ៏មានប្រសិទ្ធភាពលើគណបក្សនយោបាយ ការងារដ៏ស្ទិតស្ទាញជាអ្នកបកប្រែ និងអារម្មណ៍រីករាយជានិច្ចនៅពេលធ្វើដំណើរ ។ យើងខ្ញុំសូមអរគុណផងដែរដល់លោក សេន ស៊ីណា ដែលបានជួយសហការប្រមូលឯកសារ និងលោក ឱក សេរី សោភ័ក្តិ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំប្រើប្រាស់ទំនាក់ទំនងដ៏ធំទូលាយរបស់លោក និងជួយសំរបសំរួលឱ្យយើងខ្ញុំអាចជួបទាក់ទងនឹងមជ្ឈដ្ឋានអ្នកកាន់អំណាច ។

# សេចក្តីសង្ខេប

ការសិក្សានេះពិនិត្យពីការវិវត្តន៍នៃយន្តការគ្រប់គ្រងទំនាស់នានាតាំងពីឆ្នាំ១៩៩៨ និងពីភាពសក្តិសិទ្ធិរបស់វា ក្នុងកិច្ចបង្ការការរីករាលដាលទំនាស់ក្នុងការបោះឆ្នោតជាទូទៅនៅឆ្នាំ២០០៣ ។ ការសិក្សាបានផ្អែកយ៉ាងច្រើន លើការចុះស្រាវជ្រាវដល់កន្លែងដែលក្រុមអ្នកស្រាវជ្រាវនៃ វបសអ បានធ្វើឡើងលើការបោះឆ្នោតឆ្នាំ១៩៩៨ និង ២០០៣ ព្រមទាំងលើបទពិសោធន៍ជាក់ស្តែងដែលបុគ្គលិកមជ្ឈមណ្ឌលដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៃ វបសអ ទទួលបានតាមរយៈ ក្រុមការងារបង្ការទំនាស់ក្នុងយន្តការបោះឆ្នោតនៅកម្ពុជា (ខប់សែល) របស់ខ្លួន ក្នុងកិច្ចដំណើរការកម្មវិធីជួបប្រជុំរយៈពេល ៤ឆ្នាំ រវាងអ្នករៀបចំការបោះឆ្នោត និងតំណាងគណបក្សនយោបាយ និងសង្គមស៊ីវិល ។

ការសិក្សានេះពិនិត្យលំអិតពីការវិវត្តន៍ជាក់លាក់បី ដែលជាប់ទាក់ទិននឹងការគ្រប់គ្រងទំនាស់ និងដែលបានកើតឡើងពីឆ្នាំ១៩៩៨ ដល់ ២០០៣ ពោលគឺកំណែទំរង់ស្ថាប័នរដ្ឋមួយចំនួនដែលជាប់ទាក់ទិននឹងការគ្រប់គ្រងទំនាស់លើការបោះឆ្នោតជាពិសេស គជប និងអាជ្ញាធរកំរិតឃុំ, ការកសាងកម្មវិធីរបស់សង្គមស៊ីវិលសំរាប់គ្រប់គ្រងទំនាស់, និងការផ្លាស់ប្តូរក្នុងនីតិវិធីបោះឆ្នោត មានជាអាទិ៍ ក្របខ័ណ្ឌច្បាប់ជាទូទៅសំរាប់ការបោះឆ្នោត, នីតិវិធីប្តឹងតវ៉ា, និងនីតិវិធីចុះបញ្ជីអ្នកបោះឆ្នោត ។ ការចុះសិក្សាដល់កន្លែងបានធ្វើឡើងក្នុងរយៈពេលបោះឆ្នោតឆ្នាំ២០០៣ ដើម្បីស្រាវជ្រាវមើលពីផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះ ទៅលើលទ្ធភាពគ្រប់គ្រងទំនាស់បោះឆ្នោតនៅកំរិតជាតិ និងកំរិតមូលដ្ឋាន ។ ការសិក្សានេះបានសំគាល់ថា លទ្ធភាពគ្រប់គ្រងទំនាស់ដ៏សក្តិសិទ្ធិ គឺជាសញ្ញាមួយបង្ហាញពីសមត្ថភាពបច្ចេកទេស និងភាពពេញលក្ខណៈច្បាប់នៃស្ថាប័ននានា, និងពីទំនុកចិត្ត និងឆន្ទៈល្អ រវាងតួអង្គខាងនយោបាយនានា ។ ការសិក្សាបានសំគាល់ទៀតថា ការគ្រប់គ្រងទំនាស់យ៉ាងសក្តិសិទ្ធិអាចជួយកែលំអភាពពេញលក្ខណៈច្បាប់ខាងនយោបាយរបស់ស្ថាប័ននានា និងកំរិតនៃទំនុកចិត្តគ្នារវាងតួអង្គខាងនយោបាយនានា ។

ទំនាស់បោះឆ្នោត បានរកឃើញនៅ ៣ កំរិតនៃការស្រាវជ្រាវ ។ នៅមុនពេលបោះឆ្នោត ទំនាស់បោះឆ្នោត បានរកឃើញតាមរយៈការធ្វើសំភាសន៍ជាដំបូងៗជាមួយតំណាងគណបក្សនយោបាយ, តាមរយៈការធ្វើអង្កេតលើសេចក្តីថ្លែងការណ៍នានារបស់តួអង្គខាងនយោបាយ ទាំងជាសាធារណៈ ទាំងក្នុងការប្រជុំ ខប់សែល, និងតាមរយៈការធ្វើអង្កេតលើបញ្ហានានាដែលមានលើកឡើងក្នុងសារពត៌មានក្នុងរយៈពេល ៦ខែមុនធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ។ ក្នុងរយៈពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ទំនាស់បានរកឃើញតាមរយៈការធ្វើសំភាសន៍ជាមួយតួអង្គខាងនយោបាយនៅកំរិតជាតិ និងកំរិតមូលដ្ឋាន ។ ក្រោយថ្ងៃបោះឆ្នោត ទំនាស់បានរកឃើញតាមរយៈ ការធ្វើសំភាសន៍បន្ថែមជាមួយតួអង្គខាងនយោបាយ, ការធ្វើវិភាគលើបណ្តឹងតវ៉ាដែលដាក់ជូន គជប, និងតាមរយៈ ការធ្វើអង្កេតលើហេតុផលដែលគណបក្សចាញ់ឆ្នោតនានាបានលើកបញ្ជាក់ពីការបដិសេធរបស់ខ្លួនចំពោះលទ្ធផលបោះឆ្នោត ។ ការគ្រប់គ្រងទំនាស់បានសិក្សាជាសំខាន់ តាមរយៈការធ្វើសំភាសន៍ជាមួយភាគីនានានៃទំនាស់ និងអ្នកគ្រប់គ្រងទំនាស់, និងតាមរយៈការធ្វើអង្កេតលើឯកសារទាំងអស់ដែលអាចរកបាន ។

សរុបមក ការសិក្សាបានធ្វើសេចក្តីសន្និដ្ឋានជាពីរបែប ។ ទី១ ធ្វើការសន្និដ្ឋានពីផលប៉ះពាល់នៃការវិវត្តន៍សំខាន់ៗដែលបានរកឃើញលើសមត្ថភាពបច្ចេកទេស និងភាពពេញលក្ខណៈច្បាប់ខាងនយោបាយនៃបណ្តាស្ថាប័នទទួលបន្ទុកលើការគ្រប់គ្រង

ទំនាស់ ជាពិសេស គជប គខប គឃប និងអាជ្ញាធរឃុំ ។ ទី២ ធ្វើការសន្និដ្ឋានពីប្រភេទទំនាស់ដែលស្រួលគ្រប់គ្រងជាងគេ សំរាប់ស្ថាប័នដែលមានស្រាប់នៅកម្ពុជា ព្រមទាំងស្វែងរកមើលពីសមាសធាតុមានចោទបញ្ហាផ្សេងៗ ដែលអាចនាំឱ្យមានការរីករាលដាលទំនាស់ ។

*ស្ថាប័នសំរាប់ការគ្រប់គ្រងទំនាស់*

ការសិក្សាបានរកឃើញថា កំណែទំរង់មានជោគជ័យសំរាប់ គជប នៅកំរិតជាតិ គឺដោយសាររបៀបរបបធ្វើការងារបានទទួលការយល់ព្រមកាន់តែច្រើនពីតួអង្គខាងនយោបាយនៃគណបក្សផ្សេងៗនៅឆ្នាំ២០០៣ បើធៀបនឹងឆ្នាំ១៩៩៨ ។ ដោយឡែកសមត្ថភាពបច្ចេកទេស និងតំលាភាពនៃរបៀបរបបធ្វើការងាររបស់ គជប បានទទួលការលើកសរសើរ ។ រឿងនេះកើតមានមួយចំណែកដោយសារការផ្លាស់ប្តូរសមាសភាព គជប និងការផ្លាស់ប្តូរក្នុងច្បាប់បោះឆ្នោតដែលបានកំណត់យ៉ាងលំអិតនូវរបៀបរបបដំណើរការនៃ គជប និងមួយចំណែកទៀតដោយសារការប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការអូសទាញ គជប ឱ្យចូលរួមក្នុងកិច្ចសន្ទនាមានលក្ខណៈកសាង ជាមួយតួអង្គខាងនយោបាយផ្សេងៗទៀត ព្រមទាំងចំលើយតបជាវិជ្ជមានរបស់ គជប ចំពោះគំនិតផ្តួចផ្តើមទាំងនេះ ។

មធ្យោបាយសំរាប់ធ្វើការតែងតាំង គជប និងសាខាកំរិតខេត្ត និងឃុំ របស់ គជប នៅតែទទួលការរិះគន់យ៉ាងខ្លាំងដែលនាំទៅដល់ការចោទប្រកាន់ពីភាពលំអៀងខាងនយោបាយ ។ ការចោទប្រកាន់ទាំងនេះពុកាន់តែខ្លាំង ជាពិសេសក្នុងរយៈពេលមិនសូវរៀបរយនៃការដោះស្រាយបណ្តឹងតវ៉ានៅក្រោយថ្ងៃបោះឆ្នោត ហើយអព្យាក្រឹតភាពរបស់ គជប នៅឆ្នាំ២០០៣ក៏ដូចជានៅឆ្នាំ១៩៩៨ ដែរ ត្រូវបានលើកជាបញ្ហាចោទដែលនាំឱ្យមានការបដិសេធលទ្ធផលបោះឆ្នោត ទោះបីមានការវាយតំលៃវិជ្ជមាន ជាងពីលទ្ធផលការងាររបស់ គជប នៅមុនពេលបោះឆ្នោតក្តី ។ ដូចនៅឆ្នាំ១៩៩៨ ដែរ ដំណើរការដោះស្រាយបណ្តឹងតវ៉ាបានក្លាយជាចំណុចមានចោទបញ្ហាខ្លាំងជាងគេនៅក្នុងការងាររបស់ គជប ។ នៅឆ្នាំ២០០៣ បញ្ហាដែលនៅមានចោទជាបន្តក្នុងចំណាត់ការលើបណ្តឹងតវ៉ា បានធ្វើឱ្យខូចខាតដល់ទំនុកចិត្តដ៏ផុយស្រួយដែលកសាងបានហើយរវាង គជប និងតួអង្គខាងនយោបាយផ្សេងៗទៀតក្នុងដំណាក់កាលមុនៗនៃដំណើរការបោះឆ្នោត ។ ការផ្លាស់ប្តូរក្នុងដំណើរការដោះស្រាយបណ្តឹងតវ៉ានៅឆ្នាំ២០០៣ មិនបានជួយសំរាលបញ្ហាចោទជាដុំកំភួនអ្វីទេ ។

ទំនាស់ជាប់ទាក់ទិននឹង គជប ផ្សេងៗទៀត ផុសចេញពីកង្វះភាពលួនគ្នារវាងអំណាចតាមផ្លូវច្បាប់នៃ គជប ជាពិសេសក្នុងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋផ្សេងទៀត ហើយនិងចំណាប់អារម្មណ៍ពីដែនសមត្ថកិច្ចរបស់ គជប ។ ឧទាហរណ៍ ក្នុងការប្រឹងប្រែងពង្រឹងការអនុវត្តន៍ក្រមសីលធម៌ សំរាប់មន្ត្រីរាជការកំរិតមូលដ្ឋាន និងសំរាប់ប្រព័ន្ធផ្សព្វផ្សាយ, គជប មើលឃើញថាខ្លួនគ្មានមធ្យោបាយដាក់ពិន័យចំពោះការមិនប្រតិបត្តិតាមនោះទេ ហើយតួអង្គខាងនយោបាយផ្សេងៗ ក៏ទិតៀន គជប ថា ទន់ខ្សោយ គ្មានចង្កូម និងក្នុងករណីខ្លះ ថាលំអៀងខាងនយោបាយផង ។

កំណែទំរង់អាជ្ញាធរកំរិតឃុំ មានផលប៉ះពាល់គួរកត់សំគាល់ទៅលើលទ្ធភាពរបស់គណបក្សនយោបាយក្នុងការឃោសនាបោះឆ្នោតនៅកំរិតមូលដ្ឋាន ។ ក្រុមប្រឹក្សាឃុំដែលមានសមាសភាពមកពីច្រើនគណបក្ស បានផ្តល់ភាពពេញលក្ខណៈច្បាប់ដល់វត្តមានសកម្មជននានាដែលទ្រទ្រង់គណបក្សទាំងនេះ ព្រមទាំងផ្តល់ឱ្យពួកគេមានឱកាសពង្រីកបណ្តាញរបស់ខ្លួន និងមានបទពិសោធន៍ធ្វើការងារជាមួយគ្នា ។ រឿងនេះបានលុបបំបាត់ចោលនូវប្រភពទំនាស់ដ៏ធ្ងន់ធ្ងរមួយដែលបានពិនិត្យឃើញក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ។

ប៉ុន្តែ យោងតាមរយៈពេលដ៏ខ្លីក្រោយការបោះឆ្នោតឃុំ, សមាជិកក្រុមប្រឹក្សាឃុំជាច្រើននៅខ្វះបទពិសោធន៍ ហើយដំណើរយឺតយ៉ាវនៃការផ្ទេរធនធានទៅឱ្យក្រុមប្រឹក្សាឃុំ ធ្វើឱ្យស្ថាប័ននេះមានលទ្ធភាពតិចតួចណាស់ក្នុងការកសាងយន្តការរបស់ខ្លួនសំរាប់គ្រប់គ្រងទំនាស់ ។ ក្នុងឃុំមួយចំនួនសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្ស សម រង្ស៊ី (SRP) និងហ្វ៊ុនស៊ិនប៉ិច

(FUNCINPEC) បានរាយការណ៍ថា ខ្លួនត្រូវសហសេវិកមកពីគណបក្សប្រជាជនកម្ពុជា (CPP) ច្រានចេញពីតួនាទីមានឥទ្ធិពល ហើយក្នុងឃុំខ្លះប្រធានភូមិហាក់ដូចបានរាយការណ៍ឡើងផ្ទាល់ទៅថ្នាក់ស្រុក ឬគណបក្សរបស់ខ្លួន ដោយរំលងចោលក្រុមប្រឹក្សាឃុំដែលកាន់តែត្រូវចុះខ្សោយក្នុងតួនាទីជាអ្នកគ្រប់គ្រងទំនាស់ ។

លក្ខណៈទន់ខ្សោយខាងស្ថាប័នរបស់ក្រុមប្រឹក្សាឃុំ និងគណបក្សនយោបាយ គឺជាប្រភពនៃការអនុវត្តន៍មិនបានល្អនូវនីតិវិធីថ្មីៗសំរាប់ការចុះបញ្ជីអ្នកបោះឆ្នោត ។ គណបក្សជំទាស់បានចោទថា ការផ្តល់ពត៌មានដោយមិនស្មើភាព បានផ្តល់ផលចំណេញដល់អ្នកគាំទ្រ CPP ក្នុងការចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត ហើយរឿងនេះបានបង្កើនទំនាស់រវាងគណបក្ស ។ រដ្ឋមិនទាន់មានលទ្ធភាពផ្តល់ឱកាសឱ្យបានស្មើគ្នា និងមិនប្រកាន់បក្សពួក ដល់អ្នកបោះឆ្នោតទាំងអស់គ្នានោះទេ (ហើយជាក់ស្តែងលទ្ធភាពនេះវាធ្វើឱ្យខូចខាតដល់ឧត្តមភាពខាងអង្គការចាត់តាំងរបស់ CPP) ។ សមាជិកក្រុមប្រឹក្សាឃុំដែលមានបទពិសោធន៍តិច ជាពិសេសអ្នកមកពីគណបក្សថ្មីៗ ត្រូវការជំនួយទ្រទ្រង់ដើម្បីក្លាយជាអ្នកដឹកនាំក្នុងស្រុក ហើយជួយផ្តល់ពត៌មាន និងធ្វើការកៀងគរអ្នកភូមិ ទោះបីធនធាននៅខ្វះខាតក្តី ។ អង្គការផ្សេងៗទៀត ក៏គួរទទួលការលើកទឹកចិត្តឱ្យចូលរួមក្នុងការងារនេះដែរ ។ ក្នុងនេះ គជប ត្រូវដោះស្រាយបញ្ហាប្រកាន់បក្សពួកក្នុងការផ្តល់ពត៌មានទៅឱ្យអ្នកភូមិ ដោយធ្វើសកម្មភាពតាមរយៈកម្មវិធីរបស់ខ្លួនផ្ទាល់ ។

ក្នុងរយៈពេលឃោសនាបោះឆ្នោត មានបណ្តឹងតវ៉ាពីសកម្មភាពរបស់អាជ្ញាធរឃុំ តិចជាងកាលពីឆ្នាំ១៩៩៨ ដូច្នេះទោះបីមានការខ្វះខាតខាងបច្ចេកទេសខ្លះក្តី ក៏អាជ្ញាធរឃុំកាន់តែមានភាពពេញលក្ខណៈច្បាប់ឡើងហើយនៅឆ្នាំ២០០៣ ។ ប៉ុន្តែមានបណ្តឹងតវ៉ាច្រើននៅឡើយអំពីទង្វើរបស់អាជ្ញាធរមូលដ្ឋាន ជាពិសេសពួកប្រធានភូមិ ។ ការប្រឹងប្រែងរបស់ គជប ដើម្បីត្រួតពិនិត្យពួកប្រធានភូមិ បានទទួលជោគជ័យតិចតួចណាស់ សំខាន់គឺដោយសារតួនាទី គជប ក្នុងរឿងនេះគ្មានចែងច្បាស់នៅក្នុងច្បាប់បោះឆ្នោត ។

### *អាំងឌីកាទ័រនៃលទ្ធភាពមានជោគជ័យក្នុងការគ្រប់គ្រងទំនាស់*

ដើម្បីពិនិត្យលើជោគជ័យ និងបរាជ័យនៃស្ថាប័នខាងលើក្នុងការគ្រប់គ្រងទំនាស់ជាក់លាក់មួយចំនួននាពេលបោះឆ្នោតឆ្នាំ២០០៣ ក្រុមអ្នកស្រាវជ្រាវបានសិក្សាលើករណីដូចតទៅៈ ទំនាស់លើការចុះបញ្ជី ទំនាស់ស្តីពីប្រធានភូមិ ទំនាស់ពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងទំនាស់អំពីដំណើរការប្តឹងតវ៉ា ។ ការវិភាគលើករណីសិក្សាទាំងនេះ បានបំផុសនូវលក្ខណៈវិនិច្ឆ័យដូចតទៅ សំរាប់បង្ហាញពីលទ្ធភាពមានជោគជ័យនៃវិធានការគ្រប់គ្រងទំនាស់នានាដែលមានសព្វថ្ងៃក្នុងការបោះឆ្នោតនៅកម្ពុជាៈ

ការគ្រប់គ្រងទំនាស់មានជោគជ័យក្នុងករណីៈ

- មានការឯកភាពគ្នាពីចរិតនៃទំនាស់
- មានការឯកភាពគ្នាពីយន្តការសមស្របសំរាប់គ្រប់គ្រងទំនាស់
- អ្នកគ្រប់គ្រងទំនាស់មានសិទ្ធិអំណាចគ្រប់គ្រាន់ដើម្បីដាក់អនុវត្តដំណើរការគ្រប់គ្រងទំនាស់ ទោះបីត្រូវដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តខុសដែលមកពីស្ថាប័នផ្សេងទៀតក្តី
- មានការឯកភាពគ្នាពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងជោគជ័យ
- យន្តការសំរាប់គ្រប់គ្រងទំនាស់ បានដាក់អនុវត្តយ៉ាងជាក់ស្តែង មានតំលាភាព និងអាចទាក់ទងប្រើប្រាស់បាន

ការគ្រប់គ្រងទំនាស់បរាជ័យក្នុងករណីៈ

- គ្មានការឯកភាពគ្នាពីចរិតនៃទំនាស់
- គ្មានការឯកភាពគ្នាពីយន្តការសំរាប់គ្រប់គ្រងទំនាស់

- អ្នកគ្រប់គ្រងទំនាស់មិនច្បាស់លាស់ពីសិទ្ធិអំណាចរបស់ខ្លួនដើម្បីដាក់អនុវត្តដំណើរការគ្រប់គ្រងទំនាស់ បើសិនអាចមានការទទឹងរឹងរូសពីសំណាក់ស្ថាប័នផ្សេងៗទៀត
- គ្មានការឯកភាពគ្នាពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងជោគជ័យ
- យន្តការសំរាប់គ្រប់គ្រងទំនាស់ ដាក់អនុវត្តមិនបានល្អ គ្មានតំលាភាព និងមិនអាចទាក់ទងប្រើប្រាស់បាន ។

ការសន្និដ្ឋានទាំងនេះផ្តល់គំនិតថា យន្តការគ្រប់គ្រងទំនាស់នៅកម្ពុជា បន្តមានបញ្ហាចោទមួយចំនួនៈ

- ចំណាប់អារម្មណ៍មិនស៊ីគ្នាជាមូលដ្ឋានដែលបន្តកើតមាន រវាងតំណាងនៃគណបក្សនយោបាយផ្សេងៗ ស្តីពីការពិតជាក់ស្តែងនានា នៅក្នុងមជ្ឈដ្ឋាននយោបាយបច្ចុប្បន្ននៅកម្ពុជា
- កង្វះវេទិកាសំរាប់កិច្ចសន្ទនាត្រង់ទៅត្រង់មក អំពីចំណាប់អារម្មណ៍ទំនាស់គ្នាទាំងនេះ
- កង្វះគំនិតច្នៃប្រឌិតថ្មីសំរាប់ការគ្រប់គ្រងទំនាស់
- ការមិនទុកចិត្តគ្នារវាងគណបក្សនានា មានច្រើនគ្រប់គ្រាន់អាចរាំងខ្ទប់កិច្ចសន្ទនាត្រង់ទៅត្រង់មក និងការដកបទពិសោធន៍លើការគ្រប់គ្រងទំនាស់
- កង្វះឆន្ទៈពីសំណាក់តួអង្គខាងនយោបាយ ក្នុងការផ្ទេរអំណាចសមស្របដល់ស្ថាប័នអព្យាក្រឹត្យនានាដើម្បីគ្រប់គ្រងទំនាស់
- កង្វះសមត្ថភាពបច្ចេកទេសនៃបណ្តាស្ថាប័ន និងអ្នកគ្រប់គ្រងទំនាស់
- កង្វះវប្បធម៌មានតំលាភាព និងភាពអាចទាក់ទងគ្នាបាននៃស្ថាប័នរដ្ឋនានា ។

# ជំពូកទី ១

# គំរូការស្រាវជ្រាវ និងវិធីសាស្ត្រ

គំរូវិការធ្វើការសិក្សានេះផុសចេញពីការងារកន្លងមករបស់ វិបសអ ដែលផ្តោតលើមូលហេតុនៃការរីករាលដាលទំនាស់នយោបាយក្នុងការបោះឆ្នោតនៅកម្ពុជា ។ ការងាររបស់ វិបសអ នាពេលកន្លងមកក្នុងបញ្ហាទាំងនេះ អាចបែងចែកចេញជាពីរប្រភេទ ។ ទី១ ការស្រាវជ្រាវស្តីពីចរិត និងមូលហេតុនៃការរីករាលដាលទំនាស់ក្នុងការបោះឆ្នោតឆ្នាំ១៩៩៨[១] ។ ទី២ គណៈកម្មាធិការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល) នៃ វិបសអ បានរៀបចំការប្រជុំប្រចាំខែមួយខែៗមានរយៈពេល ៤ឆ្នាំ ដែលក្នុងនេះមានអញ្ជើញតួអង្គខាងនយោបាយសំខាន់ៗ មកលើកពីចំណុចព្រួយបារម្ភ និងពិភាក្សាពីប្រភពទំនាស់ជាយថាហេតុ ក្នុងការបោះឆ្នោតក៏រិតឃុំ និងក៏រិតជាតិ ។ តាមរយៈសកម្មភាពទាំងនេះ វិបសអ អាចកសាងបាននូវប្រភពជំនាញ និងសំភារៈយ៉ាងសំបូរដែលជាប់ទាក់ទិននឹងដំណើរការគ្រប់គ្រងទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។

ការស្រាវជ្រាវពីមុននៃ វិបសអ ស្តីពី ចរិតនិងមូលហេតុនៃការរីករាលដាលទំនាស់ក្នុងការបោះឆ្នោតក៏រិតជាតិឆ្នាំ១៩៩៨ បានរកឃើញឧបសគ្គមួយចំនួនដែលរារាំងលទ្ធភាពរបស់ស្ថាប័នកម្ពុជានានា ដើម្បីទប់ស្កាត់ការរីករាលដាលទំនាស់ក្នុងរយៈពេលបោះឆ្នោត និងដែលអាចបែងចែកជា ២ប្រភេទធំៗគឺ បញ្ហាខាងរចនាសម្ព័ន្ធស្ថាប័នរដ្ឋ និងភាពទន់ខ្សោយរបស់សហគមន៍នយោបាយ ។ ទំនាស់នានាបានផុសឡើងដោយចៀសមិនរួចអំពីពីធីតិវិធីដ៏ស្មុគស្មាញ ពោរពេញទៅដោយការចោទប្រកាន់បែបនេះ និងបានរីករាលដាលឡើងគឺមិនមែនត្រូវបានដោះស្រាយយ៉ាងសមស្របនិងសក្តិសិទ្ធិនោះទេ ពីព្រោះស្ថាប័ននានាខ្វះខាត *សមត្ថភាព* និង *ភាពពេញលក្ខណៈច្បាប់* ដើម្បីបំពេញមុខងាររបស់ខ្លួន, ហើយទំនាស់ទាំងនេះ ក៏មិនអាចដោះស្រាយបានតាមរយៈឆន្ទៈល្អទៅវិញទៅមកនោះដែរ ។

ការសិក្សាបានកំណត់សមត្ថភាពនៃស្ថាប័នរដ្ឋនានាក្នុងការបំពេញមុខងាររបស់ខ្លួនថា ជារបាយនៃសមត្ថភាពខាងបច្ចេកទេស និងនយោបាយ ។ សមត្ថភាពបច្ចេកទេស រួមមានទាំងធនធានសំភារៈ និងធនធានមនុស្សដ៏ចាំបាច់ សំរាប់ប្រើវាឱ្យមានប្រសិទ្ធភាព ។ សមត្ថភាពនយោបាយរួមមានក្របខណ្ឌច្បាប់ដ៏សមស្រប និងអាណត្តិខាងនយោបាយ, សិទ្ធិអំណាចបំពេញការងារទាំងនេះនៅពេលអនុវត្តជាក់ស្តែង និងជាពិសេសសមត្ថភាពដើម្បីជំនះរាល់ឧបសគ្គមិនពេញលក្ខណៈច្បាប់ ឬការរាំងស្ទះផ្សេងៗ ដែលបង្កឡើងដោយតួអង្គខាងនយោបាយផ្សេងៗទៀត ។ ការសិក្សាបានពិភាក្សាថែមទៀតពីសារៈសំខាន់នៃភាពពេញលក្ខណៈច្បាប់របស់ស្ថាប័ននានា ក្នុងបរិបទនៃការមិនទុកចិត្តគ្នាយ៉ាងខ្លាំងរវាងគណបក្សនយោបាយប្រជែងគ្នា និងការព្រួយបារម្ភតឈប់ឈរពីជំហរមិនប្រកាន់បក្សពួកនៃស្ថាប័នរដ្ឋសំខាន់ៗ ។ ការសិក្សាបានសន្និដ្ឋានថា ក្នុងបរិបទនៃការមិនទុកចិត្តគ្នាយ៉ាងខ្លាំងរវាងតួអង្គនានានៅក្នុងសហគមន៍នយោបាយ ទិដ្ឋភាពទាំងពីរនៃស្ថាប័ននានា វាជំពាក់ជំពិនគ្នា ។ សមត្ថភាពបច្ចេកទេសនៃស្ថាប័នរដ្ឋនានា ត្រូវបានពង្រឹងដោយជំហរធ្វើសហប្រតិបត្តិការគ្នាពីសំណាក់តួអង្គផ្សេងៗទៀត រីឯភាពពេញលក្ខណៈច្បាប់ខាងនយោបាយត្រូវបានពង្រឹងដោយសកម្មភាពខាងរដ្ឋបាលដែលមានប្រសិទ្ធភាព/តម្លាភាព និងធ្វើឱ្យខូចខាត ដោយអប្រសិទ្ធភាព និងការមិនឆ្លើយតបរបស់ស្ថាប័នរដ្ឋនានា ។

---

[១] Caroline Hughes and Real Sopheap, The Nature and Causes of Conflict Escalation in the 1998 National Election, (Phnom Penh: CDRI, 2000)

ទំនាក់ទំនងរវាងភាពទន់ខ្សោយខាងស្ថាប័ន និងអារម្មណ៍ផ្សារភ្ជាប់នឹងសហគមន៍នយោបាយរបស់តួអង្គខាងនយោបាយនានា មានលក្ខណៈស្មុគស្មាញ ។ កត្តាទាំងពីរអាចជួយពង្រឹងគ្នាទៅវិញទៅមក ឬក៏អាចគួបផ្សំគ្នា បង្កើតជាអន្ទាក់វិលវង់គ្មានច្រកចេញ ។ សកម្មភាពដ៏មានប្រសិទ្ធភាពរបស់ស្ថាប័នមានសិទ្ធិអំណាចនានា អាចផ្តល់ដំណោះស្រាយមានយុត្តិធម៌ និងលើកកំពស់ចំណងផ្សារភ្ជាប់ និងភក្តីភាពចំពោះសហគមន៍នយោបាយ ។ ក្នុងពេលជាមួយគ្នា អារម្មណ៍ទុកចិត្ត និងធ្វើសហប្រតិបត្តិការគ្នាយ៉ាងរឹងប៉ឹងក្នុងចំណោមសមាជិកនៃសហគមន៍នយោបាយ បានសំរួលដល់ការផុសឡើងនូវស្ថាប័នដ៏មានសិទ្ធិអំណាចនានាដែលអាចធ្វើសកម្មភាពដោយមានប្រសិទ្ធភាពខ្ពស់ (ក្រាហ្វិក១) ។ ផ្ទុយទៅវិញ ទំនុកចិត្តខ្សោយ និងសហប្រតិបត្តិការខ្សោយ តែងធ្វើឱ្យខូចខាតដល់លទ្ធភាពបំពេញការងាររបស់ស្ថាប័ននានា ហើយស្ថាប័នខ្សោយៗដែលធ្វើការងារតាមបែបបទមិនរលូនល្អ និងគ្មានប្រសិទ្ធភាព តែងតែបង្កើនការមិនទុកចិត្តគ្នារវាងតួអង្គខាងនយោបាយ និងកាត់បន្ថយក៏រិតនៃកិច្ចសហប្រតិបត្តិការខាងនយោបាយ (ក្រាហ្វិក២) ។ ក្នុងករណីសិក្សានានាអំពីទំនាស់ដែលផុសឡើងក្នុងឆ្នាំ២០០៣ មានការប្រើប្រាស់គំរូនេះសំរាប់ធ្វើវិភាគ ដោយបានយកចិត្តទុកដាក់ជាពិសេសបញ្ហាដែលការគ្រប់គ្រងទំនាស់មិនបានសមស្របរបស់ស្ថាប័ននានា បាននាំឱ្យមានការរីករាលដាលទំនាស់ដូចមានបង្ហាញក្នុងក្រាហ្វិក៣ ។

**ក្រាហ្វិក១. ស្ថាប័ននានា និងសហគមន៍នយោបាយៈ បែបបទល្អនៃការគ្រប់គ្រងដ៏សក្តិសិទ្ធិ**




**ក្រាហ្វិក២. ស្ថាប័ននានា និងសហគមន៍នយោបាយៈ អន្ទាក់វិលវង់នៃការគ្រប់គ្រងមិនសក្តិសិទ្ធិ**



ការសិក្សាឆ្នាំ១៩៩៨ បានរកឃើញបញ្ហាមួយចំនួននៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ ដោយឡែកការសិក្សារកឃើញថា ការប្រស្រ័យទាក់ទងអន់ខ្សោយរវាងតួអង្គផ្សេងៗនៅកំរិតមូលដ្ឋាន ជារឿយៗ បានធ្វើឱ្យទំនាស់ត្រូវបញ្ជូនឡើងទៅដល់ថ្នាក់មជ្ឈិមដើម្បីដោះស្រាយ ។ រឿងនេះបង្កើនការតានតឹងរវាងតួអង្គថ្នាក់ជាតិនានា និងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរលើស្ថាប័នថ្នាក់ជាតិនានាដែលខិតខំស្រាវជ្រាវ គ្រប់គ្រង និងដោះស្រាយទំនាស់ខ្នាតតូចរាប់ពាន់នៅទូទាំងប្រទេស ។

នៅពេលកំណត់របៀបវារៈសំរាប់ការសិក្សានេះ ការពិនិត្យឡើងវិញនូវវិវត្តន៍ខាងនយោបាយសំខាន់ៗតាំងពីឆ្នាំ១៩៩៨មក បានបង្ហាញពីការផ្លាស់ប្តូរមួយចំនួនដែលអាចមានផលប៉ះពាល់គួរកត់សំគាល់ទៅលើការរីករាលដាលទំនាស់ និងរបៀបរបបដោះស្រាយទំនាស់នៅកំរិតជាតិ និងកំរិតមូលដ្ឋាន ។ ការវិវត្តន៍សំខាន់ៗដែលបានពិនិត្យឃើញមានដូចតទៅ:

- យុទ្ធនាការតស៊ូមតិធ្វើដោយតួអង្គនានានៃសង្គមស៊ីវិល ទាក់ទិននឹងក្របខ័ណ្ឌខាងច្បាប់ និងខាងស្ថាប័ន សំរាប់ការបោះឆ្នោតនៅកម្ពុជា
- រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកម្មវិធីកែទំរង់ស្ថាប័នមួយនៅកំរិតជាតិ ដែលមានជាសំខាន់គឺ កំណែទំរង់ គជប ដែលជាស្ថាប័នជាតិទទួលបន្ទុករៀបចំការបោះឆ្នោត
- កម្មវិធីកំណែទំរង់ស្ថាប័នមួយដែលសំដៅធ្វើវិមជ្ឈការ និងវិសហមជ្ឈការអំណាចពីថ្នាក់មជ្ឈិម ទៅថ្នាក់ មូលដ្ឋាន ដោយចាប់ផ្តើមពីការបោះឆ្នោតក្រុមប្រឹក្សាឃុំនៅខែកុម្ភៈ ២០០២ និង
- ការផ្លាស់ប្តូរក្នុងប្រព័ន្ធចុះបញ្ជីអ្នកបោះឆ្នោត តាមការអនុវត្តន៍ប្រព័ន្ធចុះបញ្ជីជាអចិន្ត្រៃយ៍ដោយ អាជ្ញាធរឃុំ

ការវិវត្តន៍ទាំងនេះមានពិភាក្សាលំអិតក្នុងជំពូក២ ។

## ១.១ គោលដៅនៃការសិក្សា

យោងតាមមូលហេតុដូចខាងលើ ការសិក្សានេះមានគោលដៅ ៤ :

- ប្រៀបធៀបការគ្រប់គ្រងទំនាស់ក្នុងការបោះឆ្នោតឆ្នាំ២០០៣ ជាមួយនឹងការគ្រប់គ្រងទំនាស់ក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ដើម្បីផ្តល់អនុសាសន៍សំដៅពង្រឹងបណ្តាយន្តការគ្រប់គ្រងទំនាស់ថែមទៀត
- ផ្តោតការយកចិត្តទុកដាក់ឱ្យបានច្រើនជាងការសិក្សាលើកមុនៗ ស្តីពីការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន ដោយយោងតាមលទ្ធផលរកឃើញក្នុងឆ្នាំ១៩៩៨ ដែលបង្ហាញថា ការរីករាលដាលទំនាស់ពីកំរិតមូលដ្ឋាន ទៅដល់កំរិតជាតិ គឺជាប្រភពគួរកត់សំគាល់មួយនៃអស្ថិរភាពនៅក្នុងពេល និងនៅក្រោយពេលបោះឆ្នោត
- ផ្តោតជាពិសេសលើការផ្លាស់ប្តូរនានាដែលបានកើតមានឡើងតាំងពីឆ្នាំ១៩៩៨ ដូចជា ការតស៊ូមតិរបស់សង្គមស៊ីវិល គោលនយោបាយវិមជ្ឈការ ការផ្លាស់ប្តូរក្នុងនីតិវិធីចុះបញ្ជីអ្នកបោះឆ្នោត និងកំណែទំរង់ គជប. ដើម្បីវាយតំលៃពីផលប៉ះពាល់របស់វា ទៅលើកត្តាសំខាន់ៗពីរ សំរាប់គ្រប់គ្រងទំនាស់ឱ្យបានសក្តិសិទ្ធិ ដូចបានពិនិត្យឃើញក្នុងឆ្នាំ១៩៩៨ ពោលគឺអារម្មណ៍ផ្សារភ្ជាប់រឹងប៉ឹងជាមួយសហគមន៍នយោបាយ ហើយនិងស្ថាប័នដ៏សក្តិសិទ្ធិ និងពេញលក្ខណៈច្បាប់សំរាប់គ្រងគ្រងទំនាស់ និង
- ពិនិត្យផងដែរនូវចំណុចនានាដែលមានការផ្លាស់ប្តូរតិចតួច ជាពិសេសក្នុងរចនាសម្ព័ន្ធនៃលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងធ្វើវិភាគពីផលប៉ះពាល់នៃកម្មវិធីសំរាប់ជួយកែលំអនានា ដែលបណ្តាទីភ្នាក់ងារអន្តរជាតិបានឧបត្ថម្ភគាំទ្រដើម្បីដោះស្រាយបញ្ហានេះ ។

## ១.២ វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់ទីកន្លែងបានធ្វើឡើងតាំងពីពេលចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនៅថ្ងៃទី២៦ មិថុនា រហូត ដល់សេចក្តីសំរេចចុងក្រោយរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី២៧ សីហា ២០០៣ ។ ការស្រាវជ្រាវបានធ្វើឡើងនៅ ២កំរិត គឺ កំរិតជាតិ និងកំរិតមូលដ្ឋាន ។

### *១.២.១ ការស្រាវជ្រាវនៅកំរិតជាតិ*

នៅកំរិតជាតិ របៀបវារៈស្រាវជ្រាវបានរៀបចំឡើងដើម្បីពិនិត្យទិដ្ឋភាព ៣ នៃការគ្រប់គ្រងទំនាស់ក្នុងការបោះឆ្នោត នៅកម្ពុជា ។ ទី១ ការស្រាវជ្រាវមានគោលដៅស្វែងរកប្រភពទំនាស់នានាដែលបានផុសឡើងនៅក្នុងដំណើរការបោះឆ្នោតដែល កំពុងប្រព្រឹត្តទៅ ។ ទី២ ការស្រាវជ្រាវមានគោលដៅប្រៀបធៀបទំនាស់ទាំងនេះ ទៅនឹងទំនាស់ដែលផុសឡើងក្នុងឆ្នាំ១៩៩៨ ដើម្បីវាយតំលៃពីការផ្លាស់ប្តូរខាងនយោបាយនានានៅក្នុងចន្លោះពេលនោះ ។ ចំណុចយកចិត្តទុកដាក់ដោយឡែកមួយគឺ ដំណើរ ការផ្លាស់ប្តូរនានាដែលជាប់ទាក់ទិននឹងគោលនយោបាយវិមជ្ឈការ, កាជួយមតិនៅក្នុងសង្គមស៊ីវិល និងកំណែទំរង់ស្ថាប័ន ។ ទី៣ ការស្រាវជ្រាវមានគោលដៅវាយតំលៃពីការរីករាលដាលទំនាស់ និងការគ្រប់គ្រងទំនាស់ ដោយពិនិត្យទៅតាមការផ្លាស់ប្តូរទាំង នេះ ។ ការងារនេះបានធ្វើឡើងដោយប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ជាពិសេស បទសំភាសន៍ជាមួយតួអង្គខាង នយោបាយសំខាន់ៗ, ការសិក្សាពីឯកសារ និងសេចក្តីថ្លែងការណ៍ផ្សេងៗដែលពួកគេបានធ្វើឡើង និងការសង្កេតពិនិត្យពីព្រឹត្តិ ការណ៍នានា នៅពេលដែលវាលាតត្រដាងឡើង ។ ខុសប្លែកពីការសិក្សាឆ្នាំ២០០០ ដែលក្នុងនេះទិន្នន័យបានប្រមូលនៅដើម ឆ្នាំ១៩៩៩ គឺពី ៦ ទៅ ១០ខែក្រោយពេលបោះឆ្នោត, ការសិក្សានេះបានធ្វើឡើងក្នុងពេលដែលការបោះឆ្នោតកំពុងប្រព្រឹត្តទៅ គឺ នៅខែកក្កដា និងសីហា ២០០៣ ។ ដោយមូលហេតុនេះការងារធ្វើអង្កេតត្រូវបានកាត់បន្ថយឱ្យនៅតិចបំផុត ពីព្រោះព្រឹត្តិការណ៍ ដែលកំពុងលាតត្រដាងចេញ វាធ្វើឱ្យចំលើយនានាដែលបានផ្តល់នៅដើមខែកក្កដា អាចខុសគ្នាយ៉ាងខ្លាំង អំពីចំលើយផ្តល់ឱ្យនៅ ចុងខែសីហា ដូច្នេះហើយចំលើយតបនានាចំពោះការធ្វើអង្កេត គឺមិនអាចប្រៀបធៀបគ្នាបានទេ ។ ដោយមូលហេតុនេះ ក្រុម អ្នកស្រាវជ្រាវបានប្រើប្រាស់ការធ្វើសំភាសន៍ស៊ីជំរៅជាមួយតួអង្គសំខាន់ៗធ្វើជាវិធីសាស្ត្រស្រាវជ្រាវដំបូង ។ បើមានលទ្ធភាព សំភាសន៍ទាំងនេះបានធ្វើឡើងវិញពីរ ឬបីដង ដើម្បីវាស់ស្ទង់ពីការឆ្លើយតបរបស់តួអង្គនានាទៅនឹងព្រឹត្តិការណ៍ដែលកំពុងលាត ត្រដាងចេញ ។ ការសិក្សាឆ្នាំ២០០០ បានធ្វើការវាយតំលៃពីការបោះឆ្នោតដោយពិនិត្យត្រឡប់ក្រោយវិញទៅលើរឿងរ៉ាវដែល បានកន្លងហួសហើយ រីឯការសិក្សាលើកនេះបានបកស្រាយលំអិតពីសកម្មភាព និងចំណុចព្រួយបារម្ភរបស់តួអង្គខាងនយោបាយ នានាដែលកំពុងឆ្លងកាត់ដំណើរការបោះឆ្នោតតែម្តង[២] ។

#### *១.២.១.១ ប្រភពទំនាស់នានា*

ប្រភពទំនាស់នានាមុនពេលបោះឆ្នោត បានរកឃើញតាមរយៈការពិនិត្យអត្ថបទសារពត៌មានជាភាសាខ្មែរ និងអង់គ្លេស ក្នុងរយៈពេល ៦ខែមុន និងកំណត់ហេតុនៃការការប្រជុំប្រចាំខែ COPCEL ដែលជាវេទិកាមួយសំរាប់ឱ្យតួអង្គខាងនយោបាយនា នា លើកពីការតវ៉ា ការមិនពេញចិត្ត ឬបញ្ហាផ្សេងៗទៀតមកពិភាក្សាជាមួយពួកអ្នកតំណាងរបស់រដ្ឋ គណបក្សនយោបាយ និង NGOs ។ ក្រៅពីនេះ មានការធ្វើសំភាសន៍ស្ទាបស្ទង់ជាមួយតួអង្គខាងនយោបាយ មកពីគណបក្សនានា និង NGOs ។ ក្នុង ជំហានជាដំបូងៗនេះ បានរកឃើញទំនាស់ស្តីពីតួនាទីរបស់ប្រធានភូមិ, លទ្ធភាពអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបានងាយស្រួល និងសិទ្ធិអំណាចរបស់ គជប នៅក្នុងទំនាក់ទំនងជាមួយស្ថាប័នរដ្ឋផ្សេងៗទៀត ។

---

[២] ដើម្បីរក្សាសំងាត់ ក្នុងរបាយការណ៍ស្រាវជ្រាវនេះ គ្មានការបញ្ជាក់ឈ្មោះអ្នកឆ្លើយសំភាសន៍ទេ ប៉ុន្តែមានផ្តល់ឈ្មោះអង្គការដែលពួកគេ តំណាង ។ មានការបង់លេខសំគាល់ឱ្យគ្រប់អ្នកឆ្លើយសំភាសន៍ ដូច្នេះមតិយោបល់ផ្សេងៗរបស់បុគ្គលណាម្នាក់គឺ អាចរកឃើញនៅក្នុង របាយការណ៍ទាំងមូល ថ្វីបើបុគ្គលនោះគ្មានបញ្ជាក់ចំឈ្មោះក្តី ។

អង្កេតពីដំបូងនេះបានបង្ហាញថា តួនាទីរបស់ អាជ្ញាធរកំរិតឃុំមិនសូវមានបញ្ហាចោទដូចពីមុនទេ សំខាន់គឺដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធនៃអាជ្ញាធរឃុំ ។ អង្កេតក៏បង្ហាញដែរថា អ្នកផងពុំមានសតិអារម្មណ៍ចាត់ទុកការចុះបញ្ជីអ្នកបោះឆ្នោតថាអាចក្លាយប្រភពទំនាស់ទេនៅពេលនេះ ថ្វីបើ COMFREL បានបញ្ជាក់ពីការបារម្ភរបស់ខ្លួន ស្តីពីអត្រាទាបនៃការចុះបញ្ជីអ្នកបោះឆ្នោតថ្មីនៅខែកុម្ភៈក្តី[៣] ។ អង្គការឃ្លាំមើលការបោះឆ្នោតនានា (EMOs) ក៏បានបញ្ជាក់ពីការបារម្ភអំពីសកម្មភាពរបស់មន្ត្រីនៅមូលដ្ឋានដែរ ការតវ៉ាជាច្រើនស្តីពីការបំភិតបំភ័យ និងការទិញសន្លឹកឆ្នោត ហើយនិងអព្យាក្រឹតភាពនៃគណៈកម្មាធិការរៀបចំការបោះឆ្នោតនៅមូលដ្ឋាន[៤] ។

ការបដិសេធលទ្ធផលដោយ SRP និង FUNCINPEC ភ្លាមៗក្រោយដែលការបោះឆ្នោតបានគូសរំលេចបញ្ហាជាច្រើនស្តីពីការចុះបញ្ជីអ្នកបោះឆ្នោត តួនាទីរបស់ប្រធានភូមិ និងការអះអាងថា មន្ត្រីនៃការិយាល័យបោះឆ្នោត មិនបានផ្តល់ទំរង់សមស្របឱ្យអ្នកសង្កេតការណ៍តំណាងគណបក្ស ដើម្បីឱ្យពួកគេអាចផ្ទៀងផ្ទាត់លទ្ធផលបាន គឺជាចំណុចព្រួយបារម្ភចំបងគេ ។ បញ្ហាលទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បានធ្លាក់ចេញពីបញ្ជីនៃការតវ៉ា ហើយវាបង្ហាញថា បញ្ហានេះអាចគ្រប់គ្រងបានល្អនៅមុនថ្ងៃបោះឆ្នោត ។ បន្ទាប់មកទៀត SRP និង FUNCINPEC ដែលនៅក្រោយការបោះឆ្នោត បានរួមគ្នាបង្កើតជាសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ ក៏បានតវ៉ាផងដែរអំពីអព្យាក្រឹតភាព និងតំលាភាពរបស់ គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការដោះស្រាយបណ្តឹងតវ៉ា ។

គួរកត់សំគាល់ថា ការតវ៉ាពីអំពើហិង្សាខាងនយោបាយ មិនសូវលេចធ្លោក្នុងការតវ៉ាលើការបោះឆ្នោតពីសំណាក់សមាជិកគណបក្សនយោបាយទេ ប៉ុន្តែឃើញមានចុះនៅក្នុងរបាយការណ៍របស់អ្នកសង្កេតការណ៍ក្នុងស្រុក និងអន្តរជាតិ[៥] ។

តួនាទីរបស់ប្រធានភូមិ ត្រូវបានស្រាវជ្រាវភ្ជាប់ជាមួយនឹងការវិភាគពីការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន តាមរយៈករណីសិក្សានានាអំពីឃុំ (ចុះនៅខាងក្រោម) ។ បញ្ហាលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បានស្រាវជ្រាវជាសំខាន់តាមរយៈបទសំភាសន៍ស៊ីជំរៅជាមួយមន្ត្រីទទួលបន្ទុកខាងប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សនយោបាយធំៗ ស្តីពីសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកនៅក្នុងយុទ្ធសាស្ត្រឃោសនាបោះឆ្នោត និងចំណាប់អារម្មណ៏របស់ពួកគេអំពីកម្មវិធីផ្សេងៗដែលបានរៀបចំឡើង ដើម្បីសំរួលឱ្យលទ្ធភាពនេះមានលក្ខណៈស្មើភាព និងមានសមធម៌ ។ ការសង្កេតដែលប្រើបញ្ជីសំនួរមួយបានធ្វើឡើងនៅសប្តាហ៍ទី៣ និងទី៤ នៃខែកក្កដា ទៅលើគណបក្សនយោបាយតូចៗ ស្តីពីចំណាប់អារម្មណ៏របស់ពួកគេចំពោះលទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ហើយមាន ១១គណបក្ស (ក្នុងចំនោម ១៨ គណបក្ស) បានចូលរួមក្នុងអង្កេតនេះ ។ សកម្មភាពខាងលើត្រូវបានបំពេញបន្ថែមដោយបទសំភាសន៍ជាមួយតួអង្គសំខាន់ៗក្នុងរឿងប្រព័ន្ធផ្សព្វផ្សាយ ជាអាទិ៍ បណ្តាអ្នកតំណាងអង្គការអន្តរជាតិនានាដែលជាប់ពាក់ព័ន្ធនឹងគំរោងផ្សព្វផ្សាយទាក់ទិននឹងការបោះឆ្នោត នាយក និងអ្នកយកពត៌មាននានារបស់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយជ្រើសរើសមួយចំនួន ។

ចំណាប់អារម្មណ៏ពីការផ្លាស់ប្តូរក្នុងតួនាទីរបស់ គជប ត្រូវបានសិក្សាតាមមធ្យោបាយធំៗពីរគឺ បទសំភាសន៍ជាមួយតំណាងគណបក្សនយោបាយនៅកំរិតជាតិ ខេត្ត និងឃុំ ដើម្បីវាស់ស្ទង់ពីទស្សនវិស័យរបស់ពួកគេស្តីពីគណៈកម្មាធិការកំរិតជាតិ

---

[៣] COMFREL, “Concerns over the Low Rate of Registration for New Voters and an Increase in Irregularities Reported in the Registration Process,” Press Release, Phnom Penh, 7 Feb 2003.

[៤] COMFREL, NICFEC, “Concerns over the Increase of Cases of Violence, Threats, Intimidation, and Vote Buying during the First Two Weeks of the Electoral Campaign,” press release, Phnom Penh, 19 July 2003; COMFREL, “Report on the Irregularities of Provincial Electoral Commission’s Recruitment Procedures,” press release, Phnom Penh, 23 May 2003.

[៥] COMFREL, “COMFREL Urges Government to Open Up the Political Environment and Requests NEC to Review the Interpretation of the Election Law’s Vote Counting Process,” press statement, Phnom Penh, 19 June 2003;

ខេត្ត និងឃុំ, និងការសង្កេតមើលពីរបៀបរបបធ្វើការងាររបស់ គជប ដែលមានជាអាទិ៍ ការវិភាគពីក្របខ័ណ្ឌច្បាប់ថ្មីសំរាប់ឱ្យ គជប ធ្វើប្រតិបត្តិការ, ការធ្វើទស្សនកិច្ចយ៉ាងទៀងទាត់នៅមជ្ឈមណ្ឌលពត៌មាន គជប, ការចូលរួមក្នុងសន្និសីទសារពត៌មាន គជប, ការប្រមូល និងការវិភាគលើឯកសារនានារបស់ គជប, និងការសង្កេតពិនិត្យពីការចូលពាក់ព័ន្ធរបស់ គជប ក្នុងការប្រជុំ COPCEL ។ ពត៌មានទាំងអស់នេះត្រូវបានបំពេញបន្ថែមដោយបទសំភាសន៍ជាមួយសមាជិក និងបុគ្គលិក គជប ដែលបានធ្វើឡើង ៦សប្តាហ៍ក្រោយការបញ្ចប់រយៈពេលបោះឆ្នោត គឺភ្លាម១បន្ទាប់ពី គជប បានធ្វើការវាយតំលៃពីលទ្ធផលការងាររបស់ខ្លួនផ្ទាល់ ។

*១.២.១.២ ការវាយតំលៃពីការផ្លាស់ប្តូរ*

នៅកំរិតជាតិ ការផ្លាស់ប្តូរចំបង១ដែលកើតមានឡើងក្នុងចន្លោះពេលពីឆ្នាំ១៩៩៨-២០០៣ គឺមានកំណែទំរង់លើស្ថាប័នជាតិនានា និងការតស៊ូមតិរបស់សង្គមស៊ីវិល ។ កំណែទំរង់លើស្ថាប័នជាតិ បានស៊ើបអង្កេតតាមរយៈបទសំភាសន៍ស្រាវជ្រាវជាមួយសមាជិកនានានៃ គជប, សកម្មជនរបស់គណបក្សនយោបាយ និងអង្គការឃ្លាំមើលការបោះឆ្នោត ។ មានការស្រាវជ្រាវបន្ថែមទៀតតាមរយៈការសង្កេតពិនិត្យពីទំនាក់ទំនងសាធារណៈរបស់ គជប និងការអង្កេតសិក្សាឯកសារលើពត៌មាន គជប ។ ចំណុចយកចិត្តទុកដាក់មួយទៀតនៅកំរិតជាតិ គឺការវាយតំលៃពីផលប៉ះពាល់នៃការតស៊ូមតិរបស់សង្គមស៊ីវិលទៅលើចំណាប់អារម្មណ៍អំពីទំនាស់ និងការគ្រប់គ្រងទំនាស់ ។ ការតស៊ូមតិរបស់សង្គមស៊ីវិល បានសិក្សាអង្កេតតាមរយៈវិធីសាស្ត្រស្រាវជ្រាវចំបង១ ៣ គឺបទសំភាសន៍ជាមួយតួអង្គសំខាន់១ ការអង្កេតសិក្សាលើឯកសារផលិតដោយអង្គការសង្គមស៊ីវិល និងការសង្កេតមើលក្នុងរយៈពេលបោះឆ្នោត ពីផលប៉ះពាល់នៃសេចក្តីប្រកាសផ្សេង១របស់សង្គមស៊ីវិល ។ បទសំភាសន៍រួមមាន ការធ្វើសំភាសន៍ស៊ីជំរៅជាមួយនាយក និងបុគ្គលិកបណ្តាញធំ១ពីរនៃអ្នកសង្កេតការណ៍លើការបោះឆ្នោតគឺ COMFREL និង NICFEC និងបទសំភាសន៍ស៊ីជំរៅជាមួយបុគ្គលិកស្ថាប័នទាំងនេះជាបន្ថែមទៀតក្នុងករណីសិក្សានៅ ៤ខេត្ត ។

បទសំភាសន៍ក៏បានធ្វើផងដែរជាមួយសមាជិក ១៤នាក់ នៃដំណើរការ COPCEL ។ អ្នកសួរសំភាសន៍បានជ្រើសរើសអ្នកណាដែលបានចូលរួមប្រជុំ COPCEL យ៉ាងទៀងទាត់ក្នុងប៉ុន្មានខែថ្មី១ ។ មានការទទួលស្គាល់ថា វិធីនេះអាចផ្តល់ការវាយតំលៃជាវិជ្ជមានលើ COPCEL ជាងការជ្រើសរើសតាមវិធីផ្សេងទៀត ពីព្រោះអ្នកចូលរួមទៀងទាត់ តែងផ្តល់តំលៃខ្ពស់ដល់ដំណើរការ ជាងពួកអ្នកអវត្តមានជាទៀងទាត់ ។ ប៉ុន្តែ ក៏អាចមានហេតុផលជាច្រើនផ្សេងទៀត ការមិនចូលរួម ឬការចូលរួមមិនទៀងទាត់នោះដែរ ដូចជា រចនាសម្ព័ន្ធអង្គការចាត់តាំងទន់ខ្សោយ កង្វះខាតបុគ្គលិក ឬការផ្លាស់ប្តូរបុគ្គលិកលឿនក្នុងបណ្តាអង្គការដែលបញ្ជូនពួកគេមក ។ ដោយសារពេលវេលា និងធនធានមានកំរិត មានការពិចារណាថា ការស្វែងរក និងធ្វើសំភាសន៍ពួកអ្នកមិនចូលរួមដែលមានការអាក់អន់ចិត្ត មិនសូវមានប្រយោជន៍ ដូចការវាយតំលៃលើមតិរបស់អ្នកមានការប្តេជ្ញាចិត្តគាំទ្រដំណើរការនោះទេ ក្នុងរឿងថាតើដំណើរការបានសំរេចអ្វីខ្លះ និងតើគេអាចកែលំអវាយ៉ាងណា ។ ដូច្នេះហើយ ការជ្រើសរើសអ្នកឆ្លើយសំភាសន៍ បានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីប្រភេទធំ១បីនៃអង្គការដែលមានតំណាងក្នុងការប្រជុំ COPCEL គឺមានសង្គមនយោបាយ សង្គមស៊ីវិល និងស្ថាប័នរដ្ឋ ។ បទសំភាសន៍បានធ្វើឡើងជាមួយតំណាងក្នុង COPCEL នៃ SRP, CPP, និង FUNCINPEC ក្នុងប្រភេទទី១ ហើយ ADHOC, KID, CSD, CCHR, WFP, COMFREL, និង NICFEC ក្នុងប្រភេទទី២, និងក្រសួងការពារជាតិ, និងគណៈកម្មការជាតិសំរាប់សិទ្ធិមនុស្ស ក្នុងប្រភេទទី៣ ។ បទសំភាសន៍ត្រូវបានបំពេញបន្ថែមដោយការធ្វើវិភាគលើឯកសារកំណត់ហេតុនានានៃការប្រជុំ COPCEL ។

ចំណុចយកចិត្តទុកដាក់ចំបងមួយទៀតក្នុងការស្រាវជ្រាវបែបនេះ គឺការស្វែងរកភាគីសំខាន់១នៃទំនាស់ និងភាគីនានាដែលបានខិតខំគ្រប់គ្រងទំនាស់, ព្រមទាំងវាយតំលៃពីជោគជ័យនៃយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់ ដោយស៊ើបអង្កេតលើករណីជាក់លាក់មួយចំនួននៅកំរិតមូលដ្ឋាន ការចាត់ចែងរបស់ពួកគេនិងលទ្ធផលទទួលបាន, ហើយបន្ទាប់មកធ្វើការតាមដានពីការតវ៉ាក្នុងសេចក្តីប្រកាសផ្សេង១នៅកំរិតជាតិ និងការតវ៉ាក្រោយពេលបោះឆ្នោត ។

### ១.២.២ ការស្រាវជ្រាវនៅកំរិតមូលដ្ឋាន

ការសិក្សាលើកនេះ ខិតខំបន្តពីលទ្ធផលនៃការសិក្សាលើការបោះឆ្នោតឆ្នាំ១៩៩៨ ដោយធ្វើការស្រាវជ្រាវនៅកំរិតជាតិ ខេត្ត និងឃុំ ។ ក្នុងគោលដៅនេះ បានជ្រើសរើសកន្លែងសំរាប់ចូលស្រាវជ្រាវនៅក្នុង ៤ខេត្ត គឺ បាត់ដំបង កំពង់ចាម កំពត និង តាកែវ ។ ក្នុងខេត្តនីមួយៗ បានធ្វើករណីសិក្សាលំអិតនៅក្នុងឃុំមួយ (ពីរឃុំ សំរាប់បាត់ដំបង) និងមានបំពេញបន្ថែមដោយបទសំភាសន៏ជាមួយតួអង្គខាងនយោបាយមួយចំនួននៅកំរិតខេត្ត ។

ការចុះសិក្សាដល់កន្លែងសំរាប់ការសិក្សានេះ គួរចាត់ទុកជាជំហានដំបូងមួយ មិនមែនជាលទ្ធផលដាច់ណាត់ទេ ។ ដោយឡែក គំរូតាងមិនធំគ្រប់គ្រាន់ដើម្បីអាចទាញយកសេចក្តីសន្និដ្ឋានជាទូទៅបានទេ ។ ប៉ុន្តែផ្អែកលើចំណេះដឹងយ៉ាងច្រើនអំពីអន្តរកម្មរវាងនយោបាយនៅកំរិតជាតិ និងកំរិតមូលដ្ឋាន ការយល់ដឹងទទួលបាន ថ្វីបើវាផ្តោតតាមកន្លែងជាក់លាក់ក្តី ក៏បានផ្តល់គំនិតពីទិសដៅនានានៃការស្រាវជ្រាវក្នុងពេលអនាគត ។ម្យ៉ាងទៀតប្រវែងពេលវេលា សំរាប់ធ្វើការសិក្សានេះ បានកាត់បន្ថយលទ្ធភាពនៃការស្រាវជ្រាវដើម្បីកសាងចំណងទាក់ទងជិតស្និទ្ធជាមួយកន្លែងចុះសិក្សា ។ រឿងនេះ បានបង្កបញ្ហាមួយចំនួនៈ ជួនកាលអ្នកឆ្លើយសំភាសន៏ដែលត្រូវបានកំណត់ថាសំខាន់ចំពោះការសិក្សានេះ គឺមិនអាចរកឃើញទេ ពីព្រោះជាប់រវល់ទៅឃោសនា ឬក៏ត្រូវកោះហៅទៅភ្លាមៗទាក់ទិននឹងការងារបោះឆ្នោត ហើយបើសិនអាចរកគាត់ឃើញ និងទាក់ទងគ្នាបានវិញនៅទស្សនកិច្ចលើកក្រោយៗ ក៏ពុំមានពេលគ្រប់គ្រាន់ ដើម្បីកសាងទំនាក់ទំនងដែលអនុញ្ញាតឱ្យពិនិត្យបានយ៉ាងល្អិតល្អន់ពីឥរិយាបថ និងចំណាប់អារម្មណ៏នោះដែរ ។ ក្រុមអ្នកស្រាវជ្រាវបានប្រឹងប្រែងខ្លាំងណាស់ ដើម្បីស្វែងរកធ្វើសំភាសន៏ និងទៅជួបសាជាថ្មីនូវអ្នកតំណាងរបស់រដ្ឋ គណបក្សកាន់អំណាច គណបក្សជំទាស់ និងសង្គមស៊ីវិល ដើម្បីសាកសួរពីចំណាប់អារម្មណ៏ស្តីពីព្រឹត្តិការណ៏ដែលកំពុងលាតត្រដាងឡើង ។ ប៉ុន្តែជួនកាលមិនអាចធ្វើដូច្នេះបានទេ ហើយត្រូវរកអ្នកជំនួសនៅក្នុងប្រភេទដូចគ្នា ។ ឧបសគ្គទាំងនេះ មានលើកមកបញ្ជាក់ និងពិភាក្សា នៅក្នុងជំពូកស្តីពីកំហិតនានាចំពោះការសិក្សា និងមានការផ្តល់មតិមួយចំនួនសំរាប់ការស្រាវជ្រាវទៅអនាគត ។ ដោយឡែកមូលដ្ឋានគ្រឹះដែលការសិក្សានេះបានកសាងឡើង គឺអាចយកទៅកែច្នៃថែមទៀតដើម្បី ស្វែងយល់ឱ្យបានកាន់តែស៊ីជំរៅអំពីបញ្ហានានាដែលកំពុងចោទឡើង ។

### ១.២.៣ រវាងទំនាស់នៅកំរិតជាតិ និងនៅកំរិតមូលដ្ឋាន

ក្រុមអ្នកស្រាវជ្រាវបានប្រៀបធៀបរបកគំហើញនៅកំរិតមូលដ្ឋាន និងកំរិតជាតិ ដើម្បីស្រាវជ្រាវពីបែបបទ ដែលព្រឹត្តិការណ៏នៅមូលដ្ឋាន បានប្រែក្លាយជាប្រភពនៃការរីករាលដាលទំនាស់នៅកំរិតជាតិ ។ ដំណាក់កាលក្រោយពេលបោះឆ្នោតមានសារៈសំខាន់ជាពិសេសក្នុងរឿងនេះ និងត្រូវបានសិក្សាស្រាវជ្រាវ តាមការធ្វើវិភាគលើសេចក្តីថ្លែងការណ៏ផ្សេងៗរបស់គណបក្សនយោបាយ, បទសំភាសន៏ជាមួយតំណាងគណបក្សនយោបាយនៅកំរិតមូលដ្ឋាន និងកំរិតជាតិ, ការវិភាគលើសេចក្តីថ្លែងការណ៏ធ្វើដោយអ្នកសង្កេតការណ៏កំរិតមូលដ្ឋានជាតិ និងអន្តជាតិ ។

ដោយសារមធ្យោបាយដូចខាងលើ ការរីករាលដាលទំនាស់ ពោលគឺការកៀងគរដោយតួអង្គកំរិតជាតិនានានូវការតវ៉ាដែលសេសសល់ពីដំណាក់កាលមុនៗនៃការបោះឆ្នោត និងទំនាស់ថ្មីៗដែលផុសឡើងនៅមូលដ្ឋាន គឺអាចតាមដានឃើញ ។ ចំណុចយកចិត្តទុកដាក់សំខាន់មួយទៀតគឺ អន្តរាគមន៏របស់អ្នកគ្រប់គ្រងទំនាស់ ជាពិសេសអ្នកគ្រប់គ្រងទំនាស់ជាផ្លូវការ ដូចជា គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ហើយនិងអ្នកគ្រប់គ្រងទំនាស់ក្រៅផ្លូវការជាច្រើនទៀត ដូចជា បណ្តាញអ្នកសង្កេតការណ៏បោះឆ្នោតតួអង្គខាងសង្គមស៊ីវិល អ្នកការទូត និងអង្គការបរទេសនានា ។

## ជំពូកទី ២

# ឆ្នាំ១៩៩៨ និង ២០០៣ ប្រៀបធៀបគ្នា

### ២.១ កំណែទំរង់ច្បាប់

ការត្រៀមរៀបចំសំរាប់ការបោះឆ្នោតឆ្នាំ១៩៩៨ ជួបឧបសគ្គនៃកង្វះទំនុកចិត្តពីសំណាក់គណបក្ស FUNCINPEC និង SRP នៅក្នុងរដ្ឋសភាដែលបានអនុម័តច្បាប់បោះឆ្នោតនៅខែធ្នូ ១៩៩៧ ។ កង្វះការចូលរួមពីសមាជិកសំខាន់ៗរបស់ FUNCINPEC និង SRP នាំឱ្យមានវិបត្តិនៅជិតថ្ងៃបោះឆ្នោត នៅពេលដែលគណបក្សទាំងពីរត្រឡប់មកវិញ ហើយបដិសេធទាំងភាពពេញលក្ខណៈច្បាប់ និងការត្រៀមរៀបចំផ្សេងៗសំរាប់ច្បាប់នេះផង ។ វិវាទទាំងនេះបាននាំទៅដល់ពហិការសភានៅខែឧសភា ១៩៩៨ ដោយ FUNCINPEC និង BLDP ដែលបានរាំងស្ទះ ការបោះឆ្នោតអនុម័តវិសោធនកម្មសំខាន់ៗមួយចំនួនលើច្បាប់បោះឆ្នោត ។ វិវាទមួយផ្តោតលើកន្លែងរាប់សន្លឹកឆ្នោតៈ នៅឆ្នាំ១៩៩៣ សន្លឹកឆ្នោតរាប់នៅកំរិតខេត្ត ប៉ុន្តែច្បាប់ឆ្នាំ១៩៩៧ កំណត់ឱ្យរាប់នៅការិយាល័យបោះឆ្នោត ។ បន្ទាប់មកក៏អាចចរចាបានការសំរុះសំរួលមួយឱ្យរាប់នៅកំរិតឃុំ ។ វិវាទពិបាកដោះស្រាយជាងមួយបានផុសឡើងពីរឿងពេលបោះឆ្នោត ។ FUNCINPEC និង SRP ស្នើឱ្យពន្យាថ្ងៃបោះឆ្នោតដើម្បីពួកគេមានពេលកសាងឡើងវិញនូវបណ្តាញរបស់គណបក្ស ដែលត្រូវខូចខាតដោយសារការវាយប្រយុទ្ធក្នុងខែកក្កដាឆ្នាំ១៩៩៧ ។ CPP និងសម្ព័ន្ធមិត្តរបស់ខ្លួនបានជំទាស់ថា ការពន្យាពេលបោះឆ្នោត ធ្វើឱ្យខូចខាតផលប្រយោជន៍ជាតិ ដោយសារប្រទេសកម្ពុជាត្រូវ UN និងអាស៊ាន ផាត់ចេញនៅក្រោយខែកក្កដា ១៩៩៧ ។ ទំនាស់នេះមិនទាន់ដោះស្រាយទេ នៅមុនពេលបោះឆ្នោត ហើយវាផុសឡើងទៀតក្រោយការផ្សព្វផ្សាយលទ្ធផល ។

នៅឆ្នាំ២០០២ នៅពេលធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ស្ថានការណ៍ខុសប្លែកគ្នាច្រើន ។ ក្រសួងមហាផ្ទៃ បានធ្វើសំណើវិសោធនកម្មច្បាប់ ដោយបានគិតគូរពីការទិតៀននានាចំពោះការបោះឆ្នោតឆ្នាំ១៩៩៨ ។ ឧទាហរណ៍ ច្បាប់បោះឆ្នោតបានកែទំរង់សមាសភាព គជប ដែលជាការឆ្លើយតបនឹងការតស៊ូមតិតាំងពីឆ្នាំ១៩៩៨ រហូតមករបស់គណបក្សនយោបាយ និង NGOs ។ ក្នុងច្បាប់បោះឆ្នោតក៏មានផងដែរនូវបទប្បញ្ញត្តិលំអិតលើបញ្ហាមួយចំនួនដែលទំនាស់គ្នាក្នុងឆ្នាំ១៩៩៨ ។ ឧទាហរណ៍ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨ មានវិវាទអូសបន្លាយលើបញ្ហារូបមន្តបែបណាដែលគួរប្រើដើម្បីគណនាចំនួនអាសនៈនៅសភា ចេញពីចំនួនសន្លឹកឆ្នោតដែលគណបក្សនីមួយៗទទួលបាន ។ ឯកសារខុសៗគ្នារបស់ក្រសួងមហាផ្ទៃ មានបង្ហាញរូបមន្តខុសៗគ្នាដែរ ដែលធ្វើឱ្យគណបក្សជំទាស់ចោទថា មានការបន្លំបោកប្រាស ។ នៅឆ្នាំ២០០៣ រូបមន្តសំរាប់បែងចែកអាសនៈ មានចុះនៅក្នុងច្បាប់បោះឆ្នោត ។

ក្រៅពីបានឆ្លើយតបនឹងការព្រួយបារម្ភកាលពីឆ្នាំ១៩៩៨ ច្បាប់បោះឆ្នោតធ្វើវិសោធនកម្មត្រូវបានអនុមតិដោយរដ្ឋសភាមួយដែលមានភាពពេញលក្ខណៈច្បាប់យ៉ាងច្រើនជាងកាលពីឆ្នាំ១៩៩៨ ។ ថ្វីបើនៅមានការព្រួយបារម្ភមួយចំនួនទាក់ទិននឹងលទ្ធភាពរបស់សភាជាតិ ក្នុងការពិនិត្យពិច័យលើនយោបាយ និងសកម្មភាពរបស់រដ្ឋាភិបាលក្តី ច្បាប់វិសោធនកម្មឆ្នាំ២០០៣ ត្រូវបានអនុមតិដោយមិនសូវមានការប្រទាំងប្រទើសអ្វីទេ ហើយគណបក្សទាំងអស់ បានចូលរួមក្នុងការជជែកដេញដោលនៅសភា ។ គណបក្សនយោបាយធំៗទាំងអស់បានឯកភាពថា ច្បាប់បោះឆ្នោតធ្វើវិសោធនកម្មនេះ មានលក្ខណៈល្អជាងច្បាប់ពីមុន ។

ការទិតៀនចំបងលើដំណើរការធ្វើកំណែទំរង់ច្បាប់គឺ ការពិគ្រោះយោបល់បានធ្វើតិចតួចពេកជាមួយភាគីនានានៅក្រៅរដ្ឋាភិបាល នៅមុនពេលដែលសេចក្តីព្រាងច្បាប់បានបញ្ជូនទៅដល់សភា ។ នេះជាការទិតៀនដែលមានជាយូរហូរហែរមកហើយចំពោះប្រតិបត្តិការរបស់រដ្ឋាភិបាលនៅកម្ពុជា ហើយដែល NGOs អង្គការអន្តរជាតិ និងអ្នកផ្តល់ជំនួយបានប្រកាសឡើងជារឿយៗ ។ ប៉ុន្តែទោះក្នុងរឿងនេះក្តី ក៏មានតួអង្គខាងនយោបាយមួយចំនួនបានលើកសរសើររដ្ឋាភិបាលពីការប្រឹងប្រែងបើកចំហឱ្យមានការពិភាក្សាលើសេចក្តីព្រាងវិសោធនកម្ម មុននឹងសភាជាតិធ្វើការជជែកដេញដោល ។ ឱកាសដ៏ធំមួយសំរាប់ឱ្យភាគីជាប់ពាក់ព័ន្ធនានាផ្តល់មតិលើសេចក្តីព្រាងច្បាប់ គឺការប្រជុំ COPCEL នៅខែកក្កដា ២០០២ ដែលនៅពេលនោះ ឯ.ឧ សក់ សេដ្ឋា អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ បានតាងនាមឱ្យក្រសួង ដើម្បីរាយការណ៍ពីសេចក្តីព្រាងវិសោធនកម្ម ។

ការពិភាក្សាពីសេចក្តីព្រាងវិសោធនកម្មនៅក្នុងការប្រជុំ COPCEL ផ្តោតលើការប្រទាំងប្រទើសដែលបន្តនៅមានលើសមាសភាព គជប (សូមអានផ្នែក ២.២ ខាងក្រោម) ។ តំណាងក្រសួងមហាផ្ទៃ បានឯកភាពយកមតិនានារបស់សមាជិក COPCEL ទៅជូនក្រសួងវិញ ដើម្បីពិនិត្យពិភាក្សា ។ បុគ្គលនានាដែលបានចូលរួមក្នុងការប្រជុំ យល់ឃើញខុសៗគ្នាពីសារៈសំខាន់នៃដំណើរការពិគ្រោះយោបល់នេះ ។ តំណាងខាងអង្គការឃ្លាំមើលការបោះឆ្នោតម្នាក់មើលឃើញថា ការពិគ្រោះយោបល់នេះមានរូបភាពតូចពេក ទុកលទ្ធភាពតូចពេកសំរាប់ការចូលរួម និងបើកការអនុញ្ញាតតែចំពោះប្រតិកម្មមកពីភាគីនានានៅក្រៅរដ្ឋាភិបាលប៉ុណ្ណោះ:

> *"ការប្រស្រ័យទាក់ទងរវាង NGOs និងរដ្ឋាភិបាល នៅលំបាកនៅឡើយ ។ រឿងនេះទាក់ទងនឹងបទពិសោធន៍: ខ្ញុំធ្វើការខាងទំនាក់ទំនងខាងក្រៅ ហើយខ្ញុំមានការលំបាកក្នុងការប្រស្រ័យទាក់ទងជាមួយរដ្ឋាភិបាល: ឧទាហរណ៍ ក្រសួងមហាផ្ទៃ និងរដ្ឋសភាផងដែរ ។ នៅពេលខ្ញុំចង់បានសេចក្តីព្រាងខ្លះនៃច្បាប់បោះឆ្នោត (ព្រោះចង់ផ្តល់មតិរបស់យើងលើច្បាប់បោះឆ្នោត) យើងពិបាករកវាបានណាស់ ។ ពួកគេតែងនិយាយថា យើងមិនអាចផ្តល់ឱ្យបានទេ មុនពេលយើងមានសេចក្តីព្រាងជាផ្លូវការ (ប៉ុន្តែយើងចង់បានវាជាមុន ពីព្រោះយើងចង់ជះឥទ្ធិពលនៅដំណាក់កាលពីដំបូងៗ"[៦] ។*

តាមមតិរបស់តួអង្គខាងនយោបាយនេះ អឆន្ទៈរបស់រដ្ឋាភិបាលក្នុងការបើកចំហដំណើរការកសាងគោលនយោបាយឱ្យកាន់តែទូលាយដើម្បីទទួលយកមតិរបស់ NGOs វាជាសញ្ញានៃការលំបាកក្នុងការប្រស្រ័យទាក់ទង រវាងតួអង្គនានាខាងរដ្ឋាភិបាល និង NGOs ។ ប៉ុន្តែអ្នកឆ្លើយសំភាសន៍ម្នាក់ទៀត (បុគ្គលិក UNDP) មើលឃើញដំណើរការពិគ្រោះយោបល់ក៏រិតតូចនេះថាបានបោះជំហានទៅមុខហើយទាក់ទិននឹងតំលាភាពក្នុងជួររដ្ឋាភិបាល ។

> *"នៅឆ្នាំ២០០២ ពេលកំពុងធ្វើវិសោធនកម្មច្បាប់ ហាក់ពុំមានការពិគ្រោះយោបល់ទេ ។ ប៉ុន្តែនៅពេលចុងក្រោយបំផុត ក្រសួងមហាផ្ទៃបានយកវិសោធនកម្មនានាមកបង្ហាញក្នុងការប្រជុំ COPCEL ។ នេះមិនមែនជាដំនើរការពិគ្រោះយោបល់មួយល្អទេ ប៉ុន្តែក៏មានខ្លះៗដែរ... ការអាចទាញក្រសួងមហាផ្ទៃ ឱ្យមកពន្យល់ពីច្បាប់ថ្មីនេះ គឺជារឿងថ្មីហើយ"[៧] ។*

ថ្វីបើនៅមានការទិតៀនពីដំណើរការកសាងច្បាប់ក្តី ប៉ុន្តែក្របខ័ណ្ឌច្បាប់សំរាប់ការបោះឆ្នោតបានទទួលអត្ថប្រយោជន៍ច្រើនណាស់ពីដំណើរការកសាងច្បាប់បើកចំហជាងមុននៅឆ្នាំ២០០២នេះ បើធៀបនឹងឆ្នាំ១៩៩៧ ។ ការទិតៀនពីទិដ្ឋភាពជាក់លាក់មួយចំនួននៃច្បាប់ គឺនៅតែមាន និងមានលើកមកពិភាក្សាក្នុងផ្នែកជាច្រើននៅខាងក្រោម ។ ប៉ុន្តែដំនើរការទាំងមូលនៃការអនុម័តច្បាប់ មិនត្រូវបានចោទថា មិនពេញលក្ខណៈច្បាប់ទាំងស្រុងនោះទេ ។ នេជាការកែលំអមួយ បើធៀបនឹងឆ្នាំ១៩៩៨ ។

---

[៦] តំណាងក៏រិតជាតិរបស់ COMFREL (1), មតិផ្ទាល់ខ្លួន, ៦ សីហា ២០០៣ ។

## ២.២ កំណែទំរង់ស្ថាប័នៈ កំណែទំរង់ គជប

នៅឆ្នាំ១៩៩៨ ភាពទន់ខ្សោយខាងស្ថាប័នគឺជាមូលហេតុចំបងមួយនៃការរីករាលដាលទំនាស់ក្នុងការបោះឆ្នោត ។ ការសិក្សារបស់ វិបសអ ពីការរីករាលដាលទំនាស់នៅឆ្នាំនោះ បានរកឃើញកត្តាមួយចំនួនដែលរួមចំណែកធ្វើឱ្យមានភាពទន់ខ្សោយខាងស្ថាប័ន ។ ស្ថាប័ននានាបានទទួលនិយមន័យថាជា "អ្នកគ្រប់គ្រងដែលមិនអាចសាកសួរជំទាស់បានទូវការរំពឹងទុក និងអាកប្បកិរិយា"[៨] ។ នៅឆ្នាំ១៩៩៨ ស្ថាប័នរដ្ឋចំបងៗជាប់ពាក់ព័ន្ធនឹងការបោះឆ្នោត គឺមានតាំងពីរដ្ឋសភាដែលអនុមតិច្បាប់បោះឆ្នោត គណៈកម្មាធិការរៀបចំការបោះឆ្នោតនៅកំរិតជាតិ ខេត្ត និងឃុំ ដែលត្រូវអនុវត្តច្បាប់នេះ, និងស្ថាប័នខាងប៉ូលីស និងតុលាការដែលត្រូវពង្រឹងការអនុវត្តន៏ច្បាប់ បានបាត់បង់ទំនុកចិត្តពីសំណាក់តួអង្គខាងនយោបាយមួយចំនួនច្រើនគួរកត់សំគាល់ ។ រដ្ឋសភាដែលអនុមតិច្បាប់បោះឆ្នោត ខ្វះការចូលរួមពីតំណាងនានាខាង FUNCINPEC ដែលបានចាកចេញពីប្រទេសក្រោយពីការវាយប្រយុទ្ធនៅឆ្នាំ១៩៩៧ ក្នុងនេះមានទាំងអ្នកដឹកនាំគណបក្សក្នុងសភា និងនាយករដ្ឋមន្ត្រីទី១គឺ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិផង ។ រឿងនេះបានធ្វើឱ្យខូចខាតដល់ភាពពេញលក្ខណៈច្បាប់របស់សភា នៅក្នុងក្រសែភ្នែករបស់តួអង្គខាងនយោបាយជាច្រើន ។ ការអះអាងពីភាពលំអៀងខាងនយោបាយ, ពាក្យចចាមអារាមស្តីពីអំពើពុករលួយ និងការគំរាមកំហែង, និងការតវ៉ាពីការផាត់ចេញ, បានផុសឡើងនៅជុំវិញការបង្កើត គជប និងបណ្តាស្ថាប័នក្រោមបង្គាប់ ។ ក្រោយមកទៀត ស្ថាប័នទាំងនេះត្រូវបានមើលឃើញថា ខ្វះសមត្ថភាព និងសិទ្ធិអំណាចដ៏ចាំបាច់នានា ដើម្បីអាចឯករាជ្យអំពីអាជ្ញាធរមូលដ្ឋាន ជាពិសេសនៅកំរិតឃុំ និងភូមិ ។ តួអង្គខាងនយោបាយជាច្រើនរបស់គណបក្សជំទាស់ និង NGOs មើលឃើញថា អាជ្ញាធរទាំងនេះប្រកាន់បក្សពួកគាំទ្រ CCP ជាខ្លាំង ។ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលដើរតួជាតុលាការចុងក្រោយសំរាប់បណ្តឹងតវ៉ាផ្សេងៗ គឺទើបតែបានបង្កើតថ្មីៗ ហើយមានវិវាទមួយចំនួនទាក់ទិននឹងការតែងតាំងសមាជិកស្ថាប័ននេះ ។

ពីឆ្នាំ១៩៩៨ ដល់ ២០០៣ ស្ថាប័នបោះឆ្នោតសំខាន់ៗមួយចំនួនបានធ្វើកំណែទំរង់ ហើយមានជាច្រើនបានកើនសមត្ថភាពបច្ចេកទេស ។ ប៉ុន្តែនាឆ្នាំ២០០៣ នៅមានការលំបាកនៅឡើយ ហើយឯកសារនេះនឹងរាយការណ៏បង្ហាញ ។ ស្ថាប័ននានាបានកសាងកាន់តែប្រសើរឡើង តាមរយៈនីតិវិធីមានការចូលរួមកាន់តែច្រើន ។ ក្នុងករណីមួយចំនួន ស្ថាប័នទាំងនេះមានពេលវេលាពង្រឹងស្ថានភាពរបស់ខ្លួន និងមានសមត្ថភាព និងប្រសិទ្ធភាពកាន់តែខ្ពស់ក្នុងការធ្វើប្រតិបត្តិការ ។ ប៉ុន្តែមានកត្តាចំបង ៣ ដែលបន្តធ្វើឱ្យចុះខ្សោយស្ថាប័នទាំងនេះ:

- កង្វះការបែងចែកដាច់ពីគ្នារវាងគណបក្ស និងរដ្ឋ និង/ឬ រវាងបុគ្គល និងមុខតំណែង, ទាំងនៅក្នុងសកម្មភាពរបស់ពួកមន្ត្រី និងក្នុងចំណាប់អារម្មណ៏របស់តួអង្គខាងនយោបាយឯទៀតៗចំពោះពួកនេះ
- ស្ថាប័ននានាមាននិន្នាការធ្វើសកម្មភាពជាអ្នកសំរបសំរួល ដោយជួយសំរុះសំរួលក្នុងក្នុងការចរចារកច្រកចេញរវាងគណបក្សនានា ជាជាងធ្វើជាអាជ្ញាធរដែលចេញសេចក្តីសំរេចអារកាត់ទៅតាមច្បាប់
- កង្វះទំនុកចិត្តដែលបន្តនៅមានជាច្រើនចំពោះក្របខ័ណ្ឌស្ថាប័នរដ្ឋាភិបាលជាទូទៅ ជាពិសេសចំពោះ ប៉ូលីស និងតុលាការ ។

ការសិក្សាផ្តោតលើកំណែទំរង់ គជប ដោយយកធ្វើជាករណីសិក្សាពីការអភិវឌ្ឍន៍ស្ថាប័នពីឆ្នាំ១៩៩៨-២០០៣ ។ ដំណើរការកំណែទំរង់ និងបញ្ហានៅមានជាបន្ត ក្នុងការកសាង គជប ឱ្យទៅជាអ្នកគ្រប់គ្រងទំនាស់ដ៏មានអំណាច គឺមានពិភាក្សានៅ

---

[៧] តំណាង UNDP (2), មតិផ្ទាល់ខ្លួន, ៦ សីហា ២០០៣ ។

[៨] Guillermo O’Donnell, “Illusions About Democratic Consolidation.” Journal of Democracy 7.2 (1996): 36.

ខាងក្រោម. ចំណែកឯផលប៉ះពាល់ចំពោះលទ្ធផលបោះឆ្នោត មានពិភាក្សាក្នុងជំពូកទី៥ ។

នៅឆ្នាំ២០០៣ រចនាសម្ព័ន្ធ គជប បានផ្លាស់ប្តូរ គឺមានបង្កើតនីតិវិធីថ្មីសំរាប់ជ្រើសតាំងសមាជិក គជប គខប និង គឃប និងមានតាក់តែងរបៀបរបបថ្មីសំរាប់ជ្រើសរើសគណៈកម្មាធិការនានា ។ តាមមតិជាទូទៅនៅឆ្នាំ១៩៩៨ ក្នុងមជ្ឈដ្ឋានអ្នកនយោបាយ និងសង្គមស៊ីវិល ដូចដែលការសិក្សារបស់ វិបសអ ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨ បានរកឃើញ, គជប នៅពេលនោះ គឺមានជំហរប្រកាប់បក្សពួកមិនមែនអព្យាក្រឹត្យទេ ហើយរឿងនេះជាកត្តាសំខាន់ដែលកាត់បន្ថយសមត្ថភាព គជប ក្នុងការគ្រប់គ្រងទំនាស់ ដូច្នេះកំណែទំរង់ស្ថាប័ននេះមានអត្ថន័យខ្លាំងណាស់ ។ ទំនាស់ជុំវិញ គជប និងស្ថាប័នក្រោមឱវាទគឺ គខប និង គឃប ផ្តោតលើបញ្ហាទាំង៣: ការមិនប្រកាន់បក្សពួក ស្វ័យភាព និងសមត្ថភាពបច្ចេកទេស ។ ចំពោះការបោះឆ្នោតឆ្នាំ១៩៩៨ មានការទិតៀនជាច្រើនថា គជប គ្រប់គ្រងដោយពួកបុគ្គលដែលមានចំណងទាក់ទងជាមួយគណបក្សកាន់អំណាច គជប ខ្វះសិទ្ធិអំណាចត្រួតត្រាលើដំណើរការបោះឆ្នោត និងទទួលយកជំនួយ និងការណែនាំមិនសមរម្យអំពីអាជ្ញាធរមជ្ឈិម និងមូលដ្ឋាន, និងមានសមត្ថភាពបច្ចេកទេស ខ្សោយដោយខ្វះខាតធនធានមនុស្ស និងសំភារៈ ។ ដើម្បីបង្កើនសិទ្ធិអំណាចឱ្យ គជប ក្នុងការគ្រប់គ្រងទំនាស់បោះឆ្នោត កំណែទំរង់ត្រូវព្យាយាមដោះស្រាយបញ្ហាទាំងនេះ ។

### *២.២.១ កំណែទំរង់លើសមាជិក គជប*

តាមវិសោធនកម្មឆ្នាំ២០០២ នៃច្បាប់បោះឆ្នោត, ប្រតិបត្តិការ និងសមាសភាព គជប បានផ្លាស់ប្តូរច្រើនយ៉ាង ។ ចំនួនសមាជិក គជប បានកាត់បន្ថយពី ១១នាក់ មក ៥នាក់ គឺមានការដកចេញនូវសមាជិកមួយចំនួនដែលការជ្រើសតាំងបង្កការប្រទាំងប្រទើសនៅឆ្នាំ១៩៩៨ ។ វិសោធនកម្មបានធ្វើឱ្យសាមញ្ញដល់នីតិវិធី និងមានទិសដៅកាត់សមាជិក គជប ចេញពីឋានៈជាតំណាងគណបក្សនយោបាយ ។ នៅឆ្នាំ១៩៩៨ សាមីជនមកចូលជាសមាជិក គជប ក្នុងឋានៈជាតំណាងគណបក្ស, ប៉ុន្តែនៅឆ្នាំ២០០៣ សមាជិក គជប ត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជនខ្មែរ ដែលមានសមត្ថភាពខាងនយោបាយ មានបទពិសោធន៏ការងារ និងមានកេរ្តិ៍ឈ្មោះល្អ[៩] ។ ដៃគូទាំងពីរក្នុងរដ្ឋាភិបាលគឺ CPP, និង FUNCINPEC ដែលបានរួបរួមគ្នាវិញ, បានចូលរួមជ្រើសតាំងសមាជិក គជប ថ្មី ។ សំណើជ្រើសតាំងសមាជិកថ្មី បានធ្វើឡើងដោយក្រសួងមហាផ្ទៃដែលដឹកនាំដោយសហរដ្ឋមន្ត្រីចេញមកពីគណបក្សទាំងពីរ និងអនុមតិដោយរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋមន្ត្រី ។

ប្រធាន គជប ក៏បានផ្លាស់ប្តូរដែរ ហើយគណៈកម្មការរៀបចំការបោះឆ្នោតកំរិតខេត្ត និងឃុំ ត្រូវបានជ្រើសរើសសាថ្មី ។ ច្បាប់បោះឆ្នោតធ្វើវិសោធនកម្ម បានបង្កើនចំនួនប្រភេទបុគ្គលដែលមិនអនុញ្ញាតឱ្យដាក់ពាក្យចូលបំរើការក្នុងគណៈកម្មការទាំងនេះ ។ ច្បាប់បោះឆ្នោតឆ្នាំ១៩៩៧ បានចែងថា កងទ័ព ប៉ូលីស មន្ត្រីខាងតុលាការ ព្រះសង្ឃ ប្រធានឃុំ និងអនុប្រធានឃុំ មិនអនុញ្ញាតឱ្យកាន់កាប់តួនាទីក្នុង គឃប ទេ ទោះបីបានលាឈប់ពីមុខតំណែងទាំងនេះហើយក្តី ។ ក្នុងច្បាប់ធ្វើវិសោធនកម្មមានបន្ថែមក្រុមមួយចំនួនទៀតទៅក្នុងបញ្ជីហាមឃាត់ មានជាអាទិ៍ អភិបាល/អភិបាលរងស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកគណៈកម្មការភូមិ ។ ក្នុងការជ្រើងតាំង គជប គខប និង គឃប, គជប បានកសាងលក្ខណៈវិនិច្ឆ័យគុណសម្បត្តិ ៣ សំរាប់ធ្វើការជ្រើសរើសៈ បទពិសោធន៏ គុណសម្បត្តិ និងលទ្ធផលនៃការធ្វើសំភាសន៏[១០] ។

ប៉ុន្តែមានការទិតៀនមួយចំនួនលើកំណែទំរង់ទាំងនេះ ។ ដំណើរការជ្រើសរើសសមាជិក គជប នៅតែជារឿងខ្វែងគំនិតគ្នា ដោយ NGOs និង គណបក្សនយោបាយមួយចំនួនបានជជែកវែកញែកថា ដំណើរការដែលឱ្យក្រសួងមហាផ្ទៃជ្រើសរើសសមាជិក គជប ធ្វើឱ្យខូចខាតដល់អព្យាក្រឹតភាពនៃដំណើរការ ។ ឧទាហរណ៏ ក្នុងពេលប្រជុំ COPCEL ដែលបានលើកពីកំណែទំរង់ទាំងនេះ តំណាងខាង SRP និង FUNCINPEC បានជជែកថា ការឱ្យក្រសួងមហាផ្ទៃទទួលបន្ទុកលើដំណើរការជ្រើសរើស

---

[៩] Law on Election of Members of the National Assembly, 2002, Art. 13.

[១០] NEC Regulations, §3.9

ធ្វើឱ្យការជ្រើសតាំង "បាត់បង់ឯករាជភាព និងអព្យាក្រឹតភាព"[១១] ។ តំណាង SRP ម្នាក់លើកឡើងថា ការកាត់បន្ថយចំនួនសមាជិកគ្មានប្រយោជន៍ទេ បើសិនដំណើរការជ្រើសរើសស្ថិតក្រោមការត្រួតត្រារបស់ក្រសួងមហាផ្ទៃ "ពីព្រោះយើងដឹងថាក្រសួងមហាផ្ទៃស្ថិតក្រោមការត្រួតត្រារបស់គណបក្សកាន់អំណាច"[១២] ។ SRP, COMFREL និងស្ថាប័នជាច្រើនទៀតលើកមតិថា គួរបង្កើតគណៈកម្មាធិការជ្រើសរើសមួយ ដែលមានតំណាងមកមកពីគណបក្សនយោបាយទាំងអស់ដែលមានអាសនៈនៅរដ្ឋសភា និងអ្នកទទួលការតែងតាំងពីព្រះមហាក្សត្រ ។

ម្យ៉ាងទៀត សេចក្តីសំរេចជ្រើសរើសសមាជិកឯករាជ្យ មិនយកតំណាងគណបក្សនយោបាយ ក៏ជាប្រភពវិវាទដែរ ។ ថ្វីបើក្រុមសង្គមស៊ីវិលនានាគាំទ្រការជ្រើសរើសសមាជិកឯករាជ្យក្តី ប៉ុន្តែ FUNCINPEC និង SRP ចង់បានរូបមន្តមួយដែលក្នុងនោះ គណបក្សនយោបាយមានអាសនៈនៅរដ្ឋសភា ដាក់ស្នើឡើងនូវសមាសភាពសមាជិក ។ រូបមន្តចុងក្រោយសំរាប់ជ្រើសសមាជិកឯករាជ្យនៃ គជប ដែលក្រសួងមហាផ្ទៃដាក់អនុវត្ត បានធ្វើឱ្យ FUNCINPEC ដែលជាសមាជិកមួយនៃរដ្ឋាភិបាលចំរុះ មានសិទ្ធិច្រើនឡើងក្នុងការបង្កើតស្ថាប័នបោះឆ្នោតនានា ប៉ុន្តែ SRP នៅតែមិនពេញចិត្ត ។ នៅខាងដើមយុទ្ធនាការឃោសនាបោះឆ្នោត មន្ត្រី SRP ម្នាក់មានមតិថា កំណែទំរង់ គជប ធ្វើឱ្យស្ថានភាពកាន់តែលំបាកឡើងសំរាប់ SRP:

> *"ក្នុង គជប លើកទី១ យើងមានសមាជិកម្នាក់ ក្នុងចំណោម ១១នាក់ ។ ក្នុង គជប លើកទី២ យើងគ្មានសមាជិកម្នាក់សោះក្នុងចំណោម ៥នាក់ ។ តើបែបណាប្រសើរជាង ។ មានសមាជិកម្នាក់ក្នុងចំណោម ១១នាក់ គឺមិនអាចមានឥទ្ធិពលទៅលើការធ្វើសេចក្តីសំរេចទេ ប៉ុន្តែយ៉ាងហោចណាស់យើងមានម្នាក់នៅខាងក្នុង ដូច្នេះយើងដឹងពីរបៀបធ្វើសេចក្តីសំរេចផ្សេងៗ ។ ក្នុង គជប កែទំរង់ថ្មី យើងគ្មានដឹងអ្វីសោះ"[១៣] ។*

ប៉ុន្តែសមាជិក គជប និយាយថា ពួកគេត្រូវបានជ្រើសជួលក្នុងលក្ខណៈជា "អ្នកវិជ្ជាជីវៈឯករាជ្យ" ធ្វើការស្របតាមច្បាប់:

> *"យើងអាចឯកភាពគ្នាបាន ពីព្រោះយើងមានមូលដ្ឋានរួម ហើយមូលដ្ឋានរួមនោះគឺច្បាប់"[១៤] ។*

ក្រុម NGOs ក្នុងនេះមានទាំងអង្គការឃ្លាំមើលការបោះឆ្នោតចំបង២ពីរគឺ COMFREL និង NICFEC ផង បានតវ៉ាថាដំណើរការជ្រើសរើសសមាជិក គជប ដោយក្រសួងមហាផ្ទៃ គ្មានតំលាភាព និងគ្មានដំណើរការពិគ្រោះយោបល់ទេ ហើយគេសន្និដ្ឋានថា "នៅមានបញ្ហាធ្ងន់ធ្ងរជាច្រើនទាក់ទិនលក្ខណៈវិនិច្ឆ័យ និងនីតិវិធីដែលបានប្រើប្រាស់ក្នុងដំណើរការជ្រើសរើស"[១៥] ។

ការតវ៉ាពីការលំអៀងខាងនយោបាយទាក់ទិននឹងគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត និងឃុំ នៅតែមានឮសួរជាបន្តទៀត ។ ការសិក្សារបស់ វិបសអ ពីការបោះឆ្នោតឆ្នាំ១៩៩៨ រកឃើញថា តួអង្គខាងនយោបាយជាច្រើនមានការបារម្ភ ដោយគណៈកម្មការរៀបចំការបោះឆ្នោតកំរិតមូលដ្ឋាន ត្រូវការការជួយឧបត្ថម្ភគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋានដែលអាចធ្វើឱ្យខូចខាតដល់ឯករាជភាព និងអព្យាក្រឹតភាពរបស់ខ្លួន ។ អង្គការឃ្លាំមើលការបោះឆ្នោត COMFREL បានទិតៀនទិដ្ឋភាពមួយចំនួននៃដំណើរការជ្រើសរើសឡើងវិញ ។ ទី១ COMFREL តវ៉ាថា ដំណើរការជ្រើសរើសមន្ត្រី គឃប ឡើងវិញ អនុវត្តមិនបានល្អ ខ្វះតំលាភាព និងផ្សព្វផ្សាយមិនបានទូលំទូលាយ ដែលនាំឱ្យចំនួនបេក្ខជនមកដាក់ពាក្យថយចុះអស់ ៥០% បើប្រៀបធៀបទៅនឹង

---

[១១] Thaom Bunsrun, FUNCINPEC, qtd in COPCEL minutes, 36th Conflict Prevention in Cambodian Elections (COPCEL) Meeting, 25 July 2002, trans. Sen Sina, 8

[១២] Meng Rita, SRP, qtd in COPCEL minutes, 36th Conflict Prevention in Cambodian Elections (COPCEL) Meeting, 25 July 2002, trans. Sen Sina, 7.

[១៣] SRP national representative (3), personal interview, Phnom Penh, 10 July 2003.

[១៤] NEC member (4), personal interview, Phnom Penh, 8 Oct 2003.

[១៥] COMFREL, "Annual Narrative Report for the Period 1st Jan-31st Dec 2002," Phnom Penh Mar 2003, 20.

ឆ្នាំ១៩៩៨ ។ ទី២ គេទិតៀនថា នីតិវិធីជ្រើសរើសឡើងវិញនេះ ជារឿយៗជ្រើសបានបុគ្គលដូចពីមុនដដែលៗ ជាពិសេសពួកប្រធាន គខប ដែលមាន ៨៣% ធ្លាប់បំរើការក្នុង គខប កាលពីឆ្នាំ១៩៩៨ បើតាមពតិមានពី COMFREL ។ COMFREL លើកពីការបារម្ភជាពិសេសមួយថា គខប កាលពីមុន មិនអាចត្រួតត្រាលើដំណើរការបោះឆ្នោត និងមិនអាចដាក់ទ័ណ្ឌកម្មអ្នកប្រព្រឹត្តល្មើសបានទេ ដូច្នេះការជ្រើសរើសបុគ្គលដដែលៗឡើងវិញ អាចនាំឱ្យមានកំហុសដូចមុនកើតឡើងទៀត ។ COMFREL លើកមតិថា:

> *"យើងទទួលស្គាល់ថា អតីតមន្ត្រី គខប មានសមត្ថភាពនិងបទពិសោធន៍ក្នុងដំណើរការបោះឆ្នោត ។ ប៉ុន្តែ ការបារម្ភរបស់យើង គឺលទ្ធផលការងាររបស់អតីតមន្ត្រី គខប ទាំងនេះ មិនបានផ្តល់ទំនុកចិត្តទេក្នុងការដោះស្រាយបណ្តឹងតវ៉ាពីការល្មើសច្បាប់/បទប្បញ្ញត្តិ និងនីតិវិធីនៃ គជប ។ ដោយឡែក មិនដែលមានដាក់ទោសទ័ណ្ឌអ្វីសោះចំពោះអ្នកធ្វើការគំរាមកំហែង បំភិតបំភ័យ ទិញសន្លឹកឆ្នោត ទោះបីមានភស្តុតាងគ្រប់គ្រាន់ និងមានឈ្មោះជនល្មើសក៏ដោយ"*[១៦] ។

ទី៣ COMFREL បានអះអាងថា ការជ្រើសរើស គខប នានា មានជាប់ទាក់ទងច្រើនណាស់នឹងគណបក្សនយោបាយក្នុងរដ្ឋាភិបាលចំរុះគឺ CPP និង FUNCINPEC ។ ពួកគេសន្និដ្ឋានថា ក្នុងចំណោមសមាជិក គខប ១២៦នាក់ ក្នុង ១៧ខេត្តដែលបានជ្រើសរើសឡើងវិញបន្ទាប់ពីធ្លាប់បានបំរើការពីមុនក្នុង គខប គឺមាន ៥៨% ជាប់ខ្សែរយៈជាមួយ CPP, ៣% ជាមួយ FUNCINPEC និង ២% ជាមួយ SRP ។ COMFREL បានអះអាងដែរថា ការស្រាវជ្រាវពីខ្សែរយៈរបស់សមាជិក គខប ជាទូទៅមានទាំងសមាជិកថ្មី និងសមាជិកជ្រើសរើសឡើងវិញ ក្នុង ១១ខេត្ត បានបង្ហាញថា ៧៩% ជាប់ខ្សែរយៈជាមួយ CPP, និង ២១% ជាមួយ FUNCINPEC ។ COMFREL បានកត់សំគាល់ជាបញ្ចប់ថា បទប្បញ្ញត្តិជាក់លាក់របស់ គជប សំដៅលើកទឹកចិត្តឱ្យមាននារីយ៉ាងហោចម្នាក់នៅក្នុង គខប នីមួយៗហាក់ដូចជាបរាជ័យ ព្រោះក្នុងចំណោម គខប ទាំងអស់ ២៤ គឺមាន ១៤ គខប ដែលគ្មានសមាជិកជានារី ហើយក៏រិតភាគរយនៃសមាជិកនារីគិតជាទូទៅថយចុះពី ៨% នៅឆ្នាំ១៩៩៨ មកនៅត្រឹម ៦% នៅឆ្នាំ២០០៣"[១៧] ។ ថ្វីបើមូលដ្ឋានដែល COMFREL បានប្រើប្រាស់ដើម្បីធ្វើការវាយតំលៃ ព្រមទាំងចងភ្ជាប់រឿងនេះទៅនឹងបញ្ហា "អព្យាក្រឹតភាព" នៃ គខប គឺមានតួអង្គជាច្រើនទៀតមិនឯកភាព ហើយសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ COMFREL ខ្លួនឯងក៏មិនច្បាស់លាស់ដែរក្តី, ក៏ការបារម្ភរបស់ COMFREL នេះមានអ្នកនិពន្ធជាច្រើនបានយកចុះផ្សាយបន្តក្នុងរបាយការណ៍មួយស្តីពីដំណើរការប្តឹងតវ៉ាក្នុងការបោះឆ្នោត ដែលចេញផ្សាយក្រោយពេលបោះឆ្នោត ដោយមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) ។ ក្រុមអ្នកនិពន្ធលើកឡើងថា:

> *"ការជ្រើសរើសនៅគ្រប់កំរិត គ្មានតំលាភាព យុត្តិធម៌ និងសមធម៌ទេ ។ រឿងនេះធ្វើឱ្យបាត់បង់ទំនុកចិត្ត ហើយប្រតិបត្តិការមិនអាចធ្វើបានល្អទេ"*[១៨] ។

អ្នកឆ្លើយសំភាសន៍ជាប្រធាន គខប ម្នាក់បានផ្តល់មតិពីការជ្រើសរើសរូបគាត់ផ្ទាល់:

> *"ពួកយើងត្រូវបានជ្រើសរើសផ្អែកតាមបទពិសោធន៍ ហើយនិងអ្នកមានចំណេះដឹងខ្ពស់ និងអ្នកមានប្រជាប្រិយភាពផងដែរ ។ ភាគច្រើនមានបទពិសោធន៍ ។ ប៉ុន្តែអ្នកគាំទ្រខ្លាំងដល់គណបក្សនយោបាយណាមួយ គេមិនយក*

---

[១៦] COMFREL, "Report on the Irregularities of Provincial Electoral Commission's Recruitment Procedures," press release, Phnom Penh, 23 May 2003.

[១៧] COMFREL, "Report on the Irregularities of Provincial Electoral Commission's Recruitment Procedures," press release, Phnom Penh, 23 May 2003.

[១៨] Sek Sophon , Community Legal Education of Cambodia, presentation, Workshop on the Process of Complaints Resolution in the 2003 Election, Phnom Penh, 9 Oct 2003.

*ទេ ។ តាមពិត គេយកអ្នកដែលគេស្គាល់-អ្នកធ្លាប់ធ្វើការនៅឆ្នាំ១៩៩៨ និង ២០០២- អ្នកដែលគេស្គាល់ ។ ហើយគេដឹងថា អ្នកនោះចូលគណបក្សនយោបាយ ឬក៏អត់"*[១៩] ។

នៅកំរិតឃុំ ក៏នៅមានការទិតៀនខ្លះដែរ ។ ឧទាហរណ៍ តំណាង COMFREL ម្នាក់នៅខេត្តកំពតមានមតិថា គឃបឆ្នាំ២០០៣ មានលក្ខណៈល្អច្រើនណាស់ជាងការបោះឆ្នោតមុនៗ និងលើកពីករណីមានជោគជ័យមួយចំនួនដែល គឃប អាចជួយសំរួលទំនាស់ដោយ "មិនបង្ខិតបង្ខំ" ។ ប៉ុន្តែគាត់បន្ថែមថា បញ្ហាបញ្ចូលរឿងនយោបាយ និងការបំភិតបំភ័យនៅមាននៅឡើយ:

*"ជាទូទៅ គឃប មានមនុស្ស ៥០% ដែលគាំទ្រ CPP... ប៉ុន្តែ ៣០% បានល្អជាងមុន ។ សមាជិក គឃប ភាគច្រើនជាគ្រូបង្រៀន ។ ប៉ុន្តែបញ្ហាចោទ គឺគ្រូបង្រៀនជារឿយៗខ្លាចមិនហ៊ានប្រឆាំងនឹង CPP ទេ ។ CPP អាចកាត់ប្រាក់ខែ អាចបង្ខំពួកគេឱ្យធ្វើអ្វីមួយ ។ ពួកគេមើលឃើញថាបានធ្វើខុស ប៉ុន្តែពួកគេខ្លាច ។ ភាគច្រើនមានឆន្ទៈល្អ ។ ពួកគេចង់ និយាយខ្លះដែរ ប៉ុន្តែខ្លាច ។ រឿងនេះផុសចេញពីសង្គមយើង ។ គឃប ប្រហែល ៥០% គឺល្អ ។ ក្នុង ៥០% នេះ ប្រហែល ៣០% មិនខ្លាចទេ"*[២០] ។

ជាទូទៅ COMFREL និង NICFEC បានទិតៀនពីតួនាទីសំរបសំរួលរបស់ គឃប ដោយលើកឡើងថា:

*"ដំណើរការដោះស្រាយនៅកំរិតភូមិ ហាក់ដូចខ្វះស្តង់ដារមួយ ហើយមានសេចក្តីរាយការណ៍ថា អ្នកតវ៉ាតែងត្រូវបានលើកទឹកចិត្តឱ្យឈប់ ឬបោះបង់ចោលការតវ៉ារបស់ខ្លួនជានិច្ច"*[២១] ។

ការអះអាងថា សមាជិក គឃប ស្ថិតក្រោមការគាបសង្កត់ពីគណបក្សនយោបាយ (ដូចជាការចោទថា សមាជិក គឃប ជាអ្នកគាំទ្រគណបក្សនយោបាយ) ធ្វើឱ្យខូចខាតទំនុកចិត្តចំពោះ គឃប ។ បញ្ហាអព្យាក្រឹតភាពនៃ គឃប នៅបន្តឆេះឆំរហូតដល់ក្រោយពេលបោះឆ្នោត ហើយបន្ទាប់មកគណបក្សចាញ់ឆ្នោត បានយកមកតវ៉ាថាជាកំហុសងាប់រស់ក្នុងដំនើរការបោះឆ្នោត ។

### *២.២.២ ការលើកកំពស់តំលាភាព និងលទ្ធភាពអាចប្រស្រ័យទាក់ទងបាន*

ក្រោយពីជ្រើសតាំងហើយ សមាជិកម្នាក់ៗត្រូវបានរំពឹងថា នឹងបំរើការងារក្នុងសមត្ថកិច្ចឯករាជ្យ មិនមែនតំណាងឱ្យផល ប្រយោជន៍ខាងនយោបាយទេ ។ មន្ត្រីបោះឆ្នោតទាំងអស់បានស្បថប្រកាន់អព្យាក្រឹតភាព អហិង្សា និងប្តេជ្ញាផ្តល់សេវាដ៏ល្អដល់ អ្នកបោះឆ្នោត តាមរយៈក្រមសីលធម៌ថ្មីមួយដែល គជប បានតាក់តែងសំរាប់មន្ត្រីបោះឆ្នោត ។ សេចក្តីសំរេចនៅថ្នាក់មជ្ឈិម ធ្វើឡើងតាមកុងសង់ស៊ុស, ហើយប្រព័ន្ធពីមុនដែលសមាជិក គជប ម្នាក់ៗ ទទួលខុសត្រូវលើទិដ្ឋភាពខុសៗគ្នានៃការបោះឆ្នោត ត្រូវបានជំនួសដោយប្រព័ន្ធមួយដែលសមាជិកមានការទទួលខុសត្រូវតាមតំបន់ភូមិសាស្ត្រវិញ ។ វិធីធ្វើប្រតិបត្តិការនៃ គឃប មានចែងលំអិតជាងក្នុងច្បាប់បោះឆ្នោតធ្វើវិសោធនកម្ម និងក្នុងវិធាន និងនីតិវិធីដែល គជប កសាងឡើងដោយខ្លួនឯង ។

ក្រៅពីការកែទំរង់រចនាសម្ព័ន្ធ គជប, គជប បានធ្វើកំណែទំរង់ដែរលើរបៀបរបបធ្វើការងារ ដើម្បីបង្កើនតំលាភាព និងលទ្ធភាពអាចប្រស្រ័យទាក់ទងបានរបស់ខ្លួន នៅក្នុងការយល់ឃើញរបស់គណបក្ស និងអង្គការឃ្លាំមើលការបោះឆ្នោតនានា ។ គជប បានអនុវត្តដំណើរការពិគ្រោះយោបល់មួយក្នុងការតាក់តែងបទប្បញ្ញត្តិនានា ។ ចាប់ពីខែមករា ២០០៣ មក មានការប្រជុំប្រចាំខែជាមួយគណបក្សនយោបាយ NGOs និងអង្គការខាងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពិភាក្សាពីបញ្ហាទាក់ទិននឹងការបោះឆ្នោត ។

---

[១៩] PEC Chief (5), Kompong Cham, personal interview, Kompong Cham, 9 July 2003.

[២០] COMFREL provincial representative (6), Kampot Province, personal interview, 16 July 2003.

[២១] COMFREL-NICFEC, “Pre-Election Assessment Joint Statement,” Phnom Penh, 25 July 2003.

លើសពីនេះទៀត គណបក្សនយោបាយ NGOs និងអង្គការខាងប្រព័ន្ធផ្សព្វផ្សាយ អាចស្នើសុំការជួបម្នាក់ឯងជាមួយ គជប ហើយ គណបក្សនយោបាយ និង NGOs ក៏បានប្រើប្រាស់ឱកាសល្អទាំងនេះ ។ លំនាំនេះមានធ្វើដូចគ្នានៅកំរិតខេត្ត និងឃុំ ។ គជប បានចូលពាក់ព័ន្ធផងដែរ ក្នុងគំនិតផ្តួចផ្តើមនានារបស់អង្គការសង្គមស៊ីវិល ជាពិសេសតាមរយៈការចូលរួមយ៉ាងទៀងទាត់របស់អគ្គលេខាធិការក្នុងការប្រជុំប្រចាំខែ COPCEL ។

ទោះបីអ្នកទិតៀន គជប ក៏បានទទួលស្គាល់ដែរថា តារាងពេលជួបប្រជុំរបស់ គជប មានប្រយោជន៍ ហើយ គជប បានខិតខំដោះស្រាយដោយជំហរកសាងនូវបញ្ហានានាដែលមានលើកឡើង ។ ឧទាហរណ៍ SRP មានការជួបពីខាងដើមមួយជាមួយ គជប ដើម្បីលើកពីបញ្ហាទាក់ទិននឹងការចុះបញ្ជីអ្នកបោះឆ្នោត ។ ការចាត់ចែងខាងបច្ចេកទេស ដើម្បីថតរូបអ្នកបោះឆ្នោតសំរាប់ធ្វើប័ណ្ណបោះឆ្នោត បានផ្លាស់ប្តូរ ពីព្រោះកាលពីមុនប្រើប្រដាប់ថត Polaroid យករូបបានភ្លាម តែក្នុងប្រព័ន្ធថ្មីប្រើប្រដាប់ថតប្រើហ្វីលដែលត្រូវយកទៅលាង និងផ្តិត ។ ប៉ុន្តែតាម SRP មានហ្វីលជាច្រើនត្រូវខូច ហើយក្នុងកន្លែងខ្លះគេប្រាប់ថា អ្នកបោះឆ្នោតត្រូវមកម្តងទៀតដោយយករូបថតមកផង បើសិនចង់បានប័ណ្ណបោះឆ្នោត ។ SRP តវ៉ាថា រឿងនេះបង្កើតបន្ទុកហិរញ្ញវត្ថុមិនសមរម្យលើអ្នកបោះឆ្នោត ហើយជាការគេចវេសរបស់ គជប ពីការទទួលខុសត្រូវរបស់ខ្លួនក្នុងការផ្តល់ប័ណ្ណបោះឆ្នោត ។ ក្រោយការជួបជាមួយ គជប តំណាង SRP ម្នាក់លើកឡើងថា:

> *"ខ្ញុំសូមបញ្ជាក់ថា ក្រោយពីយើងបានលើកបង្ហាញជូន ឯ.ឧ អ៊ឹម សួស្តី. ឯ.ឧ បានឆ្លើយតបភ្លាម ។ ខ្ញុំមានការចាប់អារម្មណ៍ខ្លាំងណាស់ពីវិធីឆ្លើយតបនេះ -ឯកឧត្តមបានធ្វើសេចក្តីថ្លែងការណ៍..."*[២២] ។

ប៉ុន្តែអ្នកតំណាងបានអះអាងជាបន្តថា:

> *"បញ្ហាចោទគឺដូច ឯ.ឧ អ៊ឹម សួស្តី ប្រាប់យើង -ឯកឧត្តមនិយាយត្រង់ទៅត្រង់មក បើគិតជាបុគ្គល -ឯកឧត្តមជាមនុស្សល្អ ស្រួលធ្វើការជាមួយ- -ឯកឧត្តមចង់បានអ្វីដែលល្អ ប៉ុន្តែពិបាកទទួលបានកិច្ចសហប្រតិបត្តិការនៅកំរិតមូលដ្ឋាន ។ ឧទាហរណ៍ បើសិនប្រធានភូមិគំរាមកំហែងអ្នកភូមិ -ឯកឧត្តមសារភាពថា ឯកឧត្តមមិនអាចធ្វើឱ្យអ្នកទាំងនោះអនុវត្តស្របតាមច្បាប់បោះឆ្នោតបានទេ"* ។

ចំណាប់អារម្មណ៍នេះ ដែលថា គជប មានបំណងល្អ ប៉ុន្តែត្រូវបាត់សិទ្ធិអំណាចក្នុងកំរិតណាមួយ ដោយសារផលប្រយោជន៍ខាងនយោបាយនៅកំរិតមូលដ្ឋាន គឺជាការផ្លាស់ប្តូរពីចំណាប់អារម្មណ៍ប្រឆាំងដែលថា គជប ជាឧបករណ៍បំរើគណបក្សកាន់អំណាចនាពេលបោះឆ្នោតឆ្នាំ១៩៩៨ ។ តំណាង SRP មួយទៀត មានមតិប្រហែលគ្នា ស្តីពីជំហរ គជប ចំពោះ CPP នៅកំរិតជាតិ:

> *"ឯ.ឧ ទេព នីថា មានលក្ខណៈសាមញ្ញ និងងាយប្រស្រ័យទាក់ទងណាស់ -ឯកឧត្តមឆ្លើយសំនួរទាំងអស់របស់អ្នក ប៉ុន្តែក្នុងរង្វង់មួយមានកំរិត ។ នោះគឺរង្វង់កំណត់ដោយក្រុម ដោយ ឯ.ឧ អ៊ឹម សួស្តី... បើខ្ញុំសួរអ្វីមួយដែលឯកឧត្តមឆ្លើយមិនបាន ឯកឧត្តមអាចនិយាយថា ខ្ញុំទទួលយកសំណួររបស់លោក ហើយដាក់ជូនថ្នាក់លើខ្ញុំ ហើយបន្ទាប់មកផ្តល់ចំលើយ ។ យ៉ាងហោចណាស់ ឯកឧត្តមអាចធ្វើរឿងនេះបាន ។ ជារឿយៗ តំណាងនានារបស់ក្រសួង អង្គុយស្ងៀមស្ងាត់ គ្មានលើកមតិអ្វីទេ... ជួនកាលពួកគេមិនមកតែម្តង... គជប ងាយប្រស្រ័យទាក់ទងជាង ប៉ុន្តែ គជប ក៏មានធ្វើរឿងមិនល្អដែរ"*[២៣] ។

ដោយឡែក មានការយល់ឃើញជាទូទៅថា ស្ថានភាព គជប ត្រូវចុះខ្សោយដោយសារអំណាចរបស់ក្រសួងមហាផ្ទៃ

---

[២២] SRP national representative (3), personal interview, Phnom Penh, 10 July 2003.

[២៣] SRP national representative (7), personal interview, Phnom Penh, 7 Aug 2003.

ដែលអ្នកនយោបាយខាងគណបក្សជំទាស់យល់ឃើញជាទូទៅថា ស្ថិតក្រោមការត្រួតត្រារបស់គណបក្សកាន់អំណាច ។ កាលណា គជប ត្រូវការកិច្ចសហប្រតិបត្តិការរបស់ក្រសួងមហាផ្ទៃ ដើម្បីធានាឱ្យមានការបោះឆ្នោតដោយយុត្តិធម៌ តួអង្គខាងនយោបាយមួយចំនួនមានការសង្ស័យអំពីលទ្ធផល ។ ឧទាហរណ៍ អ្នកឆ្លើយសំភាសន៍ខាង NGOs មួយចំនួនអះអាងថា អំពើហិង្សាខាងនយោបាយនៅតែជាបញ្ហាធ្ងន់ធ្ងរមួយដែលប៉ះពាល់ដល់ភាពសុចរិតនៃការបោះឆ្នោត ប៉ុន្តែ ក្រសួងមហាផ្ទៃបានរារាំងរាល់កិច្ចពិភាក្សាពីរឿងនេះ រវាងតួអង្គខាងនយោបាយ និង គជប ដោយគ្រាន់តែប្រកាសថា ករណីឃាតកម្មមួយចំនួនដែលអាចជារឿងនយោបាយ គឺសុទ្ធតែជាបទឧក្រិដ្ឋធម្មតាៗ ។ NGOs មួយចំនួនខិតខំជំរុញ គជប ឱ្យធ្វើការសន្មតជាដំបូងថា ឃាតកម្មលើសមាជិកគណបក្សនយោបាយគឺជាអំពើខាងនយោបាយ លើកលែងតែមានភស្តុតាងបញ្ជាក់ផ្ទុយ ប៉ុន្តែរឿងនេះមិនបានជោគជ័យទេ ។ ដោយសារជំហរផ្ទុយគ្នាក្នុងបញ្ហានេះ គេអាចដោះស្រាយបានតិចតួចណាស់នូវបញ្ហាមិនទុកចិត្ត និងការស្អប់គ្នាដែលផុសចេញពីអំពើហិង្សាខាងនយោបាយ ។

គឃបឃ មានធ្វើការប្រជុំប្រចាំសប្តាហ៍សំរាប់តំណាងគណបក្សនយោបាយទាំងអស់ ក្នុងឃុំនានាដែលយើងបានចុះសិក្សា ហើយឃើញមានគេចូលរួមយ៉ាងច្រើន (សូមអានជំពូក៣) ។ ប៉ុន្តែក៏មានការរិះគន់ពីរបៀបដំណើរការប្រជុំទាំងនេះដែរ ។ អ្នកសង្កេតការណ៍បោះឆ្នោត និងសមាជិកគណបក្សជំទាស់ បានជជែកវែកញែកថា វិធីគ្រប់គ្រងទំនាស់តាមបែបសំរុះសំរួលដែលប្រើក្នុងការប្រជុំប្រចាំសប្តាហ៍នេះ ជារឿយៗវាឆ្លុះបញ្ចាំងពីបរាជ័យនៃ គឃប ក្នុងការអនុវត្តសិទ្ធិអំណាចទៅលើដំណើរការបោះឆ្នោត ។ តាមរយៈដំណើរការសំរុះសំរួល គឃប លើកទឹកចិត្តគណបក្សនយោបាយឱ្យរកដំណោះស្រាយសំរុះសំរួលគ្នា ចំពោះទំនាស់ផ្សេងៗដែលផុសឡើងក្នុងការបោះឆ្នោត ដើម្បីរក្សាសន្តិភាព និងសណ្តាប់ធ្នាប់នៅក្នុងឃុំ ។ ប៉ុន្តែអ្នកសង្កេតការណ៍មួយចំនួនជជែកថា ដំណោះស្រាយបែបនេះមិនសមស្របទេសំរាប់ករណីរំលោភច្បាប់បោះឆ្នោតធ្ងន់ធ្ងរ ។ តំណាង COMFREL ម្នាក់លើកឡើងថា "គជប ផ្តោតខ្លាំងពេកលើក្រមសីលធម៌ ប៉ុន្តែគេត្រូវអនុវត្តច្បាប់ផងដែរ"[២៤] ។

ការប្រកាន់យកតួនាទីសំរុះសំរួលបែបនេះ គឃប លើកទឹកចិត្តគណបក្សនានាឱ្យមានការយល់ព្រមដោយខ្លួនឯងលើរឿងទំនាស់ផ្សេងៗ ប៉ុន្តែវាបានន័យថា គឃប ប្រកាន់ជំហរជាអ្នកសំរុះសំរួលក្នុងការចរចាគ្នាខាងនយោបាយ មិនមែនជាអ្នកសំរេចអាជ្ញាកាត់ជាផ្លូវការលើវិវាទទេ ។ អ្នកសង្កេតការណ៍មួយចំនួនជជែកថា នៅពេលមានសកម្មភាពឧក្រិដ្ឋកើតឡើង វាមិនសមស្របទេដែល គជប អនុញ្ញាតឱ្យមានដំណោះស្រាយកើតចេញពីលទ្ធផលនៃការតថ្លៃគ្នា រវាងគណបក្សធំៗ ។ ក្នុងករណីមានការប៉ះពាល់ដល់ច្បាប់ គជប ត្រូវតែប្រើសិទ្ធិអំណាចរបស់ខ្លួនទៅលើគណបក្ស ។

### *២.២.៣ ការលើកកំពស់សមត្ថភាពបច្ចេកទេស*

នៅកំរិតជាតិ លទ្ធផលការងារ គជប មានប្រសិទ្ធភាពល្អជាងកាលពីឆ្នាំ១៩៩៨ បើតាមមតិអ្នកឆ្លើយសំភាសន៍សំរាប់ការសិក្សានេះ ។ ប៉ុន្តែនៅកំរិតមូលដ្ឋានវិញ លទ្ធផលនេះទទួលបានមិនសូវខ្លាំងក្លាទេ ។ ការវាយតំលៃរបស់ គជប លើការងាររបស់ខ្លួនផ្ទាល់ ទាមទារឱ្យយកចិត្តទុកដាក់ថែមទៀតដល់ការបណ្តុះបណ្តាលបុគ្គលិក និងពង្រឹងរបៀបរបបត្រួតពិនិត្យ ដើម្បីតាមដានការងាររបស់ពួកគេ[២៥] ។ តំណាងជាន់ខ្ពស់ម្នាក់នៃនាយកដ្ឋានបណ្តុះបណ្តាលនិងពត៌មាននៃ គជប បានលើកឡើងថា ការបណ្តុះបណ្តាលនៅឆ្នាំ២០០៣ ធ្វើបានល្អជាងឆ្នាំ១៩៩៨ ។ គាត់និយាយថា មានរៀបចំឯកសារបានច្រើនជាង និងលំអិតជាងស្តីពីទិដ្ឋភាពជាក់លាក់នានានៃការងារ ។ ប៉ុន្តែ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) បានរិះគន់សៀវភៅណែនាំដែលផ្ញើឱ្យ គខប គឃប និងមន្ត្រីបោះឆ្នោតថា មានខ្លឹមសារមិនស៊ីគ្នា ពិបាកយល់ និងមានឧទាហរណ៍ជាក់ស្តែងតិចពេកសំរាប់ជួយបំភ្លឺ

---

[២៤] COMFREL national representative (1), personal interview, Phnom Penh, 6 Aug 2003.

[២៥] Tep Nytha, NEC, presentation, Workshop on the Performance of the NEC in Implementing the 2003 National Elections, Sihanoukville, 3 Oct. 2003.

អំពីដំណើរការ ។ CLEC លើកឡើងថា មានបញ្ហាច្រើនជាងនៅកំរិតមូលដ្ឋាន ហើយក្នុង ២០ខេត្តដែល CLEC បានសិក្សា មាន ៦ខេត្តដែលសមាជិកជាបុគ្គលិកនៃ គខប រាយការណ៍ថា បានទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់[២៦] ។ តំណាង គជប មើលឃើញថា ការលំបាកផុសចេញជាពិសេសពីកង្វះបទពិសោធន៍ និងសមត្ថភាពមិនដូចគ្នានៃក្រុមប្រឹក្សាឃុំ ដែលធ្វើឱ្យការចុះបញ្ជីពិបាកខ្លាំងជាងឆ្នាំ១៩៩៨ ។ អ្នកតំណាងបន្ថែមថា កង្វះពេលវេលានិងធនធាន ពិសេសនៅកំរិត គឃប បានបង្កបញ្ហាឡើង ។ កង្វះថវិកាបង់ឱ្យមន្ត្រី គឃប ធ្វើឱ្យគេមិនអាចជ្រើសអ្នកមានកំរិតអប់រំល្អបានទេ ហើយវិធាននិងបទប្បញ្ញត្តិនានាដែលអនុម័តចេញយឺតយ៉ាវ ព្រមទាំងភាពដាច់ស្រយាលនៃឃុំមួយចំនួន មិនអនុញ្ញាតឱ្យគេធ្វើការបណ្តុះបណ្តាលបានសព្វគ្រប់ល្អទេ[២៧] ។

គឃប ទទួលខុសត្រូវផងដែរលើការផ្សព្វផ្សាយពត៌មានពី គជប ទៅដល់គណបក្សនយោបាយ និងតួអង្គខាងបោះឆ្នោតផ្សេងៗទៀត ជាពិសេសបទបញ្ជា និងការចាត់ចែងផ្សេងៗសំរាប់ការឃោសនា និងការបោះឆ្នោត ។ ក្នុងវគ្គសិក្សាមួយដែលយើងបានសង្កេតមើលនៅឃុំត្នោត ស្រុកបាទី ខេត្តតាកែវ ការបណ្តុះបណ្តាលធ្វើឡើងដោយប្រធាន គឃប អានបញ្ជីបទប្បញ្ញត្តិ គជប យ៉ាងវែងមួយ ហើយភាគីពាក់ព័ន្ធនានាអង្គុយស្តាប់ ។ នៅចុងបញ្ចប់ ប្រធាន គឃប សួរថាតើមានសំណួរអ្វីទេ ហើយគ្មានអ្នកណាសួរអ្វីសោះ ។ ថ្វីបើអ្នកស្តាប់ហាក់ដូចយកចិត្តទុកដាក់ល្អ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវគិតថា វិធីបណ្តុះបណ្តាលនេះប្រហែលមិនអាចធ្វើឱ្យយល់ដឹងបានច្បាស់លាស់ពីលក្ខណៈស្មុគស្មាញនៃដំណើរការទេ[២៨] ។

### ២.២.៤ ការពិនិត្យត្រួសៗពីទំនាស់លើ គជប ក្នុងឆ្នាំ២០០៣

ធៀបនឹងឆ្នាំ១៩៩៨ គជប រៀបចំបានល្អជាង ងាយប្រស្រ័យទាក់ទងជាង មានភារកិច្ច និងនីតិវិធីកំណត់បានច្បាស់ជាងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិ ប៉ុន្តែនៅតែមានបញ្ហា ។ ដោយឡែក NGOs និង SRP នៅតែមើលឃើញថា សមាជិក គជប ប្រកាន់បក្សពួក ។ NGOs គិតថា ការជ្រើសរើស គខប ឡើងវិញ បានធ្វើឡើងតាមបែបបទដែលធានាថា មនុស្សមុខដដែលៗបានចូលវិញ និងដែលបង្កើតជំហរប្រឈមគ្នារវាងគណបក្សនយោបាយ ។ មានការសន្មតថា ការជ្រើសរើសមនុស្សដែលជាប់ខ្សែរយៈជាមួយគណបក្សនយោបាយ នឹងនាំឱ្យបែបបទអនុវត្តការងារមានលក្ខណៈលំអៀង ។ ភាពទន់ខ្សោយនៃ គជប នៅចំពោះមុខស្ថាប័នរដ្ឋដ៏មានអំណាចដូចជា ក្រសួងមហាផ្ទៃជាដើម ត្រូវគេមើលឃើញថាជាចំណុចខ្សោយដ៏ធំមួយ ។ ទំនាស់ស្តីពីប្រព័ន្ធផ្សព្វផ្សាយក៏បានបញ្ជាក់លើចំណុចនេះដែរ ។ ម្យ៉ាងទៀត ថ្វីបើ គជប គខប និង គឃប មានអាណត្តិច្បាស់លាស់ដើម្បីអនុវត្តសិទ្ធិអំណាចទៅលើបុគ្គល ឬស្ថាប័ន និងដាក់ពិន័យចំពោះការរំលោភច្បាប់បោះឆ្នោតក្តី ប៉ុន្តែស្ថាប័នទាំងបីកំរប្រើសិទ្ធិអំណាចនេះណាស់ ដោយព្យាយាមរកដំណោះស្រាយតាមការសំរុះសំរួលតថ្លៃគ្នាវិញ ដែលជារឿយៗបានទុកឱ្យភាគីអ្នកឈ្លានពានឱ្យមានអំណាចក្នុងដៃដដែល ។

បញ្ហាដែល គជប ជួបប្រទះ បានឆ្លុះបញ្ចាំងភាពទន់ខ្សោយបីខាងស្ថាប័នដូចមានសង្ខេបនៅខាងលើ ។ វិវាទដែលមានជាបន្តស្តីពីអព្យាក្រឹតភាពរបស់ពួកសមាជិក បានឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍ជាបន្តថា ចំណូលចិត្តខាងនយោបាយរបស់បុគ្គល បង្កឱ្យមានលំអៀងនៅក្នុងការអនុវត្តន៍ភារកិច្ចជាផ្លូវការ ។ នៅមានការមិនទុកចិត្តរបស់តួអង្គអ្នកនយោបាយខាងជំទាស់ និង NGOs ជាច្រើនចំពោះស្ថាប័នរដ្ឋជាទូទៅ ជាពិសេសក្រសួងមហាផ្ទៃ តុលាការ និងប៉ូលីស ដែលធ្វើឱ្យកិច្ចសហប្រតិបត្តិការរបស់ គជប ជាមួយអ្នកទាំងនេះមានចោទបញ្ហា ជាពិសេសក្នុងរឿងអំពើហិង្សាខាងនយោបាយ ។ ម្យ៉ាងទៀត គជប មានទិន្នាការធ្វើជាអ្នកសំរុះសំរួល ជាជាងអ្នកសំរេចអាការកាត់ជាផ្លូវការលើទំនាស់ផ្សេងៗ ធ្វើឱ្យអំណាចនៅតែជាធនធានមួយសំរាប់ឱ្យ

---

[២៦] មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ "ការអនុវត្តន៍ដំណើរការប្តឹងតវ៉ា នៅក្នុងពេលបោះឆ្នោតជ្រើសរើសរដ្ឋសភាជាតិឆ្នាំ២០០៣" ពង្រាង នៅភ្នំពេញ ថ្ងៃ០៩ តុលា ២០០៣ ។

[២៧] NEC representative (8), personal interview, Phnom Penh, 6 Oct 2003.

[២៨] ការសង្កេតរបស់ក្រុមស្រាវជ្រាវ ឃុំត្នោត ១៥ កក្កដា ២០០៣ ។

គណបក្សនយោបាយធ្វើការតថ្លៃ គឺមិនមែនសំរាប់ឱ្យ គជប ប្រើប្រាស់សិទ្ធិអំណាចតាមច្បាប់របស់ខ្លួនទៅលើដំណើរការបោះឆ្នោតនោះទេ ។ កត្តាទាំងអស់នេះ បានជះឥទ្ធិពលទៅលើ គជប ដែលបានកែទំរង់ហើយ ដើម្បីគ្រប់គ្រងទំនាស់ឱ្យបានជោគជ័យនៅក្នុងរយៈពេលបោះឆ្នោត ។

## ២.៣ ការតស៊ូមតិរបស់សង្គមស៊ីវិល

ដូចបានបញ្ជាក់ខាងលើ របាយការណ៍ វបសអ លើការបោះឆ្នោតឆ្នាំ១៩៩៨ បានរកឃើញថា ភាពទន់ខ្សោយខាងស្ថាប័ន និងកង្វះសហគមន៍នយោបាយ គឺជាប្រភពសំខាន់នៃបញ្ហានានាក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ។ ការពិនិត្យឡើងវិញលើការវិវត្តន៍ខាងនយោបាយតាំងពីឆ្នាំ១៩៩៨ បានបង្ហាញថា កម្មវិធីតស៊ូមតិជាច្រើនរបស់សង្គមស៊ីវិលបានផុសឡើង ដើម្បីជួយដោះស្រាយបញ្ហាទាំងនេះ ។ បណ្តាញឃ្លាំមើលការបោះឆ្នោតបីគឺ COFFEL, COMFREL, និង NICFEC បានដឹកនាំការតស៊ូមតិលើបញ្ហាក្របខ័ណ្ឌច្បាប់ និងស្ថាប័ន សំរាប់ការបោះឆ្នោតនៅកម្ពុជា ។ ចាប់ពីឆ្នាំ១៩៩៩ បណ្តាញទាំងនេះរៀបចំការពិគ្រោះយោបល់ជាសាធារណៈយ៉ាងធំទូលាយក្នុងទូទាំងប្រទេសកម្ពុជា ដើម្បីវាស់ស្ទង់ចំណាប់អារម្មណ៍របស់សាធារណជន អំពីក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលមាននៅឆ្នាំ១៩៩៨ ។ ផ្អែកលើលទ្ធផលនៃការពិគ្រោះយោបល់ បណ្តាញទាំង៣ បានចាប់ផ្តើមកម្មវិធីតស៊ូមតិរួមគ្នាមួយនៅឆ្នាំ២០០០ ទាមទារកំណែទំរង់ក្នុងវិស័យ ៣ ចំបងៗ: សមាសភាព គជប, កិរិតចូលរួមរបស់បេក្ខនារីសំរាប់មុខតំណែងខាងនយោបាយ និងការឈានទៅកាន់ប្រព័ន្ធបោះឆ្នោតឯកត្តនាម មិនមែនប្រព័ន្ធសមាមាត្រទេសំរាប់ការបោះឆ្នោតឃុំ ។ កំណែទំរង់ទាំងនេះមានគោលដៅបង្កើនភាពពេញលក្ខណៈច្បាប់នៃស្ថាប័នបោះឆ្នោតនានា ធ្វើឱ្យស្ថាប័នទាំងនេះឃ្លាតឆ្ងាយពីផលប្រយោជន៍តាមក្រុម/គណបក្សនយោបាយ ហើយក្លាយជាតំណាងកាន់តែល្អនៃសហគមន៍នយោបាយទាំងមូល ។ អង្គការឃ្លាំមើលការបោះឆ្នោត (EMOs) រំពឹងថា តាមមធ្យោបាយនេះ នឹងមានកំណើនសមត្ថភាពនៃស្ថាប័នបោះឆ្នោតនានា សំរាប់គ្រប់គ្រងទំនាស់ដែលផុសចេញពីកង្វះទំនុកចិត្តគ្នារវាងតួអង្គខាងនយោបាយ និងសំរេចបានលទ្ធផលបោះឆ្នោតមួយដែលគេអាចទទួលយកបានជាសាកល ។

កំណែទំរង់ គជប បានកើតមានជាក់ស្តែង ប៉ុន្តែរដ្ឋាភិបាលមិនបានទទួលយកចំណុចផ្សេងទៀតក្នុងកម្មវិធីតស៊ូមតិទេ គឺបានន័យថា នៅមានគំលាតចំណាស់រវាង EMOs និងរដ្ឋាភិបាល ក្នុងការយល់ឃើញពីវិធីត្រូវកែលំអការគ្រប់គ្រងទំនាស់ និងគុណភាពនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ EMOs ក៏មិនពេញចិត្តដែរនឹងផែនការកែទំរង់ គជប ដែលទុកអំណាចឱ្យក្រសួងមហាផ្ទៃជ្រើសរើសបេក្ខជន ។ EMOs និងគណបក្សជំទាស់ បានតស៊ូមតិឱ្យមានការបង្កើតគណៈកម្មាធិការជ្រើសរើសឯករាជ្យមួយសំរាប់ធ្វើការជ្រើសរើសបេក្ខជន ។

ក្រៅពីកម្មវិធីតស៊ូមតិ EMOs បានពង្រីកកម្មវិធីរបស់ខ្លួនច្រើនណាស់រវាងការបោះឆ្នោតលើទី១របស់ខ្លួននៅឆ្នាំ១៩៩៨ និងការបោះឆ្នោតលើកទី៣ នៅឆ្នាំ២០០៣ ។ COMFREL ដែលជាអង្គការធំជាងគេ បានកសាងមូលដ្ឋានទិន្នន័យមួយស្តីពីសកម្មជន ដូច្នេះ គឺអាចទាក់ទងហៅអ្នកសង្កេតការណ៍មានបទពិសោធន៍ឱ្យមកបំរើការទៀតបាននៅពេលបោះឆ្នោតលើកក្រោយៗទៀត ។ កម្មវិធីនានាបានពង្រីកឡើង ដោយមានបញ្ចូលនូវការងារតាមដានប្រព័ន្ធផ្សព្វផ្សាយធំទូលាយជាងមុន, កម្មវិធី តាមដានបន្តសំរាប់វាយតំលៃពីការរក្សាពាក្យសន្យាពីសំណាក់អ្នកនយោបាយ, ការរៀបចំវេទិកាផ្សេងៗសំរាប់ឱ្យអ្នកភូមិបានជួប ជាមួយអាជ្ញាធរឃុំ ។ល។ EMOs ចំបងពីរគឺ COMFREL និង NICFEC ហាក់ដូចបានខិតចូលជិតគ្នា ដោយបានចេញរបាយការណ៍ ដាច់ដោយឡែក ប៉ុន្តែជារឿយៗ ធ្វើសេចក្តីថ្លែងការណ៍រួមគ្នា ហើយសឹងតែរាល់លើកមានកម្មវិធីដូចគ្នាក្នុងការបញ្ចេញមតិ និង ចំណុចបារម្ភស្តីពីប្រព័ន្ធផ្សព្វផ្សាយ ។ អង្គការទាំងពីរមានចំណងទាក់ទងធំទូលាយជាមួយទីភ្នាក់ងារអន្តរជាតិនានា ដូចជាបណ្តាញអាស៊ីសំរាប់ការបោះឆ្នោតដោយសេរី (Asian Network for Free Elections) ហើយជារឿយៗក៏មានចេញសេចក្តីថ្លែង

ការណ៍រួមជាមួយពួកគេដែរ ។ ចំណុចខុសគ្នាគួរកត់សំគាល់មួយរវាងឆ្នាំ១៩៩៨ និង ២០០៣ គឺក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ចៀសវាងធ្វើការវាយតំលៃដាច់ណាច់លើដំណើរការបោះឆ្នោត នៅមុនពេល COMFREL និង NICFEC បានធ្វើសេចក្តីថ្លែងការណ៍ របស់ខ្លួន ។ ជំហរនេះខុសពីឆ្នាំ១៩៩៨ ដែលនៅពេលនោះការវាយតំលៃមុនជាវិជ្ជមានរបស់ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ រួមគ្នា បានធ្វើឱ្យចុះខ្សោយដល់ការទិតៀនរបស់ EMOs កម្ពុជា ហើយក៏ត្រូវ NGOs កម្ពុជាទិតៀនច្រើនណាស់ ។

កំណើនទំហំនិងសមត្ថភាពនៃអង្គការទាំងនេះ ធ្វើឱ្យមានការទទួលស្គាល់កាន់តែច្រើនថា ជាតួអង្គខាងនយោបាយពេញលក្ខណៈច្បាប់ ។ នៅឆ្នាំ២០០៣ COMFREL និង NICFEC ទទួលការអញ្ជើញឱ្យទៅចូលរួមការប្រជុំទៀងទាត់ ជាមួយសមាជិក គជប ។ សមាជិក គជប បានឆ្លើយសំភាសន៍ថា ខ្លួនយកចិត្តទុកដាក់ទទួលយកការជួយមតិរបស់ EMOs និងអនុមតិយកតាម បើសិនអាចធ្វើបាន ។ ការអះអាងបែបនេះ ទោះបីអាចនាំឱ្យមានសហប្រតិបត្តិការកាន់តែច្រើនក្នុងការអនុវត្តជាក់ស្តែង ឬក៏អត់ ក៏បានឆ្លុះបញ្ចាំងពីស្ថានភាពកាន់តែរឹងប៉ឹងនៃសមាគមសង្គមស៊ីវិលនានា ក្នុងឋានៈជាតួអង្គខាងនយោបាយដែលមានឥទ្ធិពល ។

ដំណើរការប្រជុំ COPCEL គឺជាគំនិតផ្តួចផ្តើមមួយរបស់សង្គមស៊ីវិលសំដៅឱ្យមានទំនុកចិត្តទៅវិញទៅមកកាន់តែច្រើន និងអារម្មណ៍ផ្សារភ្ជាប់នឹងសហគមន៍នយោបាយក្នុងចំណោមតួអង្គខាងនយោបាយសំខាន់ៗ ។ ក្រោយពីការធ្វើសន្និសីទមួយស្តីពីបញ្ហាទាំងនេះ COPCEL បានកើតឡើងនៅឆ្នាំ១៩៩៩ ។ ក្នុងនេះមានការប្រជុំតុមូលប្រចាំខែ ដែលមានអញ្ជើញតួអង្គខាងនយោបាយសំខាន់ៗមកចែករំលែកពតិមានផ្លាស់ប្តូរមតិ និងពិភាក្សាលើបញ្ហានានា ដែលគេយល់ថាអាចមានទំនាស់ក្នុងពេលបោះឆ្នោតខាងមុខ ។ អ្នកចូលរួមមានជាអាទិ៍ តំណាងគណបក្សនយោបាយ (គឺមានគណបក្សធំៗទាំង៣ផង), ស្ថាប័នរដ្ឋ (ជាពិសេសអគ្គលេខាធិការ គជប បានមកចូលរួមទៀងទាត់), NGOs (មាន EMOs ផង) និងអង្គការអន្តរជាតិ ។ របៀបវារៈកំណត់ឡើងតាមការពិគ្រោះយោបល់ និងមានផ្ញើជូនជាមុន ។ យោងទៅតាមចរិតនៃប្រធានបទលើកមកពិភាក្សា មានអញ្ជើញមន្ត្រីថ្នាក់ខ្ពស់ៗនៃស្ថាប័នរដ្ឋផ្សេងៗមករាយការណ៍ជូនអង្គប្រជុំ ។ ក្នុងការប្រជុំនីមួយៗ អ្នកចូលរួមមានឱកាសលើកពីចំណុចព្រួយបារម្ភនានា ។ ចំពោះប្រធានបទនីមួយៗដែលលើកឡើង គេបើកវេទិកាឱ្យអ្នកចូលរួមលើកមតិ ឬសំណួរ ហើយអ្នកចូលរួមឯទៀតមានឱកាសផ្តល់ចំលើយ ឬលើកជាគំនិត ។ ជួនកាលមានសំណើឱ្យអ្នកចូលរួមទាក់ទងទៅអង្គការរបស់ខ្លួនវិញ ដើម្បីសុំពតិមានបន្ថែម និងរាយការណ៍ជូនអង្គប្រជុំលើកក្រោយ ។ ដំណើរការប្រជុំមានថតសំលេងទុក និងស្រង់ធ្វើកំណត់ហេតុជាភាសាខ្មែរ និងអង់គ្លេសដែលផ្ញើទៅជូនមជ្ឈដ្ឋានធំទូលាយដែលមានអង្គការអន្តរជាតិ ស្ថាប័នរដ្ឋ គណបក្សនយោបាយ និង NGOs ។

ទិសដៅ COPCEL បានកំណត់ឡើងដើម្បីឆ្លើយតបនឹងបញ្ហានានាដែលការសិក្សាឆ្នាំ១៩៩៨ បានបំផុសឡើង ។ ដើម្បីដោះស្រាយបញ្ហាភាពទន់ខ្សោយខាងស្ថាប័ន, COPCEL បានជំរុញការពិភាក្សារវាងតួអង្គខាងនយោបាយសំខាន់ៗ ស្តីពីអង្គការបោះឆ្នោតនានា ។ តាមរយៈនេះ COPCEL មានគោលដៅជួយសំរួលការផ្លាស់ប្តូរពតិមានក្នុងចំណោមតួអង្គខាងនយោបាយសំខាន់ៗ ក្នុងពេលដែលកំណែទំរង់នានាកំពុងតាក់តែងឡើង ។ ការសំរបសំរួលនេះ មានគោលដៅ ៤: ការរកឃើញពីដើមទីនូវបញ្ហាដែលអាចបង្កទំនាស់, ការបង្កើនចំណាប់អារម្មណ៍ថា ស្ថាប័ននានាកាន់តែមានតំលាភាព និងគណនេយ្យភាពច្រើនហើយ, ការបង្កើនអារម្មណ៍ចង់ចូលរួម ហើយតាមរយៈនេះ គឺភាពជាម្ចាស់នៃតួអង្គទាំងអស់នៅក្នុងដំណើរការកែទំរង់ និងការញ៉ាំងឱ្យគ្រប់ភាគីមានចំណាប់អារម្មណ៍កាន់តែច្រើនពីការលំបាក ទាំងខាងការអនុវត្តន៍ជាក់ស្តែង និងខាងនយោបាយដែលតួអង្គផ្សេងទៀតត្រូវប្រឈមមុខ ។

ដើម្បីដោះស្រាយបញ្ហាភាពទន់ខ្សោយនៃសហគមន៍នយោបាយ COPCEL មានគោលដៅ ៤ ផ្សេងទៀត: ការកសាងកន្លែងមានសុវត្ថិភាព និងអព្យាក្រឹតភាពសំរាប់ការពិភាក្សាខាងនយោបាយ ក្នុងគំនិតជួយបង្កើនទំនុកចិត្តគ្នារវាងតួអង្គខាងនយោបាយ, ការកសាងចំណងទាក់ទងផ្ទាល់ខ្លួនរវាងសមាជិកនានាមកពីបណ្តាស្ថាប័ន និងអង្គការដែលគេតែងយល់ថា ប្រឆាំងគ្នាខាងនយោបាយ, ជំរុញវប្បធម៌មួយដែលក្នុងនេះទំនាស់ផលប្រយោជន៍ត្រូវគេមើលឃើញថា ពេញលក្ខណៈច្បាប់ និងអាចគ្រប់

គ្រងបាន, និងការកសាងក្នុងចំណោមសមាជិកនូវចំណូលចិត្តប្រើប្រាស់ ការចរចាដើម្បីគ្រប់គ្រងទំនាស់ ជាជាងប្រើយុទ្ធសាស្ត្រ ចៀសវាងទំនាស់ដែលបង្កើនការមិនទុកចិត្តគ្នា ។ COPCEL គឺជាវេទិកាតែមួយដែលក្នុងនេះអ្នកពាក់ព័ន្ធខាងនយោបាយធំៗទាំងអស់អាចជួបជាមួយគ្នា ហើយសមាជិក COPCEL មួយចំនួនមើលឃើញរឿងនេះថាសំខាន់ ។

គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលទាំងពីរនេះ តំណាងឱ្យការឆ្លើយតបនឹងបញ្ហាពីរប្រភេទសំខាន់ៗដែលចុះក្នុងរបាយការណ៍របស់ វិបសអ ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨ ព្រមទាំងចំណុចផ្តោតនានានៃសកម្មភាពរបស់បណ្តាទីភ្នាក់ងារដែលជាប់ពាក់ព័ន្ធ, ដូច្នេះហើយក៏ត្រូវបានជ្រើសរើសធ្វើជាករណីសិក្សាពីការផ្លាស់ប្តូរខាងនយោបាយ និងផលប៉ះពាល់របស់វាទៅលើនិន្នាការរីករាលដាលនៃទំនាស់បោះឆ្នោត និងទៅលើសមត្ថភាពនៃស្ថាប័ននានាដើម្បីគ្រប់គ្រងការរីករាលដាលបែបនេះ ។

## ២.៤ ការវិវត្តន៍ខាងនយោបាយ

ក្រៅពីភាពទន់ខ្សោយខាងស្ថាប័ន ការសិក្សាឆ្នាំ១៩៩៩ របស់ វិបសអ រកឃើញនូវកង្វះអារម្មណ៍ចូលជាសហគមន៍នយោបាយរវាងតួអង្គខាងនយោបាយសំខាន់ៗ (ជាពិសេសរវាងគណបក្សនយោបាយ និងរវាងរដ្ឋាភិបាល និង NGOs ក្នុងកិរិតណាមួយ) បានបង្កើនការមិនទុកចិត្ត និងធ្វើឱ្យខូចខាតថែមទៀតដល់បណ្តាស្ថាប័នដែលទន់ខ្សោយស្រាប់ហើយ ។ កំរិតទុកចិត្តគ្នាមិនអាចវាស់វែងដោយផ្ទាល់បានទេ ប៉ុន្តែចំណុចលេចធ្លោខ្លះៗបានផ្តល់គំនិតថា យ៉ាងហោចណាស់បរិយាកាសនយោបាយនៅឆ្នាំ២០០៣ មិនសូវតានតឹងដូចឆ្នាំ១៩៩៨ ទេ ។ អ្នកឆ្លើយសំភាសន៍មួយចំនួនមើលឃើញការមិនទុកចិត្តគ្នាដែលបង្កប់ក្នុងមជ្ឈដ្ឋាននយោបាយកម្ពុជាថាជាកេរ្តិ៍ដំណែលនៃប្រវត្តិសាស្ត្រ ឬវប្បធម៌ ។ ឧទាហរណ៍:

> *"នៅកម្ពុជា តាំងពីរបប ប៉ុល ពត មក កេរ្តិ៍ដំណែលកង្វះទំនុកចិត្តគឺនៅតែមាន ។ យើងត្រូវផ្លាស់ប្តូរគំនិត ប៉ុន្តែយើងមិនសូវមានការឯកភាពគ្នាទេ ។ ការមូលមតិ គឺពិបាករកបាន ។ មនុស្សម្នាប្រឹងប្រែងប្រកាន់យកម្ខាងៗ យ៉ាងខ្លាំង និងប្រយុទ្ធយ៉ាងខ្លាំងដើម្បីយកឈ្នះ ។ បើសិនគ្មានការជួបប្រជុំដើម្បីសំរុះសំរួលការតានតឹងទេ នឹងមានបញ្ហាចោទ... ការតានតឹងខាងនយោបាយនឹងកើនឡើង ហើយអស្ថិរភាពខាងនយោបាយនឹងកើតមាន"*[២៩] ។

ប៉ុន្តែព្រឹត្តិការណ៍នយោបាយសព្វថ្ងៃមានសារៈសំខាន់គួរសមក្នុងការជួយសំរួល ឬរាំងស្ទះដល់កិច្ចប្រឹងប្រែងកែលំអទំនាក់ទំនងខាងនយោបាយ ។ តាមមើល កត្តាសំខាន់បំផុតដែលកំណត់ពីកំរិតទំនុកចិត្តគ្នាខាងនយោបាយ អាចជាចំនួនឃាតកម្មខាងនយោបាយដែលបានរាយការណ៍ឡើង ។ ចំនួននេះបានថយចុះជាលំដាប់ ប៉ុន្តែសមាជិកគណបក្សជំទាស់ និងសកម្មជនរបស់ NGOs បន្តរាយការណ៍ពីករណីឃាតកម្មខាងនយោបាយ ដែលបានជះឥទ្ធិពលយ៉ាងច្បាស់ពាសពេញសង្គមជាតិ ។ ក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ មានមនុស្សជាង ២០០នាក់បានស្លាប់ដោយអំពើឃាតកម្មទាក់ទិននឹងការបោះឆ្នោត ។ ពីខែកក្កដា ១៩៩៧ ដល់ខែកញ្ញា ១៩៩៨ ឃាតកម្មខាងនយោបាយ មានចំនួនប៉ាន់ស្មានពី ៩១ ទៅ ១៣៣ករណី ។ ការស្លាប់ពី ៤០ ទៅ ៦០ ជាប់ទាក់ទិននឹងការប្រយុទ្ធគ្នាខាងកងទ័ពនៅខែកក្កដា-សីហា ឆ្នាំ១៩៩៧ ដោយបានប៉ះពាល់ជាពិសេសដល់ មន្ត្រី និងនាយទាហាន FUNCINPEC ក្នុងនេះមានឧត្តមសេនីយ៍យោធាម្នាក់ គឺលោក ចៅ សម្បត្តិ ដែលលើខ្លួនមានស្លាកស្នាមទារុណកម្ម និងរដ្ឋលេខាធិការម្នាក់គឺ ឯ.ឧ ហូ សុខ ដែលប្រហែលត្រូវបាញ់សំលាប់ក្នុងបរិវេណក្រសួងមហាផ្ទៃ ។ COHCHR បានកត់ត្រា ៣៣ ឃាតកម្មដោយមូលហេតុខាងនយោបាយថែមទៀតពីខែសីហា ១៩៩៧ ដល់ មេសា ១៩៩៨, ពី ១៦-២២ឃាតកម្ម ពីខែឧសភា ១៩៩៨ ដល់ខែសីហា ១៩៩៨ និងការស្លាប់បាតុករ ២នាក់ និងការរកឃើញសាកសព ១៦នាក់ ដែលប្រហែលជាត្រូវសំលាប់ក្រៅផ្លូវតុលាការនៅខែកញ្ញា ឆ្នាំ១៩៩៨[៣០] ។

---

[២៩] Ministry of National Defence representative (9), personal interview, Phnom Penh, 11 July 2003.

[៣០] Hughes and Real, 55/6.

ក្នុងរយៈពេលមុនធ្វើការបោះឆ្នោតឃុំនៅខែកុម្ភៈ ២០០២ អំពើហិង្សាខាងនយោបាយហាក់ដូចបន្តកើតមាន ប៉ុន្តែក្នុងកំរិតទាបជាង ។ UN បានកត់ត្រា ១៧ឃាដកម្មជាប់ទាក់ទិននឹងការបោះឆ្នោត ក្នុងរយៈពេលដែលនៅជុំវិញការបោះឆ្នោតឃុំ ។ ក្រោយពីការបោះឆ្នោតឃុំ ឃាដកម្មលើសមាជិកគណបក្សនយោបាយមានជាបន្ត ។ ពីខែមករា ២០០៣ ដល់ថ្ងៃបោះឆ្នោតមានស្លាប់មនុស្ស ៣១នាក់ ក្នុងការវាយប្រហារ ២៨លើក ដែល COMFREL កត់ត្រាថា ប្រហែលជាប់ទាក់ទិននឹងនយោបាយ ក្នុងនេះមានសមាជិក SRP ១១នាក់, សមាជិក FUNCINPEC ៩នាក់, និងសមាជិក CPP ១១នាក់[៣១] ។ UN បានកត់ត្រាការស្លាប់សកម្មជននយោបាយ ១៣នាក់ ពីខែកុម្ភៈ ២០០២ ដល់ពេលចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនៅខែមិថុនា ២០០៣ ។ ក្នុងរយៈពេលនេះ អ្នកនយោបាយជាន់ខ្ពស់ម្នាក់របស់ FUNCINPEC គឺ ឯ.ឧ ឱម រាជ្ជសាឌី ត្រូវបាញ់សំលាប់ ហើយ UN បានទិតៀនក្រសួងមហាផ្ទៃពីការចេញសេចក្តីថ្លែងការណ៍យ៉ាងលឿនថា ចោរកម្ម ជាមូលហេតុនៃការវាយប្រហារ "គឺបានវិនិច្ឆ័យជាមុនពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនផ្ទាល់ និងធ្វើឱ្យខូចដល់ទំនុកចិត្តលើការស៊ើបអង្កេត និងអព្យាក្រឹតភាពរបស់ក្រសួងមហាផ្ទៃ" ។ តំណាងពិសេសរបស់ UN សំរាប់សិទ្ធិមនុស្សនៅកម្ពុជាបានលើកឡើងថា គាត់ "នៅបារម្ភពីនិន្នាការជាបន្តរបស់អ្នកជាក់អនុវត្តច្បាប់ និងមន្ត្រីរដ្ឋាភិបាលកម្ពុជា ដែលប្រកាសជាសាធារណៈថា ករណីទាំងនេះគ្មានទាក់ទងនឹងនយោបាយទេ មុនពេលធ្វើការស៊ើបអង្កេតចប់"[៣២] ។

UN បានរាយការណ៍ថា រយៈពេលឃោសនាបោះឆ្នោតមានអំពើហិង្សាតិចជាងមុន[៣៣] ប៉ុន្តែ COMFREL បានកត់ត្រាការស្លាប់របស់សមាជិកគណបក្សនយោបាយ និងសកម្មជន ១៧នាក់ ក្នុងរយៈពេលនោះ និង ២១៣ករណីបំភិតបំភ័យ និងគំរាមកំហែង[៣៤] ។ នៅមានឃាដកម្មច្រើនទៀតលើជនមានជាប់ទាក់ទងខាងនយោបាយ ក្នុងនេះ មានការបាញ់សំលាប់ឃ្លាតគ្នាតែមួយសប្តាហ៍នូវអ្នកចំរៀងគាំទ្រ FUNCINPEC ម្នាក់ និងអ្នកកាសែតម្នាក់នៃស្ថានីយវិទ្យុ FUNCINPEC ដែលកើតឡើងក្រោយពេលបោះឆ្នោត[៣៥] ។

ចំណុចគួរបារម្ភដោយឡែកមួយគឺ សាក្សីឃើញការបាញ់និងឃាដកម្ម ជារឿយៗអះអាងថា អ្នកប្រព្រឹត្តល្មើស ស្លៀកឯកសណ្ឋានកងសន្តិសុខ ។ ការវិភាគរបស់ COMFREL លើករណីគំរាមកំហែង បំភិតបំភ័យ និងប្រើហិង្សា ក្នុងពេលចុះបញ្ជីអ្នកបោះឆ្នោតនៅខែមករា-កុម្ភៈ ២០០៣ បង្ហាញថា ៣៥% នៃករណីទាំងនេះប្រព្រឹត្តឡើងដោយសមាជិកកងសន្តិសុខ និង ៣៥% ដោយសមាជិកនៃអាជ្ញាធរមូលដ្ឋាន[៣៦] ។

ករណីបំភិតបំភ័យ និងគំរាមកំហែង ក៏មានកត់ត្រាបានច្រើនដូចគ្នា ។ របាយការណ៍មួយរបស់ Human Right Watch (តាមដានសិទ្ធិមនុស្ស) បានកត់ត្រាពីការបំភិតបំភ័យដោយ CPP ទៅលើអ្នកបោះឆ្នោតគាំទ្រ FUNCINPEC គឺអ្នកបោះឆ្នោតគាំទ្រ FUNCINPEC ទាំងនោះបានទទួលការអញ្ជើញឱ្យទៅប្រជុំនៅការិយាល័យ CPP, ដែលនៅទីនោះ មានការចែកអំណោយឱ្យ និងការបង្ខិតបង្ខំឱ្យស្បថសន្យាបោះឆ្នោតឱ្យគណបក្ស ។ COMFREL បានកត់ត្រាផងដែរពីករណីជនមួយចំនួនដែលគេឱ្យផឹក

---

៣១ COMFREL and NICFEC, "Pre-Election Assessment Joint Statement," press release, Phnom Penh, 25 July 2003.

៣២ Peter Leuprecht, "Situation of Human Rights in Cambodia," Report by the Special Representative for Human Rights in Cambodia to the General Assembly, 22 Aug. 2003, para. 18.

៣៣ Peter Leuprecht, "Situation of Human Rights in Cambodia," Report by the Special Representative for Human Rights in Cambodia to the General Assembly, 22 Aug. 2003, para. 19.

៣៤ COMFREL and NICFEC, "Pre-Election Assessment Joint Statement," press release, Phnom Penh, 25 July 2003.

៣៥ Cheang Sokha and Caroline Huot, "Actress Shot After Journalist Slain," Phnom Penh Post, online edition, 24 Oct –6 Nov 2003, available online at www.phnompenhpost.com, accessed on 7 Nov 2003.

៣៦ COMFREL, Assessment Report on Voter Registration Process for the July 2003 National Assembly Elections, Phnom Penh, 7 Mar 2003, appendix 3.

"ទឹកសម្បថ" សន្យាបោះឆ្នោតឱ្យ CPP[៣៧] ។ របាយការណ៍មួយរបស់តំណាងពិសេសសំរាប់សិទ្ធិមនុស្ស បានទិតៀនទង្វើ គជប លើបញ្ហាទាំងនេះថា:

> *"នៅចំពោះមុខការក្លែងបន្លំបោះឆ្នោត ការទិញសន្លឹកឆ្នោត ការបំភិតបំភ័យ និងអំពើហិង្សា, គជប បរាជ័យសឹង តែរាល់លើកក្នុងការប្រើប្រាស់សិទ្ធិអំណាចដ៏ធំសំបើមរបស់ខ្លួនដើម្បីផាកពិន័យ និងដាក់ទោសទណ្ឌផ្សេងទៀត ។ ថ្វីបើមន្ត្រីអ្នកពង្រឹងការអនុវត្តន៍ច្បាប់ បានចាត់វិធានការមួយចំនួន ដើម្បីស៊ើបអង្កេតពីឃាដកម្មលើសកម្មជន គណបក្សនយោបាយក្តី ប៉ុន្តែដំណើរការខាងស៊ើបអង្កេត និងតុលាការ ដើម្បីយកជនល្មើសមកកាត់ទោស នៅតែ មានចំណុចខ្វះខាត និងមិនសក្តិសិទ្ធិក្នុងករណីភាគច្រើន"*[៣៨] ។

គជប ខ្លួនឯងបានអះអាងថា ការស៊ើបអង្កេតករណីឧក្រិដ្ឋកម្មជាតួនាទីរបស់ប៉ូលីស និងតុលាការ មិនមែនរបស់ គជប ទេ និងបានបញ្ជាក់ថា ការបង្ខំឱ្យស្បថ និងការប្រមូលប័ណ្ណបោះឆ្នោតដោយពួកប្រធានភូមិ និងមន្ត្រីគណបក្ស "ត្រូវបានចាត់ទុកថា ជារឿងផ្ទៃក្នុងរបស់គណបក្ស" បើសិនធ្វើឡើងនៅក្នុងការិយាល័យរបស់គណបក្ស និងនៅក្រៅម៉ោងធ្វើការ[៣៩] ។ គជប បញ្ជាក់ ទៀតថា "គជប គ្មានមធ្យោបាយអ្វីផ្សេងក្រៅពីការសំរុះសំរួលទេ" នៅពេលដោះស្រាយរឿងអាជ្ញាធរមូលដ្ឋានរំលោភលើ វិធាននានា[៤០] ។ អ្នកសង្កេតការណ៍ក្នុងស្រុក និងអន្តរជាតិមួយចំនួនសំគាល់ចំលើយទាំងអស់នេះថាជាការគេចវេសមិនទទួលខុស ត្រូវរបស់ គជប, ហើយគណបក្សជំទាស់តែងមើលឃើញថាជាភស្តុតាងនៃការលំអៀងរបស់ គជប ទៅគាំទ្រគណបក្សកាន់ អំណាចដែលគេចោទថា មានការទទួលខុសត្រូវលើការរំលោភភាគច្រើន ។

វិវាទមួយទៀតទាក់ទិននឹងលក្ខណៈនៃអំពើហិង្សាណាមួយថាជារឿងនយោបាយ ឬរឿងព្រហ្មទណ្ឌ ។ ក្រសួងមហាផ្ទៃ ជារឿយៗអះអាងថា រឿងរ៉ាវផ្ទាល់ខ្លួន ឬខាងព្រហ្មទណ្ឌ គឺជាមូលហេតុ ហើយបដិសេធការជាប់ទាក់ទងរវាងអំពើហិង្សា និង បញ្ហានយោបាយ ។ NGOs និងសកម្មជនគណបក្សជំទាស់ជាច្រើន ព្រមទាំងអង្គការអន្តរជាតិផង គេយល់ឃើញផ្សេង ។ ការយល់ឃើញខុសគ្នានេះ បានលេចឃើញច្បាស់នៅក្នុងសិក្ខាសាលាកាលពីខែវិច្ឆិកា ២០០៣ របស់ វិបសអ ស្តីពីការគ្រប់គ្រង ទំនាស់ក្នុងការបោះឆ្នោត ។ ក្នុងក្រុមជំនាញខាងស្ថានភាពសន្តិសុខ មានអ្នកឧទ្ទេសនាម ២នាក់គឺ ឧត្តមសេនីយ ម៉ៅ ច័ន្ទដារិទ្ធ នៃប៉ូលីសជាតិ និងលោក កុយ ច័ន្ទដារិទ្ធ នៃ COMFREL ។ ឧត្តមសេនីយ ម៉ៅ ច័ន្ទដារិទ្ធ លើកសរសើរពីការគ្មានអំពើហិង្សា ក្នុងពេលបោះឆ្នោត រីឯលោក កុយ ច័ន្ទដារិទ្ធ រាយការណ៍ពីការបារម្ភរបស់ COMFREL អំពីកំណើនចំនួនការវាយប្រហារ[៤១] ។ គំលាតដ៏ធំនៃការយល់ឃើញពីសភាពការណ៍បែបនេះ វាបង្កើនការមិនទុកចិត្តគ្នាជាខ្លាំងរវាងគណបក្សនានា ។ រឿងនេះកាន់តែ ធ្ងន់ធ្ងរថែមទៀត ពីព្រោះស្ថាប័នរដ្ឋ (ប៉ូលីស និងប្រព័ន្ធតុលាការ) ដែលទទួលខុសត្រូវធ្វើការស៊ើបអង្កេតអំពើហិង្សា និងដាក់ ទោសជនល្មើស គឺជាស្ថាប័នមានដំណើរការទន់ខ្សោយ ដែលខាងជំទាស់យល់ថា មានពាក់ព័ន្ធនឹងនយោបាយច្រើន និងដែល សាធារណជនមានទំនុកចិត្តតិចតួច ។

---

[៣៧] Human Rights Watch, "Don't Bite the Hand that Feeds You, a Human Rights Watch Backgrounder Report," available online at www.hrw.org/backgrouner/asia/cambodia/elections.htm, accessed on 7 Nov 2003.

[៣៨] Human Rights Watch, "Don't Bite the Hand that Feeds You, a Human Rights Watch Backgrounder Report," available online at www.hrw.org/backgrouner/asia/cambodia/elections.htm, accessed on 7 Nov 2003.

[៣៩] Tep Nytha, NEC, statement to COPCEL meeting, minutes of 44th COPCEL Meeting, trans. Sen Sina, Phnom Penh, 26 Mar 2003, 8.

[៤០] Tep Nytha, NEC, statement to COPCEL meeting, minutes of 44th COPCEL Meeting, trans. Sen Sina, Phnom Penh, 26 Mar 2003, 3.

[៤១] Panel on "Security", Workshop on the Evolution of Conflict Management over Three Cambodian Elections, Phnom Penh, 24 Nov 2003.

ម្យ៉ាងទៀត កង្វះខាតធនធានធ្ងន់ធ្ងរបានរាំងស្ទះសកម្មភាពដ៏សក្តិសិទ្ធិពីសំណាក់ប៉ូលីសដែលស៊ើបអង្កេតបណ្តឹងតវ៉ា ។ តំណាងម្នាក់របស់ក្រសួងការពារជាតិដែលចូលរួមក្នុងការប្រជុំ COPCEL បានរៀបរាប់ពីបញ្ហាដែលប្រឈមមុខមន្ត្រីអ្នកស្រាវជ្រាវលើរបាយការណ៍ស្តីពីអំពើហិង្សាខាងនយោបាយ:

*"ស្ថាប័នរបស់ខ្ញុំគ្មានធនធានទេ និងមានបៀវត្សរ៍ទាបណាស់ ។ បើសិនត្រូវស្រាវជ្រាវ ខ្ញុំត្រូវទៅខ្លួនឯង ។ នេះជាបញ្ហាមួយ ប៉ុន្តែខ្ញុំមានការតានតឹង បើសិនត្រឡប់មក COPCEL វិញ ហើយគ្មានអ្វីរាយការណ៍សោះ ។ អង្គការមានបៀវត្សរ៍ច្រើន៧រាប់យដុល្លារក្នុងមួយខែ ឯពួកយើងគ្មានទេ... ជាគោលការណ៍យើងមានប្រាក់ឧបត្ថម្ភសំរាប់ដោះស្រាយការស៊ើបអង្កេត ប៉ុន្តែក្នុងការពិតជាក់ស្តែងយើងមិនបានទទួលវាទេ ។ ឧទាហរណ៍ ក្នុងបទប្បញ្ញត្តិ បើយើងទៅបាត់ដំបង យើងត្រូវបាន ៣០ដុល្លារក្នុងមួយថ្ងៃ ។ ប៉ុន្តែតាមពិតគ្មានប្រាក់ទេ ។ គេដកវាយកទៅប្រើលើអ្វីផ្សេង ។ ជាលទ្ធផល នៅពេលអ្នកណាម្នាក់ត្រូវចុះទៅដល់កន្លែង គេមិនចង់ទៅទេ"*[៤២] ។

បញ្ហាទាំងនេះដែលកត់សំគាល់ឃើញក្នុងឆ្នាំ១៩៩៨ដែរ ហាក់ដូចមិនបានផ្លាស់ប្តូរអ្វីច្រើនទេក្នុង ៥ឆ្នាំបន្ទាប់មក ។

វិវាទស្តីពីចរិតនៃអំពើហិង្សាដែលកើតមានក្នុងរយៈពេលបោះឆ្នោត គឺជារោគសញ្ញានៃចំណាប់អារម្មណ៍ផ្ទុយគ្នាពីកិរិតសន្តិភាពដែលស្ថិតនៅពីខាងក្រោមរូបភាពស្ងប់ស្ងាត់នៃការបោះឆ្នោត ។ គណបក្សជំទាស់ និង NGOs មួយចំនួនបានអះអាងថា អ្នកភូមិរស់នៅក្នុងសភាពមានការភ័យខ្លាចជាអចិន្ត្រៃយ៍ចំពោះអាជ្ញាធរមូលដ្ឋានដែលគាំទ្រ CPP និងកងប្រដាប់អាវុធ ។ ផ្ទុយទៅវិញ គណបក្សកាន់អំណាចបានអះអាងពីទំនាក់ទំនងសាមគ្គីភាពជាមួយសាធារណជនកម្ពុជា ។ រឿងនេះនៅតែជាការខ្វែងគំនិតពិបាកដោះស្រាយបំផុតក្នុងសង្គមកម្ពុជា ហើយជាមូលហេតុដើមមួយនៃបញ្ហាជាច្រើនដូចមានរៀបរាប់ត្រួស១ខាងក្រោម ។

ប្រភពព្រួយបារម្ភមួយនៅឆ្នាំ២០០៣ គឺការបះបោរប្រឆាំងថៃ កាលពីខែមករា ។ រឿងនេះបង្កការបារម្ភចំពោះការបោះឆ្នោត ពីព្រោះមានការផ្សារភ្ជាប់វាយ៉ាងលឿនទៅនឹងគណបក្សនយោបាយ នៅក្នុងសុន្ទរកថាអ្នកនយោបាយនានា ដោយអ្នកដឹកនាំគណបក្សជំទាស់ចោទ CPP ថាបានអុចអាលអំពើហិង្សា ចំណែកឯ CPP ក៏ចោទគណបក្សជំទាស់ពីរឿងដូចគ្នា ។ ការចោទគ្នានេះមានភស្តុតាងបញ្ជាក់តិចតួចណាស់ ប៉ុន្តែ អន្តរាគមន៍ដ៏ទន់ខ្សោយនៃកងប្រដាប់អាវុធ ដែលហាក់ដូចមិនចង់ ឬមិនអាចត្រួតត្រាសភាពការណ៍ ប្រហែលបានបង្កើនការភ័យខ្លាចក្នុងចិត្តគំនិតរបស់ប្រជាជនក្រុងភ្នំពេញ ។ ក្រោយមកទៀត កងប្រដាប់អាវុធមានប្រតិកម្មយ៉ាងខ្លាំងទៅលើការធ្វើបាតុកម្មដោយសន្តិភាពក្នុងរាជធានី ហើយនៅលើកមួយនោះ មានមនុស្សស្លាប់ពីរនាក់ក្នុងបាតុកម្មមួយរបស់កម្មកររោងចក្រ ។ សកម្មភាពមិនស៊ីសង្វាក់គ្នារបស់កងប្រដាប់អាវុធ ដែលហាក់ដូចបានបរាជ័យក្នុងការទប់ស្កាត់អំពើហិង្សាក្នុងករណីទី១ និងបង្កអំពើហិង្សាក្នុងករណីទី២ គ្មានបានជួយអ្វីទេដល់ការពង្រឹងបរិយាកាសស្ងប់ស្ងាត់សំរាប់ការបោះឆ្នោត ។

ក្រោយពីមានការសំលាប់ ឯ.ឧ ឱម រាដ្ឋសាឌី និងសង្ឃអ្នកដឹកនាំ ព្រះនាម សំ ប៊ុនធឿន នៅខែកុម្ភៈ ២០០៣, COMFREL បានលើកឡើងថា:

*"ឧប្បត្តិហេតុទាំងនេះ បានជះឥទ្ធិពលបង្កើតអារម្មណ៍ភ័យខ្លាចដែលគំរាមកំហែងដល់អ្នកនយោបាយ, សកម្មជនខាងនយោបាយ, សកម្មជន NGOs, និងជាពិសេសអ្នកបោះឆ្នោត ក្នុងការបញ្ចេញមតិនិងឆន្ទៈ និងចូលរួមដោយសេរីក្នុងដំណើរការបោះឆ្នោត ។ ការភ័យខ្លាចទាំងនេះ បង្កការបារម្ភប៉ុនគ្នា បើធៀបនឹងស្ថានភាពមុនពេលបោះឆ្នោតកិរិតជាតិឆ្នាំ១៩៩៨... ការភ័យខ្លាចនេះជាក់ស្តែងបានរារាំងដល់សេរីភាពក្នុងការបញ្ចេញមតិ ការធ្វើបាតុកម្ម*

[៤២] Ministry of National Defence representative (9), personal interview, Phnom Penh, 11 July 2003.

និងការជួបប្រជុំគ្នាក្នុងរយៈពេលបោះឆ្នោត”[៤៣] ។

[៤៣] COMFREL and NICFEC, Cambodian Human Rights Action Committee, Advocacy Commission of Star Kampuchea and Youth Council ofCambodia, “Joint Statement on Concerns over Assassination and Intimidation Related to the Political Environment of the 2003 National Assembly Election Process,” Phnom Penh, 22 Feb. 2003.

ទោះដូច្នេះក្តី បើធៀបនឹងឆ្នាំ១៩៩៨ អ្នកដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយនានា ឥឡូវនេះមានបទពិសោធន៍ច្រើនជាងក្នុងការសំរបសំរួលជាមួយគ្នា និងធ្វើការរួមគ្នា ។ នៅឆ្នាំ១៩៩៨ ថ្នាក់ដឹកនាំ FUNCINPEC និង SRP ទើបត្រឡប់មកពីបាងកកវិញ ក្រោមការពិនិត្យរបស់អ្នកតាមដាននៃ UN, បន្ទាប់ពីបានទៅស្នាក់នៅទីនោះ ក្រោយពីការវាយប្រយុទ្ធខាងយោធានៅឆ្នាំ១៩៩៧ ។ ក្រោយពេលប្រយុទ្ធគ្នានេះ ព្រះអង្គម្ចាស់ រណឫទ្ធិ ត្រូវបានកាត់ទោស ដាក់ទោស និងលើកលែងទោសចំពោះបទល្មើសរត់ពន្ធអាវុធ ហើយការវិលត្រឡប់របស់ព្រះអង្គជួបការបះបោរនៅមុខព្រះដំណាក់រវាងអ្នកគាំទ្រគណបក្សនយោបាយប្រជែងគ្នា ។ ផ្ទុយទៅវិញនៅឆ្នាំ២០០៣ FUNCINPEC និង CPP បានរួមរស់ដោយសន្តិភាពក្នុងរដ្ឋាភិបាល ចំរុះអស់រយៈ ៥ឆ្នាំ ហើយបទពិសោធន៍នេះវាខុសគ្នាស្រឡះពីទំនាក់ទំនងដ៏តឹងតែង និងរកាំរកូសរវាងដៃគូក្នុងរដ្ឋាភិបាលចំរុះពីឆ្នាំ១៩៩៣-១៩៩៨ ។

រវាង SRP និង CPP នៅមានការមិនទុកចិត្តគ្នាកំរិតខ្ពស់ ។ តាំងពីឆ្នាំ១៩៩៨ មក SRP នៅតែទាមទារថា ការបោះឆ្នោតឆ្នាំ១៩៩៨ មានការក្លែងបន្លំ ហើយនាយករដ្ឋមន្ត្រី និងអ្នកដឹកនាំ CPP គឺសម្តេច ហ៊ុន សែន មិនសមរម្យនឹងចូលរួមក្នុងឆាកនយោបាយកម្ពុជាទេ ។ ក្នុងពេលជាមួយគ្នា SRP បានជោគជ័យក្នុងការបំពេញតួនាទីជាគណបក្សជំទាស់ពីឆ្នាំ១៩៩៨-២០០៣ ហើយបានពង្រឹងកំលាំង និងចំនួនអ្នកគាំទ្រជាបន្តបន្ទាប់ក្នុងរយៈពេលនោះ ។ ថ្វីបើ SRP ជារឿយៗបានចោទប្រកាន់ប្រតិបត្តិការរបស់រដ្ឋាភិបាលថា មិនពេញលក្ខណៈច្បាប់ និងខុសរដ្ឋធម្មនុញ្ញ ប៉ុន្តែបានធ្វើសហប្រតិបត្តិការដោយរក្សាឱ្យរដ្ឋសភាមានដំណើរការ ហើយតាំងពីឆ្នាំ២០០២ មក បានដើរតួនាទីយ៉ាងសកម្មក្នុងអាជ្ញាធរនៅមូលដ្ឋាន ។

តាំងពីឆ្នាំ២០០២ ដែរ តំណាងមកពីគណបក្សនយោបាយខុសៗគ្នា បានរួមរស់ជាមួយគ្នាក្នុងក្រុមប្រឹក្សាឃុំក្នុងទូទាំងប្រទេស ស្របតាមលទ្ធផលនៃការបោះឆ្នោតឃុំដែលបានធ្វើឡើង ជាចំណែកមួយនៃគោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ មុនការបោះឆ្នោតឃុំឆ្នាំ២០០២ ប្រធានឃុំនៅសឹងគ្រប់កន្លែងក្នុងប្រទេសកម្ពុជា គឺជាអ្នកបានទទួលការតែងតាំងនៅដើមទសវត្សរ៍១៩៨០ នៅក្រោមរបបរដ្ឋមានគណបក្សតែមួយគឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) ។ គេយល់ឃើញជាទូទៅថា អ្នកទាំងនេះមានភក្តីភាពចំពោះគណបក្សបន្តវេនគឺ CPP ។ វិវាទស្តីពីភក្តីភាពខាងនយោបាយរបស់ប្រធានឃុំ គឺជាប្រភពដ៏ចំបងមួយនៃការរកាំរកូសក្នុងសភាទី១ ពីឆ្នាំ១៩៩៣-១៩៩៨ នៃព្រះរាជាណាចក្រកម្ពុជា និងការបាក់បែករបស់រដ្ឋាភិបាលចំរុះរវាង CPP និង FUNCINPEC និងការផ្ទុះអំពើហិង្សានៅខែកក្កដា ១៩៩៧ ។ ទាំងនៅក្នុងស្រុក និងនៅអន្តរជាតិ គេផ្តល់សារៈសំខាន់ខ្ពស់ណាស់ ចំពោះតំរូវការធ្វើឱ្យអាជ្ញាធរឃុំកាន់តែមានគណនេយ្យភាព និងភាពពេញលក្ខណៈច្បាប់ ចំពោះមជ្ឈដ្ឋានអ្នកបោះឆ្នោត និងឆ្លុះបញ្ចាំងបានកាន់តែល្អនូវភាពពហុបក្សនៃសង្គមនយោបាយកម្ពុជានៅក្រោយឆ្នាំ១៩៩៣ ។

ការបោះឆ្នោតឃុំឆ្នាំ២០០២ បានផ្លាស់ប្តូរប្រធានឃុំចាស់ ជាប្រព័ន្ធថ្មីមួយនៃក្រុមប្រឹក្សាឃុំមានសមាជិកច្រើនដែលតំណាងឱ្យគណបក្សខុសៗគ្នា តាមប្រព័ន្ធតំណាងសមាមាត្រ ។ ថ្វីបើ CPP បានទទួលជ័យជំនះដាច់គេ ក្នុងការបោះឆ្នោតឃុំ ដែលផ្តល់លទ្ធផលឱ្យប្រធានឃុំចាស់អាចរក្សាមុខតំណែងរបស់ខ្លួនបាន ប៉ុន្តែ បច្ចុប្បន្នក្នុងឃុំភាគច្រើនពួកគេត្រូវបែងចែកអំណាចពីព្រោះក្រុមប្រឹក្សាឃុំមានសមាសភាពចំរុះមកពីគណបក្សធំៗទាំង ៣ ។ ក្រុមប្រឹក្សាឃុំទទួលបានលទ្ធផលចំរុះក្នុងការលើកកំពស់ស្មារតីពហុបក្ស និងការរួមរស់ដោយសន្តិភាពរវាងគណបក្សនយោបាយខុសគ្នា ។ នៅកំពង់ចាម អ្នកសង្កេតការណ៍បោះឆ្នោតម្នាក់បានផ្តល់ការវាយតំលៃយ៉ាងទាបថា:

> *"មេឃុំគឺជាប្រធានគណបក្ស -FUNCINPEC- និង SRP គ្មានអំណាចអ្វីទេ ។ ពួកគេមានតែឈ្មោះ ។ ពួកគេខ្លាចការបំភិតបំភ័យ... ពួកគេគ្មានអំណាចទេនៅក្នុងឃុំ ។ ពួកគេធ្វើការដើម្បីប្រាក់ចំណេញសំរាប់គ្រួសារគេ ប៉ុន្តែពួកគេមិនបានដោះស្រាយបញ្ហា"*[៤៤] ។

---

៤៤ COMFREL provincial representative (10), Kompong Cham, personal interview, 9 July 2003.

ដូចគ្នាដែរ សកម្មជនថ្នាក់ខេត្តរបស់ SRP នៅកំពតបានលើកឡើងថា "យើងគ្មានអំណាចទេក្នុងក្រុមប្រឹក្សាឃុំ ។ មានតែមេឃុំទេដែលមានអំណាច ។ ពួកគេមិនផ្តល់អំណាចទៅឱ្យជំទប់ទី១ និងទី២ ទេ"[៤៥] ។ ទោះបីមានការត្អូញត្អែរបែបនេះ និងទោះបីក្រុមប្រឹក្សាឃុំមានសកម្មភាពកិតទាបនៅឡើយ ប៉ុន្តែក៏គ្មានរបាយការណ៍ណាមួយដែរដែលថា ការរៀបចំបែងចែកអំណាចនៅក្នុងឃុំទទួលបរាជ័យទាំងស្រុង ។ ជាក់ស្តែងទៅ គណបក្សជំទាស់ដែលមានមុខតំណែងនៅក្នុងអាជ្ញាធរមូលដ្ឋាន ទោះបីមានតែឈ្មោះក្តី ក៏ផ្តល់ភាពពេញលក្ខណៈច្បាប់ដល់ពួកគេក្នុងឋានៈជាអ្នកចូលរួមក្នុងជីវិតនយោបាយ ។ បើធៀបនឹងរយៈពេលពីឆ្នាំ១៩៩៣-១៩៩៨ នៅពេលដែលផ្លាកររបស់គណបក្សត្រូវបានវាយបំផ្លាញជាទៀងទាត់ និងយ៉ាងចំហ និងនៅពេលដែលគណបក្សនយោបាយនានា ត្រូវបានអាជ្ញាធរមូលដ្ឋានប្រើកំលាំងរារាំងមិនឱ្យបើកការិយាល័យនៅជនបទ ដោយសំអាងថាការិយាល័យបែបនេះ គ្មានការអនុញ្ញាតទេ, ដូច្នេះរយៈពេលពីឆ្នាំ២០០១-២០០៣ អាចសំគាល់ថាមានការរីកចំរើនច្រើននៃរបបពហុបក្សក្នុងទូទាំងប្រទេស ។ មន្ត្រីជាន់ខ្ពស់ម្នាក់ក្នុងយុទ្ធនាការឃោសនារបស់ SRP បានកត់សំគាល់ថា:

> *"ក្នុងពេលឃោសនាបោះឆ្នោតឆ្នាំ១៩៩៨ យើងមាន ៧០០-៨០០ផ្លាកសញ្ញា ក្នុងទូទាំងប្រទេស ។ ឥឡូវនេះយើងមាន ៨.០០០ ។ មានការបំភិតបំភ័យ និងអំពើហិង្សា ប៉ុន្តែនៅតែមានអ្នកត្រៀមខ្លួនលើកផ្លាកសញ្ញា ។ មានមនុស្សកាន់តែច្រើនដែលហ៊ានក្រោកឈរ និងរាប់បញ្ចូលបាន"*[៤៦] ។

ក្នុងការឃោសនាបោះឆ្នោតឆ្នាំ២០០៣ រឿងខាងលើធ្វើឱ្យបុគ្គលមកពីគ្រប់គណបក្សនយោបាយ មានសេរីភាពកាន់តែច្រើនក្នុងការបង្ហាញពីចំណងខ្សែរយៈខាងនយោបាយ និងធ្វើការឃោសនាឱ្យគណបក្សរបស់ខ្លួន ។

ការសិក្សារបស់ វិបសអ ពីការបោះឆ្នោតឆ្នាំ១៩៩៨ បង្ហាញថា តួនាទីរបស់អាជ្ញាធរមូលដ្ឋានជាប្រភពព្រួយបារម្ភដ៏ធំមួយចំពោះតួអង្គខាងនយោបាយ និងសង្គមស៊ីវិលមួយចំនួន និងត្រូវបានលើកឡើងម្តងហើយម្តងទៀតថាជាមូលហេតុចំបងនៃទំនាស់ក្នុងការបោះឆ្នោតទាំងនោះ ។ ការសិក្សារបស់ វិបសអ ដែលបោះផ្សាយនៅឆ្នាំ២០០២ ស្តីពីកិតចំណេះដឹងទាក់ទិននឹងរបៀបរបបគ្រប់គ្រងទំនាស់នៅថ្នាក់មូលដ្ឋាន បានបង្ហាញថា មន្ត្រីថ្នាក់ឃុំគឺជាអ្នកគ្រប់គ្រងទំនាស់ដ៏សំខាន់បំផុត ។ ដូច្នេះហើយកំណែទំរង់ដ៏ជ្រាលជ្រៅនៃស្ថាប័នថ្នាក់នេះដែលកើតចេញពីការបោះឆ្នោតឃុំឆ្នាំ២០០២ គឺជាទិដ្ឋភាពមួយសំខាន់បំផុតនៃការផ្លាស់ប្តូរខាងនយោបាយ ។

## ២.៥ វិស័យមានការរីកចំរើនតិចៈ ប្រព័ន្ធផ្សព្វផ្សាយ

ការពិនិត្យឡើងវិញពីការវិវត្តន៍ខាងនយោបាយពីឆ្នាំ១៩៩៨-២០០៣ បានបង្ហាញដែរថា ក្នុងចំណោមប្រភពទំនាស់នានាដែលរកឃើញក្នុងការសិក្សាពីការបោះឆ្នោតឆ្នាំ១៩៩៨ នៅមានវិស័យចំបងមួយដែលតួអង្គនយោបាយកម្ពុជានានា មិនទាន់ដោះស្រាយបានច្រើននោះគឺ លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ។ អ្នកសង្កេតការណ៍នៅកម្ពុជាបានទទួលស្គាល់ជាទូទៅថា នៅឆ្នាំ២០០៣ ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិករបស់រដ្ឋ និងឯកជន បន្តបង្ហាញបទ្ទាត់វិចារណកថាដែលគាំទ្រ CPP យ៉ាងខ្លាំង ។ សំណើរបស់ SRP នូវអាជ្ញាប័ណ្ណដើម្បីបើកស្ថានីយវិទ្យុរបស់ខ្លួនផ្ទាល់មួយ នៅតែត្រូវបដិសេធ ។ លើកលែងតែក្នុងករណីមួយ-ពីរចេញ គណបក្សផ្សេងក្រៅពី CPP ចេញ មានលទ្ធភាពតិចតួចណាស់ក្នុងការប្រើប្រាស់កម្មវិធីពត៌មាន ឬទិញម៉ោងធ្វើឃោសនាខាងនយោបាយនៅក្នុងវិទ្យុ និងទូរទស្សន៍នៅកម្ពុជា ។

នៅឆ្នាំ២០០៣ អង្គការអន្តរជាតិបានដោះស្រាយបញ្ហាខាងលើតាមរយៈកម្មវិធីជាច្រើន ។ ក្នុងនេះកម្មវិធីលេចធ្លោមានដូចជា កម្មវិធីស្មើភាពគ្នារបស់ UNDP ដែលខិតខំបើកលទ្ធភាពដល់គ្រប់គណបក្សនៅក្នុងនាទីពត៌មានរបស់ស្ថានីយវិទ្យុ និង

---

[៤៥] SRP provincial activist (11), Kampot, personal interview, 16 July 2003.

[៤៦] SRP national representative (12), personal interview, Phnom Penh, 4 July 2003.

ទូរទស្សន៍រដ្ឋ, កម្មវិធីស្មើភាពគ្នារបស់ គជប ដែលផ្តល់ម៉ោងផ្សព្វផ្សាយស្មើគ្នាដល់គ្រប់គណបក្សនយោបាយ ដើម្បីធ្វើឃោសនា, ការផ្សព្វផ្សាយក្នុងប៉ុស្តលេខ៩ និងក្នុងវិទ្យុ ។ ការលូតលាស់មួយទៀតគឺ ការផ្សព្វផ្សាយបន្តតាមរយៈវិទ្យុសំបុកឃ្មុំនូវបទយកពត៌មានពីការបោះឆ្នោតរបស់វិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ។ ក្នុងពេលនោះ នៅតែមានបញ្ហានៃការព្យាយាមរារាំងពីមជ្ឈដ្ឋានផ្លូវការនូវការផ្សព្វផ្សាយបន្តពីវិទ្យុអាស៊ីសេរី និង VOA នេះ, ការតវ៉ារបស់គណបក្សនយោបាយទាក់ទិននឹងកម្មវិធីស្មើភាពគ្នារបស់ UNDP និងការខ្វែងមតិរវាង គជប និងស្ថានីយទូរទស្សន៍/វិទ្យុឯកជននៅកម្ពុជា ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថានីយទាំងនេះក្នុងការផ្សព្វផ្សាយពត៌មានពីការបោះឆ្នោត ។ កម្មវិធីពិសេស១រៀបចំឡើងសំរាប់ការបោះឆ្នោត បានបើកចំហក្នុងប្រព័ន្ធផ្សព្វផ្សាយច្រើនជាងកាលពីការបោះឆ្នោតលើកមុន១ ។ ប៉ុន្តែការរៀបចំពិសេស១សំរាប់ការបោះឆ្នោតទាំងនេះ បានបញ្ឈប់ភ្លាមក្រោយពេលចប់ការបោះឆ្នោត ហើយហាក់ដូចមានកំណែទំរង់តិចតួចណាស់ក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធផ្សព្វផ្សាយដែលជាលទ្ធផលទទួលបានពីការបោះឆ្នោត ។

# ជំពូកទី ៣

## ការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន ~ ករណីសិក្សាប្រៀបធៀបគ្នា

### ៣.១ ការជ្រើសរើសករណីសិក្សា

*៣.១.១ ការជ្រើសរើសខេត្ត*

ការជ្រើសរើសខេត្តធ្វើតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ។ ខេត្តជ្រើសរើសមានលក្ខណៈខុសគ្នាទាំងខាង ទីតាំង ប្រជាជន កំរិតនៃការតវ៉ាខាងនយោបាយ និងប្រវត្តិនៃអំពើហិង្សា ។ ខេត្តទាំងនេះជ្រើសរើសចេញពីភាគពាយ័ព្យ (បាត់ដំបង) នីរតី (កំពត) បូព៌ា (កំពង់ចាម) និងអគ្នេយ៍ (តាកែវ) ។ ភាគឦសានមិនបានជ្រើសរើសយកទេ ពីព្រោះពិបាកទៅកាន់តំបន់នោះឱ្យបានទៀងទាត់ ។ ខេត្តជ្រើសរើសមានចំនួនប្រជាជនទាំងមធ្យម និងខ្ពស់ គឺកំពត និងតាកែវ មានតំណាងនៅរដ្ឋសភា ៦នាក់ និង ៩នាក់ រីឯបាត់ដំបង និងកំពង់ចាម មានដល់ ១២នាក់ និង ១៨នាក់ ។ កំរិតប្រណាំងប្រជែងខាងនយោបាយក៏ខុសគ្នាដែរ ដោយសារមួយចំណែកគឺ ប្រវត្តិនយោបាយខុសៗគ្នានៃខេត្តទាំងនេះ ។ លំនាំការបោះឆ្នោតក្នុងខេត្តទាំង៤ មានបង្ហាញក្នុងឧបសម្ព័ន្ធ ក តារាង១, រីឯលទ្ធផលនៃគណបក្សចំបងៗក្នុងខេត្តទាំងនេះ ធៀបនឹងលទ្ធផលមធ្យមកំរិតជាតិ មានចុះក្នុងឧបសម្ព័ន្ធ ក ក្រាហ្វិក១-៤ ។

ការប្រៀបធៀបលទ្ធផលរបស់គណបក្ស ក្នុងខេត្តករណីសិក្សានីមួយៗ ក្នុងពេលបោះឆ្នោតជាបន្តបន្ទាប់ ដោយពិនិត្យតាមមធ្យមភាគកំរិតជាតិ (ក្រាហ្វិក១-៤) បានបង្ហាញពីចរិតផ្ទុយគ្នានៃខេត្តទាំងនេះ ។ កំពង់ចាមបន្តគាំទ្រគណបក្សជំទាស់រហូត ដោយខាងជំទាស់តែងទទួលបានភាគរយសន្លឹកឆ្នោតក្នុងខេត្តនេះ ខ្ពស់ជាងអត្រាទទួលបានគិតក្នុងប្រទេសទាំងមូល ចំណែកឯ CPP ទទួលបានភាគរយសន្លឹកឆ្នោតក្នុងខេត្តនេះ ទាបជាងមធ្យមភាគទទួលបានក្នុងទូទាំងប្រទេសជានិច្ច ។ ថ្វីបើមណ្ឌលបោះឆ្នោតនេះហាក់ដូចមាន "សុវត្ថិភាព" ក្តី ប៉ុន្តែដោយសារជាខេត្តមានអាសនៈច្រើនបំផុតនៅសភា ដូច្នេះការប្រកួតប្រជែងគ្នាតែងក្តៅគគុកជានិច្ច ។ ផ្ទុយទៅវិញ នៅតាកែវ CPP បានលទ្ធផលល្អជាប់រហូតធៀបនឹងក្រុមគណបក្សជំទាស់រួមគ្នា (ក្នុងខេត្តនេះ FUNCINPEC មានការធ្លាក់ចុះទាបជាងកំរិតជាមធ្យម ប៉ុន្តែលទ្ធផលអន់របស់ SRP ធ្វើឱ្យ CPP អាចនៅតែឈ្នះលើគណបក្សជំទាស់គូបគ្នា) ។ ជាប្រវត្តិសាស្ត្រ តាកែវមិនសូវមានការតឹងតែងខ្លាំងក្នុងការបោះឆ្នោតទេ បើធៀបនឹងតំបន់ឯទៀតៗ ដូច្នេះយើងជ្រើសយកខេត្តនេះក្នុងលក្ខណៈជាតំបន់ដែលយើងគិតថា នឹងពុំមានទំនាស់អ្វីធំដុំទេ ។

ខេត្តបាត់ដំបងដែលមានប្រវត្តិ "តស៊ូ" ជាប្រពៃណី បានផ្តល់លទ្ធផលប្លែកគ្នាជាខ្លាំងគឺ FUNCINPEC ធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ រីឯ SRP បានកើនឡើងយ៉ាងច្រើន ។ CPP បានឈ្នះគេជាលើកទី១ ក្នុងការបោះឆ្នោតឆ្នាំ២០០២ ។ ទំហំនៃការស្ទុះឡើងនៅក្នុងខេត្តមួយដែលមានអាសនៈច្រើន ធ្វើឱ្យគេសំគាល់ខេត្តនេះថាជាសមរភូមិដ៏សំខាន់មួយក្នុងការបោះឆ្នោតឆ្នាំ២០០៣ ។ ដូចគ្នាដែរ កំពត ដែលជាបង្អែកដ៏រឹងមាំរបស់ CPP តាំងពីយូរមកហើយ បានផ្តល់ជាលើកទី១ នៅឆ្នាំ២០០២ ដល់គណបក្សជំទាស់គូបគ្នានូវកំណើនលទ្ធផលជិតដល់ ៤៥% នៃសន្លឹកឆ្នោត គឺខ្ពស់ជាងមធ្យមភាគកំរិតជាតិរបស់ខាងជំទាស់ ។ ផ្ទុយទៅវិញ CPP

ទទួលបានសន្លឹកឆ្នោតទាបជាងមធ្យមភាគកំរិតជាតិរបស់ខ្លួនជាលើកទី១នៅឆ្នាំ២០០២ ។ នៅកំពត មានកើតអំពើហិង្សាយ៉ាងច្រើននៅជុំវិញការបោះឆ្នោតឆ្នាំ២០០២ និង ២០០៣ ដូច្នេះខេត្តនេះត្រូវបានចាត់ទុកជាខេត្តមានការប្រកួតប្រជែងកំរិតខ្ពស់ ។

លក្ខណៈវិនិច្ឆ័យមួយទៀតដែលបានប្រើក្នុងការជ្រើសរើសខេត្តករណីសិក្សានានា គឺស្ថានភាពខេត្តទាំងនោះ ទាក់ទិននឹងសង្គ្រាមស៊ីវិល ។ ក្នុងគំរូតាងមាន ២ខេត្តដែលធ្លាប់មានការប្រយុទ្ធច្រើនគួរកត់សំគាល់រហូតមកដល់ក្នុងទសវត្សរ៍១៩៩០ (បាត់ដំបង និងកំពត) និង ២ខេត្តដែលមានសង្គ្រាមតិចជាងជាខ្លាំង តាំងពីមានចុះកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ (កំពង់ចាម និងតាកែវ) ។ ប៉ុន្តែគួរកត់សំគាល់ថា អំពើហិង្សាមានច្រើនគួរសមនៅកំពង់ចាម ក្នុងរូបភាពជាការសំលាប់ក្រៅផ្លូវតុលាការនៅពេលមានការប្រយុទ្ធគ្នាខាងយោធានៅភ្នំពេញក្នុងឆ្នាំ១៩៩៧ ។

នៅកំរិតខេត្ត ការស្រាវជ្រាវមានធ្វើជាបទសំភាសន៍ពាក់កណ្តាលរៀបរយជាមួយអ្នកឆ្លើយសំភាសន៍ ដែលមានតួនាទីអាចផ្តល់មតិពីស្ថានភាពក្នុងខេត្តទាំងមូលបាន មានជាអាទិ៍ អ្នកសង្កេតការណ៍បោះឆ្នោតបំរើការក្នុងការិយាល័យខេត្តរបស់បណ្តាញសង្កេតការណ៍បោះឆ្នោត, មន្ត្រីការិយាល័យខេត្តរបស់គណបក្សនយោបាយ, តំណាងគណបក្សថ្នាក់ជាតិដែលទទួលបន្ទុករៀបចំការឃោសនាបោះឆ្នោតក្នុងខេត្ត, និងសមាជិក គខប ។ ពួកគេត្រូវបានជ្រើសរើសក្នុងលក្ខណៈជាតំណាងគណបក្សធំៗទាំង៣ សង្គមស៊ីវិល និងរដ្ឋ ។

### *៣.១.២ ការជ្រើសរើសឃុំ*

ក្នុងខេត្តនីមួយៗ មានជ្រើសយកឃុំមួយចំនួនសំរាប់ចុះសិក្សាលំអិតដល់កន្លែង គឺមានៈ

- ឃុំត្នោត ក្នុងស្រុកបាទី ខេត្តតាកែវ
- ឃុំតាខែន ក្នុងស្រុកឈូក ខេត្តតាកែវ
- ឃុំវាលវង់ ក្នុងស្រុកកំពង់ចាម ខេត្តកំពង់ចាម
- ឃុំពាមឯក ក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង
- ឃុំវត្តតាមឹម ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង

លក្ខណៈវិនិច្ឆ័យទី១ សំរាប់ជ្រើសរើសឃុំ ឆ្លុះបញ្ចាំងពីចំណុចផ្តោតនៃការសិក្សា ក្នុងការពិនិត្យពីផលប៉ះពាល់នៃក្រុមប្រឹក្សាឃុំទៅលើការរីករាលដាលទំនាស់ និងការគ្រប់គ្រងទំនាស់ ។ ដូច្នេះហើយ ឃុំត្រូវជ្រើសយកដោយយោងតាមលក្ខណៈពហុបក្សក្នុងក្រុមប្រឹក្សាឃុំ ។ ឃុំត្នោត និងឃុំវាលវង់ មានកំរិតពហុបក្សខ្ពស់ ។ ឃុំត្នោតមានសមាជិកក្រុមប្រឹក្សាឃុំ ៧នាក់ ក្នុងនេះ ៣នាក់តំណាងឱ្យ CPP, ៣នាក់តំណាង FUNCINPEC, និង ១នាក់តំណាង SRP ។ ឃុំវាលវង់ មានសមាជិកក្រុមប្រឹក្សាឃុំ ១១នាក់ គឺ ៥នាក់តំណាងឱ្យ CPP, ៥នាក់តំណាងSRP, និង ១នាក់ តំណាង FUNCINPEC ។ ឃុំសិក្សាទាំង២ នៅបាត់ដំបង មានសមាសភាពក្រុមប្រឹក្សាឃុំដូចគ្នា ហើយ CPP មានច្រើនជាងគេ ដោយក្រុមប្រឹក្សាឃុំនីមួយៗមាន ៧នាក់ជាតំណាង CPP, ៣នាក់ជា FUNCINPEC, និង ១នាក់ជា SRP ។ ក្នុងឃុំករណីសិក្សាទាំងអស់ CPP បានទទួលជ័យជំនះនៅឆ្នាំ២០០២ ដែលឆ្លុះបញ្ចាំងពីកំណើនប្រជាប្រិយភាពរបស់ CPP នៅឆ្នាំនោះក្នុងទូទាំងប្រទេស ។ ប៉ុន្តែក្នុង ២ឃុំករណីសិក្សា (វាលវង់ និងឯកភ្នំ) SRP បានឈ្នះក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ និងក្នុង ២ឃុំទៀត (វត្តតាមឹម និងត្នោត) FUNCINPEC បានឈ្នះនៅឆ្នាំ១៩៩៨ ។ ដូច្នេះ ឃុំទាំង៤ តំណាងឱ្យករណីដែល CPP ប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងតឹងតែងពីគណបក្សផ្សេងទៀត ។

ឃុំតាខែន មានសមាជិកក្រុមប្រឹក្សាឃុំ ៥នាក់មកពី CPP, និង ១នាក់មកពី FUNCINPEC ។ ប៉ុន្តែសមាជិកជា CPP ក្នុងឃុំនេះ ទើបតែចូលគណបក្សក្នុងពេលថ្មីៗ ពីព្រោះឃុំនេះស្ថិតក្នុងតំបន់ត្រួតត្រាដោយកងទ័ពជាតិនៃកម្ពុជាប្រជាធិបតេយ្យ

(NADK) ចាប់ពីឆ្នាំ១៩៧០ រហូតដល់១៩៩៦ ។ នៅឆ្នាំ១៩៩៦ មេបញ្ជាការ NADK ក្នុងតំបន់នោះ បានចុះចូលរដ្ឋាភិបាល ហើយក៏ត្រូវបានរក្សាទុកនៅនឹងកន្លែង ។ ដូច្នេះ សមាជិកក្រុមប្រឹក្សាឃុំនៅខាង CPP គឺជាអតីតមេបញ្ជាការ NADK ដែលធ្លាប់កាន់អំណាចយូរមកហើយនៅក្នុងតំបន់ ។ ករណីសិក្សានេះបានផ្តល់ឱកាសឱ្យពិនិត្យមើលពីនយោបាយនៃការបោះឆ្នោតនៅក្នុងតំបន់ទើបធ្វើសមាហរណកម្មថ្មី ។

ក្រៅពីខ្សែរយៈផ្សារភ្ជាប់ខាងនយោបាយ ឃុំទាំង ៥ មានលក្ខណៈខាងសេដ្ឋកិច្ច-សង្គមកិច្ចខុសគ្នាជាខ្លាំង ។ តាខែនជាឃុំជនបទក្រីក្របំផុតមួយ ស្ថិតនៅក្នុងតំបន់ដ៏ឆ្ងាយដាច់ស្រយាល ។ ដោយសារប្រវត្តិខាងនយោបាយ និងទីតាំងភូមិសាស្ត្រឃុំនេះទទួលឥទ្ធិពលតិចតួចពីដំនើរការពង្រឹងអំណាចរដ្ឋ និងការជ្រាបចូលនៃមូលធននិយម ។ ឃុំនេះស្ថិតនៅក្រោមការត្រួតត្រារបស់ NADK ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៦ ដូច្នេះត្រូវកាត់ផ្តាច់ពីតំបន់ឯទៀត រហូតដល់ការធ្វើសមាហរណកម្មឃុំនៅពេលបញ្ចប់សង្គ្រាម ។ ដោយមូលហេតុខាងលើ ឃុំនេះមិនបានបោះឆ្នោតទេនៅឆ្នាំ១៩៩៣ និង ១៩៩៨ ដូច្នេះអ្នកភូមិមានតែបទពិសោធន៍នៃការបោះឆ្នោតឆ្នាំ២០០២ ប៉ុណ្ណោះ ដើម្បីត្រៀមខ្លួនធ្វើការបោះឆ្នោតកំរិតជាតិឆ្នាំ២០០៣ ។

ត្នោត ក៏ជាឃុំជនបទដែរ ប៉ុន្តែគេអាចសង្កេតឃើញថាធូរធារជាងឃុំតាខែន ។ ដោយស្ថិតនៅជិតភ្នំពេញ និងផ្លូវជាតិធំៗឃុំតាខែនជាមជ្ឈមណ្ឌលចំបាញ់ស្ករត្នោតដ៏សំខាន់មួយ ។ ឃុំនេះតូចទេ ប៉ុន្តែមានដង់ស៊ីតេប្រជាជនខ្ពស់ (៦.៦១៨នាក់ រស់នៅលើផ្ទៃដីតែ ១.៤០១ហិកតា) ។ ដូចគ្នាដែរ ឃុំពាមឯកស្ថិតនៅប្រហែល ១៥គ.មពីទីរួមខេត្តបាត់ដំបង មានប្រជាជនច្រើនណាស់ (១៥.០០០នាក់) និងងាយស្រួលចុះឡើងទៅទីផ្សារ ។ ឃុំនេះសំបូរចំការដំណាំហូបផ្លែ ហើយអ្នកភូមិក៏មានធ្វើស្រែ ធ្វើជំនួញតូចតាច ដូចជា កិនស្រូវជាដើម ធ្វើនេសាទ ជួញផ្លែឈើ និងមានធ្វើចំណាកស្រុកជារឿយៗទៅធ្វើការនៅថៃ ។ ឃុំវត្តតាមឹមស្ថិតនៅប្រហែល ១៨គ.ម ពីក្រុងបាត់ដំបង ក្នុងតំបន់ដីជីជាតិល្អ ដោយសារល្បាប់ដែលវង្គទឹកជំនន់ស្ទឹងសង្កែបាននាំយកមក ។ ឃុំមានផ្ទៃដី ៣២គ.ម$^2$ ហើយសកម្មភាពសេដ្ឋកិច្ចមានជាអាទិ៍ ដំណាំស្រូវ ចំការក្រូចនិងដំណាំហូបផ្លែផ្សេងទៀត ជំនួញតូចតាច និងចំណាកស្រុកទៅធ្វើការនៅថៃ ។ រីឯឃុំវាលវង់ គឺជាតំបន់ទីក្រុង នៅជាយទីរួមខេត្តកំពង់ចាម ។ ឃុំនេះមាន ៦ភូមិ និង ប្រជាជន ១៥.០០០នាក់ ដែលភាគច្រើនធ្វើជំនួញតូចតាចនៅក្រុងកំពង់ចាម ជាពិសេសលក់ដូរនៅទីផ្សារ ។ ដោយសារជាចំណែកមួយនៃទីក្រុងដ៏ធំ ប្រជាជនឃុំនេះមានការងាយស្រួលជាខ្លាំងក្នុងការទទួលបានពត៌មាន ដូចជា សារពត៌មានលក់នៅក្នុងក្រុង, ការិយាល័យថ្នាក់ខេត្តនៃបណ្តាអង្គការសិទ្ធិមនុស្ស និងគណបក្សនយោបាយ ។ ក្នុងទីក្រុង ក៏មានការដង្ហែក្បួនធំៗខាងនយោបាយ ធ្វើដោយអ្នកដឹកនាំគណបក្សក្នុងពេលឃោសនាបោះឆ្នោត ហើយប្រជាជនឃុំវាលវង់ ក៏អាចចូលរួមយ៉ាងងាយស្រួលក្នុងព្រឹត្តិការណ៍ទាំងនេះបាន ។

ក្រុមស្រាវជ្រាវបានចុះដល់ឃុំមួយៗ ពាដងក្នុងរយៈពេលឃោសនាបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ ក្នុងឃុំនីមួយៗមានការប្រឹងប្រែងស្វែងរក និងធ្វើសំភាសន៍តួអង្គខាងនយោបាយសំខាន់ៗទាំងអស់ គឺមានសកម្មជនចុះឃោសនារបស់គណបក្សធំៗ, តំណាងនៃគណបក្សនីមួយៗនៅក្នុងក្រុមប្រឹក្សាឃុំ មេឃុំ ប្រធានភូមិ និងសមាជិក គឃប ។ ប្រធានបទលើកមកសួរក្នុងសំភាសន៍មានជាអាទិ៍ ចំណាប់អារម្មណ៍នៃតួអង្គនីមួយៗពីតួនាទីរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត, ចំណាប់អារម្មណ៍របស់ពួកគេពីអត្ថន័យនៃពាក្យ "ទំនាស់", ការបារម្ភពីទំនាស់ដែលបានផុសឡើង ឬអាចផុសឡើង ក្នុងដំណើរការបោះឆ្នោត, ចំណាប់អារម្មណ៍របស់ពួកគេពីយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់ដែលបានប្រើប្រាស់, តួនាទីរបស់ពួកគេក្នុងរឿងទាំងអស់នេះ, និងការយល់ឃើញទាក់ទិននឹងការវិវត្តន៍ដំណើរការគ្រប់គ្រងទំនាស់តាំងពីឆ្នាំ១៩៩៨ មក ។ ចំណុចបានយកចិត្តទុកដាក់ជាពិសេសមួយគឺចំណាប់អារម្មណ៍ពីការផ្លាស់ប្តូរតួនាទីនៃស្ថាប័ននានា, ចំណាប់អារម្មណ៍ពីលទ្ធភាពមានពត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ, និងចំណាប់អារម្មណ៍ពីគុណភាពនៃដំណើរការចុះបញ្ជីអ្នកបោះឆ្នោត ។

## ៣.២ ការបង្ហាញលទ្ធផលរកឃើញក្នុងមួយករណីៗ

### *៣.២.១ ឃុំវាលវង់ ក្នុងស្រុកកំពង់ចាម ខេត្តកំពង់ចាម*

#### *៣.២.១.១ អាជ្ញាធរឃុំ និងនយោបាយ*

វាលវង់ គឺជាឃុំទីក្រុងមួយ ស្ថិតនៅជាយទីរួមខេត្តកំពង់ចាម ក្នុងស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ ឃុំនេះ មាន ៦ភូមិ និងប្រជាជន ១៥.០០០នាក់ ។ ក្រុមប្រឹក្សាឃុំមានសមាជិក ១១នាក់ គឺខាង CPP ៥នាក់, SRP ៥នាក់, និង FUNCINPEC ១នាក់ ។ មេឃុំគឺជា CPP, ជំទប់ទី១ ជា SRP, និងជំទប់ទី២ ជា FUNCINPEC ។ កំពង់ចាម ជាខេត្តគាំទ្រគណបក្សជំទាស់យ៉ាងខ្លាំង ហើយឃុំវាលវង់ ក៏ដូច្នេះដែរ ។ នៅឆ្នាំ១៩៩៨ SRP បានឈ្នះយ៉ាងងាយក្នុងខេត្តនេះ ដោយទទួលបានសន្លឹកឆ្នោត ៤២%, ធៀបនឹង FUNCINPEC ២៩%, និង CPP ២១% ។ ប៉ុន្តែនៅឆ្នាំ២០០២ CPP បានយកឈ្នះលើ SPR បន្តិចបន្តួចត្រឹម ០,៥៣% នៃសន្លឹកឆ្នោត ។ លំនាំបោះឆ្នោតក្នុងការបោះឆ្នោត ៣លើកចុងក្រោយមានដូចតទៅ:

**ប្រវត្តិនៃការបោះឆ្នោត: ឃុំវាលវង់** [៤៧]

| | |
|---|---|
| 1998 | 1st SRP, 2nd FUNCINPEC, 3rd CPP |
| 2002 | 1st CPP, 2nd SRP, 3rd FUNCINPEC |
| 2003 | 1st SRP, 2nd CPP, 3rd FUNCINPEC |

មានរបាយការណ៍ខុសៗគ្នាពីទំនាក់ទំនងរវាងគណបក្សនានាក្នុងឃុំ ។ តាមមេឃុំដែលជាតំណាង CPP ទំនាក់ទំនងគឺល្អូនល្អ ។

*"គ្មានបញ្ហាអ្វីទេរវាង CPP និង SRP នៅក្នុងក្រុមប្រឹក្សាឃុំ ។ យើងមានយោបល់ខុសគ្នាពីអ្វីដែលអាចធ្វើបាន ។ ប៉ុន្តែ សំរាប់រឿងភាគច្រើន យើងមើលច្បាប់ ហើយធ្វើអ្វីៗទៅតាមច្បាប់ ។ យើងខិតខំសំរបសំរួល ។ យើងពិនិត្យបទប្បញ្ញត្តិផ្សេងៗដើម្បីរកមើលថា ក្រែងមានអ្វីខុសច្បាប់ ។ យើងទៅប្រជុំជាមួយ គឃប ហើយនិយាយពីអ្វីដែលយើងប្រុងធ្វើស្របទៅតាមក្រមសីលធម៌ ។ នេះជារឿងសំខាន់ជាងគេ"* [៤៨] ។

ជំទប់ទី២ ដែលជាសមាជិក FUNCINPEC បានឯកភាពនឹងមតិនេះ ។ ប៉ុន្តែជំទប់ទី១ មកពី SRP មានយោបល់ខុសប្លែកគ្នា:

*"ទោះបីជាយើងបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំក្តី ប៉ុន្តែ ស្រុក និងគណបក្ស នៅតែត្រួតត្រាលើអ្វីៗទាំងអស់ ។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ អ្នកមកពីគណបក្សជំទាស់នៅតែត្រូវរំលងចោល"* [៤៩] ។

លោកជំទប់ក៏បានអះអាងដែរថា "ប្រធានភូមិទាំងអស់នៅជារបស់ CPP ហើយពួកគេប្រហែលអាចបង្កទំនាស់ក្នុងតំបន់មូលដ្ឋាន" ។ គាត់បានរែកញែកថា បញ្ហារីករាលដាលពីកំរិតមូលដ្ឋានពីព្រោះ "ប្រជាជនក្នុងឃុំ និងអាជ្ញាធរភូមិ នៅតែមានខ្សែរយៈចងភ្ជាប់ជាមួយគណបក្ស ហើយពួកគេធ្វើការឱ្យគណបក្សមិនមែនឱ្យរដ្ឋទេ" [៥០] ។

---

[៤៧] លទ្ធផលសំរាប់ឆ្នាំ១៩៩៣ មិនបានកត់ត្រាទេ ពីព្រោះនៅឆ្នាំនោះសន្លឹកឆ្នោតយកទៅរាប់នៅខេត្ត ហើយលទ្ធផលតាមឃុំ មិនបានផ្សព្វផ្សាយទេ ។

[៤៨] Commune Chief, Veal Vong (13), personal interview, Kompong Cham, 9 July 2003.

[៤៩] SRP First Deputy Commune Chief, Veal Vong (14), personal interview, Kompong Cham, 9 July 2003.

[៥០] SRP First Deputy Commune Chief, Veal Vong (14), personal interview, Kompong Cham, 9 July 2003.

បទសំភាសន៍ជាមួយប្រធានភូមិម្នាក់ក្នុងឃុំវាលវង់ ហាក់ដូចបានបញ្ជាក់គាំទ្រមតិខាងលើ ។ ប្រធានភូមិបានលើកឡើងថា "យើងធ្វើការយ៉ាងខ្លាំងដើម្បីពន្យល់ប្រជាជនអំពីកម្មវិធីនយោបាយរបស់ CPP ប៉ុន្តែគណបក្សឯទៀតក៏មានសិទ្ធិលើកបង្ហាញពីកម្មវិធីនយោបាយរបស់ខ្លួនដូចគ្នាដែរ" ។ គាត់បន្ថែមថា:

*"សព្វថ្ងៃខ្ញុំធ្វើការឱ្យរដ្ឋ មិនមែនឱ្យគណបក្សទេ ប៉ុន្តែគណបក្ស និងរដ្ឋ គឺដូចតែគ្នា ។ ឥឡូវនេះមានវិស័យពីរ: មួយគឺរដ្ឋ, មួយគឺគណបក្ស ។ ខ្ញុំធ្វើការឱ្យទាំងពីរ... នៅកន្លែងខ្លះ យើងអំពាវនាវប្រជាជនឱ្យបោះឆ្នោតឱ្យគណបក្សនេះ ឬគណបក្សនោះ ប៉ុន្តែនៅភូមិខ្ញុំយើងមិនធ្វើដូច្នេះទេ ។ គ្មានអ្នកណាប្រាប់ខ្ញុំថា នឹងមានអ្វីកើតឡើងបើសិនអ្វីមួយដំណើរការខុស ។ រដ្ឋគ្មានប្រាប់អ្វីខ្ញុំទេ ។ គណបក្សអាចនឹងប្រាប់ខ្ញុំពីអ្វីដែលត្រូវធ្វើ"*[៥១] ។

ប្រធានភូមិដដែលបានទទួលស្គាល់ពីឥទ្ធិពលគណបក្សនៅលើបញ្ហាអភិវឌ្ឍន៍ក្នុងភូមិរបស់គាត់ ។ គាត់ពន្យល់ថា ជំនួយអភិវឌ្ឍន៍ភាគច្រើនមកពី CPP ហើយគាត់រាយការណ៍ទៅការិយាល័យស្រុកនៃ CPP ពីតំរូវការក្នុងភូមិគាត់ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិក CPP ៥នាក់ទៀតនៅក្នុងភូមិ ។ គាត់លើកទៀតថា គាត់ដឹងអ្នកណាចូលគណបក្សណាក្នុងភូមិគាត់ ប៉ុន្តែមិនច្បាស់ទេថា គ្រប់ៗគ្នានឹងបោះឆ្នោតឱ្យគណបក្សរបស់ខ្លួន ។ គាត់បញ្ជាក់ដែរថា គាត់មិនដឹងទេតើពួកក្មេងៗដែលទើបចុះឈ្មោះថ្មីជាអ្នកបោះឆ្នោត នឹងគាំទ្រគណបក្សដូចគ្នានឹងឪពុកពួកគេឬយ៉ាងណា:

*"ជួនកាលគ្រួសារមួយមានកូនធំពេញវ័យ ។ ឪពុកអាចជា CPP ប៉ុន្តែកូនមិនមែនទេ ។ រឿងនេះពិបាកនិយាយបាន ។ ប៉ុន្តែយើងស្តាប់ និងនិយាយថា បើអ្នកចូលគណបក្សនោះនឹងគ្មានការអភិវឌ្ឍន៍ទេ"*[៥២] ។

តួនាទីផ្សេងៗរបស់បុគ្គលនេះ (ជាមន្ត្រីរបស់រដ្ឋ, តំណាងនៃតំរូវការអភិវឌ្ឍន៍ភូមិ, អ្នកបំរើការឱ្យគណបក្ស, និងក្នុងករណីនេះជាប្រធានគណៈកម្មការវត្តក្នុងភូមិផង) ហាក់ដូចជំពាក់ជំពិនគ្នាយ៉ាងខ្លាំង ។ គួរកត់សំគាល់ថា ក្នុងបទសំភាសន៍ជាមួយប្រធានភូមិឯទៀតៗនៅកំពង់ចាម និងកន្លែងផ្សេងទៀត អ្នកឆ្លើយសំភាសន៍បានរាយការណ៍ច្បាស់លាស់ជាងខ្លាំងណាស់ពីការបែងចែកខុសគ្នារវាងតួនាទីទាំងនេះ ។ ប្រធានភូមិភាគច្រើនប្រាប់ថា គាត់មិនបានខិតខំបញ្ចុះបញ្ចូលអ្នកភូមិឱ្យបោះឆ្នោតឱ្យ CPP ទេ ។

ប៉ុន្តែ តំណាង SRP និងអ្នកសង្កេតការណ៍ COMFREL នៅគ្រឹះតខេត្ត បានអះអាងថា ប្រធានភូមិក្នុងទូទាំងខេត្តបានធ្វើសកម្មភាពមួយចំនួនដែលផ្ទុយពីបទប្បញ្ញត្តិ គជប និងដែលគេអាចមានអារម្មណ៍ថា ជាការបំភិតបំភ័យចំពោះអ្នកបោះឆ្នោត ។ មន្ត្រី SRP ម្នាក់ដែលឆ្លើយសំភាសន៍នៅការិយាល័យថ្នាក់ខេត្តនៃ SRP នៅកំពង់ចាម បានអះអាងថា ពួកប្រធានភូមិនៅកំពង់ចាមបានប្រមូលប័ណ្ណបោះឆ្នោតរបស់សមាជិក SRP បានហាមឃាត់ SRP ក្នុងការលើកផ្លាកសញ្ញានៅកន្លែងមួយចំនួន និងបំភិតបំភ័យប្រជាជនមិនឱ្យទៅស្តាប់ SRP ធ្វើការឃោសនា ។ គាត់អះអាងថា មានការប្រើសមាជិកជាអតីតកងស្វ័យត្រាណឱ្យបំភិតបំភ័យប្រជាជនក្នុងឃុំ ហើយ គឃប និង គខប តំណាងឱ្យ CPP និង FUNCINPEC ។ គាត់ឯកភាពជាមួយជំទប់ទី១ឃុំវាលវង់ថា ក្នុងក្រុមប្រឹក្សាឃុំ សមាជិក SRP ត្រូវបានពួកមេឃុំដែលគាំទ្រ CPP រំលងចោល និងគ្មាន "សិទ្ធិអំណាចអ្វីទាំងអស់"[៥៣] ។

មន្ត្រី SRP បានរាយការណ៍ពីការតវ៉ារបស់ SRP ទៅ គខប ពីការរិបអូសយកប័ណ្ណបោះឆ្នោតពីអ្នកគាំទ្រ SRP ដោយមេឃុំម្នាក់នៅស្រុកស្ទឹងត្រង់ ។ គាត់និយាយថា ការខិតខំតវ៉ាទៅ គខប គ្មានបានផលអ្វីទេ ដោយ គខប បានបញ្ជាឱ្យ គឃប ធ្វើ

---

[៥១] Village Chief, Veal Vong Commune (15), personal interview, Kompong Cham, 9 July 2003.

[៥២] Village Chief, Veal Vong Commune (15), personal interview, Kompong Cham, 9 July 2003.

[៥៣] SRP provincial representative (16), personal interview, Kompong Cham, 9 July 2003.

ការសំរបសំរួលយកដំណោះស្រាយ ហើយជាលទ្ធផល ការតវ៉ា "ត្រឡប់ទៅត្រឡប់មក ធ្វើឱ្យយើងអស់ប្រាក់យ៉ាងច្រើន ។ នេះជាឧបសគ្គមួយដ៏ធំចំពោះសកម្មភាពរបស់យើង" ។ តំណាង SRP យល់ថា ការដោះស្រាយទំនាស់មិនបានជោគជ័យនេះគឺដោយសារ SRP មិនត្រូវបានអនុញ្ញាតឱ្យមានតំណាងក្នុង គឃប និង គខប, ហើយស្ថាប័នទាំងនេះ និងអាជ្ញាធរមូលដ្ឋាន "ចេញមកពី CPP ដូច្នេះគេដោះស្រាយមិនយុត្តិធម៌ទេ"[៥៤] ។

អ្នកឃ្លាំមើលរបស់ COMFREL ក្នុងខេត្តម្នាក់ មានមតិថា ការប្រឹងប្រែងរបស់អាជ្ញាធរមូលដ្ឋានដើម្បីត្រួតត្រាលើមជ្ឈដ្ឋានអ្នកបោះឆ្នោត មានលក្ខណៈស៊ីជំរៅជាងក្នុងការបោះឆ្នោតមុនៗ ។ គាត់លើកឡើងថា:

*"កាលពីមុន ការឃោសនាធ្វើតាមភូមិ ឬតាមក្រុម ។ ឥឡូវនេះគេរៀបចំធ្វើវាសំរាប់ ៤ ឬ ៥គ្រួសារ ដូចកាលជំនាន់ ប៉ុល ពត ។ មនុស្សម្នាក់មើលលើ ៤ ឬ ៥គ្រួសារ ហើយនេះជាប្រព័ន្ធ ប៉ុល ពត... មន្ត្រីរាជការមាន ៨០% ជា CPP, ពួកគេបំភិតបំភ័យ និងធ្វើបាបគណបក្សមួយ ។ ពុំមានការជ្រើសរើស គខប ជាសាធារណៈទេ ដូច្នេះការបោះឆ្នោតគឺគ្មានតំលាភាព ។ ពួកគេហ៊ានធ្វើអ្វីៗទាំងអស់ ។ គ្មានការបែងចែកទេរវាងអាជ្ញាធរមូលដ្ឋាន និង គខប"[៥៥] ។*

ប្រធាន គខប នៅកំពង់ចាមនិយាយថា គាត់បានទទួលរបាយការណ៍ពីការបំភិតបំភ័យដោយពួកប្រធានភូមិ ប៉ុន្តែគាត់មិនបានទទួល "ការតវ៉ាអ្វីជាក់លាក់ទេ" ។ ការតវ៉ាតែមួយដែលគាត់បានទទួល គឺជារបស់ SRP ដែលចោទថា ប្រធាមភូមិម្នាក់បាន "កោះប្រជុំប្រជាជនដើម្បីរារាំងការឃោសនា" ។ ប្រធាន គខប និយាយថា គាត់បានចូលរួមការប្រជុំប្រចាំសប្តាហ៍របស់ គឃប ហើយក្នុងនោះបញ្ហាខាងលើត្រូវបានដោះស្រាយដោយមានអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិចូលរួមផង ។ គាត់ពិពណ៌នាពីការពិភាក្សាថា:

*"ពួកគេនិយាយថា អាជ្ញាធរមូលដ្ឋានបំរើគណបក្ស ។ ខ្ញុំនិយាយថា ពួកគេត្រូវតែអព្យាក្រឹត្យ ។ ខាង SRP មិនហ៊ានឆ្លើយតបទេ"[៥៦] ។*

ប្រធាន គខប លើកបន្ថែមថា សិទ្ធិអំណាច គខប លើប្រធានភូមិ គឺមានកំរិត:

*"យើងមិនអាចធ្វើអ្វីៗបានទាំងអស់ទៅលើប្រធានភូមិទេ ។ យើងបានផ្ញើលិខិតទៅសំណូមពរប្រធានភូមិនានាថា អស់លោកជាអាជ្ញាធរមូលដ្ឋាន អស់លោកគួរតែប្រកាន់អព្យាក្រឹតភាព ។ សូមកុំបង្កការលំបាកដល់ SRP"[៥៧] ។*

របាយការណ៍ពីដំណើរការសំរបសំរួលនេះ អាចឆ្លុះបញ្ចាំងពីបញ្ហា២ ដែលបង្កការព្រួយបារម្ភយ៉ាងខ្លាំង និងយ៉ាងទូលំទូលាយជាងក្នុងពេលបោះឆ្នោត ។ ទី១ ការពិភាក្សាដ៏ខ្លីដូចបានរៀបរាប់ខាងលើ និងបែបបទដែលវាបញ្ចប់ទៅ (ខាង SRP មិនហ៊ានឆ្លើយតបទេ) បានគូសរំលេចពីការពិបាកបង្កើត (ក្នុងបរិយាកាសមិនទុកចិត្តគ្នាជាខ្លាំង) នូវវេទិកាមួយដែលក្នុងនេះតំណាងនានាអាចលើកយកមកពិភាក្សាយ៉ាងចំហ មិនមែនគ្រាន់តែឆ្លិបទុកនោះទេ ។ ទី២ វាគូសរំលេចពីចំណាប់អារម្មណ៍របស់ស្ថាប័នបោះឆ្នោតថា ខ្លួនឯងខ្វះសិទ្ធិអំណាចទៅលើអាជ្ញាធរមូលដ្ឋាន ។

---

[៥៤] SRP Provincial representative (16), personal interview, Kompong Cham, 9 July 2003.

[៥៥] COMFREL provincial representative (17), personal interview, Kompong Cham, 9 July 2003.

[៥៦] PEC Chief, Kompong Cham Province (5), personal interview, Kompong Cham, 9 July 2003.

[៥៧] PEC Chief, Kompong Cham Province (5), personal interview, Kompong Cham, 9 July 2003.

គួរយកចិត្តទុកដាក់កត់សំគាល់ថា នៅក៏រិតខេត្តក៏ដូចគ្នាដែរ តួអង្គខុសៗគ្នាមើលឃើញទំនាស់បោះឆ្នោតខុសៗគ្នា ។ ឧទាហរណ៏ ក្នុងបទសំភាសន៏នៅក៏រិតខេត្ត តំណាង COMFREL នៅកំពង់ចាម និងប្រធាន គខប (ដែលជាសមាជិក FUNCINPEC) មានការយល់ឃើញខុសគ្នាពីបញ្ហាចោទ ។ ចំពោះ COMFREL ទំនាស់បោះឆ្នោតផុសចេញពីកង្វះ "ការបែងចែករវាងតួនាទីរបស់រដ្ឋ និងរបស់គណបក្ស ជាពិសេសនៅក៏រិតឃុំ និងភូមិ" ។ រឿងនេះធ្វើឱ្យស្ថាប័នបោះឆ្នោត និងអាជ្ញាធរមូលដ្ឋានខិតខំសំរបសំរួលទំនាស់នានា ជាជាងដោះស្រាយវាទៅតាមច្បាប់ ។ គាត់មានមតិថា "ពួកគេនៅក្នុងរដ្ឋទាំងអស់គ្នា - អ្នកដោះស្រាយគឺ CPP- បើសិនជាបញ្ហាខាងសិទ្ធិមនុស្ស ពួកគេគួរប្រើច្បាប់ -ប៉ុន្តែពួកគេខ្ជិល ឬខ្លាច ឬក៏មិនចេះច្បាប់" ។ ក្នុងគំនិតអ្នកតំណាង COMFREL រឿងនេះជាបញ្ហាខាងនយោបាយ, ជាកង្វះឆន្ទៈនយោបាយដើម្បីដាក់ទោសជនល្មើសដែលគេសន្មតថា មានភក្តីភាពចំពោះ CPP ។ គាត់អះអាងថា គជប និង គខប ត្រូវបានជ្រើសរើសតាមប្រព័ន្ធកូតារវាង CPP និងFUNCINPEC ដូច្នេះហើយមិនអព្យាក្រឹត្យទេ ហើយគាត់បន្ថែមថា " តាមពិតទៅគណបក្សនានាមិនគោរពមុខងាររបស់ គជប និង គខប ទេ"[៥៨] ។

ប្រធាន គខប មានទស្សនះខុសពីនេះ ។ គាត់ឯកភាពថា បញ្ហានានាបានផុសឡើងនៅឆ្នាំ១៩៩៨ ពីព្រោះ បុគ្គលិក គជប និង គខប ជាប់ខ្សែរយៈនយោបាយ ។ ប៉ុន្តែគាត់និយាយថា នៅឆ្នាំ២០០៣ នីតិវិធីជ្រើសរើសបានបដិសេធ "អ្នកដែលមានការគាំទ្រខ្លាំងដល់គណបក្សណាមួយ" ហើយជាលទ្ធផល គខប ថ្មីនានាបានដំណើរការតាមបែបបទអព្យាក្រឹត្យ ។ គាត់បន្ថែមថា ស្តង់ដាសង្កេតការល្អជាងមុននៅឆ្នាំ២០០៣ បានជួយទប់ស្កាត់ការប្រព្រឹត្តិខ្លះរបស់គណបក្សនានាដែល "ខ្លាចការដាក់ទោស" ។ គាត់មានមតិទៀតថា សន្តិសុខល្អជាទូទៅនៅក្នុងខេត្ត ក្រោយពីការកែលំអទំនាក់ទំនងរវាង FUNCINPEC និង CPP និងការបញ្ចប់សង្គ្រាមប្រឆាំងនឹង "ខ្មែរក្រហម" ក៏បានកែលំអបរិយាកាសជាទូទៅសំរាប់ការបោះឆ្នោតដែរ ។ ប៉ុន្តែគាត់ឯកភាពថា អាជ្ញាធរមូលដ្ឋាននៅ "ប្រកាន់បក្សពួក" និង "មានលក្ខណៈនយោបាយ" ហើយរឿងនេះធ្វើឱ្យស្ថានភាពវាពិបាក ជាពិសេសទាក់ទិននឹងការអប់រំអ្នកបោះឆ្នោត ។ ប្រធាន គខប មានមតិថា នៅកន្លែងខ្លះប្រជាជនមានទំនុកចិត្តតិចតួចលើការអប់រំអ្នកបោះឆ្នោតធ្វើដោយអាជ្ញាធរមូលដ្ឋានដែលប្រកាន់បក្សពួក ប៉ុន្តែ ការអប់រំតាមរយៈប្រព័ន្ធផ្សព្វផ្សាយ តាមរលកធាតុអាកាសមិនគ្រប់គ្រាន់ទេ ដើម្បីបញ្ជូនពតិមានឱ្យដល់គោលដៅ ។ គាត់លើកឡើងថា:

> *"ប្រជាជនចូលចិត្តមើលទូរទស្សន៏ និងស្តាប់វិទ្យុ ប៉ុន្តែពេលផ្សាយខ្លីពេក ។ ពួកគេត្រូវការអប់រំជាបុគ្គល -អប់រំប្រជាជនឱ្យដឹង ។ ពេលណាប្រជាជនយល់ច្បាស់ពីការបោះឆ្នោត ពេលនោះនឹងបានប្រសើរឡើងហើយ ពីព្រោះសព្វថ្ងៃ ប្រជាជនខ្លះនៅភ័យខ្លាចនៅឡើយ ។ ពួកគេភ័យខ្លាចថា គណបក្សនានាអាចដឹងថា ពួកគេបោះឆ្នោតឱ្យអ្នកណា ។ រឿងនេះដោយសារពួកគេមិនយល់ពីការបោះឆ្នោតជាសំងាត់ ព្រមទាំងវប្បធម៌នៃការភ័យខ្លាច"[៥៩] ។*

### *៣.២.១.២ ស្ថាប័នបោះឆ្នោត*

នៅឃុំវាលវង់ គឃប មានសមាជិក ៥នាក់ ដែលសុទ្ធតែជាគ្រូបង្រៀន ។ បញ្ហាចំបងដែលសមាជិកជា បុគ្គលិក គឃប រាយការណ៏ថាខ្វះថវិកា ។ ពួកគេនិយាយថា ពិបាកនឹងរៀបចំការប្រជុំតុមូលឱ្យបានច្រើនគ្រប់គ្រាន់ ពីព្រោះខ្វះថវិកា ។ ពួកគេធ្លាប់មានករណីទំនាស់មួយចំនួនត្រូវដោះស្រាយ ។ ករណីលេចធ្លោមួយគឺការតវ៉ាប្រឆាំងនឹងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលបាន "ដាក់ងារឱ្យ ហ៊ុន សែន" ។ សមាជិក CPP ម្នាក់នៅក្នុងឃុំ បានតវ៉ាឡើង ហើយរឿងនេះបានយកមកពិភាក្សាក្នុងការប្រជុំប្រចាំសប្តាហ៏ គឃប នាថ្ងៃទី១១ កក្កដា ២០០៣ ។ ប៉ុន្តែ តាមមន្ត្រី គឃប នានាដែលឆ្លើយសំភាសន៏ រឿងនេះត្រូវបានសំរេចជាមុនថា ហួសពីសមត្ថភាពសំរបសំរួលរបស់ពួកគេ ហើយត្រូវបញ្ជូនទៅថ្នាក់លើដើម្បីដោះស្រាយ[៦០] ។

---

[៥៨] COMFREL provincial representative (17), Kompong Cham province, personal interview, 9 July 2003.

[៥៩] PEC Chief, Kompong Cham Province (5), personal interview, Kompong Cham, 9 July 2003.

[៦០] CEC member, Veal Vong (18), personal interview, Kompong Cham, 9 July 2003.

ការតវ៉ាទី២ ដោះស្រាយដោយ គឃប នៅវាលវង់ គឺជារបស់ SRP ស្តីពីការប្តូរទីតាំងការិយាល័យបោះឆ្នោត ។ ជំទប់ទី១ (ជា SRP) នៃឃុំវាលវង់ បានឆ្លើយសំភាសន៍ថា ការផ្លាស់ប្តូរនេះធ្វើដោយគ្មានពិគ្រោះយោបល់ និងមិនបានផ្សព្វផ្សាយល្អទេ ។ គាត់និយាយថា "ពួកគេមិនបានពិគ្រោះយោបល់ជាមួយយើងទេ គឺគេពិគ្រោះតែជាមួយនឹងថ្នាក់លើគណបក្សនៅកំរិតឃុំ និងស្រុកប៉ុណ្ណោះ ។ ពួកគេមិនបានផ្តល់ពត៌មានដល់ប្រជាជនឱ្យបានល្អពីរឿងនេះទេ ។ អ្នកបោះឆ្នោតជាច្រើននឹងមានការភ័ន្ត ច្រឡំពីរឿងការិយាល័យបោះឆ្នោត ហើយខ្ញុំបារម្ភទៀតថាប្រជាជនអាចនឹងមិនទៅបោះឆ្នោត បើសិនគេធ្វើឱ្យរឿងរ៉ាវស្មុគ ស្មាញយ៉ាងដូច្នេះ"[៦១] ។

តំណាង SRP និយាយថា គាត់បានដាក់បណ្តឹងតវ៉ាមួយទៅ គឃប, គខប និង គជប ប៉ុន្តែ "មិនទាន់មានដំណោះស្រាយតាមច្បាប់នៅឡើយទេ"[៦២] ។ ប៉ុន្តែ បុគ្គលិក គឃប ដែលឆ្លើយសំភាសន៍ក្នុងថ្ងៃជាមួយគ្នាបានលើកឡើងថា:

> *"មានបញ្ហាធំៗរវាងចំរាស់នៃកាត់បន្ថយការិយាល័យបោះឆ្នោត... SRP មិនសប្បាយចិត្តទេ ពីព្រោះ គឃប មិនបានផ្តល់ពត៌មានឱ្យប្រជាជនបានទូលំទូលាយ ។ ប៉ុន្តែ គឃប បានជូនពត៌មានឱ្យ NGOs និងបានបិទប៉ូស្ទ័រ ហើយឥឡូវនេះ SRP បានឯកភាពលើការផ្លាស់ប្តូរហើយ"[៦៣] ។*

ចំណាប់អារម្មណ៍ខុសគ្នានេះបង្ហាញថា ដំណើរការសំរបសំរួលសំដៅដោះស្រាយបញ្ហាមិនសូវសក្តិសិទ្ធិល្អទេ និងបានបំផុសសំណួរថា តើដំណើរការបែបនេះវាជួយជំរុញការផ្សះផ្សាទំនាស់ ជាជាងការដោះស្រាយទំនាស់ឬយ៉ាងណា ។

*៣.២.១.៣ ការចុះបញ្ជីអ្នកបោះឆ្នោត*

នៅឃុំវាលវង់ អ្នកឆ្លើយសំភាសន៍ទាំងអស់ឯកភាពថា ចំនួនភាគរយអ្នកបោះឆ្នោតដែលចុះបញ្ជីមានកំរិតខ្ពស់ ហើយដំណើរការអនុវត្តមានប្រសិទ្ធភាពល្អ ។ មេឃុំបានលើកឡើងថា ដោយសារឃុំមានផ្ទៃដីតូច ដូច្នេះប្រជាជនពុំមានបញ្ហាអ្វីទេក្នុងការមកការិយាល័យឃុំដើម្បីចុះបញ្ជីនៅពេលសមស្រប ។

*៣.២.១.៤ ការឃោសនាបោះឆ្នោត*

ការឃោសនាបោះឆ្នោតត្រូវបានរៀបចំដោយ គឃប ហើយគណបក្សតូចៗជាច្រើន ព្រមទាំងគណបក្សធំៗទាំងបីបានធ្វើការឃោសនាយ៉ាងសកម្មនៅក្នុងឃុំ ។ មេឃុំបានអធិប្បាយពីសភាពការណ៍ថា:

> *"ធៀបនឹងឆ្នាំ១៩៩៨ គឺពុំមានបញ្ហាចោទទេ អ្វីៗធ្វើបានល្អ ។ ដូចឆ្នាំ២០០២ ដែរ គ្មានបញ្ហាអ្វីទេ ។ យើងបានជួបប្រជុំយ៉ាងញឹកញាប់ជាមួយ គឃប ។ ពួកគេរៀបចំការឃោសនាដើម្បីកុំឱ្យគណបក្សនានាឆ្លងកាត់គ្នា"[៦៤] ។*

គណបក្សធំៗពុំមានរាយការណ៍ពីការលំបាកក្នុងការឃោសនាបោះឆ្នោតទេ ។ អ្នកបោះឆ្នោតនៅឃុំវាលវង់ មានភ័ព្វល្អព្រោះមានការចុះមកជួបរបស់បេក្ខជនតំណាងរាស្ត្រជាច្រើន ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រីសំខាន់ៗ គឺ ឯ.ឧ សម រង្ស៊ី និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ[៦៥] ។ ការចុះជួបរបស់អ្នកនយោបាយថ្នាក់ខ្ពស់ ឬអ្នកដឹកនាំគណបក្ស កំរមានណាស់នៅតាមឃុំឆ្ងាយៗដែលយើងបានចុះសិក្សា ។ គណបក្សជំទាស់បារម្ភពីការបំភិតបំភ័យអ្នកបោះឆ្នោត ជាងការរំខានដល់សកម្មភាពឃោសនារបស់គណបក្ស ។

---

[៦១] SRP First Deputy Commune Chief, Veal Vong (14), personal interview, Kompong Cham, 9 July 2003.

[៦២] SRP First Deputy Commune Chief, Veal Vong (14), personal interview, Kompong Cham, 9 July 2003.

[៦៣] CEC member, Veal Vong (18), personal interview, Kompong Cham, 9 July 2003.

[៦៤] Commune chief, Veal Vong (13), personal interview, Kompong Cham, 30 July 2003.

[៦៥] នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនចូលរួមក្នុងការឃោសនាបោះឆ្នោតទេ ។

ជាទូទៅ នៅក្នុងខេត្តមានការប្រកួតប្រជែងឃោសនាយ៉ាងខ្លាំង និងមានរបាយការណ៍មួយចំនួនពីគណបក្សមួយ ទៅទំលាក់ផ្លាករបស់គណបក្សមួយទៀត និងពីរឿងអាជ្ញាធរមូលដ្ឋាន និងនិយោជក បានហាមប្រាមអ្នកភូមិ និងបុគ្គលិកកម្មករ មិនឱ្យទៅចូលរួមការប្រជុំរបស់គណបក្សជំទាស់ ។ ប៉ុន្តែតំណាងគណបក្សជំទាស់ និងអ្នកសង្កេតការណ៍បោះឆ្នោតនានា បានឯកភាពថាបញ្ហាធ្ងន់ៗបំផុតកើតមានឡើងនៅតំបន់ជនបទ ។

### *៣.២.១.៥ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងពីរឿងបោះឆ្នោត*

ដោយវាលវង់ស្ថិតក្នុងតំបន់ទីក្រុង និងមានប្រជាជនឃុំជាច្រើនទៅធ្វើការនៅទីផ្សារក្នុងក្រុងកំពង់ចាមដែលនៅជិតនោះ ដូច្នេះឃុំនេះមានការងាយស្រួលច្រើនណាស់ក្នុងការបានពាក់ព័ន្ធជាមួយប្រព័ន្ធផ្សព្វផ្សាយ និងទទួលពត៌មានពីការបោះឆ្នោត ។ តាមសំដីមេឃុំ គណបក្សធំៗទាំងបី បានធ្វើសកម្មភាពផ្តល់ពត៌មានដល់សមាជិកខ្លួនពីការបោះឆ្នោត និងលើកទឹកចិត្តពួកសមាជិកឱ្យទៅចុះឈ្មោះ និងទៅបោះឆ្នោត ។ ប៉ុន្តែគាត់បន្ថែមថា អ្នកបោះឆ្នោតមានការពិភាក្សាគ្នាតិចតួចណាស់ពីកម្មវិធីនយោបាយរបស់គណបក្សផ្សេងៗ:

> *"ប្រជាជនមានការផ្សារភ្ជាប់ភាគច្រើនទៅនឹងគណបក្សធំៗទាំងបី ។ ពួកគេមិនបានពិភាក្សាអ្វីច្រើនពីគណបក្សនានាទេ -ពួកគេហ៊ាននិយាយ ប៉ុន្តែអ្នកខ្លះមិនចង់និយាយ ។ ពួកគេខ្លាច ឬក៏ខ្ជិល ។ ពួកគេមិនចង់ឈ្លោះប្រកែកទេ ។ ពួកគេមិនខ្លាច តែខ្ជិល ។ ពួកគេបានពត៌មានពីការអានសារពត៌មាន... និងមើលទូរទស្សន៍" ។*

មេឃុំមានមតិបន្ថែមថា "សារពត៌មានមិនសូវល្អទេ -សារពត៌មានធ្វើការបំបែកបំបាក់ខ្លាំងណាស់ និងបំរើឱ្យក្រុមណាមួយ ប៉ុន្តែទូរទស្សន៍គឺគ្មានបញ្ហាទេ"[៦៦] ។

### *៣.២.១.៦ ថ្ងៃបោះឆ្នោត*

ថ្ងៃបោះឆ្នោតមានដំណើរការរលូនល្អនៅឃុំវាលវង់ ។ តាមសំដីមេឃុំ ៨៤% នៃអ្នកបោះឆ្នោតបានចុះបញ្ជី គេបានមកបោះឆ្នោត គឺតិចជាងឆ្នាំ១៩៩៨ ប៉ុន្តែច្រើនជាងឆ្នាំ២០០២ ។ បញ្ហាចំបងនៅថ្ងៃបោះឆ្នោត គឺប្រជាជនមួយចំនួនដែលបានបោះឆ្នោតនៅឆ្នាំ១៩៩៨ ប៉ុន្តែមិនបានបោះនៅឆ្នាំ២០០២ បានមកការិយាល័យបោះឆ្នោតដោយមិនបានចុះបញ្ជីឡើងវិញ ។ ប៉ុន្តែវិធានស្តីពីការចុះបញ្ជីអចិន្ត្រៃយ៍កំណត់ឱ្យប្រើបញ្ជីបោះឆ្នោតឆ្នាំ២០០២ ជាគោល គឺបានន័យថា អ្នកដែលបានបោះឆ្នោតនៅឆ្នាំ១៩៩៨ ប៉ុន្តែមិនបានបោះនៅឆ្នាំ២០០២ ត្រូវចុះបញ្ជីឡើងវិញ ដើម្បីអាចបោះឆ្នោតបាននៅឆ្នាំ២០០៣ ។ ការច្របូកច្របល់បង្កឡើងដោយបទប្បញ្ញត្តិនេះ ឃើញមានរាយការណ៍នៅទាសពេញប្រទេស ។ បញ្ហាមួយទៀតដែលមានរាយការណ៍ច្រើននៅកំពង់ចាម គឺវត្តមានមេឃុំ និងប្រធានភូមិនៅជុំវិញការិយាល័យបោះឆ្នោត ប៉ុន្តែរឿងនេះកើតមាននៅតំបន់ជនបទ ច្រើនជាងនៅតំបន់ទីក្រុង ។ មេឃុំវាលវង់និយាយថា "ពួកគេឱ្យខ្ញុំបោះឆ្នោតមុនគេ រួចឱ្យចាកចេញ"[៦៧] ។ គាត់បដិសេធពីរឿងប្រធានភូមិបានដឹកនាំប្រជាជនឱ្យមក និងបោះឆ្នោត (COMFREL និងអ្នកឆ្លើយសំភាសន៍ជាសមាជិក គយប នៅស្រុកក្រូចឆ្មារម្នាក់បានរាយការណ៍ពីការអនុវត្តន៍បែបនេះ) ប៉ុន្តែនិយាយថា SRP បានដឹកនាំអ្នកគាំទ្ររបស់ខ្លួនមកការិយាល័យបោះឆ្នោតក្នុងឃុំ ។

## *៣.២.២ ឃុំពាមឯក ក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង*

### *៣.២.២.១ អាជ្ញាធរឃុំ និងនយោបាយ*

ឃុំពាមឯក ស្ថិតក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ប្រហែល ១៥គ.ម ពីទីរួមខេត្ត ។ ឃុំនេះមាន ៨ភូមិ និងប្រជាជន ២.៥០០គ្រួសារ ត្រូវជា ១៥.០០០នាក់ ដែលភាគច្រើនជាកុមារក្រោមអាយុ ១៥ឆ្នាំ ។ ឃុំនេះសំបូរចំការ ដំណាំហូបផ្លែ

---

[៦៦] Commune chief, Veal Vong (13), personal interview, Kompong Cham, 9 July 2003.

[៦៧] Commune chief, Veal Vong (13), personal interview, Kompong Cham, 30 July 2003.

មានដង់ស៊ីតេប្រជាជនខ្ពស់ និងងាយស្រួលទៅមកទីផ្សារ ។ យុទ្ធសាស្ត្រកចិញ្ចឹមជីវិតប្រចាំថ្ងៃមានជាអាទិ៍ ការដាំស្រូវ, ការធ្វើចំណាកស្រុកទៅធ្វើការនៅថៃ, មុខរបរតូចតាចក្នុងតំបន់ ដូចជា កិនស្រូវ នេសាទ ជួញផ្លែឈើ ។ល។ តាមមើលឃើញ អ្នកភូមិមានស្ថានភាពសេដ្ឋកិច្ចក្រីក្រ ពីព្រោះដីសំរាប់ដាំដុះមានតិច ហើយសេវាសន្តិសុខសង្គមរបស់រដ្ឋក៏មានតិច ជាពិសេសប្រព័ន្ធថែទាំសុខភាព ។ ប្រជាជនជាច្រើនគ្មានដីធ្លីទេ ។

សំរាប់ការបោះឆ្នោតក៏រិតជាតិលើកនេះ មាន ៦គណបក្សបានចុះបញ្ជីក្នុងឃុំ ក្នុងនេះ ៣គណបក្សធ្វើសកម្មភាពខ្លាំង ។ ប្រធាន គឃប ក្នុងឃុំបានពន្យល់ថា "ការបោះឆ្នោតលើកនេះ យើងមានទាំងអស់ ៦គណបក្ស បានចុះបញ្ជីធ្វើការឃោសនា ។ ប៉ុន្តែគណបក្សតូចៗខ្លះ បានមកឃោសនាតែម្តងទេ រួចហើយក៏បាត់ទៅ"[៦៨] ។

តាំងពីការបោះឆ្នោតឃុំឆ្នាំ២០០២ រចនាសម្ព័ន្ធនយោបាយក្នុងឃុំមានលក្ខណៈចំរុះ ៣គណបក្ស ។ សមាជិកក្រុមប្រឹក្សាឃុំមានទាំងអស់ ១១នាក់ ក្នុងនេះ ៧នាក់ជា CPP, ៣នាក់ជា FUNCINPEC, និង ១នាក់ជា SRP ។ មេឃុំចេញមកពី CPP, ជំទប់ទី១ មកពី FUNCINPEC, និងជំទប់ទី២ មកពី SRP ។ ប្រវត្តិបោះឆ្នោតក្នុងឃុំនេះគឺ SRP បានឈ្នះក្នុងការបោះឆ្នោតក៏រិតជាតិឆ្នាំ១៩៩៨ ហើយ CPP បានឈ្នះក្នុងការបោះឆ្នោតឃុំឆ្នាំ២០០២ ។ ក្រុមស្រាវជ្រាវបានចុះទៅដល់ឃុំជាលើកទី២ ក្រោយពេលរាប់សន្លឹកឆ្នោតរួច ។ គឃប ប្រាប់ថា មាន ៥.៧៤៥នាក់បានចុះបញ្ជីដើម្បីបោះឆ្នោត ។ ការរាប់សន្លឹកឆ្នោតបង្ហាញថា SRP ឈ្នះគេដោយទទួលឆ្នោតបាន ២.០៥៩, បន្ទាប់មកគឺ CPP ដែលបានឆ្នោត ១.៧៥៥ និង FUNCINPEC ដែលបាន ៥៥៦ ។

**ប្រវត្តិនៃការបោះឆ្នោត: ឃុំពាមឯក**

| | |
|---|---|
| 1998 | 1st SRP, 2nd FUNCINPEC, 3rd CPP |
| 2002 | 1st CPP, 2nd FUNCINPEC, 3rd SRP |
| 2003 | 1st SRP, 2nd CPP, 3rd FUNCINPEC |

សមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិនានា តួនាទីសំខាន់ក្នុងការបោះឆ្នោតក៏រិតជាតិ ។ ក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតមានសមាសភាពមកពី ៣គណបក្សគឺ CPP, FUNCINPEC និង SRP ។ ដូច្នេះ ថ្វីបើគណបក្សមិនមែន CPP បានទទួលជោគជ័យក្នុងការបោះឆ្នោតក៏រិតជាតិក្តី ប៉ុន្តែ CPP នៅត្រួតត្រាលើអាជ្ញាធរក៏រិតមូលដ្ឋានទាំងភាពលុបលើគេនៅក្នុងក្រុមប្រឹក្សាឃុំ និងការរក្សាបាននូវភក្តីភាពរបស់ពួកប្រធានភូមិដែលត្រូវបានជ្រើសតាំងនៅក្នុងទសវត្សរ៍១៩៨០ ។ ម្យ៉ាងទៀតដោយសារមានប្រភពគាំទ្រពីគណបក្សមជ្ឈិម CPP អាចដោះស្រាយតំរូវការជំនួយនៅមូលដ្ឋាន បានប្រសើរជាងគណបក្សឯទៀត ជាពិសេសនៅមុនពេលបោះឆ្នោត និងក្នុងពេលឃោសនាបោះឆ្នោត ។ រឿងនេះតួអង្គខាងនយោបាយឯទៀតៗមើលឃើញថា មានការប្រទាំងប្រទើស ។ អន្តរកម្ម (ការប្រស្រ័យទាក់ទងតាមខ្សែបញ្ឈរ និងខ្សែផ្តេក) រវាងសមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិនានាខាង CPP ជាមួយនឹងមនុស្ស និងខ្សែរយៈរបស់គណបក្ស គឺសកម្មខ្លាំងណាស់ បើធៀបនឹងគណបក្សឯទៀតៗ ។ រឿងនេះធ្វើឱ្យ CPP អាចឆ្លើយតបបានចំល្អណាស់ទៅក្រុមគោលដៅណាមួយនៅមូលដ្ឋាន ។

មានការចោទប្រកាន់ជាច្រើនចំពោះសមាជិកក្រុមប្រឹក្សាឃុំ ជាពិសេសអ្នកមកពី CPP ថាបានចូលរួមក្នុងការឃោសនាឱ្យគណបក្ស ។ ការចោទប្រកាន់ទាំងនេះឆ្លុះបញ្ចាំងពីការច្របូកច្របល់អំពីសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ និង គជប ដែលថាអាជ្ញាធរមូលដ្ឋានត្រូវស្ថិតនៅជាអព្យាក្រឹត្យ ប៉ុន្តែ (ដូចដែលមេឃុំ និងប្រធាន គឃប ឃុំពាមឯក បានពន្យល់ឡើង) ការដាក់

[៦៨] CEC chief, Peam Ek commune (19), personal interview, Battambang, 23 July 2003.

កំរិតនេះសំដៅតែលើ "ម៉ោងធ្វើការ"[៦៩] ។ បទបញ្ជាពី គជប និងក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋានធ្វើការឃោសនាបោះឆ្នោត បើសិនជាគេបានដាក់លិខិតសុំលាឈប់ជាមុន ។ សមាជិកខាង SRP ម្នាក់នៃក្រុមប្រឹក្សាឃុំពាមឯក បានអះអាងថា នៅក្នុងឃុំមាន "ប្រធានភូមិជាច្រើននាក់បានដាក់លិខិតសុំលាឈប់ ដើម្បីបានការអនុញ្ញាតទៅធ្វើការឃោសនាឱ្យ CPP ។ ប៉ុន្តែពួកគេអាចបាន ឬក៏មិនបានជូនដំណឹងដល់អ្នកភូមិ ហើយអ្នកភូមិមិនបានដឹងទាំងអស់គ្នាទេ ។ ពួកគេមានគំនិតថាប្រធានភូមិនៅតែមានអំណាចក្នុងការត្រួតត្រាលើមជ្ឍដ្ឋានអ្នកបោះឆ្នោត"[៧០] ។

ប្រធានភូមិ ៣នាក់ ត្រូវបានអញ្ជើញមកធ្វើសំភាសន៍ ។ ទាំងអស់គ្នាមានសុទិដ្ឋិនិយមខ្ពស់ និងហាក់ដូចបានដឹងច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការបោះឆ្នោត ។ ពួកគេសារភាពថា ការបោះឆ្នោតកាលពីឆ្នាំ១៩៩៣ និង១៩៩៨ មានបញ្ហាយ៉ាងច្រើន ប៉ុន្តែបច្ចុប្បន្នមានការរីកចំរើនច្រើនហើយ ។ ប្រជាជនមានបទពិសោធន៍បោះឆ្នោតច្រើនដង លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមានការកែលំអ ហើយតួនាទីរបស់ គឃប និងអាជ្ញាធរមូលដ្ឋាន ក៏មានការបំភ្លឺឡើង ។ ប៉ុន្តែពួកគេអះអាងថា ប្រជាជនជាច្រើនមានជីវភាពក្រីក្រ ដូច្នេះបានខិតខំរកចិញ្ចឹមជីវិតជាសំខាន់ និងមិនបានគាំទ្រគណបក្សណាមួយខ្លាំងក្លាទេ ។ ប្រធានភូមិទាំងអស់យល់ដឹងពីតួនាទីរបស់ខ្លួន, ឧទាហរណ៍ ប្រធានភូមិម្នាក់និយាយថា "ខ្ញុំដឹងថាក្នុងឋានៈជាប្រធានភូមិ ខ្ញុំពុំមានការអនុញ្ញាតឱ្យធ្វើការឃោសនាទេ ។ ខ្ញុំមិនអាចធ្វើការឃោសនាទេ លើកលែងតែខ្ញុំបានដាក់លិខិតសុំលាឈប់ជាមុន"[៧១] ។

ពួកគេក៏បានយល់ពីតួនាទីរបស់ខ្លួនជាអ្នកចាំយាមសកម្មភាពអភិវឌ្ឍន៍គ្រប់ប្រភេទនៅក្នុងភូមិដែរ ។ ប្រធានភូមិដដែលបន្តថា "យើងទទួលយកប្រាក់ទាំងអស់ដែលសំរាប់អភិវឌ្ឍន៍ភូមិយើង ដូចជាប្រាក់ដែលយើងអាចទទួលបានពីរដ្ឋាភិបាល, NGOs, និងគណបក្សនយោបាយនានា ។ ឧទាហរណ៍ ទេសរដ្ឋមន្ត្រី CPP ម្នាក់បានជួយកសាងច្រើនណាស់ក្នុងឃុំយើង ដូចជា សាលារៀន និងផ្លូវថ្នល់"[៧២] ។ ពួកគេរាយការណ៍ថា ក្នុងចន្លោះពេលនោះ នៅតែមានបញ្ហាខ្លះៗដូចជាទំនាស់ពាក្យសំដីជាដើម ។ ក្នុងពេលឃោសនាគេប្រើភាសាអាក្រក់ស្តាប់ និងមានបញ្ហាបច្ចេកទេសមួយចំនួន ដូចជា ក្នុងពេលចុះបញ្ជីអ្នកបោះឆ្នោត អ្នកខ្លះត្រូវគេថតរូបឱ្យមិនបានល្អទេ ។

### *៣.២.២.២ ស្ថាប័នបោះឆ្នោត*

សមាជិក គឃប អះអាងថា ពួកគេធ្វើការមានប្រសិទ្ធភាពខ្ពស់ជាងកាលពីការបោះឆ្នោតលើកមុនៗ ដោយហេតុថាពួកគេភាគច្រើនមានការអប់រំជាគ្រូបង្រៀន និងមានបទពិសោធន៍ក្នុងការងារបែបនេះ ។ បញ្ហាដ៏សំខាន់មួយគឺ ការចុះបញ្ជីអ្នកបោះឆ្នោត ។ សំរាប់ការបោះឆ្នោតកំរិតជាតិលើកនេះ គឃប គ្មានការទទួលខុសត្រូវចុះបញ្ជីអ្នកបោះឆ្នោតទេ ប៉ុន្តែគឺក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ដែលជាអ្នកធ្វើការងារទាំងអស់នេះ ។ ដូច្នេះ សមាជិក គឃប មិនគ្រប់គ្រងទាំងស្រុងទៅលើរឿងក្រដាសស្នាម ហើយបើសិនមានបញ្ហាអ្វីនៅថ្ងៃបោះឆ្នោត ដូចជា ឈ្មោះសរសេរខុស, អត្តសញ្ញាណប័ណ្ណ ឬរូបថតត្រូវបាត់ជាដើម, ពួកគេមិនអាចដោះស្រាយបានសក្តិសិទ្ធិល្អទេ ។

សព្វថ្ងៃ សកម្មជន SRP និងFUNCINPEC នៅតែមានទំនុកចិត្តខ្សោយលើសមាជិក គឃប ។ សកម្មជន SRP ម្នាក់នៅក្នុងឃុំនិយាយថា:

---

[៦៩] Commune chief (20) and CEC chief (19) Peam Ek commune, personal interviews, Battambang, 22 July 2003.

[៧០] SRP councillor Peam Ek commune (21), personal interview, Battambang, 23 July 2003.

[៧១] Village chief, Peam Ek Commune (22), personal interview, Battambang, 22 July 2003.

[៧២] Village chief, Peam Ek Commune (23), personal interview, Battambang, 22 July 2003.

*"បុគ្គលិក គឃប ទាំងអស់សុទ្ធតែជាបុគ្គលិករដ្ឋភាគច្រើនគ្រូបង្រៀន ។ ពួកគេគឺជាអតិថិជនរបស់រដ្ឋាភិបាល ដូច្នេះខ្ញុំមិនទុកចិត្តពួកគេទេ ពីព្រោះក្រោយពេលបោះឆ្នោត ពួកគេនឹងត្រឡប់ទៅបំរើការងារធម្មតាប្រចាំថ្ងៃនោះវិញ និងស្ថិតក្រោមការត្រួតត្រាដោយផ្ទាល់ពី CPP ។ តើអ្នកគិតថាតើពួកគេមានការទទួលខុសត្រូវចំពោះគណបក្សផ្សេងទៀត ក្រៅពី CPP ឬយ៉ាងណា ។ ចំលើយគឺច្បាស់ជាមិនមែនទេ"*[៧៣] ។

ពុំមានការតវ៉ាជាផ្លូវការអ្វីប្រឆាំងនឹង គឃប នៅឃុំពាមឯកទេ ។ តាមសំដីប្រធាន គឃប បុគ្គលិកទាំងអស់ និងអាជ្ញាធរមូលដ្ឋាន បានខំធ្វើការខ្លាំងណាស់ដើម្បីរក្សាបរិស្ថានមានសន្តិភាពនៅក្នុងឃុំ ។ គាត់និយាយថា:

*"យើងរៀនសូត្របានពីបញ្ហាទាំងអស់ អំពីការបោះឆ្នោតជាច្រើន ដូច្នេះលើកនេះយើងត្រូវធ្វើការខ្លាំងដើម្បីទប់ស្កាត់បញ្ហាទាំងនោះកុំឱ្យកើតឡើងទៀត ។ មានវិធីជាច្រើនដែលយើងអាចធ្វើការរួមគ្នាដើម្បីចៀសវាងបញ្ហានៅលើកនេះ គឺមានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងប៉ូលីស, ធ្វើការប្រជុំប្រចាំសប្តាហ៍ជាមួយគណបក្សជាប់ទាក់ទិនទាំងអស់, រឿងច្របូកច្របល់គ្រប់ប្រភេទត្រូវដោះស្រាយយ៉ាងលឿនដោយ គឃប ។ សមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត ធ្វើសហប្រតិបត្តិការបានល្អជាមួយ គឃប ។ បទប្បញ្ញត្តិទាំងអស់ពី គជប និងក្រសួងមហាផ្ទៃ ត្រូវបានផ្សព្វផ្សាយទាន់ពេលទៅដល់ប្រជាជន ។ យើងអាចអញ្ជើញមនុស្សមកអង្គុយទល់មុខគ្នាដើម្បីពិភាក្សាបញ្ហាដោយផ្ទាល់ ។ មនុស្សទាំងអស់មានលទ្ធភាពបានប្រើប្រព័ន្ធផ្សព្វផ្សាយ និងយល់ពីសភាពការណ៍បានល្អ"*[៧៤] ។

### *៣.២.២.៣ ការចុះបញ្ជីអ្នកបោះឆ្នោត*

តាមការធ្វើសំភាសន៍ជាមួយស្មៀនឃុំ, ជំទប់ទី១ និង ទី២ ដែលទទួលខុសត្រូវធ្វើការចុះបញ្ជីអ្នកបោះឆ្នោត, រឿងនេះជាបន្ទុកខាងរដ្ឋបាលមួយដែលប្រគល់ទៅឱ្យអាជ្ញាធរឃុំរ៉ាប់រងជាបន្ថែមលើការចុះបញ្ជីអត្រានុកូលដ្ឋាន ។

*"យើងជួបបញ្ហាជាច្រើនក្នុងពេលចុះបញ្ជី ពីព្រោះវាជាបទពិសោធន៍ធ្វើការងារនេះជាលើកទី១របស់យើង ។ យើងខ្វះខាតសំភារ: ដូចជា សំភារ:ការិយាល័យ និងមធ្យោបាយដឹកជញ្ជូន ។ ការចុះបញ្ជីបានគ្រោងថាជាការទទួលខុសត្រូវរបស់ស្មៀនឃុំ ប៉ុន្តែយើងបានអញ្ជើញមេឃុំ និងជំទប់ទាំង២ មកជួយផងដែរ"*[៧៥] ។

អ្នកទើបដល់អាយុ ១៨ឆ្នាំបានមកចុះបញ្ជី ៨០០នាក់, រីឯអ្នកបានចុះបញ្ជីទាំងអស់មាន ៥.៧៤៨នាក់ ។ អាជ្ញាធរមូលដ្ឋានបានធ្វើការយ៉ាងខ្លាំងដើម្បីលើកទឹកចិត្តប្រជាជនឱ្យមកចុះបញ្ជីដោយធ្វើការប្រកាសនៅសាលាឃុំ និងដោយប្រាប់ផ្ទាល់មាត់តាមរយ:ប្រធានភូមិ ។ គណបក្សនយោបាយនីមួយៗដែលធ្វើការក្នុងឃុំ បានកេណ្ឌប្រមូលអ្នកគាំទ្ររបស់ខ្លួនឱ្យមកយ៉ាងសកម្ម ។ ប៉ុន្តែមានមនុស្សជាច្រើនមិនបានចុះបញ្ជីទេ ពីព្រោះគេគិតថា គេមានប័ណ្ណបោះឆ្នោតឆ្នាំ១៩៩៨ ហើយដូច្នេះមិនបាច់ចុះបញ្ជីឡើងវិញទេ ។ នេះជាបញ្ហាបច្ចេកទេសមួយដ៏ធ្ងន់ធ្ងរបំផុត ។ សមាជិក គឃប ក្នុងឃុំរាយការណ៍ថា:

*"ការបោះឆ្នោតលើកនេះច្របូកច្របល់ណាស់ ពីព្រោះ គឃប មិនទទួលខុសត្រូវធ្វើការចុះបញ្ជីដូចកាលពីការបោះឆ្នោតលើកមុនៗទេ ។ នៅពេលយើងទទួលបញ្ជីអ្នកបោះឆ្នោត យើងគ្រាន់តែធ្វើតាមបញ្ជីនោះ ។ នៅថ្ងៃបោះឆ្នោត សកម្មជនរបស់គណបក្សនយោបាយមួយចំនួនបានបន្ទោស គឃប ថាអញ្ចេះមួយ-អញ្ចុះមួយ ។ ខ្ញុំប្រាប់ពួកគេថា សូមកុំបន្ទោស គឃប, ត្រូវបន្ទោសអាជ្ញាធរមូលដ្ឋានវិញ ។ តាមមើលសមាជិកក្រុមប្រឹក្សាឃុំមកពី*

---

[៧៣] SRP chief, Peam Ek (24), personal interview, Battambang, 22 July 2003.

[៧៤] CEC chief, Peam Ek (19), personal interview, Battambang, 23 July 2003.

[៧៥] Commune chief and commune clerk, Peam Ek (20, 25), group interview, Battambang, 23 July 2003.

*ទាំង ៣គណបក្ស ហាក់ដូចជាបានចូលរួមក្នុងការងារចុះបញ្ជីទាំងអស់គ្នា*[៧៦] ។

រឿងបច្ចេកទេសមួយទៀតទាក់ទិននឹងបញ្ហាថា មានមនុស្សជាច្រើនដែលបានចុះបញ្ជីហើយ គេមិនមកបោះឆ្នោត ។ នៅឃុំពាមឯក ក្នុងចំណោមអ្នកចុះបញ្ជី ៥.៧៤៨នាក់ មានតែ ៤.៨៤៧នាក់ប៉ុណ្ណោះដែលមកបោះឆ្នោត ដូច្នេះត្រូវបាត់អស់ ១.០០១នាក់ ។ តាមមតិ គឃប និងអាជ្ញាធរមូលដ្ឋាន មនុស្សជាច្រើនមិនបានមកការិយាល័យបោះឆ្នោត ពីព្រោះនៅបាត់ដំបងមានប្រជាជនច្រើននាក់ជាពលករចំណាកស្រុកទៅធ្វើការនៅថៃ ។ អ្នកខ្លះមានជំងឺ ខ្លះទៀតបានចាកចេញពីឃុំ ខ្លះបានស្លាប់ ប៉ុន្តែឈ្មោះពួកគេនៅតែមានសុពលភាព ។

*៣.២.២.៤ ការឃោសនាបោះឆ្នោត*

គណបក្សនីមួយៗត្រូវដាក់តារាងពេលនៃការឃោសនារបស់ខ្លួន ជូនស្ថាប័នសន្តិសុខ (ការិយាល័យប៉ូលីសក្នុងឃុំ) ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយ គឃប ។ ទាំង គឃប និងប៉ូលីស ត្រូវរាយការណ៍ប្រាប់គ្នាទៅវិញទៅមករៀងរាល់ថ្ងៃពីព្រឹត្តិការណ៍ខាងសន្តិសុខនៃការឃោសនាបោះឆ្នោត ។ តាមខាងប៉ូលីស និងសកម្មជនគណបក្សនានា:

*"ការឃោសនាលើកនេះមានលក្ខណៈល្អជាងការបោះឆ្នោតឆ្នាំ១៩៩៨ ពីព្រោះ ឥឡូវនេះយើងនៅសល់តែ ៣ថ្ងៃ ប៉ុណ្ណោះដល់ថ្ងៃបោះឆ្នោតហើយ ហើយពុំមានករណីអ្វីធ្ងន់ធ្ងរកើតឡើងទេ"*[៧៧] ។

តាមបទសំភាសន៍ និងការសង្កេតរបស់យើងនៅពេលគេឃោសនា គណបក្សនីមួយៗមានយុទ្ធសាស្ត្រប្រហែលគ្នាក្នុងការធ្វើឃោសនា ។ CPP ប្រើប្រាស់ការដង្ហែក្បួនជាក្រុមធំៗដើម្បីពន្យល់ពីកម្មវិធីនយោបាយរបស់គណបក្សផ្លាក/សន្លឹកប័ណ្ណរបស់គណបក្ស, និងធ្វើការជួបជុំគ្នាក្នុងឃុំដើម្បីពន្យល់ពីកម្មវិធីនយោបាយ និងថ្នាក់ដឹកនាំរបស់ខ្លួន ។ CPP ផ្តោតផងដែរលើការអភិវឌ្ឍន៍ជនបទ និងកំរិតជាតិរបស់ខ្លួន, ជោគជ័យក្នុងការបញ្ចប់ការប្រយុទ្ធគ្នាជាមួយខ្មែរក្រហម, និងការសំរបសំរួលឱ្យប្រទេស "រស់ឡើងវិញ" នៅថ្ងៃ ៧ មករា ១៩៧៩ ។ យុទ្ធសាស្ត្រជាទូទៅខាង FUNCINPEC គឺការប្រើប្រដាប់បំពងសំលេង ការដង្ហែក្បួន ផ្លាក/សន្លឹកប័ណ្ណរបស់គណបក្ស ។ ខ្លឹមសារនៃការឃោសនា គឺការគាំទ្ររបបរាជានិយម និងបញ្ហាផ្សេងៗទាក់ទិននឹងរឿងព្រំដែន ជនចំណាកស្រុកវៀតណាម ការប្រឆាំងកុម្មុយនីស្ត និងប្រយុទ្ធអំពើពុករលួយក្នុងរដ្ឋាភិបាល ។ SRP ធ្វើការឃោសនាភាគច្រើនដោយប្រើផ្លាក/សន្លឹកប័ណ្ណរបស់គណបក្ស ប្រដាប់បំពងសំលេង និងការជួបជុំគ្នាជាមួយសកម្មជនក្នុងភូមិ ។ ការឃោសនាមានខ្លឹមសារប្រហែលគ្នានឹង FUNCINPECដែរ ដោយមានសន្យាបន្ថែមថា បង្កើនប្រៀវត្សរ៍ពលករដល់ ១០០ដុល្លារ ប្រយុទ្ធអំពើពុករលួយ, ដោះស្រាយបញ្ហាព្រំដែន ជនចំណាកស្រុកខុសច្បាប់ សន្តិសុខសង្គម និងការអភិវឌ្ឍន៍ជនបទ ។

សភាពការណ៍ជាទូទៅនៃការឃោសនាក្នុងឃុំ មានលក្ខណៈគួរពេញចិត្តសំរាប់គ្រប់គណបក្ស ប៉ុន្តែខាង SRP បានតវ៉ាខ្លះពីការទិញសន្លឹកឆ្នោត និងទំនាស់ផលប្រយោជន៍របស់ប្រធានភូមិមួយចំនួននៅភូមិឆ្ងាយៗ (ករណីទាំងនេះមានលើកមកពិភាក្សានៅក្នុងជំពូកបន្ទាប់) ។ ប៉ុន្តែ SRP ហាក់ដូចបានពេញចិត្តនឹងបរិយាកាសទូទៅនៃការឃោសនា ពីព្រោះប្រជាជនមានលទ្ធភាពល្អក្នុងការទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ និងគណបក្សផ្សេងៗ, កំលាំងសន្តិសុខបានបំពេញតួនាទីរបស់ខ្លួន, ការបំភិតបំភ័យមានតិចជាងការបោះឆ្នោតលើកមុនៗ ដែលអនុញ្ញាតឱ្យសកម្មជនគណបក្សទាំងអស់អាចឃោសនាបានដោយសេរី ។ ប៉ុន្តែនៅមានការមិនពេញចិត្តខ្លះៗចំពោះអាជ្ញាធរមូលដ្ឋាន ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិ ។

---

[៧៦] CEC chief, Peam Ek (19), personal interview, Battambang, 23 July 2003.

[៧៧] Policeman and SRP member, Peam Ek (26), personal interview, Battambang, 23 July 2003.

### *៣.២.២.៥ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងពីរឿងបោះឆ្នោត*

ក្នុងចំណោមប្រជាជននៅជនបទនេះ ការយល់ដឹងពីរឿងបោះឆ្នោតមានកំរិតខ្ពស់គួរឱ្យភ្ញាក់ផ្អើល ។ ប្រជាជនភាគច្រើនមានលទ្ធភាពល្អក្នុងការប្រើប្រាស់វិទ្យុ ទូរទស្សន៍ ទូរស័ព្ទចល័ត និងសកម្មភាព NGOs ។ ប្រព័ន្ធដឹកជញ្ជូនមានការកែលំអធ្វើឱ្យប្រជាជនកាន់តែមានចលនាច្រើន ។ ប៉ុន្តែលទ្ធភាពមានតិចតួចក្នុងការបានអានសារពត៌មាន ។ តាមសមាជិកក្រុមប្រឹក្សាឃុំ និងបុគ្គលិក គឃប ជាច្រើននាក់ ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស នៅតែជាមធ្យោបាយតែមួយ ដើម្បីបញ្ជូនពត៌មានស្តីពីការបោះឆ្នោតទៅឱ្យប្រជាជន ។ ថ្វីបើមានការតាំងបង្ហាញផ្លាក និងសន្លឹកប័ណ្ណក្តី ប៉ុន្តែកំរិតអនក្ខរកម្មធ្វើឱ្យមធ្យោបាយទាំងនេះមិនសូវសំខាន់ទេ ។

មានទំលាប់សង្គម ឬប្រពៃណីមួយគឺ ប្រជាជនរស់នៅជនបទមិនចូលចិត្តនិយាយពីរឿងនយោបាយជាសាធារណៈទេ ។ នៅពេលសាកសួរថាតើដោយសារហេតុផលខាងសន្តិសុខឬយ៉ាងណា ចំលើយគឺ មិនមែនទេជានិច្ច ។ តាមការសង្កេតរបស់យើង ការយល់ដឹងពីការបោះឆ្នោតមានកំរិតខ្ពស់ ហើយប្រជាជនដឹងថា ការបោះឆ្នោតដោយសំងាត់ជាអ្វី ។ ពួកគេរៀនសូត្រពីការបោះឆ្នោតតាមរយៈទូរទស្សន៍ និងវិទ្យុ ។ សមាជិកក្រុមប្រឹក្សាឃុំជា CPP នៅឃុំវត្តតាមឹម និងពាមឯក បានអះអាងដែរថា ការយល់ដឹងពីរឿងបោះឆ្នោត ជាលទ្ធផលនៃសកម្មភាពអប់រំរបស់គណបក្សនយោបាយនានា ។

### *៣.២.២.៦ ថ្ងៃបោះឆ្នោត និងថ្ងៃរាប់សន្លឹកឆ្នោត*

នៅថ្ងៃបោះឆ្នោត គឃប បានប្រុងប្រយ័ត្នណាស់ក្នុងរឿងថ្នាក់ដឹកនាំអាជ្ញាធរមូលដ្ឋាន ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិ ព្រោះគេមើលឃើញថា អាចក្លាយជាប្រភពទំនាស់យ៉ាងងាយ។ មធ្យោបាយសក្តិសិទ្ធិមួយសំរាប់ចាត់ចែងរឿងនេះ គឺអញ្ជើញអាជ្ញាធរមូលដ្ឋានទាំងអស់ឱ្យមកបោះឆ្នោតពីព្រលឹម ហើយសុំឱ្យទៅផ្ទះវិញភ្លាមក្រោយពីបោះឆ្នោតហើយ ។ ការរក្សាហិបឆ្នោត និងរាប់សន្លឹកឆ្នោត គឺជាបញ្ហាចំរូងចំរាស់បំផុតនៅឆ្នាំ១៩៩៨ ។ លើកនេះអ្នកពាក់ព័ន្ធទាំងអស់ ដូចជា សកម្មជននយោបាយ និងសមាជិក គឃប ប្រុងប្រយ័ត្នខ្លាំងណាស់ក្នុងរឿងនេះ ។ ខាងSRP និងប្រធាន គឃប បានលើកឡើងថាៈ

> *"យើងនៅចាំច្បាស់ណាស់ពីបញ្ហានានាដែលកើតឡើងក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ដូច្នេះលើកនេះយើង ត្រូវមើលវាឱ្យជាប់ ។ នៅយប់រក្សាហិបឆ្នោត មានមនុស្សប្រហែល ២៥០នាក់ តាំងពីភ្នាក់ងារសន្តិសុខ, សកម្មជននយោបាយ, អ្នកសង្កេតការណ៍ និងអ្នកស្នាក់នៅវត្ត, បានជួយឃាមការពារហិបឆ្នោតទាំងនោះ ។ ចំពោះការរាប់សន្លឹកឆ្នោតវិញ សកម្មជននយោបាយ និងអ្នកសង្កេតការណ៍ មានការចង់ដឹងណាស់អំពីការរាប់ស្របច្បាប់ ហើយទំរង់១១០៥ ត្រូវបានចែកឱ្យអ្នកជាប់ពាក់ព័ន្ធទាំងអស់ ។ សរុបមក ឃុំយើងគ្មានបញ្ហាអ្វីធ្ងន់ធ្ងរទេ[៣៨] ។*

អ្នកសង្កេតការណ៍ក្នុងឃុំ មានមកពី COMFREL, NICFEC, ស្ថាប័នជាតិ និងអន្តរជាតិ, និងមានសកម្មភាពខ្លាំងក្នុងពេលបោះឆ្នោត ។ កត្តាមួយទៀតដែលជួយឱ្យការបោះឆ្នោតមានដំណើរការរលូនល្អគឺ សន្តិសុខដ៏ល្អនៅតាមកន្លែងភាគច្រើននៃតំបន់នោះ ដោយមានទាំងកន្លែងមួយចំនួនដែលជាអតីតតំបន់បង្អែករបស់ខ្មែរក្រហមផង ។

## *៣.២.៣ ឃុំវត្តតាមឹម ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង*

### *៣.២.៣.១ អាជ្ញាធរឃុំ និងនយោបាយ*

ឃុំវត្តតាមឹម ស្ថិតក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ចំងាយប្រហែល ១៨គ.ម ពីទីរួមខេត្តបាត់ដំបង ។ ឃុំនេះ មាន ៦ភូមិ និងប្រជាជន ២.៦០៤គ្រួសារ ត្រូវជា ១៤.៨២៣នាក់ ។ ផ្ទៃដីសរុបគឺ ៣២គ.ម$^2$ ដែលមានដីលំនៅដ្ឋាន ដីស្រែ ហើយនិងចំការក្រូច និងដំណាំហូបផ្លែផ្សេងទៀត ។ នៅគ្រប់កន្លែងក្នុងឃុំ មានដីល្បាប់នាំមកដោយទឹកជំនន់ស្ទឹងសង្កែ ។ មើលត្រួសៗ

---

[៣៨] SRP representative and CEC chief, Peam Ek (20, 24), group interview, Battambang, 5 Aug. 2003.

តាមទិដ្ឋភាពសេដ្ឋកិច្ច ប្រជាជនក្នុងឃុំនេះមានកំរិតជីវភាពខ្ពស់ជាងក្នុងឃុំឯទៀតៗនៅបាត់ដំបង[៧៩] ។ យុទ្ធសាស្ត្រកចិញ្ចឹមជីវិតគឺធ្វើស្រែ, ធ្វើចំការក្រូច និងដំណាំហូបផ្លែផ្សេងទៀត, អាជីវកម្មតូចតាច, ធ្វើចំណាកស្រុកទៅធ្វើការនៅថៃ ។ អ្នកខ្លះមានសាច់ញាតិនៅអាមេរិក ឬអឺរ៉ុបខាងលិច ដែលបានផ្ញើប្រាក់មកជួយទ្រទ្រង់ជីវភាពផងដែរ ។ មាន ៦គណបក្សបានចុះបញ្ជីធ្វើការឃោសនាក្នុងឃុំ ប៉ុន្តែគណបក្សធ្វើសកម្មភាពខ្លាំង មានតែ ៥ ទេគឺ CPP, SRP, FUNCINPEC, គណបក្សព្រលឹងជាតិរបស់ព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស, និងគណបក្ស ហង្ស ដារ៉ា ចលនាប្រជាធិបតេយ្យ ។

មេឃុំមកពី CPP ហើយសមាជិកក្រុមប្រឹក្សាឃុំមាន ៧នាក់មកពី CPP, ៣នាក់ពី FUNCINPEC (ធ្វើជាជំទប់ទី១), និង ១នាក់ពី SRP (ធ្វើជាជំទប់ទី២) ។ នៅឆ្នាំ១៩៩៨ FUNCINPEC បានឈ្នះដាច់ដោយបានសន្លឹកឆ្នោត ៣៩%, ធៀបនឹង CPP បាន ៣៤%, និង SRP ១៧% ។ នៅឆ្នាំ២០០២ CPP ស្ទុះទៅមុខដោយបាន ៥៧%, ធៀបនឹង FUNCINPEC ២៧%, និង SRP ១៣% ។ សន្ទុះនេះ ថយចុះនៅឆ្នាំ២០០៣ ដោយ CPP បាន ៣៨%, SRP បាន៣១%, និង FUNCINPEC បាន ២០% ។

**ប្រវត្តិនៃការបោះឆ្នោត: ឃុំវត្តតាមឹម**

| | |
|---|---|
| 1998 | 1st FUNCINPEC, 2nd CPP, 3rd SRP |
| 2002 | 1st CPP, 2nd FUNCINPEC, 3rd SRP |
| 2003 | 1st CPP, 2nd SRP, 3rd FUNCINPEC |

រឿងទំនាស់ចំបងមួយក្នុងពេលបោះឆ្នោតគឺ តួនាទីរបស់អាជ្ញាធរមូលដ្ឋានដែលមានសមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត និងប្រធានភូមិដែលដែលត្រូវបានជ្រើសតាំង ។ នេះជាលើកទី១ នៅកម្ពុជា ដែលអាជ្ញាធរមូលដ្ឋាន បានជាប់ឆ្នោតមានការទទួលខុសត្រូវចូលរួមរៀបចំការបោះឆ្នោត ដូចជា ស្មៀនឃុំ និងក្រុមប្រឹក្សាឃុំ ដែលទទួលបន្ទុកចុះបញ្ជីអ្នកបោះឆ្នោតជាដើម ។ អាជ្ញាធរមូលដ្ឋានទាំងនេះដើរតួនាទីសំខាន់ក្នុងការបោះឆ្នោត ពីព្រោះពួកគេចេញមកពីគណបក្សធំៗទាំង៣ និងតំណាងឱ្យមជ្ឈដ្ឋានអ្នកបោះឆ្នោត ។ នាពេលបោះឆ្នោត សណ្ដាប់ធ្នាប់សាធារណៈជាការទទួលខុសត្រូវចំបងរបស់អាជ្ញាធរមូលដ្ឋានផងដែរ ជាពិសេស ប៉ូលីសឃុំ និង គឃប ដែលធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីធានាសន្តិសុខ ។ ប្រជាជនជាទូទៅមានអារម្មណ៍ចំរុះ ពីព្រោះក្រុមប្រឹក្សាឃុំអនុវត្តបានលទ្ធផលជាវិជ្ជមានមួយចំនួន ។ មានការរីកចំរើនជាច្រើន បើធៀបនឹងការបោះឆ្នោតឆ្នាំ១៩៩៨ គឺមាន ១) គឃប ប៉ូលីស និងអាជ្ញាធរឃុំ ធ្វើការយ៉ាងជិតស្និទ្ធដើម្បីធានាឱ្យការបោះឆ្នោតដំណើរការល្អ, ២) ឆ្លងតាមបទពិសោធន៍បានពីការបោះឆ្នោតឃុំ ប្រជាជនមានចំណាប់អារម្មណ៍ថា ទោះអ្នកណាឈ្នះ ក៏ខ្លួននៅតែរស់នៅតាមរបៀបដដែល, ដូច្នេះការអត់ឱនគឺជាទិដ្ឋភាពដ៏សំខាន់បំផុត, ៣) តាមរយៈក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត ប្រជាជនបានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗជាមួយអាជ្ញាធរមូលដ្ឋាន និង NGOs ហើយរឿងនេះបានជួយលើកកំពស់ការយល់ដឹងពីចំណាប់អារម្មណ៍ក្នុងចំណោមប្រជាជន, ៤) អាជ្ញាធរឃុំ រួមមាន សមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត និងដែលចេញមកពីគណបក្សធំៗទាំង៣ ហើយរឿងនេះធ្វើឱ្យគណបក្សនយោបាយទាំងអស់មានការទទួលខុសត្រូវ និងធ្វើការចែករំលែកពត៌មាន ។

*"ប្រជាជនឥឡូវមានការវ៉ៃឆ្លាត និងដឹងថាអ្នកណាល្អ អ្នកណាអាក្រក់នៅក្នុងសហគមន៍ ។ ពួកគេមានលទ្ធភាពល្អក្នុងការមានវិទ្យុ និងទូរទស្សន៍ប្រើប្រាស់ ។ គ្រប់គ្នាដឹងថា ការបោះឆ្នោតសំងាត់ជាអ្វី ប៉ុន្តែពួកគេមិនចង់ប្រាប់អ្នក ហើយក្ដីដំណែលពីរបបខ្មែរក្រហម ធ្វើឱ្យប្រជាជនរារែកមិនចង់និយាយ ឬចែករំលែកពត៌មានជា*

[៧៩] សមាជិកក្រុមស្រាវជ្រាវម្នាក់គឺ លោក គឹម សេតារា ធ្លាប់ទៅដល់ឃុំនេះជាច្រើនដងតាំងពីឆ្នាំ១៩៩៦ មក ហើយថ្មីៗនេះទៀតក្នុងការសិក្សារបស់ វិបសអ ស្ដីពីវិមជ្ឈការ ។ អ្នកស្រាវជ្រាវរូបនេះ បានកសាងទំនាក់ទំនងយ៉ាងល្អជាមួយមនុស្សជាច្រើនក្នុងឃុំ ដែលបានជួយឱ្យក្រុមស្រាវជ្រាវអាចមានលទ្ធភាពចូលទៅពាក់ព័ន្ធក្នុងសហគមន៍បាន ។

*សាធារណៈ ។ ប្រជាជនធ្លាប់ពាក់ព័ន្ធនឹងកម្មវិធីអភិវឌ្ឍន៍គ្រប់ប្រភេទ ក្នុងនេះមានទាំងមូលនិធិអភិវឌ្ឍន៍ឃុំផង ហើយយើងកំពុងប្រើប្រាស់វិធីសាស្ត្រចូលរួមដោយស្ម័គ្រចិត្ត ដោយឈរលើគោលការណ៍ប្រជាធិបតេយ្យ ។ សំរាប់ការឃោសនា យើងបានបែងចែកជាតារាង ពេលខុសៗគ្នាសំរាប់គណបក្សនយោបាយនីមួយៗ ហើយទង្វើនេះមានប្រសិទ្ធភាព ដើម្បីចៀសវាងទំនាស់ពាក្យសំដីដែលអាចកើតមាន*[៨០] ។

ប៉ុន្តែនៅមានការតវ៉ាជាច្រើនស្តីពី តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ។ ឧទាហរណ៍ សមាជិកក្រុមប្រឹក្សាឃុំខាង SRP និង FUNCINPEC បានចោទសកម្មជន CPP ថា បានធ្វើការទិញសន្លឹកឆ្នោតក្នុងពេលឃោសនា, ហើយគណបក្សទាំង២ ខ្វះទំនុកចិត្តលើ គឃប និងអាជ្ញាធរមូលដ្ឋាន ដោយអះអាងថា ស្ថាប័នទាំងនេះធ្វើការឱ្យ CPP ។ ក្នុងយប់ពីថ្ងៃបោះឆ្នោតទៅថ្ងៃរាប់សន្លឹកឆ្នោត នៅពេលដែលហិបឆ្នោតត្រូវរក្សាទុកនៅក្នុងវត្ត SRP និង FUNCINPEC បានសុំឱ្យ គឃប យកហិបនានាទៅទុកនៅអគារមួយទៀត ដោយលើកឡើងថា អគារដែលកំពុងទុកហិបឆ្នោតគឺជារបស់សកម្មជន CPP ម្នាក់ ។ ក្នុងការតវ៉ានេះ SRP និង FUNCINPEC បានអំពាវនាវដល់ គខប និងអភិបាលស្រុក (ដែលជាសមាជិក FUNCINPEC) ឱ្យធ្វើអន្តរាគមន៍ ។ នៅចុងបញ្ចប់ គឃប បានយល់ព្រមប្តូរបន្ទប់ ។ ការតវ៉ាមួយទៀតទាក់ទិននឹងការអះអាងរបស់សកម្មជន SRP ម្នាក់ថា បានឃើញប្រធានភូមិម្នាក់នៅជិតការិយាល័យបោះឆ្នោតកំពុងប្រាប់ប្រជាជនឱ្យបោះឆ្នោតឱ្យ CPP ។

សមាជិកក្រុមប្រឹក្សាឃុំខាង SRP ម្នាក់លើកឡើងថា "សកម្មជនរបស់ខ្ញុំបានឃើញប្រធានភូមិម្នាក់កំពុងប្រាប់ពួកអ្នកភូមិឱ្យបោះឆ្នោតឱ្យ CPP ហើយយើងថតរូបបានមួយផងដែលកំពុងយកទៅផ្តិត"[៨១] ។ នៅមានការតវ៉ាច្រើនទៀតដែលភាគច្រើនទាក់ទងនឹងប្រធានភូមិ និងសមាជិកក្រុមប្រឹក្សាឃុំខាង CPP ។ ការតវ៉ាជាទូទៅ២ គឺការទិញសន្លឹកឆ្នោត និងទំនាស់ផលប្រយោជន៍ ដូចជាពាក់អាវយឺត មួក ឬទាឡិកាដៃ មានរូបសញ្ញា CPP, ឬក៏សកម្មជន CPP ប្រើប្រាស់សាលាឃុំ ដើម្បីប្រជុំពួកសមាជិកសំរាប់ធ្វើការឃោសនា ។

ក្រុមស្រាវជ្រាវបាននិយាយជាមួយប្រធានភូមិ ៤នាក់ក្នុងឃុំនេះ ។ ពួកគេដឹងច្បាស់ពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងពេលបោះឆ្នោត ។ ឧទាហរណ៍ ពួកគេនិយាយថា ពួកគេមិនអាចពាក់អាវយឺតរបស់គណបក្ស ឬធ្វើការឃោសនាបានទេ លើកលែងតែបានផ្ញើលិខិតសុំលាឈប់ទៅឱ្យអាជ្ញាធរឃុំ ។ ទាំងអស់គ្នានិយាយថា គាត់មិនដឹងច្បាស់ទេថា អ្នកមានភក្តីភាពចំពោះ CPP ឬគណបក្សឯទៀត មានប៉ុន្មាននាក់:

*"គ្មានអ្នកណាដឹងថា មានមនុស្សប៉ុន្មាននៅក្នុងគណបក្សណាមួយទេ ពីព្រោះប្រជាជនមិននិយាយពីគំនិតរបស់ខ្លួនប្រាប់គ្នា ។ ប៉ុន្តែប្រជាជនធ្វើការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលអាចធ្វើបាននៅក្នុងឃុំរបស់ខ្លួន"*[៨២] ។

ពួកប្រធានភូមិបង្ហាញពីភក្តីភាពយ៉ាងជ្រាលជ្រៅចំពោះ CPP ពីព្រោះគណបក្សនេះបានជួយធ្វើផ្លូវ ប្រព័ន្ធស្រោចស្រព និងសាលារៀននៅក្នុងឃុំ ។ សកម្មជន SRP ម្នាក់នៅក្នុងឃុំ មានប្រតិកម្មឡើងដោយចោទសួរពីប្រភពប្រាក់កាសសំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធនានារបស់ CPP ។

តំណាង SRP និង FUNCINPEC មិនសូវបារម្ភទេអំពីសន្តិសុខ ឬស្ថាប័នសន្តិសុខនៅក្នុងឃុំ ។ គេប្រាប់យើងថា មានសន្តិសុខល្អក្នុងរយៈពេលឃោសនា និងបោះឆ្នោត ។ មេឃុំពន្យល់ថា "ខ្ញុំមានការទទួលខុសត្រូវចំបងមួយក្នុងការធ្វើបច្ចុប្បន្នភាពពតិមានរាល់ថ្ងៃពីរឿងសន្តិសុខ ។ បើសិនមានអ្វីកើតឡើងក្នុងពេលបោះឆ្នោត យើងនឹងមានការទទួលខុសត្រូវ ។ មកទល់ពេល

---

[៨០] Commune chief, Wat Tamim (27), personal interview, Battambang, 21 July 2003.

[៨១] SRP commune councillor, Wat Tamim (28), personal interview, Battambang, 4 Aug. 2003.

[៨២] Village chiefs, Wat Tamim (29, 30, 31, 32), personal interviews, Battambang, 21 July 2003.

នេះពុំមានបញ្ហាឬអំពើហិង្សាទាក់ទិននឹងការបោះឆ្នោតទេ"[៨៣] ។

*៣.២.៣.២ ស្ថាប័នបោះឆ្នោត*

ដោយមានការបោះឆ្នោតជាបន្តបន្ទាប់ បុគ្គលិក គឃប ប្រមូលបានបទពិសោធន៍ថែមក្នុងការរៀបចំការបោះឆ្នោត ។ ការប្រជុំប្រចាំសប្តាហ៍រៀបចំដោយ គឃប សំរាប់អ្នកជាប់ពាក់ព័ន្ធទាំងអស់ ដូចជា តំណាងគណបក្សនយោបាយ និងអាជ្ញាធរមូលដ្ឋានជាដើម ហាក់ដូចជាមធ្យោបាយមួយមានប្រសិទ្ធភាពល្អដើម្បីដោះស្រាយបញ្ហា និងកសាងទំនុកចិត្តក្នុងចំណោមគណបក្សនយោបាយនានា ។ ក្នុងរយៈពេលឃោសនា គឃប ទទួលរបាយការណ៍ប្រចាំថ្ងៃពីខាងប៉ូលីស ហើយ គឃប មានបុគ្គលិកខ្លួនផ្ទាល់សំរាប់ត្រួតពិនិត្យសភាពការណ៍ ។ គឃប នៅវត្តតាមឹម បង្ហាញថាគណបក្សទាំងអស់អាចទាក់ទងមកខ្លួនបានដោយទទួលពិចារណាការតវ៉ារបស់ SRP ស្តីពីការផ្លាស់កន្លែងទុកហិបឆ្នោត ។ បុគ្គលិក គឃប ជាច្រើនមានទំនុកចិត្តខ្លាំងលើសមាជិកក្រុមប្រឹក្សាឃុំជាប់ឆ្នោត ដែលមកពីគណបក្សធំៗទាំង៣:

> *"លើកនេះ អាជ្ញាធរមូលដ្ឋានមានការទទួលខុសត្រូវច្រើនឡើងក្នុងរឿងសណ្តាប់ធ្នាប់សង្គម និងសន្តិសុខក្នុងឃុំ ។ គណបក្សទាំង៣ មានសមាជិករបស់ខ្លួនដែលប្រចាំនៅសាលាឃុំ ។ អ្នកទាំងនោះសុទ្ធតែជាតំណាង ។ គណបក្សនីមួយៗត្រៀមរៀបចំបានល្អជាងកាលពីការបោះឆ្នោតឆ្នាំ១៩៩៨"[៨៤] ។*

ក្រុមស្រាវជ្រាវបានឮគ្រប់កន្លែងថា SRP និង FUNCINPEC មិនទុកចិត្តការងារ គឃប ទេ ពីព្រោះមានមេរៀនមិនល្អដែលរៀនសូត្របានពីការបោះឆ្នោតមុនៗ ។ SRP នៅវត្តតាមឹម បានធ្វើការចោទប្រកាន់ធំៗពីរចំពោះ គឃប គឺ ទី១ នីតិវិធីជ្រើសរើស គឃប មានចំណុចខ្វះខាតនាំឱ្យជ្រើសរើសបានមនុស្សដដែលៗមកប្រើរាល់ៗលើក, និង ទី២ អ្នកបំរើការទាំងនេះសុទ្ធតែជាបុគ្គលិករដ្ឋដែលស្ថិតក្រោមអំណាច CPP ។ ប៉ុន្តែ គឃប វត្តតាមឹម បានជំទាស់នឹងមតិ SRP ដោយលើកឡើងថា "នៅតំបន់ជនបទភាគច្រើនគឺគ្រូបង្រៀនដែលមានចំណេះដឹងសំរាប់ការងារបែបនេះ ដូច្នេះហើយបានជាយើងទទួលយកពួកគេជាបន្តបន្ទាប់ ។ បុគ្គលិក គឃប ទាំងអស់ធ្វើការងារខ្លាំង និងនឿយហត់ណាស់ដោយសារការងារមមាញឹកក្នុងពីរខែនេះ ។ គ្មានថ្ងៃឈប់សំរាកទេ ហើយប្រាក់កំរៃក៏ខ្សត់ខ្សោយ"[៨៥] ។

*៣.២.៣.៣ ការចុះបញ្ជីអ្នកបោះឆ្នោត*

ចំនួនអ្នកបោះឆ្នោតបានចុះបញ្ជីត្រឹមត្រូវ គឺ ៩២% នៅក្នុងឃុំនេះ ។ អ្នកជាប់ពាក់ព័ន្ធទាំងអស់ដូចជា គណបក្សនយោបាយ អាជ្ញាធរឃុំ និងប្រធានភូមិ, បានលើកទឹកចិត្តប្រជាជនឱ្យចុះបញ្ជីបោះឆ្នោត ។ អ្នកខ្លះអវត្តមានពីព្រោះជាប់ទៅធ្វើការនៅថៃឬនៅភ្នំពេញ ។ ស្មៀនឃុំ ជំទប់ទី១ និងជំទប់ទី២ ទទួលខុសត្រូវក្នុងការចុះបញ្ជីអ្នកបោះឆ្នោត ។ ពួកគេប្រាប់ថា:

> *"យើងទាំងអស់គ្នារវល់បំផុតក្នុងរយៈពេលចុះបញ្ជី ។ យើងមិនដឹងពីនីតិវិធីទេ ថ្វីបើយើងបានទទួលការបណ្តុះបណ្តាលខ្លះ ហើយប្រជាជនក៏មិនធ្វើសហប្រតិបត្តិការពេញលេញដែរ ។ ជារឿយៗ យើងស្នើឱ្យអាជ្ញាធរមូលដ្ឋាន និងសកម្មជននយោបាយ ជួយផ្តល់ពត៌មានប្រជាជនឱ្យមកចុះបញ្ជី ។ ក្នុងឋានៈជាស្មៀនឃុំ ខ្ញុំត្រូវធ្វើការងារប្រចាំថ្ងៃក្នុងសាលាឃុំ ព្រមទាំងជួយក្នុងការងារចុះបញ្ជីផង ។ យើងជួបបញ្ហាបច្ចេកទេសខ្លះៗក្នុងការថតរូប និងសរសេរឈ្មោះខុស ។ ពិតហើយយើងខ្វះជំនួយខាងសំភារៈ និងដឹកជញ្ជូន"[៨៦] ។*

---

[៨៣] Commune chief, Wat Tamim (27), personal interview, Battambang, 4 Aug. 2003.

[៨៤] CEC members, Wat Tamim (33), group interview, Battambang, 3 Aug. 2003.

[៨៥] CEC members, Wat Tamim (33), group interview, Battambang, 3 Aug. 2003.

[៨៦] Commune clerk (34) and various councillors, Wat Tamim, group interview, Battambang, 21 July 2003.

បញ្ហាបច្ចេកទេសខ្លះៗក្នុងការចុះបញ្ជី បានកើតមានមួយចំណែកដោយសារកង្វះបុគ្គលិកក្នុងឃុំ និងកង្វះជំនាញ ។ នៅពេលនោះ គឃប មិនទាន់បង្កើតឡើងទេ និងមានការតវ៉ាជាច្រើនពី SRP និង FUNCINPEC ។ សមាជិក គឃប មានយោបល់ថា ការចែករំលែកការទទួលខុសត្រូវចេញពី គឃប ធ្វើឱ្យពួកគេពិបាកគ្រប់គ្រងដំណើរការ:

*"មានបញ្ហាបច្ចេកទេសមួយចំនួននៅក្នុងការចុះបញ្ជីអ្នកបោះឆ្នោត ។ គឃប ពិតជាមិនយល់ទេ បើសិនមានអ្វីខុស"*[៨៧] ។

បុគ្គលិក គឃប មួយចំនួនដែលយើងបានជជែកជាមួយនៅក្រោយថ្ងៃបោះឆ្នោត បានឯកភាពថា:

*"លើកក្រោយ គួរទុកឱ្យ គឃប ទទួលខុសត្រូវធ្វើការចុះបញ្ជីទើបប្រសើរ. ពីព្រោះលើកនេះយើងជួបបញ្ហាបច្ចេកទេសច្រើន ហើយយើងមិនដឹងថា អ្នកណាអាចដោះស្រាយបញ្ហាទាំងអស់នោះ"*[៨៨] ។

*៣.២.៣.៤ ការឃោសនាបោះឆ្នោត*

ក្នុងឃុំនោះ ការឃោសនាត្រូវបានបែងចែកតាមតារាងពេលខុសៗគ្នាសំរាប់គណបក្សទាំងអស់ ជាពិសេសគណបក្សធំៗទាំង៣ ។ គឃប ធ្វើការជាមួយអាជ្ញាធរឃុំក្នុងការកំណត់តារាងពេល ដើម្បីកាត់បន្ថយទំនាស់ពាក្យសំដីក្នុងពេលឃោសនា ។

*"យើងមានបទពិសោធន៍ពីឆ្នាំ១៩៩៨ និងការបោះឆ្នោតឃុំឆ្នាំ២០០២ថា ការប្រទាំងប្រទើស និងប្រកពទំនាស់ភាគច្រើន វាកើតមានឡើងក្នុងពេលឃោសនា ។ លើកនេះ ការធ្វើតារាងពេលសំរាប់គណបក្សជាប់ទាក់ទិននានា គឺជាមធ្យោបាយសក្តិសិទ្ធិមួយសំរាប់ឃុំយើង ។ រឿងនេះក៏បានជួយដល់ប៉ូលីសក្នុងការធ្វើផែនការរក្សាសន្តិសុខក្នុងឃុំដែរ"*[៨៩] ។

គណបក្សទាំង៥ ក្នុងឃុំ មានយុទ្ធសាស្ត្រប្រហែលគ្នាដើម្បីធ្វើឃោសនា ដូចជា ការប្រើផ្លាកសញ្ញាគណបក្ស សន្និកប័ណ្ណ ការដង្ហែក្បួនដោយមានរថយន្តនិងប្រដាប់បំពងសំលេង ការជួបប្រជុំជាមួយសកម្មជនក្នុងឃុំ ការប្រើអាវយឺតនិងមួក ។ សមាជិកក្រុមប្រឹក្សាឃុំខាង SRP និង FUNCINPEC បានតវ៉ាថា:

*"ថ្វីបើយើងមានតារាងពេលមួយសំរាប់ធ្វើឃោសនា និងគ្មានអំពើហិង្សាក្តី ប៉ុន្តែខាង CPP បានចាប់ផ្តើមឃោសនាមុន គណបក្សឯទៀតយ៉ាងយូរ ដោយប្រើប្រព័ន្ធរដ្ឋាភិបាល ។ ឧទាហរណ៍ ពួកប្រធានភូមិដែលបានជ្រើសតាំង និងសមាជិកក្រុមប្រឹក្សាឃុំមកពី CPP សកម្មជាខ្លាំង និងជាយូរមកហើយ ក្នុងការជួយដល់គណបក្សរបស់គេ ។ ពួកគេមានប្រាក់ និងមានធនធាន បើធៀបនឹងគណបក្សឯទៀត ។ គ្មានអ្វីសង្ស័យទេ ដែលពួកគេធ្វើការទិញសន្លឹកឆ្នោតនៅគ្រប់កន្លែង"*[៩០] ។

សកម្មជន SRP និង FUNCINPEC មានការសង្ស័យ និងបានប្រុងប្រយ័ត្នបំផុតក្នុងបញ្ហាខាងលើនេះ ។ ថ្វីបើ ពួកគេអះអាងថា CPP បានរំលោភក្រមសីលធម៌ច្រើនបែបយ៉ាងក្តី ប៉ុន្តែមិនបានផ្តល់ភស្តុតាងដើម្បីបញ្ជាក់គាំទ្រដល់ការអះអាងទាំងនេះទេ ។ ប្រធាន CPP នៅក្នុងឃុំបានបដិសេធរាល់ការចោទប្រកាន់ដោយនិយាយថា:

[៨៧] CEC members, Wat Tamim (33), group interview, Battambang, 3 Aug. 2003.

[៨៨] CEC members (33), Wat Tamim, personal interview, Battambang, 3 Aug. 2003.

[៨៩] CEC chief (35) and police, Wat Tamim, group interview, Battambang, 20 Aug. 2003.

[៩០] SRP and FUNCINPEC commune councillors (36, 37), Wat Tamim, personal interviews, Battambang, 22 July 2003.

*"ខ្ញុំមិនដែលរំលោភ ឬក៏ឆ្លៀតប្រើប្រាស់ប្រជាជនដោយសារហេតុផលខាងនយោបាយទេ ។ សកម្មជន CPP ទាំងអស់ធ្វើការងារប្រចាំថ្ងៃជាធម្មតា ពីព្រោះយើងត្រូវមានការទទួលខុសត្រូវសំរាប់ឃុំយើង ។ រឿងមួយទៀតគឺយើងទាំងអស់គ្នាបានឃើញមនុស្សចូលរួមក្នុងការដង្ហែក្បួនទាំងអស់ រៀបចំដោយគណបក្សនានាទាំងអស់ ។ ក្មេងៗចូលចិត្តអង្គុយស្រែកលើរថយន្ត ។ អ្នកខ្លះចង់ដឹងថា គណបក្សមួយទៀតនិយាអ្វី ។ នេះជាសេរីភាព ។ជួនកាលអ្នកភូមិមកជួបខ្ញុំ ដើម្បីសាកសួរពីការបោះឆ្នោត និងសភាពការណ៍នយោបាយ ។ ខ្ញុំប្រាប់ពួកគេថាគេមិនអនុញ្ញាតឱ្យខ្ញុំនិយាយទេ"*[៩១] ។

*៣.២.៣.៥ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងជាសាធារណៈពីការបោះឆ្នោត*

ចំណាប់អារម្មណ៍ជាទូទៅរបស់អ្នកឆ្លើយសំភាសន៍គឺ ការបោះឆ្នោតលើកនេះមានសុវត្ថិភាពជាងឆ្នាំ១៩៩៨ ហើយអ្វីៗមានការកែលំអ ។ នៅឃុំវត្តតាមីម មានសកម្មភាពអភិវឌ្ឍន៍ជនបទជាច្រើនឧបត្ថម្ភដោយ NGOs ជាតិ និងអន្តរជាតិ ដែលនាំឱ្យមានការកែលំអគ្រឹតជីវភាព ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំមានសមាសភាពមកពីទាំង ៣ គណបក្សធំៗ និងសន្តិសុខល្អក្នុងប្រទេស បានអនុញ្ញាតសកម្មជនគណបក្សធ្វើដំណើរចុះឡើងកាន់តែងាយស្រួល ។ បុគ្គលិក គឃប ដែលមានបទពិសោធន៍ និងអាជ្ញាធរមូលដ្ឋាន បានជួយផ្សព្វផ្សាយពតិមានដល់អ្នកភូមិពីការបោះឆ្នោត ។ កត្តាទាំងនេះបានជួយកែលំអចំណាប់អារម្មណ៍ជាសាធារណៈពីការបោះឆ្នោត ។

អ្នកភូមិបានឆ្លើយសំភាសន៍ប្រាប់ថា យន្តការដ៏សក្តិសិទ្ធិបំផុតក្នុងការឃោសនា គឺតាមរយៈប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ការបណ្តុះបណ្តាលដោយ NGOs និងការពាក់ព័ន្ធរបស់ប្រជាជនជាមួយតំបន់ទីក្រុង ។ ប៉ុន្តែ ប្រជាជនមួយចំនួនមានមតិថា ស្ថានីយវិទ្យុ និងទូរទស្សន៍ភាគច្រើនស្ថិតក្រោមការត្រួតត្រាយ៉ាងតឹងរឹងពី CPP ។ លទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព គឺមានគ្រឹត ។ ទោះបីវត្តតាមីម ជាឃុំធូរធារមួយក្នុងខេត្ត និងស្ថិតនៅជិតទីរួមខេត្តបាត់ដំបងក្តី ប្រជាជនក៏មិនទាន់មានលទ្ធភាពបានអានសារពតិមានដែរ ។ ដូច្នេះហើយប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ដើរតួនាទីសំខាន់បំផុតក្នុងការអប់រំអ្នកបោះឆ្នោត ។

*៣.២.៣.៦ ថ្ងៃបោះឆ្នោត និងថ្ងៃក្រោយមកទៀត*

ជាទូទៅ ដំណើរការនៅថ្ងៃបោះឆ្នោត និងថ្ងៃរាប់សន្លឹកឆ្នោត មានលក្ខណៈរលូនល្អ ។ មានបញ្ហាបច្ចេកទេសខ្លះដូចជាការចុះបញ្ជី ការចុះឈ្មោះខុសកន្លែងលើបញ្ជីបោះឆ្នោត និងអត្តសញ្ញាណប័ណ្ណគ្មានរូបថតជាដើម ។ អ្នកខ្លះដែលមិនបានចុះបញ្ជីបានមកបោះឆ្នោត ។ នៅពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានវត្តមានអ្នកសង្កេតការណ៍របស់គណបក្សនយោបាយ, អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ, និងខាង COMFREL និង NICFEC ។

## *៣.២.៤ ឃុំឆ្នោត ក្នុងស្រុកបាទី ខេត្តតាកែវ*

*៣.២.៤.១ អាជ្ញាធរឃុំ និងនយោបាយ*

ឆ្នោត ជាឃុំជនបទមួយស្ថិតនៅជិតផ្លូវជាតិលេខ២ ក្នុងស្រុកបាទី ។ ឃុំនេះមាន ៨ភូមិ មានផ្ទៃដីសរុប ១.៤០១ហិកតានិងប្រជាជន ៦.៦១៨នាក់ ដែលរកចិញ្ចឹមជីវិតភាគច្រើនដោយធ្វើស្រែ និងតំបាញសូត្រ ហើយគេអាចមើលឃើញការងាររបស់ NGO ក្នុងការអភិវឌ្ឍន៍សកម្មភាពតំបាញសូត្រនេះ ។ ឃុំក៏ទទួលផលចំណេញខាងសេដ្ឋកិច្ចដោយសារស្ថិតនៅជិតក្រុងភ្នំពេញ ។ នៅថ្ងៃបោះឆ្នោត គេឃើញកម្មករកាត់ដេរជាច្រើនបានមកដល់ឃុំនេះ ដើម្បីបោះឆ្នោត ។ គណបក្សដែលសកម្មនៅក្នុងឃុំនេះមាន CPP, FUNCINPEC, SRP, និង គណបក្ស ហង្ស ដារ៉ា ចលនាប្រជាធិបតេយ្យ ។

---

[៩១] Commune chief (27) and other CPP activists, Wat Tamim, group interview, Battambang, 4 Aug. 2003.

ក្រុមប្រឹក្សាឃុំមានសមាសភាព សមាជិក ៣នាក់មកពី CPP, ៣នាក់មកពី FUNCINPEC, និង ១នាក់មកពី SRP ។ ឃុំនេះតែងល្បីថាគាំទ្រខាង FUNCINPEC, ចំណែកឯខេត្តតាកែវជាប្រពៃណីតែងជាបង្អែករបស់ CPP ។ នៅឆ្នាំ១៩៩៨ FUNCINPEC បានឈ្នះយ៉ាងងាយនៅក្នុងខេត្ត ដោយទទួលឆ្នោតបាន ៥៥%, ធៀបនឹង CPP ២១% និងSRP បាន ១៦% ។ ប៉ុន្តែក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ CPP បានឈ្នះនៅក្នុងឃុំដោយទទួលឆ្នោត ៧១% ធៀប នឹង FUNCINPEC ២១% និង SRP ៧% ។ ដូច្នេះមេឃុំ គឺជាតំណាង CPP ហើយគាត់លើកឡើងថា ភក្តីភាពចំពោះ FUNCINPEC ក្នុងការបោះឆ្នោតក៏រិតជាតិ គឺអ្នក បោះឆ្នោតមានការគោរពបូជាចំពោះព្រះមហាក្សត្រ ប៉ុន្តែជ័យជំនះរបស់គាត់ក្នុងឆ្នាំ១៩៩៨ គឺដោយសារប្រជាប្រិយភាពផ្ទាល់ខ្លួន របស់គាត់ ។ គាត់ធ្លាប់ធ្វើចៅហ្វាយឃុំតាំងពីឆ្នាំ១៩៨៣ ដល់ ១៩៩០ ហើយអ្នកភូមិដែលគាំទ្រ CPP បានបញ្ចុះបញ្ចូលឱ្យគាត់ ឈរឈ្មោះនៅឆ្នាំ២០០២ ព្រោះខ្លាច FUNCINPEC បានឈ្នះម្តងទៀតនៅក្នុងឃុំ ។ គាត់មានមតិថា "ការបោះឆ្នោត (ឆ្នាំ២០០៣) គឺសំរាប់អ្នកថ្នាក់ខ្ពស់ៗ ដែលយើងមិនស្គាល់ទេ ។ ប៉ុន្តែនៅក្នុងឃុំ អ្នកណាក៏ស្គាល់អ្នកណាដែរ"[៩២] ។ មេឃុំរាយ ការណ៍ថា មានទំនាស់មួយចំនួនក្នុងដំណើរការរាប់សន្លឹកឆ្នោតនៅឆ្នាំ២០០២ ទាក់ទិននឹងបញ្ហាសន្លឹកឆ្នោតខូច ប៉ុន្តែរឿងនេះអាច ដោះស្រាយបានតាមការសំរុះសំរួលគ្នា ។

| **ប្រវត្តិនៃការបោះឆ្នោតៈ ឃុំធ្នោត** | |
|---|---|
| 1998 | 1st FUNCINPEC, 2nd CPP, 3rd SRP |
| 2002 | 1st CPP, 2nd FUNCINPEC, 3rd SRP |
| 2003 | 1st FUNCINPEC, 2nd CPP, 3rd SRP |

ក្នុងរយៈពេលបោះឆ្នោតឆ្នាំ២០០៣ សមាជិកក្រុមប្រឹក្សាឃុំ ខាង CPP និង FUNCINPEC ព្រមទាំងពួកអ្នកឃោសនា បានរាយការណ៍ពីបញ្ហា និងទំនាស់តិចតួចក្នុងឃុំ ។ មេឃុំបានរាយការណ៍នូវការតវ៉ាពីសំលេងឮខ្លាំងនៃប្រដាប់បំពងសំលេងរបស់ FUNCINPEC និងទំនាក់ទំនងមិនល្អនៅក្នុងភូមិរវាងអ្នកដើរតាមគណបក្សខុសៗគ្នា ប៉ុន្តែ គាត់លើកឡើងថា "គ្មានអ្វីធំដុំទេ" ។ សមាជិកក្រុមប្រឹក្សាឃុំខាង CPP និង FUNCINPEC ហាក់ដូចមានទំនាក់ទំនងធ្វើការជាមួយគ្នាល្អ និងមានរាយការណ៍ពីការ លំបាកតិចតួចទេក្នុងការគ្រប់គ្រងការងារឃុំ ថ្វីបើជំទប់ទី១ ជា FUNCINPEC បានត្អូញត្អែរថា ក្រុមប្រឹក្សាឃុំមានលទ្ធភាព តិចណាស់ ដោយសាររដ្ឋាភិបាលថ្នាក់មជ្ឈិមមិនបានបើកផ្តល់ថវិកាឱ្យពួកគេ ។ គាត់លើកឡើងថាៈ

> *"គណបក្សនីមួយៗមានកម្មវិធីសំរាប់ជួយប្រជាជន ប៉ុន្តែយើងមិនឃើញមានអ្នកណារក្សាការសន្យារបស់ខ្លួនទេ ។ ក្នុងឃុំយើងគ្មាន NGOs ទេ គ្មានទំនិញមកពីក្រៅ គ្មានប្រាក់សំរាប់អភិវឌ្ឍន៍ទេ ។ គឃប ទទួលបានប្រាក់ជាង ៥លានរៀល ប៉ុន្តែក្រុមប្រឹក្សាឃុំគ្មានទទួលអ្វីសោះ ។ តើយើងអាចឱ្យអ្វីដល់ពួកគេបាន បើយើងគ្មានប្រាក់សោះ? ក្នុងឃុំនេះ យើងចង់ធ្វើជាតំណាងដើម្បីជួយប្រជាជនដែលជួបការលំបាក ។ ប៉ុន្តែប្រជាជាតិ មិនបានឃើញ លទ្ធផលអ្វីទេ ។ យើងបោះឆ្នោត ឬមិនបោះ គឺវាដូចតែគ្នា, នៅក្នុងឃុំយើងគ្មានប្រាក់ទេ យើងមិនអាចទាំងជួស ជុលផ្លូវបានផង"[៩៣] ។*

ជំទប់ទី១ ជឿថា រឿងនេះមានផលប៉ះពាល់មិនល្អទៅលើក៏រិតនៃផលប្រយោជន៍នយោបាយនៅក្នុងនយោបាយជាតិនៅ ក្នុងឃុំ ប៉ុន្តែបានអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំជំនះលើការខុសគ្នាខាងនយោបាយៈ

---

៩២ Commune Chief, Thnaot (38), personal interview, Takeo, 8 July 2003.

៩៣ FUNCINPEC First Deputy Chief, Thnaot (39), personal interview, Takeo, 8 July 2003.

*"ចំណាប់អារម្មណ៍មិនទុកចិត្តលើរដ្ឋាភិបាល កាន់តែកើនឡើង ពីព្រោះកន្លងមករដ្ឋាភិបាលមានចំលើយតបដ៏តិចតួច ។ ប្រជាជនមិនរវល់អ្វីច្រើនពីរឿងប្រព័ន្ធពហុបក្សក្នុងក្រុមប្រឹក្សាឃុំទេ ។ ប៉ុន្តែក្នុងឋានៈជាអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយប្រជាជន ពួកប្រជាជនគេបានសាកសួរយើងយ៉ាងច្រើន"*[៥៤] ។

ទាំងមេឃុំ និងជំទប់ទី១ បានលើកមតិថា នយោបាយនៅមូលដ្ឋាន ជាពិសេសតាំងពីការបោះឆ្នោតឃុំមក បានក្លាយជាសំខាន់ជាងនយោបាយថ្នាក់ជាតិទៅទៀតសំរាប់ប្រជាជននៅឃុំធ្នោត ហើយហេតុផលមួយចំណែកគឺ ចំណាប់អារម្មណ៍ថា អ្នកនយោបាយថ្នាក់ជាតិមិនបានយកចិត្តទុកដាក់ពីឃុំទេ ។ មេឃុំលើកមតិថា CPP បានចាត់ទុកឃុំនេះថា មានសារៈសំខាន់ជាយុទ្ធសាស្ត្រតិចតួច ពីព្រោះជាបង្អែកទោលតែឯងរបស់ FUNCINPEC នៅក្នុងខេត្តមួយដែលគាំទ្រ CPP យ៉ាងខ្លាំង ។ ទស្សនៈដែលថា ឃុំធ្នោតគឺជាមណ្ឌលបោះឆ្នោតអន់ថយមួយ ត្រូវបានបញ្ជាក់ឡើងដោយសមាជិក គឃប ម្នាក់ដែលឆ្លើយសំភាសន៍ប្រាប់ថា ការបោះឆ្នោតនឹងមានការកែលំអ បើសិនមានការជជែកវែកញែកជាសាធារណៈច្រើនថែមទៀតរវាងបេក្ខជនតំណាងរាស្ត្រ និងអ្នកបោះឆ្នោត ។ គាត់និយាយថា បញ្ហាចោទធំបំផុតចំពោះរបបប្រជាធិបតេយ្យនៅកម្ពុជា គឺប្រជាជនមានការភ័យខ្លាច មិនហ៊ាននិយាយចេញ ដូច្នេះហើយពួកអ្នកនយោបាយមិនដែលឮអ្វីដែលពួកគេចង់និយាយទេ ។ គាត់លើកឡើងថា "មនុស្សរបស់គណបក្សនយោបាយ ត្រូវស្តាប់ការត្អូញត្អែររបស់ប្រជាជន"[៥៥] ។

ប៉ុន្តែឃើញមានភាពតានតឹងយ៉ាងច្បាស់រវាងតំណាង CPP និង SRP នៅក្នុងភូមិ ។ ប្រធានខាងឃោសនាបោះឆ្នោតរបស់ CPP បានលើកឡើងថា ការបោះឆ្នោតឆ្នាំ២០០៣ មានទំនាស់តិចជាងកាលពីមុន ពីព្រោះអ្នកតំណាងខាងនយោបាយនានាមានការជួបប្រជុំជាប្រចាំដើម្បីលើកពីបញ្ហា និងទំនាស់នានា ប៉ុន្តែគាត់បន្ថែមថា:

*"ការធ្វើការជាមួយ SRP នៅតែចោទបញ្ហាធំ ។ SRP និយាយមិនល្អជាមួយយើង ប៉ុន្តែ គឃប ប្រាប់ពួកគេឱ្យទៅឃោសនានៅកន្លែងមួយផ្សេង ។ FUNCINPEC និងយើងធ្លាប់ធ្វើអ្វីៗជាមួយគ្នា ប៉ុន្តែ SRP មិនបានយកចិត្តទុកដាក់បែបនេះទេ"* ។

ដូចគ្នាដែរ តំណាង SRP ក្នុងក្រុមប្រឹក្សាឃុំ អះអាងថា សមាជិក CPP ខ្លះ បានបំភិតបំភ័យអ្នកគាំទ្រ SRP ដោយសួរពួកគេថា "បើសិនអ្នកចាញ់ តើអ្នកនឹងរស់នៅយ៉ាងណាក្នុងភូមិនេះ?" ។

ថ្វីបើមិនទុកចិត្តលើ គឃប និង គខប ប៉ុន្តែតំណាង SRP បង្ហាញពីទំនុកចិត្តចំពោះវិធានការសង្កេត និងសំរបសំរួល ដែលបានកសាងឡើងសំរាប់គ្រប់គ្រងការបោះឆ្នោត ។ គាត់មានមតិថា តួនាទីអាជ្ញាធរមូលដ្ឋានបានល្អច្រើនណាស់ជាងការបោះឆ្នោតមុនៗ ហើយ "គណបក្សនីមួយៗមានយន្តការល្អសំរាប់ត្រួតពិនិត្យសភាពការណ៍" ។ គាត់ក៏ប្រាកដក្នុងខ្លួនដែរអំពីតួនាទីរបស់គាត់ជាអ្នកសង្កេតការណ៍របស់គណបក្សនៅថ្ងៃបោះឆ្នោត និងថ្ងៃរាប់សន្លឹកឆ្នោត ដោយបានលើកឡើងថា:

*"ខ្ញុំមានបំណងចង់សង្កេតការណ៍ -យើងទៅជួយ ហើយគណបក្សទាំងអស់ឯកភាពគ្នាពីចំនួនសន្លឹកឆ្នោតដែលយើងមាន- យើងជជែកគ្នារហូតដល់យើងឯកភាពគ្នា ហើយបន្ទាប់មកយើងចុះហត្ថលេខាដើម្បីបង្ហាញថា យើងឯកភាព ។ យើងធ្លាប់ទៅចូលរួមការប្រជុំមួយ ដើម្បីរៀនធ្វើរឿងនេះ"* ។

គាត់បន្ថែមទៀតថា ការយល់ដឹងកាន់តែប្រសើរពីដំណើរការបោះឆ្នោតក្នុងចំណោមប្រជាជនជាទូទៅ គឺបានកាត់បន្ថយលទ្ធភាពដែលគណបក្សនយោបាយអាចប្រើមធ្យោបាយខុសច្បាប់ផ្សេងៗដើម្បីបានសន្លឹកឆ្នោត:

---

៥៤ FUNCINPEC First Deputy Chief, Thnaot (39), personal interview, Takeo, 8 July 2003.

៥៥ CEC member, Thnaot (40), personal interview, Takeo, 8 July 2003.

*"ស្ថានការណ៍បានល្អជាងមុនច្រើនណាស់ ។ ឥឡូវនេះស្ងប់ស្ងាត់ ពីព្រោះប្រជាជនយល់ដឹងច្រើនជាងមុន ដូច្នេះគេអាចធ្វើអ្វីៗបាន ។ សព្វថ្ងៃប្រជាជនយល់ច្រើន ។CPP និង FUNCINPEC មិនហ៊ានធ្វើអ្វីច្រើនពេកទេ"[៥៦] ។*

ជំទប់ទី១ខាង FUNCINPECក៏ឯកភាពដែរថា "ប្រជាជនដឹងពីការបោះឆ្នោតជាសំងាត់ ដូច្នេះហើយអាជ្ញាធរមូលដ្ឋាន និងសកម្មជននយោបាយ មិនសូវមានលទ្ធភាពគ្របសង្កត់លើការបោះឆ្នោតទេ"[៥៧] ។ ដូចគ្នាដែរ សមាជិក គឃប ម្នាក់មានមតិថា:

*"ធៀបនឹងកាលពីមុន -ខ្ញុំមិនមែនជាសមាជិក គឃប ទេនៅឆ្នាំ១៩៩៨ ប៉ុន្តែខ្ញុំគិតថាអ្វីៗបានត្រឹមត្រូវល្អនៅលើកនេះ ។ ពុំមានការគំរាមកំហែង ឬអំពើហិង្សាទេឥឡូវនេះ ពីព្រោះក្រុមប្រឹក្សាឃុំត្រួតត្រារឿងនយោបាយ និងពីព្រោះប្រជាជនមានការយល់ដឹងកាន់តែប្រសើរ ។ ប្រជាជនយល់ដឹងពីច្បាប់ ។ ពួកគេទទួលពត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស តាមរយៈវិទ្យុ និងទូរទស្សន៍ និងតាមរយៈប៉ូស្ទ័រដែលយើងចែក ។ មានមន្ត្រីនានាបានមកបណ្តុះ បណ្តាលយើងចំនួន ២ថ្ងៃ ពីក្រុមសីលធម៌របស់គណបក្សនយោបាយ មន្ត្រីរាជការ និងកងទ័ព"[៥៨] ។*

តាមមតិអ្នកឆ្លើយសំភាសន៍ ការភ័យខ្លាចនៅមាននៅឡើយ ។ ជំទប់ទី១ ខាង FUNCINPEC មានមតិថា "យើងគ្មានប្រជាធិបតេយ្យទេ ពីព្រោះប្រជាជនមិនទាន់ក្លាហានគ្រប់គ្រាន់ដើម្បីបញ្ចេញមតិរបស់ខ្លួនជាសាធារណៈ ។ វប្បធម៌នៃការភ័យខ្លាចនៅចាក់ឫសជ្រៅណាស់" ។ សមាជិកក្រុមប្រឹក្សាឃុំដែលជា SRP ក៏លើកពីការបារម្ភថា ពួកប្រធានភូមិអាចធ្វើសកម្មភាពទិញសន្លឹកឆ្នោត ឬធ្វើការបំភិតបំភ័យ ប៉ុន្តែគាត់និយាយថា តំណាងគណបក្សនយោបាយនានាប្រុងប្រយ័ត្នខ្លាំងណាស់ក្នុងរឿងនេះ ។

ប្រធានភូមិអ្នកឆ្លើយសំភាសន៍នានាបានអះអាងថា ពួកគាត់ប្រកាន់អព្យាក្រឹតភាពដ៏តឹងរ៉ឹង ក្នុងការពាក់ព័ន្ធជាមួយគណបក្សនយោបាយនានា ថ្វីបើពួកគាត់ជាបុគ្គលផ្ទាល់ខ្លួនគឺគាំទ្រ CPP ក្តី ។ ប្រធានភូមិម្នាក់លើកឡើងថា:

*"ពួកយើងអព្យាក្រឹត្យ ។ អាជ្ញាធរមូលដ្ឋានជួយគ្រប់គណបក្សនយោបាយ -ជួយរក្សាសន្តិសុខសំរាប់គណបក្សនយោបាយនានា ។ នៅទីនេះគ្មានបញ្ហាខាងសន្តិសុខទេ- កន្លងមកមិនដែលមានអំពើហិង្សាសោះ ។ មានគណបក្សធំៗ ៣ –SRP, FUNCINPEC, និង CPP ។ FUNCINPEC បានលើកចំណុចជាច្រើនពី CPP -ពួកគេឈ្លះ CPP ហើយនិយាយថា ពួកយើងពុករលួយ ចោរ ។ ពួកគេធ្វើការឃោសនាបែបនេះតាមកាសែត ។ យើងបានឃើញ ហើយយើងខឹង ប៉ុន្តែយើងមិនប្រតិកម្មទេ ។ យើងឃើញការពិត ។ លោក ហ៊ុន សែន និយាយថា យើងមិនត្រូវធ្វើអ្វីទេ ។ ប្រជាជនមិនជឿការឃោសនាទេ គេឃើញការពិត គេមើលឃើញការអនុវត្តន៍"[៥៩] ។*

ដូចគ្នាដែរ អ្នកគ្រប់គ្រងការឃោសនាខាង CPP បានលើកឡើងថា ពីដំបូងគណបក្សមានផែនការធ្វើឃោសនាក្នុងឃុំដោយប្រើប្រាស់សមាជិកក្រុមប្រឹក្សាឃុំដើម្បីដឹកនាំការឃោសនា. ប៉ុន្តែ ក្រោយដែល គជប បានចេញបទបញ្ញត្តិ ហាមឃាត់រឿងនេះ ខ្លួនគាត់ត្រូវបានជ្រើសរើសពីក្នុងចំណោមសមាជិកផ្សេងៗទៀតរបស់គណបក្ស ដើម្បីទទួលរ៉ាប់រងការងារនេះ ។

### *៣.២.៤.២ ស្ថាប័នបោះឆ្នោត*

---

[៥៦] SRP member, Thnaot (41), personal interview, Takeo, 8 July 2003.

[៥៧] FUNCINPEC member, Thnaot (42), personal interview, Takeo, 8 July 2003.

[៥៨] CEC member, Thnaot (40), personal interview, Takeo, 8 July 2003.

[៥៩] Village chief, Thnaot (43), personal interview, Takeo, 15 July 2003.

គឃប នៅឃុំត្នោត បានរាយការណ៍ពីទំនាស់តិចតួចក្នុងពេលឃោសនាបោះឆ្នោត គឺមានទំនាស់ពាក្យសំដីខ្លះបានកើតឡើង ប៉ុន្តែអាចដោះស្រាយបានយ៉ាងស្រួល ។ សមាជិក គឃប ម្នាក់រាយការណ៍ថា កំរិតនៃទំនាស់បានថយចុះច្រើនណាស់តាំងពីឆ្នាំ១៩៩៨ ពីព្រោះ "ស្ថាប័ននីមួយៗដូចជា គឃប និងក្រុមប្រឹក្សាឃុំ មានការឆ្លើយតប និងការទទួលខុសត្រូវកាន់តែខ្ពស់ឡើង" ។ ក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត ត្រូវបាន គឃប មើលឃើញថា "ដើរតួនាទីគន្លឹះក្នុងការរក្សាបរិយាកាសបោះឆ្នោតឱ្យមានស្ថិរភាព និងពន្យល់ប្រជាជនពីពីរបបប្រជាធិបតេយ្យ" ។

បុគ្គលិក គឃប មើលឃើញតួនាទីរបស់ពួកខ្លួនក្នុងរយៈពេលឃោសនាបោះឆ្នោតថា មានរួមបញ្ចូលការសង្កេតពិនិត្យលើការឃោសនាបោះឆ្នោត និងសកម្មភាពរបស់គណបក្សនានា ដើម្បីរាយការណ៍ជូន គខប ពីការមិនប្រតិបត្តិតាមបទប្បញ្ញត្តិផ្សេងៗ, និងជួយធ្វើការសំរបសំរួលជាមួយគណបក្សនយោបាយនានា និងពួកអ្នកបោះឆ្នោត ដើម្បីដោះស្រាយទំនាស់ផ្សេងៗ ។ សមាជិកជាបុគ្គលិកម្នាក់និយាយថា ភារកិច្ចទី២ ទាមទារការកសាងទំនុកចិត្តគ្នា រវាង គឃប អាជ្ញាធរមូលដ្ឋាន និងប្រជាជន ។ គាត់លើកឡើងថា:

> *"បើសិនមានអ្វីកើតឡើង យើងត្រូវកោះប្រជុំ ឬដោះស្រាយវាយ៉ាងលឿន ដើម្បីចៀសវាងការប្រមូលគរកំហឹង ឬការមិនយល់គ្នា"*[១០០] ។

ការប្រជុំ គឃប ធ្វើឡើងប្រចាំសប្ដាហ៍ និងមានរួមបញ្ចូលគ្រប់តំណាងគណបក្ស អាជ្ញាធរមូលដ្ឋាន និងប៉ូលីសមូលដ្ឋាន ។ នៅពេលចុះសិក្សាដល់កន្លែង បានសង្កេតមើលការប្រជុំមួយដែលធ្វើឡើងនៅឯវត្តក្នុងមូលដ្ឋាន និងដែលផ្ដោតលើការបញ្ជូនពត៌មានពីនីតិវិធីបោះឆ្នោត ទៅដល់គណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ។ ការប្រជុំទាំងនេះហាក់ដូចបើកចំហសំរាប់គ្រប់ៗគ្នា និងមានប្រធាន គឃប បានអានឡើងនូវបទបញ្ជាផ្សេងៗដែល គខប បញ្ជូនមក ។ តាមការឆ្លើយសំភាសន៍ប្រាប់ការប្រជុំផ្សេងៗទៀតផ្ដោតលើការសំរបសំរួលលើទំនាស់ពាក្យសំដីនានា និងការបែងចែកម៉ោងពេលឃោសនានៅតាមកន្លែងផ្សេងៗក្នុងឃុំទៅឱ្យគណបក្សនានា ។

### *៣.២.៤.៣ ការចុះបញ្ជីអ្នកបោះឆ្នោត*

អត្រាចុះបញ្ជីអ្នកបោះឆ្នោតនៅក្នុងឃុំមានកំរិតខ្ពស់ណាស់ -ជំទប់ទី១ FUNCINPEC អះអាងថា ជិតដល់ ១០០% រីឯមេឃុំប៉ាន់ស្មានថា ប្រហែល ៩០% ។ មានអ្នកបោះឆ្នោតថ្មី ៣០០នាក់ បានមកចុះបញ្ជី ។ ស្មៀនឃុំយល់ថា ការយកចិត្តទុកដាក់នេះ គឺដោយសារសកម្មភាពរបស់គណបក្សធំៗទាំង៣ ដែលលើកទឹកចិត្តសមាជិករបស់គេឱ្យមកចុះបញ្ជី ។ ជំទប់ទី១ មានមតិថា ស្ត្រីក្មេងៗប្រើប្រាស់ប័ណ្ណបោះឆ្នោតដើម្បីសុំការងារធ្វើនៅរោងចក្រកាត់ដេរ ហើយជួនកាលបានមកចុះបញ្ជីដោយសារហេតុផលនេះ ។

### *៣.២.៤.៤ ការឃោសនាបោះឆ្នោត*

ការឃោសនាបោះឆ្នោត ភាគច្រើនគឺជារឿងក្នុងស្រុក ។ ថ្វីបើរូបថតរដ្ឋមន្ត្រី CPP ម្នាក់ មានដាក់តាំងយ៉ាងលេចធ្លោពាសពេញតំបន់នោះក្ដី ក៏គណបក្សធំៗទាំង៣ នៅក្នុងឃុំបាននិយាយថា គ្មានអ្នកនយោបាយថ្នាក់ខ្ពស់មក ធ្វើទស្សនកិច្ចក្នុងឃុំទេនៅពេលបោះឆ្នោត ។ សកម្មជននៅមូលដ្ឋានបានយកកូនសៀវភៅ និងសន្លឹកប័ណ្ណផ្សេងៗពីការិយាល័យគណបក្សថ្នាក់ស្រុកមកចែកចាយក្នុងឃុំ និងបានចាក់ខ្សែអាត់ដែលមានថតសារផ្សេងៗរបស់អ្នកដឹកនាំគណបក្ស ។ គឃប បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការរក្សាគណបក្សនានាឱ្យនៅដាច់ពីគ្នាក្នុងពេលឃោសនាបោះឆ្នោត ទោះបីសមាជិកគណបក្សនានាបានបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់ខ្លួនដើម្បីចៀសវាងទំនាស់ក្ដី ។ ឧទាហរណ៍ អ្នកគ្រប់គ្រងការឃោសនា CPP បានលើកឡើងថា:

---

[១០០] CEC member, Thnaot (40), personal interview, Takeo, 8 July 2003.

*"CPP ដើរតាមគោលនយោបាយរបស់គណបក្ស ក្រមសីលធម៌ និងតាមគោលនយោបាយរបស់រដ្ឋាភិបាល និង ហ៊ុន សែន ។ ហ៊ុន សែន ប្រាប់យើងថា បើយើងជួបពួកគេនៅពេលយើងកំពុងឃោសនា យើងត្រូវដើរតាម ចំហៀងផ្លូវម្ខាងទៀត និងមិនត្រូវបង្កហិង្សាទេ"*[១០១] ។

សកម្មជនអ្នកឃោសនាខាង FUNCINPEC រាយការណ៍ថា ពួកគេខ្លាចការបំភិតបំភ័យក្រោយការបោះឆ្នោត ប៉ុន្តែ "ស្ថានភាពគឺល្អជាងឆ្នាំ១៩៩៨ -នៅឆ្នាំ១៩៩៨ យើងភ័យខ្លាចពីការបែងចែកអំណាច ប៉ុន្តែឥឡូវយើងយល់ច្បាស់ណាស់" ។

ឧបសគ្គចំបងរាយការណ៍ឡើងដោយអ្នកឃោសនា គឺមានភ្លៀងច្រើនធ្វើឱ្យអ្នកភូមិជាប់រវល់ណាស់សឹងពេញៗមួយថ្ងៃ គឺមានតែ "អ្នកក្រីកខ្លាំង" ប៉ុណ្ណោះដែលអាចមកស្តាប់ការឃោសនា ។ ប្រធានភូមិម្នាក់បានឆ្លើយសំភាសន៍ថា ប្រជាជនមិនសូវយកចិត្តទុកដាក់នឹងការឃោសនាទេ ដោយសារហេតុផលប្រហាក់ប្រហែលគ្នា:

*"ប្រជាជនមិននិយាយច្រើនពីរឿងគណបក្សនយោបាយទេ -ពួកគេមិនសូវយកចិត្តទុកដាក់ទេ ។ ពួកគេមិនសូវ យល់ពីរឿងនយោបាយ ហើយពួកគេរវល់ខ្លាំងណាស់"*[១០២] ។

អ្នកឆ្លើយសំភាសន៍ភាគច្រើនរាយការណ៍ពីការកែលំអយ៉ាងច្រើន បើធៀបនឹងឆ្នាំ១៩៩៨ ហើយនិងជោគជ័យនៃការប្រជុំនានាដែលបានធ្វើដើម្បីសំរបសំរួលវិវាទផ្សេងៗ ។

### *៣.២.៤.៥ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងពីការបោះឆ្នោត*

ថ្វីបើប្រធានភូមិទាំងពីរ និងមេឃុំ បានអះអាងថា ការខ្វាយខ្វល់ពីរឿងជីវភាពបានរារាំងអ្នកភូមិក្នុងការចូលរួមឱ្យបានច្រើនៗក្នុងការឃោសនាបោះឆ្នោតក្តី ប៉ុន្តែអ្នកឆ្លើយសំភាសន៍ភាគច្រើនជឿថា នៅឆ្នាំ២00៣ ពត៌មានផ្សេងៗគឺមានច្រើនខ្លាំងណាស់ជាងឆ្នាំ១៩៩៨ ហើយពួកគេអះអាងថា បទពិសោធន៍ពីការបោះឆ្នោតលើកមុនៗ បានជួយប្រជាជនឱ្យយល់ដឹងកាន់តែប្រសើរពីគោលការណ៍ប្រជាធិបតេយ្យ ។ សារពត៌មានពុំមានច្រើនពាសពេញទេ ប៉ុន្តែក្នុងឃុំមានទូរទស្សន៍ជាង ៦0គ្រឿង ហើយមានការឯកភាពជាទូទៅថា ប្រភពពត៌មានដ៏ល្អបំផុតគឺ ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ព្រមទាំងគណបក្សនយោបាយនានា ។NGOs មានធ្វើការអប់រំអ្នកបោះឆ្នោតនៅតំបន់នោះ ប៉ុន្តែ មន្ត្រី គឃប បានស្នើសុំឱ្យមានច្រើនថែមទៀត ។

ថ្វីបើមានពត៌មានច្រើនពាសពេញពីរឿងបោះឆ្នោតក្តី ប៉ុន្តែដូចបានលើកខាងលើ អ្នកឆ្លើយសំភាសន៍មួយចំនួនបានលើកនូវការបារម្ភពីកង្វះការយកចិត្តទុកដាក់ពីសំណាក់គណបក្សនយោបាយចំពោះឃុំនេះ និងកង្វះឱកាសល្អ សំរាប់ឱ្យអ្នកភូមិបញ្ចេញមតិរបស់ខ្លួន ជំរាបដល់ពួកអ្នកតំណាងខាងនយោបាយ ។ មេឃុំក៏លើកដែរថា កង្វះពត៌មានជាក់លាក់អំពីបេក្ខជនតំណាងរាស្ត្រដែលឈរឈ្មោះក្នុងខេត្ត បើធៀបនឹងពត៌មានពីគោលនយោបាយជាទូទៅរបស់គណបក្ស បានបន្ថយបង្អាក់អ្នកបោះឆ្នោតក្នុងការគិតគូរឱ្យបានហ្មត់ចត់ល្អពីរឿងបោះឆ្នោត ។

### *៣.២.៤.៦ ថ្ងៃបោះឆ្នោត និងថ្ងៃក្រោយមកទៀត*

ជាទូទៅការបោះឆ្នោតមានដំណើរការរលូនល្អ ហើយ ៩២% នៃអ្នកបោះឆ្នោតបានចុះបញ្ជី បានមកបោះឆ្នោត ។ គេឃើញមានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិយ៉ាងច្រើននៅតាមការិយាល័យបោះឆ្នោតទាំង៣ ព្រមទាំងតំណាងគណបក្សនានា និងតំណាងរបស់ COMFREL និង NICFEC ។ ឃើញមានទំនាស់ខ្លះៗ រវាងមន្ត្រីការិយាល័យបោះឆ្នោត និងអ្នកសង្កេតការណ៍របស់គណបក្សនយោបាយ នៅពេលដែល គឃប បានសុំឱ្យឆ្មាំសន្តិសុខយកចេញនូវអ្នកសង្កេតការណ៍របស់ SRP ម្នាក់ដែលបានបំពានលើបទប្បញ្ញត្តិ ។ ក្រោយមកទៀត SRP បានតវ៉ាទៅ គឃប ពីរឿងនេះ ។ បញ្ហាផ្សេងទៀតត្រូវបានសង្កេត

---

[១០១] CPP campaign manager, Thnaot (44), personal interview, Takeo, 15 July 2003.

[១០២] Village chief, Thnaot (43), personal interview, Takeo, 15 July 2003.

ឃើញពេលរាប់សន្លឹកឆ្នោតនៅពេលអ្នកសង្កេតការណ៍បំរុងរបស់គណបក្ស បានព្យាយាមចូលក្នុងដែរ ដើម្បីសង្កេតមើលការរាប់ ថ្មីបើតាមគោលការណ៍ពួកនេះត្រូវរង់ចាំនៅខាងក្រៅ ។ បញ្ហាមួយទៀត គឺវត្តមានប្រធានភូមិ និងមេឃុំ ដែលមកឈរនៅ ខាងក្រៅការិយាល័យបោះឆ្នោត ។ ការិយាល័យនេះស្ថិតក្នុងទីតាំងវត្តមួយយ៉ាងធំ ដែលតាមទំលាប់តែងប្រើការជាកន្លែងជួប ជុំគ្នា ។ អ្នកបោះឆ្នោតជាច្រើនក៏ឃើញឈរនៅក្នុងទីតាំងដែរក្រោយពីបានបោះឆ្នោតរួចហើយ ជាពិសេសកម្មករកាត់ដេរដែល ទើបត្រឡប់មកពីភ្នំពេញសំរាប់ថ្ងៃនោះ ហើយឈប់ជជែកគ្នាលេងជាមួយមិត្តភក្តិខ្លួន ។

### *៣.២.៥ ឃុំតាខែន ក្នុងស្រុកឈូក ខេត្តកំពត*

#### *៣.២.៥.១ អាជ្ញាធរឃុំ និងនយោបាយ*

តាខែន ជាឃុំដាច់ស្រយាលមួយក្នុងស្រុកឈូក ។ ឃុំនេះមានភ្នំព័ទ្ធជុំវិញ និងត្រូវជិះឡានប្រហែលមួយម៉ោងចុះពីផ្លូវ ជាតិ ។ ឃុំតាខែនមាន ១២ភូមិស្ថិតនៅរាយប៉ាយឆ្ងាយពីគ្នា និងខ្សត់ផ្លូវទាក់ទងគ្នា ដោយភូមិខ្លះអាចទៅដល់តែតាមម៉ូតូ និងខ្លះ ទៀតត្រូវកាត់ផ្តាច់ទាំងស្រុងនៅរដូវភ្លៀង ។ ដង់ស៊ីតេប្រជាជនក្នុងឃុំ មានតិចជាង ០,៣នាក់/ហិកតា ធៀបនឹង ៤,៧នាក់/ ហិកតានៅឃុំត្នោត ។ បទសំភាសន៍ជាមួយមន្ត្រីមូលដ្ឋាន សកម្មជនគណបក្ស និងពួកអ្នកភូមិបង្ហាញថា ប្រជាជនមានចំរុះដោយ អតីតទាហានរបស់ NADK ដែលមកតាំងលំនៅក្នុងតំបន់នេះក្នុងចន្លោះឆ្នាំ១៩៧០-១៩៩៨ និងជនស៊ីវិលដែលរស់នៅទីនេះតាំង ពីដូនពីតាមក ។ អ្នកឆ្លើយសំភាសន៍រាយការណ៍ពីភាពតានតឹងរវាងក្រុមទាំងនេះ ពិសេសទាក់ទិននឹងកម្មសិទ្ធិដីធ្លី ។ សកម្មភាព សេដ្ឋកិច្ចរួមមាន ការប្រមូលផលិតផលព្រៃឈើ និងការដាំស្រូវ និងដំណាំលក់យកប្រាក់ ។ ស្ថានភាពដាច់ស្រយាល ធ្វើឱ្យទំនាក់ ទំនងមានតិចតួច ជាមួយពិភពខាងក្រៅ ។ ឃុំនេះមានអត្រាអនក្ខរកម្មប្រហែល ៧០% តាមការប៉ាន់ស្មានរបស់មេឃុំ, មាន គំរោងអភិវឌ្ឍន៍តិចតួចដែលកំពុងដំណើរការ ហើយអ្នកភូមិឆ្លើយសំភាសន៍បានរាយការណ៍ថា មានកុមារតិចតួចណាស់បានទៅ សាលារៀន ។ មន្ត្រីឃុំលើកឡើងថា ប្រជាជនពីមុនមួយចំនួនបានចាកចេញពីឃុំនៅពេលធ្វើសមាហរណកម្មឡើងវិញ ដើម្បីទៅ រកការងារធ្វើនៅទីក្រុង ។

ក្រុមប្រឹក្សាឃុំមានសមាជិក ៧នាក់ ក្នុងនេះ ខាង CPP មាន ៦នាក់ ។ សមាជិកជា CPP បានបង្ហាញខ្លួនឯងថា ជា អតីតអ្នកតស៊ូនៃ NADK ក្នុងតំបន់ តា ម៉ុក ដែលបានត្រួតត្រាលើឃុំនេះអស់ជាច្រើនឆ្នាំ ។ នៅពេលពួកគេចុះចូលរដ្ឋាភិបាល ក្នុងឆ្នាំ១៩៩៧ ពួកគេត្រូវបានរក្សាទុកនៅនឹងកន្លែងក្នុងឋានៈជាមន្ត្រីឃុំ ហើយបន្ទាប់មកបានជាប់ឆ្នោតចូលក្រុមប្រឹក្សាឃុំនៅ ឆ្នាំ២០០២ ។ មេឃុំបានរៀបរាប់ពីលក្ខខណ្ឌចុះចូលដូចតទៅ:

> *"នៅពេលចុះចូល យើងចូល CPP ។ CPP បានផ្តល់ឱ្យយើងនូវដីធ្លី និងអ្វីៗទាំងអស់សំរាប់រស់-បៀវត្សរ៍ និង អ្វីៗទៀត ។ យើងមានឯករាជ្យ-យើងរកចិញ្ចឹមជីវិតដោយខ្លួនឯង ។ ដូច្នេះភាគច្រើនចូល CPP ដើម្បីដោះ ស្រាយជីវភាព និងទ្រទ្រង់ជីវភាពកូនចៅ ។ ដីខ្មែរក្រហមដែលយើងត្រួតត្រាត្រូវបានចែកចាយ ដូច្នេះ សព្វថ្ងៃ យើងបានរក្សាទុកដីទាំងនោះ"[១០៣] ។*

ទំនាក់ទំនងកសាងបានតាំងពីពេលធ្វើសមាហរណកម្ម រវាងអាជ្ញាធរឃុំតាខែន និង CPP ហាក់ដូចជិតស្និទ្ធល្អ ។ តាម តំណាង COMFREL នៅខេត្តកំពត នាយករដ្ឋមន្ត្រី ហ៊ុន សែន "មានទំនាក់ទំនងរឹងប៉ឹងជាមួយតំបន់នេះ" និងបានជួយឧបត្ថម្ភ កម្មវិធីកសាងផ្លូវនៅទីនោះ ។

តាំងពីការធ្វើសមាហរណកម្ម ពួកអតីតមេបញ្ជាការ NADK បានបន្តគ្រប់សង្កត់លើនយោបាយឃុំដោយទទួលបាន ៧១% នៃសន្លឹកឆ្នោតសំរាប់មុខតំណែងក្នុងក្រុមប្រឹក្សាឃុំនៅក្នុងឆ្នាំ២០០២, ធៀបនឹង ១៨% ខាង FUNCINPEC, និង ១១% ខាង

---

[១០៣] Commune Chief, Ta Khaen (45), personal interview, Kampot, 7 July 2003.

SRP ។ ក្នុងការបោះឆ្នោតឆ្នាំ២០០៣ គំលាតរវាង CPP (៦៧%) និង FUNCINPEC (២៤%) ថយចុះបន្តិច, ឯ SRP បាត់បង់ការគាំទ្រដោយទទួលបានតែ ៩% ។

**ប្រវត្តិនៃការបោះឆ្នោត: ឃុំតាខែន**

| | |
|---|---|
| 1998 | គ្មានការបោះឆ្នោត |
| 2002 | 1st CPP, 2nd FUNCINPEC, 3rd SRP |
| 2003 | 1st CPP, 2nd FUNCINPEC, 3rd SRP |

ថ្វីបើ CPP គ្របសង្កត់លើលទ្ធផលបោះឆ្នោតក្តី ប៉ុន្តែតំណាង FUNCINPEC និង SRP មានសកម្មភាពច្រើននៅក្នុងឃុំ ។ សមាជិក FUNCINPEC តែម្នាក់ក្នុងក្រុមប្រឹក្សាឃុំ ជាអ្នកទើបមកដល់ថ្មីក្នុងឃុំ ហើយគាត់និយាយថា បានត្រឡប់មកវិញក្រោយ ពេលធ្វើសមាហរណកម្មនៅឆ្នាំ១៩៩៦ ដើម្បីទាមទារយកដីក្រុមគ្រួសារគាត់វិញ ។ គាត់ប្រាប់ទៀតថា សមាជិកក្រុមប្រឹក្សាឃុំ ឯទៀតគាបសង្កត់គាត់ឱ្យចូល CPP -ជាពិសេសគាត់អះអាងថា អាជ្ញាធរឃុំមិនព្រមទទួលស្គាល់ការទាមទារដីរបស់គាត់ទេ លើកលែងតែគាត់ផ្លាស់ប្តូរគណបក្ស ។ គាត់ពន្យល់សភាពការណ៍ថា:

> *"បើខ្ញុំទៅចូល CPP គេនឹងទទួលស្គាល់ការទាមទារដីរបស់ខ្ញុំ ។ បើសិនខ្ញុំនៅក្នុង FUNCINPEC ពួកគេមិនព្រមទទួលស្គាល់ទេ ។ ពួកគេមិនបានដកហូតដីនោះទេ -គ្មានអ្នកណាអាចទាមទារសិទ្ធិកាន់កាប់ដីបានទេ បើនៅមានទំនាស់ គឺត្រូវចាំរហូតដល់ពេលដោះស្រាយទំនាស់បាន ។ ហើយខ្ញុំមិនបណ្តោយឱ្យគេយកដីខ្ញុំទេ ។ ពីមុនមានអ្នកគាំទ្រ FUNCINPEC ម្នាក់ទៀតនៅទីនេះ ប៉ុន្តែពួកគេបានបញ្ចុះបញ្ចូលគាត់ឱ្យចូល CPP ។ ពួកគេចង់ឱ្យដីខ្ញុំពាក់កណ្តាលទៅអ្នកនោះ ។ ខ្ញុំគ្មានផែនទីព្រំដីពិតប្រាកដទេ ដូច្នេះពួកគេចង់កាត់យកដីខ្ញុំពាក់កណ្តាល"*[១០៤] ។

SRPក៏មានកន្លែងឈរជើងក្នុងឃុំដែរ ប៉ុន្តែប្រវត្តិការងាររបស់ពួកគេមានជួបឧបសគ្គ ។ នៅឆ្នាំ២០០២ SRP បានព្យាយាមលើកផ្លាកគណបក្ស ប៉ុន្តែផ្លាកនេះមានគេទំលាក់ចុះវិញ និងមានការតវ៉ាជាច្រើនពីការបំភិតបំភ័យចំពោះសមាជិក SRP ។ សកម្មជន SRP ម្នាក់ដែលឈានមុខនៅឆ្នាំ២០០២ បានលាឈប់ពីនយោបាយនៅឆ្នាំ២០០៣ ហើយសហសេវិកនានារបស់គាត់នៅក្នុង SRP បានអះអាងថា គឺដោយសារគាត់ភ័យខ្លាច ។ ប៉ុន្តែប្រធានភូមិនិយាយថា ការលាឈប់របស់សកម្មជន SRP គឺដោយសារការលំបាកខាងហិរញ្ញវត្ថុនៅក្រោយពេលបោះឆ្នោត: "គាត់បានឈរឈ្មោះក្នុងការបោះឆ្នោតឃុំ ហើយគាត់បានចាញ់គេ, បន្ទាប់មកគាត់ក៏លក់គោញី និងគោឈ្មោលរបស់គាត់ដើម្បីសងបំណុល, ហេតុដូច្នេះគាត់ក៏បានលាឈប់"[១០៥] ។ មេឃុំលើកឡើងថា ការតវ៉ាពីសំណាក់ SRP ក្នុងរឿងផ្លាកសញ្ញានៅឆ្នាំ២០០២ គឺជាការយល់ច្រឡំ -ផ្លាកនោះធ្លាក់ចុះខ្លួនឯងក្នុងពេលមានខ្យល់ខ្លាំងមួយ ។ គាត់និយាយថា:

> *"ពីដំបូងមានបញ្ហាទាក់ទិននឹងការលើកផ្លាក ។SRP បានលើកផ្លាកមួយ ហើយវាធ្លាក់ចុះវិញ, ដូច្នេះហើយពួកគេក៏ខឹង ហើយស្នើឱ្យយើងការពារពួកគេ ។ ពួកគេសុំឱ្យ-ប៉ូលីសការពារពួកគេ ។ ប៉ុន្តែយើងបានដោះស្រាយបញ្ហានេះជាមួយគ្នាទាំងអស់ ហើយតាំងពីនោះមកគ្មានបញ្ហាអ្វីទេ ។ ពួកគេបានលើកផ្លាក ហើយយើងទាំងអស់គ្នាគោរពច្បាប់"*[១០៦] ។

---

[១០៤] FUNCINPEC commune councillor, Ta Khaen (46), personal interview, Kampot, 18 July 2003.

[១០៥] Village chief, Ta Khaen Commune (47), personal interview, Kampot, 17 July 2003.

[១០៦] Commune chief, Ta Khaen Commune (45), personal interview, Kampot, 7 July 2003.

ក្រុមស្រាវជ្រាវមិនអាចរកឃើញបេក្ខជនឈរឈ្មោះបោះឆ្នោតឃុំឆ្នាំ២០០២ ដើម្បីធ្វើសំភាសន៏ទេ ។ គខប, COMFREL និង SRP នៅទីរួមខេត្តកំពត មិនយល់ស្របតាមការរៀបរាប់របស់មេឃុំនេះទេ ហើយពួកគេនិយាយថា នៅឃុំតាខែនមានទំនាស់ និងការបំភិតបំភ័យជាច្រើនចំពោះគណបក្សនយោបាយនានាក្រៅពី CPP ក្នុងពេលបោះឆ្នោតឆ្នាំ២០០២ ។ តាមពត៌មានពី UN ក្នុងចំណោម ១៧ករណីគំរាមកំហែង វុកគួន និងបំភិតបំភ័យ ដែលត្រូវបានរាយការណ៏ឡើងពីខែមិថុនា ដល់តុលា ២០០១ នៅខេត្តកំពត មាន ១២ករណីបានកើតមានឡើងនៅតំបន់ តាខែនកោះស្លា ។ ប្រធាន គខប ខេត្តកំពត ប្រាប់យើង ថា គណៈប្រតិភូ គខប ទៅតំបន់នោះ ត្រូវបានមេឃុំចាប់ខ្លួនមួយរយៈពេលខ្លី ហើយក្រោយមកទៀតពួកគេទៅកាន់តំបន់នោះ តែជាមួយអ្នកសង្កេតការណ៏អន្តរជាតិប៉ុណ្ណោះ ។ ដើម្បីឆ្លើយតបនឹងការបារម្ភទាំងនេះ លោក Peter Leuprecht ជាតំណាង ពិសេសខាងសិទ្ធិមនុស្ស បានធ្វើទស្សនកិច្ចនៅឃុំតាខែន នៅខែវិច្ឆិកា ២០០១ និងបានពិភាក្សាពីបញ្ហាសិទ្ធិមនុស្សជាមួយមន្ត្រីឃុំ និងស្រុក ។ អ្នកតំណាងនេះនិយាយថា នៅក្រោយទស្សនកិច្ចរបស់គាត់ ការតវ៉ាចេញពីតំបន់នោះបានថយចុះក្នុងរយៈពេលនៃ ការបោះឆ្នោត ។

តំណាង COMFREL នៅទីរួមខេត្តកំពត បានបញ្ជាក់ថា សំរាប់ NGOs តាខែនក៏ជាកន្លែងពិបាកមួយដែរ ។ គាត់លើកឡើងថា COMFREL បានអញ្ជើញអង្គការអន្តរជាតិនានាឱ្យទៅជាមួយពួកអ្នកឃ្លាំមើលរបស់ COMFREL ដើម្បីស៊ើបអង្កេតពីរឿងផ្សេងៗនៅតាខែន ។ តាមពត៌មានពី COMFREL បីខែមុនពេលចាប់ផ្តើមការឃោសនាបោះឆ្នោតឆ្នាំ២០០៣ អាជ្ញាធរឃុំបានប្រមូលប័ណ្ណបោះឆ្នោតទាំងអស់ ។ COMFREL បានសុំឱ្យអង្គការអន្តរជាតិនានាជួយអន្តរាគមន៏ ហើយក្រោយមកគេក៏ប្រគល់ប័ណ្ណបោះឆ្នោតទៅឱ្យពួកអ្នកភូមិវិញ ។ តំណាង COMFREL លើកឡើងថាៈ

> *"នៅពេលដកប័ណ្ណបោះឆ្នោត ពួកគេប្រាប់ប្រជាជនថា យកទៅចុះឈ្មោះ ។ យើងបានសុំឱ្យអ្នកសង្កេតការណ៏អន្តរជាតិទៅ -ពួកគេជួបជាមួយអាជ្ញាធរមូលដ្ឋាន ហើយស្នើឱ្យប្រគល់ប័ណ្ណត្រឡប់ទៅវិញ ។ គាត់ថា គាត់ត្រូវការប័ណ្ណដើម្បីប្រាប់ប្រជាជនថា ទៅបោះឆ្នោតនៅឯណា ប៉ុន្តែយើងខ្លាចគាត់ប្រាប់ប្រជាជនថា "មកទីនេះ និងបោះ ឆ្នោតឱ្យយើង"[១០៧] ។*

សកម្មជន SRP និង FUNCINPEC ដែលបានឆ្លើយសំភាសន៏នៅតាខែន នៅខែកក្កដា ២០០៣ បានឯកភាពថា អាជ្ញាធរភូមិ និងឃុំ បានបំភិតបំភ័យអ្នកភូមិដើម្បីរារាំងប្រជាជនកុំឱ្យទៅចូលរួមជាមួយគណបក្សទាំងពីរ ប៉ុន្តែ អ្នកទាំងនេះនិយាយថា ក្នុងឋានៈជាសកម្មជនរបស់គណបក្សនយោបាយពួកខ្លួនពុំមានអារម្មណ៏ថា បានទទួលការគំរាមកំហែងទេ ។ ពួកគេពន្យល់ពីទំនុកចិត្តខ្ពស់នេះថាៈ

> *"ប្រជាជនភ័យខ្លាច ព្រោះមិនយល់ពីច្បាប់ ។ យើងមិនខ្លាច ពីព្រោះយើងយល់ច្បាប់ ។ ប្រជាជនមិនយល់ច្បាប់ ពីព្រោះពួកគេរស់នៅក្រោមអំណាចមួយដែលលំអៀងទៅគណបក្សមួយ ។ ពួកគេមិនហ៊ានតវ៉ាទេ ។ ប៉ុន្តែ ច្បាប់អាចការពារពួកគេបាន ។ យើងជាប្រជាពលរដ្ឋខ្មែរ ដូច្នេះគ្មានអ្នកណាអាចដេញយើងចេញពីទីនេះបានទេ"[១០៨] ។*

សកម្មជន FUNCINPEC ម្នាក់បន្ថែមថា "គឃប អាចការពារយើង, ប៉ូលីសអាចការពារយើង, គ្មានបញ្ហាអ្វីទេ" ។ ទំនុកចិត្តនេះអាចមើលឃើញច្បាស់តាមការដែលយើងសង្កេតឃើញ ពួកអ្នកឃោសនាខាង FUNCINPEC ដើរពីផ្ទះមួយទៅផ្ទះមួយ ដោយពាក់អាវយឺត និងមួករបស់គណបក្ស និងចែកចាយសន្លឹកប័ណ្ណ ប៉ុន្តែក៏អាចថាវត្តមានរបស់យើងបានបំផុសសកម្មភាពនេះ

[១០៧] COMFREL provincial representative, Kampot (6), personal interview, Kampot, 16 July 2003.

[១០៨] SRP activist, Ta Khaen (48), group interview, Kampot, 17 July 2003.

ឡើង ។ ដូចគ្នាដែរ អ្នកទៅចូលរួមការប្រជុំ គឃប បានពាក់ខោអាវឃោសនា និងបង្ហាញច្បាស់ថា ពួកគេស្ម័គ្រចិត្តធ្វើដំណើរពាសពេញឃុំ ទាំងអាចមើលស្គាល់យ៉ាងច្បាស់ថា ជាអ្នកគាំទ្រ SRP និង FUNCINPEC ។ ទំនុកចិត្តលើកំលាំងការពារនៃច្បាប់នៅក្នុងតំបន់ឆ្ងាយដាច់ស្រយាលបែបនេះ ប្រហែលជាលទ្ធផលនៃការខិតខំរបស់អ្នកសង្កេតការណ៍ និងអាជ្ញាធរបោះឆ្នោត ក្នុងការតំរែតំរង់ឡើងវិញនូវតំរិយាបថនៃអាជ្ញាធរមូលដ្ឋាននៅតាខែន បន្ទាប់ពីមានអំពើហិង្សា និងការបំភិតបំភ័យអស់មួយរយៈមុនការបោះឆ្នោតឆ្នាំ១៩៩៣ ។

មេឃុំតាខែន បានសង្កត់ធ្ងន់ពីរឿងនេះដែរ ដោយលើកឡើងថាៈ

*"ពីដំបូងមានបញ្ហាខ្លះ ប៉ុន្តែឥឡូវគ្មានបញ្ហាអ្វីទេសំរាប់គណបក្សនានាដែលនៅទីនេះ ។ យើងគោរពច្បាប់... ខ្ញុំបានជួបប្រធានភូមិ ហើយប្រាប់ពួកគេឱ្យការពារប្រឆាំងនឹងការបំភិតបំភ័យក្នុងនាមរបស់គណបក្ស និងអ្វីៗទៀត ។ យើងមិនចង់មានវាក្នុងតំបន់យើងទេ... នេះជាសិទ្ធិរបស់ប្រជាជន... យើងដឹកនាំប្រជាជនឱ្យបានយល់ ។ ប្រជាជននៅទីនេះគោរពច្បាប់ -មិនមែនត្រឹមតែបុគ្គលទេ ប៉ុន្តែច្បាប់"*[១០៩] ។

នៅក្រោយថ្ងៃបោះឆ្នោត មេឃុំបញ្ជាក់ចំណុចនេះម្តងទៀត "យើងទាំងអស់គ្នាដឹងពីសិទ្ធិរបស់ពួកគេ ហើយមិនហ៊ានធ្វើអ្វីទេ ។ យើងខ្លាចពួកគេប្តឹងតវ៉ាពីយើង ។ យើងចេះច្បាប់ ហើយយើងខ្លាចច្បាប់" ។

ប្រធានភូមិម្នាក់ក៏បានឆ្លើយសំភាសន៍សង្កត់ធ្ងន់ពីសារៈសំខាន់នៃការគោរពតាមច្បាប់ និងបទប្បញ្ញត្តិបោះឆ្នោតដែរ ។ គាត់លើកឡើងថា "គ្មានការបំភិតបំភ័យទៅខាងជំទាស់ទេ -យើងគិតថា យើងទាំងអស់គ្នានៅក្នុងឃុំតែមួយ ហើយយើងមានមេឃុំម្នាក់ល្អណាស់ ដូច្នេះយើងមិនត្រូវការការបំភិតបំភ័យទេ ។ ជាពិសេសពួកអ្នកដឹកនាំក្នុងមូលដ្ឋានយើង ចាស់ចិត្តចាស់គំនិតល្អណាស់ក្នុងការងារដឹកនាំ ពីព្រោះពួកគេធ្លាប់ធ្វើប្រធានសំរាប់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣"[១១០] ។

ការឆ្លើយសំភាសន៍របស់អ្នកភូមិតាខែន បង្ហាញច្បាស់ថា ការគាំទ្រគណបក្សនយោបាយដោយចំហត្រូវគេចាត់ទុកថាអាចមានគ្រោះថ្នាក់ ។ បុរសចំណាស់ម្នាក់ក្រោយបានងាកមើលក្រោយដើម្បីផ្ទៀងផ្ទាត់ថា គ្មានអ្នកណាស្តាប់ឮទេ បានខ្សឹបថាៈ

*"ខ្ញុំស្រឡាញ់ព្រះមហាក្សត្រ ។ ខ្ញុំបាននិយាយជាមួយកូនចៅខ្ញុំពីរឿងនយោបាយ ។ ខ្ញុំប្រាប់ពួកគេថា រូបខ្ញុំ ឪពុកខ្ញុំ និងជួនតាខ្ញុំទាំងអស់ ដើរតាមព្រះមហាក្សត្រ ។ ប៉ុន្តែគឺស្រេចតែពួកគេ បើពួកគេចង់ដើរតាមព្រះមហាក្សត្រ ឬចង់ដើរតាមអ្នកដែលមកធ្វើផ្លូវ និងសាលារៀន... ខ្ញុំគាំទ្រ FUNCINPEC ប៉ុន្តែខ្ញុំមិនហ៊ានជជែករឿងនេះជាមួយអ្នកណាទេ ក្រៅពីកូនចៅខ្ញុំ"*[១១១] ។

### *៣.២.៥.២ ស្ថាប័នបោះឆ្នោត*

គឃប នៅតាខែន មានសមាជិក ៥នាក់ ហើយទាំងអស់គ្នាធ្លាប់ធ្វើជា សមាជិក គឃប នៅឆ្នាំ២០០២ និងមកពីឃុំមួយជិតនោះនៅកោះស្លា ។ អ្នកឆ្លើយសំភាសន៍ប្រាប់ថា ការជ្រើសយកសមាជិក គឃប មកពីក្រៅឃុំ គឺដោយសារនៅតាខែនមានប្រជាជនតិចពេកដែលមានសមត្ថភាពអាចទទួលការងារនេះបាន ។ ផលប៉ះពាល់នៃការយកសមាជិក គឃប ពីក្រៅឃុំដូច្នេះគេមិនដឹងច្បាស់ទេ -រឿងនេះហាក់ដូចផ្តល់ការធានាល្អចំពោះអព្យាក្រឹតភាព និងឯករាជ្យនៃ គឃប ឯឃុំជិតនោះក៏ជាចំណែកមួយនៃតំបន់ធ្វើសមាហរណកម្មកោះស្លាដែរ ហើយត្រូវបានគ្រប់គ្រងជាអង្គភាពតែមួយកាលពីសម័យតស៊ូ ។ ទំនាក់ទំនងខាងនយោបាយរវាងឃុំទាំងពីរនៅរឹងប៉ឹងល្អ ។ ប្រធានភូមិម្នាក់បានលើកឡើងថាៈ "ថ្វីបើយើងមានសមាជិក គឃប មកពីឃុំមួយ

[១០៩] Commune chief, Ta Khaen (45), personal interview, Kampot, 7 July 2003.

[១១០] Village chief, Ta Khaen (47), personal interview, Kampot, 17 July 2003.

[១១១] Villager, Ta Khaen (49), personal communication, Kampot, 17 July 2003.

ទៀតក្តី ប៉ុន្តែយើងស្គាល់គ្នាល្អណាស់" ។

ប្រធាន គជប នៅតាខែន មិនសូវបារម្ភដូចប្រធាន គឃប ដែលឆ្លើយសំភាសន៍នៅខេត្តផ្សេងៗទៀតទេ ក្នុងការគូសបញ្ជាក់ថា គាត់ឯករាជ្យចេញពីអាជ្ញាធរមូលដ្ឋាន ។ ប៉ុន្តែគាត់បានគូសបញ្ជាក់ពីសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ. ឧទាហរណ៍ "ក្រុមប្រឹក្សាឃុំធ្វើការជាមួយយើងដើម្បីរៀបចំការបោះឆ្នោត ដូច្នេះគ្មានបញ្ហាអ្វីទេ" ។ គាត់លើកឡើងទៀតថា មេឃុំបានរង់ចាំនៅខាងក្រៅការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ប៉ុន្តែគាត់មិនចាត់ទុករឿងនេះជាបញ្ហាលំបាកមួយទេ:

*"គ្មានបញ្ហាអ្វីជាមួយអាជ្ញាធរមូលដ្ឋានទេ ក្រោយការបោះឆ្នោត ។ ពួកគេទៅអង្គុយខាងក្រៅជាមួយឆ្មាំសន្តិសុខ -ពួកគេមិននៅខាងក្នុងទេ"[១១២] ។*

មេឃុំមិនឯកភាពតាមការរៀបរាប់ខាងលើទេ ដោយគាត់និយាយថា "ខ្ញុំទៅបោះឆ្នោត, ប៉ុន្តែខ្ញុំមិនបានរង់ចាំនៅខាងក្រៅទេ ។ ខ្ញុំបានទៅហៅអ្នកមិនទាន់បោះឆ្នោតឱ្យមកបោះឆ្នោត"[១១៣] ។

បញ្ហាចំបងដែល គឃប នៅតាខែនត្រូវប្រឈមមុខ គឺទំហំឃុំ និងការពិបាកធ្វើដំណើរចុះឡើងក្នុងឃុំ ។ គឃប ប្រាប់ថា រឿងនេះបានបង្កបញ្ហាក្នុងពេលចុះបញ្ជី ។ម្យ៉ាងទៀតប្រហែលមានបញ្ហាក្នុងការប្រាស្រ័យទាក់ទង រវាង គឃប និង SRP និង FUNCINPEC -នៅពេលក្រុមស្រាវជ្រាវទៅពិនិត្យមើលការប្រជុំប្រចាំសប្តាហ៍របស់ គឃប, យើងបានឃើញការប្រជុំត្រូវលុបចោលវិញ ដោយសារការកោះហៅសមាជិក គឃប ឱ្យទៅប្រជុំនៅឈូក ។ តំណាង CPP សំរាប់ការប្រជុំ ហាក់បានទទួលពតិមានយ៉ាងច្បាស់ពីរឿងនេះ ប៉ុន្តែសមាជិក SRP និង FUNCINPEC មិនបានដឹងទេ ហើយអង្គុយចាំធ្វើការតវ៉ា ។

សកម្មជន SRP បានឆ្លើយសំភាសន៍បញ្ជាក់ពីទំនុកចិត្តលើតួនាទី គឃប ក្នុងការសំរបសំរួលទំនាក់ទំនងរវាងគណបក្សនានា ។ សកម្មជនម្នាក់លើកឡើងថា:

*"បើសិនមានបញ្ហាអ្វីមួយ យើងនឹងតវ៉ាទៅ គឃប ។ កាលមុនយើងតវ៉ាទៅ គឃប ពីរឿង CPP ចែកក្រមា និង ពីរឿងពួកប្រធានភូមិ ។ នៅមុនពេលឃោសនាបោះឆ្នោតនៅថ្ងៃទី២៦ មិថុនា គឺមានការអនុញ្ញាតឱ្យពួកគេចែកអំណោយ ។ ពួកប្រធានភូមិបានចែកអំណោយ -ពួកគេជួយ CPP ។ ពួកប្រធានភូមិគឺជាប្រធាននៃការឃោសនា -ពួកគេមិនអនុញ្ញាតអ្វីឱ្យ FUNCINPEC និង SRP ទេ ។ ខ្ញុំពេញចិត្តនឹងការឆ្លើយតបរបស់ គឃប"[១១៤] ។*

នៅពេលលុបការប្រជុំខាងលើ សកម្មជន FUNCINPEC ម្នាក់បានបង្ហាញក្រុមស្រាវជ្រាវនូវលិខិតតវ៉ាមួយ ដែលគេគ្រោងដាក់ជូន គឃប ស្តីពីការបំភិតបំភ័យប្រឆាំងនឹងសមាជិក FUNCINPEC នានា ដោយប្រធានភូមិនៅភូមិតំណាក់ត្រយឹង ។ តាមសំដីសកម្មជន FUNCINPEC នេះ មានការប្រាប់ដល់ប្រជាជនថា ពួកគេអាចបាត់បង់ដី បើសិនត្រូវគេមើលឃើញច្បាស់ថាបានចូល FUNCINPEC ។ ដូចនៅឃុំត្នោតដែរ មានការចោទថា អាជ្ញាធរភូមិ បានសាកសួរអ្នកគាំទ្រ FUNCINPEC ថា "បើសិនអ្នកចាញ់ តើអ្នកនឹងរស់នៅយ៉ាងណាក្នុងភូមិនេះ?"។ សកម្មជនបានលើកទៀតថា រឿងនេះធ្វើឱ្យពួកអ្នកគាំទ្រ FUNCINPEC ភ័យខ្លាច និងមិនចង់ធ្វើសកម្មភាពឃោសនាសំរាប់គណបក្ស[១១៥] ។ ប៉ុន្តែប្រធាន គឃប បានឆ្លើយសំភាសន៍នៅក្រោយពេលបោះឆ្នោតប្រាប់ថា គាត់មិនបានទទួលការតវ៉ាអ្វីពីការបំភិតបំភ័យទេ ។ សកម្មជន FUNCINPEC ខាងលើ យើងមិនអាចរកឃើញទេដល់ក្រោយមកទៀត ដូច្នេះក្រុមស្រាវជ្រាវមិនអាចផ្ទៀងផ្ទាត់បានថាតើគាត់បានដាក់ពាក្យតវ៉ាឬទេ ។

---

[១១២] CEC chief, Ta Khaen (50), personal interview, Kampot, 1 Aug. 2003.

[១១៣] Commune chief, Ta Khaen (45), personal interview, Kampot, 1 August 2003.

[១១៤] SRP activist, Ta Khaen (48), group interview, Kampot, 17 July 2003.

### *៣.២.៥.៣ ការចុះបញ្ជីអ្នកបោះឆ្នោត*

អាជ្ញាធរមូលដ្ឋានបានគូសបញ្ជាក់ថា គ្មានបញ្ហាអ្វីក្នុងពេលចុះបញ្ជីទេ ។ ប្រធានភូមិម្នាក់និយាយថា:

*"ការចុះបញ្ជីធ្វើបាន ១00% សំរាប់ភូមិខ្ញុំ និងឃុំខ្ញុំ ។ លទ្ធផលនេះមួយចំណែក គឺដោយសារប្រជាជនទីនេះមិនចេញទៅក្រៅដើម្បីធ្វើការទេ ។ ពួកគេជាអ្នកបរបាញ់ និងបេះប្រមូលផលក្នុងតំបន់នេះ ។ ហើយអាជ្ញាធរមូលដ្ឋានទាំងអស់លើក ទឹកចិត្តប្រជាជនឱ្យបោះឆ្នោត"*[១១៦] ។

ប្រធាន គឃប ប្រាប់ថា ការចុះបញ្ជីបានជួបការលំបាកខ្លះដូចជា ការលំបាកខាងបច្ចេកទេសក្នុងការថតរូប ។ គាត់បន្ថែមថា "ការចុះបញ្ជីប្រជាជនពិបាកខ្លាំង ពីព្រោះពួកគេរស់នៅឆ្ងាយណាស់និងរវល់ធ្វើការងារ ។ ប្រជាជនគឺ ពិបាកនឹងបានជួបដើម្បីថតរូបពួកគេ ។ល។ ប៉ុន្តែអ្នកមិនបានចុះបញ្ជីមានតិចតួចណាស់" ។ សកម្មជន SRP នៅក្នុងមូលដ្ឋានមិនយល់ស្របតាមការរៀបរាប់នេះទេដោយសារពួកគេបានលើកឡើងថា "នៅពេលចុះបញ្ជីបោះឆ្នោត ប្រជាជនមិនហ៊ានបង្ហាញមុខទេ បើសិនជាពួកគេ SRP"[១១៧] ។

### *៣.២.៥.៤ ការឃោសនាបោះឆ្នោត*

តាមសំដីប្រធាន គឃប, គណបក្សធំៗទាំង៣ បានធ្វើការឃោសនាក្នុងខេត្ត ។ FUNCINPEC បានធ្វើការដង្ហែក្បួន ៣លើក ដោយមានការជួយទ្រទ្រង់ពីការិយាល័យគណបក្ស FUNCINPEC នៅទីរួមស្រុកឈូក ។ អ្នកឃោសនាខាង CPP មកពីការិយាល័យស្រុក ក៏បានមកជួយឃោសនាដែរ ។ មន្ត្រី គឃប និយាយថា "ខាង SRP ធ្វើការឃោសនាទេ ១ថ្ងៃទេ ពីព្រោះគ្មានប្រាក់... និងគ្មានអ្នកពីខាងក្រៅមកជួយ SRP ទេ"[១១៨] ។

ពួកសកម្មជន SRP ខ្លួនឯងបានបញ្ជាក់គាំទ្រការរៀបរាប់ខាងលើ ដោយប្រាប់ថា "ថ្នាក់លើរបស់គណបក្សមិនបានជួយឃោសនាទេ ពីព្រោះយើងមិនមែនជាឃុំធំ ។ ពួកគេមិនបានមកជួយយើងទេ... យើងពុំមានធនធានច្រើនទេ" ។ ប៉ុន្តែតាមមតិពួកសកម្មជន SRP ឧបសគ្គចំបងបំផុតចំពោះការឃោសនាគឺ ការភ័យខ្លាចរបស់អ្នកភូមិក្នុងមូលដ្ឋាន: "អ្នកភូមិជាច្រើនគាំទ្រយើង ប៉ុន្តែពួកគេភ័យខ្លាច ។ ពួកគេមិនហ៊ានគាំទ្រដោយចំហទេ ។ ពួកគេហ៊ានបោះឆ្នោតឱ្យ SRP ប៉ុន្តែមិនហ៊ានគាំទ្រដោយចំហទេ ។ ពួកគេមិនហ៊ានពិភាក្សាពីគោលនយោបាយរបស់ SRP ទេ" ។ SRP ក៏បានខិតខំរៀបចំឱ្យអ្នកភូមិចូលរួមក្នុងការដង្ហែរក្បួននៅកំពតស្រុក, ប៉ុន្តែពួកសកម្មជននិយាយថា អ្នកភូមិរវល់ខ្លាំងពេក និងក្រីក្រពេកមិនអាចទៅបានទេ ។ ពួកសកម្មជនបន្ថែមថា "ពួកគេមិនខ្លាចនឹងទៅទេ ប៉ុន្តែពួកគេខ្លាចដល់ពេលត្រឡប់មកវិញអាចមានបញ្ហា"[១១៩] ។

អ្នកឆ្លើយសំភាសន៍បានលើកមតិផ្សេងៗថា លក្ខណៈឆ្ងាយដាច់ស្រយាលនៃឃុំ ក៏បានប៉ះពាល់ដល់ចំណាប់អារម្មណ៍ជាទូទៅពីការបោះឆ្នោតដែរ ។ នៅឃុំឆ្នោត ពួកសកម្មជនគណបក្សលើកមតិថា កង្វះការយកចិត្តទុកដាក់ពីសំណាក់អ្នកនយោបាយថ្នាក់ខ្ពស់ៗចំពោះឃុំ បានធ្វើឱ្យអ្នកបោះឆ្នោតលែងសូវយកចិត្តទុកដាក់ពីរឿងនយោបាយ ។ នៅឃុំតាខែន សកម្មជន SRP ម្នាក់មានមតិថា "ប្រជាជនមិនសូវយកចិត្តទុកដាក់ពីរឿងនយោបាយទេ ពីព្រោះគ្មានការផ្លាស់ប្តូរអ្វីសោះ"[១២០] ។ មេឃុំយល់ថា

---

[១១៥] FUNCINPEC commune councillor, Ta Khaen (46), personal interview, Kampot, 17 July 2003.

[១១៦] Village chief, Ta Khaen, personal interview (47), Kampot, 17 July 2003.

[១១៧] SRP activists, Ta Khaen (48), group interview, Kampot, 17 July 2003.

[១១៨] CEC chief, Ta Khaen (50), personal interview, Kampot, 1 Aug 2003.

[១១៩] SRP activist, Ta Khaen (48), group interview, Kampot, July 2003.

[១២០] Sam Rainsy Party activist, Ta Khaen (48), group interview, Kampot, 17 July 2003.

ពួកអ្នកបោះឆ្នោតក្នុងឃុំគាត់យកចិត្តទុកដាក់ពី "អ្វីដែលគេអាចមើលឃើញ" ។ គាត់និយាយថា ប្រជាជននៅទីនេះគ្មានការអប់រំទេះ ប្រជាជន ៧០% មិនចេះអាន, ពួកកុមារមិនទៅសាលាទេ ។ ប៉ុន្តែពួកគេដឹងថា ខ្លួនគេស្រឡាញ់គណបក្សណា ។ ពួកគេអាចមើលឃើញថា គណបក្សណាមកជួយពួកគេ ។ អ្នកធំៗបានអញ្ជើញមក, ប្រជាជនគេមើលឃើញ ហើយគេបោះឆ្នោតតាមដែលគេមើលឃើញ ។ គឺអ្នកដែលមកដោះស្រាយបញ្ហាឱ្យពួកគេធ្វើផ្លូវ សង់សាលារៀន"[១២១] ។

ពួកសកម្មជន SRP បានលើកពីគោលគំនិតប្រហាក់ប្រហែលគ្នា "ខ្ញុំមានគំនិតថា បើប្រជាជនបោះឆ្នោតឱ្យ សម រង្ស៊ី ហើយគាត់ឈ្នះ គាត់នឹងជួយពួកយើង, កសាងសាលារៀន, អណ្តូងទឹក, និងអ្វីៗទៀត" ។ ប៉ុន្តែសកម្មជនម្នាក់បានចង្អុលបង្ហាញពីកំរិតព្រំដែននៃការឃោសនាបែបនេះ "ប្រជាជនខ្លះមិនយល់ទេ ។ គេនិយាយថា យើងមិនទាន់បានឃើញគាត់ធ្វើអ្វីសោះ"[១២២] ។

### *៣.២.៥.៥ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងពីការបោះឆ្នោត*

ពត៌មានស្តីពីការបោះឆ្នោត បញ្ជូនមកជាសំខាន់តាមរយៈការិយាល័យថ្នាក់ស្រុករបស់គណបក្សនយោបាយ សំរាប់ពួកសកម្មជន និងតាមរយៈអាជ្ញាធរមូលដ្ឋានសំរាប់ពួកអ្នកភូមិធម្មតា ។ អនក្ខរភាពកំរិតខ្ពស់ និងប្រព័ន្ធដឹកជញ្ជូនអន់ខ្សោយក្នុងតំបន់ បានរារាំងការផ្សព្វផ្សាយពត៌មាន ប៉ុន្តែទាំងមេឃុំ និងប្រធានភូមិបានលើកឡើងថា អាជ្ញាធរមូលដ្ឋានស្ទាត់ជំនាញក្នុងការកែនប្រមូលប្រជាជនក្នុងតំបន់ឱ្យចូលរួម ពីព្រោះមានបទពិសោធន៏យូរឆ្នាំក្នុងការងាររដ្ឋបាលនៅទីនេះ គឺតាំងពីឆ្នាំ១៩៧៣ មក ។

គឃប ក៏ជាប្រភពពត៌មានមួយដ៏សំខាន់ដែរ ថ្វីបើអាជ្ញាធរបោះឆ្នោតថ្នាក់ខ្ពស់ៗ និងពួកអ្នកសង្កេតការណ៍មិនបានមកដល់ឃុំនេះជាទៀងទាត់ក្តី ។ នៅពេលមានពួកទីភ្នាក់ងារខាងក្រៅមកដល់ឃុំ ប្រជាជនមូលដ្ឋានមានចិត្តសាទរចង់ចេះចង់ដឹង ។ NGOs ខាងសិទ្ធិមនុស្ស បានមកតំបន់នេះ ហើយទទួលបានការឆ្លើយតបយ៉ាងខ្លាំងក្លា "ប្រជាជនមកចូលរួមការប្រជុំនានា ។ នៅកន្លែងខ្លះប្រជាជនមកតែ ៤០% ប៉ុន្តែនៅទីនេះមក ៧០-៨០%"[១២៣] ។ នៅតំបន់នេះក៏មានចលនាលើកលែងទោសអ្នកមានអាវុធដែរ និងមានការបណ្តុះបណ្តាលពី NGO ខាងសុខភាពមួយ ។ ប៉ុន្តែតាមការមើលឃើញតំបន់នេះមិនសូវមានការពាក់ព័ន្ធប្រចាំថ្ងៃជាមួយពិភពខាងក្រៅដូចឃុំឯទៀតទេ ។

លទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមានកំរិតតូច ។ ក្នុងឃុំមានទូរទស្សន៏តិចតួច ហើយការផ្សាយរបស់ស្ថានីយ៏វិទ្យុជាច្រើនពិបាកចាប់បានណាស់ ។ សកម្មជន SRP ប្រាប់យើងថា ជួនកាលពួកគេខំចាប់ស្តាប់ការផ្សាយតាមរលកធាតុអាកាសខ្លីរបស់ RFA ឬ VOA ប៉ុន្តែភាគច្រើនពួកគេស្តាប់វិទ្យុរបស់រដ្ឋពីព្រោះឮច្បាស់ល្អជាងគេ ។

ថ្វីបើមានកត្តារាំងស្ទះបែបនេះ ប៉ុន្តែប្រធានភូមិអ្នកឆ្លើយសំភាសន៏ជឿថា សមាហរណកម្មបានជះឥទ្ធិពលទៅលើតំបន់នេះ "តាមការយល់ឃើញផ្ទាល់របស់ខ្ញុំ ប្រជាជនចាប់ផ្តើមផ្លាស់ប្តូរពីទំលាប់ចាស់, ពួកគេបានជួបពាក់ព័ន្ធនឹងទីផ្សារ បានធ្វើដំណើរច្រើនជាងមុន ។ ខ្ញុំមានបងប្អូនជីដូនមួយម្នាក់នៅភ្នំពេញ ដែលខ្ញុំទៅសួរសុខទុក្ខជាទៀងទាត់ ។ ដូច្នេះកេរ្តិ៍ដំណែលរបស់ខ្មែរក្រហមសល់កាន់តែតិចឡើងៗហើយ"[១២៤] ។

### *៣.២.៤.៦ ថ្ងៃបោះឆ្នោត និងថ្ងៃក្រោយមកទៀត*

នៅតាខែន អត្រាអ្នកទៅបោះឆ្នោតមានកំរិតទាប ។ ក្នុងចំណោមអ្នកចុះបញ្ជីបោះឆ្នោត ៣.៧៧៤នាក់ មាន

---

[១២១] Commune chief, Ta Khaen (45), personal interview, Kampot, 7 July 2003.

[១២២] SRP activist, Ta Khaen (48), group interview, Kampot, 17 July 2003.

[១២៣] Commune chief, Ta Khaen (45), personal interview, Kampot, 7 July 2003.

[១២៤] Village chief, Ta Khaen (47), personal interview, Kampot, 17 July 2003.

២.៨១៣នាក់ បានទៅបោះឆ្នោត ក្នុងនេះមាន ១៣១សន្លឹកឆ្នោតបានខូច ។ តាមសំដីមេឃុំ "ប្រជាជន ៩០០នាក់ មានជំងឺ ឬជាប់រវល់ខ្លាំងពេកមិនអាចទៅបាន" ។ មេឃុំមានមតិថា ប្រជាជនមួយចំនួនជួបទឹកជំនន់នៅឯផ្ទះ ដូច្នេះ គួរធ្វើការបោះឆ្នោតនៅខែឧសភាវិញ ដើម្បីចៀសវាងរដូវភ្លៀង ។ គាត់ផ្តល់មតិទៀតថា ពួកអ្នកដែលមិនបានទៅ ប្រហែលជាបោះឆ្នោតឱ្យ CPP ។ ប្រធាន គឃប លើកឡើងថា ដោយឃុំតាខែន មានភូមិស្ថិតនៅរាយប៉ាយ ប្រជាជនត្រូវធ្វើដំណើរយ៉ាងឆ្ងាយមកកាន់ការិយាល័យបោះឆ្នោត "ដូច្នេះប្រហែលអ្នកខ្លះមិនបានតស៊ូមកទេ" ។ គាត់បានលើកដែរពីករណី "តិចតួច" នៃប្រជាជនអ្នកមកបោះឆ្នោតដែលមិនបានចុះបញ្ជី ឬដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

## ៣.៣ ការប្រៀបធៀបឃុំករណីសិក្សា

### *៣.៣.១ សន្តិសុខ*

យើងមិនឃើញមានសកម្មជនណាមួយដែលនិយាយថា ខ្លួនគាត់ស្ថិតក្នុងគ្រោះថ្នាក់ទេ ។ យើងអាចរកឃើញសមាជិកនៃគណបក្សធំៗទាំងបី ក្នុងគ្រប់ឃុំករណីសិក្សា ប៉ុន្តែគណបក្សតូចៗមានវត្តមានតិចតួចណាស់ ។ អ្នកឆ្លើយសំភាសន៍បានទទួលស្គាល់ទាំងអស់គ្នាថា សន្តិសុខមានស្ថានភាពល្អច្រើនជាងឆ្នាំ១៩៩៨ ហើយយើងមិនបានឮការតវ៉ាអ្វីពីសកម្មភាពរបស់កំលាំងសន្តិសុខក្នុងឃុំករណីសិក្សាទេ ប៉ុន្តែយើងឮការតវ៉ាជាច្រើនពីកំលាំងសន្តិសុខនៅកំរិតខេត្ត ។ ប៉ុន្តែយើងឃើញមានជាច្រើននូវសកម្មជនគណបក្ស និងអ្នកសង្កេតការណ៍បោះឆ្នោតដែលអះអាងថា ពួកអ្នកបោះឆ្នោតជឿថាខ្លួនគេអាចជួបគ្រោះថ្នាក់បើសិនចូលគណបក្សណាផ្សេងក្រៅពីគណបក្សកាន់អំណាច និងដែលប្រើប្រាស់ហេតុផលនេះដើម្បីពន្យល់ពីកង្វះការយកចិត្តទុកដាក់ចំពោះការឃោសនារបស់គណបក្ស ។ ផ្ទុយទៅវិញ សមាជិក CPP ឬអាជ្ញាធរមូលដ្ឋាន ច្រើនតែចាត់ទុកកង្វះការចូលរួមរបស់អ្នកបោះឆ្នោតក្នុងសកម្មភាពបោះឆ្នោតផ្សេងៗ ថាមកពីការខ្ជិល ឬការរវល់រកចិញ្ចឹមជីវិតរបស់អ្នកបោះឆ្នោត ។ នេះជាប្រភពចំបងមួយនៃទំនាស់ ពីព្រោះវានាំឱ្យមានការបកស្រាយខុសគ្នាយ៉ាងខ្លាំងពីព្រឹត្តិការណ៍ និងប្រតិកម្មនានា, និងនាំឱ្យមានការមើលឃើញជាទូទៅខុសគ្នានៅលើដំណើរការបោះឆ្នោតទាំងមូល ។ ការយល់ឃើញខុសគ្នាបែបនេះ ក៏បានសង្កេតឃើញដែរនៅកំរិតជាតិក្នុងឆ្នាំ១៩៩៨ ហើយវាជាចំណុចមួយសំខាន់ដែរដែលជំហរបែបនេះឃើញមានដូចគ្នានៅកំរិតមូលដ្ឋាន ។

### *៣.៣.២ កំរិតនៃទំនាស់*

យើងបានរកឃើញថា សមាជិក SRP ច្រើនសំលឹងឃើញការបោះឆ្នោតថា មានស្ថានភាពទំនាស់ក្នុងកំរិតខ្ពស់ជាងពួកសមាជិក CPP, FUNCINPEC, គឃប, ឬក៏អាជ្ញាធរមូលដ្ឋាន ។ យើងរកឃើញថា ជាទូទៅរឿងនេះផុសចេញពីទស្សនៈខុសគ្នាស្តីពីទំនាស់ ។ អាជ្ញាធរមូលដ្ឋានច្រើនប្រើពាក្យនេះចំពោះអំពើហិង្សា ឬការចលាចលផ្សេងទៀតក្នុងសង្គម ។ ក្នុងគ្រប់ករណីសិក្សា យើងរកឃើញថា អាជ្ញាធរមូលដ្ឋានបានសង្កត់ធ្ងន់ពីសណ្តាប់ធ្នាប់ល្អនៃការបោះឆ្នោត និងសន្តិសុខកំរិតខ្ពស់ បើធៀបនឹងឆ្នាំមុនៗ ។ ផ្ទុយទៅវិញ សកម្មជន SRP ច្រើនតែមើលឃើញបញ្ហានានា (ដូចជា ការអះអាងពីការភ័យខ្លាចរបស់អ្នកបោះឆ្នោត) ថាជារឿងទំនាស់ ទោះបីវាមិនបានធ្វើឱ្យបាត់សណ្តាប់ធ្នាប់សាធារណៈក្នុងកំរិតអាចកត់សំគាល់បានក្តី ។ នេះជាការរកឃើញមួយដ៏សំខាន់សំរាប់ពន្យល់ថា ហេតុអ្វីបានជាការស្ងប់ស្ងាត់ និងសុខសន្តិភាពនៅថ្ងៃឃោសនា និងថ្ងៃបោះឆ្នោត វាមិនសុទ្ធតែនាំឱ្យមានការទទួលយកលទ្ធផលបោះឆ្នោតពីសំណាក់គណបក្សជំទាស់នោះ ។

ឃុំត្នោតហាក់ដូចមានទំណាស់តិចជាងឃុំឯទៀតៗដែលយើងបានទៅទស្សនា ។ ផ្អែកតាមការរកឃើញរបស់យើងដែលថា ទំនាស់ធំៗគឺរវាង SRP និង CPP ដូច្នេះស្ថានភាពនេះប្រហែលមកពី SRP ទន់ខ្សោយខ្លាំងនៅត្នោត, ហើយសមាជិកក្រុមប្រឹក្សាឃុំជា FUNCINPEC និង CPP មានទំនាក់ទំនងជិតស្និទ្ធ និងជាមិត្តភាពល្អណាស់ ។ នៅវាលវង់ ដែលជាឃុំករណីសិក្សាមាន SRP ខ្លាំងជាងគេ ទំនាក់ទំនងរវាងគណបក្សនានា មានលក្ខណៈតឹងតែងជាងឆ្ងាយណាស់ ។ នៅឃុំពាមឯក SRP បានដាក់ពាក្យតវ៉ាមួយចំនួន ។ នៅឃុំវត្តតាមឹម និងតាខែន សកម្មជនទាំងខាង FUNCINPEC និង SRP បានប្តឹងតវ៉ាពី

សកម្មភាពរបស់អ្នកឃោសនាខាង CPP និងរបស់អាជ្ញាធរមូលដ្ឋាន ។ ស្ថានការណ៍នៅតាខែន អាចមកពីការទើបកើតមានថ្មីៗ នៃរបបនយោបាយពហុបក្ស ។ នៅវាលវង់ វាអាចមកពីការប្រកួតប្រជែងយ៉ាងក្បៀកគ្នារវាង CPP និង SRP ក្នុងពេលបោះឆ្នោតឆ្នាំ២០០២ ។ វាក៏អាចមកពីវាលវង់ គឺជាឃុំក្នុងទីក្រុង ដែលមានសកម្មភាពឃោសនាយ៉ាងខ្លាំង ព្រមទាំងទស្សនកិច្ច និងសន្ទរកថាក្តៅគគុករបស់ថ្នាក់ដឹកនាំគណបក្សនយោបាយនានាផង ។

### ៣.៣.៣ អព្យាក្រឹតភាពនៃអាជ្ញាធរមូលដ្ឋាន

យើងរកឃើញការខ្វែងមតិជាទូទៅដូចគ្នារវាងគណបក្សនយោបាយនានា ពីរឿងអព្យាក្រឹតភាពនៃអាជ្ញាធរមូលដ្ឋាន ។ អាជ្ញាធរមូលដ្ឋានបានអះអាងសឹងតែដូចគ្នាទាំងអស់ថា ពួកគេអព្យាក្រឹត្យក្នុងការអនុវត្តសកម្មភាពរបស់ខ្លួនក្នុងពេលម៉ោងធ្វើការ ថ្វីបើសមាជិកអាជ្ញាធរមូលដ្ឋានដែលយើងបានជួបទាំងអស់ មានភក្តីភាពផ្ទាល់ខ្លួនចំពោះ CPP ។ យើងរកឃើញថា ក្នុងគ្រប់ឃុំករណីសិក្សា អាជ្ញាធរមូលដ្ឋានដឹងថា ការធ្វើឃោសនាឱ្យគណបក្សនយោបាយ, ការពាក់អាវយឺតគណបក្ស... គឺខុសនឹងបទប្បញ្ញត្តិរបស់ គជប ។ ប៉ុន្តែអ្វីទៅដែលពិតជា "ការប្រើតួនាទីរបស់ខ្លួន ដើម្បីជះឥទ្ធិពលទៅលើសេរីភាពជ្រើសរើសរបស់អ្នកបោះឆ្នោតក្នុងពេលបោះឆ្នោត" ឬ "អំពើបែបណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ដែលបំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោត" ដូចដែលពាក្យពេចន៍ក្នុងសេចក្តីណែនាំរបស់ គជប ចុះថ្ងៃទី១៧ ខែកក្កដា បានសំដៅដល់, វាជាបញ្ហាចោទនៅឡើយ ។ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋានខ្លះនិយាយថា វាជាតួនាទីរបស់ប្រធានភូមិក្នុងការរង់ចាំមើលថា អ្នកណាបានបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងទៅរកហៅអ្នកណាដែលមិនទាន់បានបោះឆ្នោត ។ អាជ្ញាធរមូលដ្ឋានសំគាល់សកម្មភាពនេះថាជាសេវាសាធារណៈ ប៉ុន្តែខាង COMFREL និងមនុស្សមួយចំនួនទៀតបកស្រាយវាថា ជាសកម្មភាពគំរាមកំហែង ។ ក្នុងឃុំ ករណីសិក្សានានារបស់យើង សកម្មជន SRP បានអះអាងសឹងតែដូចគ្នាទាំងអស់ថា អាជ្ញាធរមូលដ្ឋានទាំងនេះមានការរើសអើងប្រឆាំងនឹងពួកអ្នកគាំទ្រគណបក្សខ្លួន ព្រមទាំងប្រើការបំភិតបំភ័យ និងការគំរាមកំហែង ។ ការគំរាមកំហែងមួយដែលមានលើកជាទូទៅ គឺការអះអាងថា ប្រធានភូមិបានសាកសួរពួកអ្នកភូមិ "តើអ្នកទៅរស់នៅកន្លែងណា បើអ្នកមិនគាំទ្រ CPP?" ។ គេជឿថា សំនួរនេះបានបង្កការភ័យខ្លាចក្នុងចំណោមអ្នកភូមិពីរឿងដកហូតដីធ្លី ។ សកម្មជន SRP តាមឃុំនានានៅបាត់ដំបង និងនៅឃុំតាខែន ក៏បានចោទពួកប្រធានភូមិពីរឿងទិញសន្លឹកឆ្នោតដែរ ។ ក្នុងគ្រប់ឃុំករណីសិក្សា លើកលែងតែតាខែនចេញ យើងបានរកឃើញថា អ្នកឆ្លើយសំភាសន៍ខាង FUNCINPEC មិនសូវទិតៀនអាជ្ញាធរមូលដ្ឋានច្រើនដូចខាង SRP ទេ ។ រឿងនេះប្រហែលឆ្លុះបញ្ចាំងពីការចូលរួមច្រើនជាងរបស់ FUNCINPEC នៅក្នុងការជ្រើសរើស គជប និង គខប នៅឆ្នាំ២០០៣ ។

### ៣.៣.៤ ឥរិយាបថចំពោះស្ថាប័នបោះឆ្នោត

យើងបានរកឃើញការមិនទុកចិត្តគ្នាកំរិតខ្ពស់ ជាពិសេសក្នុងចំណោមតំណាង SRP និងអ្នកសង្កេតការណ៍នៅកំរិតខេត្ត ចំពោះ គឃប នានា ដែលពួកគេមើលឃើញថា គ្មានប្រសិទ្ធភាព និងលំអៀង ។ ប៉ុន្តែយើងបានឃើញថា ការប្រជុំប្រចាំសប្តាហ៍របស់ គឃប មានការចូលរួមល្អ ។ សមាជិក គឃប ទាំងអស់ដែលយើងជួបគឺជាគ្រូបង្រៀន ហើយភាគច្រើនមានបទពិសោធន៍ពីការបោះឆ្នោតលើកមុនៗ ។ ទាំងអស់គ្នាបានអះអាងពីអព្យាក្រឹតភាព ប៉ុន្តែបានត្អូញត្អែរពីកង្វះធនធាន ។ សកម្មជននៅមូលដ្ឋាន បានពាក់ព័ន្ធយ៉ាងសកម្មជាមួយ គឃប ដោយប្រើប្រាស់ការប្រជុំប្រចាំសប្តាហ៍ដើម្បីជំរុញការតវ៉ារបស់ខ្លួន ដែលជួនកាលអាចដោះស្រាយបានដោយពេញចិត្ត ជួនកាលក៏ដោះស្រាយមិនបាន ។ ការតវ៉ាជាក់លាក់នានាអំពី គឃប ច្រើនទាក់ទងនឹងអប្រសិទ្ធភាព ជាជាងការរើសអើងដោយចំហ (យ៉ាងហោចណាស់នៅមុនថ្ងៃបោះឆ្នោត) ។ ជាទូទៅ គឃប នៅឆ្នាំ២០០៣ ហាក់ដូចធ្វើការងារមានតំលាភាពច្រើនជាង និងងាយទាក់ទងជាង បើធៀបនឹងការបោះឆ្នោតលើកមុនៗ ថ្វីបើយើងឃើញនៅឃុំវាលវង់ និងតាខែន មានតវ៉ាផ្សេងៗរបស់សកម្មជនគណបក្សជំទាស់ នៅតែគ្មានដំណោះស្រាយ ថ្វីបើមានការខិតខំដោះស្រាយនៅកំរិត គឃប ក្តី ។ ឧទាហរណ៍ ក្នុងឃុំករណីសិក្សានានា យើងមិនបានឮពីការតវ៉ាថា គឃប បានរាំងស្ទះសកម្មភាពឃោសនារបស់គណបក្សនានាទេ ។

### ៣.៣.៥ ការចុះបញ្ជីអ្នកបោះឆ្នោត

របាយការណ៍ពីការចុះបញ្ជីអ្នកបោះឆ្នោត ប្រែប្រួលខុសគ្នារវាងឃុំនានា ។ នៅបាត់ដំបង គឃប និងក្រុមប្រឹក្សាឃុំនានា បានទទួលស្គាល់ពីការលំបាកខាងបច្ចេកទេសមួយចំនួន និងខាងការសំរបសំរួលលើការចុះបញ្ជីអ្នកបោះឆ្នោត ប៉ុន្តែមន្ត្រីមូលដ្ឋាននៅឃុំឯទៀតៗច្រើនអះអាងពីជោគជ័យយ៉ាងធំក្នុងដំណើរការនេះ ។

យើងបានឮគេនិយាយថា មេឃុំ និងប្រធានភូមិនានា បានស្ថិតនៅខាងក្រៅការិយាល័យបោះឆ្នោតនៅ ២ឃុំ ក្នុងចំណោមឃុំករណីសិក្សាទាំង ៥ ។ ចំពោះ ៣ឃុំករណីសិក្សាទៀត យើងបានឮថា មានអ្នកខិតខំមកបោះឆ្នោតដែលមិនបានចុះបញ្ជី ឬដែលមិនអាចរកឈ្មោះឃើញក្នុងបញ្ជីបោះឆ្នោត ។ រឿងនេះផ្តល់គំនិតថា ក្នុងឃុំទាំងនេះ មានពត៌មានមិនគ្រប់គ្រាន់ទេពីការចុះបញ្ជីអ្នកបោះឆ្នោត និងមានលក្ខណៈស្របគ្នាច្រើននឹងការចោទប្រកាន់នៅកំរិតជាតិដែលថា មានចំណងទាក់ទងយ៉ាងជិតស្និទ្ធរវាងការអះអាងផ្សេងៗរបស់តំណាងគណបក្សនយោបាយនៅកំរិតជាតិ និងនៅកំរិតមូលដ្ឋាន ។

### ៣.៣.៦ ប្រព័ន្ធផ្សព្វផ្សាយ និងការយល់ដឹងជាសាធារណៈ

ការត្អូញត្អែរជាទូទៅមួយគឺ ប្រជាជនបានថយចុះការយកចិត្តទុកដាក់ពីរឿងនយោបាយជាតិ ពីព្រោះពួកគេ មិនដែលឃើញមុខតំណាងរាស្ត្ររបស់ពួកគេ ហើយក៏គ្មានគំនិតថា ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាលនឹងនាំឱ្យមានការផ្លាស់ប្តូរក្នុងជីវិតរស់នៅរបស់ពួកគេ ។ ការត្អូញត្អែរនេះឮភាគច្រើនពីអ្នកឆ្លើយសំភាសន៍ខាង FUNCINPEC និងមិនសូវមានឮទេពីខាង CPP ដែលធ្វើការឃោសនាពីកម្មវិធីនយោបាយមួយដែលសង្កត់ធ្ងន់ពីប្រវត្តិល្អរបស់គណបក្សក្នុងការផ្តល់ទុនឱ្យគំរោងអភិវឌ្ឍន៍មូលដ្ឋាននានា ។

មានការខុសគ្នាច្រើនដែរពីចំនួនពត៌មានដែលបានទៅដល់ប្រជាជននៅតាមកន្លែងខុសៗគ្នាក្នុងប្រទេស ។ នៅតាមបណ្តាឃុំដែលស្ថិតនៅក្នុង ឬនៅជិតទីរួមខេត្ត មានប្រភពពត៌មានច្រើនបែបយ៉ាង ដូចជា សារពត៌មាន ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសផ្សេងៗ ការិយាល័យគណបក្សនយោបាយ និង NGOs ។ បើទៅឆ្ងាយពីទីរួមខេត្ត ប្រភពពត៌មានក៏ថយចុះដោយមានសារពត៌មានតិចជាង, ហើយស្ថានីយផ្សព្វផ្សាយតាមរលកធាតុអាកាស និងស្ថាប័នផ្សេងទៀតដែលគេអាចប្រើប្រាស់សេវាបានក៏មានតិចជាង ។ ប៉ុន្តែគួរកត់សំគាល់ថា បញ្ហាចោទនៅឃុំតាខែនក្នុងឆ្នាំ២០០២ បាននាំឱ្យមានអន្តរាគមន៍ពីខាងក្រៅ ដូចជាពីអ្នកសង្កេតការណ៍អន្តរជាតិ និងតំណាងពិសេសខាងសិទ្ធិមនុស្ស ។ អន្តរាគមន៍ទាំងនេះហាក់ដូចបានជោគជ័យខ្លាំងណាស់ក្នុងការធ្វើឱ្យសកម្មជនគណបក្សនយោបាយមានទំនុកចិត្តឡើងវិញពីសិទ្ធិអំណាចរបស់ខ្លួន និងក្នុងការជំរុញឱ្យអាជ្ញាធរមូលដ្ឋានគោរពច្បាប់, ប៉ុន្តែវាជះឥទ្ធិពលតិចជាងទៅលើអ្នកភូមិធម្មតា ។

ពត៌មានពីការបោះឆ្នោត ទទួលបានជាសំខាន់ពីអាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ។ គឃប ក៏មានធ្វើវគ្គបណ្តុះបណ្តាលដើម្បីផ្សព្វផ្សាយពត៌មានមកពី គជប និង គឃប ។ អ្នកឆ្លើយសំភាសន៍កំរមាននិយាយពីគំរោងអប់រំអ្នកបោះឆ្នោតរបស់ NGO នានាណាស់ ។ ក្នុង ២ឃុំករណីសិក្សា មានឮគេនិយាយពីតួនាទីរបស់ប្រធានភូមិ និងមេឃុំ ក្នុងការប្រមូលប្រជាជនឱ្យទៅបោះឆ្នោត ។

### ៣.៣.៧ ការឃោសនាបោះឆ្នោត

មានការទទួលស្គាល់ជាទូទៅថា CPP មានបណ្តាញយ៉ាងល្អតាំងពីថ្នាក់មជ្ឈិម ដល់កំរិតបុគ្គលក្នុងទូទាំងប្រទេស តាមរយៈប្រព័ន្ធរដ្ឋាភិបាលរបស់ខ្លួន ជាពិសេសបណ្តាញអាជ្ញាធរមូលដ្ឋាន ។ ពួកអ្នកឆ្លើយសំភាសន៍បានឯកភាពថា បណ្តាញ CPP មានតាំងពីមជ្ឈិម ដល់ខេត្ត ស្រុក ឃុំ ភូមិ ក្រុម និងក្រុមការងារ (អ្នកធំម្នាក់មានឋានៈជាឯកឧត្តមមកពីភ្នំពេញទទួលខុសត្រូវលើមួយស្រុក) ។ ចាប់ពីថ្នាក់ស្រុក ដល់កំរិតឃុំ មានធ្វើការប្រជុំជារឿយៗ ដើម្បីផ្តល់ពត៌មានមកពីថ្នាក់លើ ។ ទំនាក់ទំនងនៅក្រោមកំរិតស្រុក ជួនកាលមានលក្ខណៈផ្លូវការ ជួនកាលមិនផ្លូវការ ។ រវាងថ្នាក់ស្រុក និងថ្នាក់ជាតិ មានធ្វើការប្រជុំរៀងរាល់ត្រីមាស ។ សកម្មជន CPP នៅតំបន់ជនបទ បាននិយាយពីទំនុកចិត្តចំពោះថ្នាក់ដឹកនាំរបស់ខ្លួន ពីព្រោះពួកគេយល់ថា គំលាតមិន

ធំទេ ហើយថ្នាក់លើតែងចុះមកតំបន់មូលដ្ឋានយ៉ាងទៀងទាត់ ។ ប៉ុន្តែរឿងនេះប្រែប្រួលពីឃុំមួយទៅឃុំមួយ: នៅតាខែន មេឃុំនិយាយយ៉ាងត្រេកអរពីជំនួយដែលថ្នាក់ដឹកនាំ CPP ផ្តល់ឱ្យ ប៉ុន្តែមេឃុំត្នោតកត់សំគាល់ថា គណបក្សបានយកចិត្តទុកដាក់តិចតួចចំពោះឃុំ ។

FUNCINPEC ក៏មានបណ្តាញធំទូលាយដែរ ប៉ុន្តែ (ខុសពីបណ្តាញ CPP) គ្មានប្រតិបត្តិការនៅកំរិតក្រោមភូមិទេ ។ តាមធម្មតាកំរិតទាបបំផុតគឺ ភូមិឬឃុំ ។ អ្នកភូមិក្នុងឃុំផ្សេងៗរាយការណ៍ថា សកម្មជន FUNCINPEC ក្នុង៥ឆ្នាំកន្លងមក មិនសូវសកម្មដូចគណបក្សឯទៀតទេ ហើយសកម្មជន FUNCINPEC ខ្លះ (ពិសេសជំទប់ទី១ ខាង FUNCINPEC នៅឃុំត្នោត) បានត្អូញត្អែរយ៉ាងខ្លាំងពីកង្វះការយកចិត្តទុកដាក់ពីសំណាក់អ្នកនយោបាយថ្នាក់ខ្ពស់ៗ ចំពោះតំរូវការក្នុងឃុំ ។ សកម្មជននៅកំរិតឃុំទទួលពត៌មានពីការឃោសនាមកពីការិយាល័យថ្នាក់ស្រុក និងខេត្ត ។ អ្នកថ្នាក់ខ្ពស់នៅការិយាល័យខេត្ត ឬភ្នំពេញ កំរចុះមកដល់ឃុំ ឬភូមិណាស់ ។ សកម្មជន FUNCINPEC ភាគច្រើនដែលយើងជួបនិយាយថា ភាគច្រើនពួកគេរៀនសូត្រពីកម្មវិធីនយោបាយរបស់គណបក្ស តាមរយៈប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ។ សមាជិកក្រុមប្រឹក្សាឃុំជា FUNCINPEC ម្នាក់និយាយថា "យើងគាំទ្រ FUNCINPEC ពីព្រោះយើងស្រឡាញ់ថ្នាក់ដឹកនាំរបស់យើង និងរបបរាជានិយម ប៉ុន្តែយើងមិនមែនជ្រុលនិយមសំរាប់គណបក្សទេ"[១២៥] ។ ក្នុង FUNCINPEC មានអន្តរកម្មតិចតួចរវាងថ្នាក់មូលដ្ឋាន និងថ្នាក់មជ្ឈិម ។

SRP ហាក់ដូចមានទំនាក់ទំនងផ្ទៃក្នុងគណបក្សយ៉ាងសកម្មនៅគ្រប់កំរិត លើកលែងតែនៅឃុំតាខែន ដែលពួកសមាជិកបានទទួលការជួយគាំទ្រតិចតួចពីខាងក្រៅក្នុងរយៈពេលមុនថ្ងៃបោះឆ្នោតឆ្នាំ២០០៣ ។ នៅកន្លែងឯទៀត ទំនាក់ទំនងរវាងសកម្មជននៅតំបន់ជនបទ និងនៅការិយាល័យខេត្ត មានលក្ខណៈរឹងប៉ឹង ហើយការិយាល័យខេត្តផ្តល់ការបណ្តុះបណ្តាលឱ្យសកម្មជននៅជនបទ ។ SRP មានទិសដៅកសាងបណ្តាញមួយមានសមាជិក ៨នាក់ ក្នុងឃុំនីមួយៗ ។ ជាទូទៅ សមាជិក SRP អះអាងថា គណបក្សខ្លួនសកម្មបំផុត ហើយសកម្មភាពនេះផុសចេញឯងៗពីការប្តេជ្ញាចិត្តនៅមូលដ្ឋាន ។ សមាជិកក្រុមប្រឹក្សាឃុំពាមឯក ជា SRP ម្នាក់លើកឡើងថា:

> *"យើពុំមានយន្តការតឹងរ៉ឹង ឬសមាជិកច្រើនដូច CPP ទេ ប៉ុន្តែសកម្មជនរបស់យើងធ្វើការខ្លាំង និងការស្មោះត្រង់របស់ពួកគេគឺផុសចេញពីជំរៅនៃបេះដូង"[១២៦] ។*

### *៣.៣.៨ ថ្ងៃបោះឆ្នោត*

ក្នុងឃុំករណីសិក្សានានា បញ្ហាដែលមានជាទូទៅជាងគេ គឺអ្នកមកបោះឆ្នោតដែលមិនបានចុះបញ្ជី ឬដែលគ្មានឈ្មោះក្នុងបញ្ជី ។ ក្នុងឃុំពីរ យើងបានឮសេចក្តីរាយការណ៍ពីមេឃុំដែលនៅរង់ចាំខាងក្រៅការិយាល័យបោះឆ្នោត ។ ក្នុងឃុំទាំងអស់ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ មានវត្តមានយ៉ាងច្បាស់ ។ ក្នុងឃុំករណីសិក្សានានា គ្មានអំពើហិង្សា ឬការបាត់សណ្តាប់ធ្នាប់ទេ ។

## ៣.៤ សេចក្តីសន្និដ្ឋាន

ការប្រៀបធៀបដោយផ្ទាល់ជាមួយឆ្នាំ១៩៩៨ មិនអាចធ្វើកើតទេ ពីព្រោះនៅពេលនោះ ការសិក្សារបស់ វិបសអ ផ្តោតលើកំរិតជាតិ ជាជាងកំរិតមូលដ្ឋាន ។ ប៉ុន្តែយើងអាចធ្វើសេចក្តីសន្និដ្ឋានជាទូទៅខ្លះដែរទាក់ទិននឹងទំនាស់ជាក់លាក់មួយចំនួនដែលការសិក្សានេះបានពិនិត្យស្រាវជ្រាវ ។

---

[១២៥] Commune councillor, Wat Tamim (52), personal interview, Battambang, 21 July 2003.

[១២៦] SRP commune councillor, Peam Ek (21), personal interview, Battambang, 23 July 2003.

ក. ការស្រាវជ្រាវលើករណីសិក្សាបានបង្ហាញថា សេរីភាពធ្វើការឃោសនាគឺឃើញមានជាទូទៅ ហើយសកម្មជននៃគណបក្សធំៗទាំងអស់ អាចធ្វើសកម្មភាពឃោសនាក្នុងគ្រប់ឃុំករណីសិក្សា ។ សេរីភាពរបស់អ្នកបោះឆ្នោតក្នុងការបញ្ចេញមតិដោយគ្មានការភ័យខ្លាច វាមានលក្ខណៈមិនច្បាស់លាស់ជាង ហើយបញ្ហាថាតើអ្នកបោះឆ្នោតមានសេរីភាព ឬគ្មាន គឺជាប្រភពនៃទំនាស់ ។ តួអង្គផ្សេងៗមកពីគណបក្សខុសៗគ្នា មានយោបល់ខុសគ្នាខ្លាំងណាស់ពីរឿងនេះ ។ តំណាងខាង CPP ជាទូទៅគូសបញ្ជាក់ថា កង្វះទឹកចិត្តផុសផុលគឺដោយសារការខ្ជិល និងកង្វះការយកចិត្តទុកដាក់មិនមែនការភ័យខ្លាច ឬការបំភិតបំភ័យទេ ។ ផ្ទុយទៅវិញ តំណាង SRP អះអាងថា កង្វះទឹកចិត្តផុសផុល គឺដោយសារការភ័យខ្លាច ។ តំណាង FUNCINPEC ក្នុងឃុំករណីសិក្សានៅបាត់ដំបង និងកំពត ច្រើនស្របតាមមតិរបស់ SRP, ឯនៅតាកែវ និងកំពង់ចាមច្រើនស្របតាមមតិ CPP ។

ខ. តួអង្គខុសៗគ្នា មានមតិខុសគ្នាថា តើទំនាស់មានន័យយ៉ាងដូចម្ដេច ។ សំរាប់តំណាង CPP ទំនាស់ត្រូវតែពិភាក្សាជានិច្ចពីរឿងសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ សំរាប់ SRP ទំនាស់ត្រូវពិភាក្សាពីរឿងចំណាប់អារម្មណ៍ជាឯកជនរបស់បុគ្គល និងការអះអាងពីសកម្មភាពបំភិតបំភ័យនៅខាងក្រោយឆាក ។

គ. នៅតែមានការមិនទុកចិត្តគ្នាយ៉ាងធំរវាង SRP និង CPP នៅកំរិតមូលដ្ឋាន ។ យើងបានឮពីការតវ៉ាជារឿយៗរបស់ SRP ពីការផាត់ពួកខ្លួនចេញនៅក្នុងក្រុមប្រឹក្សាឃុំ ។ សកម្មជន SRP បានត្អូញត្អែរផងដែរ ពីសកម្មភាពរបស់ពួកប្រធានភូមិដែលគេចោទថា ធ្វើការទិញសន្លឹកឆ្នោត និងបំភិតបំភ័យ ។ ទំនាក់ទំនងរវាង FUNCINPEC និង CPP នៅកំរិតមូលដ្ឋាន ហាក់ដូចល្អជាងនេះច្រើនណាស់ក្នុងកន្លែងភាគច្រើន ។

ឃ. ឃុំករណីសិក្សានានាបង្ហាញថា ការពឹងផ្អែកយ៉ាងចំហនិងធ្ងន់ធ្ងររបស់ គឃប ទៅលើអាជ្ញាធរមូលដ្ឋានដែលអ្នកឆ្លើយសំភាសន៍ជាច្រើនបានចោទប្រកាន់នៅឆ្នាំ១៩៩៨, ហាក់ដូចបានបញ្ចប់ហើយ ។ គឃប បានអនុម័តប្រើយន្តការមួយចំនួន ដូចជា ការប្រជុំប្រចាំសប្ដាហ៍ជាដើម ដើម្បីធានាឱ្យគ្រប់គណបក្សអាចជួបទាក់ទងជាមួយខ្លួនបាន ។ ការប្រជុំប្រចាំសប្ដាហ៍ទាំងនេះ គឺជាកន្លែងចំបងសំរាប់ការគ្រប់គ្រងទំនាស់នៅកំរិតមូលដ្ឋាន ។ ប៉ុន្តែ ការដោះស្រាយទំនាស់តាមរយៈការសំរបសំរួលនៅក្នុងការប្រជុំទាំងនេះ មានជោគជ័យមិនទាន់ច្បាស់ទេ ។ ជាទូទៅ បុគ្គលិក គឃប និងសកម្មជន CPP និង FUNCINPEC វាយតំលៃវិជ្ជមានពីការប្រជុំ, ប៉ុន្តែ យើងរកឃើញករណីទំនាស់មួយចំនួនដែលមានរបាយការណ៍ខុសគ្នាជាខ្លាំង អំពីដំណោះស្រាយសំរេចបាន គឺបានសេចក្ដីថា គេមិនទាន់រកបានទេនូវការយល់ដឹងរួមគ្នាមួយអំពីស្ថានការណ៍ និងដំណោះស្រាយរបស់វា ។ ម្យ៉ាងវិញទៀត សកម្មជនរបស់ SRP នៅតែលើកឡើងពីការមិនទុកចិត្តកំរិតខ្ពស់ចំពោះ គឃប និងទំនាក់ទំនង គឃប ជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងគណបក្សនយោបាយ ហើយរឿងនេះប្រហែលជាធ្វើឱ្យខូចខាតដល់សិទ្ធិអំណាច គឃប ក្នុងការដោះស្រាយទំនាស់ ។ ការមិនទុកចិត្តនេះ ក៏ឃើញមានយ៉ាងច្បាស់នៅពេលរាប់សន្លឹកឆ្នោត ហើយជាពិសេសនៅកំរិតខេត្តដែលគេបូកសរុបសន្លឹកឆ្នោត ហើយតំណាងគណបក្សបានពិនិត្យឃើញតួលេខលំអៀងគ្នា រវាងប្រភពពតិមានខុសៗគ្នាស្ដីពីលទ្ធផលតាមឃុំ ។

ង. វិធានការកំណត់ក្នុងច្បាប់បោះឆ្នោត និងបទប្បញ្ញត្តិ គជប ដើម្បីធានាអព្យាក្រឹតភាពរបស់អាជ្ញាធរមូលដ្ឋាន បានជ្រាបយ៉ាងច្បាស់ទៅដល់កំរិតមូលដ្ឋាន ហើយអាជ្ញាធរឃុំ និងភូមិភាគច្រើនបានដឹងច្បាស់ពីវិធានផ្សេងៗជាប់ទាក់ទិននឹងការចូលរួមរបស់ពួកគេក្នុងការឃោសនានៅតាមមូលដ្ឋាន ។ ក្នុងឃុំករណីសិក្សានានា ជាទូទៅពួកគេចៀសវាងធ្វើការឃោសនាដោយចំហ ។ ការចោទថា ពួកគេបានធ្វើការឃោសនាជាលក្ខណៈឯកជន និងបានប្រើប្រាស់ការទិញសន្លឹកឆ្នោត និងការបំភិតបំភ័យ ដើម្បីរកបានការគាំទ្រពីអ្នកភូមិដែលភ័យខ្លាច គឺឃើញមានជាទូទៅក្នុងបណ្ដាឃុំករណីសិក្សា និងជាប្រភពដ៏សំខាន់នៃទំនាស់ ។ លក្ខណៈពហុបក្សនៃអាជ្ញាធរកំរិតឃុំ ហាក់ដូចមានផល

ប៉ះពាល់ខ្សោយទៅលើការគ្រប់គ្រងនៅមូលដ្ឋាន ។ ដោយឡែក សមាជិកក្រុមប្រឹក្សាឃុំ ខាង SRP រាយការណ៍ថា ពួកខ្លួនមានសិទ្ធិអំណាចតិចតួច និងមិនអាចជះឥទ្ធិពលអ្វីទៅលើការគ្រប់គ្រងនៅមូលដ្ឋានទេ ។

ច. ក្នុងឃុំករណីសិក្សានានា គ្មានទំនាស់ពីការរើសអើងប្រឆាំងនឹងសមាជិកគណបក្សជំទាស់ ឬ FUNCINPEC នៅពេលចុះបញ្ជីទេ ហើយក៏គ្មានទំនាស់ស្តីពីលទ្ធភាពធ្វើការឃោសនាដែរ ។

ជ. លទ្ធភាពទទួលពត៌មានពីការបោះឆ្នោត ប្រែប្រួលខុសគ្នាច្រើននៅក្នុងប្រទេសកម្ពុជា ។ នៅតំបន់ជនបទពត៌មានច្រើនទទួលបានពីអាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ហើយប្រភពទាំងពីរនេះត្រូវបានគ្របសង្កត់ដោយ CPP ។ គណបក្សនយោបាយនានាក៏ជាប្រភពពត៌មានដែរ ប៉ុន្តែ ពត៌មានផ្តល់ទៅឱ្យសកម្មជនគណបក្ស ក៏មានកំរិតមិនស្មើគ្នាដែរ ។ ការប្រជុំប្រចាំសប្តាហ៍របស់ គយប គឺជាវេទិកាដ៏សំខាន់មួយសំរាប់ការផ្លាស់ប្តូរពត៌មាន ។

ឈ. មានរបាយការណ៍ជាទូទៅពីកង្វះការជួបទាក់ទង រវាងអ្នកបោះឆ្នោត និងតំណាងនៅរដ្ឋសភា ហើយគេគិតថារឿងនេះវាប៉ះពាល់មិនល្អដល់ដំណើរការប្រជាធិបតេយ្យ ។

ជារួម ករណីសិក្សាកំរិតឃុំបានបង្ហាញថា នៅកំរិតឃុំ មានការលើកពីទស្សនៈប្លែកគ្នា និងមិនអាចចូលគ្នាបាន ស្តីពីនយោបាយកម្ពុជា ។ សកម្មជននៃគណបក្សខុសៗគ្នានៅកំរិតនេះ បានធ្វើការសន្មតខុសគ្នាពីព្រឹត្តិការណ៍ផ្សេងៗ ហើយក៏ទាញការសន្និដ្ឋានខុសគ្នាចេញពីការសន្មតទាំងនេះ ទៅតាមចំណងភក្តីភាពរបស់ពួកគេខាងនយោបាយ ។

កង្វះទំនុកចិត្តជាទូទៅរបស់សមាជិក SRP ចំពោះ គយប គឺជាឧទាហរណ៍មួយក្នុងរឿងនេះ ។ កង្វះទំនុកចិត្តផ្អែកលើការសន្មតថា សមាជិក គយប ដែលជាគ្រូបង្រៀន ត្រូវពឹងផ្អែកលើ CPP, ប្រហែលត្រូវ CPP គាបសង្កត់, និងប្រហែលជាទោទន់ទៅតាមការគាបសង្កត់នេះ ។ ដូច្នេះហើយ បរាជ័យ ឬកំហុសផ្សេងៗរបស់ គយប ពួកសកម្មជនមើលឃើញជាបញ្ហានយោបាយ ។ ផ្ទុយទៅវិញ អាជ្ញាធរមូលដ្ឋាននិងសមាជិកនានានៃ គយប គេពិពណ៌នា គយប ជាអង្គភាពឯករាជ្យមួយរបស់រដ្ឋដែលគ្រាន់តែជួបការលំបាកនៃកង្វះធនធាន និងក្នុងករណីខ្លះ ការពិបាកធ្វើការជាមួយគណបក្សនយោបាយដែលគ្មានជំហរធ្វើសហប្រតិបត្តិការ ។

ដូចគ្នាដែរ មានការសន្មតឡើងដោយខុសៗគ្នាអំពីមជ្ឈដ្ឋានអ្នកបោះឆ្នោត ។ សំរាប់ CPP ពួកអ្នកបោះឆ្នោតជួបឧបសគ្គក្នុងការអនុវត្តនីកាតព្វកិច្ចនយោបាយ ដោយសារការងារដ៏មមាញឹករបស់ខ្លួន ជាពិសេសនៅរដូវភ្លៀង ។ ទោះយ៉ាងនេះក្តី ពួកគេជាអ្នកប្រជាធិបតេយ្យដែលគិតពីលទ្ធផល និងដែលដឹងច្បាស់ថា គណបក្សណាជួយពួកគេ និងគណបក្សណាគ្រាន់តែថា ។ សំរាប់ SRP មជ្ឈដ្ឋានអ្នកបោះឆ្នោត គឺជាមហាជនមួយក្រុមដែលមានការភ័យខ្លាចដែលចង់រំដោះខ្លួន, ប៉ុន្តែដែលត្រូវរារាំងមិនឱ្យចូលរួមសកម្មក្នុងការងារនយោបាយ ដោយសារបណ្តាញតាមដានដ៏តឹងរ៉ឹងរបស់គណបក្ស ដែលដំណើរការដោយពួកប្រធានភូមិដោយមានយ៉ាងហោចណាស់ការឃុបឃិតពីអាជ្ញាធរឃុំ និងគណបក្សផង ។

ការសន្មតទាំងនេះធ្វើឱ្យគណបក្សផ្សេងៗមើលឃើញខុសគ្នាខ្លាំងណាស់អំពីសកម្មភាពរបស់ប្រធានភូមិ ។ សំរាប់ CPP ប្រធានភូមិគឺជាអាជ្ញាធរអព្យាក្រឹត្យ ហើយសកម្មភាពផ្សេងៗដូចជា ការកត់ត្រាលេខចុះបញ្ជីអ្នកបោះឆ្នោត ឬការរង់ចាំខាងក្រៅការិយាល័យបោះឆ្នោតរកមើលអ្នកណាមិនទាន់បោះឆ្នោត និងទៅតាមហៅពួកគេឱ្យមកបោះឆ្នោត, វាជាការបំពេញការងារជាសារវន្តជួយដល់ពួកអ្នកបោះឆ្នោត ឱ្យបានយល់ពីតួនាទីរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ។ សំរាប់ SRP សកម្មភាពបែបនេះគឺជាចំណែកមួយនៃការពិនិត្យតាមដានដែលធ្វើឱ្យអ្នកបោះឆ្នោតភ័យខ្លាច ចុះញ៉ម និងប្រហែលបាត់សេចក្តីក្លាហាននឹងបោះឆ្នោតឱ្យគណបក្សជំទាស់ ។ ការលើកមតិរបស់ប្រធានភូមិចំពោះអ្នកបោះឆ្នោត ដូចជា "បើសិនអ្នកចូលគណបក្ស SRP នឹងគ្មានការអភិវឌ្ឍន៍ទេ" ...អាចបកស្រាយជាការពិភាក្សាពីកម្មវិធីនយោបាយរបស់គណបក្សនានាដោយគ្មានគំនិតគេងចំណេញអ្វី ឬក៏ជា

ការគំរាមកំហែងផាត់ចេញពីសង្គម ប្រឆាំងនឹងអ្នកគាំទ្រគណបក្សជំទាស់ ។ ក្នុងការបោះឆ្នោតឆ្នាំ២០០៣ គជប បានទទួលស្គាល់នូវការព្រួយបារម្ភរបស់គណបក្សជំទាស់ និងបានខិតខំហាមឃាត់សកម្មភាព និងការនិយាយបែបនេះ ។ ការស្រាវជ្រាវដល់កន្លែងរបស់យើងបានបង្ហាញភស្តុតាងថា សេចក្តីណែនាំចុះថ្ងៃទី១៧ ខែកក្កដា នៅតែមានការបកស្រាយខុសគ្នាខ្លាំងណាស់ពីសំណាក់សកម្មជនគណបក្សផ្សេងៗ ។ ទស្សនៈខុសៗគ្នាបែបនេះស្តីពីនយោបាយកម្ពុជា បានបើកផ្លូវឱ្យទំនាស់ផុសឡើងនៅគ្រប់កំរិតនៃដំណើរការបោះឆ្នោត ជាពិសេសក្នុងការងារដ៏ស្មុគស្មាញនៃការរាប់ និងបូកសន្លឹកឆ្នោត ។

ទស្សនៈខុសគ្នាយ៉ាងខ្លាំងរវាង CPP និង SRP ស្តីពីការបោះឆ្នោត ជាពិសេសនៅកំរិតឃុំ គឺនៅតែមាន ថ្វីបើមានច្រកប្រសើរជាងមុនសំរាប់កិច្ចសន្ទនារវាងគណបក្សនយោបាយនានា ។ ធៀបនឹងឆ្នាំ១៩៩៨ ទំនាក់ទំនងរវាង CPP និង FUNCINPEC ហាក់ដូចល្អជាងមុនច្រើន ជាពិសេសនៅឃុំពាមឯក ត្នោត និងវាលវង់ ដែលប្រហែលជាឆ្លុះបញ្ចាំងពីបទពិសោធន៍នៃការរួមរស់ជាមួយគ្នាក្នុងរដ្ឋាភិបាលកំរិតជាតិតាំងពីឆ្នាំ១៩៩៨-២០០៣ ។

ការរួមរស់ក្នុងក្រុមប្រឹក្សាឃុំ ហាក់ដូចគ្មានឥទ្ធិពលដូច្នេះទេក្នុងទំនាក់ទំនងរវាង SRP និង CPP, តែហាក់ដូចនាំឱ្យមានការចោទប្រកាន់ដោយ SRP ថា ពួកអ្នកកាន់អំណាចជា CPP បានផាត់ពួកខ្លួនចេញ ។ ប៉ុន្តែអ្នកឆ្លើយសំភាសន៍ជាច្រើននាក់បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំមិនទាន់មានដំណើរការពេញលេញទេ ហើយរឿងនេះប្រហែលក្លាយជាកំលាំងមួយនាំឱ្យមានការផ្លាស់ប្តូរទៅអនាគត ដែលអាចជាប្រធានបទសំរាប់ការស្រាវជ្រាវនៅពេលក្រោយ ។ ដូចគ្នាដែរ ចលនា FUNCINPEC ឃ្លាតចេញពីសម្ព័ន្ធភាពជាមួយ CPP ទៅធ្វើសម្ព័ន្ធភាពជាមួយ SRP វិញ អាចធ្វើឱ្យខូចខាតដល់ទំនាក់ទំនងរវាង CPP និង FUNCINPEC នៅកំរិតមូលដ្ឋាន ។ ការសិក្សានេះ អាចជាចំណុចចាប់ផ្តើមមួយសំរាប់ធ្វើការប្រៀបធៀបរយៈពេលវែងអំពីទំនាក់ទំនងរវាងគណបក្សនយោបាយនានានៅកំរិតជាតិ និងកំរិតមូលដ្ឋាន ដើម្បីស្វែងរកកត្តាផ្សេងៗ ដែលជំរុញឱ្យមានការផ្សះផ្សារគ្នា ។

# ជំពូកទី ៤

# ការគ្រប់គ្រងទំនាស់នៅកម្រិតជាតិ
# ~ ករណីសិក្សា

## ៤.១ ទំនាស់ស្តីពីការចុះបញ្ជី

### *៤.១.១ ក្របខ័ណ្ឌច្បាប់*

ក្របខ័ណ្ឌច្បាប់សំរាប់ការចុះបញ្ជីអ្នកបោះឆ្នោតជាអចិន្ត្រៃយ៍ មានចែងក្នុងជំពូក៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចុះថ្ងៃទី២១ សីហា ២០០២ ។ គោលដៅចំបងនៃកំណែទំរង់ច្បាប់ គឺសេចក្តីចែងពីការបង្កើត និងការកាន់កាប់នូវបញ្ជីអចិន្ត្រៃយ៍នៃអ្នកបោះឆ្នោត ដែលត្រូវរក្សាទុកនៅការិយាល័យឃុំ/សង្កាត់ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដោយស្មៀនឃុំ (មាត្រា៤៨) ។ ច្បាប់ចែងថា បញ្ជីបោះឆ្នោតត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ចាប់ពីខែតុលា ដល់ខែធ្នូ នៃឆ្នាំនីមួយៗ (មាត្រា៤៩) ។ បញ្ជីបោះឆ្នោតត្រូវចំលងជូន គជប ដែលមានភារកិច្ចផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតជាផ្លូវការ ៩០ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត (មាត្រា៤៨) ។

ក្នុងប្រព័ន្ធថ្មីនេះ បុគ្គលត្រូវចុះបញ្ជីបោះឆ្នោតនៅក្នុងឃុំ/សង្កាត់ដែលខ្លួនរស់នៅ (មាត្រា៥០) ។ ពួកគេត្រូវបញ្ជាក់ពីទីលំនៅ អត្តសញ្ញាណ អាយុ និងសញ្ជាតិ ដោយបង្ហាញឯកសារនានាដែលស្រង់ចេញពីបញ្ជីមានការទទួលស្គាល់ ។ ចំពោះបុគ្គលដែលគ្មានឯកសារសមស្រប អាជ្ញាធរឃុំ/សង្កាត់ អាចចេញលិខិតបញ្ជាក់ឱ្យ (មាត្រា៥៤) ។ នៅពេលចុះបញ្ជី គេប្រាប់អ្នកបោះឆ្នោតពីការិយាល័យដែលត្រូវទៅបោះឆ្នោត ហើយគណបក្សនយោបាយទាំងអស់អាចទទួលបានបញ្ជីអ្នកបោះឆ្នោត និងបញ្ជីការិយាល័យបោះឆ្នោតដោយបង់ប្រាក់កំរៃមួយចំនួនតូច (មាត្រា៨៧) ។ នៅពេលបញ្ចប់ការចុះបញ្ជី មានបិទផ្សាយជាសាធារណៈនៅឃុំ/សង្កាត់នូវបញ្ជីបោះឆ្នោតដំបូង ដើម្បីឱ្យអ្នកបោះឆ្នោតអាចផ្ទៀងផ្ទាត់ថា ពត៌មានលំអិតផ្សេងៗលើខ្លួនគេ បានកត់ត្រាត្រឹមត្រូវហើយ (មាត្រា៦៣) ។ អ្នកណាមួយដែលមិនពេញចិត្តនឹងការចុះបញ្ជីរបស់ខ្លួន ឬរបស់អ្នកណាទៀត អាចប្តឹងតវ៉ាបាន ដំបូងទៅក្រុមប្រឹក្សាឃុំ/សង្កាត់ បន្ទាប់មកទៅ គជប និងក្រុមប្រឹក្សាធម្មនុញ្ញ (មាត្រា ៦៤, ៦៥, ៦៦) ។ អ្នកគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលបិទនៅការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត គឺពុំអាចបោះឆ្នោតបានទេ ទោះបីជាមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្តី (មាត្រា៩៨) ។

### *៤.១.២ ស្ថាប័ននានា*

#### *៤.១.២.១ ស្ថានភាពក្រុមប្រឹក្សាឃុំនៅឆ្នាំ២០០៣*

ជាលក្ខណៈទ្រឹស្តី ការផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាធរឃុំកាន់កាប់សៀវភៅបញ្ជីអ្នកបោះឆ្នោត គឺជាទង្វើដ៏សមស្រប ដោយគេបានដាក់ការទទួលខុសត្រូវអនុវត្តភារកិច្ចនេះនៅកម្រិតដ៏សមរម្យបំផុត ពីព្រោះក្រុមប្រឹក្សាឃុំជារដ្ឋអំណាចផ្លូវការកំរិតទាបបំផុត ដែលជាទូទៅប្រជាជនអាចមកទាក់ទងបាន និងដែលមានតួនាទីចុះបញ្ជីច្រើនទៀត ជាយូរមកហើយ ដូចជាចុះបញ្ជីកំណើត

មរណភាព និងអាពាហ៍ពិពាហ៍ជាដើម ។ ផ្ទុយទៅវិញ អាជ្ញាធរស្រុក និងខេត្ត អ្នកភូមិតែងមើលឃើញថានៅឆ្ងាយ រីឯអាជ្ញាធរភូមិមានការរៀបចំមិនសូវផ្លូវការ និងគ្មានលក្ខណៈសម្បត្តិ និងធនធានសំភារៈ (ការិយាល័យ...) ជាមន្ត្រីរាជការទេ ។ ម្យ៉ាងទៀត ការបោះឆ្នោតឃុំនាពេលថ្មីៗនេះ បានធ្វើឱ្យគណបក្សធំៗទាំងបីមានតួនាទីក្នុងរដ្ឋអំណាចឃុំ ហើយរឿងនេះគេរំពឹងថាក្នុងរយៈពេលវែងវានឹងជួយកាត់បន្ថយទំនាស់ក្នុងការចុះបញ្ជីអ្នកបោះឆ្នោត ដោយវាផ្តល់ឱ្យគ្រប់គណបក្សនូវសិទ្ធិអំណាចក្នុងការពិនិត្យពិច័យលើនីតិវិធីនៃការកាន់កាប់បញ្ជីបោះឆ្នោត ។

ក្នុងពេលជាមួយគ្នា ការបែងចែកការទទួលខុសត្រូវនៅរដ្ឋអំណាចក៏រិតនេះអាចមានគ្រោះថ្នាក់ ដោយសារក្រុមប្រឹក្សាឃុំទើបបង្កើតបានប្រហែលមួយឆ្នាំទេ នៅពេលដែលត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៅឆ្នាំ២០០២ ។ ក្នុងការសិក្សាជាដំបូងៗស្តីពីប្រតិបត្តិការក្រុមប្រឹក្សាឃុំ គឺមានការទទួលស្គាល់ជាទូទៅថា ១) ក្រុមប្រឹក្សាឃុំមិនទាន់មានគំនិតច្បាស់លាស់ទេពីនីតិវិធី និងទិសដៅរបស់ខ្លួន, ២) មិនទាន់មានការបើកផ្តល់មូលនិធិសំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗសំរាប់ឱ្យក្រុមប្រឹក្សាឃុំអនុវត្តសិទ្ធិអំណាចរបស់ខ្លួន, និង ៣) ទំនាក់ទំនងរវាងសមាជិកក្រុមប្រឹក្សាឃុំជាមួយមេឃុំ និងស្មៀនឃុំ និងរវាងគណបក្សនានាមិនទាន់កសាងបានល្អទេ ។ ករណីសិក្សាក៏រិតឃុំរបស់យើងបានបង្ហាញថា ទំនាក់ទំនងក្នុងក្រុមប្រឹក្សាឃុំ ជាពិសេសរវាង CPP និង SRP គឺនៅទន់ខ្សោយ ហើយសមាជិកក្រុមប្រឹក្សាខាង SRP មានអារម្មណ៍ថា ខ្លួនត្រូវគេផាត់ចោលក្នុងការធ្វើសេចក្តីសំរេចផ្សេងៗ ។ ការផ្ទេរការងារចុះបញ្ជីអ្នកបោះឆ្នោតទៅឱ្យអាជ្ញាធរក៏រិតនេះ គឺជាការផ្ទេរវាទៅឱ្យស្ថាប័នរដ្ឋមួយដែលមិនទាន់រៀបចំ និងសំរបសំរួលបានល្អទេ ។

តំណាង គជប ថ្នាក់ខ្ពស់ម្នាក់បានលើកពីបញ្ហាទាំងនេះថាៈ

*"មានបញ្ហាចោទមួយចំនួនៈ ក្រុមប្រឹក្សាឃុំមិនទាន់មានបទពិសោធន៍សោះ ក្នុងការរៀបចំការបោះឆ្នោត ។ សមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំមិនបានស្មើគ្នាល្អទេ ជាពិសេសសមត្ថភាពមេឃុំ ជំទប់ទី១ ជំទប់ទី២ និងស្មៀនឃុំ ។ ម្យ៉ាងទៀត ពួកគេរវល់ខ្លាំងណាស់ ពីព្រោះមានការងារច្រើនត្រូវធ្វើ ហើយមិនបានយកចិត្តទុកដាក់ច្រើនទេដល់ការចុះបញ្ជីអ្នកបោះឆ្នោត ។ ប៉ុន្តែសំរាប់ស្មៀនឃុំ គឺគ្មានបញ្ហាទេៈ ស្មៀនឃុំបានទទួលការបណ្តុះបណ្តាល និងមានភារកិច្ចធ្វើការងារនេះ ។ ដូច្នេះ យើងបានចេញបទបញ្ជាខ្លះដើម្បីជួយគេ និងដើម្បីពិនិត្យតាមដានបញ្ជីបោះឆ្នោត យើងបានជ្រើសជួលជំនួយការស្មៀនឃុំ ។ ប៉ុន្តែយើងជួបបញ្ហាខ្លះៗ ជាពិសេសនៅតំបន់ឆ្ងាយដាច់ស្រយាលខាងឦសានៈ រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ។ យើងបញ្ជូនមន្ត្រីពីថ្នាក់ខេត្តឱ្យទៅជួយ ពីព្រោះប្រជាជននៅទីនោះជាកុលសម្ព័ន្ធតំបន់ភ្នំ"*[១២៧] ។

ការអធិប្បាយខាងលើ បានបង្ហាញពីបញ្ហាជាក់លាក់មួយចំនួន ។ ការសង្កត់ធ្ងន់លើស្មៀនឃុំ និងជាពិសេសការជ្រើសតាំងជំនួយការស្មៀនឃុំ បានបង្ហាញពីការពឹងផ្អែកលើនិយោជិករបស់ក្រសួងមហាផ្ទៃ ជាជាងលើអ្នកតំណាងជាប់ឆ្នោត ដើម្បីបំពេញភារកិច្ចចុះបញ្ជីអ្នកបោះឆ្នោត ។ គេមើលឃើញវិធីនេះថា ចាំបាច់យោងតាម "សមត្ថភាព" ទន់ខ្សោយនៃសមាជិកក្រុមប្រឹក្សាឃុំ ។ រឿងនេះជាការប្រទាំងប្រទើសគ្នាមួយរវាងគោលដៅធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានលក្ខណៈប្រជាធិបតេយ្យ និងគំរូការរៀបចំព្រឹត្តិការណ៍នយោបាយក៏រិតជាតិ ដូចជាការបោះឆ្នោតឱ្យមានប្រសិទ្ធភាពជាដើម ។ ដោយឡែក គំរូវិការកេណ្ឌប្រមូលមន្ត្រីក៏រិតខេត្តនៅភាគឦសាន មកជួយចុះបញ្ជី ប្រជាជនជាកុលសម្ព័ន្ធតំបន់ភ្នំ បានបង្ហាញពីកង្វះការប្រស្រ័យទាក់ទង រវាងអាជ្ញាធរមូលដ្ឋាន និងជនជាតិភាគតិច ទោះបីមានការខិតខំធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានលក្ខណៈប្រជាធិបតេយ្យក្តី ។

---

[១២៧] NEC representative (8), personal interview, Phnom Penh, 5 Oct 2003.

ដូចគ្នាដែរ គជប ទទួលស្គាល់ថា សមត្ថភាព និងឆន្ទៈរបស់ស្មៀនឃុំដើម្បីអនុវត្តដំណើរការចុះបញ្ជីឱ្យបានសក្តិសិទ្ធិ ក៏មិនអាចទុកចិត្តបានដែរនៅកន្លែងខ្លះ ។ ឯ.ឧ ទេព នីថា អគ្គលេខាធិការ គជប បានលើកក្នុងពេលប្រជុំ COPCEL នាខែមករា ២០០៣ នៅចុងថ្ងៃទី១ នៃរយៈពេលសំរាប់ចុះបញ្ជីអ្នកបោះឆ្នោតថ្មីថា ស្មៀនឃុំមានការជាប់រវល់បំពេញភារកិច្ចផ្សេងៗទៀត ហើយក្នុងករណីមួយចំនួន មានសមត្ថភាពមិនគ្រប់គ្រាន់ដើម្បីអាចយល់បានពីកម្មវិធីបណ្តុះបណ្តាលរបស់ គជប, ព្រមទាំងខ្វះខាតការប្តេជ្ញាចិត្តដើម្បីអនុវត្តដំណើរការចុះបញ្ជី ពីព្រោះពួកគេគ្មានបានទទួលប្រាក់អ្វីដោយឡែកទេសំរាប់ធ្វើការងារនេះ គឺដូចបុគ្គលិកឯទៀតនៃ គជប[១២៨] ។

ការពឹងផ្អែកលើបុគ្គលិកក្រោមឱវាទក្រសួងមហាផ្ទៃ ដើម្បីធ្វើការអប់រំអ្នកបោះឆ្នោត ទាមទារឱ្យមានទំនាក់ទំនងធ្វើការងារយ៉ាងជិតស្និទ្ធរវាង គជប និងក្រសួងនេះ ។ ពួកសមាជិក គជប បានរាយការណ៍ពីការកែលំអក្នុងទំនាក់ទំនងនេះនៅឆ្នាំ២០០៣ បើធៀបនឹងការបោះឆ្នោតលើកមុនៗ ប៉ុន្តែអ្នកឆ្លើយសំភាសន៍ជាសមាជិក NGOs និងគណបក្សនយោបាយ មានអារម្មណ៍ថា ក្រសួងមហាផ្ទៃមិនសូវឯករាជ្យ ទាក់ទង និងមានគណនេយ្យភាពដូច គជប ទេ ។ ដូចគ្នាដែរ ក្នុងការវាយតំលៃលើខ្លួនឯងនៅក្នុងដំណើរការបោះឆ្នោត គជប បានមើលឃើញការប្រឹងប្រែងរបស់ខ្លួន ដើម្បីត្រួតពិនិត្យការចុះបញ្ជីបោះឆ្នោតថាមានការខ្វះចន្លោះ ហើយបានគូសចំណាំថា ទំនាក់ទំនងរវាង គជប និងអាជ្ញាធរឃុំដែលទទួលបន្ទុកការងារចុះបញ្ជី គឺជាចំណុចសំខាន់មួយសំរាប់ធ្វើការកែលំអក្នុងពេលអនាគត ។

សមាជិក គជប ម្នាក់លើកឡើងថា:

*"យើងអាចមើលឃើញតាមការចុះបញ្ជីបោះឆ្នោតថា បើសិនយើងប្រើប្រាស់ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ យើងអាចសំចៃប្រាក់ ប៉ុន្តែពួកគេថ្មីថ្មោង ពួកគេពាក់មួកពីរ ហើយយើងមានការពិបាកដើម្បីពិនិត្យតាមដានដំណើរការ បើធៀបនឹងស្ថានភាពមុនពេលយើងធ្វើការត្រួតពិនិត្យដោយផ្ទាល់ ។ សព្វថ្ងៃយើងត្រូវឆ្លងតាមក្រសួងមហាផ្ទៃ ។ ឥឡូវនេះ យើងរៀនសូត្របានហើយពីរឿងនេះ ហើយយើងនឹងធ្វើអនុសាសន៍សំរាប់ការសើរើពិនិត្យឡើងវិញពីការចុះបញ្ជី[១២៩]* ។

ថ្វីបើមានការបារម្ភដូច្នេះក្តី ប៉ុន្តែគួរកត់សំគាល់ថា ការស្រាវជ្រាវនៅកំរិតឃុំសំរាប់ការសិក្សានេះ បានបង្ហាញពីបញ្ហាចោទទាក់ទិននឹងការចុះបញ្ជីអ្នកបោះឆ្នោត មានចំនួនតិចតួចណាស់ ។ សកម្មជន SRP នៅខេត្តកំពតម្នាក់បានលើកពីបញ្ហានេះថា:

*"នៅពេលចុះបញ្ជីមានបញ្ហាចោទ ។ បើសិនអ្នកណាគ្មានប័ណ្ណ ហើយមន្ត្រីឃុំដឹងថា អ្នកនោះគាំទ្រ SRP ពួកគេមិនឱ្យអ្នកនោះចុះបញ្ជីទេ ។ ពួកគេបង្កើតបញ្ហា ដូច្នេះអ្នកនោះត្រូវតែទៅកន្លែងមួយទៀត ហើយពួកគេមិនអាចទៅណាបានទេ ។ ប៉ុន្តែចំពោះអ្នកដែលគាំទ្រ ពួកគេនឹងដឹកអ្នកនោះទៅ ។ ពួកគេដឹងថាអ្នកណាគាំទ្រអ្នកណា: ឧទាហរណ៍ ពួកគេដឹងថា ជននេះតែងទៅចូលរួមប្រជុំ SRP ។ ដូច្នេះ ជននោះនឹងជួបរឿងរំខាន ហើយ[១៣០]* ។

គឃប ក្នុងឃុំករណីសិក្សាទាំងពីរនៅបាត់ដំបងក៏បានលើកឡើងនូវការបារម្ភពីការពិបាកពិនិត្យតាមដានដំណើរការដែរ ។ អ្នកតាមដានការបោះឆ្នោតបានលើកពីការបារម្ភចំពោះការចុះបញ្ជីកំរិតទាប និងបានស្នើសុំការពន្យាពេល ហើយ គជប ក៏បានយល់ព្រមដូចការបោះឆ្នោតលើកមុនៗដែរ ។ ប៉ុន្តែនៅមុនថ្ងៃបោះឆ្នោត មានការចាប់អារម្មណ៍តិចតួចណាស់ថា អ្នកបោះឆ្នោតអាចមានការបាត់បង់សិទ្ធិច្រើនគួរកត់សំគាល់ជាងការបោះឆ្នោតលើកមុនៗ ។ ចំពោះបញ្ហាថា មានការលំអៀងជាប្រព័ន្ធមួយ

---

[១២៨] Minutes of the 42nd COPCEL meeting, Phnom Penh, 30 Jan 2003.

[១២៩] NEC member (51), personal interview, Phnom Penh, 5 Oct 2003.

[១៣០] SRP provincial activist (52), Kampot Province, personal interview, 16 July 2003.

ចំនួនត្រូវបានគេដាក់បញ្ចូលទៅក្នុងដំណើរការបោះឆ្នោត គឺគ្មាននរណាលើកឡើងទេ រហូតដល់ពេលគណបក្សនានាបានសង្កេតឃើញពីករណីដែលអ្នកគាំទ្ររបស់ខ្លួនអាចបោះឆ្នោតបាននៅថ្ងៃបោះឆ្នោត ។ យើងរកឃើញថា អាជ្ញាធរឃុំមានការរើសអើងតិចតួចណាស់ប្រឆាំងនឹងអ្នកគាំទ្រគណបក្សជំទាស់ ជាពិសេសក្នុងឃុំពហុបក្ស ដែលជាឃុំករណីសិក្សាភាគច្រើនរបស់យើង ពីព្រោះបើមិនដូច្នេះទេ មុខជាមានអ្នកគាំទ្រគណបក្ស ប្តឹងតវ៉ាតាមរយៈតំណាងរបស់ខ្លួនក្នុងក្រុមប្រឹក្សាឃុំ និងមានរបាយការណ៍ពីសមាជិកក្រុមប្រឹក្សាឃុំទៅដល់ទីស្នាក់ការគណបក្សហើយ ។

ក្រោយពីបានសង្កេតឃើញសភាពការណ៍នៅថ្ងៃបោះឆ្នោត ទំនាស់ក៏ផុសឡើងដោយគណបក្សជំទាស់អះអាងថា មានការរើសអើងជាសំងាត់ប្រឆាំងនឹងពួកសមាជិកខ្លួន ដែលមិនមែនជាការធ្វើសកម្មភាពរារាំងមិនឱ្យចុះបញ្ជីនោះទេ ប៉ុន្តែដោយការបំបិទលទ្ធភាពទទួលបានពត៌មាន ជាពិសេសពត៌មានផ្តល់ដោយប្រធានភូមិ ដែលអាចជួយឱ្យពួកគេបានបោះឆ្នោត ។ ការអះអាងពីការចែកចាយពត៌មានមិនស្មើភាព ដើម្បីផាត់ចេញពួកអ្នកគាំទ្រគណបក្សជំទាស់ គឺផ្អែកលើចំណាប់អារម្មណ៍ជាយូរមកហើយថា នៅកម្ពុជាពុំមានការបែងចែកដាច់រវាងគណបក្ស និងរដ្ឋ ។ ការបារម្ភនេះដែលមានតាំងពីការបោះឆ្នោតឆ្នាំ១៩៩៣ រៀបចំដោយ UNTAC, និងដែលបានពិនិត្យឃើញច្រើនដែរ ក្នុងការសិក្សារបស់ វិបសអ ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨, វាជាប់ទាក់ទិននឹងរឿងថា នៅពេលក្បាលម៉ាស៊ីនរដ្ឋត្រូវបានកសាងឡើងក្នុងទសវត្សរ៍១៩៨០ វាមានលក្ខណៈជារដ្ឋមានគណបក្សតែមួយ ដោយក្នុងនេះគេរំពឹងថា មន្ត្រីរបស់រដ្ឋនឹងរក្សាភក្តីភាពយ៉ាងរឹងមាំចំពោះគណបក្សកាន់អំណាច ។ ដូច្នេះហើយនៅតែមានការបារម្ភថា ភក្តីភាពនេះ មិនគ្រាន់តែស្ថិតក្នុងសតិអារម្មណ៍របស់បុគ្គលប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់ការបំពេញតួនាទីជាផ្លូវការ ហើយក៏មានការរើសអើងប្រឆាំងនឹងអ្នកគាំទ្រគណបក្សជំទាស់ ។

*៤.១.២.២ តួនាទីរបស់ប្រធានភូមិ*

ជាផ្លូវការ ការចុះបញ្ជី គឺជាភារកិច្ចរបស់អាជ្ញាធរឃុំ ប៉ុន្តែក្នុងដំណើរការនេះ ប្រធានភូមិមានតួនាទីយ៉ាងសំខាន់ ។ គជប ពិនិត្យឃើញថា ប្រធានភូមិគឺជាប្រភពពត៌មានសំខាន់បំផុតស្តីពីការបោះឆ្នោតសំរាប់ ២/៣ នៃប្រជាជនដែលមិនចេះអក្សរអាចប្រើការបាន ។ អង្កេតលើអ្នកបោះឆ្នោតធ្វើដោយអង្គការមូលនិធិអាស៊ី ក៏រកឃើញដែរថា ប្រធានភូមិ គឺជា "ប្រភពពត៌មានសំខាន់បំផុតស្តីពីការបោះឆ្នោត និង... ជាប្រភពមានប្រជាប្រិយភាពបំផុតសំរាប់ការអប់រំអ្នកបោះឆ្នោត"[១៣១] ។ ករណីសិក្សាករិតឃុំរបស់យើង ក៏ផ្តល់លទ្ធផលស្របគ្នាដែរ ។ ដូចមានលើកក្នុងរបាយការណ៍នេះរួចហើយ បញ្ហាបែងចែកដាច់រវាងរដ្ឋ-គណបក្សបានផុសឡើងយ៉ាងច្បាស់បំផុតទាក់ទិននឹងតួនាទីអាជ្ញាធរភូមិនេះ ។ សមាជិក គជប ម្នាក់លើកឡើងថា ក្នុងសន្និសីទវាយតំលៃលើខ្លួនឯងរបស់ គជប, ពួកសមាជិក គជប បានជជែកវែកញែកឱ្យមានការកំណត់តួនាទីជាផ្លូវការរបស់ប្រធានភូមិក្នុងដំណើរការចុះបញ្ជីបោះឆ្នោត ។ គាត់លើកឡើងថា:

> *"យើងគួរបណ្តុះបណ្តាលប្រធានភូមិឱ្យទទួលបន្ទុកការងារ ពីព្រោះពួកគេស្គាល់ប្រជាជនច្បាស់ណាស់ ។ ពួកគេដឹងថា អ្នកណាអាយុ ១៨ឆ្នាំ អ្នកណាចេញ អ្នកណាចូល ។ ដូច្នេះហើយ អ្នកចូលរួមសន្និសីទបានផ្តល់មតិថា ប្រធានភូមិគួរធ្វើរឿងនេះ ។ យើងគិតដែរថា ជាការប្រសើរបើសិនប្រធានភូមិទទួលបន្ទុកជួយក្រុមប្រឹក្សាឃុំក្នុងការធ្វើបច្ចុប្បន្នភាពស្ថិតិ: ប្រព័ន្ធដដែល ប៉ុន្តែកែសំរួលបន្តិចដើម្បីកែលំអបច្ចេកទេសយើង"*[១៣២] ។

ក្នុងពេលជាមួយគ្នានេះ សមាជិក គជប លើកឡើងអំពីសារៈសំខាន់នៃការបោះឆ្នោតជ្រើសរើស ឬការតែងតាំងប្រធានភូមិឡើងវិញ:

---

[១៣១] Asia Foundation, "Democracy in Cambodia –2003, A Survey of the Cambodian Electorate" Draft Report, Phnom Penh, 16 May 2003, 14.

[១៣២] NEC member (51), personal interview, Phnom Penh, 5 Oct 2003.

*"តួនាទីមិនផ្លូវការសព្វថ្ងៃ និងតួនាទីផ្លូវការអ្វីមួយទៅអនាគតរបស់ប្រធានភូមិក្នុងដំណើរការចុះបញ្ជីវាបំផុសឡើងនូវបញ្ហាការបែងចែកដាច់រវាងរដ្ឋ និងគណបក្ស ។ តើត្រូវបោះឆ្នោតជ្រើសរើសប្រធានភូមិ ឬយ៉ាងណា ត្រូវមានការវាយតំលៃយ៉ាងល្អិតល្អន់ពីឥរិយាបថរបស់ប្រធានភូមិចំពោះសមាជិកគណបក្សភាគតិចនានា សំដៅការពារសិទ្ធិរបស់ពួកគេ ដើម្បីចូលរួមក្នុងការបោះឆ្នោត"*[១៣៣] ។

អ្នកឆ្លើយសំភាសន៍មកពី គជប ខ្លះទៀត មើលឃើញខុសគ្នានូវបញ្ហាពត៌មាន ដែលគេចាត់ទុកជារឿងពហុបក្ស ជាជាងរឿងសិទ្ធិ ។ ឧទាហរណ៍ មន្ត្រីថ្នាក់ខ្ពស់ម្នាក់ខាងផ្នែកបណ្តុះបណ្តាល និងផ្សព្វផ្សាយសាធារណៈ បានវែកញែកថា ការធ្វើប្រជាធិបតេយ្យូបនីយកម្មនៃរដ្ឋអំណាចក៏រិតឃុំ បានអនុញ្ញាតឱ្យគណបក្សទាំងអស់មានកន្លែងឈរជើងនៅក្នុងឃុំ ហើយតាមរយៈនេះបានបង្កើតប្រភពពត៌មានច្រើនសំរាប់អ្នកបោះឆ្នោតៈ

*"ក្រោយពីការបោះឆ្នោតឃុំ មានគណបក្សបីនៅក្នុងក្រុមប្រឹក្សាឃុំ ។ យើងជឿថា បើសិនមានគណបក្សទាំងបីក្នុងក្រុមប្រឹក្សាឃុំ ហេតុអ្វីក៏គណបក្សឯទៀតៗមិនទៅផ្តល់ពត៌មានផង? បើសិនមានតែ CPP នៅក្នុងឃុំ វាជារឿងមួយ ប៉ុន្តែគេមិនអាចនិយាយថា មានតែ CPP ទេដែលអាចផ្តល់ពត៌មានបាន ។ SRP និង FUNCINPEC ជាសមាជិកក្រុមប្រឹក្សាឃុំដូចគ្នា ដូច្នេះពួកគេក៏មានសិទ្ធិផ្សព្វផ្សាយដែរ ។ ពួកគេអាចធ្វើការផ្សព្វផ្សាយតាមរយៈគណបក្ស"*[១៣៤] ។

ទិដ្ឋភាពសំខាន់មួយនៃទំនាស់នេះ គឺបញ្ហាអ្នកណាមានភារកិច្ចផ្តល់ពត៌មានដល់អ្នកបោះឆ្នោត ។ បើសិនរដ្ឋ មានភារកិច្ចនេះ ដូច្នេះ គជប ត្រូវអនុវត្តវា ឬមួយដោយផ្ទាល់តាមរយៈកម្មវិធីនានារបស់ខ្លួន ឬមួយតាមការត្រួតពិនិត្យយ៉ាងជិតដល់លើអាជ្ញាធរមូលដ្ឋាន ។ វិធីមួយទៀត គឺការកំណត់ថា គណបក្សនានាមានភារកិច្ចនេះ ។ ក្នុងវិធីសាស្ត្រផ្អែកលើគណបក្សនេះ មានការសន្មតថា ការបោះឆ្នោតដំណើរការជាសំខាន់ គឺការប្រកួតគ្នាខាងកំលាំង និងប្រជាប្រិយភាព រវាងគណបក្សនយោបាយនានា ។ បើសិនគណបក្សណាមួយចង់ឈ្នះ គឺត្រូវបញ្ជាក់ពីឧត្តមភាពរបស់ខ្លួនដោយបង្ហាញថា ខ្លួនអាចផ្តល់ពត៌មាន ធ្វើការរៀបចំ និងបំផុសទឹកចិត្តពួកអ្នកគាំទ្រខ្លួន ។ វិធីសាស្ត្រនេះ វាប្រឆាំងគ្នានឹងវិធីសាស្ត្រផ្អែកលើសិទ្ធិ ដែលសំគាល់ការបោះឆ្នោតថាមានតំលៃខ្ពស់ដោយផ្តល់ឱ្យបុគ្គលគ្រប់គ្នានូវសិទ្ធិស្មើគ្នាដើម្បីចូលរួមធ្វើសេចក្តីសំរេចចិត្តខាងនយោបាយ ដោយមិនគិតថាសាមីខ្លួនគាំទ្រគណបក្សណានោះទេ ។ ការផ្ទេរការទទួលខុសត្រូវផ្តល់ពត៌មានដល់អ្នកបោះឆ្នោតទៅឱ្យគណបក្សនយោបាយនានា អាចមានគុណវិបត្តិនៃការបំបាត់សិទ្ធិរបស់សមាជិកគណបក្សតូចៗ និងរៀបចំមិនសូវបានល្អ ដើម្បីចូលរួមយ៉ាងស្មើភាព ។ ប្រជាធិបតេយ្យូបនីយកម្មនៃរដ្ឋអំណាចឃុំ បានធ្វើឱ្យមានគណបក្សច្រើននៅក៏រិតមូលដ្ឋាន ហើយតាមនេះបានជួយឱ្យមានសមត្ថភាពស្មើគ្នាឡើង (យ៉ាងហោចណាស់ក្នុងចំណោមគណបក្សធំៗ) ក្នុងការផ្តល់ពត៌មានឱ្យពួកអ្នកគាំទ្រខ្លួន ។ សំរាប់ការបោះឆ្នោត វិធីសាស្ត្រផ្អែកលើគណបក្ស វាផ្ទុយគ្នាទាំងស្រុងពីវិធីសាស្ត្រផ្អែកលើសិទ្ធិ ។

ដូចគ្នាដែរ សមាជិក គជប ម្នាក់បានផ្តល់មតិលើការរិះគន់របស់ NGOs ស្តីពីការផ្តល់ពត៌មានជាសាធារណៈរបស់ គជបៈ

*"COMFREL បានតវ៉ាថា ពួកយើងមិនបានធ្វើការអប់រំអ្នកបោះឆ្នោតគ្រប់គ្រាន់ទេ ។ ប៉ុន្តែចំពោះអ្នកវិញ អ្នកបានទទួលប្រាក់យ៉ាងច្រើនពីអង្គការមូលនិធិអាស៊ី ជប៉ុន សហភាពអឺរ៉ុប... សំរាប់ធ្វើការអប់រំអ្នកបោះឆ្នោត ។ បើអ្នកតវ៉ាគឺបានសេចក្តីថា អ្នកក៏ធ្វើការងារនោះមិនបានល្អដែរ"*[១៣៥] ។

---

[១៣៣] NEC member (51), personal interview, Phnom Penh, 5 Oct 2003.

[១៣៤] NEC representative (8), personal interview, Phnom Penh, 5 Oct 2003.

[១៣៥] NEC member (4), personal interview, Phnom Penh, 8 Oct 2003.

ក្នុងការបោះឆ្នោតជាបន្តបន្ទាប់នៅកម្ពុជា គេបានឃើញកំណើនប្រភពពត៌មានសំរាប់អ្នកបោះឆ្នោត ។ ប៉ុន្តែ វិធីសាស្ត្រផ្អែកលើសិទ្ធិទាមទារឱ្យរដ្ឋទទួលខុសត្រូវ ធានាឱ្យមានពត៌មានគ្រប់គ្រាន់សំរាប់អ្នកបោះឆ្នោតគ្រប់គ្នា ។ ភស្តុតាងស្តីពីអ្នកបោះឆ្នោតដែលត្រូវពឹងផ្អែកលើពត៌មានបានពីអាជ្ញាធរមូលដ្ឋាន បានផ្តល់គំនិតថា ត្រូវយកចិត្តទុកដាក់ពីគុណភាពពត៌មានផ្តល់ទៅឱ្យអ្នកបោះឆ្នោតដោយប្រភពទាំងនេះ ។ ទោះបី គជប បានផ្តល់ពត៌មានតាមរយៈសន្លឹកប័ណ្ណផ្សព្វផ្សាយ ប៉ូស្ទ័រ ទូរទស្សន៍ វិទ្យុ និងអ៊ិនធឺណិតក្តី ប៉ុន្តែ គជប ខ្លួនឯងនៅតែបារម្ភថា សំរាប់អ្នកបោះឆ្នោត ៥០% ដែលពុំមានលទ្ធភាពខាងទូរទស្សន៍ និងវិទ្យុ ឬក៏ ៣៥% ដែលមិនចេះអានសន្លឹកប័ណ្ណផ្សព្វផ្សាយពត៌មាន គឺនៅតែមិនគ្រប់គ្រាន់ ។

### *៤.១.៣ លទ្ធផលៈ ទំនាស់ និងការគ្រប់គ្រងទំនាស់ទាក់ទិននឹងការចុះបញ្ជីអ្នកបោះឆ្នោត*

ទំនាស់ចំបងពីរបានផុសចេញពីដំណើរការចុះបញ្ជីអ្នកបោះឆ្នោត ។ ទំនាស់ទី១ ទាក់ទិននឹងការចុះបញ្ជីអ្នកគ្មានលក្ខណៈសម្បត្តិ ជាពិសេសជនដែលគេសំគាល់ថាជាវៀតណាម ។ ទំនាស់ទី២ ដែលមានលើកឡើងយ៉ាងច្រើននៅក្រោយពេលបោះឆ្នោត ដោយគណបក្សនានាដែលបដិសេធលទ្ធផលបោះឆ្នោត គឺបញ្ហាកើតឡើងនាថ្ងៃបោះឆ្នោត នៅពេលដែលមនុស្សមួយចំនួនខំមកបោះឆ្នោត តែមិនអាចបោះបាន ពីព្រោះគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬមិនអាចរកឃើញថា តើឈ្មោះខ្លួនមានចុះក្នុងបញ្ជីនៅឯការិយាល័យបោះឆ្នោតណា ។ គណបក្សចាញ់ឆ្នោតបានអះអាងនៅក្រោយថ្ងៃបោះឆ្នោតថា ពួកអ្នកគាំទ្រខ្លួនបានទទួលរងគ្រោះក្នុងចំនួនច្រើនហួសហេតុពីការច្របូកច្របល់នេះ ដែលអាចជាការបំបាត់សិទ្ធិមួយប្រឆាំងនឹងសមាជិកពួកគេ ។

#### *៤.១.៣.១ ទំនាស់ពីការចុះបញ្ជីអ្នកគ្មានសិទ្ធិ*

ក្នុងគ្រប់ការបោះឆ្នោតនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣មក បញ្ហាចុះបញ្ជីជនដែលជា ឬដែលគេចោទថា ជាជនជាតិវៀតណាមបានផុសឡើងក្លាយជាទំនាស់ក្នុងពេលចុះបញ្ជីអ្នកបោះឆ្នោត ។ នៅឆ្នាំ២០០៣ រឿងនេះបានក្លាយម្តងទៀតជាប្រភពនៃការតវ៉ាទៅ គជប ពីសំណាក់ FUNCINPEC និង SRP ។ នាយកខាងបណ្តឹងតវ៉ារបស់ SRP បានលើកនៅខែតុលា ក្នុងសិក្ខាសាលាមួយដែលពិភាក្សាពីការបោះឆ្នោតថា "យុទ្ធសាស្ត្រចាប់ផ្តើមពីការចុះបញ្ជី ។ ជនជាតិយួនរាប់ពាន់នាក់ ត្រូវបានអនុញ្ញាតឱ្យចុះបញ្ជី" ។ នេះជារឿងមានប្រជាប្រិយភាពមួយសំរាប់សារពត៌មានខាងបក្សជំទាស់ ។ ឧទាហរណ៍ សារពត៌មានគាំទ្រ SRP មនសិកាខ្មែរបានអះអាងថាៈ "ជនអន្តោប្រវេសន៍យួនខុសច្បាប់ បានបោះឆ្នោតឱ្យ CPP ដើម្បីពួកគេអាចបន្តឈ្លានពានទឹកដីកម្ពុជាដូចទឹកជំនន់ និងបំផ្លាញជាតិខ្មែរតាមអំពើចិត្ត" ។ សារពត៌មានបានអះអាងថា ប្រភពការទូតនៅហាណូយបានលើកឡើងពី "ថ្នាក់ដឹកនាំយួនបានជំរុញប្រជាជនខ្លួនដែលរស់នៅតាមព្រំដែន និងដែលមានប័ណ្ណបោះឆ្នោតកម្ពុជា ឱ្យចូលមកកម្ពុជាបោះឆ្នោតឱ្យគណបក្សប្រជាជន" ។ មានការចោទថា ប័ណ្ណបោះឆ្នោតទាំងនេះ ពួកមន្ត្រីគាំទ្រ CPP បានចេញដោយខុសច្បាប់ទៅឱ្យជនអន្តោប្រវេសន៍ខុសច្បាប់វៀតណាម ដើម្បីឆ្លើយតបនឹងការបារម្ភរបស់ក្រុងហាណូយដែលថា "បើសិនគណបក្សប្រជាជនចាញ់ឆ្នោត ហើយធ្លាក់ពីអំណាច ពួកយួនមិនអាចរំលោភ និងឈ្លានពានទឹកដីខ្មែរទៀតទេ"[១៣៦] ។ នៅពេលប្រជុំ COPCEL មួយ, ក្នុងការពិភាក្សាពីការចុះបញ្ជីអ្នកបោះឆ្នោត តំណាងម្នាក់នៃគណបក្សជំទាស់តូចមួយលើកឡើងថា "សព្វថ្ងៃនេះ ជនអន្តោប្រវេសន៍ភាគច្រើនមានអត្តសញ្ញាណប័ណ្ណកម្ពុជា ។ គាត់ប្រាប់ថា នៅឃុំប្រាផោង ស្រុកពាមរក៍ ខេត្តព្រៃវែង, ជនអន្តោប្រវេសន៍វៀតណាមប្រហែល ៣៥០នាក់ មានសញ្ជាតិខ្មែរ ទោះបីពួកគេមិនចេះនិយាយខ្មែរសោះក្តី"[១៣៧] ។ អ្នកតំណាងគណបក្សតូចមួយទៀត ដែលឆ្លើយសំភាសន៍សំរាប់ការសិក្សានេះ បានលើកឡើងថាៈ

---

[១៣៦] "Khmer Citizens Throughout the Country must Go to Vote and Protect their Ballot in order to Stop Yuon Invasion," Moneaksekar Khmer, 25 July 2003, 1,4.

[១៣៧] Lav Zuhong, representative of Hang Dara Democratic Movement Party, extract from Minutes of 42nd COPCEL Meeting, Phnom Penh, 30 January 2003.

*"បើសិនគណបក្សកាន់អំណាចនៅតែដឹកនាំប្រទេសទៀត នឹងមានវៀតណាមកាន់តែច្រើនចូលមកក្នុងប្រទេសយើងជារៀងរាល់ថ្ងៃ ។ ចំពោះអ្នកដែលបាននៅទីនេះយូរមកហើយ សព្វថ្ងៃពួកគេមានប័ណ្ណបោះឆ្នោត ដូច្នេះពួកគេក៏អាចបោះឆ្នោតដែរ ។ វាច្បាស់ណាស់ដែលពួកគេនឹងបោះឆ្នោតឱ្យគណបក្សកាន់អំណាច ។ ដូច្នេះវាទៅជាយ៉ាងម៉េច បើសិនខ្មែរដប់នាក់ទៅបោះឆ្នោត ហើយវៀតណាមទៅម្ភៃនាក់? គណបក្សវៀតណាមនឹងឈ្នះឆ្នោត ។ នៅចុងបញ្ចប់ ខ្មែរនឹងបាត់បង់ប្រទេស ហើយក្លាយជាដូចចាម"*[១៣៨] ។

ចំណងទាក់ទងរវាងប្រវត្តិគ្រប់គ្រងរដ្ឋបាលទន់ខ្សោយនៃរដ្ឋអំនាចក្នុងការចេញឯកសារសំគាល់អត្តសញ្ញាណ ហើយនិងវោហារសាស្ត្រក្នុងពេលឃោសនាដែលគេអះអាងថា តំណាងមតិមហាជន វាធ្វើឱ្យរឿងនេះនៅតែជាប្រភពទំនាស់ជាប្រចាំក្នុងឆាកនយោបាយកម្ពុជា ។ ករណីដែលនាំទៅដល់ការប្ដឹងតវ៉ា មានចំនួនតិចទេ ។ COMFREL បានរកឃើញ ១៤៤ករណីចុះបញ្ជីខុសច្បាប់ ឬគួរឱ្យសង្ស័យ ក្នុងរយៈពេលដែលខ្លួនធ្វើការពិនិត្យតាមដានការចុះបញ្ជី ។ គណបក្សផ្សេងៗបានដាក់ ៩៤បណ្ដឹងទៀតទៅជូន គជប និងក្រុមប្រឹក្សាធម្មនុញ្ញ ជាប់ទាក់ទិននឹងអ្នកបោះឆ្នោត ដែលគេចោទថា គ្មានលក្ខណៈសម្បត្តិនៅក្នុងរយៈពេលឃោសនា ។ ការតវ៉ាផ្សេងទៀតធ្វើឡើងអំពីការចុះបញ្ជីមនុស្ស ៧.៨៧៣នាក់ នៅពេលបិទផ្សាយបញ្ជីអ្នកបោះឆ្នោតបណ្ដោះអាសន្ន ។ គជប និងក្រុមប្រឹក្សាធម្មនុញ្ញ បានទាត់ចោលបណ្ដឹងទាំងនេះដោយគ្មានសវនាការជាសាធារណៈ ដូច្នេះហើយ COMFREL បានទិតៀនការទាត់ចោលនេះថា គ្មានតំលាភាព ។

នៅឆ្នាំ២០០៣ ដូចការបោះឆ្នោតលើកមុនៗដែរ គជប បានទទួលយកបណ្ដឹងតវ៉ាមួយចំនួន នៅពេលមើលឃើញថាសាមីជនខ្វះឯកសារសំគាល់អត្តសញ្ញាណដែលច្បាប់បានតំរូវឡើង ។ ប៉ុន្តែ គជប បានទាត់ចោលបណ្ដឹងតវ៉ាជាច្រើនដោយសំអាងថា ការមានសំនៀងនិយាយដូចបរទេស ឬកង្វះចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរ មិនមែនជាមូលហេតុស្របច្បាប់សំរាប់បដិសេធសិទ្ធិបោះឆ្នោតរបស់បុគ្គលណាមួយទេ បើសិនគេមានឯកសារ ( អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ...) តាមការតំរូវក្នុងច្បាប់ ។ នៅឆ្នាំ២០០៣ ដូចការបោះឆ្នោតលើកមុនៗដែរ គណបក្សជំទាស់មិនព្រមទទួលយកហេតុផលនេះថាត្រឹមត្រូវទេ ហើយរឿងនេះឆ្លុះបញ្ចាំងកង្វះទំនុកចិត្តរបស់ពួកគេចំពោះក្របខ័ណ្ឌស្ថាប័នជាទូទៅរបស់រដ្ឋាភិបាល ជាពិសេសចំពោះអាជ្ញាធរមូលដ្ឋានដែលមានសិទ្ធិអំណាចចេញអត្តសញ្ញាណប័ណ្ណ ។ ក្នុងករណីខ្លះៗ ក្រុមសកម្មជនធ្វើសកម្មភាពផ្ទាល់ ដោយខិតខំរារាំងជនដែលពួកគេយល់ថាជាវៀតណាម មិនឱ្យចូលក្នុងការិយាល័យបោះឆ្នោត ។ COMFREL រំលឹកថា បើសិន គជប បានប្រឹងប្រែងអនុវត្តដំណើរការធ្វើសវនាការឱ្យមានតំលាភាពល្អជាងនេះ គឺប្រហែលអាចកាត់បន្ថយបញ្ហាបាន ។

នៅឆ្នាំ១៩៩៨ ការអះអាងទាក់ទិននឹងការចុះបញ្ជីអ្នកបោះឆ្នោតវៀតណាមខុសច្បាប់ មានចំណែកយ៉ាងសំខាន់ក្នុងសុន្ទរកថារបស់អ្នកនយោបាយគណបក្សជំទាស់ ទាំងក្នុងពេលឃោសនាបោះឆ្នោត ទាំងក្រោយមកទៀត ក្នុងពេលមានការតវ៉ា និងបាតុកម្មប្រឆាំងនឹងលទ្ធផលបោះឆ្នោត ។ នៅឆ្នាំ២០០៣ ការអះអាងបែបនេះឃើញមានមិនសូវទៀងទាត់ដូចមុនទេក្នុងសេចក្ដីប្រកាសជាផ្លូវការរបស់គណបក្សនានា ។ ការថយចំនួនចោទប្រកាន់ជាចំហនៅក្រោយពេលបោះឆ្នោតឆ្នាំ២០០៣ គឺប្រហែលដោយសារចលនានយោបាយមួយរបស់ពួកគណបក្សចាញ់ឆ្នោត ដើម្បីស្វែងរកការគាំទ្រពីអន្តរជាតិ បន្ទាប់ពីពួកខ្លួនបានទាត់ចោលលទ្ធផលបោះឆ្នោត ។ តួអង្គអន្តរជាតិនានាមានគោលនយោបាយថ្កោលទោសការតវ៉ាបែបនេះថា ប្រកាន់ពូជសាសន៍ ហើយវាប្រហែលបានកាត់បន្ថយទំនាស់នៅឆ្នាំ២០០៣ ប៉ុន្តែ ចំណុចនេះនៅតែជាប្រភពខ្វែងមតិដ៏តឹងតែងមួយរវាងគណបក្សនយោបាយនានានៅកម្ពុជា ។

លក្ខណៈមិនច្បាស់លាស់ក្នុងដំណើរការសុំឯកសាររដ្ឋបាលនៅកម្ពុជា ក៏បង្កការលំបាកដល់ប្រជាជនកម្ពុជាជាច្រើន ពីព្រោះការទទួលបានឯកសារផ្លូវការអាចត្រូវចំណាយពេល និងសោហ៊ុយច្រើន ។ មានការតវ៉ាអំពីអាជ្ញាធរមូលដ្ឋានទាមទារប្រាក់

[១៣៨] Khmer Unity Party representative (53), personal interview, Phnom Penh, 10 July 2003.

កំរៃលើការចេញអត្តសញ្ញាណប័ណ្ណដែលគេត្រូវចេញឱ្យដោយឥតគិតថ្លៃ អាជ្ញាធរមូលដ្ឋានទាមទារឱ្យបុគ្គលខ្លះរកសាក្សី និងឯកសារផ្សេងៗដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន និងស្មៀនឃុំខ្លះបានតំរូវឱ្យមានការបញ្ជាក់ធានាពីប្រធានភូមិលើអត្តសញ្ញាណរបស់សាមីជនមុននឹងចុះបញ្ជីឱ្យ[១៣៩] ។ ក្នុងឃុំមួយនៅខេត្តកណ្តាល អង្គការ EMO និង NICFEC រាយលការណ៍ថា ស្មៀនឃុំទារប្រាក់ ២.០០០រៀល ពីអ្នកបោះឆ្នោតសំរាប់ការចុះបញ្ជី បើសិនសាមីជនពុំមានឯកសារគ្រប់គ្រាន់[១៤០] ។ ការចោទប្រកាន់ទាំងនេះបង្ហាញពីការដាក់លក្ខខ័ណ្ឌ តាមអំពើចិត្តពីសំណាក់អាជ្ញាធរមូលដ្ឋាន ជាបន្ថែមទៅលើអ្វីដែលច្បាប់បានកំណត់ ។ ក្រុមដែលជួបការលំបាកក្នុងការចុះបញ្ជីនៅឆ្នាំ២០០៣ មានជាអាទិ៍ ពួកនិស្សិតរស់នៅក្នុងវត្តដែលត្រូវមានលិខិតបញ្ជាក់កន្លែងស្នាក់នៅពីចៅអធិការ, ក្មេងកំព្រាទើបអាយុដល់ ១៨ឆ្នាំ ដែលគ្មានលិខិតស្នាមអ្វីសោះ, និងជនរងគ្រោះដោយអគ្គីភ័យដែលបានបំផ្លាញតំបន់អនាធិបតេយ្យមួយចំនួនក្នុងទីក្រុង និងដែលបានកំទេចអត្តសញ្ញាណប័ណ្ណ និងឯកសារផ្លូវការផ្សេងទៀតរបស់ប្រជាជន ។ បញ្ហានេះមានចែងក្នុងច្បាប់បោះឆ្នោត នៅក្នុងបទប្បញ្ញត្តិមួយដែលអនុញ្ញាតឱ្យសាមីជនរកសាក្សីទៅបញ្ជាក់ពីសញ្ជាតិខ្មែររបស់ខ្លួន ។ អគ្គលេខាធិការ គជប ទេព នីថា បានលើកនៅខែមករា ២០០៣ ដើម្បីឆ្លើយតបនឹងការតវ៉ារបស់គណបក្សជំទាស់នានាអំពីប្រជាជនមួយចំនួនដែលជួបការលំបាកក្នុងការចុះបញ្ជីៈ "គជប បានស្នើច្រើនលើកហើយ ឱ្យក្រសួងមហាផ្ទៃពន្លឿនការចេញអត្តសញ្ញាណប័ណ្ណឱ្យប្រជាជន និងបានណែនាំស្មៀនឃុំកុំឱ្យតឹងតែងពេកក្នុងដំណើរការចុះបញ្ជី"[១៤១] ។ ប៉ុន្តែការបញ្ចូលសមាធាតុឆន្ទានុសិទ្ធិ (លទ្ធភាពសំរេចអារកាត់បែបនេះ ជាបន្ថែមទៅលើលក្ខណៈធូរទូលាយដែលមានច្រើនស្រាប់ហើយ ក្នុងនីតិវិធីចុះបញ្ជី) វាបង្កើនការសង្ស័យថា បុគ្គលមួយចំនួន រួមទាំងអ្នកគាំទ្រគណបក្សកាន់អំណាច និង "ជនបរទេស" ផង អាចចុះបញ្ជីបានដោយខុសច្បាប់ ។

ក្នុងពេលពិភាក្សានៅ COPCEL, គជប ប្រកាន់គំនិតថា បញ្ហាជួបប្រទះនានា គឺជាបញ្ហាបច្ចេកទេសជាប់ទាក់ទិននឹងអសមត្ថភាពរបស់ស្មៀនឃុំ បញ្ហាប្រព័ន្ធអត្តសញ្ញាណប័ណ្ណកំរិតជាតិថ្មី, និងប្រព័ន្ធចុះបញ្ជីថ្មីដែលអ្នកបោះឆ្នោត និងមន្ត្រីនានាមិនទាន់ស្គាល់ច្បាស់ល្អ ។ ប៉ុន្តែគណបក្សជំទាស់បន្តមើលឃើញវាថា ជាបញ្ហានយោបាយ ដោយជជែកវែកញែកថា ការលំអៀងខាងនយោបាយរបស់ពួកស្មៀនឃុំ បានធ្វើឱ្យអ្នកដែលជួបការលំបាកក្នុងការចុះបញ្ជី គឺសុទ្ធតែជាអ្នកគាំទ្រគណបក្សជំទាស់រាល់ៗលើក ហើយអ្នកដែលទទួលការជួយសំរួលឱ្យចុះបញ្ជី គឺសុទ្ធតែជាអ្នកគាំទ្រគណបក្សកាន់អំណាច ឬ "ពួកវៀតណាម" ។ ដោយមូលហេតុនេះ ក្រុមផ្សេងៗយល់ឃើញខុសគ្នាខ្លាំងណាស់ពីអ្នកដែលប្រព្រឹត្តខុស ។ ចំពោះ គជប អ្នករំលោភច្បាប់ គឺជាពួកមន្ត្រីដែលមានការបណ្តុះបណ្តាលខ្សោយ មានការងារច្រើនហួស និងមានមុខងារដ៏ពិបាកផង ។ ចំពោះគណបក្សជំទាស់ និង NGOs, អ្នករំលោភហាក់ដូចជា អ្នកលំអៀងដែលគាំទ្រគណបក្សកាន់អំណាច និងដែលប្រឹងប្រែងប្រើតួនាទីផ្លូវការរបស់ខ្លួន ដើម្បីដកហូតសិទ្ធិបោះឆ្នោតពីបុគ្គល និងក្លែងបន្លំលើការបោះឆ្នោត ។

ដោយសារការយល់ឃើញខុសគ្នាជាមូលដ្ឋានពីឫសគល់នៃបញ្ហា ដូច្នេះក៏មានផុសគំនិតខុសគ្នាពីវិធីដោះស្រាយ ។ គជប បានតស៊ូមតិឱ្យមានអន្តរាគមន៍ និងជំនួយទ្រទ្រង់ឱ្យស្មៀនឃុំបានយល់ដឹងពីរបៀបចុះបញ្ជីឱ្យបានត្រឹមត្រូវ ដោយកត់សំគាល់ថា ស្មៀនឃុំជានិយោជិករបស់ក្រសួងមហាផ្ទៃ មិនមែនរបស់ គជប ទេ ដូច្នេះហើយ គជប មានផ្លូវដើរតែមួយគឺ ការសំរុះសំរួល ។ ផ្ទុយទៅវិញ សមាជិកគណបក្សជំទាស់ និង NGOs មួយចំនួន បានតស៊ូមតិឱ្យមានការដាក់ទោសតាមច្បាប់លើអ្នកដែលរំលោភច្បាប់បោះឆ្នោត ។ កង្វះការផ្សះផ្សារគ្នារវាងមតិទាំងនេះ បានបើកច្រកជាស្រេចសំរាប់ឱ្យបញ្ហាវាផុសឡើងវិញនៅពេលក្រោយ ក្នុងរូបភាពជាការតវ៉ាលើលទ្ធផលបោះឆ្នោត ។

---

[១៣៩] Iv Borin, extract from Minutes of 42nd COPCEL Meeting, Phnom Penh, 30 January 2003.

[១៤០] Hang Puthea, extract from Minutes of 42nd COPCEL Meeting, Phnom Penh, 30 January 2003.

[១៤១] Tep Nytha, extract from Minutes of 42nd COPCEL Meeting, Phnom Penh, 30 January 2003.

### *៤.១.៣.២ ទំនាស់ពីការបំបាត់សិទ្ធិអ្នកបោះឆ្នោតខាងគណបក្សជំទាស់*

ការចុះបញ្ជីអ្នកបោះឆ្នោតគ្មានសិទ្ធិ គឺជាការបារម្ភចំបងមួយនៅមុនពេលបោះឆ្នោត ហើយរឿងនេះនាំឱ្យមានការចោទប្រកាន់ពីការអនុវត្តន៍តាមអំពើចិត្តពីសំណាក់មន្ត្រីចុះបញ្ជី ។ ប៉ុន្តែការពិនិត្យតាមដានរបស់ COMFREL លើដំណើរការចុះបញ្ជីបានរកឃើញក្នុងទូទាំងប្រទេសតែ ៥៨ករណីជាក់លាក់នៃអ្នកបោះឆ្នោតមានសិទ្ធិ ដែលត្រូវពួកមន្ត្រីបដិសេធការចុះបញ្ជី និង ៥៩ករណីទៀតដែលមានមន្ត្រីអ្នកប្រកាន់បក្សពួកនានា បានរារាំងដល់ការប្រឹងប្រែងស្វែងរកឯកសារដ៏ចាំបាច់ៗសំរាប់ធ្វើការចុះបញ្ជី ឬក៏ការតវ៉ាពីការមិនអាចចុះបញ្ជីបានរបស់អ្នកបោះឆ្នោត ។ ប៉ុន្តែ COMFREL បានក្រើនរំលឹកថា ការជូនដំណឹងរបស់ គជប ឱ្យអ្នកបោះឆ្នោតផ្ទៀងផ្ទាត់ឈ្មោះខ្លួនលើបញ្ជីបោះឆ្នោតបណ្តោះអាសន្ន មានខ្លឹមសារមិនច្បាស់លាស់ និងមិនបានផ្សព្វផ្សាយទូលាយទេ ហើយប្រជាជនភាគច្រើន "មិនបានចងចាំពីការជូនដំណឹងនេះទេ" ។ នៅថ្ងៃបោះឆ្នោត ការក្រើនរំលឹកនេះពិតជាបានមើលឃើញត្រឹមត្រូវមែនពីបញ្ហាដ៏ធ្ងន់ធ្ងរ ។ អ្នកសង្កេតការណ៍បោះឆ្នោតបានពិនិត្យឃើញបញ្ហារដ្ឋបាលមួយចំនួនដែលក្នុងករណីខ្លះ បានរារាំងអ្នកចង់បោះឆ្នោតមិនឱ្យបោះឆ្នោតបានជាអាទិ៍ អ្នកបោះឆ្នោតដែលកាន់ប័ណ្ណបោះឆ្នោតឆ្នាំ១៩៩៨ មក ដោយគិតថា វាមានតំលៃដូចមុន តែតាមពិតគឺគ្មានតំលៃទេ, អ្នកបោះឆ្នោតដែលមកដល់ដោយអះអាងថា បានចុះបញ្ជីហើយ ប៉ុន្តែរកឈ្មោះមិនឃើញលើបញ្ជីបោះឆ្នោត និងការអះអាងថា ឈ្មោះអ្នកបោះឆ្នោតមួយចំនួនត្រូវបានដកចេញពីបញ្ជីរបស់ការិយាល័យបោះឆ្នោតមួយ ទៅដាក់ក្នុងបញ្ជីរបស់ការិយាល័យបោះឆ្នោតមួយទៀត ធ្វើឱ្យអ្នកបោះឆ្នោតត្រូវធ្វើដំណើរពីការិយាល័យបោះឆ្នោតមួយទៅការិយាល័យមួយទៀតដើម្បីរកឈ្មោះខ្លួន និងការអះអាងថា អ្នកបោះឆ្នោតខ្លះមកដល់ ហើយឃើញឈ្មោះខ្លួនមានគេគូសរួចស្រេច ដូច្នេះក៏មិនអាចបោះឆ្នោតបាន, ការអះអាងថា មន្ត្រីការិយាល័យបោះឆ្នោតមិនបានជួយអ្នកបោះឆ្នោតរកឈ្មោះលើបញ្ជីទេ និងការអះអាងថា មន្ត្រីការិយាល័យបោះឆ្នោតផ្តល់អាទិភាពឱ្យសមាជិក CPP បោះឆ្នោតមុន ។

SRP បានលើកពីបញ្ហាខាងលើក្នុងសេចក្តីប្រកាសមួយផ្ញើជូនក្រុមអ្នកសង្កេតការណ៍អន្តរជាតិមួយរយៈពេលខ្លីក្រោយពីការបោះឆ្នោត ដោយអះអាងថា ការបោះឆ្នោតមិនយុត្តិធម៌:

> *"ត្រូវកត់សំគាល់ដែរថា ៦៣% នៃប្រជាជនពេញវ័យនៅកម្ពុជា ជាអនក្ខរជន គឺបានន័យថា ប្រជាជនរាប់ពាន់នាក់មិនអាចអានបញ្ជីអ្នកបោះឆ្នោត និងមិនអាចរកឈ្មោះឃើញ ។ យើងមានរបាយការណ៍ដ៏ធ្ងន់ធ្ងរជាច្រើនដែលបញ្ជាក់ថា មន្ត្រីបោះឆ្នោតមិនបានជួយអ្នកបោះឆ្នោតដែលខិតខំមកបោះឆ្នោតទេ, ផ្ទុយទៅវិញពួកគេគ្រាន់តែបញ្ជូនអ្នកបោះឆ្នោត ទៅមើលបញ្ជីបិទនៅខាងក្រៅការិយាល័យបោះឆ្នោត គឺធ្វើឱ្យមានការច្របូកច្របល់ពេញបន្ទុក ហើយនៅទីបញ្ចប់ ប្រជាជនអស់ទឹកចិត្តក៏ទៅផ្ទះវិញដោយមិនបានបោះឆ្នោត ។ មន្ត្រីបោះឆ្នោតមានកាតព្វកិច្ចជួយអ្នកបោះឆ្នោត និងមិនត្រូវរាំងស្ទះដំណើរការទេ ។ ការចាត់ចែងពិសេសដែលអ្នកគាំទ្រ CPP ទទួលបាន គឺក្រដាសតូចមួយដែលប្រធានភូមិផ្តល់ឱ្យ និងដែលមានចុះឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកបោះឆ្នោត ដូច្នេះពួកគេអាចឆ្លងកាត់ដំណើរការយ៉ាងរលូនល្អ ដោយគ្មានការរំខានអ្វីទេ"*[១៤២] ។

ការសង្កេតឃើញទាំងនេះ ព្រមទាំងផ្សព្វផ្សាយជាផ្លូវការនូវតួលេខអ្នកបានបោះឆ្នោត ដែលបង្ហាញពីការថយចុះបើធៀបនឹងការបោះឆ្នោតក៏រិតជាតិលើកមុន នាំឱ្យអ្នកសង្កេតការណ៍មួយចំនួន និងសមាជិកគណបក្សជំទាស់សន្និដានថាមានកំហុសឆ្គងខាងរដ្ឋបាលផ្សេងៗដែលធ្វើឱ្យបាត់បង់សិទ្ធិអ្នកបោះឆ្នោតក្នុងចំនួនដ៏ច្រើនៗ ។ អ្នកខ្លះបានសន្និដ្ឋានទៀតថា រឿងនេះបានប៉ះពាល់ច្រើនហួសហេតុដល់អ្នកបោះឆ្នោតខាងគណបក្សជំទាស់ ។ លោក សម រង្ស៊ី បានសរសេរក្នុងសេចក្តីប្រកាសមួយថា:

---

[១៤២] Sam Rainsy, "A Plea from the Sam Rainsy Party to International Observers," press release, Phnom Penh, 31 July 2003, posted to Camnews, at camnews@cambodia.org.

*"តាមការប្រើប្រាស់កលល្បិចយ៉ាងប៉ិនប្រសព្វពិបាកមើលឃើញបែបនេះ គណបក្សកាន់អំណាចអាចរារាំងអ្នកបោះឆ្នោតដែលមានសិទ្ធិជាច្រើននាក់ (ដែលមិនមែនជាសមាជិកខ្លួន) មិនឱ្យបោះឆ្នោតក្នុងឱកាសបោះឆ្នោតលើកចុងក្រោយ ។ ជាលទ្ធផល អត្រាអ្នកបានបោះឆ្នោតក៏ធ្លាក់ចុះដល់កំរិតទាបបំផុត*[១៤៣] ។

ចំពោះអត្រាទាបនៃអ្នកបានបោះឆ្នោត ដែលពួកគេគិតថាមាន ៨០%នៃអ្នកបោះឆ្នោត, COMFREL និង NICFEC បានផ្តល់ការពន្យល់ច្រើន ដែលមានជាអាទិ៍:

- បញ្ហាចុះបញ្ជី និងប្រស្រ័យទាក់ទងរវាង គជប គខប និង គឃប
- ការយល់ច្រឡំរបស់អ្នកបោះឆ្នោតថាអាចប្រើប្រាស់ប័ណ្ណបោះឆ្នោតឆ្នាំ១៩៩៨ បាន ហើយក៏មិនអាចបោះឆ្នោតកើតពីព្រោះមិនបានចុះបញ្ជីនៅឆ្នាំនេះ
- អ្នកបោះឆ្នោតពិបាករកឈ្មោះ ឬរកឈ្មោះមិនឃើញនៅលើបញ្ជីចុះបញ្ជីអ្នកបោះឆ្នោតរបស់ គជប ដូច្នេះហើយក៏មិនអាចបោះឆ្នោតបាន
- មានការរៀបចំរកេតរកូតមួយចំនួននៅការិយាល័យបោះឆ្នោត ធ្វើឱ្យអ្នកបោះឆ្នោតត្រូវរង់ចាំបោះឆ្នោតយូរពេក ដូច្នេះក៏មិនបានបោះឆ្នោត
- បញ្ហាទាក់ទិននឹងការចេញត្រាឱ្យខុសនៅការិយាល័យបោះឆ្នោតខ្លះ ដែលធ្វើឱ្យការបោះឆ្នោតមួយចំនួនគ្មានតំលៃ
- ក្រុមហ៊ុនឯកជនមួយចំនួនហាមឃាត់បុគ្គលិកមិនឱ្យទៅបោះឆ្នោត
- ការប្តូរកន្លែងការិយាល័យបោះឆ្នោត ធ្វើឱ្យប្រជាជនរកការិយាល័យបោះឆ្នោតមិនឃើញ[១៤៤] ។

*អត្រាអ្នកបានបោះឆ្នោតទាបនៅប៉ោយប៉ែត:* ករណីនៅប៉ោយប៉ែតជាប្រភពទំនាស់ធំមួយ ។ SRP បានដាក់បណ្តឹងតវ៉ាពីការចាត់ចែងការបោះឆ្នោតក្នុងទីក្រុងនេះ ដែលមិនដល់ ៥០% នៃអ្នកបោះឆ្នោតបានចុះបញ្ជីទេ ដែលបានបោះឆ្នោតជាក់ស្តែង ។ ដោយហេតុនេះ SRP បានសុំឱ្យបោះឆ្នោតឡើងវិញនៅប៉ោយប៉ែត ។

គជប បានទាត់ចោលបណ្តឹងតវ៉ានេះ ដោយអះអាងថា គ្មានចំណងទាក់ទងអ្វីរវាងបញ្ហារដ្ឋបាលនៅថ្ងៃបោះឆ្នោត និងអត្រាអ្នកបានបោះឆ្នោតទាបនោះទេ ។ តំណាងថ្នាក់ខ្ពស់ គជប ម្នាក់លើកឡើងថា:

*"នៅប៉ោយប៉ែត មានបញ្ហាច្រើន ។ ទី១ ប្រជាជនច្រើនណាស់គ្មានឯកសារតាមការតំរូវដើម្បីចុះបញ្ជីទេ ដូចជាអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ព្រោះពួកគេជាជនដែលឆ្លងកាត់ ហើយមានច្រើននាក់ណាស់ជាជនចំណាកស្រុកសេដ្ឋកិច្ច ។ អ្នកខ្លះមានបញ្ហានៅថៃ ហើយត្រូវបញ្ជូនមកវិញ ។ អ្នកខ្លះរស់នៅប៉ោយប៉ែតដើម្បីរកប្រាក់ ។ ទី២ ប្រជាជននៅប៉ោយប៉ែតមិនសូវយកចិត្តទុកដាក់ពីការបោះឆ្នោតទេ ។ ពួកគេគិតគូរសំខាន់ពីការរកចិញ្ចឹមជីវិត ។ មនុស្សគណបក្សមួយចំនួន បានជួយរកឯកសារឱ្យប្រជាជនទាំងនេះ ដើម្បីឱ្យពួកគេអាចទៅបោះឆ្នោត ។ ពេលថ្ងៃបោះឆ្នោតមកដល់ បើគេចុះបញ្ជីនៅប៉ោយប៉ែត គេត្រូវបោះឆ្នោតនៅទីនោះ ប៉ុន្តែមានច្រើននាក់បានទៅស្រុកខ្លួនវិញ ឬក៏ទៅធ្វើការនៅថៃ ។ ពួកគេមិនមែនជាប្រជាជនរស់នៅទីនោះរយៈពេលវែងទេ...*[១៤៥] ។

[១៤៣] Sam Rainsy, “A Biased Comparison of Two Cambodian Leaders,” Letter to Editor of Asia Times Online, Paris, 1 Sept. 2003, available online at www.samrainsyparty.org/letter_to_editor/2003/, accessed 17 Oct. 2003.

[១៤៤] COMFREL and NICFEC, “Initial Impressions of the Polling Day and Counting Process,” joint press statement, Phnom Penh, 29 July 2003.

[១៤៥] NEC representative (8), personal interview, Phnom Penh, 5 Oct 2003.

មន្ត្រី គជប ថ្នាក់ខ្ពស់ម្នាក់ទៀតលើកឡើងថា បញ្ហាផុសចេញពីគណបក្សនានាដែលខិតខំជំរុញសមាជិកខ្លួនឱ្យចុះបញ្ជីនៅប៉ោយប៉ែត ទោះបីសមាជិកទាំងនេះគ្រាន់តែជាអ្នកឆ្លងកាត់ក្ដី ។ គាត់លើកឡើងថាៈ

*"ក្នុងឆ្នាំ២០០២ នៅប៉ោយប៉ែតមានប្រជាជន ២៥.០០០នាក់បានចុះបញ្ជី និង ១៩.៥០០នាក់បានបោះឆ្នោត ។ នៅឆ្នាំ២០០៣ មាន ៤០.០០០នាក់បានចុះបញ្ជី និង ២០.៦០០នាក់បានបោះឆ្នោត ។ នេះជាកន្លែងមានជនចំណាកស្រុកសេដ្ឋកិច្ចច្រើនណាស់ ។ នៅពេលដល់ថ្ងៃបោះឆ្នោត ពួកគេបានទៅថៃ ឬទៅផ្ទះផុតហើយ"*[១៤៦] ។

តាមមតិ គជប លក្ខណៈខាងសេដ្ឋកិច្ចទាំងនេះ បានប៉ះពាល់អត្រាអ្នកបានបោះឆ្នោត ខ្លាំងជាងការប្ដូរកន្លែងការិយាល័យបោះឆ្នោតដែល SRP បានអះអាងថា ធ្វើឱ្យមានការច្របូកច្របល់ខ្លាំង ។

*"អាចមានបញ្ហាខ្លះក្នុងការប្ដូរកន្លែងការិយាល័យបោះឆ្នោតនៅទីនោះ ។ ប៉ុន្តែនោះជាចំណុចមួយដ៏តូចៈ យើងប្ដូរកន្លែងមិនលើសពី ២០០ ឬ ៣០០ម៉ែត្រទេ ហើយដាក់ផ្លាកមួយប្រាប់ បើសិនមានប្ដូរមែន ។ យើងមិនប្ដូរកន្លែងទៅឆ្ងាយដល់ ៥គីឡូម៉ែត្រទេ ។ រឿងនេះពិតជាមិនមែនមូលហេតុធំទេ"*[១៤៧] ។

តំណាង គជប ម្នាក់បានលើកឡើងថា ការផ្លាស់ប្ដូរក្នុងប្រព័ន្ធចុះបញ្ជីអ្នកបោះឆ្នោត ក៏ធ្វើឱ្យអ្នកបោះឆ្នោតពិបាករកការិយាល័យបោះឆ្នោតជាងមុនដែរ ។ ក្នុងប្រព័ន្ធចុះបញ្ជីអ្នកបោះឆ្នោតបណ្ដោះអាសន្ន អ្នកបោះឆ្នោតចុះបញ្ជីនៅកន្លែងការិយាល័យ ដែលខ្លួនគេនឹងត្រូវមកបោះឆ្នោត ។ ក្នុងប្រព័ន្ធចុះបញ្ជីអ្នកបោះឆ្នោតអចិន្ត្រៃយ៍ អ្នកបោះឆ្នោតចុះបញ្ជីនៅសាលាឃុំ ហើយត្រូវរកការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត[១៤៨] ។

តាមមតិ គជប បញ្ហាមួយទៀតគឺ តួនាទីរបស់ប្រធានភូមិ ។ តំណាង គជប ម្នាក់បានជជែកវែកញែកថា ក្នុងការបោះឆ្នោតលើកមុនៗ ប្រធានភូមិធ្វើសកម្មភាពយ៉ាងសំខាន់ក្នុងការដឹកនាំអ្នកភូមិទៅការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោត ។ ប៉ុន្តែនៅឆ្នាំ២០០៣ ទំនាស់ដែលបានកើតមានរួចហើយស្ដីពីតួនាទីរបស់ប្រធានភូមិក្នុងពេលឃោសនាបោះឆ្នោត បានជំរុញឱ្យ គជប និងក្រសួងមហាផ្ទៃ ចេញអត្ថបទផ្សព្វផ្សាយសារពតិមានមួយដាក់បញ្ហាឱ្យប្រធានភូមិ ស្ថិតនៅជាអព្យាក្រឹត្យក្នុងដំណើរការបោះឆ្នោត ។ តំណាង គជប នានាលើកឡើងថា រឿងនេះបានបង្អាក់ទឹកចិត្តប្រធានភូមិ ក្នុងការបំពេញតួនាទីដឹកនាំអ្នកភូមិទៅបោះឆ្នោតដែលធ្វើឱ្យអត្រាអ្នកបានបោះឆ្នោតថយចុះ ។

*ពួកមន្ត្រីលំអៀងទៅខាងសមាជិក CPP:* មានការអះអាងទៀតថា នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត បានលំអៀងទៅខាងសមាជិក CPP ដោយអនុញ្ញាតឱ្យពួកនេះទៅឈរនៅខាងដើមជួរ និងបោះឆ្នោតមុនគេ ហើយក៏មិនបានជួយអ្នកបោះឆ្នោតដទៃទៀត រកឈ្មោះនៅលើបញ្ជីបោះឆ្នោតដែរ ។ សមាជិក គជប បានជជែកវែកញែកថា រឿងនេះក៏ដូចជាបញ្ហាចុះបញ្ជីអ្នកបោះឆ្នោត និងអត្រាអ្នកបោះឆ្នោតដែរ វាមិនមែនជាបញ្ហាលំអៀងរបស់ គជប និងបុគ្គលិកមូលដ្ឋានរបស់ គជប ទេ ប៉ុន្តែគឺរឿង CPP រៀបចំការងារគេបានល្អជាងគណបក្សឯទៀតៗ ។ ចំពោះការចោទថា មន្ត្រីការិយាល័យបោះឆ្នោតមិនបានជួយអ្នកបោះឆ្នោត, មន្ត្រី គជប ថ្នាក់ខ្ពស់ម្នាក់បានឯកភាពថា មានអ្នកបោះឆ្នោតមួយចំនួនដែលត្រូវការគេជួយ ដូចជា ការិយាល័យបោះឆ្នោតត្រូវបំបែកជាពីរ អ្នកបោះឆ្នោតមិនចេះអក្សរ ឬមិនអាចមើលឃើញអក្សរតូចៗនៅលើបញ្ជីអ្នកបោះឆ្នោត ឬកន្លែងនោះមានមនុស្សច្រើនពេក មិនអាចមើលបានច្បាស់ ។ ប៉ុន្តែក្នុងបទប្បញ្ញត្តិគ្មានចែងទេថា មន្ត្រីបោះឆ្នោតត្រូវជួយអ្នកបោះឆ្នោតដែលជួបការលំបាក ។ នៅការិយាល័យបោះឆ្នោតនីមួយៗមានមន្ត្រី ៥នាក់ដែលមានតួនាទីជាក់លាក់ទាក់ទិននឹងដំណើរការ

---

[១៤៦] NEC representative (54), personal interview, Phnom Penh, 7 Oct 2003.

[១៤៧] NEC representative (8), personal interview, Phnom Penh, 5 Oct 2003.

[១៤៨] NEC representative (54), personal interview, Phnom Penh, 7 Oct 2003.

បោះឆ្នោត ។ ពួកគេមិនអាចចេញពីកន្លែងខ្លួនទៅជួយអ្នកបោះឆ្នោតរកឈ្មោះនៅលើបញ្ជីបានទេ ពីព្រោះវាធ្វើឱ្យរអាក់រអួលដល់ដំណើរការបោះឆ្នោត[១៤៩] ។

មន្ត្រី គជប ម្នាក់ទៀតបានពន្យល់ដូចខាងក្រោម ពីរបាយការណ៍ដែលថា សមាជិក CPP បានទទួលក្រដាសតូចមួយសំរាប់យកទៅបង្ហាញមន្ត្រីការិយាល័យបោះឆ្នោត ដែលនាំឱ្យពួកគេអាចឡើងទៅដើមជួរបាន:

*"CPP បានផ្ទៀងផ្ទាត់ពត៌មានលំអិតទាំងអស់លើអ្នកបោះឆ្នោត គឺមាន ឈ្មោះ លេខប័ណ្ណបោះឆ្នោត និង ការិយាល័យបោះឆ្នោត ហើយកត់វាលើក្រដាសមួយ ប្រគល់ទៅឱ្យសមាជិកម្នាក់ៗ ។ FUNCINPEC មិនបានធ្វើដូច្នេះទេ ។ CPP ប្រគល់ក្រដាសនេះ ទៅឱ្យសមាជិកម្នាក់ៗរបស់ខ្លួន ដូច្នេះនៅពេលពួកគេទៅដល់ការិយាល័យបោះឆ្នោត គឺអាចរកឈ្មោះលើបញ្ជីបោះឆ្នោតឃើញលឿនណាស់ ។ ប្រជាជនគិតថា ពួកនោះគ្រាន់តែបង្ហាញក្រដាសមួយ ក៏ត្រូវបានគេអនុញ្ញាតឱ្យចូលមុនគេ ប៉ុន្តែតាមពិតគឺពីព្រោះពួកគេអាចរកឈ្មោះឃើញលឿនជាង"[១៥០] ។*

សេចក្តីរាយការណ៍ទាំងនេះបញ្ជាក់ថា នៅកន្លែងជាច្រើនក្នុងប្រទេសកម្ពុជា អ្នកបោះឆ្នោតដែល CPP បានជួយ គឺបានទទួលពត៌មានច្រើនជាងអ្នកឯទៀតៗ ។ COMFREL រាយការណ៍ដែរថា សកម្មភាពកាលពីខែកុម្ភៈរបស់ SRP ធ្វើការចែកចាយផ្ទាំងក្រដាសប៉ូស្ទ័រ និងប័ណ្ណផ្សព្វផ្សាយ ព្រមទាំងចាក់កាសែតផ្សាយសំលេងអំពាវនាវឱ្យប្រជាជនទៅចុះបញ្ជី និងផ្ទៀងមើលឈ្មោះ ត្រូវបាន គជប បញ្ឈប់វិញដោយសំអាងថា SRP ប្រើប្រាស់សកម្មភាពទាំងនេះជាលេសដើម្បីធ្វើការឃោសនាដោយខុសច្បាប់[១៥១] ។

សំណួរចោទឡើងគឺ តើភាពមិនស្មើគ្នាបែបនេះគួរចាត់ទុកជារឿងធម្មតាក្នុងការប្រកួតប្រជែងរវាងគណបក្សនយោបាយនានា ឬក៏វាធ្វើឱ្យមានភាពលំអៀងនៅក្នុងដំណើរការបោះឆ្នោត ដែលបង្កការលំបាកដល់សមាជិកគណបក្សតូចៗ និងរៀបចំមិនសូវបានល្អ ក្នុងការប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន ។ ទំនាស់អំពីការចុះបញ្ជីអ្នកបោះឆ្នោត ស្ថិតក្នុងចំណោមទំនាស់ធំៗបំផុតនៃការបោះឆ្នោត និងឃើញលេចធ្លោជាងគេក្នុងការតវ៉ា និងទាត់ចោលលទ្ធផលពីសំណាក់ SRP និង FUNCINPEC ។ ក្នុងសេចក្តីប្រកាសរួមរបស់ពួកគេដែលទាត់ចោលលទ្ធផលបោះឆ្នោត SRP និង FUNCINPEC អះអាងថា ពួកគេធ្វើឡើង:

*"ក្នុងនាមអ្នកបោះឆ្នោតមានសិទ្ធិប្រហែលប្រាំរយពាន់នាក់ដែល គជប បានបង្កើតឧបសគ្គបំបាត់សិទ្ធិរបស់ពួកគេក្នុងការចុះបញ្ជី កាលពីខែមករា និងកុម្ភៈ ២០០៣, និងក្នុងនាមអ្នកបោះឆ្នោតបានចុះបញ្ជីជាងមួយលាននាក់ដែល គជប បានប្រើកលល្បិចគ្រប់បែបយ៉ាង ដូចជា ការអនុញ្ញាតឱ្យដកហូតប័ណ្ណបោះឆ្នោតពីពួកគេ, ការផ្លាស់ប្តូរកន្លែងការិយាល័យបោះឆ្នោតដោយមិនបានជូនដំណឹងគ្រប់គ្រាន់ បញ្ជីអ្នកបោះឆ្នោតមានកំហុសពាសពេញធ្វើឱ្យអ្នកបោះឆ្នោតមួយចំនួនធំ មិនអាចរកឈ្មោះឃើញ, ដើម្បីរារាំងពួកគេមិនឱ្យបោះឆ្នោតនៅថ្ងៃទី២៧ កក្កដា ២០០៣ ដោយប្រឆាំងនឹងសិទ្ធិ និង គោលបំណងរបស់ពួកគេ"[១៥២] ។*

---

[១៤៩] NEC representative (8), personal interview, Phnom Penh, 6 Oct 2003.

[១៥០] NEC representative (54), personal interview, Phnom Penh, 7 Oct 2003.

[១៥១] COMFREL, "Assessment Report on Voter Registration Process for the July 2003 National Assembly Elections," Phnom Penh, 7 Mar. 2003.

[១៥២] Alliance of Democrats (SRP and FUNCINPEC), "Joint Declaration to Reject the Results of the Election Released by National Election Committee (NEC)," Phnom Penh, 8 Aug. 2003, posted to Camnews camnews@cambodia.org 8 Aug. 2003.

SRP បានផ្តោតជាពិសេសលើករណីនៅប៉ោយប៉ែត (ដែល SRP ពិពណ៌នាថាជា "មូលដ្ឋានរឹងមាំ" របស់ខ្លួន) ដោយដាក់បណ្តឹងតវ៉ាទៅ គជប ថា អ្នកបោះឆ្នោត ២០.០០០នាក់ក្នុងក្រុងនេះ ត្រូវបានបំបាត់សិទ្ធិ ។ SRP មើលឃើញរឿងនេះជាកត្តាដាច់ណោត់ដែលធ្វើឱ្យ SRP ត្រូវបាត់បង់អាសនៈទី២ នៅខេត្តបន្ទាយមានជ័យ ។ ការដែល គជប ទាត់ចោលបណ្តឹងតវ៉ានេះដោយ សំអាងថាគ្មានភស្តុតាងគ្រប់គ្រាន់ និងដោយមិនធ្វើសវនាការជាសាធារណៈ ត្រូវបាន SRP ទិតៀនយ៉ាងខ្លាំង ។ បញ្ហានោះនៅ មិនទាន់ដោះស្រាយបានរួចទេ ។

## ៤.២ ទំនាស់អំពីប្រធានភូមិ

### *៤.២.១ ប្រភេទទំនាស់*

ជាបន្ថែមលើតួនាទីរបស់ប្រធានភូមិក្នុងការចែកចាយពត៌មានទាក់ទិននឹងការបោះឆ្នោត មានការចោទប្រកាន់ថា ប្រធានភូមិមានធ្វើសកម្មភាពទិញសន្លឹកឆ្នោត បំភិតបំភ័យ ដកហូតប័ណ្ណបោះឆ្នោតដោយខុសច្បាប់ និងធ្វើអំពើខុសច្បាប់ និងការគំរាមកំហែងជាច្រើនទៀតក្នុងរយៈពេលបោះឆ្នោត ។ SRP និង FUNCINPEC បានលើករឿងនេះក្នុងសេចក្តីប្រកាសរបស់ខ្លួនដែលទាត់ចោលលទ្ធផលបោះឆ្នោត និងដែលបង្ហាញថា វាជាទំនាស់បោះឆ្នោតមួយដ៏សំខាន់ ។ គណបក្សទាំងពីរអះអាងថា បានបដិសេធការបោះឆ្នោត "ក្នុងនាមអ្នកបោះឆ្នោតច្រើនសែននាក់ដែលបានបោះឆ្នោតនៅថ្ងៃបោះឆ្នោត នៅក្រោមការគំរាមកំហែងរបស់ CPP ដែលប្រើប្រាស់អាជ្ញាធរមូលដ្ឋាន រួមទាំងប្រធានភូមិផង ធ្វើជាឧបករណ៍របស់ខ្លួនដោយឃុបឃិតជាមួយ គជប"[១៥៣] ។

ការចោទប្រកាន់របស់ SRP ពីអំពើហិង្សា ការបំភិតបំភ័យ និងការឆាឆៅបង្អាក់សកម្មភាពបោះឆ្នោត ឃើញមានតាំងពីដើមទីនៃការឃោសនាបោះឆ្នោត ។ ក្នុងព្រឹត្តប័ត្រឃោសនាបោះឆ្នោតរបស់ខ្លួនដែលចុះក្នុងអ៊ិនធឺណិត SRP បានចោទប្រកាន់ថាពួកប្រធានភូមិបានគំរាមកំហែងសមាជិក និងអ្នកគាំទ្រ SRP ។ ឧទាហរណ៍ អត្ថបទចុះថ្ងៃទី០១ កក្កដា បានអះអាងថាសកម្មភាពដូចតទៅបានកើតមានឡើងៈ

> *"ភ្នំពេញៈ ក្នុងខ័ណ្ឌ ៧ មករា, ថ្ងៃសុក្រ ២៧ មិថុនា ២០០៣, ប្រធានក្រុមប្រឡាយ ឈ្មោះ ជ្រុង បានហែកប័ណ្ណផ្សព្វផ្សាយរបស់ SRP និងបានព្រមានសកម្មជន និងអ្នកគាំទ្រ SRP នៅភូមិនោះមិនឱ្យរៀបចំធ្វើការឃោសនា ។ ឈ្មោះ ជ្រុង បានបញ្ជាដល់សកម្មជន SRP ឈ្មោះ អៀង ជា, ឱ្យទំលាក់ទង់ SRP ក្នុងរយៈពេល ២៤ម៉ោង ។ SRP បានដាក់បណ្តឹងមួយលេខ ០៤៨ ជូន គឃប នៅថ្ងៃដដែលនោះ"* ។

> *" កំពង់ធំ នៅថ្ងៃសុក្រ ២៧ មិថុនា ២០០៣, នៅភូមិចុគុលោក, ស្រុកបារាយ, ឈ្មោះ សៅ ចិល បានចែកចាយ និងបិទប័ណ្ណផ្សព្វផ្សាយរបស់ SRP នៅក្នុងភូមិ ។ នៅប្រហែលម៉ោងពីរ ប្រធានភូមិឈ្មោះ វេន ផល្លី បានជេរប្រមាថ សៅ ចិល ថា "ឯងជាសមាជិក SRP, ឯងកុំរស់នៅលើទឹកដីរបស់ ហ៊ុន សែន និងជា ស៊ីម" រួចបានកាប់ សៅ ចិល ធ្វើឱ្យរបួសដៃ, ក្បាលជង្គង់, និងប្រដាប់បន្តពូជ (ពង) ។ សៅ ចិល ត្រូវបានដឹកយកទៅពេទ្យ ។ ប៉ូលីសបានចាប់ខ្លួន វេង ផល្លី ហើយបន្ទាប់មកក៏លែងវិញ ។ សៅ ចិល (មិនមែន វេង ផល្លី ទេ) ត្រូវគេចោទថាបានវាយទៅលើ វេង ផល្លី ដោយប៉ូលីសបានរកឃើញដំបងដែកមួយនៅក្រោមផ្ទះ សៅ ចិល ។ ការិយាល័យ SRP ថ្នាក់ខេត្ត បានដាក់បណ្តឹងជាច្រើនជូន គខប កំពង់ធំ"[១៥៤]* ។

---

[១៥៣] Alliance of Democrats (SRP and FUNCINPEC), Joint Declaration to Reject the Results of the Election Released by National Election Committee (NEC), Phnom Penh, 8 Aug. 2003, posted to Camnews camnews@cambodia.org 8 Aug. 2003.

[១៥៤] Extracts from SRP Campaign Bulletin, 1 July 2003, online at http://www.samrainsyparty.org/campaign_bulletin/2003/20030701.htm

អ្នកធ្វើការរបស់ SRP ថ្នាក់ខេត្តម្នាក់បានលើកឡើង ក្នុងរយៈពេលឃោសនាបោះឆ្នោត:

*"មានបញ្ហាជាច្រើននៅកំរិតឃុំ ភូមិ និងក្រុម ។ ថ្នាក់ភូមិ និងក្រុម មានអំណាចខ្លាំង ហើយពួកគេបានបំភិតបំភ័យអ្នកភូមិ ។ បើសិនខាង SRP លើកផ្លាកគណបក្ស ឬជួបប្រជុំគ្នា, ពួកគេបំភិតបំភ័យពួកអ្នកភូមិនៅតាមក្រោយ ។ អាជ្ញាធរមូលដ្ឋានធ្វើដូច្នេះ នៅពេលមានអ្នកថ្នាក់ខ្ពស់ណាម្នាក់ចុះមកដល់ខេត្ត ។ បើមានអ្នកណាទៅស្តាប់ គេកត់ឈ្មោះអ្នកនោះក្នុងបញ្ជីមួយ ។ ហើយក្រោយមកបើអ្នកនោះមានបញ្ហាអ្វីមួយ គេប្រាប់អ្នកនោះឱ្យទៅរក SRP ឱ្យដោះស្រាយបញ្ហា ឱ្យចុះ"*[១៥៥] ។

ការព្រួយបារម្ភពីតួនាទីប្រធានភូមិ ក៏ឃើញមានចុះដែរនៅក្នុងរបាយការណ៍របស់អ្នកសង្កេតការណ៍បោះឆ្នោតនៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត ។ ក្នុងរយៈពេលចុះបញ្ជីអ្នកបោះឆ្នោតថ្មីពីថ្ងៃ ១៥ មករា ដល់ ២០ កុម្ភៈ, COMFREL បានរាយការណ៍ថា "ក្នុងពេលនេះអ្នកបោះឆ្នោតត្រូវបានបង្ខំឱ្យស្បថ (ដោយផឹកទឹកសម្បថ ផ្តិតមេដៃ ឬវិធីអ្វីផ្សេង) ដោយអាជ្ញាធរមូលដ្ឋានដែលមានបំណងបំរើផលប្រយោជន៍នយោបាយ (ចំពោះសមាជិកគណបក្សខ្លួន) ជាពិសេសពួកប្រធានភូមិក្នុងកន្លែងមួយចំនួននៃខេត្តបាត់ដំបង និងកំពត"[១៥៦] ។

ក្នុងរបាយការណ៍ដដែល COMFREL បានរៀបរាប់លំអិតនូវបណ្តឹងចំនួន១៩ តវ៉ាស្តីពីការគំរាមកំហែង និងបំភិតបំភ័យធ្ងន់ធ្ងរ ។ ក្នុងនេះមាន ១១ករណីដែលជនល្មើសគឺជាថ្នាក់ដឹកនាំស្រុក ឃុំ និងភូមិ ឬខាងប៉ូលីស ។ នៅថ្ងៃ ១៩ មិថុនា មុនពេលចាប់ផ្តើមឃោសនាបោះឆ្នោត COMFREL រាយការណ៍ថា "COMFREL បានពិនិត្យឃើញករណីជាច្រើនដែលថ្នាក់ដឹកនាំភូមិ និងឃុំ បានគំរាមកំហែង និងបំភិតបំភ័យគណបក្ស និងអ្នកគាំទ្រគណបក្សមួយចំនួននៅខេត្តតាកែវ កំពង់ស្ពឺ ព្រៃវែង សៀមរាប និងកំពង់ធំ ។ ក្នុងនេះគឺមានថ្នាក់ដឹកនាំភូមិដែលប្រមូលប័ណ្ណបោះឆ្នោតនៅក្នុងវត្ត (កន្លែងដែលគេស្នើឱ្យប្រជាជនសន្យាចំពោះគណបក្ស) និងថ្នាក់ដឹកនាំឃុំដែលគំរាមកំហែងប្រជាជន មិនឱ្យចូលរួមការប្រជុំរបស់គណបក្សជំទាស់ និងដែលកត់ត្រាឈ្មោះប្រជាជនអ្នកបានទៅចូលរួម"[១៥៧] ។

ប្រាំថ្ងៃក្រោយពេលចាប់ផ្តើមឃោសនាបោះឆ្នោត, NGOs ខាងសិទ្ធិមនុស្សមួយក្រុមបានចេញសេចក្តីប្រកាសមួយដែលចោទប្រកាន់ប្រធានភូមិ និងអាជ្ញាធរមូលដ្ឋានម្តងទៀតថាបានបំភិតបំភ័យ និងរារាំងដល់ពួកអ្នកឃោសនាឱ្យគណបក្សជំទាស់ ដោយលើកឡើងថា:

*"ករណីមិនប្រក្រតីក៏ឃើញមានច្រើនដែរ ដែលផ្ទុយពីច្បាប់បោះឆ្នោត ។ ឧទាហរណ៍ ប្រធានភូមិមិនព្រមអនុញ្ញាតកន្លែងណាមួយឱ្យគណបក្សមិនកាន់អំណាច ចាប់ផ្តើមធ្វើការឃោសនាបោះឆ្នោត និងផ្សព្វផ្សាយពីគោលនយោបាយរបស់គណបក្សខ្លួន, បានហាមឃាត់ប្រជាជនជាអ្នកគាំទ្រគណបក្សជំទាស់ក្នុងការចូលរួម និងស្តាប់ការឃោសនារបស់គណបក្សជំទាស់, បានបញ្ចុះបញ្ចូល និងកៀងគរប្រជាជនតាមគ្រប់មធ្យោបាយ ផ្លាកសញ្ញារបស់គណបក្សមិនកាន់អំណាច និងបានជួយសំរួលដល់ការចែកអំណោយក្នុងរយៈពេលឃោសនាបោះឆ្នោត ។ គេឃើញមានមួយចំនួនដែរនូវករណីប៉ូលីស, កងទ័ព, ថ្នាក់ដឹកនាំភូមិ និងឃុំ ដែលគាំទ្រគណបក្សកាន់អំណាច ពីព្រោះបំពេញតួនាទីរបស់ខ្លួនដើម្បីជួយឃោសនាឱ្យគណបក្សកាន់អំណាច និងមិនជួយការពារគណបក្សមិនកាន់អំណាច*

---

១៥៥ SRP provincial activist (52), Kampot province, personal interview, 16 July 2003.

១៥៦ COMFREL, "Assessment Report on Voter Registration Process for the July 2003 National Assembly Elections," Phnom Penh, 7 March 2003.

១៥៧ COMFREL, "COMFREL urges government to open up the political environment and requests NEC to review the interpretation of the election law's vote counting process," press release, Phnom Penh, 19 June, 2003.

*ទេនៅពេលមានដំណើរហែក្បួនខាង CPP និងគាបសង្កត់/រំខានដល់ការឃោសនាហែក្បួនខាង SRP ។ ព្រឹត្តិការណ៍នេះអាចបង្កអំពើហិង្សា*[១៥៨] ។

នៅចុងរយៈពេលឃោសនាបោះឆ្នោត EMOs ចំបងៗមានទាំង COMFREL និង NICFEC បានបូកសរុបថា ពួកគេមានភស្តុតាងនៃ "ករណីច្រើនពាសពេញនៃការប្រើប្រាស់ការរើសអើង និងទ័ណ្ឌកម្មខាងសង្គមកិច្ច ដើម្បីត្រួតត្រាលើអ្នកបោះឆ្នោតនៅតំបន់ឆ្ងាយៗ: ប្រធានភូមិ និងអាជ្ញាធរមូលដ្ឋាន បានផាត់អ្នកភូមិចេញពីឱកាសល្អៗនៃការអភិវឌ្ឍន៍ខាងសង្គមកិច្ច បើសិនមិនបោះឆ្នោតឱ្យគណបក្សកាន់អំណាច"[១៥៩] ។ COMFREL និង NICFEC រាយការណ៍ថា បានសង្កេតឃើញមានទាំងអស់ "៥៩៥ករណីនៃមន្ត្រីរាជការដែលមិនអព្យាក្រឹត្យក្នុងពេលបំពេញការងាររបស់ខ្លួន"[១៦០] ។

នៅថ្ងៃបោះឆ្នោត COMFREL រាយការណ៍ថា "មានយ៉ាងតិច ៤៦២ករណីប្រធានភូមិដែលនៅរ៉ែរ៉ៃខាងក្រៅការិយាល័យបោះឆ្នោត" ។COMFREL និង NICFEC លើកឡើងថា:

*"ចំណុចបារម្ភធំបំផុតគឺការបន្តលំនាំនៃការបំភិតបំភ័យ និងការឃោសនាខុសច្បាប់ដោយពួកមន្ត្រីឃុំ ដែលបានពិនិត្យឃើញក្នុងទូទាំងរយៈពេលឃោសនា ។ អ្នកដឹកនាំខ្លាំងៗនៅមូលដ្ឋាន និងប្រធានភូមិ ត្រូវបានពិនិត្យឃើញនៅរ៉ែរ៉ៃខាងក្រៅការិយាល័យបោះឆ្នោត ធ្វើឱ្យអ្នកបោះឆ្នោតមួយចំនួនមានអារម្មណ៍មិនសូវស្រួលក្នុងខ្លួន ។ថ្វីបើការគាបសង្កត់ភាគច្រើន គឺជាពាក្យសំដីក្តី ប៉ុន្តែវាបង្កើតបរិយាកាសមួយមានការគំរាមកំហែង និងអសន្តិសុខសំរាប់អ្នកបោះឆ្នោត"*[១៦១] ។

NGO សិទ្ធិមនុស្សអន្តរជាតិ Human Rights Watch (តាមដានសិទ្ធិមនុស្ស) ក៏បានផ្សព្វផ្សាយរបាយការណ៍មួយដែលមានរៀបរាប់លំអិតពីករណីចោទប្រកាន់ថាប្រធានភូមិបានបំភិតបំភ័យស្ត្រីមេម៉ាយម្នាក់នៅស្រុកគីរីវង្ស ខេត្តតាកែវ, និងករណីការជួបប្រជុំកោះហៅដោយប្រធានភូមិនៅខេត្តសៀមរាប ដែលក្នុងនេះគេបង្ខំពួកអ្នកគាំទ្រ FUNCINPEC ឱ្យចូល CPP[១៦២] ។ ការតវ៉ានៅក៏រិតជាតិស្តីពីប្រធានភូមិ បានបង្ហាញម្តងទៀតពីការបារម្ភចំពោះក្រុមនេះដោយតួអង្គថ្នាក់ឃុំនៅក្នុងករណីសិក្សានានារបស់យើង ។

### *៤.២.២ ការគ្រប់គ្រងទំនាស់*

គជប បានឆ្លើយតបនឹងការតវ៉ាជាទូទៅពីអាជ្ញាធរមូលដ្ឋាន ជាពិសេសប្រធានភូមិ ក្នុងទូទាំងរយៈពេលបោះឆ្នោត, ដោយចេញរួមគ្នាជាមួយក្រសួងមហាផ្ទៃនូវសេចក្តីណែនាំមួយឱ្យប្រធានភូមិ "ស្ថិតនៅជាអព្យាក្រឹត្យ និងមិនប្រកាន់បក្សពួក និងចៀសវាងបង្ហាញការចូល ឬមិនចូលចិត្តចំពោះគណបក្សនយោបាយ ឬបេក្ខជនណាមួយ"[១៦៣] ។ បន្ទាប់មកមានសេចក្តីណែនាំទី២ ចុះថ្ងៃ១៧ កក្កដា ដែលរៀបរាប់ពីសកម្មភាព ៥ប្រភេទដែលត្រូវហាមឃាត់:

---

[១៥៨] ADHOC, COMFREL, NICFEC and Youth Council of Cambodian (CYC), “Joint Statement On Concerns of Violence during the First Five Days of the Election Campaign for the Third Mandate of the 2003 National Assembly Elections,” pres release, Phnom Penh, 2 July 2003.

[១៥៩] COMFREL, NICFEC, “Pre-Election Joint Assessment,” press release, Phnom Penh, 25 July 2003.

[១៦០] COMFREL, NICFEC, “Pre-Election Joint Assessment,” press release, Phnom Penh, 25 July 2003.

[១៦១] COMFREL, NICFEC, “Joint Statement, The Findings of Cooling Day, Polling and Ballot Counting Periods *Phnom Penh,” press release, Phnom Penh, 6 August, 2003.*

[១៦២] Human Rights Watch, “Don’t Bite the Hand that Feeds You, Coercion, Threats and Vote-Buying in Cambodia’s National Elections,” Briefing Paper, July 2003, online at www.hrw.org/backgrounder/asia/cambodia/elections.html.

[១៦៣] NEC and MOI Joint Directive No. 004 S.N.N, 22 May 2003.

១) ប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីជះឥទ្ធិពលលើសេរីភាពជ្រើសរើសរបស់អ្នកបោះឆ្នោតក្នុងការបោះឆ្នោត

២) ដកហូតប័ណ្ណបោះឆ្នោត ឬប្តូរប័ណ្ណបោះឆ្នោត/ឯកសារសំគាល់អត្តសញ្ញាណណាមួយរបស់អ្នកបោះឆ្នោត ទោះក្នុងកាលៈទេសៈអ្វីក៏ដោយ

៣) ចោទសួរអ្នកបោះឆ្នោតក្នុងគោលដៅជះឥទ្ធិពល ឬចង់ដឹងពីជំរើសបោះឆ្នោតជាសំងាត់នៃអ្នកបោះឆ្នោត

៤) ជ្រៀតជ្រែកសិទ្ធិនៃអ្នកបោះឆ្នោតក្នុងការ ធ្វើសេចក្តីសំរេចចិត្តដោយសេរី, ចូលរួមការពិភាក្សាជាសាធារណៈ, ចូលរួមក្នុងសកម្មភាពនយោបាយ, ឬទទួលពត៌មានពេញលេញពីកិច្ចការនយោបាយ

៥) ធ្វើសកម្មភាពតាមវិធីអ្វីមួយដែលបំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោត[១៦៤] ។

តំណាងរបស់ NGO មួយបានផ្តល់មតិពីសេចក្តីណែនាំនេះថា "បទពិសោធន៍របស់យើងក្នុងវិស័យនេះបង្ហាញថា លិខិតនេះល្អខ្លាំងណាស់"[១៦៥] ។ នៅថ្ងៃ២៥ កក្កដា, គជប ឈានទៅមុខទៀតដោយប្រកាសពីសេចក្តីសំរេចមួយរបស់ក្រសួងមហាផ្ទៃ ដែលព្យួរតួនាទីរបស់ប្រធានភូមិ ៣នាក់នៅខេត្តព្រៃវែង កំពង់ចាម និងក្រចេះ ដោយរង់ចាំលទ្ធផលស៊ើបអង្កេតពីការចោទប្រកាន់ថាមានការគំរាមកំហែងធ្ងន់ធ្ងរទៅលើអ្នកគាំទ្រ FUNCINPEC និង SRP ។ ក្នុងនេះ ប្រធានភូមិម្នាក់ (ដែលការិយាល័យនៅកម្ពុជានៃអគ្គស្នងការខាងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចោទប្រកាន់ក្នុងរបាយការណ៍មួយថា បានបំភិតបំភ័យអ្នកគាំទ្រខាង FUNCINPEC នៅពេលប្រជុំមួយ ឱ្យចូលខាង CPP) ត្រូវបាន គជប ឱ្យរួចផុតពីការចោទប្រកាន់វិញដោយប្រកាសថា "ពុំមានសាក្សី ភស្តុតាង និងមូលដ្ឋានច្បាស់លាស់សំរាប់ការចោទប្រកាន់ថា លោក ឡុន ដេត បានគំរាមកំហែង និងបំភិតបំភ័យពួកអ្នកគាំទ្រ, ហើយរឿងប្រជាពលរដ្ឋ ២៨នាក់ដែលបានចេញពី FUNCINPEC ទៅចូល CPP មិនមែនជាភស្តុតាងនៃការបំភិតបំភ័យ ឬការគំរាមកំហែងទេ"[១៦៦] ។

ប៉ុន្តែ សកម្មភាពនេះទទួលការរិះគន់ពីតំណាងពិសេសនៃអង្គការសហប្រជាជាតិសំរាប់សិទ្ធិមនុស្សដែលគិតថា វាយឺតហួសពេលបន្តិចៈ

> *"ក្នុងករណីភាគច្រើន គជប, អនុគណៈកម្មការថ្នាក់ខេត្ត និងមូលដ្ឋានរបស់ គជប, និងអាជ្ញាធរអ្នកពង្រឹងការអនុវត្តន៍ច្បាប់ មិនបានឆ្លើយតបទៅនឹងព្រឹត្តិការណ៍គំរាមកំហែងទាក់ទិននឹងការបោះឆ្នោតទេ ។ មានតែមួយករណីប៉ុណ្ណោះដែលគេដឹងថា មានការដាក់ទណ្ឌកម្មរបស់ គជប នៅមុនពេលបោះឆ្នោត ។ ក្នុង ៣ ករណីទៀត នៅជិតថ្ងៃបោះឆ្នោត ក្រសួងមហាផ្ទៃ បានចេញបញ្ជាព្យួរជាបណ្តោះអាសន្ននូវតួនាទីរបស់ប្រធានភូមិដែលទទួលការចោទប្រកាន់ថា បានធ្វើការបំភិតបំភ័យទាក់ទិននិងការបោះឆ្នោត"[១៦៧] ។*

គជប បានរិះគន់ថា ការរកឱ្យឃើញពួកប្រធានភូមិដែលបានរំលោភច្បាប់ និងដាក់ទណ្ឌកម្មលើពួកគេមានចោទបញ្ហាជាច្រើន ។ សមាជិក គជប ម្នាក់បានជជែករិះគន់ថា ជារឿយៗករណីបំភិតបំភ័យមានភស្តុតាងបញ្ជាក់ខ្សត់ខ្សោយណាស់:

[១៦៤] National Election Committee Directive No. 07.1499/03, 17 July 2003, available online at www.necelect.org.kh

[១៦៥] CHRC national representative (55), personal interview, Phnom Penh, 13 Aug, 2003.

[១៦៦] National Election Committee, “Clarification,” press release, Phnom Penh, 1 Sept 2003.

[១៦៧] Peter Leuprecht, “Situation of Human Rights in Cambodia,” Report by the Special Representative for Human Rights in Cambodia to the General Assembly, 22 Aug. 2003, para. 21.

*"បើសិនប្រធានភូមិម្នាក់ទៅកន្លែងការិយាល័យបោះឆ្នោត រឿងនេះគ្មានអ្វីបញ្ជាក់គាំទ្រឱ្យប្រាកដប្រជាសោះថា គាត់នៅទីនោះដើម្បីបំភិតបំភ័យអ្នកបោះឆ្នោត ។ យើងបានដាក់ទណ្ឌកម្មប៉ុន្មាននាក់ដែរ នៅពេលយើងអាចរកបានភស្តុតាង ប៉ុន្តែបើគ្រាន់តែចោទថា គាត់ឈរសំលឹងទៅប្រជាជន រឿងនេះមិនគ្រប់គ្រាន់ទេ ។ បើសិនខ្ញុំចង់ដាក់ទណ្ឌកម្មអ្នក ខ្ញុំត្រូវមានភស្តុតាងគ្រប់គ្រាន់"*[១៦៨] ។

មតិនេះគួសបញ្ជាក់ពីការលំបាកអនុវត្តឱ្យបានតឹងរ៉ឹងតាមដំណើរការច្បាប់ ក្នុងករណីដែលការគំរាមកំហែង ដូចគេបានត្អូញត្អែរនោះ ភាគច្រើនគឺគ្មានការនិយាយអ្វីទេ ។ តំណាង SRP ម្នាក់បានពិពណ៌នាពីសមត្ថភាពរបស់ប្រធានភូមិក្នុងការបង្កអារម្មណ៍ភ័យខ្លាចក្នុងចំណោមអ្នកគាំទ្រគណបក្សជំទាស់ ដោយមិនបាច់ធ្វើសកម្មភាពអ្វីយ៉ាងជាក់លាក់នោះទេ:

*"ភូមិមួយមានផ្ទះតែប៉ុន្មានរយខ្នងប៉ុណ្ណោះ ។ ប្រធានភូមិស្គាល់គ្រប់គ្នា ដឹងថាអ្នកណាបោះឆ្នោតឱ្យអ្នកណា ដឹងពីទំនោរចិត្តខាងនយោបាយ ។ គេដឹងថាអ្នកណាគាំទ្រពួកគេខ្លាំង ។ អ្នកឯទៀតជាច្រើននឹងមិននិយាយអ្វីទេ ប៉ុន្តែអ្នកដែលមិនគាំទ្រខ្លាំងជាជនជាប់សង្ស័យ ។ បើសិនប្រធានភូមិទទួលការអនុញ្ញាតឱ្យតំណាង CPP, គាត់ស្គាល់មនុស្សគ្រប់គ្នា ហើយរឿងនេះអាចធ្វើឱ្យពួកអ្នកគាំទ្រយើងមានការភ័យខ្លាច ។ បញ្ហានេះធ្វើឱ្យយើងបារម្ភ"*[១៦៩] ។

សរុបមក ការអះអាងថា ប្រធានភូមិអាចបំភិតបំភ័យអ្នកភូមិតាមរយៈវត្តមានរបស់គាត់ គឺជាការអះអាងមួយដែលពិបាកបញ្ជាក់ភស្តុតាងតាមផ្លូវច្បាប់ ។ ប៉ុន្តែករណីភាគច្រើនដែលគណបក្សនយោបាយ និងអង្គការឃ្លាំមើលការបោះឆ្នោត បានរកឃើញ គឺមានសកម្មភាពជាក់លាក់ច្រើនជាងនេះ ដូចជា ការគំរាមកំហែងពីការរើសអើង ប្រឆាំងនឹងអ្នកគាំទ្រគណបក្សជំទាស់ក្នុងគំរោងអភិវឌ្ឍន៍នៅអនាគត, ការដកហូតប័ណ្ណបោះឆ្នោត និងការកត់ត្រាលេខប័ណ្ណ, ការហាមប្រាមអ្នកភូមិមិនឱ្យចូលរួមការដង្ហែក្បួនរបស់គណបក្សជំទាស់ជាដើម ។ សកម្មភាពបែបនេះ គួរតែស្រួលរកភស្តុតាងបញ្ជាក់ជាងច្រើន ។

ប៉ុន្តែក្នុងការព្យាយាមដោះស្រាយករណីទាំងនេះ គជប មានលទ្ធភាពតិចតួច ពីព្រោះច្បាប់បោះឆ្នោតបានផ្តល់សិទ្ធិអំណាចឱ្យតិចពេកក្នុងការដាក់ទ័ណ្ឌកម្មលើអ្នកធ្វើខុស ។ ច្បាប់បោះឆ្នោតគ្មានផ្តល់សិទ្ធិអំណាចអ្វីឱ្យ គជប ដើម្បីត្រួតពិនិត្យការងាររបស់មន្ត្រីរាជការ ក្រៅពីបុគ្គលិករបស់ គខប និង គឃប នោះទេ ។ ច្បាប់បានតំរូវថា:

*អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀតត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់*[១៧០] ។

ក្នុងករណីមន្ត្រីរាជការមិនបានអនុវត្តតាមកាតព្វកិច្ចនេះ គជប អាចដកឈ្មោះពួកគេពីបញ្ជីបោះឆ្នោតចំនួន ៥ឆ្នាំ ឬ "ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនដើម្បីឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរ៍ រហូតដល់ការបណ្តេញចេញពីមុខតំណែង យោងទៅតាមកំរិតនៃបទល្មើស"[១៧១] ។ សំរាប់ពួកប្រធានភូមិ រឿងនេះតំរូវថា ការដាក់ទ័ណ្ឌកម្មត្រូវ

---

[១៦៨] NEC member (5), personal interview, Phnom Penh, 8 Oct 2003.

[១៦៩] SRP national representative (3), personal interview, Phnom Penh, 10 July 2003.

[១៧០] Law on the Election of Members of the National Assembly, as amended 2002, Art 29.

[១៧១] Law on the Election of Members of the National Assembly, as amended 2002, Art 127.

ឆ្លងកាត់តាមក្រសួងមហាផ្ទៃ ។

គជប មានសិទ្ធិអំណាចផ្តន្ទាទោសពិន័យជាប្រាក់រហូតដល់ ២៥លានរៀល និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសំរាប់រយៈពេល ៥ឆ្នាំ ចំពោះជនណាដែលរំលោភច្បាប់បោះឆ្នោត ។ បទល្មើសត្រូវផ្តន្ទាទោសរួមមាន ការយកអាវុធចូលក្នុងកន្លែងជាប់ទាក់ទិននឹងដំណើរការបោះឆ្នោត, ការរុករើអុកឡុកដល់សន្លឹកឆ្នោត និងហិបឆ្នោត, ឬការព្យាយាមជះឥទ្ធិពលលើអ្នកបោះឆ្នោតក្នុងដំណើរការបោះឆ្នោត ។ ទោសទ័ណ្ឌប្រហាក់ប្រហែលគ្នាអាចដាក់លើសមាជិកគណបក្សនយោបាយដែលរំលោភវិធានផ្សេងៗនៃការឃោសនាបោះឆ្នោត ឬពួកមន្ត្រីដែលរារាំងគណបក្សនយោបាយមិនឱ្យធ្វើការឃោសនាបានស្មើភាពគ្នា[១៧២] ។

ម្យ៉ាងទៀត ក្នុងច្បាប់បោះឆ្នោតគ្មានសេចក្តីចែងជាក់លាក់ទេពីការប្រព្រឹត្តិខ្លួនរបស់មន្ត្រីរាជការ ក្រៅពីសមាជិក គជប គខប និង គឃប ។ បទប្បញ្ញត្តិ គជប មានចែងមានចំនួនពីអព្យាក្រឹតភាពរបស់មន្ត្រីរាជការ និងអាជ្ញាធរមូលដ្ឋានជាអាទិ៍:

*"មន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋានគ្រប់កំរិត កងទ័ព ប៉ូលីសជាតិ មន្ត្រីតុលាការ ដែលកំពុងអនុវត្តភារកិច្ចមិនត្រូវ:*

១) ប្រើប្រាស់សិទ្ធិអំណាច និងតួនាទីរបស់ខ្លួន ដើម្បីជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅលើដំណើរការបោះឆ្នោត

២) កេៀងគរមន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋានគ្រប់កំរិត កងទ័ព ប៉ូលីសជាតិ មន្ត្រីតុលាការ នៅក្នុងអគារ និងការិយាល័យរបស់រដ្ឋ ដើម្បីប្រមូលសំលេងឆ្នោតដោយការបញ្ចុះបញ្ចូល និងដោយចេតនា

៣) ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសំរាប់គណបក្សនយោបាយណាមួយ[១៧៣] ។

ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត មានកំណត់និយមន័យក្នុងបទបញ្ជា ប៉ុន្តែសកម្មភាពដែលមានបញ្ជាក់ជាក់លាក់វាជាប់ទាក់ទិនភាគច្រើននឹងសកម្មភាពជាសាធារណៈដែលកើតមានក្នុងម៉ោងធ្វើការ ។ លទ្ធភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើសកម្មភាពនៅទីតាំងឯកជន ឬនៅក្រៅម៉ោងធ្វើការ គ្មានការដាក់កំរិតដូច្នេះទេ ។

ក្នុងន័យនេះ ការវិវត្តន៍ក្នុងច្បាប់នានាដែលទាក់ទិននឹងអាជ្ញាធរមូលដ្ឋាន ហាក់ដូចជាផ្អែកលើការសន្ទតផ្ទុយគ្នា ។ ម្យ៉ាងគឺនៅឆ្នាំ២០០៣ មានការប្រឹងប្រែងបង្កើនកិច្ចការពារអ្នកបោះឆ្នោតទប់ទល់នឹងការសងសឹកជាយថាហេតុអំពីមន្ត្រីមូលដ្ឋានដែលមានចំណងពាក់ព័ន្ធខាងនយោបាយ ដូចជា មានកំណត់ប្រភេទមន្ត្រីមូលដ្ឋានច្រើនទៀតដែលមិនអាចបំពេញតួនាទីក្នុងគណៈកម្មការបោះឆ្នោត[១៧៤] ។ បទប្បញ្ញត្តិ គជប បានរារាំងមេឃុំ និងប្រធានភូមិ មិនឱ្យចូលរួមការប្រជុំរបស់ គឃប សំរាប់គណបក្សនយោបាយ ដើម្បីកុំឱ្យគណបក្សជំទាស់អាចមើលឃើញវត្តមានរបស់ពួកគេ ថាជាការបំភិតបំភ័យ ។ ប៉ុន្តែក្នុងពេលជាមួយគ្នាលទ្ធភាពធ្វើការបំភិតបំភ័យ ដែលកើតមានតាមការអនុញ្ញាតឱ្យមន្ត្រីមូលដ្ឋានខ្លាំងៗ អាចចូលរួមយ៉ាងចំហជាមួយគណបក្សនយោបាយណាមួយ "នៅក្រៅម៉ោងធ្វើការ" គឺមិនត្រូវបានដោះស្រាយទេ ។ ឧទាហរណ៍ សេចក្តីប្រកាសពតិមានមួយរបស់ គជប ដើម្បីឆ្លើយតបនឹងការតវ៉ារបស់តំណាង SRP ស្តីពីសកម្មភាពប្រកាន់បក្សពួករបស់ប៉ូលីសម្នាក់នៅឃុំមួយនៅខេត្តកំពង់ធំ បានបញ្ជាក់ថា:

*"នៅថ្ងៃ២១ សីហា ២០០៣ លោក ឃុន សុផល ខាង SRP បានចោទប្រកាន់ លោក ភោគ លី អធិការរងប៉ូលីស*

---

[១៧២] Law on the Election of Members of the National Assembly, as amended 2002, Articles 129-133.

[១៧៣] NEC Regulations, §7.3

[១៧៤] Law on Election of Members of the National Assembly, as amended 2002, Arts 19\8, 20 and 22.

*នៅប្រាសាទសំបូរ ខេត្តកំពង់ធំ ថាមិនអព្យាក្រឹត្យ ។ គជប បានបំភ្លឺថា លោក ភោគ លី បានចូលរួមធ្វើការឃោសនាបោះឆ្នោតក្នុងពេលទំនេររបស់គាត់នៅថ្ងៃអាទិត្យ ២០ កក្កដា ២០០៣ ។ គជប បានគូសបញ្ជាក់ថា តាមជំពូក ៧ ប្រការ៧.៧ នៃបទបញ្ជា និងនីតិវិធី, មន្ត្រីរាជការស៊ីវិល អាជ្ញាធរមូលដ្ឋានគ្រប់កំរិត កងទ័ព ប៉ូលីសជាតិ មន្ត្រីតុលាការ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ អាចចូលរួមក្នុងសកម្មភាពឃោសនាបោះឆ្នោតបាន ។ ដូច្នេះ គជប បានបញ្ជាក់ថា សកម្មភាពរបស់លោក ភោគ លី គឺមិនផ្ទុយនឹងច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធី គជប ទេ*[១៧៥] ។

អ្នកគាំទ្រគណបក្សជំទាស់អះអាងថា លទ្ធភាពរបស់ប្រធានភូមិ និងប៉ូលីសមូលដ្ឋាន ក្នុងការគំរាមកំហែង និងបំភិតបំភ័យអ្នកបោះឆ្នោតតាមរយៈតួនាទីរបស់ខ្លួន មិនមែនមានត្រឹមតែម៉ោងធ្វើការទេ ហើយការឃោសនាដោយអាជ្ញាធរមូលដ្ឋាននៅថ្ងៃអាទិត្យ ក៏មានឥទ្ធិពលដូចគ្នានឹងថ្ងៃផ្សេងទៀតក្នុងសប្តាហ៍ដែរ ។ គណបក្សជំទាស់មើលឃើញថា គជប បានគូសបន្ទាត់បែងចែកដាច់រវាងបុគ្គល និងតួនាទីជាផ្លូវការ ដែលពុំមានសោះទេក្នុងភូមិនានានៅកម្ពុជា ពីព្រោះពួកគេជឿថា ប្រធានភូមិប្រើប្រាស់ការយល់ដឹងផ្ទាល់របស់គាត់ ពីទំនោរចិត្តខាងនយោបាយរបស់អ្នកភូមិ ដើម្បីអនុវត្តគោលនយោបាយរើសអើងនៅក្នុងតួនាទីជាផ្លូវការរបស់គាត់ ។ តួនាទីរបស់អាជ្ញាធរមូលដ្ឋាន ជាពិសេសប្រធានភូមិ នៅតែជាប្រភពខ្វែងមតិដ៏ធំ រវាងគណបក្សនយោបាយនានា និង គជប ក្នុងពេលបោះឆ្នោត ។

ការតវ៉ាពីប្រធានភូមិមួយចំនួន ជាប់ទាក់ទិននឹងសកម្មភាពដែលច្បាប់បោះឆ្នោតបានហាមឃាត់ចំពោះបុគ្គលគ្រប់គ្នា ។ ឧទាហរណ៍ច្បាប់បោះឆ្នោតមានចែងពីទោសទ័ណ្ឌពិន័យជាប្រាក់ ឬឮសិទ្ធិបោះឆ្នោតលើជនណាមួយដែលព្យាយាមៈ

- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោត ឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសំបថ ឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយ មិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់
- ប្រើកំលាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាច ការភ័ន្តច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសំងាត់នៃការបោះឆ្នោត
- ទិញសន្លឹកឆ្នោតដោយសំភារៈ ឬដោយប្រាក់កាស[១៧៦] ។

ប៉ុន្តែទោសព្រហ្មទណ្ឌនៃបទល្មើសទាំងនេះ គ្មានចែងក្នុងច្បាប់បោះឆ្នោតទេ ហើយសិទ្ធិអំណាចស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់តាមផ្លូវព្រហ្មទណ្ឌ (ឧ. ករណីមានអំពើហិង្សា) នៅតែជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ច្បាប់បោះឆ្នោតក៏គ្មានបទប្បញ្ញត្តិពិសេសអ្វី (ដូចជា ការព្យួរឬការបណ្តេញចេញពីការងារ) សំរាប់ចាត់ចែងលើមន្ត្រីរាជការដែលត្រូវបានចោទប្រកាន់ឬរកឃើញថាបានធ្វើសកម្មភាពខុសឆ្គងអ្វីមួយដូចខាងលើ ។ ថ្វីបើសេចក្តីណែនាំចុះថ្ងៃ១៧ កក្កដា របស់ គជប បានចែងពីបញ្ហាមួយចំនួនដែលគណបក្សនយោបាយមានតវ៉ាជាក្រោយមកទៀត ដូចជា ការដកហូតប័ណ្ណបោះឆ្នោត ការកត់ឈ្មោះអ្នកទៅចូលរួមការដង្ហែក្បួនរបស់គណបក្សនយោបាយណាមួយជាដើម ប៉ុន្តែសេចក្តីណែនាំទាំងនេះមិនត្រូវបានផ្តល់លក្ខណៈសម្បត្តិជាច្បាប់ទេ ។

បទប្បញ្ញត្តិដែលបានបញ្ចូលក្នុងច្បាប់ (ឧ. ការហាមឃាត់ "ការទិញសន្លឹកឆ្នោតដោយសំភារៈ ឬដោយប្រាក់កាស")

---

[១៧៥] NEC, press release, no. 09.411/03 NEC, Phnom Penh, September 2, 2003.

[១៧៦] Law on Election of Members of the National Assembly, as amended 2002, Art 124.

ពុំមានកំណត់និយមន័យច្បាស់ទេ ។ បទប្បញ្ញត្តិ គជប បានលើកពីការទិញសន្លឹកឆ្នោតដោយប្រើពាក្យថាៈ "គណបក្សនយោបាយ ឬតំណាងបេក្ខជន ឬជនណាម្នាក់ មិនត្រូវផ្តល់វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសំភារៈ ទោះបីតាមមធ្យោបាយណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញសន្លឹកឆ្នោត"[១៧៧] ។ អត្ថន័យក្នុងបទប្បញ្ញត្តិទាំងនេះធ្វើឱ្យមានការជជែកវែកញែកជាច្រើនក្នុងបរិបទ ដែលការផ្តល់ជំនួយផ្ទាល់ខ្លួនរបស់អ្នកនយោបាយដល់អ្នកបោះឆ្នោតក្រីក្រ គឺជារឿងធម្មតានៃជីវិតនយោបាយ ហើយដែលគណបក្សជំទាស់ និង NGOs បានចោទថា ប្រធានភូមិបានប្រើការគំរាមកំហែងពិន័យពួកអ្នកគាំទ្រគណបក្សជំទាស់នៅក្នុងការបែងចែកជំនួយអភិវឌ្ឍន៍ទៅអនាគត ។ ជំហររបស់ គជប ក្នុងរឿងនេះ ត្រូវបានអគ្គលេខាធិការ គជប លើកបញ្ជាក់ក្នុងការប្រជុំ COPCEL ថាៈ

> *"យើងត្រូវប្រយ័ត្នប្រយែងពីការបកស្រាយ ។ យើងគួរបែងចែកផងដែររវាងសកម្មភាពគណបក្សនៅកន្លែងសាធារណៈ និងសកម្មភាពក្នុងទីតាំងការិយាល័យរបស់គណបក្សជាមួយសមាជិករបស់ពួកគេ ។ គជប នឹងធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគណបក្សនយោបាយនានាពីវិធីទប់ស្កាត់ការទិញសន្លឹកឆ្នោត"*[១៧៨] ។

មូលដ្ឋានដ៏ខ្សត់ខ្សោយខាងផ្លូវច្បាប់និងស្ថាប័ន សំរាប់ធ្វើការចោទប្រកាន់ ប្រហែលធ្វើឱ្យគេត្រូវតែយកជំរើសនេះ, ប៉ុន្តែអគ្គលេខាធិការ គជប បានផ្តល់ហេតុផលនៃជំហរបែបនេះថាជាប់ទាក់ទិននឹងរឿងសន្តិសុខផងដែរៈ

> *"ការនិយាយពីទ័ណ្ឌកម្ម និងការថ្កោលទោសវិធីសាស្ត្រសំរុះសំរួល វាងាយស្រួលទេ ។ ប៉ុន្តែនៅនឹងកន្លែងបើសិនយើង មិនប្រយ័ត្នប្រយែងទេ វាអាចនាំឱ្យមានការប៉ះទង្គិចគ្នាដោយអំពើហិង្សាយ៉ាងលឿន"*[១៧៩] ។

ទស្សនៈនេះផ្ទុយគ្នាយ៉ាងខ្លាំងជាមួយទស្សនៈរបស់តំណាង SRP ម្នាក់ដែលបានលើកក្នុងពេលឃោសនាបោះឆ្នោតថាៈ

> *"គជប, ក្រសួងមហាផ្ទៃ និង ហ៊ុន សែន កំពុងស្រែកឱ្យប្រជាពលរដ្ឋមានចិត្តអត់ធ្មត់ និងសន្តិភាព ។ល។ ប៉ុន្តែសំណួរ គឺជាមួយនឹងការអំពាវនាវទាំងនេះ ហេតុអ្វីបានជានៅតែកើតមានរឿងបែបនេះ? តើ ហ៊ុន សែន អាចត្រួតត្រាបាន ឬមិនបាន ។ បើសិនគាត់មិនអាចត្រួតត្រាប្រទេសបានទេ គាត់ត្រូវដើរចេញ ។ គាត់បានធ្វើសេចក្តីថ្លែងការណ៍ច្រើនណាស់ ប៉ុន្តែបើសិនគ្មានឃើញអ្វីកើតឡើង ពេលនោះអ្នកចាប់ផ្តើមចោទសួរថា អ្នកណាគ្រប់គ្រងប្រទេស ។ ហើយជាក់ស្តែង គឺគ្មានអ្នកណាគ្រប់គ្រងប្រទេសពិតប្រាកដទេ ពីព្រោះគ្មានអ្នកណាទទួលខុសត្រូវលើការគ្រប់គ្រងប្រទេស ។ គ្មានអ្នកណាសុខចិត្តទទួលកំហុសសោះ"*[១៨០] ។

ជាថ្មីម្តងទៀត គឺមានការយល់ឃើញខុសគ្នាទាំងស្រុងរវាង គជប និង SRP ។ សំរាប់ គជប ប្រធានភូមិ គឺជាកំលាំងមួយដែលនៅខាងក្រៅរង្វង់ត្រួតត្រារបស់ពួកគេ និងដែលអាចមានប្រយោជន៍ខ្លាំងណាស់ក្នុងការផ្សព្វផ្សាយពត៌មានពីការបោះឆ្នោត ។ ការយកចិត្តទុកដាក់រក្សាកិច្ចសហប្រតិបត្តិការរបស់ក្រុមនេះ, រក្សាសណ្តាប់ធ្នាប់សាធារណៈ, និងរក្សាឱ្យការបោះឆ្នោតដើរចំផ្លូវ, វាមានសារៈសំខាន់បំផុត ។ ដូច្នេះវិធីសាស្ត្រគឺការសំរុះសំរួល ដោយខិតខំកែតំរង់ឥរិយាបថរបស់ប្រធានភូមិ មិនមែនដាក់ទណ្ឌកម្មទេ ។ ផ្ទុយទៅវិញ SRP ព្រមទាំង COMFREL, NICFEC, និងអ្នកសង្កេតការណ៍អន្តរជាតិដូចជា តំណាងពិសេសរបស់ UN ខាងសិទ្ធិមនុស្ស និងអង្គការតាមដានសិទ្ធិមនុស្ស (Human Rights Watch) បានមើលឃើញប្រធានភូមិជាអ្នកប្រព្រឹត្តបទល្មើសខាងបោះឆ្នោត និងព្រហ្មទណ្ឌ ហើយទាមទារឱ្យរដ្ឋដាក់ទោសជនល្មើសទៅតាមច្បាប់ ដោយវែកញែកថា នេះជាការ

---

[១៧៧] NEC Regulations §7.10.7

[១៧៨] Tep Nytha, statement to COPCEL, Minutes of 45th COPCEL Meeting, trans Sen Sina, 30 April 2003.

[១៧៩] Tep Nytha, statement to COPCEL, Minutes of 45th COPCEL Meeting, 30 April 2003.

[១៨០] SRP national representative (3), personal interview, 3 July 2003.

ទទួលខុសត្រូវរបស់រដ្ឋាភិបាលដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ កង្វះលទ្ធភាពសំរុះសំរួលទស្សនៈទាំងនេះ នាំឱ្យមានការរីករាលដាលទំនាស់ និងការអះអាងដោយ SRP និង FUNCINPEC ថា គជប ឃុបឃិតជាមួយ CPP ធ្វើយុទ្ធនាការបំភិតបំភ័យ និងទិញសន្លឹកឆ្នោត ដោយប្រើប្រាស់ប្រធានភូមិ ។ ការអះអាងនេះមានលក្ខណៈលេចធ្លោនៅក្នុងសេចក្តីប្រកាសនានារបស់ SRP និង FUNCINPEC នៅក្រោយពេលបោះឆ្នោត ហើយមកដល់ដើមខែវិច្ឆិកា ២០០៣ នៅមិនទាន់ដោះស្រាយរួចទេ ។

## ៤.៣ ទំនាស់ស្តីពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស

ករណីសិក្សាតាមឃុំរបស់យើងបង្ហាញថា បន្ទាប់ពីប្រធានភូមិ ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស គឺជាប្រភពពត៌មានសំខាន់លំដាប់ទី២ សំរាប់អ្នកបោះឆ្នោតក្នុងពេលបោះឆ្នោត ។ ដោយមូលហេតុនេះ លទ្ធភាពរបស់គណបក្សនយោបាយក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គឺជារឿងដ៏សំខាន់ទាក់ទិនដល់គុណភាពនៃការបោះឆ្នោត ។ ប្រព័ន្ធផ្សព្វផ្សាយជាវិស័យមួយហាក់ដូចមានការផ្លាស់ប្តូររចនាសម្ព័ន្ធតិចតួចតាំងពីឆ្នាំ១៩៩៨មក ទោះបីមានផុសទំនាស់ធ្ងន់ធ្ងរ និងការទិតៀនជាទូទៅពីសំណាក់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ពីដំណើរការរបស់វាក្តី ។ នៅឆ្នាំ២០០៣ មានទំនាស់មួយចំនួនស្តីពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជាអាទិ៍ ទំនាស់ពីសិទ្ធិរបស់ស្ថានីយវិទ្យុក្នុងស្រុកមួយក្នុងការផ្សព្វផ្សាយបន្តនូវការផ្សាយរបស់ RFA និង VOA, ទំនាស់រវាង គជប និងស្ថានីយវិទ្យុនានា ស្តីពីអំណាចអនុវត្តនៃសេចក្តីណែនាំនានារបស់ គជប លើសកម្មភាពប្រព័ន្ធផ្សព្វផ្សាយក្នុងរយពេលឃោសនាបោះឆ្នោត និងទំនាស់ស្តីពីការផ្តើមគំនិតថ្មីមួយរបស់ UNDP មានឈ្មោះថា "កម្មវិធីស្មើភាពគ្នា" ។ ប៉ុន្តែលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសំរាប់ធ្វើការឃោសនា មិនមែនជាចំណុចស្នូលនៃទំនាស់នៅក្រោយពេលបោះឆ្នោតទេ គឺបានន័យថា ទំនាស់ទាំងនេះអាចដោះស្រាយបានដោយជោគជ័យ ។

### *៤.៣.១ រចនាសម្ព័ន្ធនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា*

ដូចបានកត់សំគាល់ក្នុងជំពូក២ តាំងពីឆ្នាំ១៩៩៨ មក មានការផ្លាស់ប្តូរតិចតួចទេក្នុងរចនាសម្ព័ន្ធកម្មសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយ ។ SRP បន្តទាមទារប្រេកង់សំរាប់ស្ថានីយវិទ្យុរបស់ខ្លួនមួយអំពីរដ្ឋាភិបាល ប៉ុន្តែសំណើនេះនៅតែត្រូវបដិសេធ ។ ក្នុងចំណោមស្ថានីយឯកជន, វិទ្យុតាព្រហ្ម មានខ្សែបន្ទាត់វិចារណកថាគាំទ្រ FUNCINPEC យ៉ាងខ្លាំង ។ នៅខែមិថុនា ២០០៣ មានការបារម្ភពីការថយចុះឥទ្ធិពល FUNCINPEC ក្នុងប្រព័ន្ធផ្សព្វផ្សាយ នៅពេលដែលនាយករងវិទ្យុ FM 96 MHz គឺលោក នៅ ស៊ុវ៉ាថេរ៉ូ ជាសមាជិក FUNCINPEC ត្រូវបានជំនួសដោយលោក ទូច សារ៉េត ជាសមាជិក CPP ។ រឿងនេះបណ្តាលឱ្យមានការតវ៉ាពីរដ្ឋមន្ត្រីក្រសួងពត៌មាន លឺ ឡាយស្រេង ដែលគេមិនបានសុំមតិចំពោះការចោទប្រកាន់ថា "ការយកពត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយមានលក្ខណៈមិនស្មើភាព"[១៨១] ។

ស្ថានីយវិទ្យុ មជ្ឈមណ្ឌលពត៌មានស្ត្រីកម្ពុជា ដែលដំណើរការដោយ NGO មួយ ត្រូវបានគេទទួលស្គាល់ជាទូទៅថាអព្យាក្រឹត្យ ។ បុគ្គលិក RFA បានឆ្លើយសំភាសន៍ប្រាប់នៅឆ្នាំ២០០៣ ថា ពួកគេបានកសាងទំនាក់ទំនងល្អជាងមុន ជាមួយ CPP ហើយបានផ្សព្វផ្សាយកាន់តែច្រើននូវពត៌មានស្តីពី និងបទសំភាសន៍ជាមួយពួកសមាជិក CPP ។ ថ្វីបើ នៅកម្ពុជា ជាទូទៅគេមើលឃើញ RFA និង VOA ថាគាំទ្រគណបក្សជំទាស់ក្តី ប៉ុន្តែបុគ្គលិក RFA បានអះអាងថា ពួកគេមិនដែលធ្វើវិចារណកថាគាំទ្រគណបក្សណាមួយទេ គឺផ្សព្វផ្សាយតែពត៌មានប៉ុណ្ណោះ[១៨២] ។ ស្ថានីយទូរទស្សន៍ និងវិទ្យុនៅកម្ពុជាដែលផ្សាយជាភាសាខ្មែរឯទៀតទាំងអស់ ជាទូទៅត្រូវបានគេសំគាល់ថា គាំទ្រ CPP[១៨៣] ។

---

[១៨១] Far Eastern Economic Review, "Intelligence," 3 July 2003, posted online to Camnews.

[១៨២] Radio Free Asia reporter (56), personal interview, Phnom Penh, 4 July 2003.

[១៨៣] See for example, COMFREL, "Media Monitoring Preliminary Findings," Press statement, 8 Aug 2003; EU Election Observation Mission, "Preliminary Statement," press release, Phnom Penh, 30 July 2003; Special

គំរោងតាមដានប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលធ្វើឡើងនាពេលបោះឆ្នោតឆ្នាំ១៩៩៨ និង២០០២ បង្ហាញថា CPP និងសមាជិករបស់ពួកគេ បានទទួលការផ្សព្វផ្សាយក្នុងវិទ្យុ និងទូរទស្សន៍នៅកម្ពុជា ច្រើនជាងគណបក្សណាៗទាំងអស់ ។ ឧទាហរណ៍ នៅឆ្នាំ១៩៩៨ UNCOHCHR មានគេរាយការណ៍ថា នៅខែឧសភា វិទ្យុ និងទូរទស្សន៍រដ្ឋ បានចាក់ផ្សាយពីលោក ហ៊ុន សែន ១៧០លើក ធៀបនឹង ៥លើកម្នាក់ សំរាប់ព្រះអង្គម្ចាស់រណប្ញទ្ធិ និងលោក សម រង្ស៊ី ។ នៅខែមិថុនា តួលេខគឺ ១៨៦, ១៧, និង ១២ លើករៀងៗគ្នា ។ ឯនៅលើទូរទស្សន៍ឯកជនក៏បានពិនិត្យឃើញវិសមភាពដែរ ។ ឧទាហរណ៍ ក្នុង ២សប្តាហ៍ដើមខែកក្កដា ១៩៩៨ CPP មានផ្សាយ ៤៨៦លើកនៅក្នុងកម្មវិធីពត៌មានទូរទស្សន៍ឯកជន ប្រៀបធៀបទៅនឹង ៦លើក សំរាប់ FUNCINPEC និង ៩លើកសំរាប់ SRP[១៨៤] ។

នៅឆ្នាំ២០០២ នៅជិតៗពេលបោះឆ្នោតឃុំ COMFREL បានរៀបចំធ្វើការតាមដានប្រព័ន្ធផ្សព្វផ្សាយប្រហាក់ប្រហែលគ្នា ហើយបានពិនិត្យឃើញ "ការជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសមានប្រជាប្រិយភាពខ្លាំងៗបំផុត (មានទាំងវិទ្យុ និងទូរទស្សន៍រដ្ឋផង) សំរាប់ឱ្យគណបក្សនយោបាយនានាប្រើប្រាស់ក្នុងដំណើរការបោះឆ្នោត"[១៨៥] ។ ស្ថានីយទាំងនេះរួមមានទូរទស្សន៍រដ្ឋ/ឯកជនចំនួន ៦, ហើយនិង ៧វិទ្យុរដ្ឋ/ឯកជន ។ គួរកត់សំគាល់ថា ក្នុងនេះគ្មានវិទ្យុសំបុកឃ្មុំ (105 MHz) ដែលអង្កេតលើអ្នកបោះឆ្នោត ធ្វើដោយអង្គការមូលនិធិអាស៊ី បានរកឃើញថា ជាវិទ្យុមានប្រជាប្រិយភាពលំដាប់ទី៤[១៨៦] ឬ វិទ្យុតាព្រហ្ម (90.5 MHz) ទេ ។

ការតាមដានរបស់ COMFREL បង្ហាញថា ស្ថានភាពបានធ្លាក់ចុះពីឆ្នាំ១៩៩៨ ទៅ ២០០២ ហើយការផ្សព្វផ្សាយពត៌មានតាមរលកធាតុអាកាសស្តីពីការបោះឆ្នោតឃុំ បានផ្តល់មូលដ្ឋានកាន់តែតិចឡើងដល់អ្នកបោះឆ្នោត ដើម្បីសំរេចចិត្តជ្រើសយកគណបក្សណាមួយ ។ ជារួម COMFREL រកឃើញថា ស្ថានីយនានាបានផ្សព្វផ្សាយពត៌មានតិចតួចណាស់ពីការបោះឆ្នោត ។ COMFREL រាយការណ៍ថា "ក្នុងម៉ោងផ្សាយល្អបំផុត ស្ថានីយជាច្រើនមិនដែលផ្សព្វផ្សាយរបាយការណ៍ពីការរៀបចំ និងការឃោសនាបោះឆ្នោតទេ ហើយក៏មិនដែលធ្វើសំភាសន៍តំណាងគណបក្សនយោបាយ ឬបេក្ខជនណាដែរ" ។ COMFREL រាយការណ៍ទៀតថា កម្មវិធីពត៌មានពោរពេញទៅដោយ "សកម្មភាពរបស់រដ្ឋាភិបាល និងសមាជិក CPP មានទាំងការផ្តល់អំណោយដោយមេឃុំទៅឱ្យប្រជាជនផង ។ FUNCINPEC និង SRP ទទួលបានការផ្សព្វផ្សាយយ៉ាងខ្លី ចំណែកឯគណបក្សឯទៀតដែលប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំដែរ ជាទូទៅត្រូវបានបំភ្លេចចោល" ។ របាយការណ៍លើកទៀតថា គ្មានការផ្តល់នាទីឃោសនាដោយឥតគិតថ្លៃតាមរយៈស្ថានីយរដ្ឋទេ ហើយគណបក្សភាគច្រើនមិនបានចំណាយប្រាក់សំរាប់ផ្សព្វផ្សាយការឃោសនាទេ ។ របាយការណ៍បានកត់សំគាល់ថា "ក្នុងម៉ោងផ្សាយល្អបំផុត (ឃើញមាន) ការរែកញែកដេញដោលតែមួយគត់ដែលក្នុងនេះបេក្ខជន ៤នាក់មានឱកាសសំរាប់លើកមតិតែ ២-៣នាទីប៉ុណ្ណោះ"[១៨៧] ។ នៅឆ្នាំ២០០២ EU បានឧបត្ថម្ភកម្មវិធីមួយសំរាប់តាមដានពត៌មានក្នុងទូរទស្សន៍រដ្ឋ ហើយបានរកឃើញថា មានតែ ៣គណបក្សធំៗប៉ុណ្ណោះដែលត្រូវបានផ្សព្វផ្សាយ ក្នុងនេះ CPP

---

Representative for Human Rights in Cambodia, "The Situation of Human Rights in Cambodia," report to UN General Assembly A/58/317, 22 Aug 2003, Summary.

១៨៤ Information extracted from Hughes and Real, The Nature and Causes of Conflict Escalation in the 1998 National Elections, Phnom Penh: CDRI, 2000.

១៨៥ COMFREL, "Final Report of the Media Monitoring, for the Period of 4 January to 8 February, 2002," Phnom Penh, 2002, 2.

១៨៦ The Asia Foundation, "Democracy in Cambodia – 2003, a Survey of the Cambodian Electorate," draft report, Phnom Penh, 16 May 2003, Appendix 1, Table 12.5.

១៨៧ COMFREL, "Final Report of the Media Monitoring, for the Period of 4 January to 8 February, 2002," Phnom Penh, 2002, 17.

ទទួលបាន ៨៨%, FUNCINPEC ១២%, និង SRP តិចជាង ១%[១៨៨] ។

របៀបរបបអនុវត្តន៍ក្នុងវិស័យសារពត៌មាននៅកម្ពុជា មានការប៉ះពាល់អវិជ្ជមានពីកត្តាមួយចំនួន ហើយកត្តាសំខាន់បំផុតគឺសេដ្ឋកិច្ច ។ ក្នុងសេដ្ឋកិច្ចក្រីក្រដូចនៅកម្ពុជា បញ្ហារកចំណូលឱ្យបានគ្រប់គ្រាន់ ដូចជាពីការផ្សព្វផ្សាយពាណិជ្ជកម្មជាដើម គឺមានន័យថា អ្នកសារពត៌មានទទួលប្រាក់កំរៃខ្សត់ខ្សោយណាស់ ហើយអង្គភាពខាងប្រព័ន្ធផ្សព្វផ្សាយជារឿយៗត្រូវពឹងផ្អែកលើអ្នកជួយឧបត្ថម្ភដែលមានៗ ។ របៀបរបបផ្តល់ប្រាក់កាសឱ្យអ្នកសារពត៌មានដើម្បីឱ្យមានការផ្សព្វផ្សាយល្អ (និងពួកអ្នកសារពត៌មានដែលមិនផ្សព្វផ្សាយល្អពីអ្នកណាដែលមិនអាច ឬមិនព្រមបង់ប្រាក់) មានរាយការណ៍បង្ហាញថា វាកើតមានជាទូទៅ ។ នៅពាក់កណ្តាលទសវត្សរ៍១៩៩០ ការពន្យល់ជាទូទៅមួយពីគុណភាពអន់ក្នុងវិស័យសារពត៌មាននៅកម្ពុជា គឺអ្នកសារពត៌មានកម្ពុជាខ្វះខាតសមត្ថភាពបច្ចេកទេសដើម្បីផ្តល់ពត៌មានមានគុណភាពខ្ពស់ ។ តាំងពីដើមទសវត្សរ៍១៩៩០ មានកម្មវិធីបណ្តុះបណ្តាលជាច្រើនរបស់ NGOs ជាតិ និងអន្តរជាតិ ដែលបានដំណើរការ ដើម្បីខិតខំដោះស្រាយកង្វះខាតនេះ ។ ជាលទ្ធផលនៅឆ្នាំ២០០៣ គេរាយការណ៍ថា នៅកម្ពុជាមានអ្នកសារពត៌មានមានគុណភាព និងសមត្ថភាពខ្ពស់ជាច្រើន ប៉ុន្តែកត្តាខាងវចនាសម្ព័ន្ធដូចជា ការត្រួតត្រាពីមជ្ឈដ្ឋាននយោបាយទៅលើអង្គភាពផ្សព្វផ្សាយ និងកង្វះទុនបានរារាំងពួកគេមិនឱ្យប្រើប្រាស់ជំនាញរបស់ខ្លួន ។

កត្តាមួយទៀតដែលប៉ះពាល់ដល់របៀបរបបអនុវត្តន៍ក្នុងវិស័យសារពត៌មាន គឺអំពើហិង្សា ។ ក្នុងមួយភាគធំនៃទសវត្សរ៍១៩៩០ អ្នកសារពត៌មានដែលគាំទ្រគណបក្សជំទាស់ ទទួលរងគ្រោះពីការវាយប្រហារដ៏សាហាវ និងការធ្វើឃាដ ។ អំពើនេះបានថយចុះច្រើនណាស់តាំងពីឆ្នាំ១៩៩៨ ថ្វីបើមានរបាយការណ៍ខ្លះៗស្តីពីអ្នកសារពត៌មានដែលត្រូវចាប់ខ្លួន ឬវាយប្រហារនៅឆ្នាំ២០០២ ក្រោយពីបានសរសេរអត្ថបទទិតៀនដល់រដ្ឋាភិបាលមជ្ឈិម ឬមន្ត្រីមូលដ្ឋាន ។ បន្ទាប់ពីមានការបះបោរប្រឆាំងថៃនៅឆ្នាំ២០០៣ ម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំ ម៉ម សូណង់ដូ ត្រូវជាប់ពន្ធនាគារ តែក្រោយមកត្រូវបានដោះលែងវិញ ។ ក្រោយការបោះឆ្នោតឆ្នាំ២០០៣ លោក ជួ ជេតចារិទ្ធ អ្នកសរសេរវិចារណកថានៅវិទ្យុតាព្រហ្ម ត្រូវគេបាញ់សំលាប់ ។ គណៈកម្មាធិការសកម្មភាពសិទ្ធិមនុស្សកម្ពុជា បានលើកឡើងថា "ការសំលាប់ហាក់ដូចចង់បញ្ជូនសារដ៏ខ្លាំងមួយទៅដល់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ដើម្បីគាបសង្កត់សិទ្ធិបញ្ចេញមតិដោយសេរីដែលត្រូវបានធានាអះអាងដោយរដ្ឋធម្មនុញ្ញកម្ពុជា និង កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ដែលកម្ពុជាបានចូលជាសមាជិក"[១៨៩] ។

### *៤.៣.២ សិទ្ធិសេរីភាពក្នុងការផ្សព្វផ្សាយតាមរលកធាតុអាកាស និងការមានលទ្ធភាពប្រើប្រព័ន្ធផ្សព្វផ្សាយ*

ដូចមានចុះក្នុងរបាយការណ៍ របស់អ ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨, មតិនេះត្រូវបាន ឯ.ឧ ខៀវ កាញារីទ្ធ រដ្ឋលេខាធិការក្រសួងពត៌មានជំទាស់ដោយចង្អុលបង្ហាញថា គណបក្សជំទាស់បានទទួលការគាំទ្រ ជាពិសេសពីវិទ្យុសំបុកឃ្មុំ វិទ្យុតាព្រហ្ម និងកម្មវិធីផ្សាយជាភាសាខ្មែររបស់ RFA និង VOA ។ ដោយឡែក ឯកឧត្តមបានលើកនៅឆ្នាំ១៩៩៩ ថា "RFA និង VOA មានសំភារៈបរិក្ខារផ្សាយកំលាំងខ្លាំងដែលអាចបញ្ជូនការផ្សាយទៅដល់ទីឆ្ងាយៗ" ។ នៅឆ្នាំ១៩៩៨ បញ្ហាថាតើគណបក្សនានាក្រៅពី CPP អាចបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាស ដើម្បីធ្វើការឃោសនាឬយ៉ាងណា វាទាក់ទងមួយភាគធំនឹងរឿងថាតើ RFA និង VOA ត្រូវគិតបញ្ចូលក្នុង "ប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជា" ឬទេ ។ ពួកអ្នកសង្កេតការណ៍អន្តរជាតិច្រើនតែមិនគិតបញ្ចូលទេ ប៉ុន្តែ ខៀវ កាញារីទ្ធ មើលឃើញវិទ្យុទាំងនេះ ជាចំណែកមួយយ៉ាងធំនៃសេវាពត៌មានសំរាប់សាធារណជន

---

[១៨៨] UNDP representative (2), personal interview, Phnom Penh, July 2003.

[១៨៩] Cambodian Human Rights Action Committee, "CHRAC Denounces Murder of Ta Prom Radio Station Editor," Press release, Phnom Penh, 18 October 2003.

កម្ពុជា និងជាការធានាារ៉ាប់រងឱ្យគណបក្សជំទាស់មានលទ្ធភាពប្រើប្រាស់រលកធាតុអាកាស[១៩០] ។

[១៩០] Caroline Hughes and Real Sopheap, The Nature and Causes of Conflict Escalation in the 1998 National Election, Phnom Penh: CDRI, 2000, 23.

នៅឆ្នាំ២០០៣ ស្ថានីយទាំង៤ បន្តធ្វើការផ្សព្វផ្សាយសំរាប់គណបក្សជំទាស់ ។ សេវា RFA និង VOA បានកែលំអឡើងតាមកិច្ចសន្យាជាមួយ វិទ្យុសំបុកឃ្មុំ ដែលចាប់ផ្តើមប្រើវិទ្យុ FM របស់ខ្លួន ដើម្បីជួយផ្សាយបន្តឱ្យ RFA និង VOA (យ៉ាងហោចណាស់ក៏សំរាប់តំបន់កណ្តាលនៃកម្ពុជាដែរ) ។ ពីដំបូងការផ្សាយបន្តនេះ មានការជំទាស់ ។ តំណាងវិទ្យុសំបុកឃ្មុំម្នាក់ប្រាប់ថា ស្ថានីយចាប់ផ្តើមផ្សាយបន្តឱ្យ RFA និង VOA នៅថ្ងៃ ១ កក្កដា ២០០៣ ប៉ុន្តែ មានមនុស្សរបស់លោក ខៀវ កាញារីទ្ធ ម្នាក់មកជួប "ដើម្បីប្រាប់យើងឱ្យឈប់, មិនឱ្យផ្សាយ, បើមិនដូច្នោះទេ នឹងហៅប៉ូលីសមកបិទ"[១៩១] ។ COMFREL និង NICFEC បានលើកឡើងក្នុងសេចក្តីថ្លែងការណ៍រួមគ្នាមួយពីរឿងដែល ខៀវ កាញារីទ្ធ ជំជែកវែកញែកថា បានធ្វើសកម្មភាពនេះ ពីព្រោះវិទ្យុសំបុកឃ្មុំ មិនបានសុំការអនុញ្ញាតពី គជប ដើម្បីផ្សព្វផ្សាយពត៌មាន RFA និង VOA ក្នុងរយៈពេលបោះឆ្នោត ។

COMFREL និង NICFEC បានកត់សំគាល់ថា "ពុំមានបទប្បញ្ញត្តិអ្វីដែលចែងថា ប្រព័ន្ធផ្សព្វផ្សាយត្រូវសុំការអនុញ្ញាតពី គជប ដើម្បីស្រង់ពត៌មានពីប្រភពផ្សេងៗ និងធ្វើការផ្សព្វផ្សាយនោះទេ" ហើយការតាមដានប្រព័ន្ធផ្សព្វផ្សាយរបស់ពួកគេផ្ទាល់បានបង្ហាញថា របៀបរបបបែបនេះមានអនុវត្តជាទូទៅ ។ ពួកគេលើកពីការបារម្ភថា ការព្យាយាមបញ្ឈប់ការផ្សព្វផ្សាយរបស់វិទ្យុសំបុកឃ្មុំ គឺជាការរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដែលរដ្ឋធម្មនុញ្ញបានធានា[១៩២] ។ តំណាងវិទ្យុសំបុកឃ្មុំម្នាក់និយាយថា ក្រោយពេលមកជួបនោះ វិទ្យុបានសុំការអនុញ្ញាតពី គជប ដើម្បីផ្សាយបន្តឱ្យ RFA និង VOA ពីការបោះឆ្នោត ហើយ គេបានប្រាប់មកវិញថា ស្ថានីយវិទ្យុមានលក្ខណៈស្របច្បាប់ ហើយ គជប គ្មានសិទ្ធិអំណាចអ្វីដើម្បីរារាំងវិទ្យុមិនឱ្យធ្វើដូច្នេះទេ ។ ក្រោយមកទៀត រដ្ឋមន្ត្រីក្រសួងពត៌មាន លឺ ឡាយស្រេង ក៏បានបញ្ជាក់គាំទ្រជាផ្លូវការនូវសេចក្តីសំរេចនេះ ។ តាំងពីពេលបោះ ឆ្នោត វិទ្យុសំបុកឃ្មុំ បានទទួលសំភារៈបរិក្ខារផ្សាយមួយខ្លាំងជាងមុនទៀត ដើម្បីពង្រីកដែនផ្តល់សេវាកម្មផ្សព្វផ្សាយរបស់ខ្លួន ។

ជារួម រឿងថាតើគណបក្សជំទាស់មានឱកាសបញ្ចេញមតិរបស់ខ្លួនតាមរលកធាតុអាកាសនៅកម្ពុជាឬយ៉ាងណា គឺជាបញ្ហាមួយមានការខ្វែងមតិគ្នានៅឆ្នាំ២០០៣ ដូចគ្នានឹងឆ្នាំ១៩៩៨ ដែរ ។ វត្តមានវិទ្យុតាព្រហ្ម និងសំបុកឃ្មុំ ព្រមទាំង RFA និង VOA បានផ្តល់ឱកាសឱ្យអ្នកបោះឆ្នោតបានស្តាប់ពត៌មានពីគណបក្សផ្សេងទៀតក្រៅពី CPP បើសិនគេចង់ដឹង ។ អង្កេតតាមដានប្រព័ន្ធផ្សព្វផ្សាយឆ្នាំ២០០៣ របស់ COMFREL បានបង្ហាញថាៈ

> *VOA (វិទ្យុមានគេស្តាប់ច្រើនបំផុត លំដាប់ទី៣ នៅភាគឦសាន និងលំដាប់ទី៥ក្នុងទូទាំងប្រទេស) បានផ្សព្វផ្សាយពី ១០គណបក្សក្នុងកម្មវិធីពត៌មាន ដោយធ្វើការផ្សព្វផ្សាយច្រើនបំផុតទាំងនៅក្នុង និងនៅក្រៅកម្មវិធីពត៌មានអំពី SRP ។ វិទ្យុមានប្រជាប្រិយភាពលំដាប់ទី២នៅភ្នំពេញ (FM 105) បានផ្សព្វផ្សាយពី ១១គណបក្សក្នុងកម្មវិធីពត៌មាន ដោយផ្តល់ការផ្សព្វផ្សាយច្រើនបំផុតឱ្យ SRP ទាំងនៅក្នុង និងនៅក្រៅកម្មវិធីពត៌មាន ។ វិទ្យុ FM 90.5 របស់ FUNCINPEC (គ្មានតួលេខចំនួនអ្នកស្តាប់ទេ) ផ្តល់ការផ្សព្វផ្សាយជិត ១០០% ឱ្យ FUNCINPEC ទាំងនៅក្នុង និងនៅក្រៅកម្មវិធីពត៌មាន*[១៩៣] ។

ច្បាស់ណាស់ បើសិនអ្នកបោះឆ្នោតមិនចូលចិត្តពត៌មានគាំទ្រ CPP របស់ស្ថានីយវិទ្យុ និងទូរទស្សន៍ជាច្រើន ពួកគេក៏មានជំរើសផ្សេងដែរ ។ ក្នុងពេលជាមួយគ្នា កត្តាបច្ចេកទេសនានាដូចជា កំលាំងរលកធាតុអាកាសផ្សាយ, ទិដ្ឋភាពមិនមែននយោបាយនៃកម្មវិធី..., អាចប៉ះពាល់យ៉ាងច្រើនដល់ជំរើសរបស់អ្នកស្តាប់ ។ ក្នុងរឿងនេះ ការគ្របសង្កត់ជាប់រហូតរបស់

---

[១៩១] Beehive Radio Station representative (57), personal interview, Phnom Penh, 8 Aug. 2003.

[១៩២] COMFREL, NICFEC and Youth Council of Cambodia, "Joint Statement on Concern of the Violation of the Freedom of the Media concerning the Warning to Shut Down FM 105 Sambok Khmom (Beehive Radio) by a High-Ranking Ministry of Information Official," press release, Phnom Penh, July 10, 2003.

[១៩៣] COMFREL, "Media Monitoring Statement," press release, Phnom Penh, 6 August 2003.

គណបក្សនយោបាយតែមួយទៅលើការផ្សព្វផ្សាយពីការបោះឆ្នោត អាចប៉ះពាល់មិនល្អដល់ឱកាសរបស់គណបក្សឯទៀតៗ ដើម្បីធ្វើការឃោសនាតាមរយៈស្ថានីយនានាដែលមានប្រជាប្រិយភាពជាងគេ ។ ការផ្សព្វផ្សាយច្រើនជាងគេពី CPP នៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ធ្វើឱ្យមានការបារម្ភថែមមួយទៀតថា រដ្ឋខ្លួនឯងក៏ហាក់ដូចជាបានគាំទ្រគណបក្សណាមួយជាក់លាក់ដែរ ដែលរំលោភលើគោលការណ៍អព្យាក្រឹតភាពរបស់រដ្ឋ និងការបែងចែកដាច់រវាងគណបក្ស និងរដ្ឋ, ដែលជាលក្ខណៈសម្បត្តិជាគំរូនៃរបបប្រជាធិបតេយ្យសេរី ។

ទិដ្ឋភាពមួយទៀតគឺ ការប្រកាសពីសេចក្តីសំរេចរបស់ស្ថានីយទូរទស្សន៍ឯកជននានានៅខែមិថុនា ២០០៣ ស្តីពីការមិនព្រមទទួលផ្សព្វផ្សាយនូវការឃោសនាខាងនយោបាយរបស់គណបក្សនយោបាយណាៗទាំងអស់ និងការចៀសវាងផ្សព្វផ្សាយពត៌មានពីការបោះឆ្នោតជាទូទៅ និងការឃោសនាខាងនយោបាយ ។ សេចក្តីសំរេចនេះគឺ ជាការឆ្លើយតបទៅនឹងសេចក្តីណែនាំរបស់ គជប ដែលទាមទារឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងអស់ទទួលផ្សព្វផ្សាយការឃោសនាខាងនយោបាយពីគណបក្សនយោបាយនានាឱ្យបានស្មើភាពគ្នា និងត្រូវមានកម្មវិធីពត៌មានដែលមានតុល្យភាពល្អមិនប្រកាន់បក្សពួក ។ ការមិនផ្សាយពត៌មាននេះបានដាក់អនុវត្តស្មើគ្នាលើគ្រប់គណបក្សនយោបាយ ប៉ុន្តែ វាបានកាត់បន្ថយយ៉ាងខ្លាំងនូវលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសពីសំណាក់ភាគីមិនមែនរដ្ឋាភិបាលនានា ។ ក្នុងនេះ ចំណុចសំខាន់គឺការបែងចែករវាងពត៌មានស្តីពីគណបក្សនយោបាយ និងពត៌មានស្តីពីរដ្ឋាភិបាល ហើយគំរោងតាមដានប្រព័ន្ធផ្សព្វផ្សាយនានាបានបង្ហាញថា កម្មវិធីពត៌មានរបស់ស្ថានីយទូរទស្សន៍ឯកជន គឺពោរពេញទៅដោយពត៌មានស្តីពីរដ្ឋាភិបាល ជាពិសេសស្តីពីរដ្ឋមន្ត្រីនានារបស់រដ្ឋាភិបាល ដែលចូលរួមក្នុងពិធីចែកអំណោយផ្សេងៗ ។ ដូច្នេះ សេចក្តីសំរេចបន្តផ្សព្វផ្សាយពត៌មានស្តីពីរដ្ឋាភិបាល និងមិនមែនពីគណបក្សនយោបាយនានាបានបំបាត់ចោលអស់នូវឱកាសសំរាប់ឱ្យអ្នកនយោបាយដែលមិនមែនស្ថិតក្នុងរដ្ឋាភិបាល ដើម្បីបញ្ចេញមតិរបស់ខ្លួន តាមរយៈទូរទស្សន៍ ប៉ុន្តែបានបន្តផ្តល់ការចេញមុខមាត់យ៉ាងច្រើនដល់ភាគីនានាខាងរដ្ឋាភិបាល ។

រឿងនេះបានគូសរំលេចផងដែរពីឧបសគ្គខាងសេដ្ឋកិច្ច ចំពោះការកសាងទូរទស្សន៍ឯករាជ្យនៅកម្ពុជា ។ សេចក្តីសំរេចរបស់ស្ថានីយឯកជន ដើម្បីបដិសេធការផ្សព្វផ្សាយនយោបាយដោយបង់ថ្លៃ នៅក្នុងបរិបទនៃទីផ្សារផ្សាយពាណិជ្ជកម្មមួយដ៏តូចបានបង្ហាញថា ស្ថានីយទាំងនេះមានការពឹងផ្អែកខាងសេដ្ឋកិច្ចទៅលើការជួយឧបត្ថម្ភពីមជ្ឈដ្ឋាននយោបាយ ជាជាងលើការផ្សាយពាណិជ្ជកម្ម ។ រឿងនេះមានសារៈសំខាន់ ពីព្រោះវាធ្វើឱ្យការពេញចិត្តរបស់អ្នកជួយឧបត្ថម្ភ វាសំខាន់ជាងការពេញចិត្តរបស់ទូរទស្សនិកជន និងធ្វើឱ្យស្ថានីយទូរទស្សន៍ពុំសូវមានការឆ្លើយតបល្អទេទៅនឹងផលប្រយោជន៍ និងចំណូលចិត្តរបស់ទស្សនិកជន ។ ស្ថានភាពនេះបានរារាំងដល់ការផុសឡើងនូវប្រព័ន្ធផ្សព្វផ្សាយមួយដែលឯករាជ្យខាងនយោបាយ និងដែលជួយលើកកំពស់របបប្រជាធិបតេយ្យ ។

នៅឆ្នាំ២០០៣ មានការអនុវត្តន៍ដោយជោគជ័យនូវវិធានការមួយចំនួនសំដៅកែលំអលទ្ធភាពគណបក្សនយោបាយក្នុងការបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយស្មើភាពគ្នា និងបង្កើនគុណភាព និងបរិមាណការផ្សព្វផ្សាយខាងនយោបាយទៅឱ្យប្រជាជន ។ មានការផ្តួចផ្តើមគំនិតចំបងៗ ៣ៈ ការរៀបចំក្របខ័ណ្ឌច្បាប់ និងគោលការណ៍ណែនាំផ្សេងៗសំរាប់ប្រព័ន្ធផ្សព្វផ្សាយ, ការបង្កើត "កម្មវិធីស្មើភាពគ្នា" ដំណើរការដោយ UNDP, និងការបង្កើតឡើងវិញនូវកម្មវិធីស្មើភាពគ្នា សំរាប់ឱ្យគណបក្សនយោបាយនានាផ្សព្វផ្សាយការឃោសនាខ្លីៗនៅក្នុងទូរទស្សន៍ និងវិទ្យុរដ្ឋ ។ ការផ្តួចផ្តើមគំនិតមួយចំនួនទៀតក៏បានផុសឡើងដែរ ដូចជា របៀបរបបឃើញមានជាទូទៅនៃការរៀបចំ និងការផ្សព្វផ្សាយតាមទូរទស្សន៍នូវការជជែកដេញដោលរវាងគណបក្សនយោបាយ និងកម្មវិធីសំណួរ-ចំលើយតាមទូរស័ព្ទ ដែលក្នុងនេះអ្នកនយោបាយឆ្លើយតបនឹងសំនួររបស់សាធារណជន ។ ប៉ុន្តែទាំងសេចក្តីណែនាំរបស់ គជប ទាំងកម្មវិធីស្មើភាពគ្នា សុទ្ធតែជាប្រភពនៃទំនាស់ ។

### ៤.៣.៣ ទំនាស់អំពីសេចក្តីណែនាំរបស់ គជប

ច្បាប់បោះឆ្នោតមាន ៣មាត្រា ដែលគ្មានការកែប្រែសោះតាំងពីឆ្នាំ១៩៩៨ ហើយដែលជាប់ទាក់ទងនឹងតួនាទីរបស់ប្រព័ន្ធ ផ្សព្វផ្សាយក្នុងការឃោសនាបោះឆ្នោត ។ មាត្រា៧៤ អនុញ្ញាតឱ្យ គជប ប្រើប្រាស់គ្រប់ប្រព័ន្ធផ្សព្វផ្សាយពតិមាន ដើម្បី ផ្សព្វផ្សាយដោយមិនយកថ្លៃពីការងារបោះឆ្នោត និងអប់រំដល់អ្នកបោះឆ្នោត ។ មាត្រា៧៥ កំណត់ឱ្យ គជប រៀបចំកម្មវិធី ស្មើភាពគ្នា ដោយផ្តល់ចំនួនម៉ោងស្មើគ្នាដល់គណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនារបស់ខ្លួន ។ មាត្រា៧៦ ចែងថា "គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយមិនត្រូវសាប ព្រួសឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើឱ្យប្រឫកច្របល់បាត់ទំនុកចិត្តលើការសំងាត់នៃការបោះឆ្នោត"[១៩៤] ។

ក្នុងការបកស្រាយមាត្រាទាំងនេះ គជប បានតាក់តែងបទប្បញ្ញត្តិមួយចំនួនសំរាប់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងបទបញ្ជារបស់ខ្លួន ព្រមទាំងផ្តល់ឧបសម្ព័ន្ធពិសេសមួយសំរាប់បទបញ្ជានេះ មានចំណងជើងថា គោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយពតិមាន ។ បទបញ្ជាមានចែងពីកំហិតធំ១ពីរសំរាប់ប្រព័ន្ធផ្សព្វផ្សាយ ។ ទី១ ប្រព័ន្ធផ្សព្វផ្សាយឯកជនត្រូវទទួលយកការផ្សព្វផ្សាយឃោសនានយោបាយដោយបង់ថ្លៃរបស់គណបក្សនយោបាយលើមូលដ្ឋានស្មើភាពគ្នា ។ បើសិនគេទទួលផ្សព្វផ្សាយការឃោសនារបស់គណបក្សនយោបាយណាមួយ គេត្រូវតែទទួលផ្សព្វផ្សាយក្នុងតំលៃស្មើគ្នាឱ្យគណបក្សនយោបាយផ្សេង១ទៀត ដែលចង់ផ្សព្វផ្សាយដែរ ។ ទី២ ការឃោសនាខាងនយោបាយតាមប្រព័ន្ធផ្សព្វផ្សាយត្រូវចៀសវាងការប្រើរូបភាព ឬភាសាដែល "មាក់ងាយ បំភិតបំភ័យ ប្រមាថ សំដែងការមាក់ងាយ ឬអសីលធម៌ ដែលអាចបង្កអំពើហិង្សា ឬធ្វើឱ្យបាត់ទំនុកចិត្តលើ ភាពសំងាត់នៃការបោះឆ្នោត, សាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភាន់ច្រឡំ និងខូចរបៀបរបបសង្គម, ឬដែលមានពតិមានមិនត្រឹម ត្រូវចំពោះដំណើរការបោះឆ្នោត"[១៩៥] ។ គជប បានព្រមានថា "ការផ្សព្វផ្សាយ ការចុះផ្សាយ ឬបោះពុម្ពផ្សាយសំភារៈអប់រំ និង សំភារៈឃោសនា ដែលត្រូវបានរកឃើញថារំលោភបទប្បញ្ញត្តិខាងលើ គជប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និង ការប្រើប្រាស់សំភារៈខុសច្បាប់ទាំងនោះ"[១៩៦] ។

គជប ក៏បានកសាងគោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយដែរ ហើយបានទាមទារឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជនអនុវត្តតាមគោលការណ៍នេះ ដោយឈរលើមូលដ្ឋានថា ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសមានសារៈសំខាន់សំរាប់ការបោះឆ្នោត:

> *"អ្នកបោះឆ្នោតមានសិទ្ធិធ្វើការជ្រើសរើសទៅតាមពតិមានដែលខ្លួនទទួលបាន ។ សិទ្ធិនេះតំរូវឱ្យប្រព័ន្ធផ្សព្វផ្សាយពតិមានទាំងរដ្ឋ និងឯកជន មានកាតព្វកិច្ចអនុវត្តតាមគោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយពតិមាន ដូចមានចែងក្នុងឧបសម្ព័ន្ធ ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌"[១៩៧] ។*

គោលការណ៍បានតំរូវឱ្យប្រព័ន្ធផ្សព្វផ្សាយផ្តល់អាទិភាពដល់ការផ្សព្វផ្សាយពីការបោះឆ្នោតតាមការផ្តល់ "ពតិមានត្រឹមត្រូវមិនប្រកាន់បក្សពួក និងមានតុល្យភាពល្អ", ការចៀសវាងភាសាញុះញង់ ឬរំលោភបំពានក្នុងការរាយការណ៍ពីបញ្ហានានា

---

[១៩៤] Law on the Amendment to the Law on the Election of the National Assembly, as amended 2002, Arts. 74-6.

[១៩៥] NEC Regulations, 7.13.8.1-7.13.8.4.

[១៩៦] NEC Regulations, 7.13.9

[១៩៧] NEC Regulations, 7.20.1.

ដែលអាចបង្កការបាត់សណ្តាប់ធ្នាប់សង្គម ឬអំពើហិង្សា" ។ អ្នកសារពតិមាន ក៏ត្រូវចៀសវាងការលំអៀងដោយសារបានអំណោយ និងត្រូវលើកកំពស់ស្ថានភាពរបស់នារី និងជនពិការក្នុងសេចក្តីរាយការណ៍របស់ខ្លួន ។

គោលការណ៍មួយចំនួន គឺសំរាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ជាពិសេសដោយបានដាក់បញ្ជាឱ្យ "ធ្វើការបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយពតិមានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ ឬបេក្ខជន" ។ម្យ៉ាងទៀតមានការព្រមានដល់អ្នកសារពតិមាន និងអ្នកយកពតិមានរបស់រដ្ឋថា "ត្រូវជៀសវាងសំដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈការលើកដាក់សំលេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត" ។ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋក៏ "ត្រូវបង្ហាញនូវកិរិតគុណភាពខ្ពស់នៃវិជ្ជាជីវៈសារពតិមាន និងត្រូវផ្តល់ពតិមាន និងហេតុការណ៍ថ្មីៗ ឱ្យបានសមរម្យពិតប្រាកដ និងឥតលំអៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាព តាមគោលការណ៍សមធម៌ដល់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតទាំងអស់"[១៩៨] ។ គជប បានបញ្ជាក់ទៀតថា ប្រព័ន្ធផ្សព្វផ្សាយណាមួយខាងរដ្ឋ ឬឯកជន ដែលមិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួន "ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់"[១៩៩] ។

ក្រោយការឃោសនាបានចាប់ផ្តើម គេសង្កេតឃើញថា ស្ថានីយផ្សព្វផ្សាយឯកជននានាគោរពតាមមិនបានល្អគួរឱ្យពេញចិត្តទេនូវគោលការណ៍ទាំងឡាយខាងលើ ។ ក្នុងរបាយការណ៍ពីការឃោសនាបោះឆ្នោតក្នុង ២ថ្ងៃដំបូង គជប បានលើកឡើងថា "វិទ្យុ និងទូរទស្សន៍ឯកជនជាច្រើន មានសកម្មភាពប្រកាន់បក្សពួក ដោយធ្វើការផ្សព្វផ្សាយសុន្ទរកថារបស់តែ ២-៣គណបក្សប៉ុណ្ណោះ"[២០០] ។ ការទិតៀនបានផ្តោតជាពិសេសលើវិទ្យុតាព្រហ្មរបស់ FUNCINPEC ដែលគេចោទថា បានផ្សព្វផ្សាយពាក្យប្រមាថចំពោះនាយករដ្ឋមន្ត្រី និងពាក្យសំដីប្រកាន់ពូជសាសន៍ ចំពោះជនជាតិវៀតណាម, និងលើវិទ្យុ FM 103 ដែលគេចោទថាបានអនុញ្ញាតឱ្យអ្នកហៅទូរស័ព្ទចូលប្រើពាក្យប្រមាថព្រះអង្គម្ចាស់ រណឫទ្ធិ និងលោក សម រង្ស៊ី[២០១] ។ ដើម្បីឆ្លើយតបក្នុងរឿងនេះ គជប បានចេញ "សេចក្តីអំពាវនាវ" មួយចុះថ្ងៃ២៨ មិថុនា ចំពោះប្រព័ន្ធផ្សព្វផ្សាយឯកជន និងចេញ "ឧសានវាទ" មួយទៀតនៅថ្ងៃ ៧ កក្កដា ។ ឧសានវាទបានបញ្ជាក់ឡើងវិញឱ្យគ្រប់ប្រព័ន្ធផ្សព្វផ្សាយ "ចៀសវាងការប្រើភាសាដែលមាក់ងាយ, ប្រមាថ ញុះញង់ បំភិតបំភ័យ ឬអសីលធម៌" ដែលអាចបង្កការភ័យខ្លាច ការច្របូកច្របល់ឱ្យ និងការខូចរបៀបរបបក្នុងសង្គម និងក្នុងបរិយាកាសបោះឆ្នោត" និងត្រូវ "ផ្តល់ពតិមានពិតប្រាកដឥតលំអៀង និងមានតុល្យភាព" ។ ឧសានវាទបានណែនាំបន្ថែមថា ការផ្សព្វផ្សាយពីគណបក្សនយោបាយនានា "ត្រូវឈរលើគោលការណ៍សមធម៌សំរាប់គ្រប់គ្នា" ។ គជប បានគំរាមផ្អាកការផ្សាយរបស់ស្ថានីយណាដែលបន្តរំលោភលើគោលការណ៍ទាំងនេះ, រហូតដល់បោះឆ្នោតរួច ។

តាមរបាយការណ៍ ឧសានវាទទទួលបានជោគជ័យភ្លាមៗក្នុងការពង្រាបការផ្សព្វផ្សាយតាមវិទ្យុ ប៉ុន្តែករណីវិទ្យុតាព្រហ្មដែលមិនព្រមបញ្ឈប់កម្មវិធីផ្សាយមានទំនាស់របស់ខ្លួន បានធ្វើឱ្យស្ថានីយវិទ្យុគាំទ្រ CPPនានា គេត្រឡប់ទៅធ្វើដូចមុនវិញដែរ ។ នៅពេលនោះ គជប ពិនិត្យឃើញថា ខ្លួនគ្មានសិទ្ធិអំណាចតាមច្បាប់អ្វី ដើម្បីផ្អាកការផ្សាយរបស់ស្ថានីយនានាទេ ។ រឿងនេះនាំឱ្យមានការទិតៀនថា គជប ជា "ខ្លាក្រដាស" ។

ដូចទំនាស់ស្តីពីតួនាទីរបស់ប្រធានភូមិដែរ ទំនាស់ពីការរំលោភលើគោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងពេលឃោសនាបោះឆ្នោត បានបង្ហាញច្បាស់ពីកំរិតព្រំដែននៃសិទ្ធិអំណាច គជប ។ ក្នុងករណីប្រធានភូមិ គជប ធ្វើសហប្រតិបត្តិការ

---

[១៩៨] NEC Regulations, Chapter 7, Annex, Guidelines for the Media.

[១៩៩] NEC Regulations, 7.20.2.

[២០០] NEC, "Report on the Two First Days of the Electoral Campaign," press release, Phnom Penh, 28 June 2003.

[២០១] COMFREL, "Media Monitoring Unit Summary Report 5," July 19-July 25, 2003.

បានសំរេចមួយចំនួនជាមួយក្រសួងមហាផ្ទៃ ក្នុងការចេញសេចក្តីណែនាំរួមគ្នា និងព្យួរការងាររបស់ជនល្មើសខ្លះៗ, ប៉ុន្តែជាមួយក្រសួងពត៌មាន គឺពុំមានកិច្ចសហប្រតិបត្តិការបែបនេះទេ ។ ក្នុងករណីទំនាស់ទាក់ទិននឹងប្រព័ន្ធផ្សព្វផ្សាយទាំងពីរខាងលើ ក្រសួង ពត៌មាន និង គជប ហាក់ដូចធ្វើការងារក្នុងគោលដៅផ្ទុយគ្នា ។ ក្នុងករណីវិទ្យុសំបុកឃ្មុំ ក្រសួងពត៌មានគំរាមបិទស្ថានីយវិទ្យុ ទោះបី គជប រកឃើញថា ការផ្សាយរបស់វិទ្យុនេះមិនបានរំលោភលើគោលការណ៍នៃការបោះឆ្នោតត្តី ។ ប៉ុន្តែនៅពេល គជប ព្យាយាមដាក់ការត្រួតត្រាលើស្ថានីយផ្សាយ ដែលរំលោភលើគោលការណ៍ក្រសួងពត៌មានមិនបានជួយផ្តល់ការគាំទ្រទេ ។ បញ្ហានេះប្រហែលកាន់តែធ្ងន់ធ្ងរថែម ដោយសារនៅក្នុងក្រសួងពត៌មាន រដ្ឋមន្ត្រី លី ឡាយស្រេង និងរដ្ឋលេខាធិការ ខៀវ កាញារីទ្ធ មានការខ្វែងមតិជារឿយៗពីរឿងទំនាស់ទាក់ទិននឹងប្រព័ន្ធផ្សព្វផ្សាយ ។

ក្នុងការព្យាយាមដាក់ការត្រួតត្រាលើប្រព័ន្ធផ្សព្វផ្សាយក្នុងរយៈពេលឃោសនាបោះឆ្នោត គជប បានខិតខំកែប្រែជាបណ្តោះអាសន្ននូវតិរិយាបថ និងរបៀបរបបអនុវត្តន៍របស់ស្ថាប័នមួយដែលមានបញ្ហាខាងនយោបាយ និងសេដ្ឋកិច្ច ដែលមិនទាន់ដោះស្រាយ និងកំពុងបន្តកើតមាន ។ ការសិក្សារបស់ វិបសអ ពីការបោះឆ្នោតឆ្នាំ១៩៩៨ បង្ហាញថា អ្នកឆ្លើយសំភាសន៍ "ដែលទិតៀនដល់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ជារឿយៗ បាននិយាយពីទិដ្ឋភាពនៃការផ្សាយដែលស្ថិតនៅខាងក្រៅដែនអនុវត្តន៍នៃបទបញ្ជា គជប" ។ ការសិក្សាបញ្ជាក់ទៀតថា ភាពទន់ខ្សោយខាងស្ថាប័ននៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា (ភាពទន់ខ្សោយដែលកាន់តែអូសបន្លាយ និងធ្ងន់ធ្ងរឡើងដោយសារកង្វះសន្តិសុខ កង្វះតំលាភាពពីសំណាក់រដ្ឋាភិបាល និងកំហិតខាងសេដ្ឋកិច្ចផងដែរ) ធ្វើឱ្យការខិតខំកែប្រែប្រព័ន្ធផ្សព្វផ្សាយក្នុងរយៈពេលបោះឆ្នោត ជួបការលំបាកខ្លាំងណាស់ ។ ឆ្នាំ២០០៣ មានស្ថានភាពដូចមុនទៀត ។ នៅកម្ពុជា មានអ្នកសារពត៌មានដែលមានការបណ្តុះបណ្តាល និងសមត្ថភាពល្អៗ ប៉ុន្តែស្ថាប័ននៃប្រព័ន្ធផ្សព្វផ្សាយនៅតែទន់ខ្សោយ ។ កំណើនកិច្ចសហប្រតិបត្តិការនៅក្នុងក្រសួងពត៌មាន, រវាងក្រសួងពត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ, និងរវាងក្រសួងពត៌មាន និង គជប, អាចជួយឱ្យ គជប មានសិទ្ធិអំណាចកាន់តែខ្លាំងឡើងទៅលើប្រព័ន្ធផ្សព្វផ្សាយក្នុងរយៈពេលបោះឆ្នោត ។ ប៉ុន្តែបើរបបប្រជាធិបតេយ្យត្រូវមានវិសាលភាពធំជាងរយៈពេលបោះឆ្នោត ដូច្នេះ ត្រូវតែមានកំណែទំរង់លើរចនាសម្ព័ន្ធនៃប្រព័ន្ធផ្សព្វផ្សាយ ។

### *៤.៣.៤ សមធម៌ក្នុងលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ*

ពីឆ្នាំ១៩៩៨-២០០៣ ការផ្សព្វផ្សាយពត៌មានពីការបោះឆ្នោតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ត្រូវបានពង្រីកច្រើនណាស់ ។ នៅឆ្នាំ១៩៩៨ ដើម្បីឆ្លើយតបនឹងការគំរាមកំហែងធ្វើពហិការបោះឆ្នោតពីសំណាក់ SRP និង FUNCINPEC, គជប បានបង្កើតកម្មវិធីស្មើភាពគ្នា ដែលក្នុងនេះគណបក្សនយោបាយនីមួយៗទទួលបាន ៥នាទីសំរាប់ឃោសនាផ្សព្វផ្សាយពីកម្មវិធីនយោបាយរបស់ខ្លួន នៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ក្នុងរយៈពេលឃោសនាបោះឆ្នោត ។ នៅឆ្នាំ២០០២ គ្មានធ្វើកម្មវិធីនេះទៀតទេ ។ នៅឆ្នាំ២០០៣ កម្មវិធីនេះត្រូវបានបង្កើតឡើងវិញ និងបន្ថែមដោយ "កម្មវិធីពត៌មានសមធម៌" ដែលសំដៅពង្រីកលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឱ្យបានលើសពីនាទីឃោសនានានាដែលបានកំណត់ ជាពិសេសក្នុងកម្មវិធីពត៌មានទូរទស្សន៍ ។

ដូចបានបញ្ជាក់ភស្តុតាងនៅខាងលើ ការចាត់ចែងមិនស្មើភាពគ្នាលើគណបក្សនយោបាយពីសំណាក់អ្នកសរសេរពត៌មានក្នុងទូរទស្សន៍ គឺជាចំណុចបារម្ភយូរមកហើយរបស់អ្នកតាមដានប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ។ កម្មវិធីស្មើភាពគ្នា ត្រូវបានរៀបចំឡើងដើម្បីប៉ះប៉ូវរឿងនេះវិញ ដោយបែងចែករយៈពេលជាក់លាក់មួយក្នុងពត៌មានពេលយប់សំរាប់ "ការផ្សព្វផ្សាយពីការបោះឆ្នោត" និងផ្តល់ចំណែកជាភាគរយផ្សេងៗនៃរយៈពេលនេះ ទៅឱ្យគណបក្សនានាទៅតាមទំហំរបស់គណបក្ស ។ គោលដៅគឺ "ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់ក្រសួងពត៌មាន ក្នុងការដោះស្រាយការផ្សព្វផ្សាយពត៌មានស្មើភាពគ្នានៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាល អំពីសកម្មភាពគណបក្សនយោបាយនានា ក្នុងរយៈពេលមុនដល់ថ្ងៃបោះឆ្នោតក៏រីត

ជាតិឆ្នាំ២០០៣"[២០២] ។

ទិដ្ឋភាពគន្លឹះមួយនៃលទ្ធភាពឃោសនាមានសមធម៌ គឺវាមិនផ្តល់ចំនួននាទីផ្សាយស្មើគ្នាដល់គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីនោះទេ ប៉ុន្តែផ្តល់នាទីផ្សាយច្រើនដល់គណបក្សនានាដែលគេសន្មតថា មានប្រជាជនគាំទ្រច្រើន ។ ហេតុផលគឺពត៌មានសំរាប់បំរើផលប្រយោជន៍របស់សាធារណជន មិនមែនគណបក្សនយោបាយទេ ហើយផលប្រយោជន៍របស់សាធារណជនផ្តោតលើគូប្រកួតចំបងៗក្នុងការបោះឆ្នោត ។ ការគណនាបែងចែកនាទីផ្សាយធ្វើតាមរូបមន្តមួយដែលគិតតាមចំនួនអាសនៈ និងសន្លឹកឆ្នោតបានទទួលក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ និង ២០០២ ។ រូបមន្តនេះផ្តល់ ៥៦% ឱ្យ CPP, ២៧% ឱ្យ FUNCINPEC, ១៣% ឱ្យ SRP, និង ៣% ឱ្យគណបក្សផ្សេងៗទៀត ។ បន្ទាប់មកត្រូវកែសំរួលតួលេខទាំងនេះដើម្បីតំរូវតាមកត្តាមួយចំនួនដូចជា FUNCINPEC និង CPP ជាសមាជិកក្នុងរដ្ឋាភិបាល ដូច្នេះបានទទួលការផ្សព្វផ្សាយបោះឆ្នោតច្រើនហើយក្នុង ៥ឆ្នាំកន្លងមក, SRP ជាគណបក្សជំទាស់ចំបងគេ ដូច្នេះត្រូវទទួលបានការចាត់ចែងជាពិសេស, ចំណែករបស់ FUNCINPEC ក្នុងចំនួនអាសនៈ និងសន្លឹកឆ្នោត មាននិន្នាការថយចុះក្នុងការបោះឆ្នោត ៣លើកកន្លងមក រីឯ SRP បានកើនប្រជាប្រិយភាព ។ កត្តាទាំងអស់នេះ គាំទ្រការដកយកភាគរយខ្លះពី CPP សំរាប់បែងចែកឱ្យគណបក្សតូចៗ និងគណបក្សជំទាស់ចំបងដោយរក្សាទុកភាគរយរបស់ FUNCINPEC នៅដដែល ។ នៅទីបញ្ចប់ នាទីផ្សាយមានដូចតទៅ: CPP ៤៤% FUNCINPEC ២៧%, SRP ១៩% និងគណបក្សផ្សេងៗទៀត ១០% ។ ក្រៅពីជួយសំរួលការផ្សព្វផ្សាយសំរាប់គណបក្សផ្សេងៗក្រៅពី CPP នៅក្នុងវិទ្យុ និងទូរទស្សន៍រដ្ឋ, កម្មវិធីពត៌មានសមធម៌ បានព្យាយាមកែលំអគុណភាពពត៌មានក្នុងទូរទស្សន៍ ដោយមានបញ្ចូលច្រើនថែមទៀតនូវបទសំភាសន៍ផ្ទាល់ និងការលើកមតិខ្លីៗរបស់អ្នកនយោបាយ, មតិរបស់ប្រជាជននៅតាមផ្លូវ, ពត៌មានពីបញ្ហាទំនាស់ផ្សេងៗ, និងការអានអ៊ីមែល និងលិខិតទទួលបានពីទស្សនិកជន ។

UNDP បានអនុវត្តកម្មវិធីខាងលើដោយប្រើប្រាស់ទីប្រឹក្សាខាងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសំរបសំរួលគំរោងជាជនបរទេសម្នាក់ឱ្យគ្រប់គ្រងចំនួនភាគរយ និងពិនិត្យមើលលើសេចក្តីសំរេចនានាខាងវិចារណកថា ដើម្បីកាត់បន្ថយជាអតិបរមានូវការលំអៀងផ្សេងៗដែលអាចជ្រៀតចូលក្នុងកម្មវិធី ។ ក្របខ័ណ្ឌការងារសំរាប់គំរោងនេះ ធ្វើឱ្យវាអាចដំណើរការដោយឯករាជ្យដាច់ពីអ្នកដឹកនាំ TVK នានាជាអ្នកនៅក្រៅក្រុមស្នូលដែលត្រូវបានចាត់តាំងឱ្យអនុវត្តគំរោង គឺបានកាត់បន្ថយជាអតិបរមានូវគ្រោះថ្នាក់នៃការជ្រៀតជ្រែកខាងនយោបាយ ។ ការលំបាកធំៗដែល UNDP បានជួបក្នុងការអនុវត្តន៍គំរោង គឺការលំបាកខាងបច្ចេកទេសដោយសារសំភារៈបរិក្ខារផ្គត់ផ្គង់ខុសប្រភេទវា ឬមកដល់យឺត ។

មានទំនាស់ចំបងពីរ បានផុសឡើងពីកម្មវិធីនេះ ។ ទំនាស់ទី១ ផុសឡើងនៅពេលដែល SRP បានប្រកាសនៅខាងដើមរយៈពេលឃោសនាបោះឆ្នោតថាដកខ្លួនចេញពីកម្មវិធី ដោយចោទថា ការផ្សព្វផ្សាយពីសកម្មភាពគណបក្សខ្លួនមានលក្ខណៈអវិជ្ជមានជាងការផ្សព្វផ្សាយពីគណបក្សទៀតៗ ។ តំណាង SRP ម្នាក់បានលើកពីការតវ៉ារបស់គណបក្សខ្លួនដូចតទៅ:

> *"ខ្ញុំបានពិនិត្យតាមដានពីគុណភាពនៃពេល ២នាទីដែលយើងមាន (ក្នុងរវៀងរាល់ពេលដប់ៗនាទីនោះ) ហើយឃើញមានការលំអៀងយ៉ាងច្បាស់ទែង ។ ឧទាហរណ៍ នៅថ្ងៃដំបូងនៃការឃោសនា ពួកគេបានថតរូបភាពមួយចំនួនពីការដង្ហែក្បួនរបស់យើង ហើយអះអាងថាមានអ្នកចូលរួមប្រហែល ២.០០០នាក់នៅទីនោះ ។ រឿងនេះមិនពិតទេ ព្រោះមានយ៉ាងតិច ១០.០០០នាក់"[២០៣] ។*

ម្យ៉ាងទៀត គណបក្សបានតវ៉ាពីគោលនយោបាយជ្រើសរើសប្រជាជននៅតាមផ្លូវ ឱ្យផ្តល់មតិពីព្រឹត្តិការណ៍:

---

[២០២] UNDP, "Equity News, a Breakthrough in Cambodian Broadcasting," report, Phnom Penh, Aug. 2003, 2.

[២០៣] SRP national representative (3), personal interview, Phnom Penh, 10 July 2003.

*"ក្នុងចំណោករបស់ CPP គេជ្រើសយកអ្នកដឹកនាំយុវជនម្នាក់ ។ ប៉ុន្តែក្នុងកម្មវិធីរបស់យើង គេគ្រាន់តែជ្រើសយកអ្នកគាំទ្រម្នាក់នៅតាមផ្លូវប៉ុណ្ណោះ ។ ដូច្នេះការផ្តល់មតិមានគុណភាពខុសគ្នា: មួយគឺអ្នកដឹកនាំគណបក្សមានការប្តេជ្ញាចិត្ត, ឯមួយទៀតគឺគ្រាន់តែជាអ្នកគាំទ្រម្នាក់នៅតាមផ្លូវ" ។*

តាម SRP, រឿងនេះកាន់តែធ្ងន់ធ្ងរឡើងនៅថ្ងៃបន្ទាប់ ពេលដែល SRP ទៅកាន់ទីផ្សារ និងនិយាយជាមួយអ្នកលក់ដូរ ។

*"គេជ្រើសយកអ្នកលក់ដូរម្នាក់ឱ្យនិយាយពីការសង្ស័យរបស់គាត់ថា SRP នឹងអាចអនុវត្តតាមការសន្យារបស់ខ្លួនបាន ។ ប៉ុន្តែក្នុងនាទីរបស់ CPP អ្នកឆ្លើយសំភាសន៍ទាំងអស់សុទ្ធតែជាសមាជិករបស់ CPP ហើយពួកគេសុទ្ធតែនិយាយថាCPP អស្ចារ្យណាស់" ។*

បញ្ហាមួយទៀតគឺគុណភាពអន់នៃហ្វីលដែលថតកម្មវិធី SRP ។ ដោយសារចំណុចត្រូវទិតៀនទាំងនេះ SRP បានចេញសេចក្តីប្រកាសមួយថា គណបក្សមានផែនការដកខ្លួនចេញពីកម្មវិធីពិតមានសមធម៌ ។

ទំនាស់រវាង SRP និង UNDP ក្រោយមកបានស្ងប់អស់វិញ ថ្វីបើការប្រឹងប្រែងគ្រប់គ្រងទំនាស់គឺមានតិចក៏ដោយ ។ តំណាង SRP បានអះអាងថា សំណើពីដំបូងរបស់ SRP សុំជួបពិភាក្សាជាមួយមន្ត្រី UNDP ត្រូវបានគេបំភ្លេចចោល ហើយ UNDP មិនបានយកចិត្តទុកដាក់អ្វីច្រើនពីការទិតៀនរបស់ SRP ទេ ។ នៅពេល គជប ស្នើឱ្យ SRP ចរចាជាមួយ UNDP, ខាង SRP បានវែកញែកថា គ្មានអ្វីត្រូវចរចាទេ បើសិន UNDP យល់ថាកម្មវិធីមិនអាចកែលំអបានទេនោះ ។ ក្រោយមក SRP បានចូលពិភាក្សាជាមួយ UNDP ក្រោយដែលទីប្រឹក្សាខាងប្រព័ន្ធផ្សព្វផ្សាយ របស់ UNDP បានផ្តល់បទសំភាសន៍មួយក្នុងវិទ្យុអាស៊ីសេរីដែល SRP ពិនិត្យឃើញថា មានការទទួលស្គាល់ថា អាចមានកន្លែងកែលំអបាននៅក្នុងកម្មវិធីពិតមានសមធម៌[២០៤] ។

មន្ត្រី UNDP ម្នាក់បានឆ្លើយសំភាសន៍នៅខែសីហា ប្រាប់ថា វិវាទនេះគឺជាវិធីឃោសនាមួយធ្វើដោយ SRP: "នៅពេលមានការផ្តួចផ្តើមគំនិតអ្វីមួយ SRP ស្វែងរកមុខមាត់ដោយធ្វើការទិតៀនគំនិតនោះ" ។ គាត់បន្ថែមថា "ខ្ញុំមិនបន្ទោសពួកគេពីរឿងនេះទេ ពីព្រោះជាក់ស្តែងពួកគេពុំមានលទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទេ"[២០៥] ។

គជប បានអនុវត្តតួនាទីសំរុះសំរួលមួយក្នុងរឿងនេះ ប៉ុន្តែមិនបានជោគជ័យរាល់ៗលើកទេ ។ SRP និយាយថា SRP បានឯកភាពជាមួយ គជប ពីរបៀបធ្វើការមួយគឺ SRP អាចបញ្ជូនតំណាងម្នាក់ទៅរួមសហការនៅពេលមានថតឈុតអ្វីមួយសំរាប់នាទី SRP ប៉ុន្តែក្រោយមក UNDP បានបដិសេធវិធីធ្វើការបែបនេះ ។ តំណាង SRP ម្នាក់បានលើកឡើងថា:

*"គជប បានជួយជ្រោមជ្រែងច្រើន ហើយយើងក៏មានទំនាក់ទំនងធ្វើការងារល្អជាមួយ គជប ប៉ុន្តែ គជប ទន់ខ្សោយ ។ ក្នុងកម្មវិធីនេះ ពួកគេទុកឱ្យ UNDP ធ្វើអ្វីៗទាំងអស់ ហើយបន្ទាប់មកពួកគេបានលើកពីការសំរុះសំរួលនេះឡើង ប៉ុន្តែ UNDP មិនយល់ព្រមទេ ។ គ្មានអ្នកណាស្តាប់ គជប សោះ តែតាមគោលការណ៍ UNDP ត្រូវធ្វើការឱ្យ គជប"[២០៦] ។*

UNDP បានទិតៀនច្រើនពីការប្រឹងប្រែងរបស់ គជប ។ របាយការណ៍របស់ UNDP ពីទំនាស់នេះ បានលើកឡើងថា ការប្រឹងប្រែងសំរុះសំរួលរបស់ គជប បានធ្វើឱ្យ "ទស្សនៈស្តីពីពិតមានបានប្រែប្រួលខុសលំនាំដើមកាន់តែខ្លាំងឡើង" ហើយ "បើសិនការលើកគំនិតរបស់ គជប បានទទួលជោគជ័យនោះ អាជីពសារពត៌មានឯករាជ្យប្រហែលត្រូវអន្តរាយអស់បាត់

[២០៤] Information from SRP national representative's account of the conflict (3), personal interview, Phnom Penh 10 July 2003.

[២០៥] UNDP representative (2), personal interview, Phnom Penh, 4 Aug 2003.

[២០៦] SRP national representative (3), personal interview, 18 July 2003.

ហើយ"[២០៧] ។ UNDP អះអាងថា រឿងនេះបាន "សំរួលទៅវិញ" នៅពេល UNDP បានពន្យល់ពីសេចក្តីសំរេចរបស់ខ្លួនអំពីកម្មវិធីនេះ ។ នៅថ្ងៃ ១៨ កក្កដា តំណាង SRP ម្នាក់បានលើកឡើងថា ការយកពតិមានពី SRP សំរាប់កម្មវិធីពតិមានសមធមិហាក់ដូចជាមានការកែលំអ ។ ការសំរេចអារកាត់លើការអះអាងខុសៗគ្នាក្នុងរឿងទំនាស់នេះ វាស្ថិតនៅខាងក្រៅរង្វង់ព្រំដែននៃការសិក្សារបស់យើង ប៉ុន្តែវាច្បាស់ណាស់ដែលអ្នកចូលរួមខុសៗគ្នា មានចំណាប់អារម្មណ៍ខុសៗគ្នាថាតើចំណុចទិតៀនចំបងរបស់ SRP ជាអ្វី និងត្រឹមត្រូវប៉ុណ្ណា ។ ទំនាស់ហាក់ដូចវិលវល់ជុំវិញរឿងទស្សនៈខុសៗគ្នាពីអ្វីជាការយកពតិមានមានតុល្យភាព ហើយ UNDP បានអធិប្បាយច្រើនណាស់ពីរឿងនេះនៅក្នុងរបាយការណ៍អំពីគំរោងរបស់ខ្លួន ។ ការដែល UNDP បន្តផ្សព្វផ្សាយពតិមានពី SRP ទោះបី SRP "ដកខ្លួនចេញ" ក្តី បានកាត់បន្ថយឱកាសរបស់គណបក្សនេះក្នុងការបង្អាក់ដំណើរការកម្មវិធី ហើយការទទួលស្គាល់ជាក្រោយមកទៀតដោយ SRP ថា ការផ្សព្វផ្សាយពតិមានអាចទទួលយកបាន វាបង្ហាញថា ទំនាស់នេះមិនបានប៉ះពាល់ដល់ការវាយតំលៃជារួមពីភាពសុចរិត និងសេរីភាពនៃការបោះឆ្នោតទេ ។ ជាក់ស្តែង អង្គការតាមដានការបោះឆ្នោតនានា ដែលបានពិនិត្យតាមដានពីខ្លឹមសារវិជ្ជមាន/អវិជ្ជមាន និងចំនួនម៉ោង និងដែលបានវិនិច្ឆ័យថា កម្មវិធីមានជោគជ័យធំណាស់, គឺបានបញ្ជាក់គាំទ្រយ៉ាងសំខាន់ដល់ការប្រឹងប្រែងរបស់ UNDP ។

ក្របខ័ណ្ឌនៃកម្មវិធីខាងលើ បានទទួលការទិតៀនច្រើនទៀតពីសំណាក់គណបក្សតូចៗ ដែលទាំងអស់គ្នាបានចំណែកតែ ១០% ក្នុងកម្មវិធីពតិមាន ។ គណបក្សតូចៗដែលយើងធ្វើអង្កេត បានទិតៀនដូចៗគ្នាពីការបែងចែកម៉ោងមិនស្មើ ។ គជប និង UNDP បានរៀបចំសិក្ខាសាលានៅខែមិថុនា ដើម្បីព្យាយាមជំរាបដល់គណបក្សនយោបាយទាំងអស់ពីគោលការណ៍សមធមិដែលបានយកមកប្រើដើម្បីកំនត់ចំនួនភាគរយនៃពេលម៉ោងបែងចែកឱ្យគណបក្សនីមួយៗ ។ តំណាង UNDP ម្នាក់លើកឡើងថា គណបក្សតូចៗ "មិនបានទទួលយកគោលការណ៍នេះទេនៅថ្ងៃនោះ ហើយក៏មិនបានទទួលយករហូតដល់ចប់ ។ នេះជាការខូចខាតមួយនៅក្នុងដំណើរការ"[២០៨] ។ អង្កេតលើគណបក្សតូចៗដែលធ្វើឡើង សំរាប់ការសិក្សានេះ បានបញ្ជាក់គាំទ្រដល់មតិខាងលើ ។ ក្នុង ១១គណបក្សតូចៗដែលបានធ្វើអង្កេតអំពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ១០គណបក្សយល់ថា លទ្ធភាពមិនយុត្តិធមិទេ គឺគ្របសង្កត់ដោយគណបក្សធំៗ ។ មតិយោបល់លើកម្មវិធីពតិមានសមធមិមានជាអាទិ៍:

> *"កម្មវិធីសមធមិក្នុង TVK លំអៀងខ្លាំងណាស់ ។ ពួកគេមិនផ្តល់លទ្ធភាពច្រើនឱ្យគណបក្សតូចៗ ដើម្បីអាចបានទៅដល់ប្រជាជនកាន់តែច្រើននោះទេ"[២០៩] ។*

> *"យើងចង់បញ្ជាក់ពីការជំទាស់ចំពោះកម្មវិធីពតិមានសមធមិក្នុង TVK ។ កម្មវិធីនេះមិនយុត្តិធមិសោះ ។ ពួកគេផ្តល់ ៩០% ឱ្យគណបក្សធំៗ និង ១០% ឱ្យគណបក្សតូចៗ ដូច្នេះវាច្បាស់ជាការប្រកួតប្រជែងមិនស្មើភាព និងមិនយុត្តិធមិទេ ។ ម្យ៉ាងទៀតជួនកាលពួកគេចាក់ផ្សាយពីការឃោសនារបស់គណបក្សតូចៗ ជួនមិនផ្សាយទេ"[២១០] ។*

> *"កម្មវិធីសមធមិអយុត្តិធមិខ្លាំងណាស់ ។ គណបក្សធំៗអាចមានម៉ោងច្រើន រីឯគណបក្សតូចៗមានម៉ោងតិចណាស់ ។ ឧទាហរណ៍ គណបក្សកាន់អំណាចមានទូរទស្សន៍ និងវិទ្យុរបស់ខ្លួនផ្ទាល់ ហើយពួកគេនៅតែបានម៉ោងច្រើនពីកម្មវិធីសមធមិទៀត ។ រឿងនេះអយុត្តិធមិខ្លាំងណាស់ចំពោះគណបក្សតូចៗ"[២១១] ។*

[២០៧] UNDP "Equity News…" 15.

[២០៨] UNDP representative (2), personal interview, Aug. 4 2003.

[២០៩] Farmer's Party representative (58) , personal interview, 14 July 2003.

[២១០] Khmer Angkor Party representative (59), personal interview, 14 July 2003.

[២១១] Norodom Chakrapong Proloeung Khmer Party representative (60), personal interview, Phnom Penh, 16 July 2003.

*"ខ្ញុំមិនសប្បាយចិត្តជាខ្លាំងចំពោះរូបមន្តដែលពួកគេប្រើដើម្បីបែងចែកម៉ោងសំរាប់គណបក្សនីមួយៗ ។ ថ្វីបើយើងមិនសប្បាយចិត្ត ប៉ុន្តែយើងមិនអាចធ្វើអ្វីបានទេ ពីព្រោះយើងជាគណបក្សតូច ។ ចំពោះគណបក្សតូចដូចយើង មួយនាទីតាមរលកធាតុអាកាសវាសំខាន់ងាប់រស់"*[២១២] ។

*"យើងមិនពេញចិត្តជាខ្លាំងជាមួយកម្មវិធី (សមធម៌) ។ យើងចង់ទិតៀនកម្មវិធីនេះជាសាធារណៈ ពីព្រោះវាបំរើផលប្រយោជន៍របស់គណបក្សកាន់អំណាច"*[២១៣] ។

*"ខ្ញុំចង់ឱ្យគណបក្សទាំងអស់បានស្មើភាពគ្នាក្នុងការឃោសនា ដើម្បីយើងអាចធ្វើការប្រកួតប្រជែងគ្នាបានដោយយុត្តិធម៌ ។ ខ្ញុំមិនចង់ឃើញអ្វីដែលមិនស្មើភាពគ្នា ដូចជា កម្មវិធីសមធម៌ក្នុង TVK នោះទេ"*[២១៤] ។

ជំហរដែលថា គណបក្សទាំងអស់គួរទទួលបានការគិតគូរពិចារណាដោយស្មើភាព និងទទួលបានម៉ោងស្មើគ្នា គឺត្រូវស្របតាមគោលការណ៍ផ្សព្វផ្សាយពតិមានដូចក្នុងកម្មវិធីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពីលើកមុនៗ ដូចជា កម្មវិធីលទ្ធភាពស្មើគ្នាក្នុងឆ្នាំ១៩៩៨ និងកម្មវិធីវិទ្យុ UNTAC ឆ្នាំ១៩៩៣ ជាដើម ។ តាំងពីឆ្នាំ១៩៩៣ មក ការផ្តួចផ្តើមគំនិតផ្សេងៗរបស់អន្តរជាតិសំរាប់កម្ពុជា គឺតែងជួយគាំទ្រគណបក្សតូចៗ ដោយគេមើលឃើញថា ការផុសឡើងនៃគណបក្សតូចៗ គឺជាការធានាឱ្យមានកំណើនរបបពហុបក្សនៅក្នុងសង្គមកម្ពុជា ។ ផ្ទុយទៅវិញ កម្មវិធីសមធម៌បានកាត់បន្ថយសារៈសំខាន់នៃគណបក្សតូចៗ ដោយជជែកវែកញែកថា អ្នកបោះឆ្នោតយកចិត្តទុកដាក់នឹងគណបក្សធំៗច្រើនជាង ហើយគណបក្សធំៗគួរបានម៉ោងច្រើនជាង ពីព្រោះពួកគេតំណាងផលប្រយោជន៍របស់អ្នកបោះឆ្នោតច្រើននាក់ជាង ។ ក្នុងរឿងនេះ ទស្សនៈ UNDP ស្តីពីសមធម៌ ថ្វីបើវាត្រឹមត្រូវបើគិតតាមគំរូបែបប្រជាធិបតេយ្យនៃតួនាទីរបស់សារពតិមាន ប៉ុន្តែ វាផ្ទុយពីជំហរស្មារតីរបស់អន្តរជាតិចំពោះរបបប្រជាធិបតេយ្យតាមការបោះឆ្នោតនៅកម្ពុជាដែលឃើញមានជាទូទៅក្នុងទសវត្សរ៍១៩៩០ ។ ការបដិសេធរបស់គណបក្សតូចៗ និង SRP ផងដែរ ដើម្បីកែប្រែគំនិតយល់ឃើញពីរបបប្រជាធិបតេយ្យរបស់ខ្លួនពីការផ្តែកលើភាពស្មើគ្នារវាងគណបក្សនានាទៅផ្អែកលើសមធម៌រវាងគណបក្សនានាវិញ ដោយយោងតាមចំនួនប្រជាជនអ្នកគាំទ្រខ្លួន គឺជារឿងដែលគេអាចយល់បាន ឬក៏អាចទាយទុកមុនបានផង ។

ការមិនពេញចិត្តរបស់គណបក្សតូចៗចំពោះកម្មវិធីពតិមានសមធម៌ គួរយកមកពិចារណាធៀបនឹងរបាយការណ៍ UNDP ស្តីពីអ៊ីមែលជាច្រើនរបស់ទស្សនិកជនដែលពេញចិត្តចំពោះបែបបទនេះ និងដែលមានអារម្មណ៍ថា កម្មវិធីបានផ្តល់ឱ្យពួកគេនូវពតិមានកាន់តែប្រសើរសំរាប់ប្រើជាមូលដ្ឋានក្នុងការសំរេចចិត្តបោះឆ្នោត ។ UNDP បានសង្កត់ធ្ងន់ជារឿយៗថា កម្មវិធីពតិមានគឺសំរាប់បំរើផលប្រយោជន៍របស់អ្នកបោះឆ្នោត មិនមែនគណបក្សនយោបាយនានាទេ ។

គោលដៅ "មិនប្រកាស" មួយទៀតនៃកម្មវិធីសមភាព គឺកម្មវិធីដែលតាក់តែងឱ្យរស់រវើក និងស្របតាមចំណូលចិត្តរបស់ទស្សនិកជន អាចជំរុញឱ្យមានការផ្លាស់ប្តូរវប្បធម៌ក្នុង TVK ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាជាទូទៅ ។ ប៉ុន្តែតាមពិតតែមួយរយៈពេលខ្លីសោះក្រោយការបោះឆ្នោត កម្មវិធីពតិមានក្នុងទូរទស្សន៍ បានត្រឡប់ទៅជាការផ្សព្វផ្សាយផ្តោតលើរដ្ឋាភិបាលដូចធម្មតាវិញ ដោយមានលេចឮរបាយការណ៍មួយចំនួនថា អ្នកសារពតិមានដែលបានចូលរួមក្នុងកម្មវិធីសមធម៌ត្រូវបានមន្ត្រីថ្នាក់លើនៅ TVK និងក្រសួងពតិមាន ធ្វើការបន្ទុចបង្អាក់មិនឱ្យបន្តបទពិសោធន៍ធ្វើរបាយការណ៍មានការទិតៀន

---

២១២ Union of National Solidarity Party representative (61) , personal interview, Phnom Penh, 21 July 2003.

២១៣ Hang Dara Democratic Movement Party representative (62), personal interview, Phnom Penh, 21 July 2003.

២១៤ Liberal Democratic Party representative (63), personal interview, Phnom Penh, 22 July 2003.

ទៀត[២១៥] ។ ការសង្ឃឹមថា តំរូវរបស់ទស្សនិកជន អាចឈ្នះលើផលប្រយោជន៍របស់គណបក្សដែលព្យាយាមរក្សាការត្រួតត្រាយ៉ាងណែនលើប្រព័ន្ធផ្សព្វផ្សាយ, ប្រហែលមិនប្រាកដនិយមទេ យោងតាមការក្រខ្សត់តំរូវការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ ដែលធ្វើឱ្យការពឹងផ្អែកលើអ្នកជួយឧបត្ថម្ភនៃមជ្ឈដ្ឋាននយោបាយកាន់តែចាំបាច់ឡើង ។ សង្គ្រាមធ្វើការវាយតំលៃប្រហែលមិនកើតមានទេក្នុងបរិបទនេះ ហើយកម្មវិធីមានប្រជាប្រិយភាព និងការច្នៃប្រឌិតថ្មី ប៉ុន្តែហ៊ានប្រឈមខ្លះៗខាងនយោបាយដូចជាកម្មវិធីសមធម៌នេះជាដើម ប្រហែលមិនសូវមានលទ្ធភាពច្រើនទេក្នុងការបន្តដំណើរការទៅមុខទៀត ។

គោលដៅជំរុញការតំរង់ទិសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាឡើងវិញក្នុងរយៈពេលវែង មានលក្ខណៈបន្ទាប់បន្សំ និងគ្មានប្រកាសចេញក៏ពិតមែន ប៉ុន្តែវាមានសារៈសំខាន់ ។ ជោគជ័យក្នុងការផ្តល់កម្មវិធីរយៈពេលខ្លីដែលអាចផ្តល់លក្ខណៈពេញច្បាប់ដល់ការបោះឆ្នោត ប៉ុន្តែបរាជ័យក្នុងការជំរុញការផ្លាស់ប្តូរក្នុងរយៈពេលវែងនូវរចនាសម្ព័ន្ធ កម្មសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយ អាចជួបគ្រោះថ្នាក់នៃការពន្យាពេលកំណែទំរង់ដ៏សំខាន់ៗ ។ គណបក្សតូចៗដែលឆ្លើយសំភាសន៍ក្នុងការសិក្សានេះ មានជំនឿទាំងអស់គ្នាថា អយុត្តិធម៌ធំបំផុតក្នុងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាគឺ ការគ្របសង្កត់លើប្រព័ន្ធផ្សព្វផ្សាយឯកជនដោយគណបក្សធំៗ ។

សរុបមក កម្មវិធីសមធម៌បានសំរេចគោលដៅចំបងរបស់វា (បើកចំហទូរទស្សន៍ និងវិទ្យុរដ្ឋ ចំពោះគណបក្សនានាឱ្យបានច្រើនជាងមុន ជាពិសេស SRP) ។ អ្នកតាមដានប្រព័ន្ធផ្សព្វផ្សាយដូចជា COMFREL ជាដើម បានវាយតំលៃការប្រឹងប្រែងនេះថា បានជោគជ័យទាំងខាងបរិមាណ និងគុណភាព ។ ពត៌មានត្រឡប់ទទួលពីទស្សនិកជនបង្ហាញថា ទស្សនិកជនបានរីករាយជាមួយកម្មវិធី និងយល់ថាមានប្រយោជន៍សំរាប់ជួយកំណត់ជំរើសបោះឆ្នោត ។ ចំណុចខ្វះខាតកម្មវិធី គឺបរាជ័យរបស់ពួកអ្នករៀបចំក្នុងការវាយតំលៃពីកំលាំងក្រាញរបស់ SRP និងគណបក្សតូចៗ ក្នុងការទទួលយកទស្សនៈសមធម៌ ដែលខុសពីគោលការណ៍ពីលើកមុនៗនៃការគាំទ្ររបស់អន្តរជាតិដល់គណបក្សនយោបាយនានា និងដែលផ្ទុយពីផលប្រយោជន៍របស់គណបក្សទាំងនេះផង ។ អ្នករៀបចំកម្មវិធីបានព្យាយាមម្តងហើយម្តងទៀត ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃជំហររបស់ខ្លួន ប៉ុន្តែពួកគេមិនបានត្រៀមខ្លួនទេ ចំពោះទំនាស់ដែលអាចផុសឡើងជាមួយគណបក្សតូចៗ និង SRP ហើយក្រោយមកក៏ពិនិត្យឃើញថា ទំនាស់ទាំងនេះគឺ ពិបាកគ្រប់គ្រង ។

### *៤.៣.៥ លទ្ធផលនៃទំនាស់ស្តីពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ*

គិតជារួម កម្មវិធីផ្សេងៗសំរាប់កែលំអលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បានទទួលជោគជ័យក្នុងការបើកចំហគួរកត់សំគាល់នូវលទ្ធភាពនេះសំរាប់ SRP និងគណបក្សតូចៗក្នុងកំរិតណាមួយ ។ COMFREL បានវាយតំលៃពីស្ថានភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដូចតទៅ:

> *"គួរកត់សំគាល់ថា ពិនិត្យតាមគ្រប់កម្មវិធីក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ការផ្សព្វផ្សាយពីគណបក្សធំៗទាំងបី គឺមានតុល្យភាពគួរសម ដោយ CPP បានទទួល ១% ច្រើនជាង FUNCINPEC និង SRP ។ វិទ្យុក៏បើកចំហ និងសកម្មភាពកាន់តែច្រើន តាមរយៈការផ្សព្វផ្សាយពីការជជែកដេញដោលខាងនយោបាយ ការពិភាក្សាតុមូល បទសំភាសន៍ជាមួយថ្នាក់ដឹកនាំគណបក្ស និងការឃោសនាខាងនយោបាយតាមរយៈស្ថានីយវិទ្យុមួយចំនួន"* ។

ចំពោះស្ថានីយទូរទស្សន៍ឯកជនវិញ COMFREL បានលើកឡើងថា ស្ថានភាពគ្មានប្រែប្រួលទេ ។ នៅ TV5 និង TV3 (ទូរទស្សន៍ពីរដែលមានប្រជាប្រិយភាពជាងគេ) "ការផ្សព្វផ្សាយពត៌មាននយោបាយភាគច្រើនផ្តោតលើរដ្ឋាភិបាល និងនាយករដ្ឋមន្ត្រី ហើយ CPP ជាគណបក្សតែមួយដែលមានលើកឡើង"[២១៦] ។

---

[២១៥] Kuch Naren and Porter Barron, "After Elections, TVK Gets Back to Normal," Cambodia Daily, 11 Aug 2003, 17.

[២១៦] COMFREL, "Report of Media Monitoring," press release, Phnom Penh, 6 Aug 2003.

ច្បាស់ហើយ ការបើកចំហទូរទស្សន៍ និងវិទ្យុរដ្ឋ វាគ្រប់គ្រាន់សំរាប់បន្ធូរបញ្ហាដែលជាប្រភពទំនាស់រវាងគណបក្សធំៗ ហើយ SRP និង FUNCINPEC ក៏មិនបានលើកពីកង្វះលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទេ នៅពេលគេប្រកែកមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ។ សំរាប់គណបក្សតូចៗ អង្កេតរបស់យើងបានបង្ហាញពីការបន្តមិនពេញចិត្តយ៉ាងខ្លាំង ប៉ុន្តែលទ្ធផលបោះឆ្នោតដ៏ខ្សត់ខ្សោយបំផុតដែលពួកគេទទួលបានក្រោយពេលដែលមានកម្មវិធីស្មើភាពគ្នាអស់រយៈពេល ១០ឆ្នាំមកហើយ បានបង្ហាញថា កង្វះការពាក់ព័ន្ធរបស់ពួកគេជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ ប្រហែលដោយសារកង្វះខាតការយកចិត្តទុកដាក់ពីសំណាក់សាធារណជន ។

## ៤.៤ ទំនាស់ស្តីពីការដោះស្រាយបណ្តឹងតវ៉ា

ដូចក្នុងការបោះឆ្នោតលើកមុនៗ ទំនាស់ស្តីពីការដោះស្រាយបណ្តឹងតវ៉ា បានក្លាយជាបញ្ហាគួរឱ្យកត់សំគាល់បំផុតមួយសំរាប់ការបោះឆ្នោតឆ្នាំ២០០៣ ។ ការសិក្សារបស់ *វបសអ* ស្តីពីការបោះឆ្នោតឆ្នាំ១៩៩៨ បង្ហាញពីពួកសមាជិក គជប បានរាយការណ៍ថា គជប ត្រូវបាត់ម្ចាស់ការដោយចំនួនបណ្តឹងតវ៉ាដ៏ច្រើន និងកង្វះនីតិវិធីសំរាប់ចាត់ចែងវា ។ បញ្ហាពិសេសមួយនៅឆ្នាំ១៩៩៨ គឺបណ្តឹងតវ៉ាត្រូវដាក់នៅថ្នាក់ជាតិ មិនមែននៅថ្នាក់មូលដ្ឋានទេ ដែលតំរូវឱ្យ គជប ថ្នាក់ជាតិត្រូវស៊ើបអង្កេតលើការចោទប្រកាន់ពីការរំលោភផ្សេងៗច្រើនពាន់ករណីក្នុងទូទាំងប្រទេស ។ ពេលវេលា ធនធាន និងជំនាញ មិនបានត្រៀមគ្រប់គ្រាន់ទេសំរាប់ការងារនេះ ដូច្នេះហើយប្រព័ន្ធក៏ត្រូវគាំងដំណើរ ។

### *៤.៤.១ នីតិវិធីសំរាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា*

ក្នុងច្បាប់វិសោធនកម្មនៃច្បាប់បោះឆ្នោត ដែលបានអនុម័តនៅឆ្នាំ២០០២ មានបន្ថែមមាត្រាមួយចំនួនដើម្បីកសាងនីតិវិធីមួយសំរាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា ហើយមាត្រាទាំងនេះត្រូវបានបំពេញបន្ថែមដោយបទបញ្ជារបស់ គជប ។ បទបញ្ជាហាក់ដូចសំរាប់ចៀសវាងការកើតបញ្ហាដូចឆ្នាំ១៩៩៨ ។ ឧទាហរណ៍ បទបញ្ជា គជប សំរាប់ការចុះបញ្ជីអ្នកបោះឆ្នោត និងការឃោសនាបោះឆ្នោត តំរូវឱ្យអ្នកតវ៉ា ដាក់ការប្តឹងជំទាស់ទៅក្រុមប្រឹក្សាឃុំ ក្នុងរយៈពេលចុះបញ្ជី ។ និងទៅ គឃប ក្នុងរយៈពេលឃោសនា ។ គឃប ត្រូវបង្កើតក្រុមមួយសំរាប់ស៊ើបអង្កេតពីបណ្តឹងតវ៉ា ដែលមានតាំងពីការចុះពិនិត្យដល់កន្លែង និងការសាកសួរសាក្សីផង ។ បើសិនស៊ើបអង្កេតឃើញថា បណ្តឹងតវ៉ាអាចទទួលយកបាន ភាគីនានានៃទំនាស់ត្រូវឆ្លងកាត់ដំណើរការសំរុះសំរួលមួយ មុននឹងត្រូវបញ្ជូនទៅថ្នាក់លើទៀត ។ នីតិវិធីបែបនេះអនុវត្តលើគ្រប់បទល្មើសលើកលែងតែបទល្មើសខាងព្រហ្មទណ្ឌដែលត្រូវតែបញ្ជូនទៅតុលាការ ។

ដូចគ្នាដែរ បទបញ្ជាសំរាប់ថ្ងៃបោះឆ្នោតបានចែងថា តំណាងគណបក្សនយោបាយនានាត្រូវដាក់បណ្តឹងតវ៉ា ស្តីពីទិដ្ឋភាពណាមួយនៃការបោះឆ្នោត ទៅជូនប្រធានការិយាល័យបោះឆ្នោតដោយផ្ទាល់ ។ មាននីតិវិធីដ៏លំអិតកំណត់ឱ្យប្រធានការិយាល័យបោះឆ្នោតត្រូវផ្អាកការបោះឆ្នោត ដើម្បីស្តាប់ការតវ៉ាជំទាស់ និងចាត់វិធានការ បើសិនជាមានតំរូវការចាំបាច់ដើម្បីដោះស្រាយបញ្ហា ។ បើសិនប្រធានការិយាល័យបោះឆ្នោត ទាត់ចោលបណ្តឹងតវ៉ារបស់អ្នកសង្កេតការណ៍នៃគណបក្សនយោបាយ បទបញ្ជាបានតំរូវឱ្យប្រធាននេះផ្តល់ហេតុផល ធ្វើកំណត់ត្រាពីព្រឹត្តិការណ៍ និងចេញទំរង់មួយ (ទំរង់១២០២) សំរាប់ឱ្យអ្នកតវ៉ាអាចបញ្ជូនបណ្តឹងទៅ គឃប ទៀត ។ បណ្តឹងតវ៉ាដែលបានធ្វើនៅក្រោយពេលចប់ដំណើរការបោះឆ្នោត មិនអាចទទួលដោះស្រាយបានទេ[២១៧] ។ នៅពេលទទួលបណ្តឹងតវ៉ា គឃប ត្រូវសំរេចថាតើត្រូវពិនិត្យផ្ទៀងផ្ទាត់សំភារៈបោះឆ្នោតឡើងវិញឬទេ ដោយយោងតាមភស្តុតាងដែលអ្នកតវ៉ាបានបង្ហាញ ។ បើសិនមានភស្តុតាងមិនគ្រប់គ្រាន់ទេ គឃប អាចទាត់ចោលបណ្តឹងតវ៉ានោះបាន ។

នៅដំណាក់កាលណាមួយនៃដំណើរការបោះឆ្នោត ការតវ៉ាជំទាស់ចំពោះនីតិវិធីនៅក៏រិត គឃប ឬចំពោះលទ្ធផលនៃ

[២១៧] NEC Regulations 8.7.1-8.7.21.7; 8.16.1, 8.16.3

ដំណើរការតវ៉ានៅកំរិត គឃប គឺអាចបញ្ជូនទៅ គខប បាន ។ នៅពេលបានទទួលបណ្តឹងតវ៉ាមានសុពលភាព, គខប ត្រូវៈ ទី១ ប្រឹងប្រែងសំរុះសំរួលថែមទៀត និងទី២ បើសិនការសំរុះសំរួលមិនបានសំរេច ត្រូវធ្វើសវនាការដោះស្រាយ[២១៨] ។ គេអាចប្តឹងឧទ្ធរណ៍ទៅ គជប ដើម្បីតវ៉ាពីសេចក្តីសំរេចរបស់ គខប បាន, ហើយ គជប ត្រូវធ្វើសវនាការដោះស្រាយថែមទៀត ។

មានការកំណត់តារាងពេលដ៏តឹងរ៉ឹងសំរាប់ធ្វើសវនាការ និងបណ្តឹងឧទ្ធរណ៍ ហើយតាមធម្មតាបណ្តឹងតវ៉ាអាចធ្វើបានក្នុងរយៈពេល ២ថ្ងៃ ។ បទបញ្ជាបានចែងថាៈ

> *"ចំពោះពាក្យបណ្តឹងតវ៉ាដែលបានទទួលក្រោយពេលវេលាកំណត់ដូចចែងក្នុងចំណុច... និងពាក្យបណ្តឹងតវ៉ាដែលគ្មានឯកសារ និងភស្តុតាងគ្រប់គ្រាន់ ដែលបានដាក់ទៅ គខប មិនត្រូវបានទទួលដោះស្រាយទេ"*[២១៩] ។

ពាក្យបណ្តឹងដែល គខប បដិសេធ អាចប្តឹងឧទ្ធរណ៍ទៅ គជប ក្នុងរយៈពេលពីរថ្ងៃ ។ គជប ក៏អាចបដិសេធពាក្យបណ្តឹងដែលបានដាក់យឺតពេល ឬមិនមានភស្តុតាងគ្រប់គ្រាន់បានដែរ ។

ចំពោះបណ្តឹងតវ៉ាជាប់ទាក់ទិននឹងដំណើរការបោះឆ្នោតជាក់ស្តែង មានការកំណត់នីតិវិធីលំអិតសំរាប់ធ្វើការចាត់ចែងលើសំភារៈបោះឆ្នោតផ្សេងៗ រួមទាំងសន្លឹកឆ្នោតផង តាំងពីការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដែលមានគេដាក់បណ្តឹងតវ៉ា ។ រឿងនេះបានដោះស្រាយចំណុចបារម្ភមួយពីឆ្នាំ១៩៩៨ ដែលនៅពេលនោះ សន្លឹកឆ្នោតមកពីឃុំដែលមានការតវ៉ា ត្រូវបានយកមកដាក់លាយគ្នាជាមួយសន្លឹកឆ្នោតមកពីកន្លែងផ្សេង ដូច្នេះគេមិនអាចដកវាយកមកត្រួតពិនិត្យតាមក្រោយទៀតបានទេ ។ នីតិវិធីក៏បានកំណត់ដែរថា អ្នកតវ៉ាមានសិទ្ធិមានវត្តមាននៅពេលសន្លឹកឆ្នោតត្រូវបានផ្ទៀងផ្ទាត់ ឬរាប់ឡើងវិញ ។ នៅតាមគ្រប់ដំណាក់កាលនីមួយៗ ការចាត់ចែងលើសំភារៈពិសេសៗ ត្រូវធ្វើយ៉ាងណាដើម្បីធានាថា បើសិនមន្ត្រីបោះឆ្នោតសំរេចត្រូវឆ្លើយតបនឹងការតវ៉ាណាមួយ លទ្ធផលសរុបចូលគ្នាពីកំរិតផ្សេងៗ គឺអាចផ្ទៀងផ្ទាត់ឡើងវិញ ឬក៏សន្លឹកឆ្នោតជាក់ស្តែងក៏អាចរាប់ឡើងវិញបានដែរ ។ បើសិនមន្ត្រី គជប សំរេចថា លទ្ធផលមិនអាចទទួលយកបានទេ ការបោះឆ្នោតឡើងវិញគឺអាចរៀបចំធ្វើបាន ។

នៅក្នុងបទបញ្ជាទាំងអស់ស្តីពីការចាត់ចែងបណ្តឹងតវ៉ា គ្មានការកំណត់ពីមូលដ្ឋានអ្វីសំរាប់ធ្វើសេចក្តីសំរេចអំពីការដាក់អនុវត្តន៍ទោសទណ្ឌ ឬការដាក់វិធានការផ្សេងៗដើម្បីកែតំរូវបញ្ហាវិញ ។ បញ្ហាថាតើភស្តុតាងនិងពត៌មានដែលអ្នកប្តឹងតវ៉ាផ្តល់ឱ្យវា "គ្រប់គ្រាន់" ឬយ៉ាងណា សំរាប់បញ្ជាក់គាំទ្រដល់ការតវ៉ា និងតើត្រូវចាត់វិធានការចាំបាច់អ្វីខ្លះដើម្បីដោះស្រាយបណ្តឹងតវ៉ាមានសុពលភាព (ឧ. ការតវ៉ាទាក់ទិននឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការគណនាលទ្ធផលឡើងវិញ ការរាប់សន្លឹកឆ្នោតឡើងវិញ ឬការបោះឆ្នោតឡើងវិញ) វាស្ថិតក្រោមសិទ្ធិ សំរេចទាំងស្រុងរបស់ពួកមន្ត្រី បើតាមខ្លឹមសារនៃបទបញ្ជា គជប ។

បទបញ្ជាទាំងនេះ បានអនុញ្ញាតឱ្យមានសវនាការ ៣ប្រភេទ គឺមានការវិនិច្ឆ័យដោយសង្ខេបដែលក្នុងនេះសេចក្តីសំរេចធ្វើតែលើបទប្បញ្ញត្តិនៃច្បាប់ មិនមែនលើអង្គហេតុទេ, សវនាការប្រតិបក្សដែលបើកឱ្យភាគីទំនាស់ ជជែកទល់មុខគ្នាអំពីរឿងវិវាទ ដោយត្រូវប្រមូលភស្តុតាងមកបញ្ជាក់ពីអង្គហេតុ, និងសវនាការដេញដោល ដែលក្នុងនេះ ក្រុមប្រឹក្សាជំនុំជំរះមានការទទួលខុសត្រូវផងដែរក្នុងការប្រមែប្រមូលអង្គហេតុផ្សេងៗ និងមានតួនាទី សំខាន់ជាអ្នកតាំងសំនួរដល់សាក្សី ។ ការជ្រើសយកប្រភេទសវនាការណាមួយមកប្រើសំរាប់ករណីជាក់លាក់ណាមួយ គឺជាសិទ្ធិសំរេចទាំងស្រុងរបស់ គជប[២២០] ។

### *៤.៤.២ ការទិតៀនពីនីតិវិធីសំរាប់បណ្តឹងតវ៉ា*

ការទិតៀនពីនីតិវិធីសំរាប់ប្តឹងតវ៉ាចែកចេញជាពីរប្រភេទៈ ការទិតៀនពីខ្លឹមសារនីតិវិធី និងការទិតៀនពីការអនុវត្តន៍ ។

---

[២១៨] Law on Election of Members to the National Assembly Article 111; NEC regulations 8.20.1; 11.1.4.5

[២១៩] NEC regulations 8.22.3

[២២០] NEC Regulations, 11.3.2.

ដូចបានលើករួចហើយក្នុងឯកសារនេះ អ្នកសង្កេតការណ៍ជាច្រើនបានទិតៀនយ៉ាងខ្លាំងពីដំណើរការសំរបសំរួលដែលមានឥទ្ធិពលធ្វើឱ្យញញើតតែតិចតួច ហើយជារឿយៗបានហុចលទ្ធផលមួយដែលអំណោយផលដល់គណបក្សដែលមានអំណាចខ្លាំងជាងគេទោះបីគណបក្សនោះជាអ្នកល្មើសច្បាប់ក៏ដោយ ។ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) បានកត់ សំគាល់ថា គ្មានការរក្សាទុកកំណត់ត្រាអ្វីពីការសំរបសំរួលរបស់ គយប តាមវិធីនេះទេ ដូច្នេះគេគ្មានលទ្ធភាពធ្វើការវាយតំលៃពីភាពស៊ីសង្វាក់គ្នារវាងបែបបទអនុវត្តន៍តាមឃុំនានានោះទេ[២២១] ។ អ្នកនយោបាយ CPP ម្នាក់បានឆ្លើយសំភាសន៍ប្រាប់ក្រុមស្រាវជ្រាវថា CPP មានគោលនយោបាយជំរុញការផ្សះផ្សារលើបណ្តឹងតវ៉ាផ្សេងៗប្រឆាំងនឹង CPP នៅកំរិត គយប ហើយមតិនេះបង្ហាញថាគណបក្សនានាអនុវត្តដំនើរការដោយមានយុទ្ធសាស្ត្រប្រើវា សំរាប់ធ្វើការតថ្លៃ ដើម្បីអាចបានផលចំណេញខាងនយោបាយ[២២២] ។ ការប្រើវិធីសាស្ត្របែបនេះចំពោះការដោះស្រាយបណ្តឹងតវ៉ា បានធ្វើឱ្យខូចខាតដល់សិទ្ធិអំណាច គជប ដើម្បីគ្រប់គ្រងការបោះឆ្នោតឱ្យបានស្មើភាពគ្នាល្អ ហើយធ្វើឱ្យសិទ្ធិអំណាចវាស្ថិតនៅក្នុងដៃគូភាគីនៃទំនាស់ ។

ហួសពីការផ្សះផ្សារនៅកំរិតមូលដ្ឋានទៅ គេគិតថា ដំណើរការប្តឹងតវ៉ាត្រូវអស់ចំណាយច្រើន និងពិបាកពេកសំរាប់ប្រជាពលរដ្ឋមធ្យម ។ CLEC បានរាយការណ៍ពីការអង្កេតរបស់ខ្លួនដែលបង្ហាញថា "ភាពស្មុគស្មាញនៃនិតិវិធីធ្វើបណ្តឹងតវ៉ា និងប្រព័ន្ធរបស់វា អាចនាំឱ្យអ្នកតវ៉ាជាសក្តានុពលបោះបង់ចោលករណីបណ្តឹងរបស់ខ្លួន[២២៣] ។ CLEC បានកត់សំគាល់ថា ជារឿយៗទំរង់១២០២ សំរាប់ប្តឹងតវ៉ា មិនបានប្រើប្រាស់ទេ ឬក៏បំពេញខុស ។ នៅកន្លែងខ្លះ ពួកមន្ត្រីមិនចង់ផ្តល់ទំរង់ឱ្យទេ ។ តំណាង SRP បានគាំទ្រមតិនេះដោយលើកឡើងថា:

> *"ក្នុងពេលរាប់ គេរាប់លឿនណាស់ ។ ក្នុងវិធានមានចែងថា អ្នកអាចតវ៉ាផ្ទាល់មាត់បាន ហើយប្រធានត្រូវបញ្ឈប់ដំណើរការដើម្បីស្តាប់ ហើយបើគេមិនឈប់ អ្នកអាចសរសេរបណ្តឹង និងដាក់ប្តឹងបាន ។ បើខ្ញុំនិយាយថា សុំពន្យឺតបន្តិច ពួកគេនិយាយថា ទេ មានពេលតិចណាស់ ។ បើសិនអ្នកមិនឯកភាពដាក់ពាក្យប្តឹងទៅ ។ ប៉ុន្តែនៅពេលអ្នកសុំទំរង់១២០២ ពួកគេនិយាយថា គ្មានទេ គឺពួកគេមិនព្រមឱ្យ ១២០២ ដល់អ្នក ។ បន្ទាប់មកនៅពេលគេទទួលបណ្តឹងអ្នក ពួកគេនិយាយថា គ្មានភស្តុតាង ឬសាក្សី - ប៉ុន្តែតើអ្នកអាចផ្តល់ភស្តុតាងពីល្បឿនរាប់យ៉ាងដូចម្តេច ។ តើអ្នកត្រូវមានប្រដាប់ថតសំលេង ឬក៏ម៉ាស៊ីនថត? នៅពេលយើងស្នើសុំសាក្សី -អ្នកមិនអាចប្រើភ្នាក់ងារគណបក្សធ្វើសាក្សីបានទេ ហើយអ្នកឯទៀត ខ្លាច CPP"[២២៤] ។*

CLEC បានកត់ត្រាពីរបាយការណ៍មួយចំនួនដែលថា បុគ្គលនានាមិនចង់ប្តឹង ឬធ្វើសាក្សីក្នុងបណ្តឹងទេ ដោយសារខ្លាចអាជ្ញាធរមូលដ្ឋាន ។

SRP ទិតៀនជាខ្លាំងនូវបទប្បញ្ញត្តិថ្មីដែលចែងថា បណ្តឹងតវ៉ាអាចត្រូវទាត់ចោល បើសិនអ្នកតវ៉ាមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ ។ តំណាង SRP ម្នាក់លើកឡើងថា:

> *"ខ្ញុំបានចោទប្រកាន់ជនបរទេសម្នាក់ដោយចំឈ្មោះ (ពីបទចុះបញ្ជីដោយខុសច្បាប់) ប៉ុន្តែពួកគេនិយាយថា ឈ្មោះមិនគ្រប់គ្រាន់ទេ ។ សំឡេងនិយាយក៏ជាភស្តុតាងមិនគ្រប់គ្រាន់ដែរ ។ ពួកគេនិយាយថា អ្នកអាចតវ៉ាបាន បើសិន*

---

[២២១] Community Legal Education Center (CLEC), “The Implementation of the Complaints Resolution Process during the 2003 National Assembly Election,” draft report, 13.

[២២២] CPP Working Group Leader (64), personal interview, Kompong Cham, 14 July 2003.

[២២៣] Community Legal Education Center (CLEC), “The Implementation of the Complaints Resolution Process during the 2003 National Assembly Election,” draft report, 16.

[២២៤] SRP national representative (12), personal interview, Phnom Penh, 7 Aug. 2003.

*ជនបរទេសនោះគ្មានឯកសារចូលសញ្ជាតិស្របច្បាប់ ។ ប៉ុន្តែតើខ្ញុំអាចមានភស្តុតាងនេះយ៉ាងដូចម្តេចបាន? គជប គួររៀបចំធ្វើសវនាការ តំរូវឱ្យជនបរទេសបង្ហាញឯកសារចូលសញ្ជាតិរបស់ខ្លួន ។ បើសិនគេរំពឹងឱ្យខ្ញុំធ្វើការងារនេះ គឺបានន័យថា គេរំពឹងឱ្យខ្ញុំធ្វើការងារប៉ូលីសដែរហើយ"*[២២៥] *។*

ក្នុងរបាយការណ៍របស់ខ្លួន CLEC បានទិតៀនស្រដៀងគ្នានេះដែរ ពីដំណើរការធ្វើបណ្តឹងតវ៉ាក្នុងការបោះឆ្នោតឆ្នាំ២០០៣ ។ CLEC បានចង្អុលបង្ហាញថា វិធានដែលតំរូវឱ្យផ្តល់ភស្តុតាងបញ្ជាក់មិនគ្រាន់តែធ្វើឱ្យគណបក្សនយោបាយនានាជួបការលំបាកប៉ុណ្ណោះទេ ប៉ុន្តែវាសឹងតែបំបាត់ចោលអស់នូវលទ្ធភាពរបស់ប្រជាជនធម្មតាក្នុងការប្តឹងតវ៉ា ។ CLEC បានលើកឡើងថាៈ

*"គេអាចជជែកវែកញែកបានថា ការតវ៉ាប្រឆាំងនឹងការរំលោភច្បាប់បោះឆ្នោត គួរចាត់ទុកថាបំរើផលប្រយោជន៍សាធារណៈ មិនមែនត្រឹមតែរបស់បុគ្គលម្នាក់ឯងនោះទេ ។ រឿងនេះបង្ហាញថា អង្គភាពឯកទេសមួយដែលមានលទ្ធភាព និងសមត្ថភាពធ្វើការងារនេះ គួរជាអ្នកប្រមែប្រមូលភស្តុតាង"*[២២៦] *។*

ក្រោយពេលបោះឆ្នោត បណ្តឹងតវ៉ារាប់រយរបស់គណបក្សនានាត្រូវបាន គខប ទាត់ចោលដោយសំអាងថា ខ្វះភស្តុតាង[២២៧] ។ តំណាង SRP ម្នាក់អះអាងថា ក្នុងករណីមួយចំនួន គជប បានប្រើលក្ខខណ្ឌ "ខ្វះភស្តុតាង" ដើម្បីចៀសវាងការធ្វើសវនាការសាធារណៈក្នុងរឿងអ្វីមួយ ។ គ្មានអ្វីគួរសង្ស័យទេ លក្ខខណ្ឌតំរូវឱ្យដាក់ភស្តុតាងបញ្ជាក់គាំទ្របណ្តឹងតវ៉ាផ្សេងៗត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌច្បាប់ថ្មី ដើម្បីទប់ស្កាត់កុំឱ្យ គជប ត្រូវទទួលបណ្តឹងតវ៉ាច្រើនពេកដែលមិនអាចរកភស្តុតាងបញ្ជាក់តាមអង្គហេតុបាន ។ ប៉ុន្តែបទប្បញ្ញត្តិថ្មីបានផ្តល់សិទ្ធិអំណាចសំរេចធំណាស់ឱ្យ គជប ជាពិសេសដោយសារបទប្បញ្ញត្តិទាំងនេះពុំមានផ្តល់ការណែនាំអំពីវិធាននៃការផ្តល់ភស្តុតាង ឬក៏ការតំរូវពីកំរិតស្តង់ដាផ្សេងៗសំរាប់ភស្តុតាង ។ រឿងនេះតំរូវឱ្យគណបក្សនានាមានទំនុកចិត្តលើ គជប ក្នុងការធ្វើសេចក្តីសំរេចផ្សេងៗដោយមិនប្រកាន់បក្សពួក - ប៉ុន្តែក្នុងបរិយាកាសតឹងតែងខ្លាំងក្រោយពេលបោះឆ្នោត ការតំរូវបែបនេះជាមធ្យោបាយមួយអន់ខ្សោយណាស់សំរាប់គ្រប់គ្រងទំនាស់ ។ CLEC ដែលបានសង្កេតពិនិត្យលើការចាត់ចែងបណ្តឹងតវ៉ាក្នុង ២០ខេត្ត បានកត់សំគាល់ពីការខុសគ្នាយ៉ាងច្រើនក្នុងរបៀបដោះស្រាយបណ្តឹងតវ៉ា និងសេចក្តីសំរេចផ្សេងៗដែលបានធ្វើឡើង ។ CLEC បានកត់សំគាល់ដែរថា ការងារគ្រប់គ្រងបណ្តឹងតវ៉ាធ្វើបានអន់ណាស់, ទិន្នន័យមិនបានរក្សាទុកយ៉ាងទៀងទាត់ល្អទេ គ្មានការរក្សាទុកកំណត់ត្រាពីបណ្តឹងតវ៉ាផ្ទាល់មាត់, ហើយកង្វះលទ្ធភាពខាងកុំព្យូទ័រ បានកាត់បន្ថយជាខ្លាំងនូវលទ្ធភាពតាមដានបណ្តឹងតវ៉ាដែលបានឆ្លងកាត់ដំណើរការនេះ ។ ការងាររបស់ គជប និង គខប មិនអាចផ្ទៀងផ្ទាត់ ឬតាមដានបានដោយស្រួលទេ ធ្វើឱ្យគណបក្សនយោបាយនានាអាចមានការបកស្រាយខុសគ្នាខ្លាំងណាស់ពីសេចក្តីសំរេចផ្សេងៗរបស់ គជប ។

បញ្ហាមួយទៀតគឺ គជប ជារឿយៗត្រូវគេប្តឹងពីទង្វើរបស់ខ្លួន ឬរបស់បុគ្គលិកថ្នាក់ខេត្ត និងឃុំរបស់ខ្លួន ។ គេបានមើលឃើញរឿងនេះថាជាករណីទំនាស់ផលប្រយោជន៍មួយ ចំពោះ គជប ផ្ទាល់ ហើយអ្នកសង្កេតការណ៍ បានកត់សំគាល់ថា ក្នុងករណីបែបនេះជារឿយៗ គជប គឺជាចៅក្រមផង និងជនជាប់ចោទផង ។ CLEC កត់សំគាល់ទៀតថា ដោយសារប្រព័ន្ធសាកសួរដេញ

---

២២៥ SRP national representative (12), personal interview, Phnom Penh, 7 Aug. 2003.

២២៦ CLEC, "The Implementation of the Complaints Resolution Process During the 2003 National Assembly Election," draft report, Phnom Penh, 9 Oct 2003, 18.

២២៧ Yun Samean, "Re-Vote Unlikely as NEC Sheds Complaints," Cambodia Daily, 6 Aug 2003, 13.

ដោលដែល គជប តែងប្រកាន់យក ជារឿយៗ គជប គឺជាតួអង្គតែមួយនៅក្នុងសវនាការដែលមានអ្នកច្បាប់មកតំណាងឱ្យ[២២៨] ។

### *៤.៤.៣ បណ្ដឹងតវ៉ាដែលបានដាក់*

បណ្ដឹងតវ៉ាចំបងៗដែលបានដាក់ប្ដឹងនៅតាមកំរិតផ្សេងៗនៃ គជប ជាប់ទាក់ទិននឹងបញ្ហាទំនាស់ធំៗដូចបានរៀបរាប់នៅខាងដើមជំពូកនេះ ដូចជា បញ្ហាភាពស្របច្បាប់នៃការចុះបញ្ជីជនមានដើមកំណើតជាវៀតណាម, ការជំទាស់ថា ការរៀបចំខាងរដ្ឋបាលសំរាប់ការបោះឆ្នោត មានលក្ខណៈច្របូកច្របល់ និងធ្វើឱ្យបាត់បង់សិទ្ធិរបស់អ្នកបោះឆ្នោតច្រើននាក់ណាស់, និងការចោទប្រកាន់ក្នុងទូទាំងរយៈពេលឃោសនាបោះឆ្នោតពីការបំភិតបំភ័យ ការទិញសន្លឹកឆ្នោត, ការឆានៅខានសកម្មភាពបោះឆ្នោត, ការដកហូតប័ណ្ណបោះឆ្នោត, និងការបង្ខំឱ្យចូលរួមពិធីស្បថស្បែផ្សេងៗ ។ ការតវ៉ាពីសកម្មភាពទាំងនេះ បានលើកមកពិភាក្សារួចហើយ ។ ក្នុងករណីទាំងនេះ គជប ពឹងផ្អែកយ៉ាងខ្លាំងលើដំណើរការសំរុះសំរួល ជាជាងការដាក់ទណ្ឌកម្មដែលនាំឱ្យមានការទិតៀនថា គជប ខ្វះសិទ្ធិអំណាចដើម្បីត្រួតត្រាលើដំណើរការបោះឆ្នោត ។

ក្រោយការរាប់សន្លឹកឆ្នោត គឺមានបណ្ដឹងតវ៉ាជាច្រើនទៀត ។ SRP ផ្ដោតជាពិសេសលើការចោទប្រកាន់មន្ត្រីការិយាល័យបោះឆ្នោតថា មិនបានផ្ដល់បញ្ជីបូកសរុប (ទំរង់១១០៥) ដែលចុះពីលទ្ធផលបោះឆ្នោតនៅកំរិតឃុំ ទៅឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ [២២៩] ។SRP បានតវ៉ានៅល្ងាចថ្ងៃបោះឆ្នោតថា:

*"ដំណើរការរាប់បានចប់នៅពេលរសៀលនោះ ប៉ុន្តែ គឃប មួយចំនួនមិនព្រមចេញឱ្យទទួវបញ្ជីសរុប ១១០៥ ដែលមានចុះលំអិតពីចំនួនសន្លឹកឆ្នោតដែលគណបក្សនីមួយៗទទួលបាន ។ ការខកខានមិនបានចេញបញ្ជីសរុបនេះភ្លាមៗ គឺជាការរំលោភលើវិធាន និងបទបញ្ជារបស់ គជប ហើយវាបានផ្ដល់ឱកាសយ៉ាងច្រើនឱ្យ CPP សំរាប់កែតំរូវតួលេខលើបញ្ជី ដើម្បីជួយគាំទ្រដល់លទ្ធផលថ្មៃប្រឌិតក្លែងក្លាយរបស់ខ្លួន"*[២៣០] ។

ការតវ៉ានេះត្រូវបានបញ្ជាក់ឡើងវិញជាសាធារណៈ ៤ថ្ងៃក្រោយមក ក្នុងការអំពាវនាវមួយរបស់ SRP ដល់អ្នកសង្កេតការណ៍អន្តរជាតិ កុំឱ្យគេទទួលស្គាល់លទ្ធផលបោះឆ្នោត:

*"វិធាន និងបទបញ្ជា គជប បានចែងថា បញ្ជីសរុបគឺ ទំរង់១១០៥ ត្រូវប្រគល់ទៅឱ្យភ្នាក់ងាររបស់គណបក្សនយោបាយភ្លាមក្រោយពីបានបញ្ចប់ដំណើរការរាប់ ។ រឿងនេះមិនបានអនុវត្តទេនៅតាមខេត្ត និងការិយាល័យបោះឆ្នោតជាច្រើនដែលនៅទីនោះ បញ្ជីសរុបគេឱ្យនៅពេលយប់ជ្រៅណាស់ទៅហើយនាថ្ងៃរាប់សន្លឹកឆ្នោត ហើយមានបញ្ជីខ្លះនៅមិនទាន់ឱ្យទេ រហូតមកដល់ថ្ងៃនេះ ។ បច្ចុប្បន្នវាហួសពេលនឹងធ្វើអ្វីបានហើយក្នុងរឿងនេះ ។ ដូច្នេះវាមានលទ្ធភាពច្រើនណាស់ដែលសន្លឹកឆ្នោតអាចត្រូវបានគេប៉ះពាល់លួកលាន់ក្នុងរយៈពេលនោះ គឺដូចគ្នានឹងបញ្ជីសរុបដែលប្រគល់ឱ្យយឺតយ៉ាវ និងដែលមានចុះតួលេខកែសំរួលដែរ"*[២៣១] ។

ក្រោយមក គជប បានទាត់ចោលបណ្ដឹងតវ៉ាផ្អែកលើមូលដ្ឋាននេះ ដោយវែកញែកថា បទបញ្ជាមិនបានចែងទេថា ទំរង់ ១១០៥ ត្រូវប្រគល់ភ្លាមទៅឱ្យភ្នាក់ងាររបស់គណបក្សនយោបាយ ។ ប៉ុន្តែបញ្ហានេះបានបង្កការសង្ស័យច្រើនណាស់ នៅពេលមានការដាក់ពង្រាយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតក្នុងទូទាំងប្រទេស ហើយពួកគេបានបញ្ជូន

---

[២២៨] CLEC, “he Implementation of the Complaints Resolution Process During the 2003 National Assembly Election,” draft report, Phnom Penh, 9 Oct 2003, 19.

[២២៩] NEC Regulations, 8.18.1

[២៣០] Sam Rainsy Party, “SRP Denounces the CPP’s Election Results,” press statement, Phnom Penh, 28 July 2003.

[២៣១] Sam Rainsy Party, “A Plea from the Sam Rainsy Party to International Observers,” press statement, Phnom Penh, 31 July 2003.

លទ្ធផលបោះឆ្នោតដែលពួកគេបានកត់ត្រាខ្លួនឯងតាមអាយកូម ទៅឱ្យទីចាត់ការនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ នៅកំពង់ចាម ក្រុមស្រាវជ្រាវពិនិត្យឃើញ តំណាង COMFREL និង SRP បានរកឃើញការខុសគ្នាគួរកត់សំគាល់រវាងរបាយការណ៍លទ្ធផល ដែលតំណាងរបស់ពួកគេនៅតាមការិយាល័យរាប់សន្លឹកឆ្នោតតាមឃុំបានបញ្ជូនមកឱ្យ និងរបាយការណ៍របស់ គខប នៅពេល សន្លឹកឆ្នោត និងទំរង់ បានមកដល់ទីរួមខេត្តកំពង់ចាម ។ ថ្វីបើអ្នកសង្កេតការណ៍ខាង COMFREL និយាយថា លេខខុសគ្នាអាច ដោយសារកំហុសក្នុងការកត់ត្រាតួលេខ និងការពិបាកចាប់សំលេងបានច្បាស់តាមអាយកូមក្តី ប៉ុន្តែអ្នកសង្កេតការណ៍ SRP ម្នាក់ ដែលយើងទៅសាកសួរ គាត់មើលឃើញរឿងលេខខុសគ្នានេះជាភស្តុតាងយ៉ាងច្បាស់ថា តួលេខបោះឆ្នោតត្រូវបានកែសំរួល ហើយ[២៣២] ។ ការចែកចាយទំរង់១១០៥ យឺតយ៉ាវនាំឱ្យមានចំណាប់អារម្មណ៍ថា តួលេខនានាត្រូវគេ "ស្លូ" វាហើយ ។

ក្នុងការដាក់បណ្តឹងតវ៉ាទៅថ្នាក់ជាតិ SRP បានផ្តោតលើ ៣តំបន់គឺ ប៉ោយប៉ែត កំពង់ធំ និងស្វាយរៀង ។ ការផ្តោតនេះ មានហេតុផលជាយុទសាស្ត្រៈ SRP បានកត់សំគាល់ជាសាធារណៈថា នៅតំបន់ទាំងនេះ SRP ទទួលសន្លឹកឆ្នោតបានជិតគ្រប់មួយ អាសនៈថែមទៀត ។ នៅបន្ទាយមានជ័យ (ប៉ោយប៉ែតស្ថិតក្នុងខេត្តនេះ) SRP ត្រូវការ ១.៨៩៨សន្លឹកឆ្នោតទៀត ដើម្បីទទួល បានអាសនៈបន្ថែមមួយ ហើយបានអះអាងថា អាចរកបានតាមតំរូវការយ៉ាងងាយបើសិនអ្នកបោះឆ្នោត ២០.០០០នាក់មិនបាន ជួបឧបសគ្គធ្វើឱ្យមិនអាចបោះឆ្នោតនៅប៉ោយប៉ែតកើត ដោយសារការផ្លាស់ប្តូរកន្លែងបោះឆ្នោតដោយមិនដឹងមុន ។ ដូចគ្នាដែរ នៅកំពង់ធំ SRP ត្រូវការតែ ៣៧៩សន្លឹកឆ្នោត ដើម្បីទទួលបានអាសនៈមួយទៀត ហើយនៅស្វាយរៀង SRP ត្រូវការថែមតែ ១៤៦សន្លឹកឆ្នោតប៉ុណ្ណោះ[២៣៣] ។ ក្នុងករណីនេះ សន្លឹកឆ្នោតបន្ថែមនឹងធ្វើឱ្យ SRP ដណ្តើមបានអាសនៈមួយពី CPP ។ រឿងនេះ វាត្រូវផ្លាស់ប្តូរលទ្ធផលបោះឆ្នោតសរុបឱ្យទៅជា ៧០អាសនៈសំរាប់ CPP, ២៦អាសនៈសំរាប់ FUNCINPEC, និង ២៧អាសនៈ សំរាប់ SRP គឺធ្វើឱ្យ SRP ក្លាយគណបក្សធំលំដាប់ទី២ក្នុងសភា ដោយគ្មានប៉ះពាល់អ្វីដល់ចំនួនអាសនៈរបស់ FUNCINPEC ។

មូលដ្ឋាននៃការទាមទាររបស់ SRP ឱ្យរាប់សន្លឹកឆ្នោតឡើងវិញនៅស្វាយរៀង និងកំពង់ធំ គឺតួលេខខុសគ្នាក្នុងបញ្ជីសរុប នានាដែលសំរាប់កត់លទ្ធផល និងរវាងតួលេខលទ្ធផលរបស់ គជប និង COMFREL ។ ថ្វីបើចំនួនខុសគ្នាក្នុងករណីនីមួយៗវាតូច ប៉ុន្តែ SRP វែកញែកថា វាបង្ហាញពីកង្វះភាពត្រឹមត្រូវដែលអាចធ្វើឱ្យ SRP ខាតសន្លឹកឆ្នោតមួយចំនួនតូចដែលគេត្រូវការ ដើម្បី បានអាសនៈបន្ថែម ។ ដូច្នេះ SRP ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញក្នុងខេត្តទាំងនេះ ។ ប៉ុន្តែ គជប បានសំរេចធ្វើតែ ការត្រួតពិនិត្យឡើងវិញនូវទំរង់ចុះលទ្ធផលផ្សេងៗទទួលមកពីឃុំនានាដែលមានចុះក្នុងបណ្តឹងរបស់ SRP ។ នៅថ្ងៃទី៦ សីហា គជប បានចេញសេចក្តីប្រកាសពត៌មានមួយថាៈ

> *"ក្នុងពេលសំរុះសំរួលនៅទីស្នាក់ការ គជប កាលពីថ្ងៃទី៥ សីហា ២០០៣ ម្សិលមិញជាមួយ SRP, គជប បាន ទទួលស្គាល់ថា មានកំហុសតូចតាចមួយចំនួនក្នុងការចំលងឡើងវិញនូវលទ្ធផលក្នុង ១៤ឃុំ នៅខេត្តស្វាយរៀង, ប៉ុន្តែអាចរកបានការព្រមព្រៀងគ្នាមួយជាមួយ SRP*[២៣៤] ។

ចំណុចគួរឱ្យកត់សំគាល់គឺ ក្រោយមក SRP បានបដិសេធថា ពុំមានការព្រមព្រៀងគ្នាណាមួយទេ ហើយតវ៉ាថា គជប មានចំលើយតបមិនគ្រប់គ្រាន់ទេចំពោះបណ្តឹងរបស់ខ្លួន ហើយរឿងនេះឆ្លុះបញ្ចាំងពីកង្វះការព្រមព្រៀងគ្នាអំពីមធ្យោបាយដ៏ សមស្របនានាសំរាប់គ្រប់គ្រងទំនាស់ ដែលនាំឱ្យពុំមានការមូលមតិថា តើទំនាស់ត្រូវបានដោះស្រាយហើយឬនៅ ។ ឧទាហរណ៍ ក្នុងសេចក្តីប្រកាសមួយចុះថ្ងៃ ៧ សីហា SRP បានអះអាងថាៈ

---

[២៣២] Various personal interviews, Kompong Cham, 29 July 2003.

[២៣៣] Sam Rainsy Party, “A Plea from the Sam Rainsy Party to International Observers,” press statement, Phnom Penh, 31 July 2003.

[២៣៤] National Election Committee, “Agreement between the NEC and the SRP on Svay Rieng and Kompong Thom,” press release, 6 Aug 2003.

*"មិនដែលមានកិច្ចព្រមព្រៀងណាមួយរវាង SRP និង គជប ក្នុងបញ្ហានៅស្វាយរៀង និងកំពង់ធំទេ ។ ការអះអាងរបស់ គជប ក្នុងសេចក្តីប្រកាសពតិមានរបស់ខ្លួនចុះថ្ងៃទី៦ សីហា ២០០៣ ជារឿងមួយគួរសោកស្តាយបំផុត និងនាំឱ្យមានការយល់ខុសទាំងស្រុង"*[២៣៥] ។

SRP អះអាងថា គជប បានធ្វើសំណើមួយដើម្បី "កែច្នៃតួលេខឱ្យវាស៊ីគ្នាទាំងអស់លើងតែតំណាង SRP បានបដិសេធសំណើនេះ"[២៣៦] ។ បន្ទាប់ពីមានព្រឹត្តិការណ៍នេះ SRP និង FUNCINPEC បានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយដែលក្នុងនោះគេអះអាងថា "អ្នកបោះឆ្នោតរាប់សែននាក់... បានបោះឆ្នោតស្របតាមមនសិការរបស់ខ្លួននៅថ្ងៃ ២៧ កក្កដា ២០០៣ ប៉ុន្តែសន្លឹកឆ្នោត (របស់ពួកគេ) ត្រូវបានលួចយក ឬបន្លែបន្លំ ពីព្រោះ គជប មិនបានបំពេញភារកិច្ចរបស់ខ្លួន"[២៣៧] ។ ក្រោយមក SRP បានសរសេរក្នុងលិខិតមួយផ្ញើថ្វាយព្រះមហាក្សត្រថា "CPP គួរបង្ហាញពីភាពស្មោះត្រង់របស់ខ្លួនដោយស្នើឱ្យ គជប ធ្វើការរាប់សន្លឹកឆ្នោតឡើងវិញសំរាប់២ករណី ដើម្បីបំបាត់ការសង្ស័យទាំងអស់ ដែលមិនមែនគ្មានមូលដ្ឋានដូចដែលអ្នកសង្កេតការណ៍អន្តរជាតិជាច្រើនបានធ្វើជាសាក្សីស្រាប់នោះទេ"[២៣៨] ។

SRP បានស្នើឱ្យមានការបោះឆ្នោតឡើងវិញនៅប៉ោយប៉ែត ដោយវែកញែកថា អ្នកបានបោះឆ្នោតដ៏តិចត្រឹម ៤៥% បង្ហាញថា អ្នកបោះឆ្នោតជាច្រើនបានបាត់បង់សិទ្ធិដោយសារការប្តូរការិយាល័យបោះឆ្នោតទៅកន្លែងថ្មី ។ គជប បានទាត់ចោលបណ្តឹងនេះ នៅថ្ងៃ ៥ សីហា ដោយសំអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ ក្រោយពីការស៊ើបអង្កេត និងបានលើកឡើងថាបានផ្តល់ពតិមានទៅឱ្យអ្នកបោះឆ្នោតហើយអំពីការផ្លាស់ប្តូរកន្លែង ហើយអ្នកបានបោះឆ្នោតមានចំនួនតិច មកពីប្រជាជននៅប៉ោយប៉ែតមានលក្ខណៈចល័តក៏រិតខ្ពស់ ក្នុងនេះមានច្រើននាក់ឆ្លងចូលទៅធ្វើការនៅថៃរៀងរាល់ថ្ងៃ ។ គជប លើកឡើងទៀតថា SRP បានផ្តល់សាក្សីតែ ២៧នាក់ ដែលអះអាងថាខ្លួនមិនអាចបោះឆ្នោតបានដោយសារការប្តូរកន្លែងការិយាល័យបោះឆ្នោត[២៣៩] ។ SRP និង FUNCINPEC ក្រោយមកបានអះអាងថា ពួកគេបដិសេធលទ្ធផលបោះឆ្នោតៈ

*"ក្នុងនាមអ្នកបោះឆ្នោតបានចុះបញ្ជីជាង ១លាននាក់ ដែល គជប បានប្រើគ្រប់ល្បិចកល - ដូចជា អនុញ្ញាតឱ្យមានការដកហូតប័ណ្ណបោះឆ្នោត, ការផ្លាស់ប្តូរកន្លែងការិយាល័យបោះឆ្នោតដោយគ្មានជូនដំណឹងឱ្យបានគ្រប់គ្រាន់, បញ្ជីអ្នកបោះឆ្នោតដែលមានកំហុសពាសពេញ ធ្វើឱ្យអ្នកបោះឆ្នោតច្រើននាក់ណាស់មិនអាចរកឈ្មោះខ្លួនឃើញ, និងការលុបឈ្មោះដោយមិនសមស្របចេញពីបញ្ជីអ្នកបោះឆ្នោត - ដើម្បីរារាំងពួកគេមិនឱ្យបោះឆ្នោតបាននៅថ្ងៃទី២៧ កក្កដា ២០០៣ ដោយផ្ទុយពីសិទ្ធិ និងបំណងរបស់ពួកគេ"*[២៤០] ។

គណបក្សតូចៗក៏ហាក់ដូចមិនពេញចិត្តនឹងដំណើរការធ្វើបណ្តឹងតវ៉ានេះដែរ ។ សារពតិមាន Cambodia Daily បានរាយការណ៍ក្នុងរយៈពេលឃោសនាបោះឆ្នោតថាៈ

*"គណបក្សភាគច្រើន ក្រៅពី CPP បានលើកពីការមិនសប្បាយចិត្តរបស់ខ្លួន (ស្តីពីការដោះស្រាយបណ្តឹងតវ៉ា) ។*

---

២៣៥ Sam Rainsy Party, "NEC Pressed to Release Misleading Press Release," press release, Phnom Penh, 7 Aug 2003.

២៣៦ Sam Rainsy Party, "NEC Pressed to Release Misleading Press Release," press release Phnom Penh, 7 Aug 2003.

២៣៧ Alliance of Democrats (FUNCINPEC Party and Sam Rainsy Party), "Joint Statement to Reject the Results of the Election Released by the National Election Committee (NEC)," press release, Phnom Penh, 8 Aug. 2003.

២៣៨ Sam Rainsy, Letter to His Majesty the King of Cambodia, Phnom Penh, 15 Sept 2003.

២៣៩ National Election Committee, "NEC Rejects a Complaint from Sam Rainsy Party Concerning Poipet Commune," press release, Phnom Penh, 5 Aug 2003.

២៤០ Alliance of Democrats (FUNCINPEC Party and Sam Rainsy Party), "Joint Statement to Reject the Results of the Election Released by the National Assembly (NEC)," by the National Assembly, Phnom Penh, 8 Aug. 2003.

*លោក ហង្ស សិរីទ្ធ អគ្គលេខាធិការរងនៃគណបក្ស ហង្ស ដារ៉ា ចលនាប្រជាធិបតេយ្យ និយាយថា "ក្នុង ១០បណ្តឹងរបស់យើងមាន ២បណ្តឹងបានដោះស្រាយ ។ គ្មានប្រយោជន៍អ្វីនឹងតវ៉ាទៅ គឃប គខប និង គជប ទេ ពីព្រោះពួកគេជាអាយ៉ងCPP*[២៤១] *។*

មតិលើកឡើងខាងលើ បានគូសបញ្ជាក់ពីសារៈសំខាន់នៃលទ្ធផលក្នុងការងារដោះស្រាយបណ្តឹងតវ៉ាចំពោះមុខមាត់ គជប ក្នុងចំណោមគណបក្សនយោបាយនានា ។

សរុបមក បទពិសោធន៍ក្នុងដំណើរការដោះស្រាយបណ្តឹងតវ៉ានៅឆ្នាំ២០០៣ វាមានចំណុចខុសគ្នាធំៗមួយចំនួនជាមួយឆ្នាំ១៩៩៨ ។ ថ្វីបើជារឿយៗការអនុវត្តន៍មានលក្ខណៈទន់ខ្សោយក្តី ប៉ុន្តែនៅឆ្នាំ២០០៣ មានសេចក្តីចែងជាលាយលក្ខណ៍អក្សរពីដំណើរការបណ្តឹងតវ៉ា ហើយនេះជាការរីកចំរើនមួយបើធៀបនឹងឆ្នាំ១៩៩៨ ។ ម្យ៉ាងទៀតគណបក្សនានាត្រៀមខ្លួនធ្វើសហប្រតិបត្តិការតាមលក្ខខណ្ឌនៃដំណើរការដោយទៅចូលរួមការប្រជុំសំរុះសំរួល, បំពេញទំរង់ផ្សេងៗ និងផ្តល់ភស្តុតាងតាមការតំរូវ ។ វិធីសាស្រ្តជាយុទ្ធសាស្រ្តនៃ SRP ក្នុងឆ្នាំ២០០៣ គឺជាការរីកចំរើនមួយ (ធៀបនឹង "វិធីសាស្រ្តទំលាក់គ្រាប់បែក" ដែលគណបក្សចាញ់ឆ្នោតបានអនុវត្តនៅឆ្នាំ១៩៩៨) ហើយវានាំឱ្យមានដំណើរការប្តឹងតវ៉ាមួយដែលអាចគ្រប់គ្រងបាន ពីព្រោះជាប់ទាក់ទិនតែនឹងតំបន់សំខាន់ខ្លះៗក្នុងប្រទេស ។

បញ្ហាច្រើនណាស់នៅសេសសល់នៅឡើយ ។ ជំហរអាងសិទ្ធិអំណាចជាផ្លូវការ និងកង្វះកិច្ចសហប្រតិបត្តិការក្នុងការចេញទំរង់ផ្សេងៗ និងការជួយដល់អ្នកតវ៉ាក្នុងការដាក់ពាក្យបណ្តឹងនៅបន្តកើតមាន ។ ការចងក្រងនីតិវិធីឱ្យកាន់តែលំអិតវាគ្រាន់តែបានបង្កើតដំណើរការមួយកាន់តែស្មុគស្មាញសំរាប់បុគ្គលអ្នកប្តឹងតវ៉ា ហើយវានៅតែទុកឱ្យពួកមន្ត្រីនូវសិទ្ធិសំរេចយ៉ាងទូលាយ, ទុកឱ្យមានការចាត់ចែងខុសគ្នាយ៉ាងច្រើនលើករណីផ្សេងៗ និងទុកឱ្យមានការគ្រប់គ្រងទិន្នន័យ និងការរក្សាទុកកំណត់ត្រាយ៉ាងអន់ខ្សោយ ។ នីតិវិធីក៏បានដាក់ឱ្យ គជប ស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់មួយ ព្រោះក្នុងករណីមួយចំនួន ត្រូវដើរតួជាចៅក្រមផង និងជាអ្នកជាប់ចោទផង ហើយស្ថានភាពនេះមិនបានលើកកំពស់ទំនុកចិត្តចំពោះឆន្ទៈហ៊ានទទួលខុសត្រូវរបស់ គជប ទេ ។ ការបដិសេធរបស់ គជប ក្នុងការរាប់សន្លឹកឆ្នោតឡើងវិញក្នុងខេត្តមួយចំនួនដែលចំណាត់ថ្នាក់ទី២ និងទី៣ ក្នុងលទ្ធផលបោះឆ្នោតសរុប វាជាប់ទាក់ទិននឹងចំនួនសន្លឹកឆ្នោតលើសខ្វះគ្នាយ៉ាងតិចតួច គឺវារំលោភលើរបៀបរបបដែលគេតែងអនុវត្តជាធម្មតាក្នុងប្រទេសភាគច្រើន ។

ដូចនៅឆ្នាំ១៩៩៨ ដែរ ការដោះស្រាយបណ្តឹងតវ៉ា គឺជាចំណែកមួយដ៏សំខាន់បំផុតនៃដំណើរការបោះឆ្នោត, ហើយដូចកាលនោះដែរ មានភស្តុតាងបង្ហាញថា កេរ្តិ៍ឈ្មោះរបស់ គជប ធ្លាក់ចុះយ៉ាងលឿនក្នុងក្រសែភ្នែករបស់ពួកអ្នកប្តឹងតវ៉ា ។ ចំណែកមួយនេះនៃដំណើរការបោះឆ្នោត គឺនៅអន់ថយគួរឱ្យកត់សំគាល់ ទាំងក្នុងការបង្កើតស្ថាប័ន ដែលមានសិទ្ធិអំណាចនានា, ក្របខ័ណ្ឌច្បាប់ដែលលំអិត និងអាចប្រើការបាន, ប្រព័ន្ធគ្រប់គ្រងដ៏សក្តិសិទ្ធិនានា, និងបរិយាកាសមួយដែលមានកិច្ចសហប្រតិបត្តិការ និងសុឆន្ទៈពីសំណាក់តួអង្គខាងនយោបាយទាំងអស់ ។

[២៤១] Porter Barron and Thet Sambath, "NEC to Begin Hearing Party Complaints," Cambodia Daily 15 July 2003, 13.

## ជំពូកទី ៥

# ការកសាងយន្តការគ្រប់គ្រងទំនាស់ក្នុងយន្តការបោះឆ្នោតនៅកម្ពុជាពីឆ្នាំ១៩៩៨ ដល់ ២០០៣

## ៥.១ ផលប៉ះពាល់នៃដំណើរការផ្លាស់ប្តូរ

### *៥.១.១ លទ្ធផលនៃការបោះឆ្នោត*

តួអង្គអ្នកនយោបាយភាគច្រើនដែលយើងបានជួបទាក់ទងសំរាប់ការសិក្សានេះ បានឯកភាពថា ដំណើរការបោះឆ្នោតឆ្នាំ២០០៣ មានលក្ខណៈល្អច្រើនណាស់ជាងនៅឆ្នាំ១៩៩៨ ។ ក្នុងរយៈពេលឃោសនាបោះឆ្នោត លទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គឺឃើញមានច្រើនជាងនៅឆ្នាំ១៩៩៨ ឆ្ងាយណាស់, ទំនាស់ពីដំបូងៗមួយចំនួនក៏អាចដោះស្រាយបានយ៉ាងលឿន, ហើយគណបក្សនានាក៏មានសេរីភាពច្រើនណាស់ដើម្បីធ្វើការឃោសនាដោយគ្មានការភ័យខ្លាចក្នុងទូទាំងប្រទេស ។ បណ្តឹងតវ៉ានានាដែលផុសឡើង មិនសូវមានជាប់ទាក់ទងនឹងការរើសអើង ឬការបំភិតបំភ័យប្រឆាំងនឹងគណបក្សនយោបាយទេ, ប៉ុន្តែមានជាប់ទាក់ទងច្រើននឹងការរើសអើង ឬការបំភិតបំភ័យដែលអ្នកបោះឆ្នោត ដូចជា ទំនាស់ស្តីពីប្រធានភូមិ និងទំនាស់ស្តីពីការចុះបញ្ជីជាដើម ។ ក្រោយពីការបោះឆ្នោត គណបក្សនានាអះអាងថា មានការរើសអើងប្រឆាំងនឹងពួកខ្លួនក្នុងដំណើរការប្តឹងតវ៉ា ហើយរឿងនេះគឺជាមូលដ្ឋាននៃការបដិសេធរបស់សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ (សម្ព័ន្ធភាពរវាង SRP និង FUNCINPEC ដែលបង្កើតឡើងនៅក្រោយពេលបោះឆ្នោត) ក្នុងការចូលរួមនៅក្នុងរដ្ឋាភិបាល ។

ដូចនៅឆ្នាំ១៩៩៨ ដែរ មានការតវ៉ាជាច្រើនអំពីភាពទន់ខ្សោយរបស់ គជប ចំពោះតួអង្គផ្សេងៗទៀត ដូចជា ប្រធានភូមិ ក្រសួងមហាផ្ទៃ ក្រសួងពត៌មាន ប្រព័ន្ធផ្សព្វផ្សាយ... ។ ខុសពីឆ្នាំ១៩៩៨ គេឃើញមានបណ្តឹងតវ៉ាតិចណាស់ពីការលំអៀងខាងនយោបាយរបស់ គជប នៅកំរិតជាតិ ប៉ុន្តែនៅកំរិតមូលដ្ឋានវិញវានៅតែមានយ៉ាងច្រើន ។

### *៥.១.២ ក្របខ័ណ្ឌច្បាប់*

ក្របខ័ណ្ឌច្បាប់ថ្មីមានចែងលំអិតច្រើនជាងមុនសំរាប់ណែនាំដល់ការរៀបចំការបោះឆ្នោតដោយ គជប ព្រមទាំងមានអមដោយក្រមសីលធម៌ ដែលបានចែងយ៉ាងជាក់លាក់គួរសមពីគោលការណ៍ប្រជាធិបតេយ្យដែលជាមូលដ្ឋានគ្រឹះនៃរបៀបរៀបចំសំរាប់ការបោះឆ្នោតផ្សេងៗ ។ ដូច្នេះលទ្ធភាពធ្វើការបកស្រាយខុសគ្នាស្រឡះពីរបៀបរបបបោះឆ្នោតដ៏សមស្រប គឺត្រូវបានកាត់បន្ថយមួយកំរិត ហើយវាបានជួយដល់ការងារគ្រប់គ្រងទំនាស់ ។ ប៉ុន្តែនៅមានកំហិតមួយចំនួន ជាពិសេសទាក់ទិននឹងដំណើរការប្តឹងតវ៉ា ដែលគេនៅតែមើលឃើញថា មានចំណុចខ្វះខាតជាមូលដ្ឋាន ដើម្បីធ្វើឱ្យគ្រប់គណបក្សសុខចិត្តទទួលយកលទ្ធផលបោះឆ្នោត និងពង្រឹងសិទ្ធិអំណាចរបស់ គជប ក្នុងការប្រកាសលទ្ធផល នៅពេលដែលមានការតថ្លៃគ្នាយ៉ាងខ្លាំងអំពីសមាសភាពនៃរដ្ឋាភិបាលថ្មី ។ ម្យ៉ាងទៀត គួរធ្វើការសើរើពិនិត្យថែមទៀតនូវច្បាប់ និងបទបញ្ញត្តិផ្សេងៗ ទាក់ទិននឹងដំណើរការប្តឹងតវ៉ា ដោយផ្តោតជាពិសេសលើសេចក្តីណែនាំពីការរក្សាកំណត់ត្រាយុទ្ធសាស្រ្តសំរបសំរួលផ្សេងៗ និងការថ្លឹងថ្លែងលើភស្តុតាង ។

### *៥.១.៣ ផលប៉ះពាល់នៃកំណែទំរង់ គជប*

ពីឆ្នាំ១៩៩៨ ដល់ ២០០៣ គជប បានលូតលាស់ក្លាយជាស្ថាប័នមួយយ៉ាងច្បាស់ ។ គជប មានទំនាក់ទំនងការងារជាមួយគណបក្សនយោបាយធំៗ បានល្អជាងមុនច្រើនណាស់នៅឆ្នាំ២០០៣នេះ បើធៀបនឹងឆ្នាំ១៩៩៨ ។ ការប្រឹងប្រែងរបស់ គជប ផ្ទាល់ ដើម្បីរៀបចំការប្រជុំយ៉ាងទៀងទាត់ ចូលរួមក្នុងវេទិកានានារបស់សង្គមស៊ីវិល និងផ្តល់ពត៌មានកាន់តែប្រសើរ, គឺជាកត្តាដែលរួមចំណែកបង្កបរិយាកាសប្រសើរឡើងនេះ ។ ប៉ុន្តែទំនុកចិត្តលើ គជប ត្រូវបានកាត់បន្ថយដោយសារវិធីជ្រើសរើសដែលធ្វើតាមរយៈក្រសួងពត៌មានត្រួតត្រាដោយ FUNCINPEC និង CPP ។ ម្យ៉ាងទៀត ការគ្រប់គ្រងទំនាស់អនុវត្តដោយ គជប ក្នុងរយៈពេលបោះឆ្នោត បានជួបឧបសគ្គដោយសារការបន្តពឹងផ្អែកលើអាជ្ញាធរខាងក្រៅដែលគណបក្សជំទាស់មិនទុកចិត្ត ជាខ្លាំង គឺមានក្រសួងមហាផ្ទៃ និងក្រសួងពត៌មាន ។ ក្រសួងទាំងពីរត្រួតត្រាលើរឿងសន្តិសុខ និងពត៌មាន ដូច្នេះគឺជាការសំខាន់ណាស់សំរាប់ជោគជ័យនៃការបោះឆ្នោត ។ ទំនាក់ទំនងការងាររបស់ គជប ជាមួយក្រសួងមហាផ្ទៃ ហាក់ដូចជាមានដំណើរការល្អនៅថ្នាក់មជ្ឈិម (ឧ. ការចេញសេចក្តីណែនាំ) ប៉ុន្តែទន់ខ្សោយនៅខាងក្រៅ (ឧ. ការដាក់កំហិតលើសកម្មភាពប្រធានភូមិ) ។ ទំនាក់ទំនងរបស់ គជប ជាមួយក្រសួងពត៌មាន, TVK, និងអ្នកគ្រប់គ្រងកម្មវិធីពត៌មានសមធម៌របស់ UNDP, ហាក់ដូចមានបញ្ហាចោទមានការយល់ខុសច្រើនណាស់ពីគោលការណ៍ និងមានការមិនច្បាស់លាស់ពីដែនសមត្ថកិច្ច ។ ម្យ៉ាងទៀត នៅតាមក្រសួងនានាត្រូវធ្វើការងារកសាងស្ថាប័ន ជាពិសេសការកសាងកេរ្តិ៍ឈ្មោះជាអ្នកអព្យាក្រឹត្យ ដូចដែល គជប បានធ្វើហើយ ដើម្បីធានាឱ្យមានដំណើរការបោះឆ្នោតដ៏រលូនល្អក្នុងពេលអនាគត ។

ដែនសមត្ថកិច្ចមានកំរិតរបស់ គជប ធ្វើឱ្យ គជប ប្រកាន់យកវិធីសាស្ត្រប្រយ័ត្នប្រយែងមួយចំពោះការរំលោភផ្សេងៗទាក់ទិននឹងការបោះឆ្នោត ដែលនាំឱ្យមានការទិតៀនពីគណបក្សជំទាស់នានា ។ មានពេលមួយ គជប បានព្យាយាមប្រឈមមុខនឹងជនល្មើស និងគំរាមដាក់ទោសទណ្ឌ (ក្នុងឧសាននវាទមួយផ្តល់ទៅឱ្យប្រព័ន្ធផ្សព្វផ្សាយ) តែក្រោយមកត្រូវបង្ខំចិត្តទទួលស្គាល់ថា ទោសទណ្ឌបែបនេះវាហួសពីសិទ្ធិអំណាច គជប, ដូច្នេះយុទ្ធសាស្ត្រនេះបានធាក់ថយវិញ ហើយជះផលអាក្រក់យ៉ាងច្រើនទៅលើកេរ្តិ៍ឈ្មោះ និងលទ្ធភាពរបស់ គជប ក្នុងការដាក់អនុវត្តន៍ក្រមសីលធម៌ ទៅលើតួអង្គខាងនយោបាយឯទៀតៗ ។ សមាជិក គជប ម្នាក់លើកឡើងថា:

> *"ក្នុង (សិក្ខាសាលាវាយតំលៃលើខ្លួនឯង) អ្នកចូលរួមម្នាក់មកពី គខប និយាយថា យើងគួរតឹងរ៉ឹងខ្លាំងថែមទៀតជាមួយនឹងការជេរប្រមាថទាំងនេះ ពីព្រោះវាជះឥទ្ធិពលលើពួកគេនៅមូលដ្ឋាន ។ នៅពេល គឃប និង គខប ព្យាយាមដាក់ទោសនៅកំរិតមូលដ្ឋាន ប្រជាជននិយាយទៅពួកគេថា "ហេតុអ្វីអ្នកដាក់ទោស? ហេតុអ្វីអ្នកតឹងរ៉ឹង? គជប មិនរវល់នឹងការជេរប្រមាថក្នុងវិទ្យុជាតិទេ, តែវាធ្វើឱ្យខូចខាតដល់សិទ្ធិអំណាចរបស់ពួកគេ""*[២៤២] ។

លទ្ធផលការងាររបស់ គខប និង គឃប នៅតែមានគេប្តឹងតវ៉ា ។ គណបក្សនយោបាយ និង EMOs នានា ជាទូទៅនៅតែមើលឃើញអង្គភាពទាំងនេះថាលំអៀង ហើយតែងទិតៀនដល់ការជ្រើសយកគ្រូបង្រៀនឱ្យធ្វើជាមន្ត្រី គឃប ដោយជជែកវែកញែកថា គ្រូបង្រៀនត្រូវពឹងផ្អែកលើរដ្ឋាភិបាលសំរាប់តួនាទីរបស់ខ្លួនសព្វថ្ងៃ និងការឡើងកាំថ្នាក់ទៅអនាគត ដូច្នេះអាចទទួលរងការគំរាមកំហែង ។ ក្នុងតំបន់ភាគច្រើននៅកម្ពុជា ដោយសារវិស័យឯកជនពុំទាន់មានការអភិវឌ្ឍន៍ល្អ គេពិបាកនឹងរកបានអ្នកចេះការងាររដ្ឋបាលដែលគ្មានកាន់តួនាទីប្រហាក់ប្រហែលគ្នាក្នុងជួររដ្ឋាភិបាល ប៉ុន្តែ បញ្ហានេះនៅតែជាប្រភពទំនាស់ជាសក្តានុពលមួយក្នុងការបោះឆ្នោតនៅកម្ពុជា ។ រឿងនេះបានបញ្ជាក់ជាថ្មីម្តងទៀតពីគណបក្សជំទាស់ និង NGOs មួយចំនួនដែលនៅតែជឿថា រដ្ឋ និង CPP នៅតែជំពាក់វាក់វិនគ្នា, លើកនេះគឺនៅកំរិតអាជ្ញាធរថ្នាក់ខេត្ត និងស្រុក, ដូច្នេះហើយភ្នាក់ងាររបស់រដ្ឋតែងលំអៀងខាងនយោបាយទៅគាំទ្រគណបក្សកាន់អំណាច ។ បញ្ហាអព្យាក្រឹតភាពរបស់រដ្ឋក្នុងចន្លោះពេល រវាងការបោះឆ្នោត និង

---

[២៤២] NEC member (51), personal interview, 6 Oct 2003.

ក្នុងរយៈពេលបោះឆ្នោត វាមានសារៈសំខាន់ជាមូលដ្ឋានដល់របបប្រជាធិបតេយ្យនៅកម្ពុជា ហើយវានឹងនៅតែធ្វើឱ្យរអាក់រអួលដល់ការគ្រប់គ្រងការបោះឆ្នោត បើសិនវានៅតែមិនទាន់ដោះស្រាយ ។

ធៀបនឹងឆ្នាំ១៩៩៨ តួនាទី គឃប ក្នុងការគ្រប់គ្រងទំនាស់បានរីកធំថែមទៀតនៅឆ្នាំ២០០៣ តាមរយៈការសំរបសំរួលការប្រជុំប្រចាំសប្តាហ៍ដើម្បីដោះស្រាយទំនាស់នៅកំរិតមូលដ្ឋាន និងទប់ស្កាត់កុំឱ្យវារីករាលដាល ក្លាយជាវិបត្តិនយោបាយកំរិតជាតិ ។ ការសិក្សានេះរកឃើញថា SRP និង EMOs មើលឃើញការប្រឹងប្រែងរបស់ គឃប ក្នុងរឿងនេះថាមានឥទ្ធិពលចំរុះ ។ ជួនកាលពួកគេអាចរកបានដំណោះស្រាយសំរុះសំរួលគ្នាមួយ ។ ជួនកាល ពួកគេបានបំបិទទំនាស់មួយដែលគួរទុកឱ្យតុលាការដោះស្រាយវិញទើបសមស្រប (ឧ. ការចោទថា គណបក្សនយោបាយណាមួយប្រព្រឹត្តខុសខាងព្រហ្មទណ្ឌ) ។ ក្នុងករណីឯទៀតៗជាពិសេសការប្តឹងតវ៉ាពីទង្វើរបស់ប្រធានភូមិ, គឃប គ្មានប្រសិទ្ធភាពទេក្នុងការរកដំណោះស្រាយ ហើយទំនាស់នៅតែកើតមានយ៉ាងច្រើនរហូតដល់អ្នកដឹកនាំគណបក្សនយោបាយថ្នាក់ជាតិ បានយករឿងនេះមកធ្វើការតថ្លៃខាងនយោបាយនៅក្រោយពេលបោះឆ្នោត ។ ការស្រាវជ្រាវកំរិតឃុំរបស់យើងបង្ហាញថា មានការស៊ីសង្វាក់គ្នាយ៉ាងច្រើនរវាងបញ្ហាដែលសកម្មជនគណបក្សកំរិតឃុំបានលើកឡើង ហើយនិងបញ្ហាដែលតំណាងរបស់ពួកគេលើកឡើងនៅភ្នំពេញ គឺបានន័យថា វិធានការសំរបសំរួលរបស់ គឃប មិនគ្រប់គ្រាន់ទេសំរាប់ទប់ស្កាត់ទំនាស់កុំឱ្យវារាលដាលឡើងដល់កំរិតជាតិ ។

ទំនុកចិត្តចំពោះ គជប នៅតែខូចខាតធ្ងន់ណាស់នៅដំណាក់កាលដែលត្រូវដោះស្រាយបណ្តឹងតវ៉ាផ្សេងៗ ។ ថ្វីបើនៅឆ្នាំ២០០៣ នីតិវិធីសំរាប់ដោះស្រាយបណ្តឹងតវ៉ាគេកសាងបានល្អជាងនៅឆ្នាំ១៩៩៨ហើយក្តី ក៏នៅតែមានចន្លោះប្រហោងធំៗជាច្រើនដែលអាចសំរេចតាមចិត្តបាន ហើយជាទូទៅនីតិវិធីនេះអនុវត្តបានយ៉ាងខ្សោយ និងមិនស៊ីសង្វាក់គ្នាល្អទេ ។ ការបដិសេធមិនព្រមរាប់ឡើងវិញក្នុងខេត្តមួយចំនួនដែលនៅទីនោះសន្លឹកឆ្នោតតែប៉ុន្មានរយ អាចប៉ះពាល់ដល់លទ្ធផលបោះឆ្នោតសរុប បានបង្ហាញពីកង្វះភាពស្មោះត្រង់ ពីព្រោះដំណើរការរាប់ និងបូកចំនួនសន្លឹកឆ្នោតដ៏ស្មុគស្មាញ អាចមានកំហុសខ្លះបាន ទោះបីក្នុងកាលៈទេសៈល្អបែបណាក្តី ។ គណបក្សនានាតវ៉ាថា គជប មិនចង់ទិតៀនពួកមន្ត្រីរបស់ខ្លួនទេ ដោយរំកញ្ចែកថា គជប ដើរតួជាអ្នកលេងផង និងជាអាជ្ញាកណ្តាលផង ដូច្នេះគួរបង្កើតតុលាការបោះឆ្នោតដាច់ដោយឡែកមួយឡើង ។ យោងតាមបរិយាកាសនយោបាយតឹងតែងយ៉ាងខ្លាំងភ្លាមៗ នៅក្រោយការបោះឆ្នោតនៅកម្ពុជារាល់លើកតាំងពីឆ្នាំ១៩៩៣ មក ការបង្កើតស្ថាប័នមួយថ្មីមិនប្រាកដថាអាចដោះស្រាយទំនាស់បានប្រសើរជាងមុនទេ ។ នីតិវិធីសំរាប់បង្កើតតុលាការមួយបែបនេះ ប្រហែលជានឹងពោរពេញទៅដោយទំនាស់ និងការមិនទុកចិត្តគ្នា ដូចនីតិវិធីសំរាប់បង្កើត គជប ដូច្នោះដែរ ។ ប៉ុន្តែការបែងចែកដាច់នូវសិទ្ធិអំណាចទាំងនេះ អាចជួយសំរាលបញ្ហាក្រាញរារាំង (ពីខាងការិយាធិបតេយ្យ មិនមែនខាងនយោបាយទេ) ការពិនិត្យពិច័យដែលគេតែងចោទប្រកាន់ចំពោះ គជប ។

### *៥.១.៤ ផលប៉ះពាល់នៃវិមជ្ឈការ*

ក្នុងការបោះឆ្នោតឆ្នាំ២០០៣ វិមជ្ឈការហាក់ដូចមានឥទ្ធិពលមួយចំនួន ។ វត្តមានមន្ត្រីខាង SRP និង FUNCINPEC ក្នុងក្រុមប្រឹក្សាឃុំក្នុងទូទាំងប្រទេស បានជួយពង្រីកលទ្ធភាពធ្វើឃោសនារបស់គណបក្សទាំងពីរនៅកំរិតជាតិ ។ រឿងនេះអាចមើលឃើញច្បាស់ក្នុងការចុះសិក្សាដល់កន្លែងរបស់យើង ដោយយើងបានឃើញគណបក្សទាំង៣ កំពុងធ្វើការឃោសនាយ៉ាងសកម្មក្នុងគ្រប់ឃុំករណីសិក្សា ។ ថ្វីបើនៅតែមានការមិនទុកចិត្តគ្នារវាងសកម្មជនមកពីគណបក្សខុសៗគ្នា ប៉ុន្តែសព្វថ្ងៃមានការទទួលស្គាល់ថា នៅជនបទកម្ពុជា គណបក្សធំៗទាំង៣ មានកន្លែងឈរជើងនៅក្នុងឃុំនានាក្នុងទូទាំងរដ្ឋនៃការបោះឆ្នោត ។ រឿងនេះខុសគ្នាយ៉ាងខ្លាំងពីស្ថានភាពមុនការបោះឆ្នោតឆ្នាំ១៩៩៨ ។

ថ្វីបើមានច្រកដើរមួយក្តី ប៉ុន្តែការទទួលបានមុខតំណែងក្នុងរដ្ឋបាលឃុំមិនសុទ្ធតែធានាថា នឹងមានឥទ្ធិពលក្នុងការងារគ្រប់គ្រងកិច្ចការនៅមូលដ្ឋាននោះទេ ។ ការសង្កត់ធ្ងន់លើតួនាទីរបស់ប្រធានភូមិ ព្រមទាំងមេឃុំ និងប៉ូលីសឃុំផង ក្នុងការ

ផ្សព្វផ្សាយពត៌មាន, រៀបចំពួកសមាជិកគណបក្សខ្លួនឱ្យទៅបោះឆ្នោត, និង (តាមការចោទប្រកាន់) ធ្វើការបំភិតបំភ័យ/គំរាមកំហែងពួកអ្នកគាំទ្រគណបក្សប្រឆាំង, បានបង្ហាញថា ឥឡូវនេះនៅក្នុងអាជ្ញាធរមូលដ្ឋានភក្តីភាពចំពោះគណបក្ស វាសំខាន់ជាងឋានានុក្រមខាងស្ថាប័ន ។

ដោយសារក្រុមប្រឹក្សាឃុំទើបបង្កើតឡើងថ្មី ពេលនេះវាឆាប់ពេកក្នុងការវាយតំលៃបានថា ការអះអាងពីការផាត់ចេញនូវពួកអ្នកនៅខាង SRP វាជាលទ្ធផលពិត១នៃដំណើរការខាងនយោបាយ ឬគ្រាន់តែជាបញ្ហារការកូសក្នុងប្រតិបត្តិការពីដំបូងនៃក្រុមប្រឹក្សាឃុំប៉ុណ្ណោះ ។ ការកសាងស្ថាប័ននៅកំរិតក្រុមប្រឹក្សាឃុំដើម្បីធានាឱ្យសមាជិកក្រុមប្រឹក្សាឃុំទាំងអស់គ្នាបានរួមសហការធ្វើសេចក្តីសំរេចចិត្ត អាចជួយច្រោះយកអំណាច និងឥទ្ធិពលចេញពីមេឃុំ ដើម្បីយកមកបែងចែកឱ្យបានស្មើភាពជាងមុនរវាងគណបក្សនានា ។ ការទទួលខុសត្រូវកាន់តែច្រើនឡើងក្នុងប៉ុន្មានឆ្នាំខាងមុខដោយក្រុមប្រឹក្សាឃុំ នៅពេលដែលថវិកាត្រូវបានបើកផ្តល់ ហើយផែនការអភិវឌ្ឍន៍ត្រូវបានដាក់ដំណើរការ, វានឹងអាចជួយពង្រឹងស្ថាប័ន បង្កើនកំរិតសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ និងជួយបង្កើនឥទ្ធិពលរបស់ក្រុមប្រឹក្សាឃុំ ក្នុងចំណោមពួកអ្នកភូមិ និងពួកប្រធានភូមិ ។

ក្នុងពេលបច្ចុប្បន្ន ប្រធានភូមិមានឋានៈមិនច្បាស់លាស់ទេធៀបនឹងក្រុមប្រឹក្សាឃុំ ហើយមានភស្តុតាងមួយចំនួនបង្ហាញថា ប្រធានភូមិរាយការណ៍ដោយផ្ទាល់ទៅអាជ្ញាធរស្រុក (ដែលមិនមែនជ្រើសតាំងតាមការបោះឆ្នោតទេ) ដោយរំលងចោលក្រុមប្រឹក្សាឃុំ ។ ការពង្រឹងទំនាក់ទំនងរវាងប្រធានភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ អាចជួយបង្កើនទំនុកចិត្តគ្នារវាងអាជ្ញាធរទាំងពីរកំរិត និងបង្កើនគណនេយ្យភាពរបស់ប្រធានភូមិចំពោះគណបក្សផ្សេង១ដែលមិនមែនជាគណបក្សខ្លួន ។ ម្យ៉ាងទៀត គួរដោះស្រាយភាពពេញលក្ខណៈច្បាប់របស់ប្រធានភូមិ ដោយធ្វើការបោះឆ្នោតឡើងវិញ និងធ្វើការជ្រើសរើសឡើងវិញ ទៅតាមនីតិវិធីមួយបានឯកភាពគ្នា ។

### *៥.១.៥ ផលប៉ះពាល់នៃការតស៊ូមតិរបស់សង្គមស៊ីវិល*

ផលប៉ះពាល់នៃការតស៊ូមតិរបស់សង្គមស៊ីវិលពិបាកនឹងវាស់វែងដោយផ្ទាល់បាន ប៉ុន្តែការផ្លាស់ប្តូរមួយចំនួន ក្នុងការបោះឆ្នោត ពិតជាបានទទួលផលល្អពីឥទ្ធិពលរបស់សង្គមស៊ីវិល ។ ឧទាហរណ៍ ការបើកចំហ គជប តាមរយៈការប្រជុំប្រចាំសប្តាហ៏ជាមួយ NGOs បានញុំាងឱ្យមានការឆ្លើយតបកាន់តែល្អអំពី គជប ចំពោះបញ្ហាមួយចំនួនដែលផុសឡើងក្នុងរយៈពេលចុះបញ្ជី និងធ្វើការឃោសនាបោះឆ្នោត ដូចជា ការប្រឹងប្រែងដោះស្រាយបញ្ហាសំភារៈថតរូប គុណភាពអន់សំរាប់ការថតរូបធ្វើប័ណ្ណសំគាល់ខ្លួន, ការប្រឹងប្រែងដាក់វិន័យលើសកម្មភាពរបស់ប្រធានភូមិ (ដែលជាការឆ្លើយតបនឹងការតស៊ូមតិរបស់ NGOs), និងការប្រឹងប្រែងជំរុញការសំរុះសំរួលទំនាស់តាមរយៈការប្រជុំប្រចាំសប្តាហ៏របស់ គឃប (ដែលឆ្លុះបញ្ចាំងពីការប្រឹងប្រែងប្រហាក់ប្រហែលគ្នាធ្វើដោយ COMFREL នៅឆ្នាំ១៩៩៨ ដើម្បីព្យាយាមដោះស្រាយទំនាស់) ។

អ្នកចូលរួមទាំងអស់ បានអបអរសាទរដំណើរការ COPCEL ថា បានបើកចំហឱកាសល្អដែលមិនធ្លាប់មាន សំរាប់ការចែករំលែកពត៌មាន ការផ្លាស់ប្តូរមតិយោបល់ ការលើកឡើង និងការស្តាប់នូវការតវ៉ានិងការពន្យល់របស់ភាគីម្ខាងទៀត ។ COPCEL ក៏បង្កើតឱកាសល្អវិសេសមួយដើម្បីឱ្យសមាជិកសង្គមស៊ីវិលលើកមតិអំពីសេចក្តីព្រាងវិសោធនកម្មលើច្បាប់បោះឆ្នោតមុននឹងបញ្ជូនចេញទៅរដ្ឋសភា ។ ដោយមូលហេតុនេះ អ្នកចូលរួមជាច្រើននាក់មើលឃើញថា COPCEL បានធ្វើឱ្យតួអង្គខាងនយោបាយសំខាន់១ខិតមកជិតគ្នា សំរាលភាពតានតឹងរវាងពួកគេ និងបានដំណើរការជាប្រព័ន្ធប្រកាសភាពអាសន្នពីដើមទីសំរាប់គូសបង្ហាញពីទំនាស់ ។ បទសំភាសន៍ធ្វើជាមួយអ្នកចូលរួម COPCEL ក្នុងរយៈពេល និងក្រោយពេលធ្វើការបោះឆ្នោតបានគូសរំលេចពីផលសំរេចមួយចំនួននៃ COPCEL ។ អ្នកឆ្លើយសំភាសន៍ភាគច្រើនជឿថា ឱកាសបានជួបទល់មុខគ្នា លើកសំនួរផ្តល់ចំលើយ និងធ្វើការតវ៉ា, បានរួមវិភាគទានយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយភាពតានតឹងក្នុងមជ្ឈដ្ឋាននយោបាយកម្ពុជាព្រមទាំងជួយកសាងសហគមន៍មួយមានទំនុកចិត្តគ្នាក្នុងចំណោមអ្នកចូលរួមក្នុងការបោះឆ្នោត ។ មតិលើកឡើងមានដូចតទៅ:

> *"COPCEL ដើរតួនាទីសំខាន់ក្នុងការផ្តល់វេទិកាមួយសំរាប់ពួកអ្នកពាក់ព័ន្ធនឹងការបោះឆ្នោត ។ រឿងនេះសំខាន់ណាស់ ។ តាមនេះយើងអាចមើលឃើញថា មនុស្សមកចូលរួមក្នុងវេទិកាដើម្បីពិភាក្សា ផ្លាស់ប្តូរមតិគ្នា ជជែកវែកញែក ជួនកាលមានបោះពាក្យសំដីលើគ្នាខ្លះដើម្បីបន្ធូរការខកចិត្ត ហើយក្រោយពីនេះក៏ចេញទៅវិញដោយមានអារម្មណ៍មួយផ្សេង ។ ពួកគេគិតថា "ខ្ញុំបាននិយាយវា ពួកគេបានឮហើយ" គឺវាបានជួយកាត់បន្ថយភាពតានតឹង និងការប្រទូសរ៉ាយ"[២៤៣] ។*

> *"COPCEL បានផ្តល់ឱកាសឱ្យពួកអ្នកតំណាងដែលមានអតីតភាពខាងនយោបាយខុសៗគ្នា មកជួបគ្នា និងលើកបញ្ហា មិនមែនគ្រាន់តែប្រឈមមុខដាក់គ្នាទេ ។ វាបង្កើតបរិយាកាសមិត្តភាព ទំនាក់ទំនងល្អ ដើម្បីយើងអាចបញ្ចេញមតិ និងលើកបញ្ហាជាសាធារណៈ ។ យើងមិនមែនគ្រាន់តែស្អប់គ្នាទៅវិញទៅមកដោយមិននិយាយរកគ្នា នោះទេ ។ វាកាត់បន្ថយវប្បធម៌ស្អប់គ្នា ។ ឧទាហរណ៍ ខាងជំទាស់មិនចូលចិត្ត CPP ទេ - វាផ្តល់ឱកាសឱ្យពួកគេ ឆ្លើយឆ្លងគ្នាទៅវិញទៅមក និងកាត់បន្ថយភាពតានតឹង"[២៤៤] ។*

អ្នកឆ្លើយសំភាសន៍មួយចំនួនមើលឃើញភាពតានតឹង និងការប្រទូសរ៉ាយមាននិន្នាការកើនឡើងក្នុងរឿងនយោបាយនៅកម្ពុជាថាជាលទ្ធផលនៃកង្វះទំនុកចិត្តគ្នារវាងពួកសមាជិកសហគមន៍នយោបាយ ។ ឧទាហរណ៍ អ្នកឆ្លើយសំភាសន៍ម្នាក់មើលឃើញរឿងនេះជាកេរ្តិ៍ដំណែលមកពីសម័យកម្ពុជាប្រជាធិបតេយ្យ:

> *"នៅកម្ពុជា តាំងពីរបប ប៉ុល ពត មក កេរ្តិ៍ដំណែលនៃកង្វះទំនុកចិត្តគ្នា គឺនៅតែមាន ។ យើងមានគំនិតចង់ធ្វើការផ្លាស់ប្តូរ ប៉ុន្តែ យើងមិនសូវមានការចងបាច់គ្នា ។ ការមូលមតិ គឺពិបាកនឹងសំរេចបាន ។ ប្រជាជនព្យាយាមគាំទ្រតែម្ខាងយ៉ាងខ្លាំង និងប្រឹងប្រយុទ្ធយ៉ាងខ្លាំងដើម្បីបានជ័យជំនះ ។ បើសិនគ្មានការប្រជុំដើម្បីសំរុះសំរួលការតានតឹងទេ នឹងមានបញ្ហាហើយ... ភាពតានតឹងខាងនយោបាយនឹងកើនឡើង ហើយអស្ថិរភាពខាងនយោបាយនឹងកើតមាន"[២៤៥] ។*

ការសិក្សារបស់ វិបសអ លើទំនាស់បោះឆ្នោតឆ្នាំ១៩៩៨ បានបង្ហាញថា ភាពតានតឹងខាងនយោបាយ និងការមិនទុកចិត្តគ្នា គឺជាកត្តាសំខាន់មួយនៃការរីករាលដាលទំនាស់ ។ វានាំឱ្យមានអន្ទះពីសំណាក់ពួកមន្ត្រីបោះឆ្នោត ដើម្បីពន្យល់ឱ្យបានពេញលេញពីសកម្មភាពរបស់ខ្លួន ធ្វើឱ្យតួអង្គខាងនយោបាយនានាកាន់តែសំលឹងឃើញពួកមន្ត្រីបោះឆ្នោតថាលំអៀងខាងនយោបាយ ព្រមទាំងចោទថា ការបរាជ័យនានាខាងស្ថាប័ន គឺមកពីកង្វះអព្យាក្រឹតភាព ។ វានាំឱ្យមានកង្វះការប្រាស្រ័យទាក់ទងនៅកំរិតមូលដ្ឋានដែលធ្វើឱ្យចំនួនទំនាស់លើកឡើងនៅកំរិតជាតិកើនឡើង ។ វានាំឱ្យមានការប្រើភាសាប្រទូសរ៉ាយ និងរំជួលចិត្តពីសំណាក់អ្នកដែលមានការតូចចិត្ត និងការប្រកាន់ឫកកោង និងមិនសហការពីសំណាក់អ្នកដែលមានអារម្មណ៍ថាត្រូវគេទិតៀនដោយអយុត្តិធម៌ ។ ថ្វីបើការរីករាលដាលទំនាស់បោះឆ្នោតឆ្នាំ១៩៩៨ មិនអាចដាក់លើបញ្ហារំជួលចិត្តតែមួយមុខបានក្តី (ពេលនោះមានបញ្ហាសំខាន់ៗជាច្រើន) ប៉ុន្តែ កង្វះទំនុកចិត្ត និងទំលាប់ធ្វើសហប្រតិបត្តិការ បានកាត់បន្ថយលទ្ធភាពអាចគ្រប់គ្រងទំនាស់បានដោយសក្តិសិទ្ធិ និងបង្កើនលទ្ធភាពដែលវាអាចរីករាលដាលជាវិបត្តិនយោបាយ ។ ដូច្នេះ ការលើកកំពស់ទំនុកចិត្តគ្នា គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការទប់ស្កាត់ទំនាស់ ។

[២៤៣] FUNCINPEC national representative (65), personal interview, Phnom Penh, 12 Aug 2003.

[២៤៤] CHRC representative (55), personal interview, Phnom Penh, 13 Aug 2003.

[២៤៥] Ministry of National Defence Representative (9), personal interview, Phnom Penh, 11 July 2003.

បញ្ហាចំបងមួយក្នុងការគ្រប់គ្រងទំនាស់នាពេលបោះឆ្នោតឆ្នាំ១៩៩៨ ផុសចេញពីវិវាទរវាងតួអង្គខាងនយោបាយ ស្តីពីព្រឹត្តការណ៍សំខាន់ៗនៃករណីជាក់លាក់មួយចំនួន ។ វិវាទទាំងនេះផុសចេញពីអង្គការខ្លះៗដែលមាននិន្នាការធ្វើការស៊ើបអង្កេតលើករណីជាក់លាក់មួយចំនួនដោយឯករាជ្យដាច់ពីគ្នា និងដោយប្រើនីតិវិធីដែលមិនសូវមានតំលាភាពល្អសំរាប់ភាគីជាប់ទាក់ទិនផ្សេងៗទៀត ។ ម្យ៉ាងទៀតកង្វះការជួបទាក់ទងជាបុគ្គលរវាងទីភ្នាក់ងារ និងអង្គការផ្សេងៗ ធ្វើឱ្យបុគ្គលិកស្ថាប័នទាំងនេះខ្វះឱកាសកសាងទំនុកចិត្តលើសមត្ថភាព និងជំនាញវិជ្ជាជីវៈរបស់សមភាគីនានានៅក្នុងអង្គការឯទៀតៗ ។ លទ្ធភាពខុសៗគ្នាក្នុងការបានប្រើប្រភពពតិមានសំខាន់ៗ ធ្វើឱ្យព្រឹត្តិការណ៍មានរូបភាពខុសៗគ្នានៅក្នុងអង្គការផ្សេងៗ ។ ការរៀបរាប់ខុសៗគ្នាអំពីព្រឹត្តិការណ៍ ជារឿយៗត្រូវបានគេសំគាល់ថា មកពីការលំអៀងខាងនយោបាយ ដែលកាន់តែបង្កើនការមិនទុកចិត្តគ្នាច្រើនថែមទៀត ។ ម្យ៉ាងទៀត ផលប្រយោជន៍សំខាន់ខុសៗគ្នា ធ្វើឱ្យអង្គការផ្សេងៗផ្តោតលើទិដ្ឋភាពខុសៗគ្នានៃករណី ។ អ្នកឆ្លើយសំភាសន៍ខាង NGO ម្នាក់បានពិពណ៌នាពីបែបបទដែលបញ្ហាទាំងនេះ បានរាលដាលចេញពីកង្វះការប្រស្រ័យទាក់ទងរវាងអង្គការនានា:

> *"ជួនកាលបើសិនអ្នកចង់ជួបមន្ត្រីទទួលខុសត្រូវ - អ្នកមិនអាចជួបទាក់ទងពួកគេបានទេ ។ បើសិនអ្នកនៅក៏រិតតូច ពួកគេគិតថាខ្លួនគេសំខាន់ជាងអ្នក ។ ជួនកាលពួកគេនិយាយថា គ្មានពេលជួបពិភាក្សាទេ ។ ពួកគេប្រែប្រួលល្អឡើង បើសិនពួកគេយល់ពីការងាររបស់អង្គការ, គោលដៅរបស់សង្គមស៊ីវិល - គឺជារឿងយើងដែលត្រូវបង្ហាញពួកគេពីតំលាភាព និងអព្យាក្រឹតភាព ។ ឥឡូវនេះខាងរដ្ឋាភិបាល ឬគណបក្សនយោបាយនានាគ្រាន់តែរំពឹងថាយើងគាំទ្រខាងបក្សជំទាស់ - ពួកគេយល់ខុសពីអង្គការរបស់យើង"*[២៤៦] ។

ដូចបង្ហាញខាងលើ កង្វះការប្រស្រ័យទាក់ទងធ្វើឱ្យការស៊ើបអង្កេតរបស់អង្គការផ្សេងគ្នា ផ្តល់ពតិមានខុសៗគ្នា ធ្វើឱ្យការមិនទុកចិត្តគ្នាខាងនយោបាយកាន់តែចោទធ្ងន់ធ្ងរ ហើយអន្ទាក់វិលវង់គ្មានច្រកចេញក៏កើតមានឡើង ។ ដូចគ្នាដែរមានភស្តុតាងបង្ហាញថា កង្វះការពិគ្រោះយោបល់ និងការចូលរួមក្នុងការកសាងនីតិវិធី បានធ្វើឱ្យខូចខាតច្រើនណាស់ដល់សិទ្ធិអំណាចនៃក្របខ័ណ្ឌច្បាប់ និងស្ថាប័នសំរាប់ការបោះឆ្នោតឆ្នាំ១៩៩៨ ។ អវត្តមានរបស់អ្នកតំណាងរាស្ត្រពីសភា ក្នុងពេលមានការអនុមតិច្បាប់ និងធ្វើការតែងតាំងសំខាន់ៗ មានផលប៉ះពាល់វែងឆ្ងាយណាស់ដល់សិទ្ធិអំណាចនៃច្បាប់ និងស្ថាប័នទាំងនេះ នៅក្នុងរយៈពេលបោះឆ្នោត ។ ស្ថានភាពនៅឆ្នាំ១៩៩៨ ជាករណីដ៏ពិសេសមួយ ប៉ុន្តែកង្វះការពិគ្រោះយោបល់ក្នុងការតាក់តែងច្បាប់នៅតែជាបញ្ហាចោទ បើតាមមតិអ្នកឆ្លើយសំភាសន៍ខ្លះ:

> *"ការប្រស្រ័យទាក់ទងរវាង NGOs និងរដ្ឋាភិបាល នៅតែពិបាកនៅឡើយ ។ រឿងនេះជាប់ទាក់ទងនឹងបទពិសោធន៍ - ខ្ញុំធ្វើការផ្នែកទំនាក់ទំនងខាងក្រៅ ហើយខ្ញុំឃើញថាពិបាកប្រស្រ័យទាក់ទងជាមួយរដ្ឋាភិបាលដូចជា ក្រសួងមហាផ្ទៃ និងរដ្ឋសភាផងដែរ ។ នៅពេលខ្ញុំចង់បានសេចក្តីព្រាងច្បាប់បោះឆ្នោតខ្លះ - យើងចង់ផ្តល់យោបល់យើងខ្លះលើច្បាប់បោះឆ្នោត - យើងឃើញថា ពិបាករកវាបានណាស់ ។ ពួកគេតែងនិយាយថា យើងមិនអាចឱ្យបានទេ មុនពេលយើងបានសេចក្តីព្រាងច្បាប់ជាផ្លូវការ - ប៉ុន្តែយើងចង់បានវាមុនពេលនោះ, យើងចង់មានឥទ្ធិពលនៅដំណាក់កាលខាងដើម"*[២៤៧] ។

ដើម្បីផ្តល់មូលដ្ឋានមួយសំរាប់ការព្រមព្រៀងគ្នាទាំងពីអង្គហេតុនៃករណី និងនីតិវិធីសំរាប់ចាត់ចែងវា ការដោះស្រាយបញ្ហាទាំងនេះ ជារឿងសំខាន់មួយសំរាប់កែលំអដំណើរការគ្រប់គ្រងទំនាស់នៅកម្ពុជា ។ ក្នុងនេះ COPCEL បានជួយរួមចំណែកតាមរយៈតួនាទីរបស់ខ្លួនក្នុងការផ្សព្វផ្សាយពតិមាន, ជំរុញកិច្ចពិភាក្សាពីអង្គហេតុ, និងលើកទឹកចិត្តដល់ការពិគ្រោះយោបល់រវាងពួកមន្ត្រី និង

[២៤៦] ADHOC representative (66), personal interview, 13 July 2003.

[២៤៧] COMFREL representative (1), personal interview, 5 Aug 2003.

សមភាគីរបស់ខ្លួនក្នុង NGOs និងគណបក្សនយោបាយដែលពាក់ព័ន្ធ ។ អ្នកឆ្លើយសំភាសន៍ ២នាក់មានមតិថា ការផ្លាស់ប្តូរពត៌មានដែល COPCEL បានជួយសំរបសំរួល ក៏មានប្រយោជន៍ដែរក្នុងការជួយពួកគេឱ្យទទួលបានពត៌មានពីខាងក្រៅវេទិកា COPCEL:

*"COPCEL ជួយយើងឱ្យធ្វើការបានកាន់តែលឿន ។ អង្គការសិទ្ធិមនុស្សក៏ទៅធ្វើការស៊ើបអង្កេតដែរ-ជួនកាលពួកគេទៅមុនយើង និងសហការជាមួយប៉ូលីសដើម្បីដោះស្រាយបញ្ហា ។ ជួនកាលយើងមិនបានដឹងពីករណីនោះទេ រហូតដល់មានគេលើកឡើងក្នុង COPCEL ។ COPCEL ក៏ជួយយើងឱ្យស្គាល់គណបក្សនយោបាយ, NGOs, ស្ថាប័នរដ្ឋ និងអង្គការសិទ្ធិមនុស្ស ។ យើងអាចផ្លាស់ប្តូរពត៌មានគ្នាតាមវិធីផ្សេងទៀត ដូចជាតាមទូរស័ព្ទ ។ នៅពេលមានបញ្ហាអ្វីកើតឡើង យើងអាចជួយធ្វើការផ្លាស់ប្តូរពត៌មានបាន"*[២៤៨] ។

*"វាអាចជាជោគជ័យមួយ បើគិតពីទំនាក់ទំនងជាបុគ្គល ។ ឧទាហរណ៍ បើខ្ញុំចង់បានពត៌មាន ខ្ញុំអាចទូរស័ព្ទទៅ CPP បើខ្ញុំនិយាយថា ខ្ញុំជាសមាជិក COPCEL រឿងនេះវាជួយឱ្យបានជួបទាក់ទង, ឱ្យគេផ្តល់ពត៌មាន"*[២៤៩] ។

ការកែលំអលំហូរពត៌មានអាចជាមធ្យោបាយសំខាន់មួយសំរាប់ជួយសំរួលដល់ការគ្រប់គ្រងទំនាស់ ។ ទោះបីបញ្ហាកើតចេញពីការយល់ច្រឡំសុទ្ធសាធ ឬចេញពីទំនាស់ខាងផលប្រយោជន៍ និងជំនឿក្តី ប៉ុន្តែការរកបានការឯកភាពគ្នាលើអង្គហេតុគឺជាជំហានមួយដ៏សំខាន់ក្នុងការគ្រប់គ្រងទំនាស់ ។ វាកាត់បន្ថយការច្របូកច្របល់ និងចំនួនបញ្ហាចោទ ធ្វើឱ្យគូភាគីក្នុងទំនាស់អាចផ្តោតការពិភាក្សាទៅលើចំណុចដ៏សំខាន់នៃទំនាស់ផលប្រយោជន៍ ។

អ្នកឆ្លើយសំភាសន៍មួយចំនួនមើលឃើញថា ក្រៅពីជួយសំរួលលំហូរពត៌មាន COPCEL ក៏មានសារៈសំខាន់ ដោយបានផ្តល់ឱ្យពួកគេនូវសំលេងមួយ ឬច្រកមួយសំរាប់ប្រស្រ័យទាក់ទងមួយជាមួយនឹងតួអង្គឯទៀតៗ ដែលមិនអាចរកបានតាមវិធីផ្សេង ។ នេះជាចំណុចបារម្ភដែលអ្នកឆ្លើយសំភាសន៍ជា NGOs មានលើកច្រើនជាពិសេសៈ

*"សង្គមស៊ីវិលនៅកម្ពុជា ទើបផុសឡើងនៅឆ្នាំ១៩៩២-៩៣ ហើយរហូតមកទល់សព្វថ្ងៃពួកមន្ត្រីរាជការនៅតែមានការលំបាកក្នុងការសំរបសំរួលជាមួយសង្គមស៊ីវិល ។ NGOs ស្ថិតនៅចន្លោះកណ្តាលរវាងស្រទាប់មហាជន និងរដ្ឋាភិបាល និងជាស្ពានតភ្ជាប់មជ្ឈដ្ឋានទាំងពីរ ។ ជួនកាលយើងពិបាកធ្វើការដោះស្រាយជាមួយមន្ត្រីរាជការ - ពួកមន្ត្រីគិតថា "នេះជាសេចក្តីសំរេចរបស់យើង" ...COPCEL គឺជាគំរោងទី១ ដែលជាប់ទាក់ទងនឹងការដោះស្រាយទំនាស់ក្នុងការបោះឆ្នោតសុទ្ធសាធ ។ គំរោងនេះសំខាន់បំផុតសំរាប់ឱ្យយើងសំរបសំរួលជាមួយខាងអាជ្ញាធរ - ក្រសួងមហាផ្ទៃ និង គជប ។ COPCEL អាចកេណ្ឌប្រមូលគ្រប់អង្គការដែលធ្វើការងារខាងបោះឆ្នោត ។ នេះជាតួនាទីមួយដ៏សំខាន់បំផុត - វិធីសាស្ត្រធ្វើសហប្រតិបត្តិការគ្នារវាង COPCEL និងស្ថាប័នរដ្ឋ ។ វាជាឱកាសដ៏ល្អសំរាប់ឱ្យសង្គមស៊ីវិលកសាងបណ្តាញ មិនត្រឹមតែជាមួយ NGOs ផ្សេងទៀតនោះទេ - យើងមិនអាចសំរេចគោលដៅកំពូលរបស់យើងបានឡើយ លើកលែងតែយើងធ្វើការជាមួយគ្នា"*[២៥០] ។

ការកសាងច្រកសំរាប់ប្រស្រ័យទាក់ទងមួយ អាចនាំឱ្យមានការយល់ដឹងពីគ្នាកាន់តែល្អរវាងតួអង្គខាងនយោបាយដែលច្រើនមានទំលាប់ចោទគ្នាជាព្រាយបិសាច ។ ការប្រស្រ័យទាក់ទងដោយផ្ទាល់ជួយឱ្យពួកអ្នកចូលរួម ចាប់ផ្តើមជំរុះចោលនូវសំពាធនយោបាយនៃទស្សនៈមិនល្អជាមុន ពាក្យចចាមអារាម រូបភាពបំផ្លើស, ហើយមានចំណាប់អារម្មណ៍ច្បាស់ឡើងពីគូប្រឆាំងរបស់ខ្លួន ។ ការយល់ដឹងពីចរិតនៃអង្គការឯទៀតៗ ជំហរនិងជំនឿរបស់ពួកគេ និងដែនធ្វើសកម្មភាព គឺមានសារៈសំខាន់

---

[២៤៨] Ministry of National Defence Representative (9), personal interview, Phnom Penh, 11 July 2003.

[២៤៩] Cambodian Human Rights Centre representative (55), personal interview, Phnom Penh, 13 Aug 2003.

[២៥០] Centre for Social Development representative (66), personal interview, Phnom Penh, 15 Aug 2003.

ក្នុងការគ្រប់គ្រងទំនាស់ ហើយវាជួយឱ្យភាគីនានានៃទំនាស់ អាចយល់បានពីជំហររឹងកំព្រឹសរបស់ភាគីម្ខាងទៀត និងពីកំរិតដែលគេអាចសំរុះសំរួលបាន ។ រឿងនេះជួយឱ្យមានការវាយតំលៃកាន់តែប្រាកដនិយមពីលទ្ធភាពសំរាប់ការដោះស្រាយទំនាស់ ។

សំរាប់អ្នកឆ្លើយសំភាសន៍មួយចំនួន បញ្ហាជាច្រើនដូចខាងលើ មិនមែនគ្រាន់តែផុសចេញពីសង្គ្រាមស៊ីវិល ឬការប្រកួតប្រជែងខាងនយោបាយសព្វថ្ងៃរវាងគណបក្សនយោបាយដើម្បីដណ្តើមអំណាចនោះទេ ប៉ុន្តែវាក៏ផុសចេញពីលក្ខណៈដោយឡែកនៃវប្បធម៌នយោបាយនៅកម្ពុជាផងដែរ ។ អ្នកឆ្លើយសំភាសន៍ទាំងនេះលើកមតិថា កម្ពុជាខ្វះវប្បធម៌សន្ទនាគ្នាដែលអាចជួយសំរួលបន្ធូរភាពតានតឹងរវាងគូប្រជែងខាងនយោបាយ ដូច្នេះហើយ គេត្រូវប្តូរទិសវប្បធម៌ជាមូលដ្ឋាននេះ មុននឹងអាចបង្កើតបាននូវច្រកសំរាប់ប្រស្រ័យទាក់ទងមួយដ៏សក្តិសិទ្ធិ ។ ឧទាហរណ៍ៈ

> *"កម្ពុជាខ្វះវប្បធម៌សន្ទនា និងចរចាគ្នា ។ បើសិនជាអ្នកម្ខាង មានអ្វីទំនាស់នឹងម្ខាងទៀត ពួកគេចាត់ទុកអ្នកទាំងនោះដូចជាសត្រូវ ។ យើងមិនចង់ពិភាក្សា ឬដោះស្រាយអ្វីទេ ។ យើងតែងគិតថា យើងត្រូវ ។ ខ្ញុំរីករាយដោយបានឃើញការប្រឹងប្រែងផ្លាស់ប្តូរវប្បធម៌បែបនេះ... វប្បធម៌កម្ពុជាមានឋានានុក្រមច្រើនណាស់ ។ ឧទាហរណ៍ មនុស្សក្នុងគ្រួសារមួយ ត្រូវប្រព្រឹត្តិខ្លួនទៅតាមអាយុរបស់ខ្លួន... បើអ្នកណានៅក្មេង យើងគិតថា ពួកគេប្រហែលមិនអាចផ្តល់គំនិតបានទេ ។ គ្មានវប្បធម៌ផ្លាស់ប្តូរគំនិតគ្នាទេ"*[២៥១] ។

បើដូចខាងលើមែន ការគ្រប់គ្រងទំនាស់កាន់តែពិបាកហើយ ។ អ្នកឆ្លើយសំភាសន៍ដែលមើលឃើញទំនាស់បោះឆ្នោតនៅកម្ពុជាថាជារឿងវប្បធម៌ មិនមែនត្រឹមតែជារឿងនយោបាយមួយមុខទេ គេយល់ថា COPCEL គួរផ្តល់វិភាគទានចំបងដើម្បីធ្វើកំណែទំរង់លើវប្បធម៌នេះ មិនមែនព្យាយាមដោះស្រាយទំនាស់នានាដែលគ្រាន់តែជារោគសញ្ញារបស់វានោះទេ ។ ឧទាហរណ៍ៈ

> *"COPCEL អាចដើរតួមួយចំណែក និងបានដើរតួមួយចំណែក - វាបានលើកកំពស់វប្បធម៌ផ្លាស់ប្តូរគំនិតគ្នា ចែករំលែកបទពិសោធន៍ រៀនទទួលយកមតិទី២ ឬទី៣ - ដែលមិនធ្លាប់មានមកទេ ទាំងនៅក្នុងរបៀបរបបកម្ពុជាជាប្រពៃណី និងនៅក្នុងរបៀបរបបកុម្មុយនីស្ត - COPCEL បានដើតួនាទីនេះក្នុងពេលកន្លងមក ។ COPCEL មិនបានគ្របដណ្តប់លើគ្រប់វិស័យនោះទេ ប៉ុន្តែបានដើរតួនាទីបានមួយចំណែក"*[២៥២] ។

តាមរយៈដំណើរការផ្សាំកែប្រែវប្បធម៌ គេអាចកសាងបាននូវច្រកសំរាប់ប្រស្រ័យទាក់ទងកាន់តែសក្តិសិទ្ធិច្រើនថែមទៀត ហើយបង្កើតបានបរិស្ថានមួយសំរាប់ការគ្រប់គ្រងទំនាស់កាន់តែប្រសើរ ។

ប៉ុន្តែពួកអ្នកឆ្លើយសំភាសន៍ក៏បានលើកពីកំហិតមួយចំនួនចំពោះ COPCEL ដែរ ។ អ្នកចូលរួមខ្លះគិតថា COPCEL ជាកន្លែងមួយដ៏មានប្រយោជន៍សំរាប់ការពិភាក្សាគ្នា ប៉ុន្តែផលប៉ះពាល់ជាក់ស្តែងទៅលើដំណើរការបោះឆ្នោត ដែលបានកើតមានក្នុងទូទាំងប្រទេស គឺមានកំរិត ។ ឧទាហរណ៍ តំណាង NGOs ២នាក់ បានលើកឡើងថាៈ

> *"ការយកចិត្តទុកដាក់របស់ខ្ញុំ កំពុងធ្លាក់ចុះ ពីព្រោះបញ្ហាដែលធ្លាប់មានពីមុន វានៅតែកើតមាន"*[២៥៣] ។

> *"COPCEL បានបង្កើតឡើងដើម្បីធ្វើឱ្យខាងរដ្ឋអំណាច និងអាជ្ញាធរបោះឆ្នោតពិភាក្សាយោបល់គ្នា ។ នេះជាការផ្លាស់ប្តូរពិតមាន មិនមែនការដោះស្រាយទំនាស់ពិតៗនោះទេ"*[២៥៤] ។

---

[២៥១] Khmer Institute of Democracy representative (67), personal interview, Phnom Penh, 14 July 2003.

[២៥២] FUNCINPEC national representative (65), personal interview, Phnom Penh, 12 Aug 2003.

[២៥៣] COMFREL national representative (1), personal interview, Phnom Penh, 6 Aug. 2003.

[២៥៤] Women For Development representative (68), personal interview, Phnom Penh, 7 Aug. 2003.

អ្នកឆ្លើយសំភាសន៏ទាំង ២នាក់ ចោទសួរថាតើវេទិកាសំរាប់ផ្លាស់ប្តូរពត៌មានគ្នា និងលើកកំពស់ការយល់ដឹង អាចជួយដោះស្រាយទំនាស់ដែលផុសចេញពីទំនាស់ផលប្រយោជន៏ឬទេ ។ ឧទាហរណ៍ អ្នកឆ្លើយសំភាសន៏ខាង NGO ម្នាក់បានលើកឡើងថា បញ្ហាជាមូលដ្ឋានគឺ NGOs ចង់ឱ្យមានកំណែទំរង់លើរដ្ឋាភិបាល ហើយរដ្ឋាភិបាលមិនចង់ធ្វើកំណែទំរង់ទេ ដូច្នេះហើយគាត់បានរែកញែកថា:

*"យើងបានយល់ហើយពីទស្សនៈខុសៗគ្នា ។ ខាង NGOs បានយល់ពីរដ្ឋាភិបាល ហើយរដ្ឋាភិបាលក៏បានយល់ពី NGOs ។ តើអ្នកណាគួរកែប្រែទស្សនៈរបស់អ្នកណា?* [២៥៥]

មតិប្រហាក់ប្រហែលគ្នាមួយស្តីពី ចរិតបដិបក្ខគ្នារហូតនៅក្នុងទំនាក់ទំនងរវាងរដ្ឋាភិបាល និងក្រុមធ្វើការគៀងគរ បាននាំឱ្យអ្នកឆ្លើយសំភាសន៏ម្នាក់ទៀតជជែករែកញែកឱ្យមានការតស៊ូមតិកាន់តែច្រើននៅក្នុង COPCEL:

*"COPCEL ល្អហើយក្នុងការប្រមូលពត៌មានពីទំនាស់អ្វីមួយ ប៉ុន្តែខ្ញុំចង់ជូនមតិឱ្យ COPCEL ប្រឹងប្រែងស្វែងរកដំណោះស្រាយ ។ ពួកគេគ្រាន់តែរាយការណ៍ និងធ្វើកំណត់ហេតុ ប៉ុន្តែធ្វើបែបនេះវាមិនឆ្លុះបញ្ចាំងពីឈ្មោះថា COPCEL ទេ ។ ពួកគេគួរមានសំលេងខ្លាំង ជំរុញរដ្ឋាភិបាលក្នុងរឿងទាក់ទិននឹងការបោះឆ្នោត ។ គួរមានការតស៊ូមតិច្រើនថែមទៀត មិនមែនគ្រាន់តែផ្តល់ពត៌មាន និយាយ និងពិភាក្សានោះទេ ។ នេះមិនមែនជាផ្លូវសំរាប់ទៅដល់អ្វីដែលយើងចង់ធ្វើ សេចក្តីសំរេចចិត្តយ៉ាងល្អនោះទេ ។ COPCEL គួរមានសំលេងតែមួយអំពីបញ្ហាផ្សេងៗដែលផុសឡើង ។ ឧទាហរណ៍ អង្គការរបស់យើងធ្វើការងារសំរាប់ការបោះឆ្នោត ដូច្នេះយើងជួបបញ្ហាជាញឹកញយ ។ យើងចង់ឱ្យ COPCEL មាន សំលេងតែមួយធ្វើអនុសាសន៏ និងសេចក្តីថ្លែងការណ៍ទៅរដ្ឋាភិបាល និង គជប ។ ម្យ៉ាងទៀត វាមិនសាធារណៈទេ - វាគ្រាន់ជាការនិយាយ ហើយមិនមែនជាសាធារណៈទេ ។ គ្មានសំលេងខ្លាំងតែមួយទេ "យើងគ្រាន់តែជូនពត៌មាន ហើយ គជប គ្រាន់តែសន្យា ។ មិនដែលមានដំណោះស្រាយអ្វីទេ"*[២៥៦] ។

នាយក EMO មួយបារម្ភថា វត្តមានវេទិកាពហុភាគីមួយដូចជា COPCEL អនុញ្ញាតឱ្យរដ្ឋាភិបាលដកថយវិញ ពីការកសាងទំនាក់ទំនងទ្វេភាគីជាមួយ NGOs នានាដែលជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការងារបោះឆ្នោត ។ គាត់លើកឡើងថា:

*"បញ្ហា COPCEL គឺជាការងារជាន់គ្នាជាមួយការងាររបស់អ្នកឯទៀត ។ ឧទាហរណ៍ COMFREL និង NICFEC ត្រូវបានស្គាល់ថា ធ្វើការសង្កេតការណ៍ ។ ប៉ុន្តែនៅពេល គជប មានឯកសារពួកគេមិនផ្ញើវាទៅឱ្យ COMFREL និង NICFEC ដែលផ្តោត លើការបោះឆ្នោតទេ តែទៅឱ្យ COPCEL ដែលជាច្រកប្រាស្រ័យទាក់ទង ។ រឿងនេះធ្វើឱ្យយើងយឺតយ៉ាវក្នុងការបានទទួលឯកសារពី គជប ។ ម្យ៉ាងទៀត គជប ប្រើឱកាសល្អនៃ COPCEL ជាកន្លែងដែល គជប ព្យាយាមគេចវេស ។ គេពិបាកធ្វើទំនាក់ទំនងទ្វេភាគីជាមួយ គជប ពីព្រោះ គជប គេចវេសដោយនិយាយថា យើងបានពិភាក្សារឿងនេះក្នុង COPCEL ហើយ ។ អ្នកចូលរួមមួយចំនួនមិនមែនជាជំនាញការខាងបោះឆ្នោតទេ ដូច្នេះមានការច្របូកច្របល់"*[២៥៧] ។

អ្នកឆ្លើយសំភាសន៏ឯទៀតៗបានលើកសំនួរថា តើចរិតនៃទំនាស់នៅកម្ពុជា ស៊ីគ្នានឹងវិធីសាស្ត្រនេះដែរឬទេ ។ ពួកគេលើកមតិថា ទំនាស់បានចាក់ឫសជាប់នឹងកត្តាខាងស្ថាប័ននិងសង្គមកិច្ចដ៏ធំទូលាយ ដូច្នេះហើយកិច្ចសន្ទនាក្នុងចំណោមមន្ត្រីមួយ

---

[២៥៥] Women For Development representative (68), personal interview, Phnom Penh, 7 Aug. 2003.

[២៥៦] COMFREL national representative (1), personal interview, Phnom Penh, 6 Aug. 2003.

[២៥៧] NICFEC national representative (69), personal interview, Phnom Penh, 11 Aug. 2003.

ក្រុមតូច ទោះបីមានលក្ខណៈកសាងយ៉ាងណាក្តី ក៏ប្រហែលមានផលប៉ះពាល់តិចតួចទេទៅលើពិភពធំទូលាយខាងក្រៅ ។ ឧទាហរណ៍ អ្នកឆ្លើយសំភាសន៍ខាង NGOs ២នាក់ បានលើកឡើងថាៈ

*"បញ្ហាខ្លះដោះស្រាយបាន និងខ្លះទៀតលើសពីសមត្ថភាព COPCEL ។ បញ្ហាដែលយើងអាចដោះស្រាយមានប្រហែល ៣០% ។ បញ្ហានានាដែលយើងមិនអាចដោះស្រាយ យើងយកមកស្វែងយល់ជាមួយគ្នា ។ យើងពិភាក្សាលើបញ្ហាសំខាន់ៗ ដើម្បីមើលឃើញថា យើងអាចដោះស្រាយបាន ឬមិនបាន - ប៉ុន្តែ បើយើងដោះមិនបាន យ៉ាងហោចណាស់ក៏យើងអាចយល់បញ្ហាបានច្បាស់ដែរ"*[២៥៨] ។

*"យើងរកឃើញថា COPCEL មិនអាចធ្វើអ្វីច្រើនដើម្បីទប់ស្កាត់អំពើហឹង្សាទេ ប៉ុន្តែក៏មិនមែនជាកំហុសរបស់ COPCEL ដែរ វាជាឆន្ទៈរបស់ក្រសួងមហាផ្ទៃ និង គជប ដើម្បីធ្វើការងារ ។ ប៉ុន្តែ វាផ្តល់ឱកាសមួយឱ្យ NGOs ដើម្បីពិនិត្យឡើងវិញពីករណី និងធ្វើឱ្យពួកគេបានដឹងពីអ្វីដែលបានកើតឡើង ។ ចំលើយសឹងតែផ្ទុយគ្នាពីអ្វីដែលពួកគេបានរកឃើញ ប៉ុន្តែនេះជាចរិតនយោបាយរវាងក្រសួងមហាផ្ទៃ គណបក្សនយោបាយនានា និង គជប ។ ពួកគេគ្រាន់តែប្រកាសពីជំហររបស់ខ្លួន - ពួកគេត្រូវបានរារាំងដោយស្ថានភាពនយោបាយដ៏ធំទូលាយ"*[២៥៩] ។

ការបារម្ភដែលមានលើកជាទូទៅមួយទៀតក្នុងចំណោមអ្នកឆ្លើយសំភាសន៍មកពីគណបក្សនយោបាយ និង NGOs គឺ តើតំណាងរដ្ឋាភិបាលនៅក្នុង COPCEL មានអំណាចគ្រប់គ្រាន់តែដើម្បីផ្លាស់ប្តូរស្ថានភាព ។ រឿងនេះមានលើកជាពិសេសទាក់ទិននឹងបញ្ហាអំពើហឹង្សាខាងនយោបាយ ។ ថ្វីបើ គជប បានចូលរួមក្នុង COPCEL យ៉ាងទៀងទាត់ ប៉ុន្តែ គជប គ្មានការទទួលខុសត្រូវអ្វីទេក្នុងការដាក់ទោសជនល្មើស ដែលត្រូវធ្លាក់ទៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ អ្នកឆ្លើយសំភាសន៍មួយចំនួនមានអារម្មណ៍ថា ក្រសួងមហាផ្ទៃមិនបានបង្ហាញនូវការប្តេជ្ញា គាំទ្រគ្រប់គ្រាន់ទេចំពោះដំណើរការ COPCEL មិនបានបញ្ជូនមន្ត្រីមានឋានៈខ្ពស់គ្រប់គ្រាន់មកប្រជុំ ដូច្នេះហើយ ក៏បាត់បង់ឱកាសចូលមកទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនក្នុងការតាមចាប់ជនល្មើសៈ

*"ប៉ុន្តែ សមាជិក - អ្នកមានមុខមាត់សំខាន់ៗមកពី គជប ក្រសួងមហាផ្ទៃ ពួកគេមិនផ្តល់ចំលើយតបអ្វីច្រើន ហើយពួកគេមិនមែនជាអ្នកធ្វើសេចក្តីសំរេចចិត្តទេ ។ ពួកគេត្រូវការការប្តេជ្ញាចិត្តច្រើនថែមទៀតពីក្រសួងមហាផ្ទៃ និង គជប"*[២៦០] ។

អ្នកចូលរួមមួយចំនួនបានចោទសួរពីការប្តេជ្ញាចិត្តរបស់អ្នកដែលបានចូលរួម ដោយផ្តល់មតិថា ពួកគេមកប្រជុំដើម្បីលើកហេតុផលមកលាងខ្លួន មិនមែនមកដោះស្រាយបញ្ហាជាលក្ខណៈកសាងនោះទេ ។

*"គជប មកប្រជុំរាល់លើក ប៉ុន្តែយើងរកឃើញថា គជប មកដើម្បីតំណាង គជប - ពួកគេមកដើម្បីការពារអ្វីដែលពួកគេបានធ្វើ ។ គណបក្សនយោបាយភាគច្រើនបានទិតៀន គជប និងបានតវ៉ាពីការចុះបញ្ជីអ្នកបោះឆ្នោត និងការឃោសនា ។ នៅពេលពួកគេលើកសំនួរទាំងនេះឡើង គជប ព្យាយាមការពារខ្លួនដោយយោងទៅក្របខ័ណ្ឌច្បាប់ ។ ប៉ុន្តែក្នុងប្រទេសនេះ ច្បាប់អនុវត្តមិនបានសមស្របទេ ។ វាមិនត្រូវបានដាក់អនុវត្តទេ ។ ប៉ុន្តែមន្ត្រីថ្នាក់ខ្ពស់គ្រាន់តែលើកពីច្បាប់ដែលខុសគ្នាយ៉ាងខ្លាំងពីស្ថានភាពពិត"*[២៦១] ។

---

[២៥៨] Centre for Social Development representative (66), personal interview, Phnom Penh, 14 Aug. 2003.

[២៥៩] Cambodian Human Rights Centre Representative (55), personal interview, Phnom Penh, 13 Aug. 2003.

[២៦០] Cambodian Human Rights Centre Representative (55), personal interview, Phnom Penh, 13 Aug. 2003.

[២៦១] Cambodian Human Rights Centre Representative (55), personal interview, Phnom Penh, 13 Aug. 2003.

ការទិតៀននទាំងនេះខុសគ្នាយ៉ាងខ្លាំងពី មតិរបស់អ្នកឆ្លើយសំភាសន៍មួយក្រុមផ្សេងទៀតដែលលើកឡើងថា ជោគជ័យរបស់ COPCEL គឺវាអាចធ្វើឱ្យពួកមន្ត្រីថ្នាក់ខ្ពស់របស់អង្គការផ្សេងៗមកជួបជុំគ្នាបាន ។ ឧទាហរណ៍:

*"COPCEL មានសមត្ថភាពអូសទាញមនុស្សមកពីប្រភពខុសៗគ្នា - មកពីរដ្ឋាភិបាល គជប និងសង្គមស៊ីវិល ។ អ្នកអាចធ្វើដូច្នេះបាន មានមិនច្រើនទេ ។ នេះជាចំណុចពិសេសរបស់ COPCEL និង ឌិក សេរី សោភក្តិ ។ បើអ្នកគ្រាន់តែមានអង្គការ ប៉ុន្តែមានមនុស្សមិនត្រូវ វាដំណើរការមិនរួចទេ ។ អ្នកមិនអាចដាក់មនុស្សថ្នាក់តូច ឬខ្វះ បទពិសោធន៍ក្នុងមុខតំណែងនេះបានទេ"*[២៦២] ។

*"ជាការពិបាកណាស់ ក្នុងការធ្វើឱ្យគណបក្សនយោបាយដែលមានប្រវត្តិខុសៗគ្នា មកជួបជុំគ្នានៅលើតុមួយ និងស្តាប់ពីបញ្ហាដោយស្ងាត់ស្ងៀម ជាជាងប្រកាន់ជំហរប្រឈមមុខគ្នា និងរំជួលចិត្តខ្លាំង ។ COPCEL បង្កើតកិច្ចសន្ទនាជាលក្ខណៈកសាងធ្វើឱ្យយើងយល់ថាតើអ្នកជាប់ពាក់ព័ន្ធឯទៀតៗធ្វើការយ៉ាងដូចម្តេច ។ "ជួនកាលយើងអាចសំរបសំរួលការងាររបស់យើងបានកាន់តែល្អនៅពេលនោះ ។ ហើយវាអាចកសាងចំណងទាក់ទងរវាងអង្គការនានា"*[២៦៣] ។

ទស្សនៈខុសគ្នា ប្រហែលអាចមកពីការរំពឹងទុកវាខុសគ្នា ។ ជននានាដែលមើលឃើញគោលដៅចំបងនៃ COPCEL គឺជាការគ្រប់គ្រងទំនាស់យល់ឃើញថា ត្រូវមានតួអង្គខាងនយោបាយថ្នាក់ខ្ពស់ៗបំផុតដើម្បីធ្វើការឱ្យបានសក្តិសិទ្ធិក្នុងការដោះស្រាយបញ្ហា ។ បើសិនគ្មានការចូលរួមបែបនេះទេ គេអាចធ្វើអ្វីបានតិចតួចណាស់ដើម្បីកែកុនព្រឹត្តិការណ៍នៅនឹងកន្លែង ។ ផ្ទុយទៅវិញមនុស្សមួយចំនួនទៀតមើលឃើញទំនាស់ដែលបានកើតមានជាក់ស្តែង (យ៉ាងហោចណាស់ក៏មួយចំណែកដែរ) ថាជាលទ្ធផលនៃសមត្ថភាពក្នុងការធ្វើកិច្ចសន្ទនារវាងពួកអ្នកលេងល្បែងនយោបាយថ្នាក់ខ្ពស់ៗបំផុត ។ ដូច្នេះហើយ គេសំគាល់ការបោះជំហានទៅមុខក្នុងទិសដៅនេះថាជាផលសំរេចជាវិជ្ជមាន សំរាប់ការបង្កើតបរិយាកាសនយោបាយមួយដែលមិនសូវប្រទូសរ៉ាយគ្នាក្នុងពេលអនាគត ។

ចំណុចខ្វះខាតមួយទៀតរបស់ COPCEL ដែលតែងមានលើកឡើងជាទូទៅគឺ កង្វះលទ្ធភាពរបស់ពួកអ្នកឆ្លើយសំភាសន៍ក្នុងការបញ្ចុះបញ្ចូលសមាគីនានាឱ្យជឿតាមការយល់ឃើញរបស់ខ្លួនលើបញ្ហាអ្វីមួយ ។ ចំណុចពិបាកបំផុតគឺ អំពើហឹង្សាខាងនយោបាយដដែលនេះ ។ តំណាង NGO ម្នាក់លើកឡើងថា:

*"ជារឿយៗ COPCEL ស្វែងរកដំណោះស្រាយ ប៉ុន្តែអ្នកដែលអាចផ្តល់ដំណោះស្រាយមិនមែន COPCEL ទេគឺក្រសួងមហាផ្ទៃ និង គជប ហើយតាមពិតទៅ យើងមិនបានឃើញក្រសួងមហាផ្ទៃចូលរួមទេ ។ ទើបតែពេលមានករណីនៅខេត្តកំពង់ស្ពឺ និងព្រៃវែងទេ ដែលក្រសួងមហាផ្ទៃបានមកព្យាយាមពន្យល់ថា វាជាគ្រោះថ្នាក់ - ពួកគេគ្រាន់តែមកពិពណ៌នាព្រឹត្តិការណ៍ថាជាគ្រោះថ្នាក់ប៉ុណ្ណោះ ។ យើងមិនអាចបញ្ចុះបញ្ចូលពួកគេបានទេ"*[២៦៤] ។

តំណាងម្នាក់ខាងស្ថាប័នរដ្ឋ បានលើកប្រហាក់ប្រហែលគ្នាថា:

*"មានបញ្ហា (អំពើហឹង្សាខាងនយោបាយ) ជាច្រើនត្រូវបានលើកឡើងក្នុង COPCEL... ពេលនោះយើងមានកាតព្វកិច្ចត្រូវទៅ និងធ្វើការស្រាវជ្រាវ ។ យើងស្តាប់ព្រឹត្តិមានក្នុង COPCEL ហើយយើងធ្វើការទាក់ទងជាមួយខេត្តនានាពីករណីដែលបានផុសឡើងក្នុងខេត្តនេះ ស្រុកនេះ ថ្ងៃនេះ និងនៅពេល... ។ ជួនកាល ភាគីនានា*

---

[២៦២] FUNCINPEC national representative (65), personal interview, Phnom Penh, 12 Aug. 2003.

[២៦៣] National Democratic Institute representative (70), personal interview, Phnom Penh, 13 Aug. 2003.

[២៦៤] Cambodian Human Rights Centre representative (55), personal interview, Phnom Penh, 13 Aug. 2003.

*បានពេញចិត្ត ។ ប៉ុន្តែ ជួនកាលពួកគេនៅតែយល់ថា មានមូលហេតុខាងនយោបាយ ។ នេះជាបញ្ហាមួយ - យើងពន្យល់ពីរឿងពិតទទួលបានពីមហាជន និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែពួកគេជួនកាលមិនពេញចិត្តទេ... យើងតាមពិនិត្យជានិច្ចនូវការតវ៉ារបស់គ្រប់គណបក្សនយោបាយ ប៉ុន្តែជួនកាលវាពិបាក ពីព្រោះ ពេលខ្លះគណបក្សនយោបាយចចេសខ្លាំងណាស់ និងមិនយល់ពីកំហុសរបស់ខ្លួនទេ"*[២៦៥] ។

ក្នុងមតិលើកឡើងទាំងនេះ ការយល់ឃើញខុសៗគ្នាពី "ការពិត" អាចពិនិត្យឃើញយ៉ាងច្បាស់ ។ គួរកត់សំគាល់ថា មតិទាំងនេះលើកឡើងដោយយោងដល់ករណីអំពើហឹង្សាខាងនយោបាយ ដែលប្រហែលជាបញ្ហាមានការខ្វែងមតិគ្នាខ្លាំងនៃការបោះឆ្នោត ។ ក្នុងទំនាស់ផ្សេងៗទៀត អ្នកឆ្លើយសំភាសន៍មួយចំនួនអាចលើកបង្ហាញពីករណីនានាដែល COPCEL បានជួយឱ្យមានការផ្លាស់ប្តូរ ។ ឧទាហរណ៏មួយដែល ៤នាក់ ( SRP ១នាក់, CPP ១នាក់, និង NGOs ២នាក់) ក្នុងចំណោមអ្នកឆ្លើយសំភាសន៏១៥នាក់ បានលើកឡើង គឺរឿងសេចក្តីប្រកាសរបស់ គជប និងក្រសួងមហាផ្ទៃ ស្តីពីតួនាទីរបស់ប្រធានភូមិៈ

*"ពួកគេមិនដែលធ្វើសេចក្តីសំរេចអ្វីក្នុងអង្គប្រជុំថា តើត្រូវធ្វើយ៉ាងណាដើម្បីទប់ស្កាត់ទំនាស់នោះទេ ។ ប៉ុន្តែ មានសេចក្តីប្រកាសរួមមួយរបស់ គជប និងក្រសួងមហាផ្ទៃ ដាក់បញ្ជាឱ្យពួកមន្ត្រីស្ថិតនៅជាអព្យាក្រឹត្យ ។ រឿងនេះមួយចំណែកបានមកដោយសារ COPCEL – COPCEL ដាក់សំពាធលើរដ្ឋាភិបាលឱ្យចេញលិខិតនោះ ។ ហើយបទពិសោធន៏របស់យើងក្នុងរឿងនេះ គឺលិខិតនោះល្អខ្លាំងណាស់"*[២៦៦] ។

ប៉ុន្តែក្នុងចំណុចជាមូលដ្ឋានខ្លះៗ ការតស៊ូមតិរបស់សង្គមស៊ីវិលមិនបានជោគជ័យទេ ។ ទី១ ជំហររបស់ គជប និងក្រសួងមហាផ្ទៃ អំពីការស៊ើបអង្កេតពីអំពើហឹង្សាក្នុងរយៈពេលបោះឆ្នោត និងឥរិយាបថរបស់ NGOs ក្នុងរឿងនេះ នៅតែមិនស៊ីគ្នាជាមូលដ្ឋាន ។ គ្មានការកសាងទំនុកចិត្តលើរបៀបស៊ើបអង្កេតរបស់ក្រសួងមហាផ្ទៃទេ ហើយក៏គ្មានកកើតទំនុកចិត្តអ្វីទៅលើសេចក្តីប្រកាសរបស់ពួកគេដែរ ។ ទី២ ជំហររបស់ គជប និង NGOs អំពីមធ្យោបាយដ៏សមស្របបំផុតសំរាប់ចាត់ចែងលើការរំលោភលើបទប្បញ្ញត្តិផ្សេងៗនៅតែខុសគ្នាយ៉ាងខ្លាំង ។ គជប បន្តអនុវត្តវិធីសាស្រ្តដែលសង្កត់ធ្ងន់លើការសំរបសំរួលយោងតាមកង្វះសិទ្ធិអំណាចរបស់ គជប ទៅលើតួអង្គនានាដែលនៅខាងក្រៅ គជប ហើយនិងការយកចិត្តទុកដាក់ធំបំផុតក្នុងការរក្សាសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់ ដែលគេយល់ថាត្រូវមានជាចាំបាច់សំរាប់ជោគជ័យនៃការបោះឆ្នោត ។ ផ្ទុយទៅវិញ NGOs ទាមទារឱ្យចាត់ចែងលើការរំលោភផ្សេងៗ ដោយអនុវត្តវិធីសាស្រ្តផ្អែកលើអំណាចនៃច្បាប់ ។ ពួកគេទាមទារឱ្យដាក់ទោសអ្នកប្រព្រឹត្តបទល្មើស ជាពិសេសបើសិនជាសកម្មភាពឧក្រិដ្ឋ ឬការរំលោភសិទ្ធិមនុស្ស ។ ការប្រើប្រាស់ដំណើរការសំរបសំរួល និងផ្សះផ្សាររវាងអ្នកប្រព្រឹត្តបទល្មើសនិងការរំលោភបំពាន ហើយនិងជនរងគ្រោះ, ពួក NGOs មើលឃើញថាជាការគេចវេសរបស់ គជប ពីការទទួលខុសត្រូវការពារសិទ្ធិអ្នកបោះឆ្នោតទាំងអស់គ្នា ។ បញ្ហានេះបានគូសរំលេចម្តងទៀតពីសារៈសំខាន់របស់ក្រសួងមហាផ្ទៃដែលទទួលខុសត្រូវធ្វើការស៊ើបអង្កេតនិងប្តឹងដាក់ទោសលើបទល្មើសព្រហ្មទណ្ឌ និងភាពទន់ខ្សោយរបស់ គជប ធៀបទៅនឹងក្រសួងមហាផ្ទៃ ។

## ៥.២ សេចក្តីសន្និដ្ឋាន

### *៥.២.១ ស្ថាប័ននានាក្នុងការបោះឆ្នោតនៅកម្ពុជា*

ដូចនៅឆ្នាំ១៩៩៨ ដែរ ការសិក្សានេះរកឃើញថា ភាពទន់ខ្សោយខាងស្ថាប័ននៅតែជាឧបសគ្គមួយដ៏ធំ ចំពោះការគ្រប់គ្រងទំនាស់ឱ្យបានសក្តិសិទ្ធិក្នុងការបោះឆ្នោតនៅកម្ពុជា ។ ធៀបនឹងឆ្នាំ១៩៩៨ យើងរកឃើញថា ទិដ្ឋភាពខាងស្ថាប័នដូចតទៅ

---

[២៦៥] Ministry of National Defence representative (9) personal interview, Phnom Penh, 11 July 2003.

[២៦៦] Cambodian Human Rights Centre representative (55), personal interview, Phnom Penh, 13 Aug. 2003.

នេះបានកែលំអឡើង ដែលបានពង្រឹងអារម្មណ៍ផ្សារភ្ជាប់គ្នារវាងតួអង្គខាងនយោបាយ និងស្ថាប័ន និងបានកាត់បន្ថយការមិនទុកចិត្តគ្នារវាងគណបក្សនយោបាយនានា:

- ការចូលរួមកាន់តែធំទូលាយក្នុងការតាក់តែង និងអនុម័តច្បាប់ និងបទប្បញ្ញត្តិបោះឆ្នោតផ្សេងៗ បានបង្កើនយ៉ាងច្រើននូវលក្ខណៈពេញច្បាប់នៃក្របខ័ណ្ឌច្បាប់ ដែលបានជួយពង្រឹងជាបន្តមកទៀតនូវលក្ខណៈពេញច្បាប់នៃស្ថាប័ន និងដំណើរការផ្សេងៗ
- ពតិមានលំអិតពីច្បាប់ និងបទប្បញ្ញត្តិបោះឆ្នោត បានបង្កើនយ៉ាងច្រើននូវតំលាភាពនៃការធ្វើសេចក្តីសំរេចចិត្ត និងកាត់បន្ថយលទ្ធភាពស្ថាប័ននានាក្នុងការធ្វើសកម្មភាពតាមអំពើចិត្ត ដែលបានបង្កើនការមិនទុកចិត្តពីសំណាក់គណបក្សនយោបាយទាំងឡាយ
- របៀបរបបធ្វើការងាររបស់ គជប នៅកំរិតជាតិ ជាពិសេសមុនថ្ងៃបោះឆ្នោត និងដោយឡែកកំណើនលទ្ធភាពរបស់គណបក្សនយោបាយ និង NGOs ក្នុងការជួបទាក់ទងជាមួយ គជប, មានសារៈសំខាន់ច្រើនក្នុងការពង្រឹងអារម្មណ៍ផ្សារភ្ជាប់គ្នារវាងតួអង្គខាងនយោបាយ និងស្ថាប័ន
- រឿងនេះក៏ត្រឹមត្រូវសំរាប់កំរិតឃុំដែរ ប៉ុន្តែក្នុងកំរិតតូចជាង នៅតាមឃុំនានាដែលយើងបានចុះសិក្សា
- ការផុសឡើងនូវក្រុមប្រឹក្សាឃុំពហុគណបក្ស បានជួយឱ្យ SRP មានវត្តមានច្រើនជាងមុននៅកំរិតមូលដ្ឋាន ដែលបានជួយបង្កើនអារម្មណ៍ផ្សារភ្ជាប់របស់ SRP ទៅនឹងដំណើរការបោះឆ្នោត

យើងរកឃើញថា ទិដ្ឋភាពខាងស្ថាប័នដូចខាងក្រោម បានធ្វើឱ្យខូចខាតដល់អារម្មណ៍ផ្សារភ្ជាប់រវាងតួអង្គខាងស្ថាប័ន និងខាងនយោបាយ ដែលបានបង្កើនការមិនទុកចិត្តគ្នា និងកាត់បន្ថយលទ្ធភាពធ្វើការគ្រប់គ្រងទំនាស់ឱ្យបានសក្តិសិទ្ធិ:

- ភាពទន់ខ្សោយខ្លាំងជាបន្តរបស់ស្ថាប័ននានាក្រៅពី គជប: ឧទាហរណ៍ កង្វះទំនុកចិត្តចំពោះក្រសួងមហាផ្ទៃជាពិសេសពីសំណាក់គណបក្សជំទាស់, លក្ខណៈមិនពេញច្បាប់នៃប្រធានភូមិដែលមិនត្រូវបានបោះឆ្នោតជ្រើសតាំងសោះក្នុង ២០ឆ្នាំកន្លងមក, និងកង្វះបទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាឃុំ ។ បញ្ហាមានចោទជាពិសេសគឺតួអង្គខាងនយោបាយមួយចំនួនដែលនៅតែមានចំណាប់អារម្មណ៍ថា ស្ថាប័នរដ្ឋ ដូចជា ប៉ូលីស និងតុលាការជាដើម មានលក្ខណៈកំរោល លំអៀងខាងនយោបាយ និងពុករលួយ
- វង្វង់ដ៏តូចនៃដែនសមត្ថកិច្ច និងសិទ្ធិអំណាចរបស់ គជប ក្នុងវិស័យខ្លះៗ: ឧទាហរណ៍ ចំពោះប្រព័ន្ធផ្សព្វផ្សាយ ប្រធានភូមិ ស្ថាប័ន និងពួកមន្ត្រី ដែលរំលោភលើក្រមសីលធម៌បោះឆ្នោត ។ រឿងនេះកាន់តែធ្ងន់ធ្ងរឡើងដោយសារ គជប និង គឃប មាននិន្នាការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់ដែលសង្កត់ធ្ងន់លើកង្វះទំនុកចិត្តលើសិទ្ធិអំណាចរបស់ខ្លួនផ្ទាល់ - ឧទាហរណ៍ ការបន្តប្រើប្រាស់មធ្យោបាយផ្សះផ្សារ ជាជាងការដាក់ទោស
- កង្វះខាតជាបន្តនៃការត្រួតពិនិត្យលើ គជប ខ្លួនឯង: ឧទាហរណ៍តាមរយៈការបង្កើតស្ថាប័នឯករាជ្យមួយសំរាប់តែងតាំងពួកសមាជិក គជប និងស្ថាប័នឯករាជ្យមួយទៀតសំរាប់ដោះស្រាយបណ្តឹងតវ៉ា
- កង្វះតំលាភាពក្នុងចំណុចសំខាន់ៗមួយចំនួននៃនីតិវិធីបោះឆ្នោត: ឧទាហរណ៍ ការតែងតាំង គខប និង គឃប និងការ ដោះស្រាយបណ្តឹងតវ៉ា
- ការតាក់តែងរចនានីតិវិធីគ្រប់គ្រងទំនាស់បានផ្តោតលើគណបក្ស ហើយមិនបានគិតគូរជាប់រហូតទៅពីទស្សនៈផ្អែកលើសិទ្ធិ ។

ចំណុចខ្សោយទាំងនេះ បង្ហាញពីបញ្ហាខាងរចនាសម្ព័ន្ធមួយចំនួនដែលចោទជាបន្ត និងដែលរារាំងដល់ដំណើរការនៃស្ថាប័នកម្ពុជានានា ដូចជា:

- កង្វះការបែងចែកដាច់រវាង រដ្ឋ និង គណបក្ស ជាពិសេសនៅកំរិតមូលដ្ឋាន
- កង្វះទំនុកចិត្តលើអព្យាក្រឹតភាពនៃស្ថាប័នរដ្ឋនានា និង
- ការអនុវត្តន៍សិទ្ធិអំណាចមិនគ្រប់គ្រាន់ពីសំណាក់ស្ថាប័ននានាចំពោះតួអង្គខាងនយោបាយ ។

គួរកត់សំគាល់ថា រឿងទាំងអស់នេះមិនមែនគ្រាន់តែជាបញ្ហាខាងបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែវាមានសារៈសំខាន់ជាមូលដ្ឋានសំរាប់ការកសាងរបបប្រជាធិបតេយ្យក្នុងជីវភាពខាងសង្គមកិច្ច នយោបាយ និងសេដ្ឋកិច្ចនៅកម្ពុជា ។ គួរកត់សំគាល់ទៀតថា កម្មវិធីដ៏មានជោគជ័យមួយក្នុងចំណោមកម្មវិធីសំដៅធ្វើការកែលំអនានា ក្នុងការបោះឆ្នោតឆ្នាំ២០០៣ (កម្មវិធីសមធម៌ដើម្បីដោះស្រាយបញ្ហាលំអៀងខាងនយោបាយក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ) ត្រូវបានបោះបង់ចោលវិញភ្លាមៗក្រោយពេលបោះឆ្នោត ដោយមានការតវ៉ាខ្លះៗដែរ ប៉ុន្តែមានការប្រឆាំងជាក់ស្តែងតិចតួចណាស់ពីសំណាក់ទស្សនិកជន ឬបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។ ថ្វីបើកម្មវិធីសមធម៌មានជោគជ័យ ក្នុងការលើកកំពស់លក្ខណៈពេញច្បាប់នៃការបោះឆ្នោតក្តី ប៉ុន្តែមានកំហិតជាមូលដ្ឋានខាងសេដ្ឋកិច្ច និងនយោបាយ ដែលរារាំងការអនុវត្តន៍កម្មវិធីបែបនេះជាបន្ត ដើម្បីជួយសំរួលដល់ដំណើរការកសាងរបបប្រជាធិបតេយ្យឱ្យកាន់តែធំទូលាយទៀត ។ ដូចគ្នាដែរ សេចក្តីណែនាំពីក្រសួងមហាផ្ទៃ និង គជប ឱ្យពួកប្រធានភូមិប្រកាន់ជំហរអព្យាក្រឹត្យក្នុងរយៈពេលឃោសនាបោះឆ្នោត បានគូសបញ្ជាក់ពីការពិតដែលប្រធានភូមិកំរស្ថិតនៅជាអព្យាក្រឹត្យណាស់ក្នុងរយៈពេលផ្សេងៗទៀតនៃវដ្តបោះឆ្នោត ។ ការធ្វើឱ្យករិយាធិបតេយ្យក្លាយជាអព្យាក្រឹត្យ វាមានសារៈសំខាន់ជាមូលដ្ឋានសំរាប់ការកសាងរបបប្រជាធិបតេយ្យ និងការធានាសិទ្ធិស្មើគ្នារបស់ប្រជាពលរដ្ឋ ហើយកង្វះអព្យាក្រឹតភាពជាបន្តនៅក្នុងស្ថាប័នរដ្ឋ គឺជាឧបសគ្គចំបងមួយចំពោះដំណើរការនេះ ។

ដូចគ្នាដែរ និន្នាការរបស់តួអង្គខាងនយោបាយក្នុងការគ្របសង្កត់ទៅលើស្ថាប័ននានា អាចមើលឃើញយ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់ដែលបណ្តាស្ថាប័នបោះឆ្នោតបានប្រើប្រាស់ក្នុងពេលបោះឆ្នោតនៅកម្ពុជា ។ ការផ្តោតលើការសំរបសំរួល ជាជាងលើការកាត់ក្តីលើទំនាស់ផ្សេងៗដោយ គជប គឺជាឧទាហរណ៍មួយក្នុងរឿងនេះ។ គជប មើលឃើញក្នុងចំណុចនេះនូវការគ្របសង្កត់របស់តួអង្គខាងនយោបាយនានាដែលអាចបង្កអស្ថិរភាពខាងនយោបាយ និងសង្គមកិច្ចបាន ដូច្នេះត្រូវតែចាត់ចែងយ៉ាងប្រុងប្រយ័ត្ន ។ ប៉ុន្តែការបន្តពឹងផ្អែកលើការតថ្លៃគ្នារវាងតួអង្គខាងនយោបាយ វាប៉ះពាល់មិនល្អដល់ការអភិវឌ្ឍន៍ស្ថាប័ន ហើយវាបន្តសិទ្ធិអំណាចរបស់តួអង្គខាងនយោបាយ ក្នុងការគំរាមកំហែងដល់សន្តិសុខរបស់រដ្ឋ ។ ការផ្លាស់ប្តូរពីការត្រួតត្រាដោយគណបក្ស ទៅជាការត្រួតត្រាដោយស្ថាប័ន និងច្បាប់វិញ វានឹងអនុញ្ញាតឱ្យមានការកសាងដំណើរការគ្រប់គ្រងទំនាស់ផ្សេងៗដែលអាចដាក់អនុវត្តបានស្មើភាពគ្នា និងតាមបែបបទគ្មានការរើសអើងទៅលើគ្រប់ជនល្មើស ។

### ៥.២.២ ផលប៉ះពាល់នៃភាពទន់ខ្សោយខាងស្ថាប័នទៅលើការកសាងសហគមន៍នយោបាយ

រឿងដែលថា គណបក្សទាំងអស់មានចំណាប់អារម្មណ៍កាន់តែរឹងប៉ឹងក្នុងការផ្សារភ្ជាប់ខ្លួនទៅនឹងសហគមន៍នយោបាយ គឺមិនទាន់មានភស្តុតាងបង្ហាញច្បាស់ទេ ។ ទី១ ចំណាប់អារម្មណ៍អំពីពហុបក្សគឺមានកាន់តែច្រើនហើយ រហូតដល់កំរិតភូមិ គឺបានន័យថា អាជ្ញាធរមូលដ្ឋានបានរីកលូតលាស់ជំហរចេះអត់ឱនគ្នា ។ ករណីសិក្សានៅឃុំតាខែន បានបង្ហាញឧទាហរណ៍មួយយ៉ាងច្បាស់នៃកំណើនការអត់ឱនសំរាប់គណបក្សជំទាស់ ថ្វីបើវាមានកំរិតព្រំដែនក៏ដោយ ។ ទី២ នៅតាមកន្លែងជាច្រើន គូប្រកួតប្រជែងខាងនយោបាយមិនបានរួមរស់ជាមួយគ្នាយ៉ាងស្រួល ឬយ៉ាងសុខសប្បាយនោះទេ ហើយជ្រោះជ្រៅដែលបែងចែកពួកគេអាចមើលឃើញតាមទំនាស់ជាប្រចាំស្តីពីអ្នកបោះឆ្នោត "វៀតណាម" និងការចោទប្រកាន់ការគំរាមកំហែងដកហូតដីធ្លីរបស់អ្នកប្រឆាំងខាងនយោបាយ ។

ការទាត់ចោលលទ្ធផលដោយ SRP និង FUNCINPEC នៅឆ្នាំ២០០៣ ផ្អែកលើការអះអាងមួយចំនួនៈ

- អ្នកបោះឆ្នោតមានសិទ្ធិ ៥សែននាក់ មិនអាចចុះបញ្ជីបានដោយសារ "ឧបសគ្គ" បង្កដោយ គជប
- អ្នកបោះឆ្នោតចុះបញ្ជី ១លាននាក់មិនអាចបោះឆ្នោតបាន ដោយសារ "កលល្បិច" របស់ គជប ដូចជា "ការអនុញ្ញាតឱ្យដកហូតប័ណ្ណបោះឆ្នោត, ការប្តូរទីតាំងការិយាល័យបោះឆ្នោតដោយគ្មានផ្តល់ដំណឹងមុនគ្រប់គ្រាន់, បញ្ជីបោះឆ្នោតមានកំហុសពាសពេញធ្វើឱ្យអ្នកបោះឆ្នោតច្រើនណាស់មិនអាចរកឈ្មោះខ្លួនឃើញ, និងការលុបឈ្មោះដោយមិនសមស្របចេញពីបញ្ជីអ្នកបោះឆ្នោត"
- អ្នកបោះឆ្នោតច្រើនសែននាក់ទទួលការគំរាមកំហែងពីអាជ្ញាធរមូលដ្ឋានដែលដើរតួជា "ឧបករណ៍" របស់ CPP ដែលឃុបឃិតជាមួយ គជប
- អ្នកបោះឆ្នោតច្រើនសែននាក់បានបោះឆ្នោតតាមមនសិការរបស់ខ្លួន ប៉ុន្តែឆ្នោតរបស់ពួកគេត្រូវបាន "លួច ឬកែបន្លំ" ដោយសារ គជប "មិនបានអនុវត្តភារកិច្ចរបស់ខ្លួន" និង
- អ្នកបោះឆ្នោតច្រើនសែននាក់បានក្លាយជាគោលដៅនៃការទិញសន្លឹកឆ្នោត ឬក៏ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងពិធីស្បថស្បែ ។

ការតវ៉ាទាំងនេះ មួយភាគធំស្រដៀងគ្នានឹងកាលពីឆ្នាំ១៩៩៨ ប៉ុន្តែវិបត្តិដែលបន្តពីការទាត់ចោលលទ្ធផល វាមិនធ្ងន់ធ្ងរដូចនៅឆ្នាំ១៩៩៨ ទេ ។ ពុំមានការធ្វើបាតុកម្មទេ ប៉ុន្តែរឿងនេះមួយភាគធំប្រហែលមកពីការដាក់ពង្រាយកងទ័ពយ៉ាងលឿននៅតាមកន្លែងសាធារណៈធំៗក្នុងទីក្រុង និងតាមផ្លូវជាតិចំបងៗមកកាន់ក្រុងភ្នំពេញ ។ បណ្តឹងតវ៉ាមានដាក់តិចជាងមុន ហើយវាផ្តោតខ្លាំងជាងមុនទៅលើបញ្ហាផ្សេងៗដែលអាចប៉ះពាល់ដល់លទ្ធផលបោះឆ្នោត ។ ប៉ុន្តែ SRP និង FUNCINPEC បានរក្សាជំហររបស់ខ្លួនថា ស្ថាប័នទាំងឡាយរបស់រដ្ឋនៅតែជាឧបករណ៍របស់ CPP ហើយប្រជាជនត្រូវបានបំភិតបំភ័យឱ្យបាត់មាត់ដោយសារក្រញាំរបស់រដ្ឋ និងគណបក្សនៅលើជីវិតរបស់ពួកគេ ។ នៅឆ្នាំ២០០៣ ក៏ដូចជានៅឆ្នាំ១៩៩៨ ដែរ SRP និង FUNCINPEC បានរកឃើញចរិតគំរាមកំហែងរបស់ CPP ក្នុងបុគ្គលដែលជានាយករដ្ឋមន្ត្រី ហើយពួកគេបានបញ្ជាក់ទាមទារអស់៣ខែមកហើយថា ពួកគេមិនចូលរួមក្នុងរដ្ឋាភិបាលណាមួយដែលដឹកនាំដោយបុគ្គលនេះទេ ។ ទំហំនៃការខ្វែងគំនិតគ្នារវាង SRP និង ហ៊ុន សែន អាចមើលឃើញតាមលិខិតមួយដែល សម រង្ស៊ី បានធ្វើថ្វាយព្រះមហាក្សត្រកាលពីថ្ងៃ ១៥ កញ្ញាៈ

> *"ច្រើនថ្ងៃថែមទៀតដែលត្រូវការសំរាប់ការរាប់សន្លឹកឆ្នោតដូចដែល SRP បានស្នើសុំ នឹងមិនបង្កការលំបាកថែមទៀត ចំពោះប្រជាជនកម្ពុជាទេ ពីព្រោះពួកគេបានឈឺចាប់ខ្លាំងណាស់ហើយនៅក្នុងប្រទេសមួយដែលកំពុងស្លាប់ទៅដោយយឺតៗ ។ ការកោះប្រជុំឡើងវិញនូវរដ្ឋសភាគួរឱ្យសង្ស័យមួយ ឬការបង្កើតរដ្ឋាភិបាលថ្មីមួយដែលដឹកនាំដោយអ្នកដឹកនាំពុករលួយដដែលៗ និងដែលអនុវត្តគោលនយោបាយហិនហោចដដែលៗ នឹងមិនអាចសំរាលការឈឺចាប់របស់ប្រជាជនយើង ឬក៏ពន្យាពេលស្លាប់របស់ប្រជាជាតិយើងបានដែរ"*[២៦៧] ។

ការបារម្ភថាប្រទេសជាតិកំពុង "ស្លាប់ទៅ" គេធ្លាប់បានឮនៅក្នុងមជ្ឈដ្ឋាននយោបាយកម្ពុជាជាច្រើនជំនាន់មកហើយ ហើយគូភាគីនានាក៏ធ្លាប់ប្រើប្រាស់វា ដើម្បីបដិសេធលក្ខណៈពេញច្បាប់របស់គូប្រឆាំង និងជំទាស់ពីសិទ្ធិរបស់គូប្រឆាំងដើម្បីចូលរួមក្នុងឆាកនយោបាយ ។ ការភ័យខ្លាចប្រជាជាតិធ្លាក់ចុះ ដែលឃើញមានយ៉ាងច្រើនទាំងនៅកំរិតមូលដ្ឋាន និងកំរិតជាតិ ធ្វើឱ្យជំហរប្រឆាំងគ្នាកាន់តែចាក់ឫសមាំ និងធ្វើឱ្យការសំរុះសំរួលជួបការពិបាក ។ ការភ័យខ្លាចដែលផុសចេញពីបញ្ហាពិតៗ និងគួរឱ្យខ្លាច ដូចជា ការរាលដាលជំងឺអេដស៍ និងការបាត់បង់ព្រៃឈើ និងអំពីបញ្ហាដែលមិនសូវមានឯកសារបញ្ជាក់ច្បាស់ដូចជា លំហូរ

---

[២៦៧] Sam Rainsy, Letter to His Majesty the King of Cambodia, Phnom Penh, 15 Sept 2003.

ចូលជនអន្តោប្រវេសន៍ខុសច្បាប់ជាដើម វាធ្វើឱ្យគាំងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា និងអនុញ្ញាតឱ្យមានការលើកកំពស់ផលប្រយោជន៍របស់គណបក្សថា ស្មើគ្នានឹងផលប្រយោជន៍របស់ជាតិ ។

ការបង្កើតស្ថាប័នផ្សេងៗដែលអាចរក្សាសណ្តាប់ធ្នាប់ និងទទួលបានការគោរពនៅក្នុងបរិស្ថានបែបនេះ គឺជាការលំបាក ។ ប៉ុន្តែស្ថាប័នដែលគេគោរពនានា បើសិនធ្វើការបានល្អក្នុងការដាក់អនុវត្តន៍នីតិវិធីឱ្យបានស្មើភាព គឺអាចជួយកាត់បន្ថយសតិអារម្មណ៍ដែលថានឹងមានគ្រោះអាសន្នឆាប់ៗ ។ ការបោះឆ្នោតឆ្នាំ២០០៣ បានបង្ហាញថា ស្ថាប័នបោះឆ្នោតនៅកម្ពុជា សំរេចការងារបានច្រើនណាស់ ប៉ុន្តែនៅមានការងារច្រើនទៀតដែលត្រូវធ្វើឱ្យបាន ។

### *៥.២.៣ មេរៀនទទួលបានពីយុទ្ធសាស្ត្រគ្រប់គ្រងទំនាស់*

ផលប៉ះពាល់នៃបញ្ហាខាងស្ថាប័នទាំងនេះទៅលើការងារគ្រប់គ្រងទំនាស់ មានលក្ខណៈជ្រាលជ្រៅណាស់ ដូចដែលការសិក្សានេះបានបង្ហាញឱ្យឃើញ ។ មេរៀនទទួលបានពីករណីសិក្សាលើទំនាស់ផ្សេងៗដូចមានពិភាក្សាក្នុងកសារនេះ គឺអាចប្រមូលផ្តុំជាលក្ខណៈវិនិច្ឆ័យខ្លីៗមួយចំនួនសំរាប់ធ្វើការវាយតំលៃពីជោគជ័យ ឬការបរាជ័យជាយថាហេតុនៃវិធានការគ្រប់គ្រងទំនាស់នានា ។

ការគ្រប់គ្រងទំនាស់មានជោគជ័យក្នុងករណីដែលៈ

- មានការឯកភាពគ្នាពីចរិតនៃទំនាស់
- មានការឯកភាពគ្នាពីយន្តការសមស្របសំរាប់គ្រប់គ្រងទំនាស់
- អ្នកគ្រប់គ្រងទំនាស់មានសិទ្ធិអំណាចសមស្របសំរាប់អនុវត្តដំណើរការគ្រប់គ្រងទំនាស់ ទោះបីក្នុងនេះត្រូវមានការដាក់ទោសលើអ្នកប្រព្រឹត្តខុសដែលមកពីស្ថាប័នផ្សេងក៏ដោយ
- មានការឯកភាពគ្នាពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងជោគជ័យ និង
- យន្តការនានាសំរាប់គ្រប់គ្រងទំនាស់ត្រូវបានដាក់អនុវត្តយ៉ាងមានប្រសិទ្ធភាព មានតំលាភាព និងអាចទាក់ទងប្រើប្រាស់បាន ។

ក្នុងករណីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយស្មើភាព លក្ខខណ្ឌទាំងអស់នេះគឺអាចបំពេញបានៈ

- ទំនាស់ចំបងទាក់ទិននិងចំនួនពេលផ្សាយតាមទូរទស្សន៍ និងវិទ្យុ
- ដំណោះស្រាយដែលលេចធ្លោគឺ រកវិធីផ្តល់ពេលវេលាច្រើនថែមទៀតដល់គណបក្សនានាដែលត្រូវចាញ់ប្រៀបគេ
- គជប និងពួកដៃគូជា NGOs និងអង្គការអន្តរជាតិផ្សេងៗ មានលទ្ធភាពប្រើប្រាស់ទូរទស្សន៍ និងវិទ្យុរដ្ឋ ដើម្បីផលិតនិងផ្សព្វផ្សាយកម្មវិធីនានារបស់ខ្លួន
- ការតាមដានប្រព័ន្ធផ្សព្វផ្សាយដោយពួកអ្នកតាមដានក្នុងស្រុក និងអន្តរជាតិ ផ្តល់ការវាយតំលៃយ៉ាងច្បាស់លាស់ពីស្ថានភាព ជាពិសេសចំនួនពេលផ្សាយសំរាប់គណបក្សនិមួយៗ ចំណែកឯរឿងគុណភាពគឺ ពិបាកតាមដានជាង
- ចរិតនៃប្រព័ន្ធផ្សព្វផ្សាយមានន័យថា គណបក្សទាំងអស់អាចតាមដានពីលទ្ធផលដោយខ្លួនឯង ។

ការគ្រប់គ្រងទំនាស់ត្រូវបរាជ័យក្នុងករណីដែលៈ

- គ្មានការឯកភាពគ្នាពីចរិតនៃទំនាស់
- គ្មានការឯកភាពគ្នាពីយន្តការសមស្របសំរាប់គ្រប់គ្រងទំនាស់

- អ្នកគ្រប់គ្រងទំនាស់មិនច្បាស់លាស់ពីសិទ្ធិអំណាចរបស់ខ្លួន សំរាប់អនុវត្តដំណើរការគ្រប់គ្រងទំនាស់, បើសិនមានលទ្ធភាពច្រើនថា នឹងមានការប្រឆាំងពីស្ថាប័នឯទៀតៗ
- គ្មានការឯកភាពគ្នាពីលក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងជោគជ័យ និង
- យន្តការនានាសំរាប់គ្រប់គ្រងទំនាស់ត្រូវបានដាក់អនុវត្តយ៉ាងអន់ខ្សោយ ខ្វះតំលាភាព និងមិនអាចទាក់ទងប្រើប្រាស់បាន ។

ក្នុងករណីទំនាស់ទាក់ទិននឹងប្រធានភូមិ គឺមានគ្រប់លក្ខខណ្ឌទាំងអស់សំរាប់ការគ្រប់គ្រងទំនាស់មិនបានជោគជ័យៈ

- គ្មានការឯកភាពគ្នាពីចរិតនៃទំនាស់ៈ តើវាមានទំរង់យ៉ាងដូចម្តេច? តើវាមានច្រើនប៉ុណ្ណា? តើមានទំនាក់ទំនងអ្វីរវាងប្រធានភូមិ និងប្រជាជន?
- គ្មានការឯកភាពគ្នាពីវិធីប្រសើរបំផុតសំរាប់គ្រប់គ្រងទំនាស់ៈ ផាត់ប្រធានភូមិចេញពីដំណើរការបោះឆ្នោត? (បើដូច្នេះមែន តើត្រូវធ្វើយ៉ាងដូចម្តេច?) ឬក៏ដាក់ការគ្រប់គ្រងលើតួនាទីរបស់ពួកគេ តាមរយៈសេចក្តីណែនាំ? ធ្វើទោស ឬសំរុះសំរួល?
- ក្នុងច្បាប់បោះឆ្នោត គ្មានការបញ្ជាក់ច្បាស់ទេពីសិទ្ធិអំណាចរបស់ គជប ទៅលើប្រធានភូមិ ថ្វីបើ គជប និយាយថា កិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ មានលទ្ធផលជាវិជ្ជមាន
- គ្មានការឯកភាពគ្នាពីវិធានការវាស់វែងជោគជ័យទេ ជាពិសេស គជប មិនបានដាក់ទោសប្រធានភូមិណាម្នាក់ទេ ហើយលក្ខណៈធ្ងន់ធ្ងរនៃស្ថានភាពនៅតែមានការប្តឹងតវ៉ា
- ការសំរុះសំរួលនៅក៏រិតមូលដ្ឋាន ជាពិសេសដោយ គឃប អនុវត្តមិនបានស៊ីសង្វាក់គ្នា មានឯកសារបញ្ជាក់ខ្សត់ខ្សោយ និងច្រើនតែទុកឱ្យគណបក្សនានាមានសិទ្ធិអំណាចតថ្លៃគ្នា ជាជាងការបញ្ជាក់បង្ហាញថា គឃប ជាអ្នកទទួលបន្ទុកក្នុងស្ថានភាពនោះ

បញ្ហាប្រឈមសំរាប់ការបោះឆ្នោតទៅអនាគត គឺត្រូវកសាងទាំងសមត្ថភាព និងលក្ខណៈពេញច្បាប់នៃស្ថាប័នទាំងឡាយ ព្រមទាំងទំនាក់ទំនងរវាងតួអង្គនានាខាងនយោបាយ ដើម្បីផ្តល់មូលដ្ឋានគ្រឹះមួយសំរាប់កិច្ចសហការបង្កើតវិធានការគ្រប់គ្រងទំនាស់ផ្សេងៗដែលអាចបំពេញបានតាមលក្ខណៈវិនិច្ឆ័យទាំងនេះ ។

## ឧបសម្ព័ន្ធ

# ខេត្តករណីសិក្សា

តារាង១. ចំណែកភាគរយនៃសន្លឹកឆ្នោតទទួលបានដោយគណបក្សធំៗទាំង៣ ក្នុងទូទាំងប្រទេស និងក្នុងខេត្ត ករណីសិក្សាទាំងឡាយក្នុងការបោះឆ្នោតជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៩៣

| | CPP | FUNCINPEC | SRP | ចំនួនសន្លឹកឆ្នោតសរុប |
|---|---|---|---|---|
| ថ្នាក់ជាតិ | | | | |
| 1993 | 39.2 | 46.5 | - | 3916430 |
| 1998 | 41.7 | 32.0 | 14.4 | 4835642 |
| 2002 | 60.9 | 22.0 | 16.9 | 4348564 |
| 2003 | 47.4 | 20.8 | 21.9 | 5168837 |
| បាត់ដំបង | | | | |
| 1993 | 30.9 | 48.2 | - | 266945 |
| 1998 | 35.9 | 27.5 | 21.4 | 300326 |
| 2002 | 65.7 | 22.1 | 12.1 | 263901 |
| 2003 | 48.8 | 14.9 | 27.1 | 325965 |
| កំពង់ចាម | | | | |
| 1993 | 30.7 | 54.0 | - | 597327 |
| 1998 | 34.4 | 38.7 | 13.7 | 715985 |
| 2002 | 57.6 | 24.0 | 18.1 | 616926 |
| 2003 | 39.9 | 22.9 | 22.9 | 717765 |
| កំពត | | | | |
| 1993 | 40.1 | 42.1 | - | 190858 |
| 1998 | 46.7 | 28.2 | 10.5 | 223794 |
| 2002 | 55.3 | 26.1 | 17.4 | 188142 |
| 2003 | 47.6 | 26.4 | 15.5 | 229856 |
| តាកែវ | | | | |
| 1993 | 40.3 | 43.0 | - | 292501 |
| 1998 | 42.9 | 36.1 | 10.6 | 358647 |
| 2002 | 64.2 | 24.1 | 11.5 | 346375 |
| 2003 | 53.1 | 24.9 | 16.8 | 402666 |

*(ប្រភព: សំរាប់ការបោះឆ្នោតពីឆ្នាំ១៩៩៣ ដល់ ២០០៣, តួលេខយកពី COMFREL "ការប្រៀបធៀបលទ្ធផលបោះឆ្នោតក្នុងឆ្នាំ១៩៩៣ - ១៩៩៨ - ២០០២" ភ្នំពេញ ។ សំរាប់ការបោះឆ្នោតឆ្នាំ២០០៣ តួលេខយកពី NEC website, www.necelect.org ។ សំរាប់តារាងនេះ តួលេខទាំងអស់គិតត្រឹមមួយខ្ទង់ក្រោមឯកតា) ។*

ក្រាហ្វិក១. សន្លឹកឆ្នោត (%) របស់ CPP នៅតាមខេត្តករណីសិក្សា: ការធៀបនឹងលទ្ធផលទទួលបានក្នុងទូទាំងប្រទេស




ក្រាហ្វិក២. សន្លឹកឆ្នោត (%) នៃ FUNCINPEC នៅតាមខេត្តករណីសិក្សា: ការធៀបនឹងលទ្ធផលទទួលបានក្នុងទូទាំងប្រទេស



ក្រាហ្វិក៣. សន្លឹកឆ្នោត (%) របស់ SRP នៅតាមខេត្តករណីសិក្សាៈ ការធៀបនឹងលទ្ធផលទទួលបានក្នុងទូទាំងប្រទេស




ក្រាហ្វិក៤. សន្លឹកឆ្នោត (%) នៃ "បក្សជំទាស់" នៅតាមខេត្តករណីសិក្សាៈ ការធៀបនឹងលទ្ធផលទទួលបានក្នុងទូទាំងប្រទេស




*(សំគាល់ៈ ពាក្យ "ជំទាស់" នេះ ត្រូវបានប្រើយ៉ាងទូលំទូលាយដើម្បីសំដៅដល់គណបក្សនានាដែលមិនមែនជា CPP និងដែលទទួលបានចំណែកសន្លឹកឆ្នោតច្រើនគួរសម ។ នៅឆ្នាំ១៩៩៣ សន្លឹកឆ្នោត "គណបក្សជំទាស់" ត្រូវបានគណនាដោយបូកបញ្ចូលសន្លឹកឆ្នោតរបស់ FUNCINPEC និង BLDP ។ ពីឆ្នាំ១៩៩៨តមក សន្លឹកឆ្នោតគណបក្សជំទាស់ត្រូវបានគណនាដោយបូកបញ្ចូលសន្លឹកឆ្នោតរបស់ FUNCINPEC និង SRP ។*

# បញ្ជីឯកសារពិភាក្សារបស់ វបសអ


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍកម្ពុជា* (ឯកសារពិ.លេខ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនទ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងប៉ូប៊ីន-ប៊ិជីលរី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្រ្តចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូតី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនទ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គីមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយៈ បទពិសោធន៍កម្ពុជា*(ឯកសារពិភាក្សាលេខ ១៥) ជាខ្មែរតំលៃ ១០.០០០រៀល ។

១៦. ស៊ិក ប៊ូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជាៈ ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន*(ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប*(ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ារី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីងថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជាៈ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ*(ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ារី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជាៈ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-ប៊ូរ័ក្ស, Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ៈ ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជាៈ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (ខែកញ្ញា ឆ្នាំ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជាៈ* ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជាៈ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ជាអង់គ្លេស៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទៈ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (ខែកញ្ញា ឆ្នាំ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មៈ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃៈ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជាៈ ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (ខែវិច្ឆិកា ឆ្នាំ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុកៈ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ ដុល្លារ ។